ខុមហ្វ្រែល COMFREL

ការវាយតម្លៃ និងរាយការណ៍

ការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១៧

ឆ្នាំ២០១៧

ខែឧសភា

មាតិកា

អក្សរកាត់ 5

បុព្វកថា 7

១. សេចក្តីផ្តើម 9

២. សេចក្តីសង្ខេប 11

២.១ ការរកឃើញសំខាន់ៗ 11

២.២ ការលើកឡើងពីមជ្ឈដ្ឋានផ្សេងៗ 23

២.៣ ការវាយតំលៃជារួម 26

៣. បរិយាកាសនយោបាយ 27

៣.១ ការធ្វើវិសោធនកម្មច្បាប់ដោយឯកតោភាគីដែលផ្ទុយនឹងសេរីពហុបក្ស និងការធ្វើទុក្ខបុកម្នេញផ្នែកច្បាប់ ដល់គណបក្សប្រឆាំង 28

៣.២ ការគំរាមកំហែង និងការបំភិតបំភ័យ 36

៣.២.១ ការរឹតបន្តឹងបណ្តឹងទៅលើសិទ្ធិសេរីរបស់ប្រជាពលរដ្ឋ និង លទ្ធិប្រជាធិបតេយ្យ 47

៣.២.២ ការបំភិតបំភ័យ និងកិច្ចអន្តរាគមន៍ដល់អ្នកសង្កេតការណ៍ 51

៤. ការឃោសនាបោះឆ្នោត 53

៤.១. រយៈពេលមុនការឃោសនាបោះឆ្នោត 54

៤.២. រយៈពេលឃោសនាបោះឆ្នោតផ្លូវការ 55

៤.៣ ការចំណាយហិរញ្ញវត្ថុសម្រាប់ឃោសនាបោះឆ្នោត 58

៤.៣.១ ការចំណាយលើសកម្មភាពឃោសនាបោះឆ្នោត 58

៤.៣.២ ការចំណាយលើប្រភេទសម្ភារៈបរិក្ខារ/សេវាកម្មសម្រាប់សកម្មភាពឃោសនាបោះឆ្នោត 60

៤.៣.៣ ប្រភពចំណាយលើសកម្មភាពឃោសនាបោះឆ្នោត 61

៤.៣.៤ សមាសភាពចូលរួមការឃោសនាបោះឆ្នោត 62

៤.៣.៥ សកម្មភាពឃោសនាបោះឆ្នោត 63

៥. ការប្រើប្រាស់ធនធានរដ្ឋ និងទីធ្លាសាធារណៈ 64

៦. តួនាទីប្រព័ន្ធផ្សព្វផ្សាយក្នុងដំណើរការបោះឆ្នោត 65

៦.១ ការរំលោភលើគោលការណ៍ណែនាំ និងក្រមសីលធម៌របស់ គ.ជ.ប 66

៦.២ កម្មវិធីផ្សាយរបស់ទូរទស្សន៍ក្នុងអំឡុងពេលឃោសនាបោះឆ្នោត 67

៦.៣ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយក្នុងទូរទស្សន៍ជាតិ 69

៦.៣.១ ការផ្សាយព័ត៌មានទាក់ទងគណបក្សនយោបាយ និងខ្លឹមសារ របស់ស្ថានីយ៍ទូរទស្សន៍ 69

៦.៣.២ ការផ្សាយកម្មវិធីរបស់គណបក្សនយោបាយតាមស្ថានីយ៍ទូរទស្សន៍ 71

៦.៤ អត្ថបទសារព័ត៌មាននៅលើបណ្តាញផ្សព្វផ្សាយ គេហទំព័រ និងហ្វេសប៊ុក 74

៦.៤.១ គណបក្សនយោបាយ និងចំនួនអត្ថបទសារព័តមាន 74

៦.៤.២ ព័ត៌មានលេចធ្លាយ ឬមិនអាចបញ្ជាក់ប្រភព ឬ/និងព័ត៌មានក្លែងក្លាយ 76

៧ .ក្របខណ្ឌច្បាប់សម្រាប់ការបោះឆ្នោត និងប្រព័ន្ធបោះឆ្នោត 78

៧.១ ការផ្លាស់ប្តូរសំខាន់ៗនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ 78

៧.២ អនុសាសន៍ដែលបានផ្តល់ដោយខុមហ្វ្រែល និងសម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត 81

៧.៣ បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប 82

៨ .ការជ្រើសរើសសមាជិកគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) 85

៨.១ ក្របខណ្ឌច្បាប់នៃការជ្រើសរើស គធ.ខប 85

៨.១.១ ការវាយតម្លៃលើក្របខណ្ឌច្បាប់ 87

៨.១.២ លទ្ធផលនៃការសង្កេតរបស់ខុមហ្វ្រែល 88

៨.១.៣ ការវាយតម្លៃលើលទ្ធផលនៃការសង្កេតរបស់ខុមហ្វ្រែល 90

៨.២ ការជ្រើសរើសគណកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត(គឃ.សប) 90

៨.៣ ការជ្រើសរើសគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (គកប/គករ) 91

៩. ការគ្រប់គ្រងការបោះឆ្នោត 92

៩.១ ការចុះឈ្មោះបោះឆ្នោត 92

៩.១.១ បញ្ជីឈ្មោះបោះឆ្នោតថ្មី និងការចុះឈ្មោះបោះឆ្នោត 94

៩.២ ការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះ និងការបោះឆ្នោត..... 99

៩.៣ ការបែងចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត..... 100

៩.៤ វិធានការរបស់ គ.ជ.ប ដើម្បីធានាការបោះឆ្នោតមួយសម្រាប់អ្នកបោះឆ្នោតម្នាក់ និងការសាកល្បងទឹកខ្មៅលុបលាងមិនជ្រះ 101

៩.៥ ការចុះឈ្មោះបេក្ខជននៃគណបក្សនយោបាយ..... 104

៩.៦ ថ្ងៃបោះ និងរាប់សន្លឹកឆ្នោត (ថ្ងៃទី៤ មិថុនា)..... 107

៩.៦.១ ភាពមិនប្រក្រតីក្នុងអំឡុងពេលបោះឆ្នោត..... 108

៩.៦.២ ភាពមិនប្រក្រតីក្នុងអំឡុងពេលរាប់សន្លឹកឆ្នោត..... 110

១០ .បណ្តឹង និងដំណោះស្រាយទាក់ទងការបោះឆ្នោត 111

១០.១ ការទទួល និងការដោះស្រាយបណ្តឹងនៅក្នុងដំណាក់កាលឃោសនាបោះឆ្នោត..... 115

១០.១.១ ការទទួល និងដោះស្រាយបណ្តឹងនៅថ្នាក់គណៈកម្មការរៀបចំការបោះឆ្នោតឃុំសង្កាត់... 115

១០.១.២ ការទទួល និងដោះស្រាយបណ្តឹងក្នុងដំណាក់កាលឃោសនាបោះឆ្នោតនៅ គធ/ខប 118

១០.១.៣. ការដាក់ ទទួល និងដោះស្រាយបណ្តឹងក្នុងដំណាក់ឃោសនាបោះឆ្នោតនៅ គ.ជ.ប..... 119

១០.២ ការទទួល និងដោះស្រាយបណ្តឹង ស្តីពីភាពមិនប្រក្រតីកើតឡើងក្នុងថ្ងៃស ថ្ងៃបោះ និងរាប់សន្លឹកឆ្នោត..... 121

១០.២.១ ការទទួល និងដោះស្រាយបណ្តឹងនៅគណៈកម្មការរៀបចំការបោះឆ្នោតឃុំសង្កាត់ 121

១០.២.២ ទទួល និងដោះស្រាយបណ្តឹងនៅ គធ.ខប..... 123

១០.២.៣ ការទទួលនិង ដោះស្រាយបណ្តឹងនៅ គ.ជ.ប 128

១០.៣. ការទទួល និងការដោះស្រាយបណ្តឹងអំពីការបិទផ្សាយលទ្ធផលបឋមនៅឃុំ សង្កាត់ 130

១០.៣.១ ការទទួល និងការដោះស្រាយបណ្តឹងនៅ គធ.ខប 130

១០.៣.២. ការទទួល និងដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប 138

១១. ការផ្ទៀងផ្ទាត់ និងវិភាគលទ្ធផលបោះឆ្នោត 141

១១.១ ការផ្ទៀងផ្ទាត់ និងភាពត្រឹមត្រូវនៃលទ្ធផលបោះឆ្នោត 141

១១.២ វិភាគលទ្ធផលបោះឆ្នោតឃុំសង្កាត់ 145

១២. ការរំពឹងទុកសម្រាប់ការបោះឆ្នោតព្រឹទ្ធសភា និងការបោះឆ្នោតថ្នាក់ជាតិឆ្នាំ២០១៨ 153

១៣. បរិយាកាសក្រោយការបោះឆ្នោត និងការវិវឌ្ឍន៍នយោបាយ 157

១៣.១ ការវាយតម្លៃទៅលើលទ្ធផល និងគុណភាពនៃការបោះឆ្នោត 157

១៣.១.១. ការយាយីពីស្ថាប័ននីតិបញ្ញត្តិ 162

១៣.១.២ ការបង្ក្រាបជាលក្ខណៈទ្រង់ទ្រាយធំ និងដោយមានការរៀបចំច្បាស់លាស់ទៅលើអង្គការសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ 165

១៣.២ ការផ្ទេរអំណាចមេឃុំ ចៅសង្កាត់ 180

១៤. ការចូលរួម និងសិទ្ធិទៅបោះឆ្នោត 183

១៤.១ អ្នកបានបោះឆ្នោត និងអ្នកបោះឆ្នោតដែលត្រូវបានដកហូតសិទ្ធិ 183

១៤.២ ការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ 186

១៤.២.២ កម្មវិធីនយោបាយរបស់គណបក្ស និងបេក្ខជនស្ត្រី 187

១៤.២.៣ អ្នកបោះឆ្នោតស្ត្រី 188

១៤.២.៤ ស្ត្រីជាប់ឆ្នោត 188

១៤.៣ យុវជន 189

១៥. ការផ្តល់កាតអ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយ 190

១៥.១ ចំនួននៃអ្នកសង្កេតការណ៍ឯករាជ្យដែលបានទទួលស្គាល់ 190

៥.២ ចំនួននៃភ្នាក់ងារគណបក្សនយោបាយ 193

១៥.៣ ការសហការណ៍ និងជួយសម្រួលរបស់ គ.ជ.ប ក្នុងដំណើរការរៀបចំកាតអ្នកសង្កេតការណ៍... 196

១៦. ការតស៊ូមតិរបស់សង្គមស៊ីវិល និងការចូលរួមជាមួយគោលនយោបាយទាក់ទងសកម្មភាពបោះឆ្នោតរបស់ខុមហ្វ្រែល..... 197

១៦.១ ការបណ្តុះបណ្តាល ការដាក់ពង្រាយ និងសកម្មភាពសង្កេតការណ៍របស់ខុមហ្វ្រែល 206

១៦.២ សម្មភាពអប់រំអ្នកបោះឆ្នោតរបស់ខុមហ្វ្រែល 208

១៧. ព្រឹត្តិការណ៍សំខាន់ៗសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៤ ឆ្នាំ២០១៧
..... 209

អក្សរកាត់

គ.ជ.ប	គណៈកម្មការជាតិរៀបចំការបោះឆ្នោត
គធ.ខប	គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត
លធ.ខប	លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត
កបឃ.ស	ក្រុមប្រឹក្សាឃុំ សង្កាត់
គឃ.សប	គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត
គ.ក.ប/គ.ក.រ	គណៈកម្មការការិយាល័យរៀបចំការបោះឆ្នោត និងរាប់សន្លឹកឆ្នោត
ច.គ.ជ.ប	ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ច.ប.ត.រ	ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
ច.ប.ឃ.ស	ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
ប.ន.ឃ.ស	បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
អ.ខ	អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
ឯ.អ	ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត
ទ.	ទម្រង់បែបបទលេខ

គណបក្សនយោបាយ

ប្រ.ជ	គណបក្សប្រជាជនកម្ពុជា
គ.ស.ជ	គណបក្សសង្គ្រោះជាតិ
ររជកឯអសស	គណបក្សហ៊្វុនស៊ិនប៉ិច
ខ.រ.ជ	គណបក្សខ្មែររួបរួម
គ.ស.ស.ប	គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ
គ.ស.ក	គណបក្សសញ្ជាតិកម្ពុជា
គ.ប.ម	គណបក្សប្រជាធិបតេយ្យមូលដ្ឋាន
គ.ស.រ.ប	គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ
គ.យ.ក	គណបក្សយុវជនកម្ពុជា
គ.អ.ខ	គណបក្សអំណាចខ្មែរ
គ.ជ.ប.ក	គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា

បុព្វកថា

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) លើកស្ទួយលទ្ធិប្រជាធិបតេយ្យ និងសកម្មភាពចូលរួមក្នុងដំណើរការបោះឆ្នោតដោយការកសាងបណ្តាញ និងសហការជាមួយសមាជិក និងអង្គការដៃគូ។ លទ្ធិប្រជាធិបតេយ្យមិនគ្រាន់តែជាការបោះឆ្នោតនោះទេ ប៉ុន្តែសេរី និងយុត្តិធម៌គឺជាលក្ខខណ្ឌ ចាំបាច់នៃលទ្ធិប្រជាធិបតេយ្យ។ ខុមហ្វ្រែលនៅតែបន្តខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការជំរុញការបោះឆ្នោតដោយលទ្ធិប្រជាធិបតេយ្យ និងពិតប្រាកដ ឆ្ពោះទៅរកការពង្រឹងអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ។

របាយការណ៍ស្តីពីការបោះឆ្នោតឃុំ សង្កាត់ឆ្នាំ២០១៧នេះ រួមបញ្ចូលទាំងការរកឃើញ ការវិភាគ ការវាយតម្លៃជារួម និងអនុសាសន៍ ដែលចងក្រងក្នុងរបាយការណ៍របស់ខុមហ្វ្រែល ហើយនិងសេចក្តីថ្លែងការណ៍របស់បន្ទប់ស្ថានការណ៍ដែលបានចេញផ្សាយជាសាធារណៈមុនយុទ្ធនាការឃោសនាបោះឆ្នោត ពេលបោះឆ្នោត និងក្រោយពេលបោះឆ្នោតភ្លាម។ ក៏ដូចជាការវិភាគអំពីលទ្ធផលនៃការបោះឆ្នោតផងដែរ។ ដូចរបាយការណ៍មុនៗ ការវិភាគ និងអនុសាសន៍ស្វែងរកការជជែកពិភាក្សាជាមុនស្តីពីកំណែទម្រង់ និងការលើកកម្ពស់ការបោះឆ្នោតនៅកម្ពុជា ប្រកបដោយសេរី និងយុត្តិធម៌។

ខុមហ្វ្រែល មានមោទនភាព និងកោតសរសើរដល់បណ្តាញក្នុងស្រុក សកម្មភាពអ្នកសង្កេតការណ៍ក្នុងស្រុក និងអង្គការដៃគូដែលជាអង្គការសង្គមស៊ីវិលរបស់បន្ទប់ស្ថានការណ៍ ដែលជាអ្នកធ្វើកិច្ចការដោយអ្នកស្ម័គ្រចិត្តក្នុងអំឡុងពេលបោះឆ្នោតឆ្នាំ២០១៧ និងបានធ្វើឱ្យ ខុមហ្វ្រែល និងអង្គការនៅក្នុងបន្ទប់ស្ថានការណ៍មានបេសកកម្មការបោះឆ្នោតដ៏ទូលំទូលាយដែលអាចធ្វើទៅបាន។ ការងាររបស់ពួកគេបានរាប់បញ្ចូលទាំងការសង្កេតមានរយៈពេលវែង និងរយៈពេលខ្លី លើការងារសវនកម្មបញ្ជីឈ្មោះអ្នកបោះឆ្នោត ការតាមដានយុទ្ធនាការលើប្រព័ន្ធផ្សព្វផ្សាយ ការរាប់សន្លឹកឆ្នោតលឿន ការសង្កេតទាក់ទងពាក្យបណ្តឹង និងការបង្កើតបន្ទប់ស្ថានការណ៍នៅថ្ងៃបោះឆ្នោត។ បន្ទប់ស្ថានការណ៍មានបណ្តុំអង្គការចំនួន៤០ ដែលបានចូលរួមចំណែកចែករំលែកព័ត៌មានពីការបោះឆ្នោត ពីអ្នកសង្កេតការណ៍នៃអង្គការសង្គមស៊ីវិល និងការបង្កើនការធ្វើអន្តរាគមន៍ និងការឆ្លើយតបភ្លាមៗ ទៅនឹងវិបត្តិដែលទាក់ទងនឹងបរិយាកាសនៃការបោះឆ្នោត។

ខុមហ្វ្រែល និងបន្ទប់ស្ថានការណ៍បានដាក់អ្នកសង្កេតការណ៍ចំនួន ១៤,៥៨០នាក់ គ្រប់ដណ្តប់ជាង ៨០.៨១ភាគរយនៃការិយាល័យបោះឆ្នោតទាំងមូល ឬ៨៦ភាគរយនៃទីតាំងបោះឆ្នោតក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១៧។ ខុមហ្វ្រែលបានចូលរួមក្នុងដំណើរ

ការតស៊ូមតិ សម្រាប់ពង្រឹងក្របខណ្ឌច្បាប់ និងអប់រំអ្នកបោះឆ្នោត តាមរយៈការផលិតវីដេអូរជាគំនូរជីវចល ប្រព័ន្ធព័ត៌មានសង្គម និងការផ្សព្វផ្សាយតាមរយៈវិទ្យុផងដែរ។

យើងសូមសម្តែងការកោតសរសើរដោយសេចក្តីគោរព ចំពោះការខិតខំពង្រីកកិច្ចសហប្រតិបត្តិការរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) និងអាជ្ញាធរពាក់ព័ន្ធដទៃទៀតដែលទាក់ទងនឹងការបោះឆ្នោតនៅគ្រប់លំដាប់ថ្នាក់។ យើងក៏សូមថ្លែងអំណរគុណដល់អង្គភាពសារព័ត៌មាន គណបក្សនយោបាយ និងក្រុមការងារ ក៏ដូចជាអ្នកពាក់ព័ន្ធដទៃទៀតដែលទាក់ទងការងារការបោះឆ្នោត។ ខុមហ្វ្រែល សូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅ និងដោយគោរពដល់ដៃគូ និងម្ចាស់ជំនួយផងដែរ។

គណៈកម្មការនាយក និងអ្នកគ្រប់គ្រងខុមហ្វ្រែល

១. សេចក្តីផ្តើម

រយៈពេល ៤អាណត្តិនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានធ្វើឡើងក្នុងឆ្នាំ ២០០២ ឆ្នាំ២០០៧ ឆ្នាំ២០១២ និងឆ្នាំ២០១៧។ ការរៀបចំដំណើរការបោះឆ្នោតបានប្រព្រឹត្តទៅតាមបែបលទ្ធិប្រជាធិបតេយ្យ ដែលបានផ្តួចផ្តើមដំណើរការជាទៀងទាត់នៅក្នុងប្រទេសកម្ពុជា។ ប្រទេសកម្ពុជាបានអនុវត្តជំហានប្រកបដោយចីរភាពក្នុងការអនុវត្តន៍កំណែទម្រង់វិមជ្ឈការនៃការធ្វើកំណែទម្រង់ឃុំ សង្កាត់ ក្នុងទសវត្សរ៍កន្លងមកនេះ។

កំណែទម្រង់ឃុំ សង្កាត់ ត្រូវបានចេញមកពីកម្មវិធីដែលហៅថាសីលា។ សីលាបានចាប់ផ្តើមនៅឆ្នាំ ១៩៩៦ ហើយត្រូវបានអនុវត្តជាក្របខ័ណ្ឌមួយ ដើម្បីផ្លូវផ្តងការផ្តល់មូលធនសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធពីអ្នកផ្តល់ជំនួយជាច្រើន និងរដ្ឋាភិបាល ដើម្បីឆ្លើយតបទៅនឹងតម្រូវការមូលដ្ឋាននៅតាមរាជធានីខេត្ត គោលដៅស្ថិតនៅក្នុងប្រទេសកម្ពុជា។ គួរឱ្យកត់សំគាល់ខណៈប្រព័ន្ធវិមជ្ឈការត្រូវបានផ្តោតសំខាន់នៅថ្នាក់ឃុំ សង្កាត់។ បើប្រៀបធៀបទៅនឹងអាណត្តិមុនៗ អាណត្តិនៃវិមជ្ឈការ (២០០២-២០១៧) បានកត់សម្គាល់ពីវឌ្ឍនភាពដែលទាក់ទងទៅនឹងកំណែទម្រង់វិមជ្ឈការ។ ក្នុងអំឡុងពេល ៣អាណត្តិ គឺមានការផ្លាស់ប្តូរតិចតួចទាក់ទងនឹងវិមជ្ឈការនយោបាយ និងការបែងចែកនយោបាយ ការត្រួតពិនិត្យ តុល្យភាព និងគណនេយ្យភាពប្រជាធិបតេយ្យ សម្រាប់មន្ត្រីជាប់ឆ្នោតជាផ្លូវការនៅមូលដ្ឋាន។

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧ គឺជាអាណត្តិទី៤ នៃការបោះឆ្នោតនៅមូលដ្ឋានក្នុងប្រទេសកម្ពុជា ការបង្ហាញរួមបញ្ចូលទាំងឱកាស និងបញ្ហាប្រឈម សម្រាប់នូវរាល់ការព្រួយបារម្ភទាំងអស់។ ជាងនេះទៀត ពួកគេបានផ្តល់ឱកាសរួមបញ្ចូលទាំងការសម្រេចបាននូវភាពរឹងមាំ នូវលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន និងការអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ តាមរយៈការបែងចែកអំណាច ជាមួយការត្រួតពិនិត្យ និងតុល្យភាពរវាងគណបក្សកាន់អំណាច និងគណបក្សប្រឆាំង។

ការបោះឆ្នោតក្នុងថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧ អាណត្តិទី៤ អ្នកសង្កេតការណ៍ជាច្រើនត្រូវបានដាក់ពង្រាយនៅតាមស្ថានីយបោះឆ្នោតក្នុងទូទាំងប្រទេសដើម្បីធ្វើការសង្កេត និងធ្វើការវាយតម្លៃ ថាតើរាល់អ្នកបានចុះឈ្មោះបោះឆ្នោត ត្រូវបានគេផ្តល់ឱកាសក្នុងការប្រើប្រាស់សិទ្ធិទៅបោះឆ្នោត រីករាយទៅបោះឆ្នោត និងចូលរួមទៅបោះឆ្នោតដោយភាពសម្ងាត់របស់ខ្លួនដែរឬទេ? ហើយមន្ត្រីរៀបចំការបោះឆ្នោតបានបំពេញមុខងាររបស់ពួកគេឱ្យមានប្រសិទ្ធភាព ដូចជាការបោះឆ្នោត រាប់សន្លឹកឆ្នោត និងការគណនា បានរៀបចំដោយសន្តិវិធី និងតាមលំដាប់លំដោយ ព្រមទាំងបង្ហាញលទ្ធផលបោះឆ្នោតជាសាធារណៈ នៅរាល់កម្រិតរាជធានី ខេត្ត និងថ្នាក់ជាតិដែរឬទេ?។

ទិន្នន័យដែលបានបង្កើតឡើងសម្រាប់របាយការណ៍នេះ គឺផ្អែកលើការអង្កេតដោយផ្ទាល់ ការសម្ភាសន៍ ឯកសារជាសាធារណៈ និងទិន្នន័យដែលមានស្រាប់(Secondary data)ត្រូវបានជ្រើសរើសយ៉ាងយកចិត្តទុកដាក់ពីការបោះពុម្ពផ្សាយរបស់អ្នកពាក់ព័ន្ធជាតិ និងអន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយដែលធ្វើការ

តាមដានមើលពីបរិយាកាសនយោបាយរបស់ប្រទេសកម្ពុជា។ ប្រភពទាំងអស់ត្រូវបានដកស្រង់ និងយោងនៅក្នុងឧបសម្ព័ន្ធនៃចុងបញ្ចប់របាយការណ៍។ របាយការណ៍នេះបានចាប់ផ្តើមជាមួយសេចក្តីសង្ខេបនៃការរកឃើញសំខាន់ៗ។ ការរកឃើញវាអាស្រ័យទៅតាមការវាយតម្លៃនៃការវិភាគ និងការវាយតម្លៃស្តីពីការបោះឆ្នោត ដោយពឹងផ្អែកលើវិធីសាស្ត្រ និងបទដ្ឋានជាតិ និងអន្តរជាតិ ដូចជារដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីថ្លែងជាសកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីកម្ពុជា ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សេចក្តីប្រកាសទីក្រុងបាងកកស្តីពីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ សេចក្តីប្រកាសស្តីពីការបោះឆ្នោតដោយសេរីនិងយុត្តិធម៌នៃសហភាពអន្តរសភា(IPU) សូចនាករសម្រាប់ការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅឌីលី និងសេចក្តីប្រកាសជាសកល។

ការវាយតម្លៃត្រូវបានបង្កើតឡើងដើម្បីរកលទ្ធផលជាវិជ្ជមាន និង/ឬ អវិជ្ជមាន ទៅលើកត្តា ៩យ៉ាងរួមមាន៖ ច្បាប់បោះឆ្នោត និងក្របខ័ណ្ឌច្បាប់ វិសោធនកម្មច្បាប់លើគណបក្សនយោបាយ ព្រំដែននៃមណ្ឌលបោះឆ្នោត និងការបែងចែកអាសនៈ ភាពឯករាជ្យ អព្យាក្រឹតភាព តម្លាភាព ជំនាញ និងសមត្ថភាពនៃស្ថាប័ន គ.ជ.ប។ ការចុះឈ្មោះអ្នកបោះឆ្នោត និងបញ្ជីឈ្មោះអ្នកបោះឆ្នោត បេក្ខជនគណបក្សនយោបាយ និងការចុះបញ្ជីឈ្មោះ ការធ្វើយុទ្ធនាការឃោសនាបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតក្នុងថ្ងៃបោះឆ្នោត ហើយនិងដំណោះស្រាយវិវាទបោះឆ្នោត។ អ្នកសង្កេតការណ៍ និងការវាយតម្លៃ គឺមិនបានរាប់បញ្ចូលជាការគាំទ្រដល់គណបក្សនយោបាយណាមួយឡើយ។ លើសពីនេះទៀត អព្យាក្រឹត្យភាពរបស់អ្នកសង្កេតការណ៍ក៏ត្រូវបានធានាថាអនុវត្តទៅតាមគោលការណ៍ផ្លូវច្បាប់ និងគោរពតាមគោលការណ៍ណែនាំរបស់ គ.ជ.ប ដែលជាកត្តាចាំបាច់ ជាពិសេសគោរពក្រមសីលធម៌នៃអ្នកសង្កេតការណ៍ ដែលអ្នកសង្កេតការណ៍មិនមែនជាសមាជិក ឬសកម្មជននៃគណបក្សនយោបាយណាមួយ។

២. សេចក្តីសង្ខេប

២.១ ការរកឃើញសំខាន់ៗ

ក្របខណ្ឌផ្លូវច្បាប់៖ ការធ្វើវិសោធនកម្មច្បាប់បោះឆ្នោតឃុំ សង្កាត់ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៧ ត្រូវបានរកឃើញថា មានភាពអវិជ្ជមានច្រើនជាងវិជ្ជមាន។ ការផ្លាស់ប្តូរដែលមានភាពវិជ្ជមានជាដុំកំភួន ឬភាពប្រសើរជាងមុនរួមមានដូចជា៖ កំណែទម្រង់ប្រព័ន្ធចុះបញ្ជីឈ្មោះបោះឆ្នោត និងការរៀបចំបញ្ជីឈ្មោះបោះឆ្នោតថ្មី ការចាត់ចែងដាក់ស្លាកសញ្ញារបស់គណបក្សនយោបាយនៅតាមទីសាធារណៈ ការហាមឃាត់យោធា ប៉ូលិស មន្ត្រីរាជការស៊ីវិល អាជ្ញាធរមូលដ្ឋាន និងមន្ត្រីតុលាការពីការចូលរួមសកម្មភាពនយោបាយជាមួយគណបក្សនយោបាយក្នុងម៉ោងធ្វើការ ឬបំពេញភារកិច្ចក្នុងរយៈពេលឃោសនាបោះឆ្នោត ការទទួលស្គាល់អ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយសង្កេតការណ៍បោះឆ្នោត ទាំងអស់នេះសុទ្ធតែមានចែងច្បាស់លាស់ក្នុងច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធី និងមានចែងអំពីពេលវេលា ដែលត្រូវអនុវត្តយ៉ាងច្បាស់លាស់ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ការផ្លាស់ប្តូរដែលមានភាពអវិជ្ជមានធ្ងន់ធ្ងររួមមាន៖ ច្បាប់បោះឆ្នោតឃុំ សង្កាត់មិនបានចែងបើកទូលំទូលាយដល់សកម្មភាពឃោសនាបោះឆ្នោត និងការរឹតត្បិតសិទ្ធិសេរីភាព ឬការកំណត់ព្រំដែនតួចចង្អៀតនៃការចូលរួមអង្គការសង្គមស៊ីវិល នៅក្នុងរដូវកាលឃោសនាបោះឆ្នោត និងការរឹតត្បិតសិទ្ធិបញ្ចេញមតិរបស់ពួកគេ ការកាត់បន្ថយពេលនៃការដង្ហែក្បួនឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ដែលចូលរួមប្រកួតប្រជែង ការទុកចន្លោះប្រហោងក្នុងច្បាប់ដែលអនុញ្ញាតអោយមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ យោធិន និងមន្ត្រីតុលាការអាច មានសិទ្ធិក្នុងការចូលរួមសកម្មការឃោសនាបោះឆ្នោត ជាមួយគណបក្សនយោបាយនៅក្រៅម៉ោងធ្វើការ ឬដាក់ច្បាប់ឈប់សម្រាកមួយរយៈពេលនៃការឃោសនាបោះឆ្នោត ដែលផ្តល់លទ្ធភាពអោយពួកគេចូលរួមឃោសនាបោះឆ្នោត ចូលរួមគាំទ្រ និងប្រឆាំងគណបក្សនយោបាយដទៃដោយសេរី។ ប្រព័ន្ធបោះឆ្នោតសមាត្រសុទ្ធ ១០០ភាគរយ នៅតែខ្វះភាពត្រឹមត្រូវនៃភាពជាតំណាងនៃម្ចាស់ឆ្នោតក្នុងដំណើរការប្រជាធិបតេយ្យ និងរូបមន្តនៃការគណនាសំឡេងឆ្នោតមធ្យមភាគខ្ពស់បំផុត បានបង្កើតជាបញ្ហាដល់ភាពជាតំណាងនៃសំឡេងឆ្នោត ក៏ដូចជាមិនលើកទឹកចិត្តដល់បេក្ខភាពចម្រុះនៃគណបក្សនយោបាយក្នុងក្រុមប្រឹក្សាឃុំ សង្កាត់។ មួយវិញទៀត ច្បាប់បោះឆ្នោតឆ្នោតនៅតែខ្វះចន្លោះដោយមិនទាន់មានចែងអំពីកូតាសម្រាប់សមាសភាពស្ត្រី និងយុវជន ដែលគួរតែចែងកំណត់បង្គាប់ដល់គណបក្សនយោបាយអោយកំណត់យ៉ាងហោចណាស់៣០ភាគនៃបេក្ខជនក្នុងបញ្ជីឈ្មោះបក្ខជននៃគណបក្សនយោបាយ ដែលចូលរួមប្រកួតប្រជែង និងមានលេខរៀងឆ្លាស់ គ្នារវាងស្ត្រីបុរសនៃបេក្ខជនទាំងនោះ ដើម្បីលើកទឹកចិត្តដល់ការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយអោយបានកាន់តែច្រើន។ ភាពចម្រុងចម្រាសនៃបញ្ញត្តិមួយចំនួននៃច្បាប់បោះឆ្នោតនៃមាត្រា៧៤ និងមាត្រា១៥៩ ដែលបញ្ញត្តិនេះបានហាមឃាត់ ឬរឹតត្បិតសិទ្ធិ និងសេរីភាពរបស់ក្រុមអង្គការសង្គមស៊ីវិលក្រៅរដ្ឋាភិបាលក្នុងរយៈពេលឃោសនាបោះឆ្នោត លើសិទ្ធិជាមូលដ្ឋានរបស់ពលរដ្ឋ ក្នុងការសំដែងមតិនយោបាយ ជាពិសេសក្រុមអង្គការឃ្លាំមើលការបោះឆ្នោតដែលសិទ្ធិ និងសេរីភាពនៃការបញ្ចេញមតិនេះ វាពិតជាមានសារៈសំខាន់ខ្លាំងក្នុងដំណើរការឃ្លាំមើល និងសង្កេតការណ៍លើដំណើរការបោះឆ្នោត

និងផ្តល់យោបល់ អនុសាសន៍ស្ថាបនា កែលម្អដល់ចំណុចខ្វះចខាតនានាដែលពួកគេរកឃើញ។ ការចែងជាបញ្ញត្តិដាក់ទោសទណ្ឌដល់ក្រុមអ្នកសង្កេតការណ៍ស្ម័គ្រចិត្ត និងស្ថាប័នអង្គការដែលធ្វើការមិនមែនដើម្បីប្រាក់ចំណេញ ដែលចូលរួមក្នុងសកម្មភាពនយោបាយ ការអភិវឌ្ឍន៍សង្គម ដែលជាការផ្លាស់ប្តូរមួយអវិជ្ជមាន មិនធ្លាប់កើតមានពីមុនមក។ កិច្ចការនេះ វាគួរតែជាការលើកទឹកចិត្តដល់ពួកគេដើម្បីរួមចំណែកក្នុងការកែលម្អ និងធ្វើអោយប្រសើរឡើងនៃតម្លាភាព គណនេយ្យភាព សុក្រឹត្យភាព និងកំណែទម្រង់ធ្វើអោយប្រសើរឡើងទាំងស្ថាប័នរៀបចំការបោះឆ្នោត និងគណបក្សនយោបាយដែលចូលរួមប្រកួតប្រជែង។

បរិយាកាសមុនការបោះឆ្នោត៖ បរិយាកាសនយោបាយមុនការបោះឆ្នោត បានជះឥទ្ធិពលយ៉ាងខ្លាំងដល់ការបោះឆ្នោត ដែលបានបង្កើតនូវបញ្ហាបីសំខាន់ៗគឺ៖ ទី១ ការកែប្រែច្បាប់គោលនយោបាយ និងការប្រើប្រាស់ប្រព័ន្ធតុលាការដើម្បីដាក់ទោសមន្ត្រី និងថ្នាក់ដឹកនាំ និងការធ្វើទុកបុកម្នេញផ្នែកនយោបាយលើគណបក្សប្រឆាំង បង្កបញ្ហាប្រឈមនានាដល់ដំណើរការចុះឈ្មោះ និងទទួលស្គាល់បេក្ខភាព និងសមាជិកផ្ទៃក្នុងរបស់គណបក្ស ទី២ បង្កើតនូវភាពគំរាមកំហែង បំភិតបំភ័យដល់សកម្មជន បេក្ខជន និងអ្នកគាំទ្រគណបក្សបក្សប្រឆាំង ដោយប្រើប្រាស់វោហារ សារនយោបាយគម្រាមកំហែង កងម្លាំងប្រដាប់អាវុធ និងបន្តរឹតត្បិតឥតឈប់ឈរនូវការយាយីដល់អង្គការសង្គមស៊ីវិល និងគណបក្សប្រឆាំង តាមរយៈការប្រើប្រាស់យន្តការនៃច្បាប់ដែលបានកែប្រែដោយអត្តនោម័តិនៃគណបក្សកាន់អំណាច និងទី៣ ការប្រើប្រាស់ប្រព័ន្ធតុលាការដើម្បីកៀបសង្កត់។

ការចុះឈ្មោះបោះឆ្នោត និងការរៀបចំបញ្ជីឈ្មោះបោះឆ្នោត៖ ក្នុងឆ្នាំ២០១៦ គ.ជ.ប បានធ្វើការចុះឈ្មោះបោះឆ្នោត និងរៀបចំបញ្ជីឈ្មោះបោះឆ្នោតថ្មី ដែលបានរំពឹងថា ប្រជាពលរដ្ឋដែលមានអាយុគ្រប់បោះឆ្នោតប្រមាណ៩,៦៦៤,២១៦នាក់ និងបានបង្កើតជាបញ្ជីឈ្មោះបោះឆ្នោតថ្មី ដែលមានប្រជាពលរដ្ឋខ្មែរបានចុះឈ្មោះបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតប្រមាណ៧,៨៥៦,០៣៣នាក់ ស្មើប្រមាណ ៨១.៣៨ភាគរយ នៃប្រជាពលរដ្ឋដែលមានសិទ្ធិ និងអាយុគ្រប់បោះឆ្នោតសរុប។ ការចុះឈ្មោះបោះឆ្នោតតាមប្រព័ន្ធថ្មីទំនើបនេះ គឺធ្វើឡើងដោយប្រើប្រាស់បច្ចេកវិជ្ជាទំនើបក្នុងប្រព័ន្ធផ្ទុកទិន្នន័យដោយកុំព្យូទ័រ ដែលមានផ្ទុក និងផ្ទៀងផ្ទាត់សុក្រឹត្យភាពនៃព័ត៌មានអ្នកចុះឈ្មោះបោះឆ្នោត តាមរយៈការប្រើប្រាស់ទិន្នន័យជីវមាត្រ (ស្នាមក្រយៅដៃ) រូបថត និងការដៅយកឯកសារគោលសម្រាប់ចុះឈ្មោះបោះឆ្នោត អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជាគោល។ ការចុះឈ្មោះបោះឆ្នោតថ្មីនេះ បានចំណាយថវិកាប្រមាណ២៣លានដុល្លារ។ ជាសរុបមានគណបក្សនយោបាយចំនួន៩ និងអង្គការ សមាគមក្រៅរដ្ឋាភិបាលចំនួន៧ បានដាក់ពង្រាយភ្នាក់ងារសង្កេតការណ៍ និងអ្នកសង្កេតការណ៍លើដំណើរការចុះឈ្មោះបោះឆ្នោត ដែលបានប្រព្រឹត្តទៅអស់រយៈពេលបីខែគត់ក្នុងឆ្នាំ២០១៦។ មានតែគណបក្សនយោបាយពីរធំៗប៉ុណ្ណោះ ដែលមានលទ្ធភាពដាក់ពង្រាយភ្នាក់ងាររបស់ខ្លួនអោយតាមឃ្លាំមើលដំណើរការចុះឈ្មោះបោះឆ្នោតបានគ្រប់ឃុំ សង្កាត់ ដែលធ្វើការចុះឈ្មោះរួមមានគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ។ អង្គការខុមហ្រ្វែល និងសម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត បានដាក់ពង្រាយអ្នកសង្កេតការណ៍របស់ខ្លួនសរុបចំនួន៩៤៧នាក់ ក្នុងឃុំ សង្កាត់ចំនួន ៩៤៧នៃឃុំសង្កាត់សរុប១,៦៤៦ឃុំ សង្កាត់ទូទាំងប្រទេស។ ផ្អែកលើការធ្វើសវនកម្មបញ្ជីឈ្មោះបោះឆ្នោត ខុមហ្រ្វែលបានរកឃើញថា ការផលិត និងរៀបចំបញ្ជីឈ្មោះបោះឆ្នោតថ្មីឆ្នាំ២០១៦ មានភាពល្អប្រសើរខ្លាំង

បើធៀបជាមួយបញ្ជីឈ្មោះបោះឆ្នោតលើកមុនៗ ដោយរកឃើញថា មានអត្រា៨៩.៣ ភាគរយនៃប្រជាពលរដ្ឋដែលមានអាយុគ្រប់បោះឆ្នោតទាំងអស់ ដែលបានរស់នៅក្នុងប្រទេសបានចេញទៅចុះឈ្មោះបោះឆ្នោត និងមានឈ្មោះ ទិន្នន័យផ្ទាល់ខ្លួន ត្រូវបានបញ្ចូនក្នុងប្រព័ន្ធផ្ទុកទិន្នន័យនៃបញ្ជីឈ្មោះបោះឆ្នោតដោយជោគជ័យ។ ឈ្មោះ និងទិន្នន័យអ្នកបោះឆ្នោតនៅក្នុងបញ្ជីឈ្មោះបោះឆ្នោត ដែលខុមហ្វ្រៃលជ្រើសរើសជាសំណាកនៃការធ្វើសវនកម្ម ត្រូវបានរកឃើញថាមានភាពសុក្រឹត្យ៩៣.៧ភាគរយ នៃព័ត៌មានរាប់បញ្ចូលទាំងថ្ងៃខែឆ្នាំកំណើត ភេទ និងឈ្មោះ។ ការឃ្លាំមើលរបស់ខុមហ្វ្រៃលរកឃើញអំពីភាពមិនប្រក្រតីមួយចំនួនទាក់ទិននឹងការចុះឈ្មោះបោះឆ្នោត រួមមាន ការមិនសូវយកចិត្តទុកដាក់លើនីតិវិធីនៃការស្ទែនម្រាមដៃអោយបានត្រឹមត្រូវ ការធ្វេសប្រហែសក្នុងការចេញបង្កាន់ដៃអោយអ្នកចុះឈ្មោះបោះឆ្នោត ប៉ុន្តែមិនបានចុះឈ្មោះមនុស្សចូលក្នុងប្រព័ន្ធផ្ទុកទិន្នន័យ និងបញ្ហាអាក់រអួលនៃការបញ្ជូនទិន្នន័យ ពីទីតាំងចុះឈ្មោះបោះឆ្នោតមកមជ្ឈមណ្ឌលផ្ទុកទិន្នន័យរបស់ គ.ជ.ប ជាដើម។ អង្គការសង្គមស៊ីវិលធ្វើការងារលើកំណែទម្រង់ការបោះឆ្នោត និងគណបក្សនយោបាយ បានស្នើអោយ គ.ជ.ប បិទផ្សាយបញ្ជីឈ្មោះបោះឆ្នោតដំបូងនៅតាមភូមិនីមួយៗ អោយបានមុនការបោះឆ្នោត។ គ.ជ.ប បានកែប្រែនីតិវិធីនៃការបិទផ្សាយបញ្ជីឈ្មោះបោះឆ្នោតដំបូង ដោយបានបន្ថែមពេលវេលាសម្រាប់ការបិទផ្សាយបញ្ជីឈ្មោះបោះឆ្នោតដំបូងនៅតាមឃុំ សង្កាត់ ដើម្បីអោយអ្នកចុះឈ្មោះបោះឆ្នោតបានទៅពិនិត្យមើលព័ត៌មានចុះឈ្មោះបោះឆ្នោតរបស់ពួកគេ ប៉ុន្តែគោលនយោបាយនេះមិនត្រូវបានផ្សព្វផ្សាយ និងអនុវត្តអោយបានទូលំទូលាយឡើយ។ មានប្រជាពលរដ្ឋដែលបានចុះឈ្មោះបោះឆ្នោតប្រមាណតែ៣០ភាគរយ នៃអ្នកបានចុះឈ្មោះសរុបប៉ុណ្ណោះបានទៅពិនិត្យមើលឈ្មោះរបស់ពួកគេដែលបានចុះ។ ឧបសគ្គក៏ត្រូវបានរកឃើញដែរ ចំពោះការចុះឈ្មោះរបស់ព្រះសង្ឃ និងជនចំណាកស្រុក និងមានការិយាល័យចុះឈ្មោះបោះឆ្នោតខ្លះ ត្រូវបានបង្កើតឡើងសម្រាប់តែកងកម្លាំងប្រដាប់អាវុធ ដោយគ្មានជនស៊ីវិលផ្សេងទៀត។ ការសង្កេតរបស់ខុមហ្វ្រៃលរកឃើញថា មិនមានអ្នកគ្មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៦ បានទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឡើយ។ ទោះជាយ៉ាងណា មានអ្នកគ្រប់អាយុបោះឆ្នោត តែមិនមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជាច្រើន មិនបានដឹងអំពីនីតិវិធីនៃការស្នើសុំឯកសារបញ្ជាក់អត្តសញ្ញាណបម្រើអោយការចុះឈ្មោះបោះឆ្នោត និងឯកសារបញ្ជាក់អត្តសញ្ញាណបម្រើអោយការបោះឆ្នោត។ ច្បាប់បោះឆ្នោត អនុញ្ញតអោយមានការប្រើប្រាស់ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើអោយការបោះឆ្នោត ប៉ុន្តែបញ្ហាផ្សព្វផ្សាយអំពីនីតិវិធីនៃការស្នើសុំនេះ មិនបានទូលំទូលាយ និងមានភាពស្មុគស្មាញ។ ក្នុងចំណោមអ្នកឆ្លើយសំណួរទាំងអស់នៃការធ្វើសវនកម្មបញ្ជីឈ្មោះបោះឆ្នោត ខុមហ្វ្រៃលរកឃើញ ១០ភាគរយនៃអ្នកឆ្លើយសំណួរ មិនមាន និងមិនទាន់ទទួលបានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដើម្បីចុះឈ្មោះបោះឆ្នោត ដោយសារបញ្ហាប្រឈមមួយចំនួនដូចជា៖ ពួកគេលំបាកស្វែងរកសាក្សីពីររូបដែលរស់នៅអចិន្ត្រៃយ៍ ក្នុងឃុំ សង្កាត់ និងមានអាយុគ្រប់បោះឆ្នោត។ វាបានបង្កភាពលំបាកជាច្រើនដល់អ្នកស្នើសុំ ក្នុងការយកពាក្យទៅសុំ ឬស្កាត់ស្វែងរកមេឃុំ ឬចៅសង្កាត់ដើម្បីចុះហត្ថលេខា ខណៈដែលនៅក្នុងរដូវកាលបោះឆ្នោត មេឃុំ ចៅ សង្កាត់ មានភាពមមាញឹកខ្លាំងក្នុងសកម្មភាពនយោបាយរបស់ពួកគេ មន្ត្រីទទួលបន្ទុកកិច្ចការនេះមិនអាចពន្យល់បកស្រាយអោយងាយស្រួលយល់ និងខ្វះខាតការណែនាំអោយបានច្បាស់លាស់ដល់អ្នកស្នើសុំឯកសារបញ្ជាក់អត្តសញ្ញាណបម្រើអោយការចុះឈ្មោះបោះឆ្នោត។ ខុមហ្វ្រៃលរកឃើញថា នៅមុនថ្ងៃបោះឆ្នោត គ.ជ.ប បានចែកចាយ ផ្តល់ប័ណ្ណព័ត៌មានបោះឆ្នោតដល់អ្នកបោះឆ្នោតបានល្អប្រសើរជាងការបោះ

ឆ្នោតមុនៗ និងមានភាគរយខ្ពស់បំផុតដោយមន្ត្រី គ.ជ.ប និងអាជ្ញាធរមូលដ្ឋាន។ នៅក្នុងរឿងនេះដែរ មានការរកឃើញថា មានបញ្ហាអវិជ្ជមាននៅក្នុងរឿងផ្តល់ប័ណ្ណព័ត៌មានបោះឆ្នោតនេះ ដូចជាការចែកចាយប័ណ្ណព័ត៌មានបានបង្កប់ចេតនានយោបាយ និងការកេងចំណេញរឿងនយោបាយលាយឡំក្នុងរឿងនេះ ប្រព្រឹត្តដោយអាជ្ញាធរមូលដ្ឋានផងដែរ។ ការមិនបានពន្យល់អោយបានច្បាស់លាស់អំពីសារៈសំខាន់ និងគោលបំណងនៃប័ណ្ណព័ត៌មានបោះឆ្នោត បានបង្កើតទៅជាការយល់ច្រឡំ ដោយមានអ្នកបោះឆ្នោតខ្លះត្រូវបានគេប្រាប់ថា បើគ្មានប័ណ្ណព័ត៌មាននេះនៅថ្ងៃបោះឆ្នោតទេ ពួកគេនឹងមិនអាចអនុញ្ញាតអោយបោះឆ្នោតបានឡើយ។

ការគ្រប់គ្រង និងចាត់ចែងការបោះឆ្នោត

ការជ្រើសរើសមន្ត្រីបោះឆ្នោតរបស់ គ.ជ.ប៖ ការបង្កើតគណៈកម្មការបោះឆ្នោតទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធ្វើការងារជ្រើសរើសមន្ត្រីបោះឆ្នោត បានធ្វើឡើងស្របជាមួយបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោតឃុំ សង្កាត់។ ការជ្រើសរើសត្រូវបានរកឃើញថា បេក្ខជនដែលដាក់ពាក្យមានចំនួនតិចតួចនៅតាមឃុំ សង្កាត់នីមួយៗ ដែលធ្វើអោយមានការសម្រិតសម្រាំង មិនសូវមានការប្រកួតប្រជែងសមត្ថភាពគ្នា។ ការជ្រើសរើសមិនសូវផ្អែកលើការប្រកួតប្រជែងស្វែងរកអ្នកមានសមត្ថភាព ពីព្រោះបេក្ខជនដែលត្រូវបានជ្រើសរើសជាមន្ត្រីបោះឆ្នោតមាន៧០ភាគរយ គឺជាមន្ត្រីដែលធ្លាប់ធ្វើការពីការបោះឆ្នោតមុនៗ និងមួយចំនួន គឺសមាជិក និងមន្ត្រីសកម្ម ឬអ្នកគាំទ្រគណបក្សកាន់អំណាច។ ក៏មានការរកឃើញដែរថា មានមន្ត្រីគណៈកម្មការជ្រើសរើសមន្ត្រីបោះឆ្នោត ទាំងថ្នាក់ខេត្ត និងថ្នាក់ក្រោមជាតិ មិនសូវសហការផ្តល់ព័ត៌មានដល់អ្នកសង្កេតការណ៍ អំពីដំណើរការនៃការជ្រើសរើស។ ដំណើរការនៃការជ្រើសរើសមន្ត្រីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ត្រូវបានធ្វើឡើងស្របតាមបទបញ្ជា និងនីតិវិធី និងមានភាពស្រដៀងគ្នានឹងការជ្រើសរើសគណៈកម្មការរៀបចំការបោះឆ្នោតខេត្ត និងឃុំ សង្កាត់ដែរ។ ការសង្កេតរកឃើញថា ដំណើរការជ្រើសរើស គឺមានភាពប្រសើរជាងការជ្រើសរើសសម្រាប់ការបោះឆ្នោតលើកមុនៗ ហើយគណៈកម្មការជ្រើសរើសបានអនុវត្តបានត្រឹមត្រូវតាមបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតឃុំ សង្កាត់ និងលក្ខខណ្ឌដែលកំណត់ដោយ គ.ជ.ប។ ដំណើរការជ្រើសរើសត្រូវបានធ្វើឡើងដោយបើកចំហ ហើយបេក្ខជនដែលជាប់ និងត្រូវបានជ្រើសដោយយុត្តិធម៌ និងត្រឹមត្រូវផងដែរ។ ក្នុងពេលជាមួយគ្នានេះដែរ ខុមហ្វ្រែលសង្កេតឃើញថា ការជ្រើសរើសមន្ត្រីការិយាល័យបោះឆ្នោត ចំណុចមួយចំនួនទាមទារអោយមានការកែទម្រង់ និងធ្វើអោយប្រសើរឡើងសម្រាប់ការបោះឆ្នោតនាពេលអនាគត។ ព័ត៌មាន និងការផ្សព្វផ្សាយព័ត៌មាន និងមធ្យោបាយនៃការជូនដំណឹងអំពីការជ្រើសរើសនៅមានកម្រិត និងមិនបានទូលំទូលាយ។ ការជ្រើសភាគច្រើនរកឃើញថា បេក្ខភាពប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតភាគច្រើន គឺជាបេក្ខជនដែលធ្លាប់ធ្វើការងារបោះឆ្នោតកាលពីពេលបោះឆ្នោតកន្លងទៅជាមួយ គ.ជ.ប។ ពួកគេភាគច្រើនជាមន្ត្រីរាជការ និងអ្នកខ្លះជាមន្ត្រីសកម្មរបស់គណបក្សកាន់អំណាចនៅមូលដ្ឋាន ប៉ុន្តែទោះជាយ៉ាងណា ដំណើរការធ្វើតេស្ត និងសម្ភាសន៍មានតម្លាភាពគួរអោយកត់សំគាល់។

ការគ្រប់គ្រងការបោះឆ្នោត

ការចុះឈ្មោះបេក្ខជនឈរឈ្មោះបោះឆ្នោត៖ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី០៤ ឆ្នាំ ២០១៧នេះ មានគណបក្សនយោបាយចំនួន១២ បានចុះឈ្មោះ និងត្រូវបានទទួលស្គាល់ជាបេក្ខភាពចូលរួម ប្រកួតប្រជែងការបោះឆ្នោត នៅតាមឃុំសង្កាត់នានាទាំង១,៦៤៦ឃុំ សង្កាត់។ នេះជាប្រវត្តិសាស្ត្រនៃការ បោះឆ្នោតជ្រើសរើសរដ្ឋបាលថ្នាក់ក្រោមជាតិរបស់កម្ពុជាដំបូងបង្អស់ ដែលមានគណបក្សលើពីមួយមានលទ្ធ ផលអាចដាក់បេក្ខជនអោយចុះឈ្មោះនៅគ្រប់ឃុំ សង្កាត់ទូទាំងប្រទេស។ ជាបញ្ហាខ្លះ យើងបានរកឃើញថា ការចុះឈ្មោះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត មានស្តង់ដាមិនឯកភាពគ្នា។ មានបេក្ខជនគណបក្ស នយោបាយជាច្រើនបានប្រឈមបញ្ហាលំបាកក្នុងការស្វែងរកបេក្ខជនឈរឈ្មោះ។ មានករណីខ្លះរកឃើញថា មានការគំរាមកំហែងផ្នែកនយោបាយទៅលើបេក្ខជនគណបក្សនយោបាយ ជាពិសេសបេក្ខជនដែលឈរ ឈ្មោះអោយគណបក្សប្រឆាំង។ មានបេក្ខជនខ្លះបានដកពាក្យវិញ ដោយសារមានការគំរាមកំហែង បំភិត បំភ័យ ដាក់សម្ពាធ កៀបសង្កត់ ហើយមានគណបក្សនយោបាយខ្លះក៏ជួបការលំបាកក្នុងការស្វែករកបេក្ខជន ដើម្បីដាក់បង្គ្រប់តាមការកំណត់នៃច្បាប់ ដើម្បីអាចចូលរួមប្រកួតប្រជែងបានក្នុងឃុំ សង្កាត់។ មានបេក្ខជន ខ្លះ បានចុះឈ្មោះជាបេក្ខជនឈរឈ្មោះអោយគណបក្សមួយហើយ ប៉ុន្តែត្រូវបានគេលួងលោម សន្យាជាថ្នូរ ហើយបានដកពាក្យចេញពីគណបក្សដែលខ្លួនបានចុះឈ្មោះជាបេក្ខជនរួចហើយ ទៅចូលរួមជាមួយគណ បក្សដទៃផងដែរ។

យុទ្ធនាការឃោសនាបោះឆ្នោត៖ ការសង្កេត និងឃ្លាំមើលរកឃើញថា ការឃោសនាបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់បានប្រព្រឹត្តទៅដោយរលូន និងសន្តិវិធី និងគ្មានអំពើហឹង្សាធ្ងន់ធ្ងរ។ គណបក្ស នយោបាយដែលបានចុះឈ្មោះជាបេក្ខភាពចូលរួមប្រកួតប្រជែង បានចូលរួមក្នុងយុទ្ធនាការឃោសនាបោះ ឆ្នោតយ៉ាងសកម្ម។ ប៉ុន្តែការរឹតត្បិតសិទ្ធិ និងសេរីភាពនៃការបញ្ចេញមតិ សំដែងមតិ សារនយោបាយ និងការ ប្រើប្រាស់ទីធ្លាសាធារណៈ ការកំរិតចំនួនដង្ហែក្បួនព្យុហយាត្រាមកនៅត្រឹមពីរដងនៃរយៈពេលទាំងមូល និង ការអនុញ្ញាតអោយប្រើប្រាស់ទីធ្លាសាធារណៈជាដើម ត្រូវបានរកឃើញ។ ស្ថានីយ៍ទូរទស្សន៍ឯកជន មិនបាន គោរពខ្ជាប់ខ្ជួននូវការណែនាំ និងការអំពាវនាវរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្តីពីគោល ការណ៍សមភាពនោះទេ។ បើយោងតាមការវាយតំលៃរបស់ខុមហ្វ្រែលបានរកឃើញថា ក្របខណ្ឌនៃច្បាប់ ពាក់ព័ន្ធនឹងការឃោសនាបោះឆ្នោតបានបង្ខើចយ៉ាងខ្លីនូវគុណភាពនៃប្រជាធិបតេយ្យ ដែលជាលទ្ធផល បញ្ញត្តិទាំងនោះបានរឹតបន្តឹងសិទ្ធិ និងសេរីភាពនៃការបញ្ចេញមតិរបស់គណបក្ស ដែលបានចុះឈ្មោះចូលរួម ប្រកួតប្រជែងការបោះឆ្នោតនេះ ជាពិសេសគណបក្សប្រឆាំង។ បញ្ហាទាំងនោះរួមមាន ការអនុវត្តន៍ដោយ លម្អៀងលើរយៈពេលនៃការដង្ហែក្បួនព្យុហយាត្រា ដែលអាជ្ញាធរមានសមត្ថកិច្ចបានអនុញ្ញាតអោយគណ បក្សកាន់អំណាចមានពេលវេលាយូរ និងទីតាំងល្អសម្រាប់ប្រើប្រាស់ក្នុងការឃោសនាបោះឆ្នោត ដូចជាការ ជួបជុំគ្នាដើម្បីសំដែងមតិជាដើម។ មានការហាមឃាត់អង្គការសង្គមស៊ីវិល ក្នុងការសំដែងមតិនយោបាយ និង ការធ្វើការស្ទង់មតិ ដែលផ្ទុយទៅវិញមានការអនុញ្ញាតអោយមន្ត្រីរាជការសាធារណៈ កងកម្លាំងប្រដាប់អាវុធ ស្លៀកពាក់ស៊ីវិល មន្ត្រីតុលាការ អាចចូលរួមសកម្មភាពឃោសនាបោះឆ្នោតយ៉ាងសេរី ដោយពួកគេបានដាក់ ច្បាប់ឈប់សម្រាកនៅថ្ងៃឃោសនាបោះឆ្នោត។

ហិរញ្ញវត្ថុសម្រាប់ឃោសនាបោះឆ្នោត៖ របាយការណ៍ស្តីពីការចំណាយរបស់គណបក្សនយោបាយ ក្នុងរយៈពេលឃោសនាបោះឆ្នោត មិនដែលត្រូវបានបញ្ចេញ និងបញ្ជូនទៅអោយ គ.ជ.ប ឡើយ។ ការសង្កេតប៉ាន់ប្រមាណថា មានការប្រើប្រាស់ធនធានកម្រិតខុសគ្នាខ្លាំងរវាងគណបក្សនយោបាយ ជាពិសេសគណបក្សធំៗ ធៀបនឹងគណបក្សដែលទើបបង្កើតថ្មី ឬគណបក្សមិនសូវមានការគាំទ្រ ឬនិងគណបក្សកាន់អំណាចជាដើម។ គណបក្សប្រជាជនកម្ពុជា ត្រូវបានរកឃើញដោយការប៉ាន់ប្រមាណតាមបែបវិទ្យាសាស្ត្រថា បានចំណាយធនធានដ៏ច្រើន ជាពិសេសគឺមូលនិធិដែលត្រូវបានផ្តល់ទៅអោយតាមខេត្ត ក្រុងស្រុកខណ្ឌ ឃុំ សង្កាត់ជាដើម ខណៈដែលគណបក្សសង្គ្រោះជាតិ ត្រូវបានរកឃើញថា ការចំណាយភាគច្រើន គឺបានមកពីវិភាគទានរបស់បេក្ខជន និងសមាជិកឈរឈ្មោះ។ ការចាយវាយក្នុងការឃោសនាបោះឆ្នោត មិនស្មើភាពគ្នារវាងគណបក្សនយោបាយចូលរួមប្រកួតប្រជែង អាចមានឥទ្ធិពលមិនល្អដល់គុណភាពនៃការបោះឆ្នោត។ អវត្តមានបទបញ្ញត្តិក្នុងច្បាប់ ការខ្វះយន្តការតម្លាភាព និងគណនេយ្យភាពនៃហិរញ្ញវត្ថុក្នុងនោះរួមមានកំណត់ត្រា ឬគណនេយ្យចំណាយ និងចំណូលរបស់គណបក្សនយោបាយ បានបង្កើតជាបញ្ហាធ្ងន់ធ្ងរពាក់ព័ន្ធដល់ការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ និងជះឥទ្ធិពលដល់ការសម្រេចចិត្តរបស់អ្នកបោះឆ្នោតផងដែរ។ បើគ្មានការបង្ហាញអោយពេញលេញជាសាធារណៈនូវរបាយការណ៍ចំណាយ ចំណូលនានារបស់គណបក្សនយោបាយក្នុងអំឡុងពេលឃោសនាបោះឆ្នោត ប្រាកដណាស់វាពិតជាមានការពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ ហើយវាពិតជាមិនយុត្តិធម៌ឡើយសម្រាប់គណបក្សមិនសូវសម្បូរធនធានសម្រាប់ចំណាយ។ គ.ជ.ប គួរតែមានអំណាច ឬសមត្ថកិច្ចក្នុងការទាមទារតម្រូវជាកាតព្វកិច្ចដល់គណបក្សនយោបាយ ដែលចូលរួមប្រកួតប្រជែង ត្រូវតែបង្ហាញដោយចំហនូវរបាយការណ៍ចំណូល និងចំណាយរបស់ខ្លួនជាសាធារណៈ។

ប្រព័ន្ធផ្សព្វផ្សាយ៖ ការឃ្លាំមើលបានរកឃើញ និងសន្និដ្ឋានថា គ.ជ.ប ហាក់បានអនុវត្តមានប្រសិទ្ធភាពតិចតួចនៅឡើយពាក់ព័ន្ធនឹងការអនុវត្តន៍បទបញ្ជា និងនីតិវិធីនៃការឃោសនាបោះឆ្នោត ពាក់ព័ន្ធនឹងបញ្ហាការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបស់គណបក្សនយោបាយ និងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ និងឯកជនជាដើម។ គោលការណ៍សមភាពដែលមានចែងក្នុងសេចក្តីណែនាំរបស់ គ.ជ.ប មានការគោរពតិចតួចបំផុតពីស្ថានីយ៍ទូរទស្សន៍ឯកជនដែលគេមើលឃើញថា ពួកគេមាននិន្នាការរណបគណបក្សកាន់អំណាច។ ពួកគេបានបិទមិនអោយមានការជួលម៉ោងផ្សាយឃោសនា ដល់គណបក្សនយោបាយ ប៉ុន្តែក្នុងកម្មវិធីព័ត៌មានប្រចាំថ្ងៃពួកគេបានរំលេចក្នុងមាតិការព័ត៌មានជួយឃោសនាបោះឆ្នោតអោយគណបក្សកាន់អំណាច និងវាយប្រហារគណបក្សដទៃ មានន័យថា ក្នុងមាតិកាព័ត៌មានទាំងអស់ យ៉ោងហោចណាស់ មាន៤០ភាគរយបានបង្កប់អត្ថន័យ ឬចរឹតព័ត៌មានជាការឃោសនាបោះឆ្នោត អោយគណបក្សកាន់អំណាច លើការឃ្លាំមើលទូរទស្សន៍ឯកជនចំនួន៤ ដែលមានប្រជាប្រិយភាពខ្លាំង។ ខុមហ្វ្រែលរកឃើថា ក្របខណ្ឌនៃច្បាប់ និងវិធានការច្បាប់នៅមានខ្វះចន្លោះ និងអនុវត្តមិនមានប្រសិទ្ធភាព ដើម្បីធានាអោយការបោះឆ្នោតមួយប្រព្រឹត្តទៅដោយយុត្តិធម៌ និងស្មើភាពគ្នារវាងគណបក្សនយោបាយចូលរួមប្រកួតប្រជែងការបោះឆ្នោត។ គណបក្សកាន់អំណាចមានឥទ្ធិពល ឱកាស និងវិសាលភាពខ្ពស់បំផុតក្នុងការប្រើប្រាស់ទូរទស្សន៍ និងវិទ្យុឯកជន ក្នុងការជួយឃោសនាគោលនយោបាយ និងសារនយោបាយគាំទ្រ និងប្រឆាំងគណបក្សដទៃ បើធៀបជាមួយគណ

បក្សដទៃ។ គណបក្សសង្គ្រោះជាតិ បានពឹងផ្អែកយ៉ាងខ្លាំងទៅលើការផ្សព្វផ្សាយការឃោសនារបស់ខ្លួន តាមរយៈបណ្តាញទំនាក់ទំនងសង្គម ជាពិសេសទំព័រហ្វេសប៊ុក។

ថ្ងៃបោះឆ្នោត៖ ការសង្កេត និងឃ្លាំមើល អំពីភាពមិនប្រក្រតីនៅក្នុងដំណើរការនៃថ្ងៃបោះឆ្នោត រកឃើញថា ដំណើរការប្រព្រឹត្តទៅនៃការបោះឆ្នោត មានភាពប្រសើរជាងការបោះឆ្នោតមុនៗ។ ទោះជាយ៉ាងណា ភាពមិនប្រក្រតី៨ប្រភេទ ដែលត្រូវរកឃើញគឺ ទី១ ការចូលរួមរបស់មន្ត្រីរាជការស៊ីវិលបានចូលរួមយ៉ាងសកម្មជាមួយការឃោសនាបោះឆ្នោតជាមួយគណបក្សកាន់អំណាច ដោយបានរំលោភបំពានបទបញ្ញត្តិនៃច្បាប់ និងបទបញ្ជានីតិវិធី (មាន៧៦៦ ករណី) ទី២ ការរារាំងអ្នកសង្កេតការណ៍មិនអោយសង្កេតការណ៍ (១៥៣ករណី) ទី៣ ការបំភិតបំភ័យ ឬគំរាមកំហែង/ហឹង្សា (មាន៨៤ ករណី) និងទី៤ ការចូលរួមរបស់កងកម្លាំងប្រដាប់អាវុធដោយពាក់ឯកសណ្ឋានក្នុងអំឡុងពេលឃោសនាបោះឆ្នោត (មាន២៩ករណី)។ សម្រាប់ការបោះឆ្នោតប្រកបដោយយុត្តិធម៌នៅពេលអនាគត ការអនុវត្តន៍មាត្រា៧៥នៃច្បាប់បោះឆ្នោតឃុំ សង្កាត់ ត្រូវតែអនុវត្តអោយមានប្រសិទ្ធភាព និងតឹងតែងបំផុត ដើម្បីធានាឯករាជ្យភាពនៃកងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការសាធារណៈ មន្ត្រីតុលាការ និងត្រូវហាមឃាត់ពួកគេចំពោះការប្រើប្រាស់ភាសា សារនយោបាយប្រឆាំង ឬគាំទ្រគណបក្សនយោបាយ និងបេក្ខជនឈរបោះឆ្នោត។ ក្រុមមនុស្សទាំងអស់ខាងលើ ចាំបាច់ត្រូវតែហាមឃាត់ពីព្រោះពួកគេដើរតួនាទីសំខាន់លើកិច្ចការងាររក្សាសន្តិសុខបោះឆ្នោត និងត្រូវតែឯករាជ្យគ្រប់ដំណើរការ និងដំណាក់កាលនៃការបោះឆ្នោត។

ខុមហ្វ្រែល សហការជាមួយអង្គការសង្គមស៊ីវិលនានាក្នុងប្រទេស បានដាក់ពង្រាយអ្នកសង្កេតការណ៍ចំនួន១៤,៥៨៩នាក់ ក្នុងនោះមាន ៦,១៥៣នាក់ជាស្ត្រី ដើម្បីធ្វើការសង្កេត និងឃ្លាំមើលនៅក្នុងថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត ក្នុងទីតាំងការិយាល័យបោះឆ្នោតប្រមាណ ៩.៨៨៩ទីតាំង (ស្មើនឹង៨៦ភាគរយ) នៃទីតាំងការិយាល័យបោះឆ្នោតសរុប ១១,៧៨១ ឬស្មើនឹង៨០.៨១ភាគរយ នៃការិយាល័យបោះឆ្នោតសរុប)។ ការបោះឆ្នោតឃុំ សង្កាត់ឆ្នាំ២០១៧ ភាពមិនប្រក្រតីដែលត្រូវបានរកឃើញរួមមាន៖ នៅថ្ងៃស មានភាពមិនប្រក្រតីចំនួន០៦ករណីបានកើតឡើង ថ្ងៃបោះឆ្នោតមានចំនួន២,២៧៦ករណី និងពេលរាប់មានចំនួន ៧៦៨ករណីបានកើតឡើង។ មានភាពមិនប្រក្រតីកើតឡើងនៅក្នុងការិយាល័យបោះឆ្នោតចំនួន១,៦៥៧ ករណី ឬស្មើនឹង៩ភាគរយនៃការណីភាពមិនប្រក្រតីសរុបនៃការិយាល័យ ដែលខុមហ្វ្រែលបានដាក់ពង្រាយអ្នកសង្កេតការណ៍។ ការិយាល័យបោះឆ្នោតសរុបសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់សម្រាប់អាណត្តិទី០៤ ឆ្នាំ២០១៧នេះ មានចំនួន២២,១៤៨ការិយាល័យ។ ភាពមិនប្រក្រតីដែលដែលកើតឡើងញឹកញយ និងច្រើនជាងគេដែលបានបង្កើតជាឧបសគ្គដល់ការទៅចូលរួមបោះឆ្នោត រួមមាន៖ (១) ការខ្វះឯកសារបញ្ជាក់អត្តសញ្ញាណបម្រើការបោះឆ្នោត (២) ខ្វះខាតប័ណ្ណព័ត៌មានបោះឆ្នោត ដែលធ្វើអោយអ្នកបោះឆ្នោតពិបាកស្វែងរកឈ្មោះ ការិយាល័យបោះឆ្នោត (៣) ការសរសរព័ត៌មានដូចជាឈ្មោះមិនត្រឹមត្រូវជាដើម និង(៤) ការបាត់ឈ្មោះពីបញ្ជីឈ្មោះបោះឆ្នោត។ ករណីភាគច្រើន គឺពាក់ព័ន្ធនឹងភាពមិនប្រក្រតីដែលកើតឡើងក្នុងអំឡុងពេលបោះឆ្នោត ដែលករណីទាំងនោះបណ្តាលមកពីកំហុស ឬបញ្ហានៃការអនុវត្តន៍បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតដែលបង្កើតឡើងដោយ គ.ជ.ប។ ភាពមិនប្រក្រតីកើតមានក្នុងរយៈពេលរាប់សន្លឹកឆ្នោតរួមមាន៖ ការហាមឃាត់អ្នកសង្កេតការមិនអោយថតរូប និងវីដេអូ នៅក្នុងដំណើរការរាប់

សន្លឹកឆ្នោត ការសម្រេចទទួលស្គាល់ និងមិនទទួលស្គាល់សន្លឹកឆ្នោតបានការ ឬមិនបានការ ដោយគ្មានការព្រមព្រាងជាមួយភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ការបិទទ្វាររាប់សន្លឹកឆ្នោតដោយហេតុផលផ្សេងៗ ការរាប់សន្លឹកឆ្នោតញាប់ ឬលឿនពេកដែលធ្វើអោយភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍តាមមិនទាន់ តួលេខខុសគ្នារវាងសន្លឹកឆ្នោតក្នុងហិបឆ្នោត ធៀបនឹងចំនួនអ្នកបោះឆ្នោតឆ្នោតដែលបានបោះឆ្នោតក្នុងបញ្ជីឈ្មោះបោះឆ្នោត ការបដិសេធមិនព្រមអោយទម្រង់លទ្ធផលប្រចាំការិយាល័យដល់ភ្នាក់ងារគណបក្សនយោបាយ និងមិនបានបិទអោយបានត្រឹមត្រូវលើជញ្ជាំង ខាងមុខបន្ទាប់ការិយាល័យរាប់ ការរំខានក្នុងខណៈកំពុងរាប់សន្លឹកឆ្នោត និងការហាមឃាត់អោយបន្តដំណើរការរាប់ ព្រមទាំងមានករណីការបូកសរុបសន្លឹកឆ្នោតខុសជាដើម។

ការទទួលស្គាល់អ្នកសង្កេតការណ៍បោះឆ្នោត៖ ដំណើរការទទួលស្គាល់ការសង្កេតការណ៍ឯករាជ្យ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១៧នេះ ធ្វើឡើងដោយទំលំទូលាយ និងអាចជឿទុកចិត្តបាន។ មានអង្គការ សមាគមមិនចំណុះគណបក្សនយោបាយចំនួន២១ ដែលមានចំនួនសរុប៧៤,៦៧១នាក់បានចូលរួមឃ្លាំមើល និងសង្កេតការណ៍បោះឆ្នោត។ ស្ថាប័នអង្គការដែលបានដាក់ពង្រាយអ្នកសង្កេតការណ៍ច្រើនជាងគេ គឺសហភាពសហព័ន្ធយុវជនកម្ពុជា របស់កូនប្រុសលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មានចំនួនរហូតដល់៣១,៤៣១នាក់ អង្គការស្ត្រីសម្រាប់សន្តិភាព និងការអភិវឌ្ឍនៅកម្ពុជា ដាក់ពង្រាយអ្នកសង្កេតការណ៍បានចំនួន១៤,៥៨០នាក់។ គ.ជ.ប បានទទួលស្គាល់ភ្នាក់ងារសង្កេតការណ៍នៃគណបក្សនយោបាយបានប្រមាណ១០៥,០៧៦នាក់ ដែលមកពីគណបក្សនយោបាយចូលរួមប្រកួតប្រជែងទាំង១២។ គណបក្សប្រជាជនកម្ពុជាបានដាក់ពង្រាយភ្នាក់ងាររបស់ខ្លួនចំនួន៨៤,៦១៨នាក់ ខណៈគណបក្សសង្គ្រោះជាតិបានដាក់ពង្រាយភ្នាក់ងាររបស់ខ្លួនបានចំនួន៨៣,៥៩៦នាក់។ ក្រៅពីអ្នកសង្កេតការណ៍ជាតិ និងភ្នាក់ងារគណបក្សនយោបាយ គ.ជ.ប ក៏បានទទួលស្គាល់អ្នកសង្កេតការណ៍អន្តរជាតិសរុបចំនួន៣៨៤នាក់ មកពី៣៤អង្គការ/ស្ថាប័ន ស្ថានទូត និងប្រទេសផ្តល់ជំនួយ។ ការសង្កេតលើការទទួលស្គាល់លើការស្នើសុំជាអ្នកសង្កេតការណ៍ រកឃើញថា មានភាពរលូនទាន់ពេលវេលា និងមានបញ្ហាតិចតួច។ បញ្ហាបន្តិចបន្តួចនោះរួមមាន ការបដិសេធមិនទទួលស្គាល់របស់ គធ.ខប រាជធានី ខេត្តខ្លះ លើកាតសង្កេតការណ៍ណាដែលមិនបានបំពេញព័ត៌មានដោយផ្ទាល់ដៃពីអ្នកសង្កេតការណ៍ដែលបានបង្កើតជាបញ្ហាលំបាកមួយចំនួន។ ការសង្កេតក៏ឃើញមានការវិវឌ្ឍន៍ប្រសើរជាងមុនលើចំណុចមួយចំនួនដូចជា មិនតម្រូវអោយសាមីខ្លួនចុះហត្ថលេខាលើកាតមុនទទួលបានការចុះហត្ថលេខា និងបោះត្រាពីប្រធាន គធ.ខប ការពន្យារពេលបន្ថែមដើម្បីពិនិត្យលើពាក្យស្នើសុំ ការចែកជូនកាតដែលមិនទាន់បំពេញអោយស្ថាប័នសាមី ដោយសហការកម្រិតខ្ពស់ពី គ.ជ.ប ដោយមិនចាំបាច់ត្រូវឆ្លងកាត់ គធ.ខប ការផ្តល់យោបល់ និងការកែតម្រូវដល់កំហុសផ្សេងៗពីមន្ត្រីទទួលបន្ទុក មុននឹងបដិសេធពាក្យស្នើសុំ។

បណ្តឹងបោះឆ្នោត និងការដោះស្រាយបណ្តឹង៖ ការសង្កេតលើបណ្តឹងរកឃើញថា យន្តការនៃការដោះស្រាយបណ្តឹងមានភាពប្រសើរជាមុនតិចតួចបំផុត ប៉ុន្តែបញ្ហានៅតែមានចំពោះតម្លាភាព និងការជឿជាក់ពីភាគីពាក់ព័ន្ធរឿងបណ្តឹង។ ការដោះស្រាយបណ្តឹងបោះឆ្នោត នៅថ្នាក់ក្រោមជាតិហាក់មានតម្លាភាព បើកទូលាយ និងជឿជាក់បានច្រើន ប៉ុន្តែការដោះស្រាយបណ្តឹងនៅថ្នាក់ គ.ជ.ប ឃើញថា ការបើកទូលាយ និងតម្លាភាពនៅ

មានកម្រិត។ ទោះជាយ៉ាងណាស្ថាប័ន គ.ជ.ប ទាំងមូល បានប្រឹងប្រែងដោះស្រាយដោយបានព្យាយាម សម្របសម្រួល និងផ្សះផ្សា ជៀសជាងការដាក់ទណ្ឌកម្ម។ ការវិភាគទៅលើបញ្ហាបទបញ្ញត្តិ នៃច្បាប់ និងបទបញ្ជា និងនីតិវិធី ក៏រកឃើញមានបញ្ហាផងដែរ។ ករណីខ្លះបានរកឃើញថា មានការបដិសេធ និងទទួលពាក្យបណ្តឹង និងការទទួលដោះស្រាយបណ្តឹងដោយខ្វះមូលដ្ឋាន ឬមូលហេតុសមរម្យ និងមិនស៊ីសង្វាក់គ្នា។ ការសង្កេតក៏រកឃើញផងដែរ គធ.ខប ខ្លះបានបដិសេធមិនរាប់សន្លឹកឆ្នោតឡើងវិញ តាមពាក្យបណ្តឹងស្នើសុំ បើទោះជាបណ្តឹងនោះគ្រប់លក្ខខណ្ឌដែលច្បាប់បានតម្រូវយ៉ាងណាក្តី។ ប្រការ ១១.៣ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតឃុំ សង្កាត់ មានចន្លោះប្រហោង និងភាពមិនច្បាស់លាស់ ដល់ការបកស្រាយ ដែលបណ្តាលអោយមានការបកស្រាយដោយការប្រើប្រាស់ឆន្ទានុសិទ្ធិលើសលប់។ ដើម្បីអាចដោះស្រាយបណ្តឹងស្នើសុំរាប់សន្លឹកឆ្នោតឡើងវិញ ដែលបានដាក់ក្រោយប្រកាសលទ្ធផលបឋមដោយ គយ.សប បានលុះត្រាតែបណ្តឹងនោះជាបណ្តឹងដែលមានមូលដ្ឋានរឹងមាំជារួមបណ្តឹងនោះ ត្រូវតែផ្សារភ្ជាប់ជាមួយបណ្តឹងស្តីពីភាពមិនប្រក្រតីមួយផ្សេងដែលត្រូវបានដាក់នៅថ្ងៃបោះ និងរាប់សន្លឹកឆ្នោត ឬយ៉ាងយូរបំផុតត្រឹមម៉ោង១១ កន្លះព្រឹកថ្ងៃបន្ទាប់នៃថ្ងៃបោះឆ្នោត ទោះបីបណ្តឹងនេះមានលក្ខខណ្ឌខ្លះដូចជាកម្រិតលម្អៀងតិចជាង ០.៥ភាគរយនៃសំឡេងឆ្នោតរវាងគណបក្សពីរ ឬច្រើន ឬ/និងភាពមិនប្រក្រតីនៃសន្លឹកឆ្នោតមិនបានការច្រើនលើសលប់ពេកត្រូវបានរកឃើញថា ក្នុងឃុំ សង្កាត់ ឬក្នុងការិយាល័យណាមួយក្នុងឃុំ សង្កាត់នោះក៏ដោយចុះ។

លទ្ធផលបោះឆ្នោត និងការផ្ទៀងផ្ទាត់៖ ចំនួនសំឡេងគាំទ្រសន្លឹកឆ្នោតនៃគណបក្សនយោបាយ ត្រូវបានកត់ត្រាទុកលើទម្រង់ ទ.១១០២ ដែលប្រមូលដោយអ្នកសង្កេតការណ៍អង្គការខុមហ្វ្រែល និងបន្ទាប់ស្ថានការណ៍ប្រមូលបានឃើញថា ៩៣.១ ភាគរយ ដូចគ្នានៃការដាក់បង្ហាញរបស់ទម្រង់ ទ.១១០២ របស់ គ.ជ.ប នៅលើគេហទំព័ររបស់ខ្លួន។ ការរកឃើញមួយចំនួន៣ក់ព័ន្ធនឹងភាពមិនប្រក្រតី ដែលបានកត់ត្រាតួលេខសំឡេងឆ្នោត និងភាពខុសគ្នាខ្លះនៃតួលេខផ្សេងទៀតនៅលើទម្រង់ ទ.១១០២ របស់ គ.ជ.ប និងទម្រង់ដែលផ្តល់ទៅឱ្យគណបក្សនយោបាយដែលត្រូវបានផ្ទៀងផ្ទាត់គ្នា ប៉ុន្តែបញ្ហាទាំងនេះ មិនបានជះឥទ្ធិពលធ្ងន់ធ្ងរដល់ការប្រែប្រួលលទ្ធផលបោះឆ្នោតនោះឡើយ។

គណបក្សប្រជាជនកម្ពុជា ឈ្នះអាសនៈចំនួន ១,១៥៦អាសនៈជាមេឃុំ ចៅសង្កាត់ រួមបញ្ចូលទាំងឃុំ/សង្កាត់ចំនួន១៤ ដែលត្រូវបានគ្រប់គ្រងដោយគណបក្សប្រឆាំងកាលពីអាណត្តិមុនផងដែរ។ គណបក្សប្រជាជនកម្ពុជាឈ្នះអាសនៈក្រុមប្រឹក្សាដាច់ទាំងអស់ចំនួន៣៧ឃុំ សង្កាត់។ ទោះជាយ៉ាងនេះក្តី នេះជាប្រវត្តិសាស្ត្រនៃការបោះឆ្នោតថ្នាក់ក្រោមជាតិ ដែលអាសនៈមេឃុំ ចៅសង្កាត់ប្រហែល៣០ភាគរយ ត្រូវបានរំលែកទៅគណបក្សផ្សេងក្រៅពីគណបក្សកាន់អំណាច ក្នុងនោះគណបក្សសង្គ្រោះជាតិទទួលបានអាសនៈជាមេឃុំ ចៅសង្កាត់បានប្រមាណ៤៨៩ឃុំ សង្កាត់ នៃឃុំ សង្កាត់សរុបចំនួន១,៦៤៦ និងមួយឃុំ បានទៅលើគណបក្សខ្មែររួបរួមជាតិ។ ផ្អែកតាមការសង្កេតរបស់អ្នកសង្កេតការណ៍ខុមហ្វ្រែល ទៅលើឃុំ សង្កាត់ចំនួន ២៣ ពាក់ព័ន្ធនឹងការផ្ទេរអំណាច (ផ្ទេរពីមេឃុំគណបក្សប្រជាជនទៅគណបក្សសង្គ្រោះជាតិ និងពីគណបក្សសង្គ្រោះជាតិទៅគណបក្សប្រជាជនកម្ពុជា) រកឃើញថា មានឃុំចំនួន១៤ ដែលមានបញ្ហា។ បញ្ហាទាំងនោះដូចជាការមិនព្រមប្រគល់បន្ទប់ការិយាល័យមេឃុំ ចៅសង្កាត់ ការមិនប្រគល់កូនសោរបន្ទប់ ត្រា និងសម្ភារៈសម្រាប់ធ្វើការ ឬឯកសារ របាយការណ៍កត់ត្រាផ្សេងៗ ទៅអោយមេឃុំ ចៅសង្កាត់កាន់តំណែងថ្មី។ ទ្រព្យស

ម្បត្តិខ្លះក៏ត្រូវបានអតីតមេឃុំគណបក្សកាន់អំណាចដកហូត រុះរើយកទៅផ្ទះផងដែរ ដោយលើកឡើងថា ជាទ្រព្យរបស់ផ្ទាល់ខ្លួន។ ករណីភាគច្រើនលើសលប់ កើតឡើងពីការផ្ទេរតំណែងពីគណបក្សប្រជាជនកម្ពុជាទៅគណបក្សឈ្នះឆ្នោតថ្មីគឺគណបក្សសង្គ្រោះជាតិ។

គណបក្សនយោបាយចំនួន៤ ដែលមិនទទួលបានសំលេងគ្រប់គ្រាន់ ដើម្បីទទួលបានតំណែងជាមេឃុំ ចៅសង្កាត់ រួមមានគណបក្សហ៊្វុនស៊ិនប៉ិច គណបក្សប្រជាធិបតេយ្យមូលដ្ឋាន គណបក្សសំបុកឃ្មុំ សង្គមប្រជាធិបតេយ្យ និងគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ប៉ុន្តែពួកគេទទួលបានអាសនៈ និងសំឡេងគាំទ្រ។ គណបក្សប្រជាជនកម្ពុជាឈ្នះច្រើនអាសនៈឃុំ សង្កាត់ភាគច្រើននៅក្នុង ២១ខេត្ត ប៉ុន្តែមានខេត្តចំនួន៩ ដែលដែលគណបក្សនេះឈ្នះអាសនៈបានចំនួនតិចក្នុងរវាងពី៥០ភាគរយ ទៅ៦០ភាគរយ។ ក្នុងការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០១៧ លទ្ធផលបង្ហាញអោយឃើញថា មានតែគណបក្សចំនួនពីរប៉ុណ្ណោះ គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ដែលមានលទ្ធផលពង្រឹងការគាំទ្ររបស់ខ្លួនក្នុងចំណោមម្ចាស់ឆ្នោត ធៀបជាមួយការបោះឆ្នោតឃុំ សង្កាត់កាលពីអាណត្តិកន្លងទៅឆ្នាំ២០១២ និងការបោះឆ្នោតថ្នាក់ជាតិឆ្នាំ២០១៣ផងដែរ។ ការបោះឆ្នោតឃុំ សង្កាត់ឆ្នាំ២០១៧នេះ គណបក្សប្រជាជនកម្ពុជាឈ្នះបានសំឡេងឆ្នោតសរុប៣,៥៤០,០៥៦សំឡេង ថយចុះ៩១,០២៦សំឡេងធៀបនឹងការបោះឆ្នោតឃុំ សង្កាត់ដូចគ្នាឆ្នាំ២០១២ ប៉ុន្តែកើនបាន៣០៤,០៨៧ សំឡេងធៀបជាមួយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣។ គណបក្សកាន់អំណាចបានបាត់បង់តំណែងមេឃុំ ចៅសង្កាត់ដែលខ្លួនធ្លាប់កាន់កាប់ចំនួន ៤៣៦ ឃុំ សង្កាត់ បើធៀបជាមួយលទ្ធផលបោះឆ្នោតឆ្នាំ២០១២ ហើយគណបក្សប្រឆាំងបានដណ្តើមយកបានអាសនៈតំណែងមេឃុំ និងចៅសង្កាត់ទាំងនោះ។ នៅក្នុងការបោះឆ្នោតឆ្នាំ២០១២ គណបក្សប្រជាជនទទួលបានអាសនៈឃុំសង្កាត់សរុបចំនួន៨,២៩២ ប៉ុន្តែនៅក្នុងការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០១៧ គណបក្សនេះទទួលបានត្រឹមតែ ៦,៥០៣អាសនៈប៉ុណ្ណោះ។ បើធៀបគ្នារវាងលទ្ធផលនៃគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិក្នុងរាជធានី ខេត្តមួយចំនួដូចជា រាជធានីភ្នំពេញ ខេត្តសៀមរាប កំពង់ចាម កំពង់ធំ គណបក្សសង្គ្រោះជាតិ ឈ្នះមេឃុំ ចៅសង្កាត់ភាគច្រើនរួមទាំងចំនួនអាសនៈក្នុងខេត្តផងដែរ។ បើធៀបជាមួយការបោះឆ្នោតឆ្នាំ២០១២ និងការការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣ គណបក្សប្រឆាំងទទួលបានសំលេងឆ្នោតច្រើនក្នុងការបោះឆ្នោតឆ្នាំ២០១៧នេះ។ គណបក្សប្រឆាំងទទួលបានសំឡេងឆ្នោត ៣,០៥៦,៨២៤ សំឡេងក្នុងការបោះឆ្នោតឆ្នាំ២០១៧ ដោយកើនបានចំនួន១,២៥១,៨៨១ សំឡេងបើធៀបជាមួយការបោះឆ្នោតឃុំសង្កាត់ដូចគ្នាក្នុងឆ្នាំ២០១២ និងកើនឡើងបានចំនួន១១០,៦៤៨សំឡេង បើធៀបជាមួយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣។ ក្រៅពីគណបក្សធំៗទាំងពីរ គណបក្សហ៊្វុនស៊ិនប៉ិចទទួលបានសំឡេងឆ្នោត១៣២,៣១៩សំឡេង នៅក្នុងការបោះឆ្នោតឃុំ សង្កាត់ឆ្នាំ២០១៧ និងធ្លាក់ចុះចំនួន ៩០,៣៥២សំឡេង ធៀបជាមួយការបោះឆ្នោតឃុំ សង្កាត់ឆ្នាំ២០១២ និង១១០,០៩៤សំឡេង ធៀបជាមួយការបោះឆ្នោតជាតិឆ្នាំ២០១៣។

អត្រាអ្នកចេញទៅបោះឆ្នោត៖ ចំនួនប៉ាន់ប្រមាណនៃប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត និងគ្រប់អាយុបោះឆ្នោតមានចំនួន៩,៦៦៤,២១៦នាក់ និងមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៦ ចំនួន ៧,៨៦៥,០៣៣នាក់ (ស្មើនឹង៨១.៣៨ភាគរយ)។ អ្នកដែលមិនបានចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៦ ភាគ

ច្រើន គឺជាក្រុមប្រជាពលរដ្ឋដែលធ្វើចំណាកស្រុក ដែលពួកគេមានបញ្ហាប្រឈមនឹងការធ្វើលិខិតបញ្ជាក់ទីលំនៅ និងបញ្ហាហិរញ្ញវត្ថុធ្វើដំណើរមកចុះឈ្មោះ។ នៅថ្ងៃបោះឆ្នោត មានសន្លឹកឆ្នោតសរុប៧,១០៧,៣៩៥ សន្លឹកឆ្នោតត្រូវបានគូស ឬប្រើប្រាស់ (ប្រហែល៩០.៣៧ភាគរយ នៃប្រជាជនដែលមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោត) ។មានមូលហេតុមួយចំនួន ដែលធ្វើអោយមានការកើនឡើងអត្រាអ្នកចេញទៅបោះឆ្នោតច្រើនបែបនេះ។ កត្តាទាំងនោះអាចជាការធ្វើកំណែទម្រង់គណៈកម្មការធិការជាតិរៀបចំការបោះឆ្នោត ភាពសកម្មនៃអ្នកតំណាងរាស្ត្រគណបក្សប្រឆាំងនៅក្នុងរដ្ឋសភា ដែលធ្វើអោយមានការប្រកួតប្រជែងតឹងតែង ក្នុងកម្រិតខ្ពស់ ការដាក់ចេញនូវគោលនយោបាយរបស់គណបក្សប្រកួតប្រជែងគ្នា ការចូលរួមសកម្មពីសំណាក់អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធក្នុងដំណើរការបោះឆ្នោត និងកំណែទម្រង់ការបោះឆ្នោត គុណភាពបញ្ជីឈ្មោះបោះឆ្នោតប្រសើរជាងមុន។ ការស្ទង់មតិក្រោយថ្ងៃបោះឆ្នោតទៅលើមនុស្សចំនួន៧៥៧នាក់ ដែលមានស្នាមទឹកខ្មៅជ្រលក់នៅលើម្រាមដៃរកឃើញថា ៤៨ភាគរយនៃពួកគេដែលត្រូវបានសម្ភាសន៍ បានទៅដល់មណ្ឌលបោះឆ្នោត តែមិនបានបោះឆ្នោត។ ៥២ភាគរយនៃពួកគាត់មិនអាច និងមិនបានទៅដល់ការិយាល័យបោះឆ្នោត។ ក្នុងចំណោមមនុស្ស៥២ភាគរយនេះ មាន៨៥ភាគរយនៃពួកគាត់បានឆ្លើយថា ពួកមានបំណងចង់បោះឆ្នោត និងមាន១៥ភាគរយ ឆ្លើយថា មិនសូវចង់បោះឆ្នោតទេ។ ក្នុងចំណោមមនុស្ស ៤៨ ភាគរយដែលទៅដល់ការិយាល័យបោះឆ្នោតហើយ តែមិនបានបោះឆ្នោត មាន៤៦ភាគរយនៃពួកគេឆ្លើយថាមិនបានបោះឆ្នោតដោយសារគ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើអោយការបោះឆ្នោត (ឯ.អ) និងមាន៤៣ភាគរយ មិនមានប័ណ្ណព័ត៌មានបោះឆ្នោតនៅនឹងដៃ មានន័យថា ពួកគេស្វែងរកការិយាលល័យបោះឆ្នោត និងឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតមិនឃើញ។ សម្រាប់ក្រុមមនុស្សដែលឆ្លើយថា ពួកគេចង់ទៅបោះឆ្នោតដែរ ប៉ុន្តែមិនបានបោះមាន ៦០ភាគរយនៃពួកគេ មិនបានទទួលព័ត៌មានគ្រប់គ្រាន់អំពីការបោះឆ្នោត និងមិនបានចុះឈ្មោះបោះឆ្នោត ខណៈដែល១៦ភាគរយទៀត មិនអាចទៅកាន់ការិយាល័យបោះឆ្នោតបាន ឬទាន់ពេលវេលា ដោយសារទីលំនៅនៅឆ្ងាយពីការិយាល័យបោះឆ្នោតខ្លាំងពេក គ្មានពេលវេលាគ្រប់គ្រាន់ រវល់ការងារ និងខ្វះការតាំងចិត្ត។

ការចូលរួមរបស់ស្ត្រីក្នុងដំណើរការបោះឆ្នោត៖ មានស្ត្រីដែលគ្រប់អាយុ និងមានសិទ្ធិបោះឆ្នោតចំនួន ៤,២១០,៩១៤នាក់ ដែលបានចុះឈ្មោះបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៦ (ស្មើនឹង ៥៣.៥៣ភាគរយនៃចំនួនអ្នកមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោត)។ មានស្ត្រីជាច្រើនធ្វេសប្រហែសមិនបានទៅចុះឈ្មោះបោះឆ្នោត និងទៅបោះឆ្នោត ដើម្បីអនុវត្តសិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ដោយសារមូលហេតុផ្សេងៗដូចជា ភាពចាស់ជរា បញ្ហាពពោះ និងសម្រាលកូន ថែទាំកូន ចំណាកស្រុក និងជាប់ពន្ធនាគារជាដើម។ ក្នុងចំណោមស្ត្រីមិនបានទៅបោះឆ្នោតដែលឧបត្ថម្ភទ្រើលបានសាកសួរចំនួន៣៨.៤៦ភាគរយ ដែលមានសិទ្ធិបោះឆ្នោតបានឆ្លើយថា ពួកគេមិនបានទៅបោះឆ្នោត ដោយសារជាប់រវល់កិច្ចការងារផ្ទះ រកស៊ី ទទួលទាន បាត់អត្តសញ្ញាណប័ណ្ណ និងមិនបានចុះឈ្មោះបោះឆ្នោត។ នៅក្នុងការបោះឆ្នោតឃុំ សង្កាត់ឆ្នាំ២០១៧នេះ មានស្ត្រីប្រមាណ២៥,៧៨៨នាក់ បានដាក់ពាក្យជាបេក្ខភាពឈរឈ្មោះអោយគេបោះឆ្នោត ក្នុងគណបក្សទាំង១២ (កើនឡើង១.៦២ភាគរយ ធៀបនឹងការបោះឆ្នោតឃុំ សង្កាត់ឆ្នាំ២០១២)។ ការសង្កេតរកឃើញថា មូលហេតុដែលចំនួនស្ត្រីនៅតែមានចំនួនតិចក្នុងការចូលរួមក្នុងវិស័យនយោបាយ រួមមាន ភាពខ្វះ

ខាតគោលការណ៍ច្បាប់ និងគោលនយោបាយនៃគណបក្សនយោបាយ ការរើសអើងលើស្ត្រីក្នុងវិស័យនយោបាយ និងឆន្ទៈនយោបាយនៃគណបក្សនយោបាយ បរិយាកាសនយោបាយក្នុងដំណើរការបោះឆ្នោតបង្កជាភាពភ័យខ្លាច និងឧបសគ្គក្នុងការចូលរួមរបស់ពួកគេ ដូចជាការគំរាមកំហែង បំភិតបំភ័យ ការបៀតបៀនជាដើម និងព្រមទាំងមកពីកត្តាខាងក្នុងនៃស្ត្រីខ្លួនឯងផ្ទាល់នៅតែចាត់ទុកថា កិច្ចការនយោបាយ គឺជាកិច្ចការរបស់មនុស្សប្រុស។

ការចូលរួមរបស់យុវជន៖ ការចូលរួមរបស់យុវជនក្នុងដំណើរការបោះឆ្នោត និងវិស័យនយោបាយមានការកើនឡើងយ៉ាងគំហុក ដោយនៅឆ្នាំ២០១៦ មានយុវជនប្រមាណ២,៦២១,១៩០នាក់ បានចូលរួមចុះឈ្មោះបោះឆ្នោត (ស្មើនឹងប្រមាណ៣៣.៣ភាគរយ នៃអ្នកមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតសរុប ៧,៨៦៥,០៣៣នាក់)។ យោងតាមទិន្នន័យរបស់ គ.ជ.ប បេក្ខជនដែលមានអាយុចាប់ពី២៥ឆ្នាំ ដល់៣៥ឆ្នាំ ត្រូវបានតែងតាំងដោយគណបក្សនយោបាយ ដែលចុះឈ្មោះចូលរួមប្រកួតប្រជែងមានប្រមាណ១០,២៨៥ នាក់។ ទោះជាយ៉ាងណាក្តី មានយុវជនចំនួនត្រឹមតែ៤,៥៣៥នាក់ប៉ុណ្ណោះ ដែលត្រូវបានចុះឈ្មោះ និងទទួលស្គាល់ក្នុងបញ្ជីបេក្ខជនរបស់គណបក្សនយោបាយ។ យោងតាមលទ្ធផលបោះឆ្នោតឃុំ សង្កាត់ មានយុវជន៨៦២នាក់ បានជាប់ឆ្នោតជាមេឃុំ ចៅសង្កាត់ ឬនិងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ប៉ុន្តែក្នុងចំណោមពួកគេទាំងអស់មានតែ៣២៨នាក់ប៉ុណ្ណោះ ដែលមានអាយុចាប់ពី២៥ ដល់៣០ឆ្នាំ។ ក្នុងដំណាក់កាលឃោសនាបោះឆ្នោត និងក្នុងសកម្មភាពឃោសនាបោះឆ្នោត ខុមហ្វ្រែលសង្កេតឃើញមានការចូលរួមយ៉ាងសស្រាក់សស្រាំពីយុវជន ដែលវាបានបង្កើតជានិន្នាការថ្មីមួយសម្រាប់គ្រប់គណបក្សនយោបាយ ដែលត្រូវតែធ្វើគោលនយោបាយទាក់ទាញការគាំទ្រពីយុវជន ដែលមានការអប់រំ និងការយល់ដឹងប្រសើរ និងទូលំទូលាយជាងយុវជនជំនាន់មុន។

បរិយាកាសក្រោយការបោះឆ្នោត៖ បញ្ហាដ៏ធ្ងន់ធ្ងរនៃការកែប្រែក្របខណ្ឌច្បាប់ បានធ្វើអោយដំណើរការប្រជាធិបតេយ្យនៅកម្ពុជាក្នុងដំណាក់កាលក្រោយការបោះឆ្នោតឃុំ សង្កាត់ឆ្នាំ២០១៧ បានដើរថយក្រោយក្នុងជំហានមួយដ៏វែង។ ការធ្វើវិសោធនកម្មច្បាប់ ស្តីពីគណបក្សនយោបាយ គឺជាចេតនានយោបាយដោយផ្ទាល់ក្នុងការធ្វើអោយខូចខាតនូវរបបប្រជាធិបតេយ្យ សេរីពហុបក្សនៅកម្ពុជា។ ច្បាប់ស្តីពីគណបក្សនយោបាយ រឹតត្បិត រារាំងគណបក្សនយោបាយទាំងអស់ដែលបានចូលរួមការបោះឆ្នោតឃុំ សង្កាត់ ដោយបង្ខំ គ្រប់គ្រងសេរីភាពនៃការបញ្ចេញមតិរបស់បុគ្គល បើទោះជាបុគ្គលនោះជាមន្ត្រីជាន់ខ្ពស់ ឬទាបក៏ដោយ។ ការធ្វើវិសោធនកម្មនេះ បានរារាំងគណបក្សនយោបាយមិនអោយប្រើសារនយោបាយ រូបភាព ពាក្យពេចន៍ សំឡេងរបស់ទណ្ឌិត។

ការធ្វើវិសោធនកម្មច្បាប់នេះ ហាក់ដូចជាជំណានមួយ ឈានទៅរកប្រព័ន្ធនយោបាយគ្រប់គ្រងដោយឯកបក្ស និងផ្តាច់ការនិយម ដែលផ្តល់លទ្ធផលដល់គណបក្សកាន់អំណាចអាចរំលាយគណបក្សនយោបាយណាក៏បាន។ ដោយមើលទៅឥទ្ធិពល និងអំណាចរបស់ស្ថាប័ននីតិប្រតិបត្តិ ប្រព័ន្ធតុលាការត្រូវតែរងឥទ្ធិពល ហើយនឹងអាចកំណត់ការប្រកួតប្រជែងនយោបាយទៅតាមអ្វីដែលពួកគេចង់បាន។ ការធ្វើទុក្ខបុកម្នេញឥតឈប់ឈរទៅលើគណបក្សប្រឆាំង ស្ថាប័នសារព័ត៌មាន អង្គការសង្គមស៊ីវិល (រួមទាំងសង្គមស៊ីវិល

អន្តរជាតិ និងសហជីព) មិនមែនត្រឹមតែជាចេតនា ឬបំណងជាក់លាក់ក្នុងការប្រតិកម្មមិនយល់ស្របជាមួយពួកគេទេ ប៉ុន្តែការធ្វើទុក្ខបុកម្នេញនេះ គឺក្នុងគោលដៅបង្កើតនូវបញ្ហាប្រឈមនានា។ ពួកគេគិតថា គណបក្សប្រឆាំង អង្គការសង្គមស៊ីវិល និងស្ថាប័នព័ត៌មានទាំងអស់នោះ គឺជាក្រុមមនុស្សតែមួយ។ ការធ្វើទុក្ខបុកម្នេញនេះ បានធ្វើអោយគណបក្សប្រឆាំងចុះខ្សោយ គំរាមកំហែងដល់សិទ្ធិទទួលបានព័ត៌មានជាសាធារណៈរបស់ប្រជាពលរដ្ឋខ្មែរ និងរួមតូចចង្អៀតនូវលំហនៃការអនុវត្តន៍សកម្មភាពរបស់អង្គការសង្គមស៊ីវិល។ ទោះជាយ៉ាងណា វាជាគុណវិបត្តិដ៏ធ្ងន់ធ្ងរសម្រាប់គណបក្សកាន់អំណាចទៅវិញទេ ដោយសារវាបានធ្វើអោយចុះខ្សោយនូវយន្តការតាមដាន និងពង្រឹងគណនេយ្យភាពរបស់រដ្ឋាភិបាលកម្ពុជាទៅវិញ។ លើសពីនេះទៀត វាបានបង្កើតលក្ខខណ្ឌកំណត់ភាពចង្អៀតសម្រាប់អង្គការសង្គមស៊ីវិល និងមហាជន ដែលវាពិតជាមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ និងបង្កើតនូវវប្បធម៌មិនទុកចិត្តគ្នា ព្រមទាំងឧបសគ្គចំពោះការរីកចម្រើននៃសង្គមខ្មែរទាំងមូល។

២.២ ការលើកឡើងពីមជ្ឈដ្ឋានផ្សេងៗ

គណបក្សប្រជាជនកម្ពុជា៖ គណបក្សប្រជាជនកម្ពុជាបានថ្លែងសារនយោបាយថា ការបោះឆ្នោតដែលបានប្រព្រឹត្តទៅនៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៧ គឺបានរៀបចំ និងប្រព្រឹត្តទៅស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ វាជាការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី និងយុត្តធម៌ ប្រកបដោយសន្តិសុខ ដែលបង្កបរិយាកាសអោយប្រជាពលរដ្ឋខ្មែរប្រើប្រាស់សិទ្ធិក្នុងការធ្វើជាម្ចាស់នៃប្រទេស ដោយបានទៅបោះឆ្នោតនៅតាមការិយាល័យបោះឆ្នោតនានាទូទាំងប្រទេស ដើម្បីជ្រើសរើសអ្នកតំណាងនៅក្នុងមូលដ្ឋានរបស់គេ ក្នុងរយៈពេល០៥ឆ្នាំម្តង។ វាគឺជាប្រវត្តិសាស្ត្ររបស់កម្ពុជាថ្មីមួយទៀត ដែលកម្ពុជាទទួលបានសុខសន្តិភាពពេញលេញ ដែលជាមូលដ្ឋានដ៏រឹងមាំនៃរបបប្រជាធិបតេយ្យ និងការអភិវឌ្ឍសេដ្ឋកិច្ចទៅពេលអនាគត។

គណបក្សសង្គ្រោះជាតិ៖ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤នេះ មិនបានបំពេញអោយបានពេញលេញនូវគោលការណ៍សេរី ត្រឹមត្រូវ និងយុត្តិធម៌ឡើយ បើទោះបីជាមានការរៀបចំបញ្ជីឈ្មោះបោះឆ្នោតថ្មី ការចុះឈ្មោះគណបក្សនយោបាយមានភាពប្រសើរជាងលើកមុនៗមែន ប៉ុន្តែស្ថានភាពដ៏តានតឹងនេះបានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ការបោះឆ្នោត រួមមានដូចជា បរិយាកាសនយោបាយមុនការបោះឆ្នោត បរិយាកាសនយោបាយនៅអំឡុងពេលឃោសនាបោះឆ្នោត និងថ្ងៃបោះឆ្នោត ដែលមិនអនុញ្ញាតអោយកម្មករ និយោជិត អាចឈប់សម្រាកមានពេលវេលាធ្វើដំណើរទៅស្រុកកំណើត ដើម្បីបោះឆ្នោត និងបញ្ហានៃការដោះស្រាយបណ្តឹងជាដើម។

អង្គការបណ្តាញអាស៊ីសម្រាប់ការបោះឆ្នោតដោយសេរី (ANFREL)៖ ការបោះឆ្នោតឃុំ សង្កាត់ឆ្នាំ២០១៧ បានប្រព្រឹត្តទៅក្រោមបរិយាកាសរឹតត្បិត តឹងតែង អំពីផ្លូវច្បាប់។ ការបង្កើតច្បាប់ស្តីពី អង្គការ សមាគម មិនមែនរដ្ឋាភិបាល វិសោធនកម្មច្បាប់ ស្តីពីគណបក្សនយោបាយបានចូលជាធរមាន បានបង្កើតអោយមានការរឹតបន្តឹងសិទ្ធិ និងសេរីភាព ក្រុមអង្គការសង្គមស៊ីវិល និងគណបក្សប្រឆាំងជាដើម។ បទបញ្ញត្តិនៃច្បាប់ទាំងនេះ ក៏មានចរិតរំលោភបំពានសិទ្ធិមនុស្ស និងលក្ខខណ្ឌសិទ្ធិមនុស្សផ្សេងៗ នៅក្នុងប្រទេស ដូចជាការចាប់

និងឃុំខ្លួនសកម្មជនសិទ្ធិមនុស្ស និងចោទប្រកាន់ កាត់ទោសសកម្មជន មន្ត្រីរបស់គណបក្សប្រឆាំង ការគំរាមកំហែង បំភិតបំភ័យអំពីការវិលត្រឡប់នៃសង្គ្រាមស៊ីវិលជាដើម ពីសំណាក់មន្ត្រីរដ្ឋាភិបាល ជាពិសេសពីសំណាក់ថ្នាក់ដឹកនាំកំពូលរបស់រដ្ឋាភិបាល ដែលបានធ្វើអោយប៉ះពាល់ និងមានឥទ្ធិពលនៅក្នុងរយៈពេលឃោសនាបោះឆ្នោត។ ភាគីពាក់ព័ន្ធនឹងការបោះឆ្នោតនៅកម្ពុជា ត្រូវខិតខំធ្វើការតស៊ូមតិបន្ថែមទៀត ដើម្បីធានាថា សង្វៀននៃការប្រកួតនយោបាយ គឺមានភាពល្អប្រសើរជាងនេះ។ បច្ចុប្បន្ននេះ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ប្រព័ន្ធយុត្តិធម៌ ក្រមខណ្ឌផ្លូវច្បាប់ និងអវត្តមានបទបញ្ញត្តិ/ច្បាប់ស្តីពីហិរញ្ញវត្ថុគណបក្សនយោបាយ គឺគណបក្សកាន់អំណាចជាអ្នកមានឱកាស មានប្រៀបច្រើនជាងគណបក្សនយោបាយដទៃលើលលប់បំផុត។ ក្រៅពីការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយដល់គណបក្សប្រឆាំង និងបង្កភាពល្អក់កករបរិយាកាសនយោបាយនៅកម្ពុជាមុនការបោះឆ្នោត ក៏មានផងដែរនូវការអនុវត្តន៍ច្បាប់ បញ្ហាដោយមិនស្មើភាពគ្នា មិនយុត្តិធម៌ មានស្តង់ដារផ្សេងគ្នា។ យុទ្ធនាការឃោសនាបោះឆ្នោត ត្រូវបានសង្កេតឃើញថា មានភាពគគ្រឹកគគ្រេង ប្រព្រឹត្តទៅដោយសន្តិវិធី ជាងការឃោសនាបោះឆ្នោតមុនៗ និងមានទំនាស់តិចតួច អំពើហិង្សា និងឧប្បត្តិហេតុតិចតួចប៉ុណ្ណោះដែលត្រូវបានកត់ត្រា។

ការវាយតំលៃរួមរបស់ **ANFREL** រកឃើញថា ការបោះឆ្នោតឃុំ សង្កាត់ឆ្នាំ២០១៧នេះ ប្រព្រឹត្តទៅដោយបរិយាកាសរលូន គ្មានអំពើហឹង្សាធ្ងន់ធ្ងរ ប៉ុន្តែស្ថិតក្នុងស្ថានភាពចង្អៀតនៃលំហប្រជាធិបតេយ្យ។ អង្គរៀបចំការបោះឆ្នោត បន្ទាប់ពីមានការកែទម្រង់ និងមានចែងកំណត់អំពីអាណត្តិច្បាស់លាស់ក្នុងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (ច.គ.ជ.ប) ក្នុងឆ្នាំ២០១៥ បានចាត់ចែង និងរៀបចំការបោះឆ្នោត បង្កើតបទបញ្ញត្តិ សេចក្តីណែនាំផ្សេងៗទាក់ទិននឹងការបោះឆ្នោត បានប្រសើរជាងការបោះឆ្នោតមុនៗ។ អ្វីដែលឃើញមានការរីកចំរើនគួរអោយកត់សំគាល់ខ្លាំងគឺ កំណែទម្រង់បញ្ជីឈ្មោះបោះឆ្នោតថ្មី ការដាក់ចេញនូវក្រមសីលធម៌សម្រាប់គ្រប់ភាគីពាក់ព័ន្ធនឹងការបោះឆ្នោត និងការទទួលស្គាល់អ្នកសង្កេតការណ៍បោះឆ្នោតបាន រហូតដល់ចំនួន៧៤.៦៧១នាក់ ដើម្បីអនុញ្ញាតអោយពួកគេធ្វើការងារស្វែងរកនូវតម្លាភាព និងភាពត្រឹមត្រូវនៃការបោះឆ្នោត ក្នុងគោលបំណងបង្កើតអោយកាន់តែរឹងមាំ នូវភាពជឿជាក់ពីសាធារណជន ពិសេសពីសំណាក់ម្ចាស់ឆ្នោតនូវប្រព័ន្ធនៃការចាត់ចែង និងការរៀបចំការបោះឆ្នោតនៅកម្ពុជា។ គ.ជ.ប ក៏បានធ្វើការសហការយ៉ាងល្អផងដែរជាមួយភាគីពាក់ព័ន្ធ។ អង្គការ **ANFREL** បានសង្កេតឃើញថា ការបោះឆ្នោតនេះបានប្រព្រឹត្តទៅក្នុងបរិយាកាសរលូន និងប្រសិទ្ធភាពនៃការអនុវត្តន៍បទបញ្ញត្តិផ្សេងៗ របស់ គ.ជ.ប នៅតាមការិយាល័យបោះឆ្នោតនីមួយៗ គឺធ្វើបានល្អប្រសើរច្រើន។ ទោះជាយ៉ាងណា ការសង្កេតក៏រកឃើញបញ្ហាខ្លះៗ ពីដំណើរការបោះឆ្នោតនៅថ្ងៃបោះឆ្នោត ប៉ុន្តែបញ្ហាទាំងនេះអាចបណ្តាលមកពីបុគ្គលិក មន្ត្រីបម្រើការ ទទួលបានការបណ្តុះបណ្តាលតិចតួច ឬមិនគ្រប់គ្រាន់។ កំហុសតិចតួចនេះ វាមិនបណ្តាលអោយប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការ និងលទ្ធផលនៃការបោះឆ្នោតនេះឡើយ។[1]

[1] http://aerc-anfrel.org/publication/anfrel-mission-reports/2017-the-international-election-observation-mission-ieomof-anfrel-to-the-kingdom-of-cambodias-commune-and-sangkat-council-elections/

អង្គការតម្លាភាពអន្តរជាតិកម្ពុជា៖ ជារួម ដំណើរការនៅថ្ងៃបោះឆ្នោត ត្រូវបានប្រព្រឹត្តទៅដោយរលូន ជាមួយនឹងការរកឃើញកើតមានអំពើហឹង្សាតិចតួចបំផុត ការគំរាមកំហែងក៏កើតមានតិចតួច ហើយមន្ត្រីរៀបចំការបោះឆ្នោតភាគច្រើន គឺបានគោរពបទបញ្ជា និងនីតិវិធីបានត្រឹមត្រូវល្អ។ ភាពមិនប្រក្រតីដែលអង្គការតម្លាភាពកម្ពុជាបានរកឃើញ ក្នុងអំឡុងពេលបោះឆ្នោតនេះបានរកឃើញថា បុគ្គលអាជ្ញាធរដែលមិនមានការអនុញ្ញាតត្រឹមត្រូវ បានបង្ហាញខ្លួននៅតាមការិយាល័យមួយចំនួន មានដូចជាប្រធានភូមិ បេក្ខជនឈរឈ្មោះ និងបញ្ហាអ្នកបោះឆ្នោតមិនអាចស្វែងរកឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតឃើញ។ ប៉ុន្តែទោះជាយ៉ាងណា បញ្ហាទាំងនេះ មិនមានកើតឡើងជាទ្រង់ទ្រាយធំនោះទេ។[2]

សហភាពសហព័ន្ធយុវជនកម្ពុជា៖ ការឃោសនាបោះឆ្នោត ត្រូវបានព្រឹត្តទៅដោយរលូន និងមានការចូលរួមប្រកួតប្រជែងយ៉ាងផុសផុល និងការអនុវត្តន៍សិទ្ធិ និងសេរីភាពពេញលេញ។ នៅថ្ងៃបោះឆ្នោត ប្រជាពលរដ្ឋដែលមានសុទិដ្ឋិនិយមជាមួយនឹងការបញ្ចេញឆន្ទៈដោយសេរី បានចេញទៅបោះឆ្នោត នៅតាមការិយាល័យបោះឆ្នោតផ្សេងៗ តាមវិធីសំងាត់ និងដោយគ្មានការបង្ខិតបង្ខំ។[3]

ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅទីក្រុងភ្នំពេញ៖ ស្ថានទូតអាមេរិកបានចេញសាទរ អបអរ ដោយលើកឡើងថាប្រជាជនកម្ពុជារាប់លាននាក់បានចេញទៅបោះឆ្នោតនៅថ្ងៃអាទិត្យ ដើម្បីជ្រើសរើសថ្នាក់ដឹកនាំមូលដ្ឋានឃុំសង្កាត់របស់ពួកគេ។ យើងក៏ចូលរួមអបអរសាទរ ផងដែរ ចំពោះស្ថានប័ន គ.ជ.ប មន្ត្រី គ.ជ.ប មន្ត្រីស្មគ្រចិត្តដែលបានលះបង់កំលាំងកាយចិត្ត ប្រាជ្ញារៀបចំការបោះឆ្នោត និងបំពេញតួនាទីរបស់ខ្លួនបានល្អ។

អង្គការឃ្លាំមើលសិទ្ធិមនុស្ស៖ បើទោះបីនៅថ្ងៃបោះឆ្នោតប្រព្រឹត្តទៅដោយសន្តិវិធី និងដំណើរការរៀបចំការបោះឆ្នោតប្រព្រឹត្តទៅដោយរលូន ប៉ុន្តែអង្គការឃ្លាំមើលសិទ្ធិមនុស្សរកឃើញនូវបញ្ហាមួយចំនួនដូចជា ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយមិនស្មើគ្នា រវាងគណបក្សប្រឆាំង និងគណបក្សកាន់អំណាច ការអនុវត្តន៍ច្បាប់ហាក់ដូចជាមានភាពលម្អៀងទៅកាន់គណបក្សកាន់អំណាចពីសំណាក់អាជ្ញាធរមូលដ្ឋាន និងភាពខ្វះឯករាជ្យភាព និងយុត្តិធម៌នៃយន្តការដោះស្រាយបណ្តឹងបោះឆ្នោត។ មានការគំរាមកំហែងដោយអាជ្ញាធរ ប្រឆាំងនឹងគណបក្សប្រឆាំង និងសកម្មជនគណបក្សប្រឆាំង នៅក្នុងដំណើរការរៀបចំការបោះឆ្នោតនេះ។[4]

អង្គការប្រជាធិបតេយ្យអ្នកកណ្តាលនិយមអន្តរជាតិ៖ យើងស្វាគមន៍ការប្រើប្រាស់ប្រព័ន្ធសេរីពហុបក្ស ការបោះឆ្នោតប្រកបដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងការបោះឆ្នោតតាមកាលកំណត់ ដើម្បីប្រកួតដណ្តើមតំណែងអាសនៈដែលនេះជាជោគវាសនារបស់កម្ពុជា។ គណៈប្រតិភូអង្គការ សូមចូលរួមអបអរសាទរចំពោះប្រជាជនកម្ពុជា និងអាជ្ញាធរពាក់ព័ន្ធនានា ចំពោះកិច្ចខិតខំប្រឹងប្រែងក្នុងការផ្តួចផ្តើមអោយមានកំណែទម្រង់ទ្រង់ទ្រាយធំនេះ ដូចជាកំណែទម្រង់ក្បាលម៉ាស៊ីននៃស្ថានប័នរៀបចំចាត់ចែងការបោះឆ្នោតជាដើម ការបង្កើតច្បាប់បោះឆ្នោតថ្មី និងច្បាប់ស្តីពីគណបក្សនយោបាយ ច្បាប់គ្រប់គ្រងអង្គការសមាគមក្រៅរដ្ឋាភិបាល

[2] http://www.ticambodia.org/sbo2017findings/

[3] https://www.facebook.com/uyfc.cambodia/photos/pcb.1752962394719509/1752955781386837/?type=3&theater

[4] https://www.hrw.org/news/2017/06/12/cambodia-commune-elections-not-free-or-fair

កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងប្រព័ន្ធវិមជ្ឈការជាដើម។ កំណែទម្រង់ទាំងអស់នេះ គឺពិតជាមានសារៈសំខាន់បំផុតចំពោះនីតិរដ្ឋ និងប្រជាធិបតេយ្យនៅកម្ពុជា។ បន្ទាប់ពីប្រជាជនកម្ពុជាបានឆ្លងកាត់ទុក្ខសោកឈឺចាប់ជាប្រវត្តិសាស្ត្រមក ការបង្ហាញសំដែងឆន្ទៈដោយការយោសនាដោយសន្តិវិធី និងឥរិយាបថចូលរួមក្នុងកិច្ចការនយោបាយនៅថ្ងៃបោះឆ្នោត ប្រជាពលរដ្ឋកម្ពុជាបាននាំគ្នាចេញទៅបោះឆ្នោតក្នុងអត្រាមួយដែលខ្ពស់ខ្លាំង វាបង្ហាញអោយឃើញគំរូសម្រាប់ប្រទេសផ្សេងៗលើសកលលោក។ យើងខ្ញុំសូមលើកទឹកចិត្តអោយសង្គមកម្ពុជា ជាពិសេសភាគីពាក់ព័ន្ធនយោបាយ និងភាគីផ្សេងៗទៀត រួមកំលាំងផ្សារភ្ជាប់គ្នា ក្នុងស្មារតីជាវេទិកាសម្រាប់រិះគន់ ដើម្បីស្ថាបនា និងកែលម្អ និងក្នុងគោលបំណងដើម្បីលើកតំកើង រក្សាសន្តិភាព ប្រជាធិបតេយ្យ ស្ថេរភាព នីតិរដ្ឋ វឌ្ឍនភាពយូរអង្វែង និងយុត្តិធម៌សង្គម។ អង្គការ.....សូមកោតសរសើរដល់គណបក្សនយោបាយទាំងពីរ គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច ដែលជាបងប្អូនប្រុសស្រីជាមួយពួកយើង ក្នុងការដើរតួនាទីដ៏សំខាន់ក្នុងដំណើរការបោះឆ្នោតនេះ និងក៏កំពុងតែជួយការពារតំលៃរួម និងគោលការណ៍នយោបាយជាគ្រួសាររបស់យើង។[5]

អង្គការសន្និសីទអន្តរជាតិអាស៊ីនៃគណបក្សនយោបាយ និងអង្គការអ្នកប្រជាធិបតេយ្យអន្តរជាតិនិយមកណ្តាលអាស៊ីហ្វិក (ICAPP-CAPDI)៖ អង្គការ ICAPP-CAPDI ចាត់ទុកការបោះឆ្នោតនៅកម្ពុជាជ ជាជ័យជំនះនៃប្រជាធិបតេយ្យ និងជាជ័យជំនះរបស់ប្រជាជនកម្ពុជាទាំងមូលក្នុងការស្វែងរកនូវអនាគតដ៏ល្អប្រសើរមួយដោយផ្អែកលើភាពរឹងមាំ និងបរិសុទ្ធភាពនៃសន្លឹកឆ្នោតរបស់ប្រជាជនកម្ពុជា។ ការបោះឆ្នោតឃុំ សង្កាត់នេះប្រព្រឹត្តទៅប្រកបដោយ សេរី ត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព ហើយលើសពីនេះទៀត គឺការបោះឆ្នោតនេះប្រព្រឹត្តទៅយ៉ាងរលូនដោយគ្មានអំពើហឹង្សា សន្តិភាព នេះបញ្ជាក់អោយឃើញថា មិនត្រឹមតែប្រជាធិបតេយ្យប៉ុណ្ណោះទេដែលមានភាពចាស់ទុំ ប៉ុន្តែផ្នែកនយោបាយក៏ចាស់ទុំដែរ។ យើងសូមសំដែងនូវការអបអរសាទរពេញទំហឹង និងអស់ពីដួងចិត្តចំពោះប្រជាជនកម្ពុជា គណបក្សនយោបាយ ថ្នាក់ដឹកនាំ ប្រព័ន្ធផ្សព្វផ្សាយ អង្គការសង្គមស៊ីវិល និងគណៈកម្មាធិការធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ចំពោះភាពជោគជ័យដ៏ត្រចះត្រចង់នៃការរៀបចំការបោះឆ្នោតដ៏មានរបៀបរៀបរយនេះ។[6]

២.៣ ការវាយតំលៃជារួម[7]

ការវាយតំលៃជារួម ខុមហ្វ្រែលអាចសន្និដ្ឋានថា ពាក់ព័ន្ធជាមួយនឹងការចុះឈ្មោះបោះឆ្នោត និងការគ្រប់គ្រងបញ្ជីឈ្មោះបោះឆ្នោត ការចុះឈ្មោះបេក្ខជន ដំណើរការថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងការ

[5] https://idc-cdi.com/en/news/following-the-invitation-of-the-national-election-committee-delegation-of-the-centrist-democrat-international-idc-cdi-led-by-h-e-mr-andres-pastrana-idc-cdi-president-and-former-president-of-col/

[6] Available at: http://www.akp.gov.kh/?p=34921

[7] COMFREL endorsed the Situation Room on Cambodian Commune Council Elections in 2017 who had more than 40 independent Civil Society Organizations (CSOs) and expert individuals together:
To provide a Nonpartisan Collaborative Platform (CP) which are able To make assessment of elections and verification of the election outcomes

ប្រកាសលទ្ធផលបោះឆ្នោត ការគ្រប់គ្រង និងចាត់ចែងការបោះឆ្នោត មានភាពល្អប្រសើរគួរអោយកត់សំគាល់ និងមានតម្លាភាពជាងការបោះឆ្នោតមុនៗ។ ទោះជាយ៉ាងណា ចំពោះការគ្រប់គ្រង និងចាត់ចែងលើការឃោសនាបោះឆ្នោត និងការដោះស្រាយបណ្តឹងបោះឆ្នោត រកឃើញថា មិនមានភាពប្រសើរច្រើនគួរអោយកត់សំគាល់នោះទេ។ បើទោះជាការបោះឆ្នោតនេះ បានប្រព្រឹត្តទៅដោយគ្មានអំពើហឹង្សាធ្ងន់ធ្ងរ ប៉ុន្តែភាពមិនប្រក្រតីនៃដំណើរការរៀបចំការបោះឆ្នោត រកឃើញនៅមានចំនួនច្រើននៅឡើយ នៅដំណាក់មុនការបោះឆ្នោត។ ភាពមិនប្រក្រតីទាំងនោះមានទាំងភាពមិនប្រក្រតីផ្នែកបច្ចេកទេស និងទិដ្ឋភាពនយោបាយ។ ភាពមិនប្រក្រតីមួយចំនួនក្នុងចំណោមភាពមិនប្រក្រតីផ្សេងៗ ដែលត្រូវបានកំណត់សំគាល់ជាករណីធ្ងន់ធ្ងររួមមាន ៖ ការយាយីធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ កង្វះតម្លាភាព វិសមភាពលើការឃោសនាបោះឆ្នោត (ជាពិសេស ហិរញ្ញវត្ថុគណបក្សនយោបាយ) ការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ ដែលអាចកំណត់បានអំពីកម្រិតលម្អៀងនៃការប្រកួតប្រជែង បទបញ្ញត្តិក្នុងមាត្រាថ្មីមួយចំនួននៃច្បាប់បោះឆ្នោតឃុំ សង្កាត់ ការធ្វើវិសោធនកម្មច្បាប់គណបក្សនយោបាយបានទាញទម្លាក់នូវដំណើរការប្រជាធិបតេយ្យ សេរី កង្វះអព្យាក្រឹត្យភាព និងឯករាជ្យភាពនៃប្រព័ន្ធតុលាការ ការចូលរួមជីវភាព និងភាពសកម្មនៃមន្ត្រីយោធា កងកម្លាំងប្រដាប់អាវុធជាន់ខ្ពស់ ក្នុងសកម្មភាពគាំទ្រ និងប្រឆាំងផ្នែកនយោបាយ និងការកៀបសង្កត់ រឹតត្បិតសិទ្ធិសេរីភាព សកម្មភាព និងសិទ្ធិរបស់អង្គការសង្គមស៊ីវិលជាដើម។ ភាពមិនប្រក្រតីទាំងនេះ បានជះឥទ្ធិពលអវិជ្ជមាន និងធ្វើអោយប៉ះពាល់មួយផ្នែកធំដល់ការបោះឆ្នោតប្រកបដោយសេរី និងយុត្តិធម៌ ដែលគួរតែកើតចេញពីការអនុវត្តន៍ឆន្ទៈប្រកបដោយសេរីរបស់ម្ចាស់ឆ្នោតក្នុងការប្រើប្រាស់សិទ្ធិ និងសេរីភាពរបស់ពួកគេ ក្នុងការចូលរួមក្នុងដំណើរការប្រជាធិបតេយ្យតាមមធ្យោបាយនៃការបោះឆ្នោត។

៣. បរិយាកាសនយោបាយ

បរិយាកាសនយោបាយមុនការបោះឆ្នោតឆ្នាំ២០១៧ គឺជាការបោះឆ្នោតដែលគួរអោយព្រួយបារម្ភបំផុត បរិយាកាសនយោបាយវាមិនត្រឹមតែប៉ះពាល់ដល់ប្រសិទ្ធភាពនៃការបោះឆ្នោតប៉ុណ្ណោះទេ តែវាថែមទាំងធ្វើអោយដំណើរការប្រជាធិបតេយ្យមានការធ្លាក់ចុះ ហើយសេរីភាពជាច្រើនក៏ត្រូវបានរឹតត្បិតផងដែរ។[8] បរិយាកាសមុនការបោះឆ្នោត គឺមានផលប៉ះពាល់ជាអវិជ្ជមានយ៉ាងខ្លាំងដែលបណ្តាលអោយមានបញ្ហា ៣ ធំៗ គឺ ទី១ ការធ្វើវិសោធនកម្មច្បាប់ដោយឯកតោភាគី (មានតែតំណាងរាស្ត្រមកពីគណបក្សកាន់អំណាចតែមួយគត់) ដែលមើលឃើញថាជាគោលការណ៍ដើម្បីដាក់គំនាបទៅលើគណបក្សប្រឆាំង ទី២ បង្កើតបរិយាកាសចលាចលបែបលក្ខណៈនយោបាយ ដូចជា ការគំរាមកំហែង និងការបំភិតបំភ័យដោយមន្ត្រីគណបក្សកាន់អំណាចក្នុងជួររដ្ឋាភិបាល ដោយមូលហេតុរក្សាសន្តិសុខសណ្តាប់ធ្នាប់ជាតិ ទី៣ បន្តពង្រឹង និងរឹតត្បិតដល់សង្គមស៊ីវិល ក៏ដូចជាគណបក្សប្រឆាំងតាមរយៈយន្តការផ្លូវច្បាប់។

[8] A broader discussion of the political conditions during the 5th mandate of the National Assembly prior to 2017 can be found in COMFREL's annual reports on democracy, parliament performance, and misuse of state resources.

៣.១ ការធ្វើវិសោធនកម្មច្បាប់ដោយឯកតោភាគីដែលផ្តុយនឹងសេរីពហុបក្ស និងការធ្វើទុក្ខបុកម្នេញផ្នែកច្បាប់ ដល់គណបក្សប្រឆាំង

ការធ្វើវិសោធនកម្មច្បាប់បានធ្វើអោយគណបក្សជាច្រើនទាមទារចូលរួមប្រកួតប្រជែង ដូចដែលមានបញ្ជាក់ក្នុងរដ្ឋធម្មនុញ្ញដែលចែងអំពីពហុបក្ស ហើយក៏ជាបរិបទនៃជម្រើសដោយសេរីសម្រាប់អ្នកបោះឆ្នោត។ ដំណើរការនេះបានជម្រុញឱ្យមានការធ្វើវិសោធនកម្មច្បាប់មានបញ្ហា ដែលបានធ្វើការអនុម័តចាប់តាំងពីការបោះឆ្នោតឆ្នាំ២០១៣ ដោយមានកំណែទំរង់លើប្រព័ន្ធតុលាការ ច្បាប់បោះឆ្នោត និងបទបញ្ជាសម្រាប់សង្គមស៊ីវិល។ នៅអំឡុងឆ្នាំ២០១៧ ការបោះឆ្នោតជ្រើសរើសបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់បានចាប់ផ្តើមធ្វើអោយមានសុទិដ្ឋិនិយមកាន់តែខ្លាំងដែលនឹងធ្វើអោយមានភាពប្រសើរឡើងសម្រាប់ការបោះឆ្នោត។ បន្ទាប់ពីមានការលើកលែងទោសពីព្រះមហាក្សត្រចំពោះប្រធានគណបក្សប្រឆាំងគឺ លោក កឹម សុខា ខណៈនោះប្រធានគណបក្សទាំងពីរគឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ បានជួបសន្ទនាគ្នានៅដើមខែធ្នូ ឆ្នាំ ២០១៦។ ក្រោយពីជំនួបនេះ គណបក្សប្រឆាំងបានទាមទារអោយមានការបន្តកិច្ចពិភាក្សាគ្នាបន្ថែមទៀត។ ហេតុដូច្នេះហើយ នៅឆ្នាំ២០១៧ បានចាប់ផ្តើមមានក្តីសង្ឃឹមយ៉ាងខ្លាំងសម្រាប់ការផ្សះផ្សាដែលទាមទារអោយមានការបោះឆ្នោតដោយរលូន ហើយមានការចូលរួមក្នុងនយោបាយដោយពេញលេញ ខណៈដែលក្រសួងមហាផ្ទៃព្រមពិភាក្សាជាមួយគណបក្សប្រឆាំង។

ទោះជាដូច្នេះក្តី នីតិវិធីច្បាប់បានធ្វើអោយប៉ះពាល់ទំនុកចិត្តនយោបាយ និងស្ថានភាពនៃការបញ្ចេញមតិជាសាធារណៈដែលមានសារៈសំខាន់សម្រាប់ដំណើរការបោះឆ្នោតពិតប្រាកដ ដែលអាចបញ្ជាក់ពីភាពជឿជាក់របស់អ្នកនយោបាយនៅចំពោះមុខសាធារណជន។ ដំណើរការច្បាប់បានចាប់ផ្តើមតាមសំណើរបស់គណបក្សកាន់អំណាច ដើម្បីកែប្រែបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា ការសុំអោយធ្វើការកែប្រែនេះ ត្រូវបានដាក់ញត្តិដោយនាយករដ្ឋមន្ត្រីក្នុងអំឡុងពេលដែលលោកនៅបរទេស ដើម្បីចូលរួមវេទិកាសេដ្ឋកិច្ចពិភពលោក ហើយបានផ្សព្វផ្សាយដំបូងតាមរយៈប្រព័ន្ធផ្សព្វផ្សាយដែលចំណុះអោយរដ្ឋាភិបាល។ វិសោធនកម្មនេះបានកែមាត្រា៤៨ វាក្យខណ្ឌទី៣ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភាដែលបានចែងថា«គណបក្សប្រឆាំងដែលមានសំឡេងភាគតិចនៅក្នុងរដ្ឋសភា ជាអ្នកដឹកនាំសំឡេងភាគតិចរបស់ខ្លួននៅក្នុងរដ្ឋសភា»។

យោងតាមប្រភពព័ត៌មានបានចុះផ្សាយបានអោយដឹងថា ប្រធានដឹកនាំភាគតិចនេះ ត្រូវបានបង្កើតឡើងមាត្រា៤៨ វាក្យខណ្ឌទី៣ ជំពូកទី១២ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ក្រោយពេលដែលគំនិតផ្តួចផ្តើមត្រូវគ្នានៃគណបក្សនយោបាយដោយសម្តេចតេជោ ហ៊ុន សែន និងឯកឧត្តម សម រង្ស៊ី ជាអតីតប្រធានគណបក្សសង្គ្រោះជាតិ ដែលត្រូវនិរទេសខ្លួននៅក្រៅប្រទេស ដែលជំនួបនេះត្រូវបានធ្វើឡើងកាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤ រវាងថ្នាក់ដឹកនាំនៃគណបក្សទាំងពីរ ក្នុងសម័យប្រជុំទី៣ នីតិកាលទី៥ រដ្ឋសភា។[9]

[9] “Roles of NA majority and minority leaders removed”, Agence Kampuchea Presse, 31 January 2017.

ការផ្តួចផ្តើមអោយមានការផ្លាស់ប្តូរគោលនយោបាយនេះ ហាក់បីដូចជាបានកំណត់ឱ្យកាន់តែប្រាកដ ដើម្បីកាត់បន្ថយវប្បធម៌សន្ទនារវាងគណបក្ស ដូចជាបានលុបចោលយន្តការជាផ្លូវការ ដើម្បីធានាដល់ការបន្ត ជំនួប ដើម្បីធ្វើការផ្សះផ្សាផ្នែកនយោបាយ។ ស្ថេរភាពនយោបាយដែលកើតចេញពីការរួបរួមគ្នា និងកំណែរទំរង់ ជាតម្រូវការដ៏សំខាន់នៅក្នុងកិច្ចព្រមព្រៀងឆ្នាំ២០១៤។[10] ប្រសិទ្ធភាព ជាមូលដ្ឋានគ្រឹះនៃការសម្រុះសម្រួលផ្នែកនយោបាយ ដែលបានកើតមានឡើងបន្ទាប់ពីមានភាពចលាចល និងភាពជាប់គាំងក្រោយការបោះឆ្នោត។ បញ្ហារបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលមិនចរចា គឺដោយសារតែបក្សប្រឆាំងបានព្យាយាមយករឿងអ្នកទោសនយោបាយដាក់ចូលក្នុងរបៀបវារៈសម្រាប់ការពិភក្សា។[11] យោងតាមសេចក្តីថ្លែងការណ៍របស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានអោយដឹងថា ការធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា ដើម្បីរារាំងពីការប្រើប្រាស់វប្បធម៌សន្ទនា ដើម្បីចរចាអោយដោះលែងអ្នកទោស។[12]

ក្នុងរយៈពេលពីរសប្តាហ៍ សមាជិកសភាគណបក្សកាន់អំណាចចំនួន៥០រូប បានចុះហត្ថលេខាដើម្បីបង្ហាញពីការគាំទ្រចំពោះសំណើច្បាប់ ហើយការវិសោធនកម្មនេះត្រូវបានទទួលយកដោយគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា។[13] នៅចុងខែមករា ការវិសោធនកម្មត្រូវបានអនុម័តដោយរដ្ឋសភាដោយមានសម្លេងគាំទ្រចំនួន៦៧ ដោយសមាជិកសភាគណបក្សកាន់អំណាច។[14] នៅពេលនោះប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋាភិបាលបានប្រកាសអំពីការផ្លាស់ប្តូរគោលនយោបាយ ហើយអះអាងថា គោលនយោបាយវប្បធម៌នៃការសន្ទនា[15] នៅតែបន្តទោះបីជា នាយករដ្ឋមន្ត្រីបានណែនាំឱ្យតុលាការត្រួតពិនិត្យ ដើម្បីរឹបអូសទីស្នាក់ការនៃគណបក្សប្រឆាំងក៏ដោយ។ លោកបានណែនាំដល់លោកឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង ឱ្យណែនាំមេធាវីផ្ទាល់ខ្លួនដើម្បីស្នើសុំអ្វីដែលត្រូវបានគ្រប់គ្រងក្នុងរឿងអាស្រូវដែលលោក សម រង្ស៊ី ត្រូវបានផ្តន្ទាទោស។ លោកបានអំពាវនាវឱ្យបង្កភាល់ទ្រព្យសម្បត្តិរបស់លោក សម រង្ស៊ី និងធ្វើការរឹបអូសទ្រព្យសម្បត្តិផងដែរ។[16]

ក្នុងពេលជាមួយគ្នានេះដែរ សម្តេចហ៊ុនសែនបានធ្វើការគំរាមធ្វើវិសោធនកម្មច្បាប់ ស្តីពីគណបក្សនយោបាយ ដើម្បីរារាំងលោក សម រង្ស៊ី មិនឱ្យដឹកនាំគណបក្សសង្គ្រោះជាតិ ដែលនាំឱ្យមានការរំលាយគណបក្ស ដោយសារមានការភ្ជាប់ទំនាក់ទំនងជាមួយអ្នកដឹកនាំទៅនឹងអ្នកដែលត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ។ លោកបានអះអាងថា ការផ្លាស់ប្តូរនីតិប្បញ្ញត្តិ គឺចាំបាច់ដើម្បីការពារ "អ្នកទោស" ពីការបម្រើជាប្រធាន ឬអនុ

[10] Thul, Chan Prak, "Cambodia's opposition leader loses key role ahead of elections", Reuters, 31 January 2017.
[11] Note that the reason for the change in the articles following political compromise between the two parties in 2014, was that the previous mechanism set out in Art 48 (II) had not been effective, as allowing for 10 lawmakers in agreement to raise an issue in plenary session had not resulted the levels of political compromise required to sustain multiparty representative government in the past.
[12] Sokhean, Ben "Prime Minister Makes Moves to End Future Talks With CNRP", Cambodia Daily, 17 Jan 2017; Sokchea, Meas "NA meeting planned on 'minority' clause", Phnom Penh Post, 20 January 2017.
[13] Sokchea, Meas "NA meeting planned on 'minority' clause", Phnom Penh Post, 20 January 2017.
[14] "Roles of NA majority and minority leaders removed", 31 January 2017
[15] Sophirom, Khan "PM reaffirms continuation of culture of dialogue", Agence Kampuchea Presse, 31 January 2017.
[16] Naren, Kuch "Hun Sen: Seize CNRP headquarters, ban Sam Rainsy from Party Leadership", Cambodia Daily 31 January 2017.

ប្រធានគណបក្សនយោបាយ ដោយសំដៅទៅលើការផ្លាស់ប្តូរគោលនយោបាយ ដែលជាទង្វើមួយដើម្បីលុបបំបាត់សិទ្ធិរបស់ពួកគេ[17]។ ការផ្លាស់ប្តូរនេះបានបន្ថែមទៅលើច្បាប់ជាច្រើនដែលបានអនុម័តដោយឯកតោភាគីរបស់គណបក្សកាន់អំណាច ដោយគ្មានការចូលរួមពីគណបក្សប្រឆាំង ឬការបោះឆ្នោតនៅក្នុងសភា។ នៅថ្ងៃទី២ ខែកុម្ភៈ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសថា «យើងនឹងរារាំង មិនត្រឹមតែមនុស្សពីរបីនាក់ប៉ុណ្ណោះទេ ប៉ុន្តែយើងនឹងកំចាត់ចោលទាំងស្រុងតែម្តង» [18]។

ការផ្លាស់ប្តូរបានកើតឡើងនៅក្នុងបរិបទមួយ នៅពេលចំនួនពាក្យបណ្តឹងប្រឆាំងនឹងមេដឹកនាំគណបក្សប្រឆាំងគឺលោក សម រង្ស៊ី បានកើនឡើងដល់ប្រាំមួយ (រាប់បញ្ចូលទាំងការផ្តន្ទាទោស និងការចោទប្រកាន់ដោយឥស្សរជនគណបក្សកាន់អំណាចពីបទបរិហារកេរ្តិ៍)។[19] ចំពោះប្រធានគណបក្សប្រឆាំងលោក សម រង្ស៊ី ដែលត្រូវបានចោទប្រកាន់ពីបទបរិហារកេរ្តិ៍ គឺត្រូវបានធ្វើឡើងក្រោយពេលដែលមានការលេចធ្លាយការសន្ទនារវាងសកម្មជនគណបក្សប្រឆាំង គឺ កញ្ញា ធី សុវណ្ណថា ដែលបានពិភាក្សាអំពីកិច្ចព្រមព្រៀងព្រំដែនជាមួយវៀតណាម និងពិភាក្សាអំពីប្រភពនៃ "ឡាយ (Like)" ទាំងអស់នៅលើទំព័រហ្វេសប៊ុកនាយករដ្ឋមន្ត្រី មកពីបរទេស។[20] លើសពីនេះ នៅក្នុងខែតុលាឆ្នាំ២០១៦ សម្តេចនាយករដ្ឋមន្ត្រី បានបញ្ជាឱ្យគ្រប់ស្ថាប័នដែលពាក់ព័ន្ធទាំងអស់ ឱ្យប្រើគ្រប់មធ្យោបាយ ធ្វើយ៉ាងណាដើម្បីរារាំងលោក សម រង្ស៊ី មិនឱ្យវិលត្រឡប់មកប្រទេសកម្ពុជាវិញ។[21]

នៅពាក់កណ្តាលខែកុម្ភៈ ឆ្នាំ២០១៧ លោក សម រង្ស៊ី បានលាលែងពីតំណែងប្រធានគណបក្សប្រឆាំង ដែលស្ថិតក្រោមការគំរាមកំហែងនៃច្បាប់ថ្មី ដែលអាចធ្វើឱ្យស្របច្បាប់ចំពោះការរំលាយគណបក្សប្រឆាំងរបស់ខ្លួន។[22] គណបក្សប្រជាជនកម្ពុជាបានជំរុញច្បាប់(បង្កើតច្បាប់ថ្មីបន្ថែម) ដើម្បីធ្វើការហាមឃាត់មេដឹកនាំដែលត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ។ ប្រសិនបើប្រធានគណបក្សប្រឆាំងដែលត្រូវបានកាត់ទោសពីបទឧក្រិដ្ឋនៅតែធ្វើនយោបាយ ឬជាប់ពាក់ព័ន្ធជាមួយគណបក្សទៀត នោះច្បាប់នេះនឹងអនុញ្ញាតឱ្យរំលាយគណបក្សនយោបាយ ប្រសិនបើគេ(គណបក្សកាន់អំណាច)ចាត់ទុកថាជាការគំរាមកំហែងដល់សន្តិសុខជាតិ និង/ឬឯកភាពជាតិ។ ព្រឹត្តិការណ៍នេះនៅតែអាចកើតឡើង បើទោះបីជាមានការអំពាវនាវឱ្យមានការពន្យារ

[17] Tha, Vuthy and Chandara Yang "Cambodian crackdown on 'culprits' targets Hun Sen's opponents", RFA 31 January 2017.
[18] Moniroth, Morm and Thay Tha "Hun Sen's push to outlaw the opposition draws fire", RFA, 7 February 2017.
[19] Ibid. See also Mech, Dara "Sovantha files suit against Rainsy", Phnom Penh Post, 18 January 2017.
[20] Sovuthy, Khy and George Wright "Hun Sen files $1million lawsuit against Rainsy", Cambodia Daily, 19 January 2017.
[21] Huot, Vuthy and Moniroth Morm "Cambodia's Hun Sen sues rival Sam Rainsy, again", RFA 18 January 2017. Notably, Rainsy's discourse, although within the bounds of free speech accepted in consolidated democracies, has also at times been provocative and not conducive to further reconciliation between political parties. For example see, Sokchea, Meas "Rainsy 'lobs' bribery claim at PM", Phnom Penh Post, 16 January 2017.

[22] Turton, Shaun "Sam Rainsy resigns as leader of CNRP", Phnom Penh Post, 11 February 2017; Naren, Kuch "Sam Rainsy resigns as opposition party president", Cambodia Daily, 11 February 2017.

ពេល ដើម្បីឱ្យមានការពិគ្រោះយោបល់ ជាច្រើនភាគីដែលពាក់ព័ន្ធឱ្យកើតមានឡើងក៏ដោយ។[23] ដូចបានសំគាល់តាមរយៈការវិភាគរបស់ក្រុមអ្នកវិភាគនយោបាយឯករាជ្យថា ព្រឹត្តិការណ៍ទាំងនេះបានបង្ហាញឱ្យឃើញឡើងវិញ នូវនិន្នាការនយោបាយដ៏យូរអង្វែងដែលមិនព្រមវែកញែករកហេតុផល ដើម្បីពិភាក្សាគោលនយោបាយ និងផ្តោតលើការផ្លាស់ប្តូរនយោបាយ។ លោក សម រង្ស៊ី បានដឹកនាំគណបក្សប្រឆាំង និងជាម្លេងសំខាន់ដែលបានអំពាវនាវឱ្យមានកំណែទម្រង់នយោបាយជាងពីរទសវត្សរ៍មកនេះ។[24] មុនចុងខែកុម្ភៈ សមាជិកព្រឹទ្ធសភា លោក ហុង សុខហួរ សមាជិកគណបក្សសង្គ្រោះជាតិ លោក មាច សុវណ្ណារ៉ា និងលោក អ៊ុំ សំអាន (អ្នកទាំងអស់នេះ បច្ចុប្បន្នត្រូវបានគេដាក់គុកដោយសារតែហេតុផលនយោបាយ) បានលាលែងពីគណបក្សប្រឆាំងក្រោមការគំរាមកំហែងនៃការរំលាយបក្ស។

ក្នុងអំឡុងពេលសប្តាហ៍ទី៤ នៃខែកុម្ភៈ ឆ្នាំ២០១៧ គណបក្សកាន់អំណាចបានបន្តវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយដោយឯកតោភាគី ដោយបញ្ជូនវាទៅអោយរដ្ឋសភា ព្រឹទ្ធសភា និងត្រូវបានពិនិត្យដោយក្រុមប្រឹក្សាធម្មនុញ្ញ ហើយច្បាប់នេះត្រូវបានចុះហត្ថលេខាអោយចូលជាធរមាន ដោយប្រមុខរដ្ឋស្តីទីប្រធានព្រឹទ្ធសភាលោក សាយ ឈុំ ខណៈពេលដែលអវត្តមានព្រះមហាក្សត្រ។[25] ថ្វីបើមានការជំទាស់ពីគណបក្សប្រឆាំងដ៏ធំ និងគណបក្សនយោបាយតូចៗ ដទៃទៀត ពីអង្គការសង្គមស៊ីវិលជាតិ ម្ចាស់ជំនួយអន្តរជាតិសំខាន់ៗ រដ្ឋប្រជាធិបតេយ្យដែលបានបង្រួបបង្រួម និងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ បានស្នើអោយមានការលុបចោលច្បាប់ដែលធ្វើវិសោធនកម្មក៏ដោយ ក៏ច្បាប់នេះត្រូវបានសភាជាតិអនុម័តផងដែរ ហើយគណបក្សកាន់អំណាច បាននិយាយថា ការធ្វើវិសោធនកម្មនេះ គឺជាបង្កើតបរិយាកាសនយោបាយអោយមានភាពប្រសើរឡើង ហើយស្របតាមលទ្ធិប្រជាធិបតេយ្យទៀតផង។[26] ការវិសោធនកម្មត្រូវបានអះអាងផងដែរថា វិសោធនកម្មនេះ មិនមែនធ្វើឡើងដើម្បីដាក់កំហិត និងដាក់ទណ្ឌកម្មគណបក្សសង្គ្រោះជាតិនោះទេ ប៉ុន្តែដោយសារច្បាប់គណបក្សនយោបាយហួសសម័យ។[27]

សម្តេចនាយករដ្ឋមន្ត្រីបានព្រមានម្តងហើយម្តងទៀតថា ជ័យជំនះរបស់គណបក្សប្រឆាំង ឬការផ្លាស់ប្តូរនាយករដ្ឋមន្ត្រី នឹងនាំឱ្យមានសង្គ្រាម។ ហេតុផលនេះហើយទើបរដ្ឋាភិបាលរបស់គណបក្សប្រជាជនកម្ពុជា បានចាត់ទុកថា ជាការខុសច្បាប់រាល់គំនិតទាំងឡាយដែលចង់ធ្វើការផ្លាស់ប្តូរគណបក្សប្រជាជនកម្ពុជា ហើយថែមទាំងហាមឃាត់មិនអោយមានការប្រើពាក្យថា «ដូរ ដូរ» នៅក្នុងវោហាសាស្ត្រយុទ្ធនាការ និងសុន្ទរកថាជាសាធារណៈ។ គណបក្សកាន់អំណាច បានប្រឈមនឹងពាក្យស្លោកក្នុងយុទ្ធនាការឃោសនាបោះឆ្នោតរបស់គណបក្សប្រឆាំងថា "ប្តូរមេឃុំដែលបម្រើបក្សដាក់មេឃុំបម្រើរាស្ត្រ"។ ក្នុងសុន្ទរកថាកាលពីខែកុម្ភៈ រដ្ឋម

[23] Sokchea, Meas "CPP sets Monday vote for party law revamp", Phnom Penh Post, 16 February 2017.
[24] Wallace, Julia "Top opposition leader in Cambodia resigns as election nears", New York Times, 12 February 2017.
[25] Handley, Erin "In the King's name: party law amendments now official", Phnom Penh Post, 10 March 2017.
[26] It should be noted that the PM has also publicly stated that the purpose of the legislation change was to provide him with powers to obstruct the opposition party. See Roeun, Van, Zsombor Peter and Ben Sokhean "Attacks on slogan grown; Party law takes effect" Cambodia Daily 10 March 2017.
[27] Vida, Taing "Senate passes amendments to Law on Political Parties", Khmer Times, 1 March 2017.

ន្ត្រីការពារជាតិបានកំណត់ថា ពាក្យស្លោករបស់គណបក្សប្រឆាំងចំពោះ "ដូរៗ" គឺជាការគំរាមកំហែងដល់សន្តិសុខជាតិ ដែលពាក្យស្លោកនេះត្រូវបានប្រើដោយប្រជាពលរដ្ឋដើម្បីអំពាវនាវអោយមានការផ្លាស់ប្តូរ (សារដែលប្រើពាក្យ ដូរ ដូរ នេះ ជាញឹកញាប់ត្រូវបានគេឮនៅពេលដែលប្រជាពលរដ្ឋបានប្រមូលផ្តុំគ្នា ក្នុងអំឡុងនិងចាប់តាំងពីការបោះឆ្នោតឆ្នាំ២០១៣មក) ជាមហន្តរាយ និងសោកនាដកម្ម។[28]

ទោះបីជាយ៉ាងណាក៏ដោយ ដំណើរនៃយុទ្ធនាការប្រឆាំងទៅលើសារ បានចាប់ផ្តើមនៅពេលដែលសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសនៅក្នុងសុន្ទរកថាសាធារណៈថា ពាក្យស្លោកដែល «ប្តូរមេឃុំដែលបម្រើបក្សដាក់មេឃុំបម្រើរាស្ត្រ» គឺជាការប្រមាថ ការបង្កបញ្ហា និងការញុះញង់។[29] ចំណែកឯអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិបានយល់ឃើញថា ពាក្យស្លោកនេះអាចទទួលយកបានសម្រាប់លទ្ធិប្រជាធិបតេយ្យ ដែលរឹងមាំ និងស្របតាមការអនុវត្តន៍ សម្រាប់ការប្រកួតប្រជែងក្នុងការបោះឆ្នោតតាមរយៈការលើកកម្ពស់គំនិតដែលភាគី និងបេក្ខជនត្រូវបានគេវាយតម្លៃតាមបទដ្ឋានសម្រាប់ការឆ្លើយតប និងគណនេយ្យភាព។ វាជារឿងធម្មតានៅក្នុងប្រព័ន្ធលទ្ធិប្រជាធិបតេយ្យ ដែលគណបក្សកំពុងស្វែងរកគំនិតសម្រាប់ការគាំទ្រដើម្បីចូលកាន់អំណាចក្នុងការផ្លាស់ប្តូរការគ្រប់គ្រង់។

ព្រឹត្តិការណ៍ជុំវិញការវាយប្រហារទៅលើពាក្យស្លោករបស់គណបក្សសង្គ្រោះជាតិចង្អុលបង្ហាញពីលក្ខណៈ តាមតែចិត្តចង់នៃការអនុវត្តន៍ច្បាប់ និងបទបញ្ជានៅក្នុងប្រទេសកម្ពុជា ហើយគណបក្សកាន់អំណាចផ្តោតលើការរឹតបន្តឹងគណបក្សប្រឆាំង ជាជាងការបង្កើតសារសម្រាប់ប្រជាប្រិយភាពរបស់ខ្លួន។ បន្ទាប់ពីការប្រកាសជាសាធារណៈរបស់នាយករដ្ឋមន្ត្រីថា លោកបានកំណត់ពាក្យស្លោកដែលដូរៗថា ជាបទឧក្រិដ្ឋ ភ្លាមៗនោះដែរគណបក្សកាន់អំណាចបានចេញសេចក្តីថ្លែងការណ៍ថ្កោលទោសពាក្យស្លោកនោះ ហើយទាមទារឱ្យមានការផ្លាស់ប្តូរ«ដើម្បីសន្តិភាពនៃប្រទេស»។ ក្នុងរយៈពេលប៉ុន្មានថ្ងៃមកទៀត អ្នកនាំពាក្យគណបក្សកាន់អំណាច បានប្រាប់ប្រព័ន្ធផ្សព្វផ្សាយ និងសាធារណជនថា គណបក្សកាន់អំណាចកំពុងពិភាក្សាជាមួយមេធាវីដើម្បីចាត់វិធានការតាមផ្លូវច្បាប់ប្រឆាំងនឹងគណបក្សប្រឆាំង។ នៅពេលដំណាលគ្នានោះដែរ មេឃុំគណបក្សកាន់អំណាចជាច្រើនបានយល់ឃើញថា ការចាប់ផ្តើមប្រើពាក្យស្លោករបស់ពួកគេដោយសំដៅទៅលើក្រុមប្រឹក្សាឃុំសង្កាត់របស់គណបក្សប្រឆាំងថា ពាក្យស្លោកនោះ ជាពាក្យស្លោកមិនពិត។[30]

បញ្ហាទី១ នៃពាក្យស្លោកបានបង្ហាញឱ្យឃើញពីវិធីសាស្ត្ររបស់គណបក្សកាន់អំណាច ដើម្បីទប់ទល់ចំពោះបញ្ហាដែលកើតពីពាក្យស្លោកនោះ គឺបានកំណត់ពីគោលដំហរនៃគោលនយោបាយនៃការប្រើពាក្យស្លោកនោះនាំអោយមានការរើសអើង ហើយនឹងនាំអោយមានការចោទប្រកាន់ពីបទញុះញង់ដោយអាជ្ញាធរ។ ក្នុងករណីនេះ ការញុះញង់ គឺស្មើនឹងអ្វីដែលបានកំណត់ដែលនាំអោយការបែកបាក់នៅក្នុងសង្គមដូចជាការមិនយល់ស្រប ឬការប្រឆាំងជាសាធារណៈត្រូវបានចាត់ជាប្រភេទបទឧក្រិដ្ឋ។[31] បញ្ហាទី២ គឺបង្ហាញអោយ

[28] Touch Sokha and Leonie Kijewski " 'Change' begets 'disaster': Banh" Phnom Penh Post 27 February 2017.
[29] Dara, Mech "Premier warns CNRP's new poll slogan 'incitement'", Phnom Penh Post, 7 March 2017.
[30] Narin, Sun "Ruling party studies legality of opposition campaign slogan", VOA 9 March 2017.
[31] Chheng, Niem "CCP commune chiefs join fray against slogan", Phnom Penh Post 9 March 2017.

ឃើញថា ជាការវាយប្រហារទៅលើបទដ្ឋានសកលនៃអភិបាលកិច្ចល្អ។ របបលទ្ធិប្រជាធិបតេយ្យដែលមានការប្រកួតប្រជែងដោយផ្អែកលើគំនិត និងគោលនយោបាយ ត្រូវបានជាប់គាំងនៅពេលដែលមានការការពារគណនេយ្យភាព និងការឆ្លើយតបរបស់រដ្ឋាភិបាល ត្រូវបានចាត់ទុកថាខុសក្រមសីលធម៌ ឬខុសច្បាប់។ យោងតាមហេតុផលរបស់គណបក្សកាន់អំណាច ដែលត្រូវបានប្រាប់អោយដឹងតាមរយៈអ្នកនាំពាក្យរបស់គណបក្សប្រឆាំងនិយាយថា ពាក្យស្លោករបស់គណបក្សសង្គ្រោះជាតិ «រំលោភលើខ្លឹមសារនៃច្បាប់ ... វានាំអោយមានការរើសអើងប្រឆាំងនឹងមេឃុំ ចៅសង្កាត់ ដែលមេឃុំ និងចៅសង្កាត់ទាំងនោះភាគច្រើនជាមេឃុំចៅសង្កាត់របស់គណបក្សប្រជាជនកម្ពុជា។ ដូច្នេះការវាយតម្លៃ ដោយប្រើប្រើពាក្យស្លោក គឺផ្ទុយនឹងច្បាប់ ហើយវាជាទង្វើមួយដែលយើងមិនអាចទទួលយកបាន។[32] ទោះបីជាយ៉ាងនេះក្តី ក៏អង្គការសង្គមស៊ីវិល និងអ្នកជំនាញសិទ្ធិមនុស្ស យល់ឃើញថាគ្មានមូលហេតុណាមួយដែលថាការអះអាងនេះខុសច្បាប់នោះទេ ហើយគណបក្សប្រឆាំងយល់ឃើញថា ពាក្យស្លោកនេះគឺដើម្បីឱ្យអ្នកបោះឆ្នោតស្វែងរកការកែលម្អនីតិរដ្ឋ និងសេវាសង្គម។ ការបោះឆ្នោតសំដៅទៅលើជម្រើសហើយវាគឺជាការអនុវត្តន៍ធម្មតានៅក្នុងការបោះឆ្នោតរបស់បណ្តាប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យដែលគណបក្សប្រឆាំងធ្វើការតស៊ូមតិ ដើម្បីផ្លាស់ប្តូរអ្នកកាន់តំណែងរដ្ឋាភិបាល។

ក្នុងរយៈពេលតែប៉ុន្មានថ្ងៃប៉ុណ្ណោះ បន្ទាប់ពីសម្តេចនាយរដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសជាលើកដំបូងថា ពាក្យស្លោកនោះគឺខុសច្បាប់ ពេលនោះ មេឃុំ ចៅសង្កាត់ និងក្រុមប្រឹក្សាឃុំ សង្កាត់របស់គណបក្សកាន់អំណាច បានចេញលិខិតជាង ៣០០លិខិត ដើម្បីប្តឹងប្រឆាំងនឹងពាក្យស្លោក។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បានថ្លែងជាសាធារណៈថា និងវាយតម្លៃភាពស្របច្បាប់លើពាក្យស្លោករបស់គណបក្សសង្គ្រោះជាតិសម្រាប់យុទ្ធនាការនេះ។ គ.ជ.ប. បានប្រកាសថាខ្លួននឹងពិនិត្យ ឬមិនពិនិត្យមើល ថាតើពាក្យស្លោកនេះមានការប៉ះពាល់អត់ មុនពេលយុទ្ធនាការឃោសនាបោះឆ្នោត ប៉ុន្តែ គ.ជ.ប នឹងផ្តល់នូវដំណោះស្រាយចំពោះបញ្ហានេះ នៅក្នុងអំឡុងពេលឃោសនាបោះឆ្នោតបានចាប់ផ្តើម។ ទោះជាយ៉ាងណាក៏ដោយ គ.ជ.ប បានចាប់ផ្តើមអនុវត្តយុត្តាធិការរបស់ខ្លួន ដោយមិនអោយប្រើពាក្យស្លោកនោះទេ ហើយថាខ្លួនពិចារណារឿងនេះ ប្រសិនបើពាក្យបណ្តឹងត្រូវបានទទួលពីគណបក្សនយោបាយ។[33]

នៅពាក់កណ្តាលខែមីនា គណបក្សសង្គ្រោះជាតិបានប្រកាសថា ខ្លួននឹងឈប់ប្រើប្រាស់ពាក្យស្លោកប្រសិនបើត្រូវបានបញ្ជាដោយអាជ្ញាធរមានសមត្ថកិច្ច ក៏ដូចជាតុលាការជាដើម។ គណបក្សប្រឆាំងក៏បានព្យាយាមទទួលយកជំហរមួយដែលបានលើកឡើងថា បើទោះជាពាក្យស្លោកអាចទទួលយកបានក៏ដោយ ក៏វាមិនមែនជាពាក្យស្លោកជាផ្លូវការរបស់គណបក្សប្រឆាំងនោះទេ ដោយសារវាមិនដែលត្រូវបានអនុម័តជាផ្លូវការនិងផ្សព្វផ្សាយដោយគណបក្សនោះឡើយ ហើយក្នុងន័យនេះគណបក្សប្រឆាំងមិនបានធ្វើអ្វីខុសដោយប្រើពាក្យស្លោកនោះទេ។[34] ការព្យាយាមធ្វើអោយមានសមតុល្យភាពបានបរាជ័យក្នុងការកាត់បន្ថយសម្ពាធ

[32] Sokhean, Ben and Zsombor Peter "Defying CPP, CNRP to keep slogan", Cambodia Daily, 8 March 2017.
[33] Sothoeuth, Ith "Interior ministry calls on opposition to change campaign slogan" VOA, 27 March 2017
[34] Sokchea, Meas "Slogan neither official, nor illegal, CNRP says" Phnom Penh Post, 20 March 2017.

ពីរដ្ឋាភិបាល ហើយរដ្ឋាភិបាលបានប្រកាសថា គណបក្សប្រឆាំងត្រូវឈប់ប្រើពាក្យស្លោក ដើម្បីជៀសវាងការកាត់ទោសស្របច្បាប់។ ការផ្លាស់ប្តូរនេះបានបង្ហាញពីផលប៉ះពាល់ទាំងអស់ លើការថ្លែងសុន្ទរកថាជាសាធារណៈនិងសកម្មភាពទាក់ទងនឹងយុទ្ធនាការរបស់គណបក្សប្រឆាំង ដែលត្រូវបានបង្ខំឱ្យសម្របខ្លួនដើម្បីរស់នៅក្នុងបរិបទនីតិបញ្ញត្តិថ្មី ដែលជាសម្ពាធរបស់រដ្ឋាភិបាល។[35]

នៅសប្តាហ៍ទី៣ ខែមីនា ក្រសួងមហាផ្ទៃបានចេញសេចក្តីថ្លែងការណ៍មួយអំពាវនាវឱ្យគណបក្សប្រឆាំងផ្លាស់ប្តូរពាក្យស្លោក មិនមែនដោយសារតែវាជាការខុសច្បាប់ទេ តែដោយសារតែវាផ្ទុយនឹងតម្លៃនៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ ទន្ទឹមនឹងនោះដែរ មន្ត្រីក្រសួងមហាផ្ទៃបានថ្លែងការណ៍ថា ពាក្យស្លោកនោះគឺខុសច្បាប់ ប៉ុន្តែក្រសួងមហាផ្ទៃមិនមានសិទ្ធិ ឬអំណាចដើម្បីទាមទារឱ្យគណបក្សប្រឆាំងផ្លាស់ប្តូរទេ។[36] នៅពេលនោះយុទ្ធសាស្ត្ររបស់គណបក្សសង្គ្រោះជាតិត្រូវអះអាងថា ពាក្យស្លោកនោះមិនមែនជាផ្លូវការទេ ប៉ុន្តែវាមិនមានបំណងហាមឃាត់អ្នកគាំទ្រគណបក្សកុំប្រើវានោះទេ។ ទោះជាយ៉ាងណាក៏ដោយ ក្រសួងមហាផ្ទៃបានចាត់វិធានការជាសាធារណៈ ដែលវាបានធ្វើអោយមានការគំរាមកំហែងដល់គណបក្សប្រឆាំងកាន់តែធ្ងន់ឡើង។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបាននិយាយថា ពាក្យស្លោកដែលអំពាវនាវឱ្យអ្នកបោះឆ្នោតគាំទ្រខ្លួនដែលពួកគេភាគច្រើនបានគិតថា ជាផលប្រយោជន៍របស់ប្រជាជននោះ គឺជាការញុះញង់ ការរើសអើង និងភាពផ្តាច់ការ។ ហើយរដ្ឋមន្ត្រីរូបនេះបានបញ្ជាក់អះអាងថា វារំលោភលើសិទ្ធិរបស់មន្ត្រីមូលដ្ឋានរបស់គណបក្សប្រជាជនកម្ពុជា និងបណ្តាលអោយមានអំពើហឹង្សានៅក្នុងសង្គម។[37]

កាលពីថ្ងៃទី២ ខែមេសា ឆ្នាំ២០១៧ គណបក្សសង្គ្រោះជាតិបានប្រកាសថា ខ្លួននឹងឈប់ប្រើពាក្យស្លោកនោះទៀតហើយ ហើយបានទទួលស្គាល់ថា ពាក្យស្លោកនេះខ្លួនធ្លាប់បានដាក់បញ្ចូលក្នុងវេទិការគណបក្សជាសាធារណទៀតផង។ គណបក្សប្រឆាំងត្រូវបានបង្ខំអោយផ្លាស់ប្តូរពាក្យស្លោករបស់ខ្លួន ហើយថែមទាំងបង្ខំអោយទទួលយកតាមការទាមទាររបស់ក្រសួងមហាផ្ទៃ និងគណបក្សកាន់អំណាច។[38] ចាប់តាំងពីពេលនោះមក ពាក្យស្លោករបស់គណបក្សប្រឆាំង ត្រូវបានក្រសួងមហាផ្ទៃប្រកាសថា ខុសច្បាប់ដោយសារតែវាបានរំលោភលើច្បាប់ស្តីពីលក្ខន្តិកៈនយោបាយរបស់ខ្លួន។[39]

ពាក្យស្លោកជាយុទ្ធនាការ ដែលកើតចេញពីការខិតខំប្រឹងរួបរួមគ្នាត្រូវបានលុបបំបាត់ទៅវិញ ដោយសារតែសេចក្តីសម្រេចអោយប្រើប្រាស់ពាក្យស្លោកនេះជាប់ពាក់ព័ន្ធនឹងប្រធានគណបក្សប្រឆាំង។ សេចក្តីសម្រេចទាំងនោះរាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកថាខុសច្បាប់ ដោយផ្អែកលើមូលដ្ឋានថាពួកគេបានរំលោភបំពានលក្ខន្តិកៈគណបក្សខ្លួនឯង ដែលវាផ្ទុយនឹងអ្វីដែលបានកំណត់ក្នុងច្បាប់។ ទោះជាយ៉ាងនេះក្តី គណបក្សប្រឆាំងបានអះអាងថា ពាក្យ «ដូរ ដូរ»នេះ បានធ្វើឡើងគឺស្របទៅតាមការវិសោធនកម្មច្បាប់ស្តីពី

[35] Sokhean, Ben "Facing legal threat, CNRP set to drop campaign slogan" Cambodia Daily, 20 March 2017.
[36] Sothoeuth, Ith "Interior ministry calls on opposition to change campaign slogan" VOA, 27 March 2017.
[37] Sokchea, Meas "CPP keeps up slogan controversy" Phnom Penh Post, 23 March 2017.
[38] Sokhean, Ben "CNRP drops slogan amid pressure for sake of 'fair election'" Cambodia Daily, 3 April 2017.
[39] Sokchea, Meas "CNRP drops contentious slogan" Phnom Penh Post, 3 April 2017.

គណបក្សនយោបាយ។[40] នៅក្នុងខែមីនា គណបក្សសង្គ្រោះជាតិបានធ្វើសមាជបក្ស ២ដង សមាជទី១ គឺដើម្បីតែងតាំងលោក កឹម សុខា ជាប្រធានបក្សសង្គ្រោះជាតិ ហើយសមាជទី២ ដើម្បីកែប្រែលក្ខន្តិក:[41]បក្ស ដោយសម្របតាមការទាររបស់ក្រសួងមហាផ្ទៃដែលលើកឡើងថា លក្ខន្តិកនោះខុសច្បាប់ ដោយតម្រូវអោយវិសោធនកម្មអោយស្របច្បាប់វិញ។[42] ក្រោយពីជំនួបរវាងគណបក្សប្រឆាំង និងក្រសួងមហាផ្ទៃរួច ក្រសួងមហាផ្ទៃក៏បានចេញសេចក្តីប្រកាសជាសាធារណៈថា គណបក្សប្រឆាំងមិនធ្វើការផ្លាស់ប្តូរលក្ខន្តិក:ទេ ហើយថែមទាំងថា វាខុសដែលគណបក្សសង្គ្រោះជាតិ បានបោះឆ្នោតផ្ទៃក្នុងបក្សដោយរើសយកលោក កឹម សុខា ជាប្រធានបក្ស ហើយ លោក ប៉ុល ហំម អ្នកស្រី មួរ សុខហួរ និងលោក អេង ឆៃអ៊ាង ជាអនុប្រធានបក្ស ដែលការរើសនេះ វាផ្ទុយនឹងលក្ខន្តិក:ផ្ទៃក្នុងរបស់គណបក្សសង្គ្រោះជាតិ។ គ.ជ.ប. បានថ្លែងថា ការរៀបចំអោយលោក កឹម សុខា ជា ប្រធានស្តីទី គឺជាការត្រឹមត្រូវនឹងស្មារតីនៃការបោះឆ្នោតខាងមុខ។[43]

ក្រសួងមហាផ្ទៃបានទទួលស្គាល់លោក កឹម សុខា ជាប្រធានគណបក្សសង្គ្រោះជាតិ ក្រោយពេលដែលគណបក្សប្រឆាំងបានយល់ព្រមមិនប្រើពាក្យស្លោកក្នុងយុទ្ធការនាបោះឆ្នោតដែលនាំអោយមានជម្លោះ ក៏ប៉ុន្តែស្រាប់តែពេលក្រោយមកទៀត ក្រសួងមហាផ្ទៃបានអះអាងថា អនុប្រធានគណបក្សសង្គ្រោះជាតិ គឺគ្មានសុពលភាពទេ ដោយតែងតាំងមិនត្រូវតាមនីតិវិធីច្បាប់។ ច្បាប់នេះពីដំបូងបានកំណត់អោយជ្រើសរើសប្រធានគណបក្សត្រូវធ្វើឡើងអោយឆាប់ តែពេលនេះច្បាប់នេះបែរជាទាមទារអោយជ្រើសរើសអនុប្រធានទាំង៣នាក់នេះយឺតយ៉ាវទៅវិញ។ នេះជាការបង្ខិតបង្ខំអោយធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងរបស់គណបក្សសង្គ្រោះជាតិជាលើកទី២ ដែលធ្វើឡើងនៅសមាជបក្សវិសាមញ្ញនៅដើមខែមេសា។[44] នៅទីបំផុតប្រហែលជាពីខែក្រោយបន្ទាប់ពីធ្វើសមាជបក្សមក ក្រសួងមហាផ្ទៃបានចេញលិខិតជាផ្លូវការមួយ ដើម្បីជូនគណបក្សសង្គ្រោះជាតិដោយបញ្ជាក់ថា ខ្លួនបានទទួលលក្ខន្តិក:ថ្មីរបស់គណបក្សសង្គ្រោះជាតិហើយ។[45] ការចេញលិខិតនេះបានបញ្ចប់ការប្រឈមទៅនឹងគណបក្សប្រឆាំង ដែលបញ្ហាប្រឈមទាំងនោះមានដូចជា ការដកហូតសិទ្ធិមិនអោយចូលរួមបោះឆ្នោត ហើយថែមទាំងអាចត្រូវបានគេរំលាយបក្សខាងមុខជាដើម ដែលជាបញ្ហាសំខាន់ៗ។ បញ្ហានេះទំនងអាចធ្វើអោយគណបក្សសង្គ្រោះជាតិ បាត់បង់ទាំងសមត្ថភាព ដើម្បីរៀបចំ

[40] According to CNRP internal rules at the time (Art. 47), following the resignation of a party president there would be an 18-month interim period before holding a party conference to elect a new president. Nevertheless, the amended Law on Political Parties held that such a change of party leadership much occur within 90 days. The very purpose of the CNRP extraordinary congress was to amend party rules and enact a change of party leadership in compliance with the Law on Political Parties, but the effort to comply with the law was itself ruled unacceptable by the MOI without clarifying the legal grounds on which that policy was based.

[41] Following changes to party internal rules, the CNRP complied with existing regulations and submitted its new regulations to the MOI. See Sokchea, Meas "CNRP vexed as CPP continues to call Sokha's presidency invalid" Phnom Penh Post, 30 March 2017.

[42] Sokchea, Meas "CNRP drops contentious slogan" Phnom Penh Post 3 April 2017.

[43] Sokchea, Meas "CNRP vexed as CPP continues to call Sokha's presidency invalid" Phnom Penh Post, 30 March 2017.

[44] The new party by-laws enabled the party's central committee to select deputies at any time following the resignation of the party president.

[45] Sokchea, Meas "Interior approves CNRP's bylaws" Phnom Penh Post, 4 May 2017.

យុទ្ធសាស្ត្រ ការបោះឆ្នោតខាងមុខ ព្រមទាំងធ្វើអោយអ្នកបោះឆ្នោតគាំទ្រគិតថា គណបក្សសង្គ្រោះជាតិ មិនមែនជាគណបក្សប្រឆាំងធំបំផុតនៅកម្ពុជាទៀតទេ។ អ្វីដែលគួរអោយព្រួយបារម្ភបំផុត គឺបញ្ហានេះបានធ្វើអោយប៉ះពាល់ដល់នីតិរដ្ឋ ដែលនីតិរដ្ឋអាចមានទៅបាន ប្រជាធិបតេយ្យត្រូវតែដើរ តែដោយសារតែបញ្ហា វាហាក់បីដូចជាចេះតែកើតឡើង ហើយគាបសង្កត់រាល់សកម្មភាពរបស់គណបក្សប្រឆាំង តាមរយៈការកែប្រែបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនអោយស្របតាមច្បាប់ដែលបានធ្វើវិសោធនកម្ម។ លើសពីហ្នឹងទៅទៀត ក្រៅពីបញ្ហាប្រឈមទាំងនោះ មានបញ្ហាមួយទៀតដែលគួរអោយព្រួយបារម្ភ គឺគណបក្សកាន់អំណាច បានទាមទារអោយប្រើពាក្យស្លោកដែលជាយុទ្ធនាការរបស់គណបក្សប្រឆាំងត្រូវស្របតាមបទដ្ឋានច្បាប់ ឬប្រើពាក្យផ្សេងក្រៅពីប្រើពាក្យថា «ដូរ ដូរ»។ ចំណែកក្រសួងមហាផ្ទៃបានបញ្ជាក់យ៉ាងច្បាស់ថា គណបក្សសង្គ្រោះជាតិត្រូវតែឈប់ប្រើពាក្យនោះទៀត ទើបក្រសួងមហាផ្ទៃព្រមទទួលស្គាល់ថ្នាក់ដឹកនាំរបស់គណសង្គ្រោះជាតិ ដែលធ្វើឡើងដោយបំពានច្បាប់។[46]

ការរឹតត្បិតដោយគ្មានប្រជាធិបតេយ្យ ទៅលើការសាមគ្គីភាព និងយុទ្ធនាការរបស់គណបក្សប្រឆាំងបានបន្តធ្វើឡើងភ្លាមៗ ក្នុងពេលយុទ្ធនាការបោះឆ្នោត។ គណបក្សកាន់អំណាចបានកំណត់ថា ពាក្យស្លោកដែលថា «ដូរ ដូរ» និង «ហ៊ុន សែន អើយចុះចេញទៅ» គឺជាពាក្យស្លោកខុសច្បាប់ បើទោះបីជាការទាមទារអោយមានការផ្ទេរអំណាច តាមរយៈបោះឆ្នោតដោយសន្តិវិធីក៏ដោយ គឺជាការខុសច្បាប់ដែរ ហើយវិធានការតាមផ្លូវច្បាប់ នឹងត្រូវធ្វើឡើងដោយតុលាការ។[47] វាពិបាកណាស់ក្នុងការមើលឃើញពីភាពខុសគ្នារវាងផ្នែកច្បាប់ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រទូទៅ ដែលស្វែងរកភាពជោគជ័យក្នុងការបោះឆ្នោត ដោយគណបក្សកាន់អំណាច ដែលជាមូលដ្ឋានធ្វើឱ្យប៉ះពាល់ដល់ការប្រកួតប្រជែងស្មើភាពគ្នា សម្រាប់ការបោះឆ្នោតដោយយុត្តិធម៌។ នេះជាការរឹតត្បិតមួយក្នុងចំណោមការរឹតត្បិតទាំងអស់ ដែលបានធ្វើឡើងតាមការយល់ឃើញរបស់គណបក្សប្រជាជនកម្ពុជា តាមរយៈការរៀបចំដែលគណបក្សកាន់អំណាចបានបង្កើតច្បាប់ ហើយការរំលោភបំពានដោយការសម្រេចចិត្តរបស់ខ្លួន។[48]

៣.២ ការគំរាមកំហែង និងការបំភិតបំភ័យ

ក្នុងប៉ុន្មានខែមុនការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ មន្ត្រីគណបក្សកាន់អំណាចបានបង្កើនការគំរាមកំហែងនៃអំពើហឹង្សា និងអស្ថិរភាពដែលធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសាធារណៈ។ នេះមានន័យថា សិទ្ធិចូលរួមដែលជាផ្នែកមួយនៃលទ្ធិប្រជាធិបតេយ្យដ៏រឹងមាំត្រូវបានរារាំងយ៉ាងខ្លាំង។ ក្នុងពេលជាមួយគ្នានេះដែរ ការរក្សាសន្តិសុខសណ្តាប់ធ្នាប់ត្រូវបានគេបង្កើនការរឹតបន្តឹងក្រោមហេតុផលនយោបាយ និងសម្រាប់គណបក្សនយោបាយ។ ការអនុវត្តន៍សិទ្ធិនៃការប្រមូលផ្តុំដោយសន្តិវិធីនៅទីសាធារណៈ ដែលជាប់ពាក់ព័ន្ធក្នុងរឿងនយោបាយ ត្រូវបានហាមឃាត់ក្រោមលេសថា ជាការការពារកុំឲ្យមានការ

[46] Sokchea, Meas "CNRP vexed as CPP continues to call Sokha's presidency invalid" Phnom Penh Post, 30 March 2017.
[47] Sokchea, Meas "CPP warns against use of slogans" Phnom Penh Post, 19 May 2017.
[48] Sokchea, Meas and Shaun Turton "CNRP slogan scandal 'follows pattern'" Phnom Penh Post, 4 April 2017.

គំរាមកំហែងអស្ថេរភាពសន្តិសុខជាតិ និងការពារកុំឲ្យកើតមានការកើតបដិវត្តន៍ពណ៌។ ពិនិត្យឲ្យស៊ីជម្រៅជាងនេះទៀតនោះ ការបញ្ចេញមតិយោបល់រិះគន់ ឬសម្តែងមតិមិនពេញចិត្តណាមួយជាសាធារណៈ បើទោះជាទង្វើទាំងអស់នោះដោយអហឹង្សាក៏ដោយ ត្រូវបានគេកំណត់ថា ជាការខុសច្បាប់ និងត្រូវបានគេមើលឃើញថា ជាផ្នែកមួយនៃចារកម្ម ដើម្បីធ្វើឱ្យបាត់ផលប្រយោជន៍ជាតិ និងការបង្កើតសង្គ្រាមស៊ីវិល។ ជាលទ្ធផល ទីធ្លាសាធារណៈសម្រាប់ការបញ្ចេញមតិយោបល់ស្វែងរកការគាំទ្របែបប្រជាធិបតេយ្យមិនត្រូវបានប្រើប្រាស់ ហើយថែមទាំងបង្កើតបរិយាកាសនៃការភ័យខ្លាច ដែលធ្វើឲ្យធ្លាក់ចុះយ៉ាងធ្ងន់ធ្ងរនូវគុណភាពនៃការចូលរួមដែលចាំបាច់របស់ប្រជាពលរដ្ឋក្នុងដំណើរការបោះឆ្នោត។ ការគំរាមកំហែង និងការបំភិតបំភ័យដែលបានកើតមានជាញឹកញាប់នោះបានធ្វើឲ្យធ្លាក់ចុះនូវជំនឿ និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងរឿងនយោបាយ។ លើសពីនេះទៅទៀត ភាពចលាចលនៃការកើនឡើងនូវការប្រើប្រាស់កងកម្លាំង បានធ្វើឱ្យមានការលំបាកយ៉ាងខ្លាំងចំពោះការរំពឹងទុកនៃការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យ។ មន្ត្រីរដ្ឋាភិបាលមកពីគណបក្សប្រជាជនកម្ពុជា ដែលទទួលបន្ទុកផ្នែកសន្តិសុខ ដែលតែងតែធ្លាប់អះអាង និងមានមោទនភាពចំពោះភាពជោគជ័យនៃការផ្តល់សន្តិភាពដល់ប្រជាពលរដ្ឋ ហាក់ដូចជាកំពុងនិយាយថា សន្តិភាពកំពុងមិនត្រូវបានធានា និងមិនមានស្ថេរភាព។ ការគំរាមកំហែងជាញឹកញាប់នៃអំពើហឹង្សា និងសង្គ្រាមស៊ីវិល ដែលនឹងអាចកើតមាន ប្រសិនបើគណបក្សកាន់អំណាចចាញ់ឆ្នោតនោះ ត្រូវបានបន្តកើតមានជាមួយការចោទប្រកាន់ថា របបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស និងការអនុវត្តន៍សិទ្ធិតាមបែបប្រជាធិបតេយ្យ គឺជាការគំរាមកំហែងដល់សន្តិសុខជាតិ។

សប្តាហ៍ទីមួយក្នុងខែមករា ឆ្នាំ២០១៧ ស្របពេលដែលសារព័ត៌មានផ្លូវការរបស់រដ្ឋាភិបាល បានប្រកាសថា គណបក្សប្រជាជនកម្ពុជានឹងបន្ត "វប្បធម៌សន្ទនា" សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសង្កត់ធ្ងន់ថា គណបក្សកាន់អំណាចនឹងមិនអត់ឱន ចំពោះអ្នកដែលមានសកម្មភាពធ្វើឲ្យបែកបាក់ជាតិកម្ពុជានោះទេ។ សម្តេចនាយករដ្ឋមន្ត្រីមានការផ្សារភ្ជាប់លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សថា ជាលេសដើម្បីឲ្យមានការធ្វើអន្តរាគមន៍ពីក្រៅប្រទេស និងបដិវត្តន៍ពណ៌ បើទោះបីជាស្របពេលសម្តេចនាយករដ្ឋមន្ត្រីបានបញ្ជាក់ពីការប្តេជ្ញាចិត្តចំពោះការប្រកាន់ខ្ជាប់នូវរបបលទ្ធិប្រជាធិបតេយ្យ និងគោលការណ៍សិទ្ធិមនុស្សទាំងនោះក៏ដោយ។[49] ការយកចិត្តទុកដាក់ ការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស តិចជាងការយកចិត្តទុកដាក់ពីការជ្រៀតជ្រែកពីក្រៅប្រទេសនឹងបន្តភាពតានតឹងដល់ការបោះឆ្នោតឆ្នាំ២០១៧។ កាលពីដើមខែមករា រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសថា ខ្លួនមានរថយន្តបង្ក្រាបបាតុកម្មចំនួន០៣គ្រឿង ដែលបំពាក់ដោយកាំភ្លើងបាញ់ឧស្ម័នបង្ហូរទឹកភ្នែក។ បើយោងតាមអ្នកវិភាគលើការពារជាតិ រថយន្តនេះក៏មានកាំភ្លើងយន្ត។ អ្នកនាំពាក្យរបស់នគរបាលជាតិបានបញ្ជាក់ថា រថយន្តបង្ក្រាបបាតុកកម្ម ត្រូវបានប្រើប្រាស់សម្រាប់គោលបំណងសន្តិសុខសាធារណៈ ហើយមន្ត្រីសន្តិសុខជាតិរូបនេះបានបញ្ជាក់ប្រាប់ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកថា យាននេះនឹងត្រូវបានប្រើប្រាស់ "បង្ក្រាបបាតុករ"។[50]

[49] Nika, C. "CPP opposes actions dividing Cambodia" Agence Kampuchea Presse, 7 January 2017.
[50] Dara, Mech and Shaun Turton "Military police machines" Phnom Penh Post, 12 January 2017.

ចុងខែមករា រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសការតែងតាំងដ៏ធំមួយដល់មន្ត្រីកងយោធពលខេមរភូមិន្ទដោយផ្តល់ឋានន្តរស័ក្តិជាឧត្តមសេនីយ៍ ដល់មន្ត្រីកងយោធពលខេមរភូមិន្ទ ចំនួន៧០០នាក់ ដែលបានចូលរួមជាកម្លាំងទ័ពតាំងពីមុនថ្ងៃ០៧ ខែមករា ឆ្នាំ១៩៧៩ ដែលរាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកជាថ្ងៃរំដោះពីរបបខ្មែរក្រហម។ យោងតាមព័ត៌មានដែលបង្ហោះលើទំព័រហ្វេសប៊ុកផ្ទាល់ខ្លួន និងការផ្សព្វផ្សាយព័ត៌មានរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន «Fresh News» បានឱ្យដឹងថា ការតំឡើងឋានន្តរស័ក្តិនេះត្រូវបានផ្តល់ដោយលោក ហ៊ុន ម៉ាណែត។ ក្រុមអ្នកវិភាគឯករាជ្យបានកត់សម្គាល់ថា ការធ្វើបែបនេះគឺជាការបន្តនូវការអនុវត្តន៍យូរអង្វែងមកហើយដើម្បីធានាការគាំទ្រ និងស្មគ្រស្មោះចំពោះគណបក្សកាន់អំណាច ស្របពេលជាការពង្រឹងអំណាចក្នុងគណបក្ស ដើម្បីស្ថិតនៅក្នុងតំណែងជានាយករដ្ឋមន្ត្រីផង។[51] នៅដើមខែកុម្ភៈ មន្ត្រីនគរបាល ចំនួន ២៥៦នាក់ ត្រូវបានតំឡើងឋានន្តរស័ក្តិជាឧត្តមសេនីយ៍ (កងទ័ព ២៤៩នាក់ និងកងទ័ពជើងទឹក ៧នាក់) តាមប្រកាសរាជកិច្ចនៅខែធ្នូ២០១៦។ នៅពេលនោះដែរ មានសេចក្តីប្រកាសថា គោលនយោបាយតំឡើងឋានន្តរស័កដល់កងកម្លាំងមុនឆ្នាំ១៩៧៩ និងក៏ត្រូវបានយកមកអនុវត្តន៍ចំពោះកងម្លាំងដែលបានចូលរួមក្នុងកងទ័ពក្រោយឆ្នាំ១៩៧៩ផងដែរ។[52] ជាមួយនឹងការអនុវត្តន៍គោលនយោបាយនេះ អ្នកនាំពាក្យក្រសួងការពារជាតិ មិនអាចផ្តល់នូវចំនួនពិតប្រាកដ នៃកងកម្លាំងដែលមានឋានន្តរស័ក្តិឧត្តមសេនីយ៍បានឡើយ។

គោលនយោបាយនេះត្រូវបានអនុវត្តបន្ថែមទៀត ក្នុងអំឡុងពេលឆ្ពោះទៅរកការបោះឆ្នោតឃុំសង្កាត់អាណត្តិទី៤ ឆ្នាំ២០១៧។ នៅខែមីនា មានកងកម្លាំងចំនួន១៣២នាក់ ត្រូវបានដំឡើងឋានៈជាឧត្តមសេនីយ៍។ យោងតាមរបាយការណ៍នានារបស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ការតំឡើងឋានន្តរស័ក្តិឧត្តមសេនីយ៍ទាំងនោះត្រូវបានគេរកឃើញថា គឺជាបញ្ហា និងធ្វើឱ្យប៉ះពាល់ដល់វិជ្ជាជីវៈនៃកងកម្លាំងការពារជាតិ។ លើសពីនេះទៀត ការដំឡើងឋានៈម្តងហើយម្តងទៀត បានបង្កើតបញ្ហានៃមន្ត្រីជាច្រើនដែលខ្វះខាតនូវគុណវុឌ្ឍិសមស្របនឹងឋានៈដែលជាហេតុផលចំបងសម្រាប់គោលនយោបាយឆ្នាំ២០១១ របស់ក្រសួងការពារជាតិដែលបានផ្អាកការដំឡើងឋានន្តរស័ក្តិ។ ដោយមានការព្រួយបារម្ភយ៉ាងខ្លាំង គោលនយោបាយមិនបានឆ្លុះបញ្ចាំងពីប្រវត្តិនៃអំពើហឹង្សាប្រឆាំងនឹងក្រុមអ្នកតវ៉ាដោយសន្តិវិធី ដើម្បីបដិសេធការដំឡើងឋានន្តរស័ក្តិដល់បុគ្គលណាមួយ។[53] នៅដើមខែមេសា មន្ត្រីក្រសួងមហាផ្ទៃចំនួន១៣នាក់ ត្រូវបានប្រគល់ងារជា "សន្តិ

[51] Dara, Mech "Promotions pledged for '79 RCAF veterans" Phnom Penh Post, 26 January 2017.

[52] Dara, Mech "RCAF add more than 250 new generals" Phnom Penh Post, 3 February 2017. A significant concern for the quality of democratic pluralism in Cambodia in the post-UNTAC period has been partisanship of security services officials. The early February 2017 promotion of Hun Manith, a major general and the head of military intelligence, to the position of deputy-head of the CPP internal monitoring committee which is charged with party discipline (after having been appointed to the committee in December 2016), actualized a further concentration of power in the hands of the PM while reasserting the practices of nepotism and the links between the top position in the party and the top positions in the security services. See Dara, Mech and Leonie Kijewski "Manith given deputy role on CPP body" Phnom Penh Post, 13 February 2017.

[53] Dara, Mech "Seeing stars: Another 84 generals minted by RCAF" Phnom Penh Post 21 March 2017.

បណ្ឌិត" ដែលជាការទទួលស្គាល់នូវការចូលរួមចំណែករបស់មន្ត្រី១៣នាក់នោះ ចំពោះសន្តិសុខសាធារណៈ។[54]

ដូចគ្នាដែរកាលពីខែមេសា ការដំឡើងឋានន្តរស័ក្តិបានកើតឡើងម្តងទៀត ដោយមន្ត្រីកងទ័ពចំនួន ៤៣៤នាក់ និងមន្ត្រីកងទ័ពជើងទឹក៨នាក់ ត្រូវបានឡើងឋានៈជាឧត្តមសេនីយ៍ បន្ទាប់ពីមានព្រះរាជក្រឹត្យមួយចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧។ នៅពេលនេះអ្នកនាំពាក្យក្រសួងការពារជាតិនៅតែមិនអាចផ្តល់ព័ត៌មាននូវចំនួនឧត្តមសេនីយ៍ដល់ប្រព័ន្ធផ្សព្វផ្សាយ និងសាធារណជនបានឡើយ។ លើសពីនេះទៅទៀត អ្នកនាំពាក្យរូបនេះមិនអាចឆ្លើយសំណួរទាក់ទងនឹងពេលវេលាដើម្បីដំឡើងឋានៈលើកចុងក្រោយ និងចំនួនមន្ត្រីត្រូវបានដំឡើងឋានៈនោះទេ។[55] កង្វះខាតតម្លាភាព និងគណនេយ្យភាពក៏ជាផ្នែកមួយយ៉ាងធំធេងនៃការព្រួយបារម្ភពីភាពអសន្តិសុខដោយកង្វះការទុកចិត្តលើអព្យាក្រឹត្យ និងវិជ្ជាជីវៈនៃកងកម្លាំង។ លើសពីនេះទៀតសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធសំខាន់ៗ មានការព្រួយបារម្ភដែលពាក់ព័ន្ធ និងការអនុវត្តរបស់អាជ្ញាធរដើម្បីធានាបាននូវភាពស្មោះត្រង់ជាមួយនឹងគណបក្សកាន់អំណាច មុនការបោះឆ្នោត។[56]

លើសពីនេះទៀត នៅចុងខែមករា ការដំឡើងឋានៈត្រូវបានផ្តល់ឱ្យដោយមន្ត្រីជំនៃអង្គភាពអង្គរក្សរបស់នាយករដ្ឋមន្ត្រី ដែលមន្ត្រីនោះត្រូវបានរកឃើញថាមានកំហុសព្រហ្មទណ្ឌ និងបានជាប់ពន្ធនាគារពីបទហឹង្សា និងវាយប្រហារដ៏ឃោរឃៅលើលោក ញ៉យ ចំរើន និងលោក គង់ សភា ដែលជាតំណាងរាស្ត្រនៅ

[54] The title is linked to the police academy and it functions to replace the practice of bestowing honorary degrees. "The 13 recipients include Interior Ministry secretaries of state Gen. Em Sam An, Gen. Teng Savong, Gen. Ouk Kimlek and Gen. Dul Koeun, ministry under-secretaries of state Gen. Lour Ramin, Heng Hak and Chan Ean and National Police Chief Gen. Neth Savouen. Gen. Mao Bunnarin, the director-general of logistics and finance, Gen. Sok Phal, the director-general of immigration, Gen. Mao Chandara, the director-general of identification, Chan Kimseng, the director-general of prisons, and Khieu Sopheak, the chief of the Interior Minister's cabinet." Sokha, Cheng "Top police honored with new royal title" Khmer Times, 5 April 2017.

[55] Ouch, Sony "434 more soldiers promoted to brigadier general" Cambodia Daily, 25 April 2017.

[56] Based local media sources and information disseminated by the RGC, observers estimate approximately 988 officers promoted to the rank of general or higher in the 2016-2017 time period (prior to the June 4, 2017 election day). Despite MoD official's claims that all promotions were merit-based and that no nepotism existed, officers indicated to local journalists that the practice was based on nepotism and corruption, especially kickbacks in exchange for appointments. Regular troops interviewed by journalists held the same view. Moreover, MoD insiders indicated that the practice was a cause of embarrassment and problem for morale. A major negative impact of the policy is its potential to generate resentment among officials who are passed over for promotion, and among regular troops that have lost confidence in the capacity of their commanders and in the legitimacy of the procedures for distributing personnel appointments. The policy risks dividing the officer corps into a group that has advanced and enjoyed significant privileges related to their rank, and a larger group of officers that has not benefited long-term service through benefits of promotion or other informal privileges. The issue of inflated rank in contradiction to established international standards is regularly attested to at the MoD itself in the now common practice of reducing rank in order to engage with security sector counterparts or officials from other states. See: Dara, Mech and Shaun Turton "Fresh round of promotions add to RCAF's 'bloated' upper ranks" Phnom Penh Post, 29 July 2016; Dara, Mech and Shaun Turton 'Too many stars in the sky': For RCAF insiders, the proliferation of generals can be embarrassing" Phnom Penh Post, 1 March 2017; Dara, Mech "Seeing stars: Another 84 generals minted by RCAF" Phnom Penh Post, 21 March 2017.

ខាងក្រៅ និងក្បែររបងវិមានរដ្ឋសភា។[57] ក្រោយពីបានជាប់ពន្ធនាគាររយៈពេលមួយឆ្នាំ នៃការកាត់ទោសរយៈពេល៨ឆ្នាំចំពោះការរំលោភនេះ អង្គរក្សមួយរូបត្រូវបានដំឡើងឋានៈជាឧត្តមសេនីយ៍ និងពីររូបផ្សេងទៀត ត្រូវបានដំឡើងឋានៈជាវរៈសេនីយ៍ឯក។ គ្មាននរណាម្នាក់ ឬមន្ត្រីរដ្ឋាភិបាលណាមួយត្រូវបានស៊ើបអង្កេត ឬទទួលខុសត្រូវចំពោះការបញ្ជាពីក្រោយខ្នងឲ្យមានអំពើហឹង្សានោះទេ។[58] ការចាប់ខ្លួន និងការផ្តន្ទាទោសជនល្មើសបានកើតឡើង តែនៅពេលដែលសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានអំពាវនាវឱ្យជនប្រព្រឹត្តអំពើល្មើសទាំងនោះចេញមុខសារភាព បន្ទាប់ពីគណៈកម្មាធិការស៊ើបអង្កេត ពិសេសទាក់ទងនឹងរឿងនេះ បានប្រកាសថា ខ្លួនមិនស្វែងរក និងចាប់ខ្លួនជនសង្ស័យនោះទេ។ បន្ថែមពីការដកសិទ្ធិនយោបាយរបស់តំណាងរាស្ត្រ គណបក្សប្រឆាំង ដោយរងការចោទប្រកាន់ពាក់ព័ន្ធនឹងបទល្មើសបរិហារកេរ្តិ៍ ក្រសួងការពារជាតិ បានប្រកាន់ជំហរថា ការដំឡើងឋានៈឲ្យក្រុមបង្កហឹង្សាលើតំណាងរាស្ត្រ គឺស្របច្បាប់ ដោយសារតែពួកគេបានអនុវត្តទោសរបស់ពួកគេរួចហើយ។[59] អ្នកនាំពាក្យគណបក្សកាន់អំណាចបានថ្លែងថា "នៅពេលពួកគេបានអនុវត្តទោសជាប់ពន្ធនាគាររួចហើយ នោះវាដល់ពេលដើម្បីដំឡើងឋានៈពួកគេហើយ"។[60]

សាធារណជនបានដឹងយ៉ាងច្បាស់ថា រាជរដ្ឋាភិបាលមិនបានដាក់ទណ្ឌកម្មធ្ងន់ធ្ងរ ចំពោះទង្វើការប្រើហឹង្សាលើតំណាងរាស្ត្រនោះទេ ប៉ុន្តែបែរជាបានអត់ឱនចំពោះសកម្មភាពបែបនេះទៅវិញ។ ទីបំផុត មានការបាត់បង់ទំនុកចិត្តយ៉ាងខ្លាំងពីសាធារណជន អំពីផ្តល់សុខសន្តិភាព និងយុត្តិធម៌ ដោយសារវាបានបង្ហាញយ៉ាងច្បាស់ថា សកម្មភាពខុសច្បាប់ប្រព្រឹត្តលើគណបក្សប្រឆាំង ត្រូវបានគាំទ្រ និងផ្តល់ការលើកទឹកចិត្តពីសំណាក់រដ្ឋាភិបាល។ ប្រសិទ្ធភាពនៃនីតិរដ្ឋ និងការគោរពដំណើរការប្រជាធិបតេយ្យ ក្នុងការប្រកួតប្រជែងនយោបាយ ត្រូវបានរងផលប៉ះពាល់ នៅពេលដែលការវាយប្រហារ និងអំពើហឹង្សាត្រូវបានលើកទឹកចិត្ត។[61]

ដើម្បីឆ្លើយតបទៅនឹងកំហឹងរបស់សហគមន៍ជាតិ និងអន្តរជាតិ គណបក្សសង្គ្រោះជាតិបានប្រកាសថា ខ្លួននឹងហៅមន្ត្រីផ្នែកសន្តិសុខឱ្យឆ្លើយសំណួរនៅចំពោះមុខសភា ដើម្បីគណនាពីគុណសម្បត្តិនៃការផ្សព្វផ្សាយ។ មន្ត្រីបក្សប្រឆាំងបានប្រកាសថា រដ្ឋមន្ត្រីក្រសួងការពារជាតិ នឹងត្រូវបានហៅឱ្យឆ្លើយសំណួរនៅចំពោះសមាជិកសភា ឬទទួលការស្តីបន្ទោសនៅក្នុងទម្រង់នៃចលនាមួយនៅលើមូលដ្ឋានថា ការលើកកម្ពស់នេះអាចមានឥទ្ធិពលអវិជ្ជមានដល់ជាតិ និងសន្តិសុខជាតិ។[62] បន្ទាប់មក តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិបានប្រកាសផែនការ ដើម្បីកោះហៅរដ្ឋមន្ត្រីក្រសួងការពារប្រទេសពិភាក្សាអំពីការលើកកម្ពស់ និងកំណែ

[57] The attack occurred as approximately 1,000 ruling party supporters had gathered outside of parliament to protest in demand of the resignation of Kem Sokha as First Vice President of the National Assembly on the grounds that he had (allegedly) had an extramarital affair.
[58] Neou, Vannarin and Khemara Sok "Three Charged for Assaults on Lawmakers but no 'masterminds' arrested" VOA, 4 November 2017.
[59] Sothoeuth, Ith "Soldier implicated in lawmaker beating promoted" VOA, 30 January 2017.
[60] Narim, Khuom "Third elite's bodyguard promoted after attack on lawmaker" Cambodia Daily, 27 January 2017.
[61] Khorn, Savi, Moniroth Morm, and Tha Vuthy "Soldier who beat Cambodian lawmakers is now a general" RFA, 26 January 2017.
[62] Ibid

ទម្រង់យោធា រដ្ឋមន្ត្រីក្រសួងការងារពិភាក្សាអំពីកម្មករចំណាកស្រុក ជំនាញការងារ ព្រមទាំងសុវត្ថិភាព ការកោះហៅរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ។[63] ការចង្អុលបង្ហាញពីការខ្វះខាតនៃការត្រួតពិនិត្យរបស់សភា លើវិស័យសន្តិសុខ និងផ្នែកនីតិប្បញ្ញត្តិដែលមានតួនាទីជាអ្នកត្រួតពិនិត្យលើផ្នែកប្រតិបត្តិ លោកនាយករដ្ឋមន្ត្រីបានចាត់វិធានការដោយ ណែនាំដល់រដ្ឋមន្ត្រីទាំង៤រូប មិនឱ្យបង្ហាញខ្លួននៅមុខតំណាងរាស្ត្រដើម្បីសាកសួរនោះទេ។[64]

នៅដើមខែកុម្ភៈ ឯកសារត្រូវបានផ្សព្វផ្សាយជាសាធារណៈទាក់ទងនឹងក្រុមការងារអន្តរក្រសួង ដើម្បីដោះស្រាយការតវ៉ាទាំងអស់ ដែលបានកំណត់ថាជា "អនាធិបតេយ្យ" និង "បដិវត្តពណ៌"។ គោលនយោបាយដែលមានបញ្ហានេះ បានផ្សារភ្ជាប់ទៅនឹងការញុះញង់ និងការបះបោរបដិវត្ត កូដកម្មការងារទាំងអស់ ការតវ៉ាទាក់ទងនឹងដីធ្លី សកម្មភាពគណបក្សប្រឆាំងក្នុងការគាំទ្រដល់ការដោះលែងសកម្មជនដែលជាប់ឃុំឃាំង និងសកម្មភាពសង្គមស៊ីវិលដើម្បីគាំទ្រដល់ការដោះលែងសកម្មជនជាប់ពន្ធនាគារ ក៏ដូចជាការជួបជុំគ្នាដោយសន្តិវិធី។ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគណៈកម្មាធិការដោះស្រាយការធ្វើបាតុកម្ម និងគ្រប់គោលដៅទាំងអស់នៃបាតុកម្មត្រូវបានពង្រឹងបន្ទាប់ពីការបាញ់ប្រហារនៅផ្លូវវែងស្រែងឆ្នាំ២០១៤ ដែលបានធ្វើឱ្យបាតុករ ៥ នាក់ ស្លាប់ដោយរាប់បញ្ចូលទាំងតួលេខសំខាន់ៗ ពីយោធា និងនគរបាលជាតិ។ ការវិភាគដោយប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៃផែនការសកម្មភាពសម្រាប់ក្រុមការងារ បានរកឃើញក្រុមនេះ ត្រូវបានគេសង្កត់ធ្ងន់លើការលុបបំបាត់ "អ្នកញុះញង់អោយរើសអើង" ដែល «បោកប្រាសប្រជាពលរដ្ឋ ដើម្បីចូលរួមសកម្មភាពអនាធិបតេយ្យរបស់ពួកគេដោយខុសច្បាប់» និង «បំផ្លាញសន្តិភាព» ។[65]

នៅដើមខែកុម្ភៈនេះដែរ នៅឯកិច្ចប្រជុំប្រចាំឆ្នាំរបស់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ របាយការណ៍មួយ ត្រូវបានចេញផ្សាយដែលរួមចំណែកដល់វប្បធម៌នៃការគំរាមកំហែង ដែលប្រឆាំងនឹងរដ្ឋាភិបាល និងការបញ្ជាក់ពីភាពជោគជ័យរបស់រដ្ឋាភិបាល ក្នុងការរារាំង និងទប់ស្កាត់សកម្មភាពបដិវត្ត។ ការផ្សារភ្ជាប់សាមគ្គីភាពរបស់អង្គការសង្គមស៊ីវិល និងសកម្មភាពសិទ្ធិមនុស្សដល់ភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន របាយការណ៍នេះ បានគាំទ្រសកម្មភាពរឹតបន្តឹងមិនអោយមានការជួបជុំជាសាធារណៈ និងការជំទាស់ទៅលើហេតុផលដែលចងធ្វើបាតុកម្ម (ឬសូម្បីតែយុទ្ធនាការតាមអ៊ិនធឺរណែត) ក៏មិនអនុញ្ញាតឱ្យធ្វើដែរ ការហាមឃាត់នេះគឺដើម្បីឯកភាពជាតិដែលមិនចង់ឱ្យមានអសន្តិសុខ ភាពចលាចល ឬធ្វើអោយសង្គមវឹកវរ។[66] តាមរយៈការដាក់ស្លាកក្នុងការចូលរួម និងការចូលរួមបែបប្រជាធិបតេយ្យ គឺជាការគំរាមកំហែងដល់សង្គម ដូចជាគំរាមកំហែងដល់គោលនយោបាយ និងវោហាសាស្ត្រដែលត្រូវបានគេដឹងដើម្បីបង្កើនអារម្មណ៍អសន្តិសុខរបស់ប្រជាពលរដ្ឋ និងផ្តល់ឱ្យពួកគេនូវការលើកទឹកចិត្តច្បាស់លាស់ (តាមរយៈការភ័យខ្លាច ឬការគំរាមកំហែងនៃការសងសឹក) ដើម្បីបញ្ឈប់ការប្រើប្រាស់សិទ្ធិតាមបែបប្រជាធិបតេយ្យរបស់ពួកគេ ក្នុងការបញ្ចេញមតិ និង

[63] Mech, Dara "CNRP plans to call labor and agriculture ministers" Phnom Penh Post, 1 February 2017.
[64] Mech, Dara and Sokchea Meas "PM Hun Sen tells ministers to ignore CNRP requests to appear at assembly" Phnom Penh Post, 2 February 2017.
[65] Dara, Mech "'Color' coups on group's agenda" Phnom Penh Post, 7 February 2017
[66] Dara, Mech "Capital police tout hard work in halting protests" Phnom Penh Post, 9 February 2017.

ការចូលរួមមុនថ្ងៃបោះឆ្នោត។ ការចោទប្រកាន់ ការគំរាមកំហែងធ្វើឱ្យមានការបែកបាក់ទំនាក់ទំនងរវាងសេវាសន្តិសុខ និងសាធារណជន និងធ្វើឱ្យមានកើតសង្គ្រាមពេញផ្ទៃប្រទេស ដែលបង្ករឱ្យមានការប្រកួតប្រជែងខាងប្រជាធិបតេយ្យ ត្រូវបានគេចាត់ទុកថា ជាការគំរាមកំហែងដល់រដ្ឋ និងត្រូវដោះស្រាយដោយប្រើកងកំលាំងប្រដាប់អាវុធរួមគ្នា។

ក្នុងការឆ្លើយតបទៅនឹងការតវ៉ាដីធ្លីនៅពាក់កណ្តាលខែកុម្ភៈ រដ្ឋាភិបាលបានគាំទ្រកងសន្តិសុខ[67] ដែលបានវាយប្រហារអ្នកតវ៉ាដីធ្លី ដែលបានប្រមូលផ្តុំដើម្បីដាក់ពាក្យបណ្តឹងទៅរដ្ឋាភិបាល អំពីស្ថានភាពរបស់ពួកគេ។ នេះជាការបង្ហាញអោយឃើញកាន់តែច្បាស់ចំពោះការគាំទ្រអំពីនិទណ្ឌភាពរបស់មន្ត្រីផ្នែកកងសន្តិសុខ នៅពេលដែលអ្នកទាំងនោះបានប្រើអំពើហឹង្សាប្រឆាំងនឹងសាធារណៈជន ចំណែកឯប៉ូលីសបានបដិសេធថាការវាយដំមិនបានកើតឡើងទេ បើទោះបីមានសាក្សី និងអ្នកសង្កេតការណ៍ជាច្រើនបានចូលរួមក្នុងព្រឹត្តិការណ៍នោះក៏ដោយ។ ការបង្ហាញពីកង្វះឯករាជ្យភាពប្រព័ន្ធតុលាការ និងភាពខ្វះខាតនៃនីតិរដ្ឋ នៅដើមខែកុម្ភៈ សាលាដំបូងរាជធានីភ្នំពេញ បានចោទប្រកាន់សកម្មជនសិទ្ធិមនុស្សពីរនាក់ពីបទញុះញង់ បើទោះបីពួកគេជាជនរងគ្រោះនៃការប្រើហឹង្សាដោយសន្តិសុខខណ្ឌដូនពេញក៏ដោយ។ ទោះបីជាមានការផ្សព្វផ្សាយយ៉ាងទូលំទូលាយពីឯកសារ ដែលជាវីដេអូ ក្នុងការវាយប្រហារខុសច្បាប់ ព្រមទាំងមានសាក្សីជាច្រើននាក់ក៏ដោយ ក៏ជនល្មើសមិនបានផ្តន្ទាទោស ចំណែកឯជនរងគ្រោះបែរជាត្រូវបានហៅមកកាត់ទោសទៅវិញ។[68] ព្រឹត្តិការណ៍នេះបានរួមចំណែកដល់វប្បធម៌និទណ្ឌភាព និងឱនភាពយ៉ាងធ្ងន់ធ្ងរនៃការទុកចិត្តនិងទំនុកចិត្តរបស់សាធារណជន នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ នៅពាក់កណ្តាលខែកុម្ភៈ ក្នុងការឆ្លើយតបទៅនឹងបាតុកម្មរបស់កម្មករប្រហែល២០០នាក់ ដែលទាមទារប្រាក់សំណងដែលជំពាក់ពីរោងចក្រកាត់ដេរ Chun Fai ពេលនោះរដ្ឋមន្ត្រីក្រសួងការងារបានអំពាវនាវឱ្យមានការដាក់ទោសព្រហ្មទណ្ឌនៃសកម្មភាពខុសច្បាប់ដែលពាក់ពន្ធនឹងការតវ៉ាផ្សារភ្ជាប់នឹង «បដិវត្តពណ៌» ហើយលោកបានបញ្ជាក់ថា បាតុកម្មបែបនេះមិនអាចត្រូវបានអនុញ្ញាតឱ្យធ្វើឡើយ។[69]

នៅចុងខែកុម្ភៈ សុន្ទរកថានយោបាយដែលធ្វើឡើងដោយសម្តេចនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការពារជាតិ បានរួមចំណែកដល់បរិយាកាសអសន្តិសុខមុនការបោះឆ្នោត។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសពីបំណងរបស់លោកក្នុងការប្រើកម្លាំងយោធា ដើម្បីគ្រប់គ្រងគណបក្សប្រឆាំង និងស្ថានភាពបោះឆ្នោត។ ក្នុងការឆ្លើយតបទៅនឹងការបាត់បង់ការបោះឆ្នោតដែលមានសម្មតិកម្មជាមួយគណបក្សប្រឆាំង

[67] Daun Penh security guards have an important role in the history of impunity in the 5th mandate of the National Assembly, effectively serving as an unaccountable paramilitary force with an unclear chain of command to higher level security sector officials. The security services body has been the agent of repeated violence against protestors and initiated the violence in the 2014 Freedom Park protest that has resulted in the imprisonment of key opposition party figures.

[68] "Cambodia: Beaten human rights activists become suspects in assault case" Asian Correspondent, 8 February 2017.

[69] Kimsay, Buth "Labor Minister slams road block, warns of color revolution" Cambodia Daily, 16 February 2017.

ដែលកាន់កាប់រដ្ឋាភិបាល គាត់បានសួរថា "តើរឿងនេះអាចកើតឡើងយ៉ាងម៉េច ប្រសិនបើកងទ័ពស្ថិតនៅក្នុងដៃខ្ញុំ?"[70] រដ្ឋមន្ត្រីការពារជាតិ បានស្តីបន្ទោសជាសាធារណៈដល់អ្នកដែលអំពាវនាវឱ្យមានការផ្លាស់ប្តូរនយោបាយ ដែលដាក់ស្លាកពួកគេថាជាការគំរាមកំហែងដល់សន្តិភាព ចលនាសង្គមដែលមិនមានអំពើហិង្សា និងចលនានៃការប្រមូលផ្តុំរបស់អង្គការសង្គមស៊ីវិលជាមួយសកម្មភាពបដិវត្តន៍ពណ៌[71] លោកបានថ្លែងថា រដ្ឋាភិបាលនឹងមិនអនុញ្ញាតឱ្យមានចលនាណាមួយទេ។[72] ក្រោយមកទៀត អ្នកនាំពាក្យរបស់ទីស្តីការគណៈរដ្ឋមន្ត្រីបានកំណត់លក្ខណៈអំពីការអំពាវនាវឱ្យមានការផ្លាស់ប្តូរ ដែលការអំពាវនាវដូចនោះ គឺមិនស្របតាមរដ្ឋធម្មនុញ្ញឡើយ។[73] នៅដើមខែមីនា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានការពារដល់ការបង្ក្រាបលើសង្គមស៊ីវិល និងគណបក្សប្រឆាំង និងសមភាពសិទ្ធិប្រជាធិបតេយ្យជាមួយភាពអនាធិបតេយ្យ ទន្ទឹមនឹងការគំរាមកំហែងអង្គការក្រៅរដ្ឋាភិបាល ជាមួយនឹងការចាប់ខ្លួន។ នាយករដ្ឋមន្ត្រីក៏បានគំរាមដល់អ្នកវិភាគនយោបាយ និងអ្នកកាសែតផងដែរ ដោយចាប់ដាក់គុកដោយសារមិនគោរពវិជ្ជាជីវៈរបស់ខ្លួន និងវិភាគបំភ្លៃការពិត។ ជាក់ស្តែងគាត់បានលើកយកអង្គការ**ខុមហ្វ្រែល** ដោយសារតែនាយប្រតិបត្តិនៃអង្គការនេះ បានធ្វើសេចក្តីថ្លែងការណ៍ទាក់ទងទៅនឹងផលប៉ះពាល់នៃការលេចធ្លាយលើគុណភាពទឹកថ្នាំជ្រលក់ដៃ ដោយការបញ្ចេញមតិចំពោះនយោបាយ និងជំនឿទុកចិត្តជាសាធារណៈ។[74]

អស់រយៈពេលជាច្រើនខែ មុខការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១៧ មានការលេចធ្លាយការសន្ទនាជាឯកជនយ៉ាងច្រើននៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម។ ការប៉ះពាល់ ឬជ្រៀតជ្រែកលើសិទ្ធិឯកជនទាំងអស់នេះ បានបង្ករអោយមានការគាំរាមកំហែង ការបង្ក្រាបទៅលើការជួបជុំ និងការសម្តែងមតិជាដើម។ យោងតាមការស៊ើបអង្កេតដោយប្រព័ន្ធផ្សព្វផ្សាយឯករាជ្យបានអោយដឹងថា ការរំលោភបំពានទាំងនេះកើតឡើងតាមរយៈបច្ចេកទេសនៃការលួចគណនី (ទាំងប្រព័ន្ធផ្សព្វផ្សាយសង្គម និងអ៊ីម៉ែល) ដោយប្រើគណនីក្លែងក្លាយ ដើម្បីទាញយកសារអេឡិចត្រូនិច។ ជនរងគ្រោះមាន ១២នាក់ ឬច្រើនជាងនេះ ដូចជាសមាជិកសភាគណបក្សប្រឆាំង ពលរដ្ឋសកម្ម និងអ្នកសារព័ត៌មានឯករាជ្យផងដែរ។[75]

នៅដើមខែមេសា រដ្ឋាភិបាលកម្ពុជាបានចេញផ្សាយរបាយការណ៍ ស្តីពីអ្វីដែលខ្លួនចាត់ទុកថាជាយុទ្ធនាការមិនពិតដើម្បីបង្ខូច និងធ្វើឱ្យប៉ះពាល់ដល់រដ្ឋាភិបាលដែលដឹកនាំដោយមហាអំណាចបរទេស រួមជាមួយសង្គមស៊ីវិលនៅកម្ពុជា។ មួយផ្នែកនៃការឃោសនារបស់របស់គេ ដែលបានចោទប្រកាន់ រួមមានការ

[70] Morm, Moniroth "Hun Sen hints at military action if he loses election" RFA, 22 February 2017.
[71] For example he stated that the political compromise and reform following the 2013 elections was equivalent to events of 1970 and 1975 (a military coup and an armed overthrowing of a regime).
[72] Sokha, Touch and Leonie Kijewski "'Change' begets 'disaster'", Phnom Penh Post, 27 February 2017
[73] Note that Article 41 of the Constitution establishes the right of citizens to freedom of expression.
[74] Dara, Mech and Erin Handley "PM defends crackdown, offers warning to analyst" Phnom Penh Post, 7 March 2017.
[75] Pavoir, Ben "Surveillance State" Cambodia Daily, 7 April 2017. Leaks critical of the government or seeming to shed light on corruption or malpractice were also released with the apparent intention of discrediting the government. This seems to have, in the eyes of the security services, given credibility claims regarding the severity of 'threats' to ruling party order. The compound effect of anti-CNRP and anti-CPP leaks has weakened the potential for compromise and the cooperation needed to resuscitate democratic political society

រិះគន់ទៅលើការធ្វើវិសោធនកម្មច្បាប់គណបក្សនយោបាយ ច្បាប់ស្តីពីគ្រប់គ្រងសមាគម និងអង្គការក្រៅរដ្ឋាភិបាល ដែលគ្រប់គ្រងដល់អង្គការសង្គមស៊ីវិល។[76] ចំណែកឯក្រុមអ្នកវិភាគ និងអ្នកសង្កេតការណ៍ឯករាជ្យ បានចង្អុលបង្ហាញថា មិនមានភស្តុតាងដែលត្រូវបានផ្តល់ ដើម្បីគាំទ្រការអះអាងរបស់របាយការណ៍នោះទេ។ អ្វីដែលគួរអោយកត់សម្គាល់របាយការណ៍នេះ គឺបានបន្ថែមនូវការគំរាមគំហែងដល់រដ្ឋកម្ពុជា ហើយនិងការចូលរួមធ្វើនយោបាយតាមបែបប្រជាធិបតេយ្យ សកម្មភាពរបស់គណបក្សប្រឆាំង អង្គការក្រៅរដ្ឋាភិបាល និងអ្នកការសែតបរទេស សុទ្ធតែបានចូលសមគំនិតគ្នា ដែលអាចឈានដល់ការបញ្ចប់ដោយមិនអនុញ្ញាអោយមានបន្តទៀត។ ប្រការនេះបានធ្វើឱ្យមានភាពខុសគ្នានៃបរិបទនយោបាយ និងភាពតានតឹងកាន់តែខ្លាំងឡើង ព្រមទាំងបានធ្វើឱ្យមានប្រតិកម្មជាទូទៅ ចំពោះការប្រកួតប្រជែងប្រជាធិបតេយ្យ ឬការតវ៉ាដោយសន្តិវិធីលើគោលនយោបាយ និងភាពជាអ្នកដឹកនាំនយោបាយ។

នៅក្នុងខែឧសភា កងកំលាំងនគរបាលជាតិបានប្រារព្ធខួបរបស់ខ្លួន ហើយបានចេញនូវសេចក្តីថ្លែងការណ៍ដ៏សំខាន់មួយ។ ក្រសួងមហាផ្ទៃបានធ្វើការអះអាងថា មានភាពអនាធិបតេយ្យយ៉ាងច្រើនប្រភេទដែលធ្វើអោយមានការគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈ ដោយមានទាំងការគំរាមកំហែងធ្វើភេរវកម្ម និងធ្វើបដិវត្តិន៍ទៀតផង ដែលស្ថានភាពបែបនេះនឹងនាំមកនូវភាពអសន្តិសុខដែលកង្វល់ដ៏ធំ ដែលជាហេតុចាំបាច់ត្រូវតែប្រើនគរបាលដើម្បីបង្ក្រាបការគំរាមកំហែងទាំងនោះ។ បន្ថែមពីលើនេះទៀត ស្នងការនគរបាលជាតិបានថ្លែងថា មន្ត្រីរបស់លោករារាំងមិនអោយមានការធ្វើបាតុកម្ម កូដកម្ម និងបដិវត្តន៍ពណ៌ ដែលមានទាំងអស់ចំនួន ១០០០ករណី។[77]

នៅក្នុងសប្តាហ៍ទី១ នៃខែឧសភា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងជាសាធារណៈថា « សូមប្រុងប្រយ័ត្នចំពោះសន្តិភាពដែលកំពុងកើតមាននេះ វានឹងអាចបាត់បងទៅវិញ ប្រសិនអស់លោកចងដឹងថាហេតុអ្វីបានអត់មានសន្តិភាព អស់លោកគ្រាន់តែមើលទៅក្នុងទំព័រហ្វេសបុករបស់គណបក្សប្រឆាំង ពេលនេះអ្នកដឹងថា សង្គ្រាមនឹងចាប់ផ្តើមយ៉ាងម៉េចហើយ»។[78] សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសថា «ខ្ញុំនៅតែទទូចហើយទទូចទៀតថា សង្គ្រាមនឹងកើតមានឡើង ប្រសិនបើគណបក្សកាន់អំណាចមិនបានកាន់អំណាចទេនោះ»។[79] សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងដូចនេះផងដែរ នៅមុនថ្ងៃបោះឆ្នោត លោកថ្លែងថា «ដើម្បីធានាអោយមានសន្តិភាព ហើយបន្តនូវការអភិវឌ្ឍន៍ ជម្រើសមានតែមួយគត់ គឺដាច់ខាតគណបក្សប្រជាជនត្រូវតែឈ្នះឆ្នោតគ្រប់អាណត្តិទាំងអស់ ដើម្បីធានាជីវិតប្រជាជនរាប់សិបលាននាក់ ហើយ

[76] Keo, Sovannarith, Sokheng Saut and Samnang Rann “Cambodia slams West, NGOs for ‘disinformation’ undermining the ruling party” RFA, 4 April 2017.
[77] Mech, Dara “Cops commended for staving off ‘color revolution’” Phnom Penh Post, 16 May 2017.
[78] Morm, Moniroth “Cambodia’s Hun Sen warns of civil war ahead of elections” RFA, 9 May 2017.
[79] AFP “Cambodia PM threatens poll protestors with ‘war’” The Daily Mail, 10 May 2017.

យើងសុខចិត្តកំទេចមនុស្ស១០០ ទៅ២០០នាក់ ដោយសារតែយើងយល់ឃើញថាពួកនេះធ្វើអោយប្រទេសជួបភាពជួរជត់ដូចកាលពីអតីតកាល»។[80]

នៅក្នុងឧសភានេះដែរ គ្រាន់តែមុនយុទ្ធនាការនៃការបោះឆ្នោត រដ្ឋមន្ត្រីក្រសួងការពារជាតិ បានធ្វើការគំរាមកំហែងជាសាធារណៈថា លោកនឹងវាយបំបាក់ធ្មេញដល់ជនទាំងឡាយណាបានជាប់ពាក់ព័ន្ធនឹងការតវ៉ាក្រោយថ្ងៃបោះឆ្នោត។[81] ក្នុងការថ្លែងជាសាធារណៈរបស់គាត់ដូចនេះ គាត់ថ្លែងម្តងទៀតថា ជំហររបស់រាជរដ្ឋាភិបាល ដើម្បីឱ្យចលនាសង្គមសន្តិភាព និងគ្រប់គ្រងសង្គមស៊ីវិល ដែលធ្វើសកម្មភាពបដិវត្តន៍ និងអនាធិបតេយ្យ ត្រូវធ្វើយ៉ាងឱ្យបានជាក់លាក់ ដើម្បីបញ្ឈប់តាមគ្រប់មធ្យោបាយដែលចាំបាច់។ គាត់បានលើកឡើងថា គ្មានការអត់ធ្មត់ទៀតទេសម្រាប់ជនណាដែលអំពាវនាវអោយមានការផ្លាស់ប្តូរ ហើយការសុំអោយមានការផ្លាស់ប្តូរ និងការចុះចេញពីតំណែង គឺមិនអាចកើតឡើងទៀតទេ។[82] បណ្តាអ្នកវិភាគឯករាជ្យបានកត់សម្គាល់ឃើញថា សេចក្តីថ្លែងការណ៍ទាំងនេះ ដែលមានការប្រើប្រាស់យោធា ដើម្បីប្រឆាំងនឹងការតវ៉ា និងដាក់ពង្រាយសន្តិសុខ[83]ទូទាំងប្រទេសសម្រាប់ការបោះឆ្នោត បានបង្ហាញអោយឃើញថាគណបក្សកាន់អំណាចមិនចង់បានបញ្ហាដែលកើតចេញពីភាពចម្រូងចម្រាសពីការបោះឆ្នោត ដែលស្ថិតនៅក្នុងការគ្រប់គ្រងរបស់ខ្លួននោះទេ។[84] ក្នុងអំឡុងពេលយុទ្ធនាការឃោសនាការបោះឆ្នោត អគ្គស្នងការកងកំលាំងប្រដាប់អាវុធបានប្រាប់ដល់កងកំលាំងទាំងអស់របស់ខ្លួន អោយការពារប្រឆាំងទៅនឹងការគាំរាមកំហែងនៃការកើតឡើងចលនាបដិវត្តន៍ និងរក្សាសណ្តាប់ធ្នាប់ជូនរដ្ឋាភិបាលស្របច្បាប់។ ក្នុងពេលនោះដែរ ការបោះឆ្នោតត្រូវបានបង្ហាញអោយឃើញថា ជាការគំរាមកំហែងដល់ប្រទេសជាតិ "អ្នកត្រូវតែធ្វើការជាមួយស្ថាប័នដែលពាក់ព័ន្ធដើម្បីការពារសន្តិសុខ និង សណ្តាប់ធ្នាប់សារណៈក្នុងអំឡុងពេលបោះឆ្នោតជ្រើសក្រុមប្រឹកក្សាឃុំសង្កាត់.... យោធាទាំងអស់ ត្រូវតែការពាររាជរដ្ឋាភិបាលដែលស្របច្បាប់"។[85]

បើទោះបីនេះជាការគំរាមកំហែងយ៉ាងច្បាស់របស់រដ្ឋមន្ត្រីការពារជាតិ ដែលពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញទៅលើក្រុមអ្នកតវ៉ាក៏ដោយ រឺឯស្ថាប័ន គ.ជ.ប ថាខ្លួនពុំមានយុត្តាធិការលើបញ្ហាទាំងនោះទេ ព្រោះបញ្ហានោះមិនបានកើតឡើងក្នុងអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោត ឬក្នុងថ្ងៃបោះឆ្នោតនោះឡើ

[80] Cochrane, Liam "Cambodian PM Hun Sen says local election worth sacrificing 200 lives" ABC News, 4 June 2017.
[81] Muong, Narith "Cambodia's Defense Chief threatens to 'smash teeth' of political opposition" RFA, 15 May 2017.
[82] Pech, Sotheary "Tea Banh warns of crackdown on poll protesters" Khmer Times, 17 May 2017.
[83] There was also confusion and a problematic lack of transparency impacting democratic governance prior to the election in relation to the actual deployment of security services, beginning with the number of troops to be deployed. In 2016 the RGC announced that it would deploy 76,000 members of the security services for election security. (See Mech, Dara "Election Security Pushed" Phnom Penh Post, 20 April 2017) However, in April of 2017 the MoI announced that there would be slightly more than 30,000 deployed. (See Roeun, Van "RCAF Chief tells troops to fight against 'color revolution'" Cambodia Daily, 23 May 2017.)
[84] Sek, Odom and Ben Paviour "General Banh to 'smash teeth' of opponents" Cambodia Daily, 17 May 2017.
[85] Roeun, Van "RCAF Chief tells troops to fight against 'color revolution'" Cambodia Daily, 23 May 2017; Sophavy, So "RCAF Commander-in-Chief: No color revolution in Cambodia" Agence Kampuchea Presse, 23 May 2017.

យ។[86] ការគំរាមកំហែងដែលធ្វើឡើងដោយមន្ត្រីសំខាន់ៗ ដែលប្តេជ្ញាការពារនូវការផ្តួលរំលំរដ្ឋាភិបាល និងមិនមានសមត្ថភាពអន្តរាគមន៍ពីស្ថាប័នបោះឆ្នោតដើម្បីគ្រប់គ្រងអោយមានយុត្តិធម៌ បានធ្វើអោយសាធារណជនអស់ជំនឿលើយន្តការ និងលទ្ធផលនៃការបោះឆ្នោតខាងមុខ។ លើសពីនេះទៅទៀត ផលប៉ះពាល់លើប្រជាពលរដ្ឋ និងសង្គមស៊ីវិលត្រូវបានអង្កេតឃើញថា មានការប៉ះពាល់កាន់តែធំឡើង។ ក្នុងអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោត និងក្នុងថ្ងៃបោះឆ្នោត គ.ជ.ប បានចេញនូវក្រមសីលធម៌ សម្រាប់ធ្វើការហាមឃាត់ដល់កងកំលាំងយោធា មិនអោយធ្វើការគំរាមកំហែង និងបំភិតបំភ័យដល់ប្រជាពលរដ្ឋឡើយ។ កងកំលាំងយោធាដែលនៅក្នុងតំណែងត្រូវតែរក្សានូវភាពអព្យាក្រឹត្យ មិនប្រកាន់បក្សពួក រាល់ការរំលោភក្រមសីលធម៌នេះ នឹងត្រូវបានដាក់ទណ្ឌកម្មដោយការពិន័យជាប្រាក់។[87] គោលការណ៍នេះទទួលបានការគាំទ្រយ៉ាងពេញទំហឹងដោយអង្គការសង្គមស៊ីវិល និងភាគីដែលពាក់ព័ន្ធការបោះឆ្នោត។

ក្នុងអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោត គណបក្សកាន់អំណាចបានចេញបទបង្ហាញមួយដល់សមាជិកតំណាងរាស្ត្រក្នុងសភា ដែលបទបង្ហាញនេះនិយាយថា «បដិវត្តន៍ពណ៌ និងការវិនាសហិនហោចដោយសារសង្គ្រាម»។ បទបង្ហាញនេះបានចោទប្រកាន់សហរដ្ឋអាមេរិចដែលព្យាយាមផ្តួលរំលំរដ្ឋាភិបាលកម្ពុជា ដោយសារតែកម្ពុជាមិនបានដើរតាមគោលនយោបាយអាមេរិក។ បទបង្ហាញនេះបានវាយប្រហារវិទ្យាស្ថានជាតិប្រជាធិបតេយ្យ(NDI) អង្គការហ្វ្រីឌឹមហោសន៍(Freedom House) មូលនិធិសង្គម(Open Societies Foundation) មូលនិធិអិនឌីឌី(NED) និងទីភ្នាក់ងារយូអេសអាយឌី (USAID) ថាជាឧបករណ៍ចារកម្មសម្រាប់ស៊ើបការណ៍សម្ងាត់របស់អាមេរិក។ លើសពីនេះទៅទៀត បទបង្ហាញនេះបានសរសេរថាប្រព័ន្ធផ្សព្វផ្សាយដែលគ្រប់គ្រងដោយបរទេសមានភាពលំអៀងដែលមិនគួរឱ្យទុកចិត្ត ហើយតែងតែវាយប្រហារទៅលើរដ្ឋាភិបាលស្របច្បាប់។[88] នៅក្នុងបទបង្ហាញនេះ អ្នកនាំពាក្យរដ្ឋសភា ក៏បានអះអាងដែរថាសហរដ្ឋអាមេរិកកំពុងដឹកនាំយុទ្ធនាការសង្គមស៊ីវិលថ្ងៃច័ន្ទពណ៌ខ្មៅ[89] (យុទ្ធនាការក្រៅផ្លូវការមួយ ដោយផ្អែកលើប្រព័ន្ធផ្សព្វផ្សាយសង្គមភាគច្រើន បានភ្ជាប់ជាមួយសង្គមស៊ីវិល និងប្រជាពលរដ្ឋដើម្បីធ្វើការគាំទ្រឱ្យមានការដោះលែងអ្នកទោសនយោបាយ)។

លើសពីនេះទៀត បទបង្ហាញនេះបានធ្វើអោយមានការប្រកាន់ជាតិសាសន៍ និងបង្កើននូវភាពតានតឹងជាមួយបរទេស ជាពិសេសគឺប្រទេសដែលជួយស្តារលទ្ធិប្រជាធិតេយ្យ។ ដោយសារតែបទបង្ហាញនេះហើយទើបធ្វើអោយបរទេសបានព្រមានជាច្រើនដង។ ការព្រមានលើកទី១ បទបង្ហាញនេះបានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់អង្គការអន្តរជាតិក្រៅរដ្ឋាភិបាល ដែលបានរួមចំណែកដើម្បីកសាងសន្តិភាព ការអភិវឌ្ឍន៍ និង ស្តារប្រជាធិបតេយ្យឡើងវិញក្រោយពេលមានជម្លោះនៅកម្ពុជា។ ជាងនេះទៀត អង្គការអន្តរជាតិទាំងនោះបានប្រកាន់ភាពអព្យាក្រឹត្យចំពោះគណបក្សនយោបាយទាំងអស់ ដោយមានភ័ស្តុតាងពីការបញ្ជាក់ដែល

[86] Sokhean, Bean “NEC won’t probe smashing teeth threat” Cambodia Daily, 19 May 2017.
[87] Amaro, Yesenia “NEC issues code of conduct for army during elections” Phnom Penh Post, 24 May 2017.
[88] Turton, Shaun “CPP calls out foreign NGOs for stirring ‘color revolution’” Phnom Penh Post, 24 May 2017.
[89] Sovuthy, Khy “US linked to color revolt” Khmer Times, 24 May 2017.

អង្គការអន្តរជាតិទាំងនេះបានសហការជាមួយគណបក្សកាន់អំណាច។ ការព្រមានលើកទី២ បទបង្ហាញនេះវាមិនបានគិតអំពីចរិកលក្ខណៈនៃការលូតលាស់របស់អង្គការសង្គមស៊ីវិល(អង្គការជាតិគ្រប់កំរិត) ហើយនឹងពីតួនាទីរបស់អង្គការទាំងនោះដែលខំព្យាយាមតស៊ូមតិដើម្បីផលប្រយោជន៍ និងគុណតម្លៃរបស់ប្រជាជនខ្មែរ។ បទបទបង្ហាញនេះត្រូវបានអ្នកសង្កេតរបស់អង្គការសង្គមស៊ីវិលរកឃើញថា វាមានផលប៉ះពាល់ដល់ប្រជាធិបតេយ្យយ៉ាងពិតប្រាកដ បើទោះបីជាពួកគេបង្ហាញថា វាស្របនឹងរដ្ឋធម្មនុញ្ញកម្ពុជាក៏ដោយ។ ការព្រមានលើកទី៣ បទបង្ហាញនេះបានបង្ហាញពីការរើសអើងមិនទទួលយកការបញ្ចេញមតិ ដើម្បីសន្តិភាព ការអភិវឌ្ឍន៍ និង ប្រជាធិបតេយ្យឡើយ។ លើកទី៤ ដោយកកអង្គការក្រៅរដ្ឋាភិបាលធ្វើជាសត្រូវនឹងរដ្ឋ ហើយក៏ធ្វើការគំរាមកំហែងដល់អង្គការទាំងនោះ ដែលវាត្រូវបានអ្នកសង្កេតការណ៍ចាត់ទុកថា ជាការកើនឡើងនូវកម្រិតគំរាមកំហែង និងការបំភិតបំភ័យទាំងមូល។

ក្នុងអំឡុងពេលនៃយុទ្ធនាការឃោសនាបោះឆ្នោត ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សរបស់រដ្ឋាភិបាល បានព្រមានដល់ក្រុមអ្នកគាំទ្របក្សប្រឆាំងថា នឹងនាំអោយមានអស្ថេរភាព ហើយនាយកប្រតិបត្តិមជ្ឈមណ្ឌលកំចាត់មីននៅកម្ពុជា បានចោទប្រកាន់អ្នកគាំទ្រគណបក្សបក្សប្រឆាំងថា «ការគាំទ្រនេះ គឺជាការលើកតម្កើងមនោគមវិជ្ជាប្រល័យពូជសាសន៍ខ្មែរក្រហម»។[90] ការព្រមានដែលគួរអោយខ្លាចបំផុត គឺសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានព្រមានថា «នឹងមានសង្គ្រាម ប្រសិនលោកមិនអាចអត់ធ្មត់ជាមួយបក្សប្រឆាំងបាន»។ គាត់បានលើកឡើងថា «រាល់ពាក្យដែលពួកប្រឆាំងប្រើសុទ្ធតែនាំអោយកើតសង្គ្រាមទាំងអស់ បើទោះបីជាបក្សប្រឆាំងគ្មានទ័ពក៏ដោយ» ហើយគាត់ថែមទាំងគំរាមថា នឹងដុតកំទេចផ្ទះរបស់គេ។[91] ចំណែកឯស្ថាប័ន គ.ជ.ប នៅតែប្រកាន់ជំហរថា «បើគ្មានពាក្យបណ្តឹងជាផ្លូវការទេ ខ្លួនមិនអាចដឹងពីការគំរាមកំហែងដែលធ្វើឡើងដោយលោកនាយករដ្ឋមន្ត្រីបាននោះទេ»។ អ្នកនាំពាក្យ គ.ជ.ប. បានលើកឡើងថា "បើគ្មានពាក្យបណ្តឹងទេ គ.ជ.ប.នឹងមិនអាចចាត់វិធានការណាឡើយ តែរឿងដែលសំខាន់ គឺការសាមគ្គីភាពរបស់ប្រជាជនខ្មែរពេលនេះ ដែលត្រូវដោះស្រាយ»។[92]

៣.២.១ ការរឹតបន្តឹងបណ្តឹងទៅលើសិទ្ធិសេរីរបស់ប្រជាពលរដ្ឋ និង លទ្ធិប្រជាធិបតេយ្យ

ក្រោយពីមានការផ្សះផ្សារបស់គណបក្សធំៗ និងការលើកលែងទោស ប្រធានស្តីទីគណបក្សប្រឆាំង គឺលោក កឹម សុខា នៅដើមខែធ្នូ ឆ្នាំ២០១៦ មានមនុស្សជាច្រើនជឿជាក់ថា វាអាចឈានទៅដល់ការធានាអោយមានការដោះលែងអ្នកទោសនយោបាយ តាមរយៈការចរចាគ្នាថែមទៀត។[93] ពីរសប្តាហ៍បន្ទាប់ នៅ

[90] Paviour, Ben and Sokhean Ben "Opposition, ruling CPP warn of dire election consequences" Cambodia Daily, 24 May 2017.
[91] Naren, Kuch "Hun Sen goes on tirade against opponents" Cambodia Daily, 26 May 2017; Sokha Touch and Alex Willemyns "PM warns CPP not to test 'patience'" Phnom Penh Post, 26 May 2017.
[92] Tha, Vuthy, Sonorg Khe, and Maly Leng "PM Hun Sen repeats threat of war if his party loses elections" RFA 25 May 2017.
[93] As of August 31, 2017 the Cambodian human rights NGO Licadho listed (for the 2016-2017 time period) 19 political prisoners still incarcerated and 16 political prisoners released. See www.licadho-cambodia.org/political_prisoners/

ពេលដែលបើកការចរចានោះ មន្ត្រីបុគ្គលិកសិទ្ធិមនុស្សអាដហុក ៤រូប[94] និងអគ្គលេខាធិការរង គ.ជ.ប ១រូប មិនត្រូវបានដាក់ក្នុងរបៀវារៈធ្វើការចរចា ដើម្បីអោយដោះលែងនោះទេ ចំណែកឯសកម្មជនដីធ្លីក៏បានផ្តួចផ្តើមរៀបចំបាតុកម្មដោយសន្តិវិធី ដោយប្រារព្ធយកយុទ្ធនាការថ្ងៃចន្ទពណ៌ខ្មៅ ដើម្បីធ្វើបាតុកម្មដោយចាប់ផ្តើមធ្វើកាលពី ឆ្នាំ២០១៧។ បើទោះបីជាការធ្វើបាតុកម្មនេះ ធ្វើឡើងក្នុងគោលបំណងដើម្បីអោយមានការដោះលែងបុគ្គលិកអាដហុក និងអគ្គលេខាធិការរង គ.ជ.ប ដែលលក្ខណៈនៃការតវ៉ាដោយសន្តិវិធីក៏ដោយ តែបែរជាត្រូវបានរដ្ឋាភិបាលចាត់ទុកថា ជាការធ្វើបដិវត្តន៍ពណ៌ទៅវិញ។

ការតវ៉ាប្រឆាំងដោយអហឹង្សានៅថ្ងៃច័ន្ទពណ៌ខ្មៅ បានប្រារព្ធធ្វើឡើងជាទ្រង់ទ្រាយតូច[95] កាលពីថ្ងៃទី ៩ ខែមករា ឆ្នាំ២០១៧ ដោយសារតែការបន្តឃុំខ្លួនមន្ត្រីអាដហុក៤រូប អគ្គលេខាធិការរង គ.ជ.ប ១រូប និងអ្នកស្រី ទេព វណ្ណនី ដែលជាសកម្មជនសិទ្ធិដីធ្លី តំណាងឱ្យសហគមន៍បឹងកក់ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ៦ខែ កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ ដោយសារតែជាប់ទាក់ទងទៅនឹងការតវ៉ាដែលបានកើតឡើងក្នុងឆ្នាំ២០១១។[96] ជំហររបស់រដ្ឋាភិបាល ហាក់បីដូចជាបន្ថែមភាពច្របូកច្របល់ទៅលើភាពតានតឹងដែលភាពតានតឹងនេះដោយសារតែការបើកសវនាការជារឿងនយោបាយ ដែលអ្នកនាំពាក្យគណបក្សកាន់អំណាចបានថ្លែងថា «រាល់បញ្ហាអាចត្រូវបានដោះស្រាយតាមប្រព័ន្ធតុលាការ ហើយការព្រមព្រៀងនយោបាយអោយដោះលែងអ្នកទោសនៅតែអាចជាដំណោះស្រាយ»។ អ្នករៀបចំអោយមានការតវ៉ាបានប្រាប់ថា ពួកគេនឹងបន្តធ្វើការជួបជុំគ្នារហូតដល់អ្នកទោសទាំងនោះត្រូវបានដោះលែង។[97] ការអះអាងថាគ្មានទោស ដែលជាការព្រមព្រៀងនយោបាយ ដើម្បីធានាអោយមានការដោះលែងនោះ ត្រូវបានអ្នកទោសទាំងនោះបដិសេធដោយខ្លួនឯងទៅវិញ។[98]

នៅចុងខែកុម្ភៈ ឆ្នាំ២០១៧ គ្រាន់តែមុនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ ប៉ុន្មានខែសោះ អ្នកស្រី ទេព វណ្ណនី ត្រូវបានតុលាការកាត់ទោសអោយជាប់គុក ៣០ខែ ទោសលើកនេះដោយសារជាប់ទាក់ទងនឹងការតវ៉ាកាលពីឆ្នាំ២០១៣។[99] នៅក្នុងរឿងក្តីនេះ បើទោះបីជាមានអ្នកតវ៉ាប្រហែល ៦០នាក់ ដែលត្រូវបានប្រឈមជាមួយកងកំលាំងសន្តិសុខ (កងរាជអាវុធហត្ថ នគរបាល និងសន្តិសុខខណ្ឌជូនពេញ) ក៏ដោយតែអ្នកស្រី ទេព វណ្ណនី ត្រូវបានគេរកឃើញថា មានស្ថានទំងន់ទោសដោយសារ

[94] ADHOC 5 refers to four staff from the human Rights NGO ADHOC (Lim Mony, Nay Vanda, Ny Sokha, Yi Soksan), and Ny Chakrya, the deputy-secretary general of the NEC. ""The problems for the Adhoc 5 started in March last year, when recordings of an intimate conversation between Cambodia's opposition leader Kem Sokha and Khom Chandaraty, believed to be Sokha's hairdresser, were leaked. Chandaraty initially denied any involvement but later acknowledged she had an affair with the president of the Cambodian National Rescue Party, claiming Sokha had promised to pay her...Later, Chandaraty accused Adhoc officials of forcing her to lie about the affair. The authorities quickly arrested the Adhoc 5, accusing four of them of bribing the witness, and Chakrya as their accomplice." Hoekstra, Ate "Who are Cambodia's ADHOC 5 Activists?" DW, 28 April 2017.
[95] An estimated 20 protestors. See Lay, Samean "Back in Black" Phnom Penh Post, 10 January 2017.
[96] Rann, Samnang "Monday turns black again in Cambodia as protest restart" RFA, 9 January 2017.
[97] Sek, Odom "Black Monday starts again as Adhoc officers languish in jail" Cambodia Daily, 10 January 2017.
[98] Morm, Moniroth "Cambodia's political prisoners urge the opposition to stay strong" RFA, 11 January 2017.
[99] Sek, Odom "Activist Tep Vanny sentenced to more than two years in prison" Cambodia Daily, 23 February 2017. At that time the human rights NGO Licadho listed Tep Vanny as one of 25 political prisoners

ការបង្កហិង្សាដោយចេតនា។[100] ក្នុងអំឡុងពេលសវនាការ កងសន្តិសុខខណ្ឌដូនពេញ មិនត្រូវបានចោទប្រកាន់ថា បានប្រើហឹង្សានោះទេ បើទោះបីជាពួកគេបានវាយពួកអ្នកតវ៉ា និងបានច្រានបុរសម្នាក់ដួលក្បែរផ្សារដែលត្រូវបានថតបានជាវីឌីអូជាភស្តុតាងក៏ដោយ។[101] កាលពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៦ សកម្មជនដីធ្លីដែលតំណាងអោយអ្នកដែលគ្មានផ្ទះសំបែងរស់នៅសហគមន៍បឹងកក់ ត្រូវបានគេកាត់ទោសអោយជាប់គុក ៦ខែ ពីបទជេរប្រមាថ និងរារាំងការងារមន្ត្រីរាជការ។ បទល្មើសនេះបានកើតឡើងក្នុងការតវ៉ាក្នុងឆាំ២០១១ ហើយបណ្តឹងឧទ្ធរណ៍របស់នាងត្រូវបានសាលាឧទ្ធរណ៍បដិសេធកាលពីដើមខែមីនា។[102]

នៅក្នុងសេចក្តីសម្រេចនេះ ត្រូវបានអង្គការសង្គមស៊ីវិលជាតិ និងអ្នកអង្កេតអន្តរជាតិ ចាត់ទុកថាមិនមានយុត្តិធម៌ ហើយតុលាការកំពូលបានធ្វើការឃុំខ្លួនមុនបើកសវនការដោយមិនអោយមានការដាក់ប្រាក់ធានា ដើម្បីឱ្យអ្នកទាំងនោះនៅក្រៅឃុំនោះទេ សម្រាប់អ្នកទោសមន្ត្រីអាដហុក៤រូប និងអគ្គលេខាធិការរង គ.ជ.ប ១រូប។ គ្មានការពន្យល់ណាអោយច្បាស់នោះទេ ថាតើហេតុអ្វីបានជារឿងក្តីនេះមិនអោយអ្នកទោសទាំងនោះនៅក្រៅឃុំ ឬហេតុអ្វីបានជាបន្តឃុំខ្លួនរយៈពេល៦ខែ ដើម្បីស៊ើបអង្កេត និងប្រមូលភស្តុតាងជាការចាំបាច់។ សេចក្តីសម្រេចរបស់តុលាការគ្រាន់តែលើកហេតុផលថា ប្រសិនបើដោះលែងអ្នកទោសទាំងនោះនឹងធ្វើឱ្យប៉ះពាល់ដល់ស្ថេរភាពសង្គមជាតិ។[103] នៅឯសវនាការសុំនៅក្រៅឃុំដែលធ្វើនៅតុលាការកំពូលចំពោះអគ្គលេខាធិការរង គ.ជ.ប ឱ្យនៅក្រៅឃុំបណ្តោះអាសន្ន នៅពេលដែលមេធាវីការពារចុងចោទបានចង្អុលបង្ហាញទៅតុលាការក្នុងការបន្តឃុំខ្លួនសកម្មជនទាំងនោះហើយដែលជាហេតុផលឱ្យមានការតវ៉ាជាច្រើន ដែលប្រឆាំងដល់សមិទ្ធិផលរបស់រដ្ឋាភិបាល ក្នុងគោលបំណងហាមឃាត់ការធ្វើបាតុកម្ម ដែលអគ្គព្រះរាជអាជ្ញាចាត់ទុកថា ជាការប៉ុនប៉ងដើម្បីដាក់សម្ពាធលើតុលាការ។[104]

នៅដើមខែមេសា តុលាការកំពូលបានចេញសេចក្តីសម្រេចច្រានចោលទៅនឹងការធានាឱ្យនៅក្រៅឃុំរបស់ សមាជិក គ.ជ.ប ដែលបានជាប់ឃុំនោះ។ ហើយនៅពេលនោះ អគ្គលេខាធិការរង គ.ជ.ប ត្រូវបានជាប់ឃុំរយៈ ៣៤០ថ្ងៃ ដោយគ្មានការកាត់ក្តី ដោយចោទប្រកាន់ថា ជាអ្នកផ្សំគំនិតក្នុងការសូកប៉ាន់។[105] នៅ

[100] Baliga, Ananth and Samean Lay “Activist gets 30 months, while security guards beat man in City Hall” Phnom Penh Post, 24 February 2017

[101] Baliga, Ananth and Samean Lay “Activist Vanny gets 30 months, while security beat man in City Hall” Phnom Penh Post, 24 February 2017.

[102] See https://www.frontlinedefenders.org/en/case/tep-vanny-sentenced-6-months-prison. Also found guilty at that time, but granted bail, were Kong Chantha, Bo Chorvy and Heng Mom. See Hul Reaksmey “Appeals court upholds verdict against prominent campaigner” VOA, 7 March 2017. Notably, prior to the September 2016 conviction, Tep Vanny was convicted in August 2016 (also for “insulting a public official”) when she criticized the lack of investigation by the government into the killing of political analyst Kem Ley. At that time she was sentenced to only 6 days imprisonment and a 20 USD fine. See Pech, Sotheary “Activists: Release Tep Vanny” Khmer Times, 9 December 2016. Note that in that case, when arrested, she was actually charged with incitement to commit a felony. See San, Sel, Neang Leang and Thai Tha “Cambodian court charges Boeung Kak lake activists with ‘incitement’”, RFA, 17 August 2016.

[103] Lay, Samean “Adhoc detention ‘legal’”, Phnom Penh Post, 14 March 2017.

[104] Sek, Odom “Supreme Court scolds lawyer for mentioning ‘Black Monday’ Cambodia Daily, 24 March 2017.

[105] Sek, Odom “No bail for NEC’s Chakrya: Supreme Court” Cambodia Daily, 3 April 2017.

ចុងខែមេសា មុនយុទ្ធនាការឃោសនាបោះឆ្នោត សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចពន្យារថែម ៦ខែ ទៀត ដើម្បីឃុំខ្លួនមន្ត្រីទាំង៥រូបនោះ (មន្ត្រីសិទ្ធិមនុស្ស ៤រូប និងអគ្គលេខាធិការរង គ.ជ.ប ១រូប) ដោយលើកហេតុផលថា ការស៊ើបអង្កេតរឿងស៊ីសំណូក ក្នុងរយៈពេលមួយឆ្នាំនេះមិនទាន់ត្រូវបានបញ្ចប់នៅឡើយទេ ហើយត្រូវការពេលបន្ថែមទៀត ដើម្បីសាកសួរជនសង្ស័យ។[106] សេចក្តីសម្រេចកាត់ទោសដូចនេះ កាន់តែបង្ហាញអោយឃើញច្បាស់ថា វាជាការកាត់ទោសដែលមានចរិតលក្ខណៈនយោបាយ ដែលសាធារណជន និងសហគមន៍ជាតិ និងអន្តរជាតិ បានដាក់ការសង្ស័យតាំងពីដំបូងម្ល៉េះ ហើយបានធ្វើការសម្របសម្រួលតាមរយៈការប្តឹងឧទ្ធរណ៍ ដើម្បីអោយនៅក្រៅឃុំជាបណ្តោះអាសន្ន តែត្រូវបានសាលាឧទ្ធរណ៍បដិសេធបន្តទៀត។ ករណីនេះវាបានបង្ហាញអោយកាន់តែច្បាស់ថា តុលាការកំពុងតែបន្តធ្វើការសាកសួរជនសង្ស័យដែលបានឃុំខ្លួនអស់ រយៈពេលជាងមួយឆ្នាំមកនេះ តុលាការមិនត្រឹមតែតែរំលោភនីតិវិធីនៃការចោទប្រកាន់លើជនសង្ស័យនោះទេ តែវាថែមទាំងធ្វើអោយបាត់បង់ភាពយុត្តធម៌ ដោយមិនអាចធ្វើការស៊ើបអង្កេតទាន់ពេលវេលា និងមានប្រសិទ្ធភាព។107 រឿងក្តីនេះបានធ្វើអោយមានផលប៉ះពាល់យ៉ាងខ្លាំងទៅអង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋ នាំឱ្យមានភាពស្ងាក់ស្ងើរ និងមិនហ៊ានបញ្ចេញមតិទៅលើបញ្ហាសង្គម។108

បរិយាកាសមុនការបោះឆ្នោត ចំពោះអង្គការសង្គមស៊ីវិលក៏មានផលប៉ះពាល់ផងដែរទៅលើការវិភាគខាងនយោបាយ និងការអត្ថាធិប្បាយ។ ពាក្យសំដី និងការវិភាគដែលពាក់ព័ន្ធនឹងនយោបាយ ត្រូវតែហាមឃាត់យ៉ាងដាច់ខាត ដោយសារលោក គឹម សុខ ដែលជាអ្នកវិភាគឯករាជ្យម្នាក់ត្រូវបានចាប់ខ្លួន កាត់ទោសអោយជាប់គុក។ ពាក្យបណ្តឹងត្រូវបានប្តឹងដោយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រឆាំងនឹងលោក គឹម សុខ កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧ ពីបទញុះញង់ និងបង្កអោយមានភាពចលាចល។ លោក ហ៊ុន សែន បានប្តឹងក្រោយពីលោក គឹម សុខ ធ្វើការអត្ថាធិប្បាយតាមវិទ្យុថា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន មានជាប់ពាក់ព័ន្ធនឹងឃាតកម្មលើលោកបណ្ឌិត កែម ឡី ហើយថាសម្តេចនាយករដ្ឋមន្ត្រីជាអ្នកនៅពីក្រោយ។[109] លោកគឹម សុខ ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងបទបង្ខូចកេរ្តិ៍ឈ្មោះជាសាធារណៈ និងបង្កអោយមានភាពញុះញង់ ដែលមានចែងក្នុងមាត្រា ៣០៥ មាត្រា៤៩៥ និងមាត្រា៤៩៤ នៃក្រមព្រហ្មទណ្ឌ។ [110]

[106] Tittara, May "Six more months for Adhoc5" Khmer Times, 28 April 2017.
[107] Baliga, Ananth and Chheng Niem "NGOs' 'Adhoc 5' effect" Phnom Penh Post, 28 April 2017.
[108] Kouth, Sophak Chakrya "Boeung Kak lake dispute 'closed'" Phnom Penh Post, 28 April 2017; Kouth, Sophak Chakrya "Boeung Kak land talks failed" Phnom Penh Post, 6 March 2015.
[109] Two lawsuits were filed against Kim Sok, one for each of the radio interviews. The first lawsuit sought 500,000USD in damages alleging Kim Sok said the PM had organized the murder, and the second lawsuit sought 2,500USD in damages alleging said that a government network was behind the murder. Sek, Odom "Commentator Kim Sok jailed over defamation, incitement charges." Cambodia Daily, 17 February 2017.
[110] Chheng, Niem and Leonie Kijewski "Analyst Kim Sok arrested, jailed after showing up for questioning" Phnom Penh Post, 20 February 2017.

អ្នកនាំពាក្យតុលាការបានប្រាប់ប្រព័ន្ធផ្សព្វផ្សាយថា លោក គឹម សុខ ត្រូវបានចោទប្រកាន់ដោយសារតែការអត្ថាធិប្បាយរបស់គាត់ថា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលជាប្រធានគណបក្សប្រជាជនកម្ពុជាជាអ្នកនៅពីក្រោយការលួចធ្វើឃាតលោកបណ្ឌិត កែម ឡី ដែលជាអ្នកវិភាគនយោបាយ។[111] លោក គឹម សុខ ស្ម័គ្រចិត្តប្រគល់ខ្លួនអោយតុលាការ ដើម្បីធ្វើការសាកសួរ ហើយក៏មានហ្វូងប្រជាពលរដ្ឋដែលមកគាំទ្រលោកយ៉ាងច្រើនបានប្រមូលផ្តុំគ្នាផងដែរ តែការជួបជុំនេះត្រូវបានរារាំងមិនអោយធ្វើដំណើរទៅតុលាការឡើយ ហើយអាជ្ញាធរបានបង្ខំអោយព្រះសង្ឃជាច្រើនអង្គចាកចេញពីការជួបជុំនេះផងដែរ។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ បានកត់សំគាល់ឱ្យឃើញថា នេះជារឿងក្តីដែលខុសប្រក្រតី ដែលអោយមានការចាប់ខ្លួនមុខបើកសវនការ។[112] សាលាឧទ្ធរណ៍បានបដិសេធពីការសុំនៅក្រៅឃុំរបស់លោក គឹម សុខ។ យោងតាមលោកមេធាវីរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានអោយដឹងថា សេចក្តីសម្រេរបស់តុលាការ គឺឆ្លុះបញ្ចាំងអោយឃើញពីជំនឿថា ចុងចោទអាចប្រព្រឹត្តបទល្មើសច្រើនទៀត ព្រោះថាគាត់អាចបន្តអោយមានការញុះញង់ដែលជាទង្វើខុសច្បាប់។ ទោះជាយ៉ាងនេះក្តី លោក គឹម សុខនឹងត្រូវបានដោះលែងវិញ ប្រសិនបើគាត់ព្រមចុះហត្ថលេខាធ្វើការសុំទោសសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ជាសាធារណៈ តែគាត់មិនព្រម។ ក្នុងការឆ្លើយតបទៅនឹងទង្វើដូចនេះ លោក គឹម សុខ ត្រូវបានមេធាវីសម្តេចនាយករដ្ឋមន្ត្រីចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌថ្មីមួយទៀត។[113]

នៅក្នុងបរិបទនៃការប្រឈមនឹងរឿងក្តីព្រហ្មទណ្ឌរបស់អង្គការសង្គមស៊ីវិល ដោយរួមបញ្ចូលទាំងការជួបជុំរបស់អង្គការទាំងអស់ និងការបោះឆ្នោតប្រកបដោយត្រឹមត្រូវ យុត្តិធម៌ ក្នុងឆ្នាំ២០១៧ គឺជាការប្រឈមយ៉ាងខ្លាំង ដោយមិនខ្វល់ជាមួយនឹងការកើនឡើងនៃការចោទប្រកាន់ពីពិរុទ្ធភាព និងការធ្វើទុក្ខបុកម្នេញតាមផ្លូវច្បាប់ទៅលើប្រជាពលរដ្ឋនោះឡើយ ហេតុផលនេះដែលបានធ្វើអោយអង្គការជាតិ អន្តរជាតិ និងប្រជាពលរដ្ឋកាត់បន្ថយការជឿជាក់ថា នឹងមានការបោះឆ្នោតដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងអាចជឿទុកចិត្តលើរដ្ឋាភិបាលបាននោះ។

៣.២.២ ការបំភិតបំភ័យ និងកិច្ចអន្តរាគមន៍ដល់អ្នកសង្កេតការណ៍

ការបិទវគ្គបណ្តុះបណ្តាល

នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៧ លោក ម៉ែ ទិត្យ ជាគ្រូបង្ហាត់ម្នាក់មកពីអង្គការសម្ព័ន្ធសហគមន៍កសិករកម្ពុជា ហៅកាត់ថា «ស៊ីស៊ីអេហ្វស៊ី-CCFC» ត្រូវបានឃាត់ខ្លួនរយៈពេល៣ម៉ោង នៅអធិការដ្ឋាននគរបាលស្រុក បន្ទាប់ពីគាត់រៀបចំវគ្គបណ្តុះបណ្តាលអ្នកសង្កេតការណ៍ចំនួន៣២នាក់ ស្តីពី«ការសង្កេតដំណើរការបោះឆ្នោត» នៅផ្ទះរបស់អ្នកភូមិម្នាក់ដែលមានឈ្មោះ ឡុង សុផល នៅក្នុងស្រុករមាសហែក ខេត្ត

[111] Morm, Moniroth "Cambodian political analyst arrested for defaming the prime minister" RFA 2 February, 2017.
[112] Ibid
[113] Lay, Samean "Court swats down Kim Sok bail bid", 7 March 2017.

ស្វាយរៀង។ លោក ម៉ែ ទិត្យ ត្រូវបានប៉ូលីស ២នាក់អមដំណើរ បន្ទាប់មកត្រូវបានចោទប្រកាន់ដោយប្រធានអធិការដ្ឋាននគរបាលស្រុក អំពីបញ្ហាទាក់ទងនៃការបណ្តុះបណ្តាល និងការអនុវត្តន៍តាមច្បាប់ ដែលទាំងអស់នេះ គឺជាអំពើខុសច្បាប់ និងជាទង្វើនៃការបំភិតបំភ័យដ៏ធ្ងន់ធ្ងរចំពោះអ្នកសង្កេតការណ៍ និងបុគ្គលិកអង្គការសង្គមស៊ីវិល។

អាជ្ញាធរទាំងនោះនៅតែក្បាជំហររបស់ខ្លួន និងគំរាមបិទជាថ្មីនូវរាល់ចេតនាដែលចង់រៀបចំវគ្គបណ្តុះបណ្តាល។ ការគំរាមកំហែងបែបនេះ ត្រូវបានរាយការណ៍ដោយប្រព័ន្ធផ្សព្វផ្សាយ និងប្រព័ន្ធផ្សព្វផ្សាយសង្គម រហូតដល់ពួកគេធ្វើការផ្លាស់ប្តូរជំហររបស់ពួកគេ។ ក្រុមសមាជិកអន្តរាគមន៍ ត្រូវបានបញ្ជូនឱ្យស៊ើបអង្កេត ហើយពួកគេក៏បានជួបជាមួយមន្ត្រីទាំងនោះ ពន្យល់ពីភាពស្របច្បាប់ និងការអនុលោមតាមច្បាប់ រួមទាំងការជួបជាមួយមន្ត្រី លេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្ត(PEC) ដើម្បីឱ្យមានការអន្តរាគមន៍ និងធានាដល់អ្នកសង្កេតការណ៍ថា គ្មានការបំភិតបំភ័យបែបនេះ និងធ្វើឡើងប្រឆាំងនឹងអ្នកសង្កេតការណ៍។

វគ្គបណ្តុះបណ្តាត្រូវបានរៀបចំដោយជោគជ័យនៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៧ ជាមួយការសម្របសម្រួល និងជួយពីក្រុមអន្តរាគមន៍(WGI) រួមទាំងការជួយអន្តរាគមន៍ពីមន្ត្រីលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តផង។ ទោះយ៉ាងណា វត្តមានរបស់មន្ត្រីនគរបាលក្នុងបរិវេណនៃវគ្គបណ្តុះបណ្តាលនៅតែបន្តការគំរាមកំហែង និងការធ្វើទុក្ខបុកម្នេញដល់អ្នកសង្កេតការណ៍នៅថ្នាក់ក្រោមជាតិដដែល ហើយសកម្មភាពទាំងអស់នេះបានបង្ហាញពីការបង្អាក់ និងរាំងស្ទះដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធក្នុងការលើកទឹកចិត្តដល់ការចូលរួមយ៉ាងសកម្ម និងមានអត្ថន័យរបស់ប្រជាពលរដ្ឋរបស់ខ្លួន ទាក់ទងនឹងការចូលរួមក្នុងសិទ្ធិ និងសេរីភាពនយោបាយ។

ការឃាត់ខ្លួនអ្នកសង្កេតការណ៍

នៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៧ លេខាឧុមប្រ្យែលប្រចាំខេត្តកណ្តាល លោកស្រី ឡេង ចាន់ណាវី បានរាយការណ៍ពីការឃាត់ខ្លួនអ្នកសង្កេតការណ៍ ដោយអាជ្ញាធរមូលដ្ឋានចំនួន៣នាក់ មានអ្នកនាង ហុក ប៉ាន់ចាន់ណា អ្នកនាង គឹម លក្ខិណា និងអ្នកស្រី ភុំ ប៊ូរី នៅឯឃុំព្រែកដាច់ ខេត្តកណ្តាល។ អ្នកទាំង៣នាក់បានធ្វើការចែកសម្ភារៈសង្កេតការណ៍សម្រាប់ការបោះឆ្នោត មានដូចជាកាតអ្នកសង្កេតការណ៍ អាវយឺត និងទម្រង់សំណួរ តែពួកគេត្រូវបានឃាត់ និងចោមរោមដោយអាជ្ញាធរមានសមត្ថកិច្ច និងអ្នកគាំទ្រគណបក្សប្រជាជនប្រហែល២០នាក់ ដែលមានសមាសភាពដូចជា មេឃុំ មន្ត្រីប៉ូលិសឃុំ និងអ្នកផ្សេងទៀត។

អ្នកសង្កេតការណ៍ទាំងបីនាក់នេះត្រូវបានចោមរោម និងឃាត់ខ្លួនចាប់ពីម៉ោង១៩:៣០នាទី រហូតដល់ពាក់កណ្តាលយប់ហើយបង្ខំឱ្យលាលែងពីតួនាទីរបស់ពួកគេជាអ្នកសង្កេតការណ៍ ដោយការផ្តិតមេដៃលើសេចក្តីថ្លែងការណ៍ដែលបានសរសេរដោយមេឃុំ។ អ្នកសង្កេតការណ៍ទាំងនោះ ត្រូវបានគំរាមថា នឹងចាប់ខ្លួន និងបញ្ជូនទៅតុលាការដោយអះអាងថា សកម្មភាពរបស់ពួកគេ គឺខុសច្បាប់ និងក្នុងគោលបំណងគាំទ្រគណបក្សប្រឆាំង។ ពួកគេបានបញ្ជាក់ថា ការឃាត់ខ្លួន និងសកម្មភាពផ្លូវច្បាប់ប្រឆាំងនឹងពួកគេនឹងមិនត្រូវបានធ្វើឡើងទេ លុះត្រាតែពួកគេធ្វើការលាលែងពីតួនាទីជាអ្នកសង្កេតការណ៍បោះឆ្នោតរបស់ពួកគេ។

ក្រុមការងារអន្តរាគមន៍(WGI) បានធ្វើអន្តរាគមន៍ស៊ើបអង្កេត និងធ្វើការរក្សាទំនាក់ទំនងជាមួយអ្នកសង្កេតការណ៍ទាំងនោះដើម្បីឱ្យច្បាស់ និងធានាថា ពួកគេមានសុវត្ថិភាព ហើយវាជាកង្វល់ចម្បងរបស់យើងទាំងអស់គ្នា។ គួរឱ្យស្តាយ អ្នកសង្កេតការណ៍ទាំង៣រូបត្រូវបានដាក់សម្ពាធ ដោយការបំភិតបំភ័យ និងការយាយីដោយការប្រើផ្លូវច្បាប់ ក៏បានសំរេចចិត្តផ្តិតមេដៃ មុនពេលមកដល់របស់ក្រុមការងារអន្តរាគមន៍។ ក្រោយមក ក្រុមការងារអន្តរាគមន៍(WGI) បានបញ្ជូនពួកគាត់ទៅផ្ទះ ហើយបានព្យាយាមពន្យល់ក្រុមគ្រួសារ និងអ្នកភូមិរបស់ពួកគេពីសកម្មភាពដែលស្របផ្លូវច្បាប់កុំឱ្យមានការបំភិតបំភ័យ ប៉ុន្តែនៅតែពួកគេមានការប្រឈមជាមួយនឹងការបំភិតបំភ័យដដែល។ ជាលទ្ធផល អ្នកសង្កេតការណ៍ចំនួន៧នាក់ផ្សេងទៀត ដែលត្រូវបានជ្រើសរើសដោយអ្នកសង្កេតការណ៍៣រូបខាងលើ ក៏សម្រេចចិត្តធ្វើការលាលែងជាអ្នកសង្កេតការណ៍ផងដែរ ដោយពួកគេមានការភ័យខ្លាចពីការបំភិតបំភ័យ ដែលបានលើកឡើងដល់អ្នកសង្កេតការណ៍៣រូបខាងលើ។

នៅក្នុងបរិបទសកម្មភាពសង្គមស៊ីវិល រួមទាំងការប្រមូលផ្តុំ ការបណ្តុះបណ្តាល និងការជួបជុំនៃបណ្តាញផង ត្រូវបានរឹតត្បិត និងឃ្លាំមើល ធ្វើឱ្យបរិបទនៃលទ្ធិប្រជាធិបតេយ្យសម្រាប់ការបោះឆ្នោតឆ្នាំ ២០១៧ ត្រូវបានរារាំងយ៉ាងធ្ងន់ធ្ងរ។ ជាអកុសល ជាមួយការកើនឡើងនៃការត្រួតពិនិត្យ និងការធ្វើទុក្ខបុកម្នេញតាមផ្លូវច្បាប់ មានការកើនឡើងជាមួយនឹងការថយចុះនូវការរំពឹងទុក ជាពិសេស គឺមន្ទិលសង្ស័យរបស់ប្រជាពលរដ្ឋ ចំពោះការបោះឆ្នោតដោយសេរី យុត្តិធម៌ និងទំនុកចិត្តលើការឆ្លើយតបរបស់អាជ្ញាធរមានសមត្ថកិច្ច និងរាជរដ្ឋាភិបាល។

៤. ការយោសនាបោះឆ្នោត

ការយោសនាបោះឆ្នោតមានលក្ខណៈវិជ្ជមាន និងមានដំណើរយ៉ាងរលូន ដោយមិនមានហឹង្សា និងទំនាស់រវាងគណបក្ស រហូតរារាំងដល់សកម្មភាពយោសនាឡើយ ហើយមានការចូលរួមយ៉ាងសកម្មពីអ្នកគាំទ្រគណបក្សនយោបាយក្នុងដំណើរការយោសនាបោះឆ្នោត។ ប៉ុន្តែមានការរឹតត្បិតពីអាជ្ញាធរ ក្នុងការប្រើប្រាស់ទីធ្លាសាធារណៈ និងសេរីភាពបញ្ចេញមតិ។ ទូរទស្សន៍ឯកជនមិនអនុវត្តតាមគោលការណ៍សមភាព និងសេចក្តីណែនាំរបស់ គ.ជ.ប។ ជាមួយគ្នានេះ គណបក្សនយោបាយមិនមានរបាយការណ៍ ឬព័ត៌មានច្បាស់លាស់អំពីប្រភពចំណាយ និងខ្ទង់ចំណាយក្នុងការរៀបចំសកម្មភាពយោសនាបោះឆ្នោត។

បើពិនិត្យលើក្របខណ្ឌច្បាប់ទាក់ទងការយោសនាបោះឆ្នោតវិញ ត្រូវបានវាយតម្លៃថា មានភាពអវិជ្ជមានច្រើនជាងភាពវិជ្ជមាន។ បញ្ញត្តិថ្មីបានរឹតត្បឹតសេរីភាពក្នុងបញ្ចេញមតិរិះគន់ និងសកម្មភាពយោសនាបោះឆ្នោតរបស់គណបក្សនយោបាយ និងបញ្ញត្តិដែលលើកទឹកចិត្តការចូលរួមរបស់មន្ត្រីតុលាការ និងកងកំលាំងក្នុងការយោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ប៉ុន្តែបែរជាហាមឃាត់ និងដាក់ទោសចំពោះបណ្តុំប្រជាពលរដ្ឋដែលជាអង្គការ ឬសមាគមក្នុងសកម្មភាពដូចគ្នានេះ និងព្រមទាំងបញ្ញត្តិមិន

ច្បាស់លាស់មួយចំនួនទៀត។[114] ទន្ទឹមគ្នានេះ ច្បាប់ស្តីពីវិសោធកម្មច្បាប់ស្តីពីគណបក្សនយោបាយមានចំណុចអវិជ្ជមានជាងមុន។ វិសោធនកម្មច្បាប់នេះមានចេតនាដើម្បីផ្អាក បញ្ឈប់ ឬរំលាយគណបក្សនយោបាយ និងប្រធាន និងថ្នាក់ដឹកនាំគណបក្សនយោបាយ ហើយការអនុវត្តន៍នៃចេតនានេះ គឺជាឧបករណ៍នយោបាយដែលនឹងរារាំង ឬបំបិទការចូលរួមសកម្ម និងការប្រកួតប្រជែងរបស់គណបក្សនយោបាយក្នុងការបោះឆ្នោតឆ្នាំ២០១៧ និង២០១៨ខាងមុខ។

៤.១. រយៈពេលមុនការឃោសនាបោះឆ្នោត

នៅអំឡុងពេលមុនការឃោសនាបោះឆ្នោតជាផ្លូវការ ការសង្កេតឃើញថា បរិយាកាសនយោបាយ និងសន្តិសុខ គឺស្ថិតនៅស្ថានភាពគ្មានអំពើហឹង្សាធ្ងន់ធ្ងរ ដែលធ្វើឲ្យប៉ះពាល់ជាអវិជ្ជមានដល់ការចាត់ចែងការឃោសនាបោះឆ្នោត ប៉ុន្តែនៅបន្តមានការរឹតត្បិតសេរីភាពធ្វើសកម្មភាពឃោសនារបស់គណបក្សប្រកួតប្រជែង។ ជាមួយគ្នានេះ ក៏មានការប្រើប្រាស់សារនយោបាយរបស់មន្ត្រីរដ្ឋអំណាចជាន់ខ្ពស់មួយចំនួន ដែលនាំឲ្យមានការព្រួយបារម្ភ និងភ័យខ្លាចដល់ប្រជាពលរដ្ឋ និងគណបក្សនយោបាយ។

ប្រមុខដឹកនាំរដ្ឋាភិបាលបានថ្លែងជាសាធារណៈជាច្រើនលើកច្រើនសាថា ប្រសិនបើគណបក្សកាន់អំណាច (គណបក្សប្រជាជនកម្ពុជា) ចាញ់ឆ្នោត នោះនឹងមានសង្គ្រាម សម្តេចនឹងបិទទ្វារវាយឆ្កែ ប្រសិនបើមានការបះបោរណាមួយ ហើយកម្ពុជានឹងវិលទៅរកបបខ្មែរក្រហមវិញជាដើម។ ជាមួយគ្នានេះ សម្តេចបានថ្លែងថា តើបោះឆ្នោតដើម្បីសន្តិភាពបន្ត ឬបោះដើម្បីសង្គ្រាម? ជ្រើសរើសទៅរវាងសន្តិភាព និងសង្គ្រាម។ បោះឆ្នោតឲ្យគណបក្សប្រជាជន សន្តិភាព និងឱកាសអភិវឌ្ឍន៍នឹងមានបន្ត ប៉ុន្តែបើគណបក្សផ្សេងឈ្នះការបោះឆ្នោតនោះ មិនអាចធានាបាននូវសន្តិភាពនោះទេ។ មិនមែនតែប្រមុខដឹកនាំរដ្ឋាភិបាលទេ ដែលព្រមានថា នឹងមានសង្គ្រាម សូម្បីតែថ្នាក់ដឹកនាំប៉ូលិស និងទាហាន ក៏បានប្តេជ្ញាការពាររដ្ឋាភិបាល ព្រមទាំងបានព្រមានចាត់វិធានការលើអ្នកដែលមានបំណងចង់បះបោរ ឬអ្នកដែលមិនព្រមទទួលយកលទ្ធផលបោះឆ្នោត

[114] Some critical restrictions in the new Commune Election Law which led to heavily criticize such as; Articles 68 restricts political party's rallying, while the old law did not limit the number of political party's rally within the election campaign period, but the new commune election law restricted to only twice per election campaign. Article 70 mandates a reduced number of campaign days (from 15 to 14). The NEC implemented a ban on polling or surveys (including on social media) for the campaign, despite the fact that LEMNA stipulates a prohibition on such activities for only a week before Election Day. Article 73 entails provisions which support the participation of civil servants, military personnel and national police forces, and judicial officials to join campaign activities of a political party outside of working hours. However, this runs counter to the provisions of Article 72 which limit the participation of persons from those sectors in campaign support for a political party. Notably, according to Article 74, civil society organizations are prohibited from participating in some important activities during the election campaign because the provisions require NGOs and associations to be impartial and to remain non-participants. The regulations and procedures of the NEC also prohibit NGO or civil society association staff from personally participating in elections campaign or political party's rally while provisions of article 73 of the law give freedom to civil servants, military personnel, national police forces and judicial officials to join the activities.

ជាដើម។ ជុំវិញសារនយោបាយទាំងនេះ ត្រូវបានមើលឃើញថា ជាការគំរាមកំហែង និងប៉ះពាល់ដល់ការសម្រេចចិត្តរបស់អ្នកបោះឆ្នោត។

យោងលើបទពិសោធន៍ក្នុងការឃោសនាកន្លងមក សារនយោបាយចេញពីការឃោសនាមានឥទ្ធិពលទៅលើការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ (គណបក្សសង្គ្រោះជាតិ «ដូរ ឬមិនដូរ...ដូរ!» គណបក្សប្រជាជនកម្ពុជា «ស្រលាញ់ ជឿ និងអាណិត ហ៊ុន សែន បោះឲ្យគណបក្សប្រជាជនកម្ពុជា» ឬ «ហ៊ានថា ហ៊ានធ្វើ!») ប៉ុន្តែវាត្រូវបានហាមឃាត់ និងព្រមានចាត់វិធានទៅលើសារនយោបាយទាំងនេះ ក្នុងរយៈពេលឃោសនាបោះឆ្នោតជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤នេះ។ មានការហាមដោយមន្ត្រីនគរបាល និងយោធាជាន់ខ្ពស់ក្នុងការប្រើវោហាស័ព្ទ «ដូរ» និង «ដូរ ឬមិនដូរ» និងសារនយោបាយមួយចំនួនទៀតដូចជា «ដូរមេឃុំបម្រើបក្ស ដាក់មេឃុំបម្រើរាស្ត្រ» របស់គណបក្សប្រឆាំង (គណបក្សសង្គ្រោះជាតិ) ជាដើម។

ក្នុងរយៈពេលមុនការឃោសនាបោះឆ្នោតនេះដែរ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានឯកភាពជាគោលការណ៍តាមសំណើរបស់អាជ្ញាធរជធានីភ្នំពេញ ហាមក្បួនឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ឆ្លងកាត់មហាវិថីសំខាន់ៗមួយចំនួននៅក្នុងរាជធានីភ្នំពេញ។ ចំណែកឯទីតាំងសាធារណៈវិញ ក៏ត្រូវបានហាមក្នុងការជួបជុំផងដែរ។ ការសម្រេចនេះ ត្រូវបានមើលឃើញថា ជាការរឹតត្បិតសិទ្ធិសេរីភាពក្នុងការធ្វើសកម្មភាពឃោសនារបស់គណបក្សនយោបាយ។

៤.២. រយៈពេលឃោសនាបោះឆ្នោតផ្លូវការ

មិនខុសប្លែកពីការបោះឆ្នោតក្នុងឆ្នាំ២០១៣ ទេ គណបក្សដែលជាគូប្រជែងដ៏ស្រួចស្រាល់ គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ បានធ្វើការឃោសនាយ៉ាងសកម្ម ហើយមានលក្ខណៈទ្រង់ទ្រាយធំ(អ្នកចូលរួមខ្ពង់ម៉ឺននាក់)នៅមណ្ឌលបោះឆ្នោតធំៗ។ បន្ទាប់ពីគណបក្សនេះ ក៏ឃើញមានគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ បានធ្វើសកម្មភាពឃោសនានៅរាជធានីភ្នំពេញគួរឱ្យកត់សម្គាល់ផងដែរ។ ដោយគណបក្សនយោបាយផ្សេងទៀត ក៏បានធ្វើសកម្មភាពនៅតាមឃុំ សង្កាត់ដែលខ្លួនចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត។

ទាក់ទងនឹងការឃោសនានេះ វិទ្យុ និងទូរទស្សន៍របស់រដ្ឋ និងវិទ្យុឯកជនមួយចំនួនបានអនុវត្តគោលការណ៍សមភាពក្នុងការផ្តល់ម៉ោងផ្សាយដល់គណបក្ស និងផ្សាយព័ត៌មានអំពីគណបក្សនយោបាយ។ ប៉ុន្តែទូរទស្សន៍ឯកជនមិនអនុវត្តតាមគោលការណ៍សមភាព និងសេចក្តីណែនាំរបស់ គ.ជ.ប។ គេសង្កេតឃើញមិនស្មើភាពគ្នាចំពោះម៉ោងផ្សព្វផ្សាយ និងខ្លឹមសារព័ត៌មានទាក់ទងគណបក្សនយោបាយផ្សាយតាមរយៈទូរទស្សន៍ឯកជន។ ហើយគណបក្សនយោបាយមិនអាចប្រើប្រាស់ម៉ោងផ្សាយរបស់ទូរស្សន៍ឯកជនដើម្បីផ្សព្វផ្សាយកម្មវិធីរបស់គណបក្សខ្លួនបានឡើយ។

ចំពោះការប្រើប្រាស់ទីធ្លាសាធារណៈ និងឱកាសសម្រាប់គណបក្សនយោបាយធ្វើសកម្មភាពឃោសនាដូចជាការដង្ហែក្បួន ការលើក ឬបិទស្លាកសញ្ញាគណបក្ស ឬការប្រមូលផ្តុំត្រូវបានបន្តយ ដោយសារការសម្រេចរបស់អាជ្ញាធរ។ ការសម្របសម្រួលឱ្យប្រើប្រាស់ទីធ្លាសាធារណៈពឹងផ្អែកលើការសម្រេចចិត្តរបស់អាជ្ញាធរ ជាងការសម្រេចចិត្តរបស់មន្ត្រី គ.ជ.ប។ មានការបកស្លាកគណបក្សលើទីធ្លាសាធារណៈដែលច្បាប់បានអនុញ្ញាត។ ដោយឡែក ការប្រើប្រាស់ធនធានរបស់រដ្ឋ ដូចជាយានជំនិះ ឬអាគាររបស់រដ្ឋឃើញថាមានតិចតួច ដែលល្អប្រសើរជាងការបោះឆ្នោតកន្លងមក ប៉ុន្តែធនធានមនុស្សរបស់រដ្ឋនៅតែបន្តចូលរួមយ៉ាងសកម្មក្នុងសកម្មភាពឃោសនារបស់គណបក្សកាន់អំណាច។

នៅស្របពេលដែលមន្ត្រីនគរបាល និងយោធាជាន់ខ្ពស់ បានហាមឃាត់ការប្រើសារនយោបាយមួយចំនួន គ.ជ.ប ក៏បានហាមឃាត់ចំពោះការស្នងមតិ តាមរយៈហ្វេសប៊ុក ដែលច្បាប់បានហាមឃាតតែមុនបោះឆ្នោតមួយសប្តាហ៍តែប៉ុណ្ណោះ។ មានការប្តឹងអ្នកសារព័ត៌មាន ពាក់ព័ន្ធនឹងការផ្តល់ឱកាសឲ្យពលរដ្ឋអនុវត្តសិទ្ធិបញ្ចេញមតិរបស់ខ្លួន។ ឱកាស ឬលទ្ធភាពរបស់គណបក្សនយោបាយមិនស្មើគ្នាក្នុងការប្រើប្រាស់សិទ្ធិបញ្ចេញមតិដើម្បីផ្សព្វផ្សាយកម្មវិធីនយោបាយរបស់គណបក្ស។ វីដេអូរបស់គណបក្សសង្គ្រោះជាតិត្រូវបានហាមឃាត់ មិនឲ្យចាក់ផ្សាយតាមទូរទស្សន៍ជាតិ។ អាជ្ញាធររាជធានីភ្នំពេញហាមឃាត់គណបក្សនយោបាយមិនឱ្យធ្វើក្បួនឃោសនាតាមដងផ្លូវមួយចំនួន។ ទន្ទឹមគ្នានេះ ការសង្កេតឃើញថា គណបក្សនយោបាយមិនមានរបាយការណ៍ ឬព័ត៌មានច្បាស់លាស់អំពីប្រភពចំណាយ ខ្វង់ចំណាយ និងប្រភពនៃការចំណាយក្នុងការរៀចចំសកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សខ្លួន។

ការឃោសនាបោះឆ្នោតជាផ្លូវការ ចាប់ផ្តើមពីថ្ងៃទី២០ ខែឧសភា ដល់ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៧។ បើយោងតាមសេចក្តីរាយការណ៍របស់អ្នកសង្កេតការណ៍បានឱ្យដឹងថា ភាពមិនប្រក្រតីក្នុងអំឡុងពេលឃោសនាបោះឆ្នោតដែលកើតឡើងច្រើនជាងគេរួមមានដូចជា៖

- ករណីអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកំលាំងប្រដាប់អាវុធ មន្ត្រីតុលាការ និងមេភូមិចូលរួមយ៉ាងសកម្មក្នុងសកម្មភាពឃោសនារបស់គណបក្សនយោបាយមានប្រមាណ៧៦៦ករណី ដែលកើតមានឡើងគ្រប់រាជធានី ខេត្ត។
- សកម្មភាពបង្កទំនាស់ ដូចជាករណីជំលោះ ឬការរារាំង ឬ/និងការរំខានមានយ៉ាងតិច១៥៣ករណី ដែលកើតមានឡើងក្នុងខេត្តកំពង់ធំ ខេត្តកោះកុង ខេត្តសៀមរាប ខេត្តព្រៃវែង ខេត្តកំពង់ឆ្នាំង ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តកំពត ខេត្តតាកែវ ខេត្តឧត្តរមានជ័យ រាជធានីភ្នំពេញ និងខេត្តរតនៈគីរី។
- សកម្មភាពបង្កការភ័យខ្លាច ដូចជាការគំរាមកំហែង ឬការប្រើអំពើហឹង្សា ឬការបំពារបំពានមានយ៉ាងតិច៨៤ករណី ដែលកើតមានឡើងច្រើនក្នុងខេត្តឧត្តរមានជ័យ ខេត្តកំពង់ឆ្នាំង ខេត្តកោះកុង ខេត្តតាកែវ និងខេត្តកំពង់ស្ពឺ។

- ករណីជនស្លៀកពាក់ឯកសណ្ឋានជាកងកម្លាំងចូលរួមសកម្មភាពឃោសនាបោះឆ្នោតមានប្រមាណ២៩ករណី ដែលកើតមានឡើងច្រើនក្នុងខេត្តកណ្តាល ខេត្តកំពត ខេត្តព្រៃវែង ខេត្តសៀមរាប និងខេត្តឧត្តរមានជ័យ។
- ករណីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេភូមិ គំរាមកំហែង បំភិតបំភ័យ ឬមានឥរិយាបថលំអៀងក្នុងការអនុវត្តតួន៍នាទី ដែលមានឥទ្ធិពលដល់អ្នកបោះឆ្នោតក្នុងការធ្វើសេចក្តីសម្រេចចិត្តគាំទ្រ ឬប្រឆាំងគណបក្សនយោបាយ ឬបេក្ខជនណាមួយមានប្រមាណ២៨ករណី ដែលកើតមានឡើងច្រើនក្នុងខេត្តកោះកុង ខេត្តក្រចេះ ខេត្តកំពង់ឆ្នាំង ខេត្តបន្ទាយមានជ័យ និងខេត្តព្រៃវែង។
- ករណីមិនផ្តល់ការពារសន្តិសុខ និងសុវត្ថិភាពចំពោះបេក្ខជន ឬគណបក្សនយោបាយ ដែលបានស្នើសុំមានយ៉ាងតិច១៧ករណី ដែលកើតមានឡើងក្នុងខេត្តកោះកុង ខេត្តក្រចេះ រាជធានីភ្នំពេញ និងខេត្តឧត្តរមានជ័យ។
- ករណីហាមឃាត់នៅមុន ឬក្នុងអំឡុងពេលកិច្ចប្រជុំរបស់បេក្ខជន ឬគណបក្សនយោបាយមានយ៉ាងតិចមាន១៧ករណី ដែលកើតឡើងក្នុងខេត្តបាត់ដំបង ខេត្តក្រចេះ ខេត្តកំពង់ស្ពឺ និងខេត្តរតនគីរី។
- ករណីប្រើប្រាស់យានជំនិះរបស់រដ្ឋ ឬប្រើប្រាស់យានជំនិះដោះស្លាកលេខចេញជាមធ្យោបាយឃោសនាដឹកជញ្ជូនរបស់គណបក្សមានយ៉ាងតិច១៦ករណី ដែលកើតមានឡើងក្នុងខេត្តព្រៃវែង ខេត្តបាត់ដំបង និងខេត្តរតន:គីរី។
- ករណីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេភូមិ ឬជំនួយការមេភូមិផ្តិបទុកព័ត៌មានបោះឆ្នោត (ចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត) ឬរើសអើងក្នុងការផ្តល់សេវា (ការបញ្ជាក់ឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់ការបោះឆ្នោត) ដល់ប្រជាពលរដ្ឋ ឬអ្នកគាំទ្រ ឬបេក្ខជនគណបក្សនយោបាយមានប្រមាណ១៦ករណី ដែលកើតមានឡើងច្រើនក្នុងខេត្តកោះកុង ខេត្តព្រៃវែង ខេត្តឧត្តរមានជ័យ។
- ករណីហាមឃាត់ ឬរឹតបន្តឹងក្នុងការប្រើប្រាស់ទីសាធារណៈ(សួនច្បារ ទីផ្សារ និងដងផ្លូវ) ដល់បេក្ខជន ឬគណបក្សនយោបាយដែលបានស្នើសុំមានយ៉ាងតិច១២ករណី ដែលកើតមានឡើងច្រើនក្នុងរាជធានីភ្នំពេញ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តព្រៃវែង និងខេត្តឧត្តរមានជ័យ។

ទន្ទឹមគ្នានេះ អ្នកសង្កេតការណ៍ក៏បានរាយការណ៍អំពីសកម្មភាពផ្តល់អំណោយ ឬជូនសគុណ ឬផ្តល់សម្ភារៈ ឬការផ្តល់រង្វាន់លើកទឹកចិត្ត និងការរៀបចំពិធីជប់លៀង ឬការផ្តល់សេវានានាដោយមិនគិតថ្លៃជូនអ្នកបោះឆ្នោតមាន១២៥ករណី ដែលករណីនេះមានការពិបាកក្នុងការបកស្រាយថា ជាការទិញសន្លឹកឆ្នោតឬយ៉ាងណា។ ការសង្កេតឃើញថា សកម្មភាពទាំងនេះមានកើតឡើងជាប្រព័ន្ធនៅមុនការឃោសនាបោះឆ្នោតដែលធ្វើឡើងទាំងគណបក្សកាន់អំណាច និងគណបក្សមិនកាន់អំណាច។ ករណីទាំងនេះកើតមានឡើងច្រើន

ក្នុងខេត្តបាត់ដំបង ខេត្តកោះកុង ខេត្តព្រៃវែង ខេត្តសៀមរាប ខេត្តកំពង់ឆ្នាំង ខេត្តប៉ៃលិន រាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ស្ពឺ ខេត្តរតនគីរី។

៤.៣ ការចំណាយហិរញ្ញវត្ថុសម្រាប់យោសនាបោះឆ្នោត

គណបក្សនយោបាយមានឱកាសយោសនាបោះឆ្នោតស្មើគ្នា ដែលមានចែងក្នុងច្បាប់ និងបទបញ្ជានីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ក៏ដោយ លទ្ធភាពនៃការប្រើប្រាស់ឱកាសទាំងនោះរបស់គណបក្សនយោបាយ គឺមិនស្មើគ្នានោះទេ នេះដោយសារតែគ្មានបទប្បញ្ញតិណានៃច្បាប់ចែងអំពីការកំណត់ខ្ទង់ចំណាយ និងប្រភពនៃខ្ទង់ចំណាយនៃសកម្មភាពយោសនាបោះឆ្នោតរបស់គណបក្សនយោបាយ។

សកម្មភាពយោសនាបោះឆ្នោតនៅចំនួន០៩ឃុំ/សង្កាត់ នៃ០៣រាជធានីខេត្ត (ធំ មធ្យម និងតូច ផ្នែកលើអាសនៈ ប្រជាសាស្ត្រ និងជីវភាពប្រជាពលរដ្ឋ)ត្រូវបានសង្កេត និងសិក្សាពីខ្ទង់ចំណាយរបស់គណបក្សចំនួន ០៤ រួមមាន គណបក្សប្រជាជនកម្ពុជា គណបក្សសង្គ្រោះជាតិ គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ដែលបានឈរឈ្មោះច្រើនជាងគេក្នុងចំណោមគណបក្សនយោបាយប្រកួតប្រជែងផ្សេងទៀត។ ខ្ទង់ចំណាយលើសកម្មភាពយោសនាបោះឆ្នោតជាមធ្យមនៃ០៩ឃុំ/សង្កាត់ ត្រូវបានចាត់ទុកថាខ្ទង់ចំណាយសម្រាប់មួយឃុំ/សង្កាត់នៃគណបក្សនយោបាយនីមួយ។ ហើយខ្ទង់ចំណាយសម្រាប់ការបោះឆ្នោតទាំងមូលសំដៅលើខ្ទង់ចំណាយសម្រាប់មួយឃុំ គុណនឹងចំនួនឃុំ/សង្កាត់ដែលគណបក្សនយោបាយបានឈរឈ្មោះប្រកួតប្រជែង។

គណបក្សនយោបាយនីមួយៗ បានរៀបចំសកម្មភាពយោសនារបស់ខ្លួន តាមធនធានហិរញ្ញវត្ថុដែលខ្លួនមាន។ គណៈបក្សប្រជាជនកម្ពុជាបានប្រើប្រាស់ហិរញ្ញវត្ថុរបស់យ៉ាងច្រើនលើសលុប ក្នុងការយោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៤នេះ បើប្រៀបធៀបជាមួយគណបក្សដៃគូប្រកួតប្រជែងរបស់ខ្លួនគឺគណបក្សសង្គ្រោះជាតិ។ ហើយថវិកាចំណាយរបស់គណបក្សប្រជាជនកម្ពុជាភាគច្រើន ទទួលបានពីគណបក្សថ្នាក់ឃុំ/សង្កាត់ខ្លួនឯង និងពីគណបក្សខេត្ត/រាជធានី ផ្ទុយមកវិញ ថវិកាចំណាយរបស់គណបក្សសង្គ្រោះជាតិទទួលបានភាគច្រើនពីបេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតផ្ទាល់តែម្តង។

ការចំណាយលើសកម្មភាពយោសនាបោះឆ្នោតរបស់គណបក្សប្រកួតប្រជែង មិនទាន់មានតម្លាភាព និងសមធម៌នោះទេ ព្រោះគណបក្សនយោបាយមិនបានបង្ហាញព័ត៌មានពីខ្ទង់ចំណាយ និងប្រភពចំណាយរបស់ខ្លួន ដែលហេតុនាំឲ្យមានការសង្ស័យថា គណបក្សនយោបាយពិតជាបានចំណាយថវិការបស់ខ្លួន ឬក៏ប្រើប្រាស់ឥទ្ធិពលនយោបាយដើម្បីទទួលបានការគាំទ្រផ្នែកសំភារៈ ដើម្បីរៀបចំសកម្មភាពយោសនា។

៤.៣.១ ការចំណាយលើសកម្មភាពយោសនាបោះឆ្នោត

ខ្ទង់ចំណាយរបស់គណបក្សនយោបាយលើសកម្មភាពយោសនាបោះឆ្នោតចំនួន១៤ថ្ងៃ ដោយផ្នែកលើចំនួនឃុំ/សង្កាត់ដែលគណបក្សបានឈរឈ្មោះប្រកួតប្រជែង មានគំលាតខុសគ្នាប្រមាណចំនួន០៥ដង

រវាងគណបក្សប្រជាជនកម្ពុជា ដែលជាគណបក្សកាន់អំណាច និងគណបក្សសង្គ្រោះជាតិ ជាគណបក្សប្រឆាំង ខណៈដែលគណបក្សប្រកួតប្រជែងទាំងពីរបានចូលរួមប្រកួតប្រជែងបោះឆ្នោតគ្រប់ឃុំសង្កាត់។ ការចំណាយនេះ មិនទាន់រាប់បញ្ចូលខ្ជង់ចំណាយបន្ថែមផ្សេងៗ នៃការសកម្មភាពឃោសនារបស់គណបក្សនយោបាយ ដែលរៀបចំដោយថ្នាក់ស្រុក/ខណ្ឌ/ក្រុង ខេត្ត/រាជធានី និងថ្នាក់ជាតិដូចជា៖ ខ្ជង់ចំណាយលើសេវាកម្មរបស់សិល្បករដែលបានចូលរួមហែក្បួនឃោសនា ឧបករណ៍តន្ត្រី និងរថយន្តធំៗដែលបានប្រើប្រាស់ជាឆាកសម្តែងសិល្បៈក្នុងសកម្មភាពហែក្បួនឃោសនានៅរាជធានីភ្នំពេញ និងខ្ជង់ចំណាយលើការទិញម៉ោងផ្សាយអំពីសកម្មភាពឃោសនា តាមរយៈទូរទស្សន៍ឯកជនបស់គណបក្សនេះ។

តារាងទី១ ប្រៀបធៀបការចំណាយក្នុងសកម្មភាពឃោសនាបោះឆ្នោត

គណបក្សនយោបាយ	ចំនួនឃុំ/សង្កាត់	ខ្ជង់ចំណាយមួយឃុំ/សង្កាត់(រ/$)[115]	ខ្ជង់ចំណាយសរុបសម្រាប់ការបោះឆ្នោត(រ/$)
គណបក្សប្រជាជនកម្ពុជា	1646	60,057,378 (រ)	98,854,443,822 (រ)
		15,014.34 ($)	24,713,610.96 ($)
គណបក្សសង្គ្រោះជាតិ	1646	13,849,003 (រ)	22,795,459,487 (រ)
		3,462.25 ($)	5,698,864.87 ($)
គណបក្សហ៊្វុនស៊ិនប៉ិច	846	2,148,500 (រ)	1,817,631,000 (រ)
		537.13 ($)	454,407.75 ($)
គណបក្សសម្ព័នដើម្បីប្រជាធិបតេយ្យ	844	3,682,444 (រ)	3,107,983,111 (រ)
		920.61($)	776,995.78 ($)

ប្រៀបធៀបខ្ជង់ចំណាយលើសកម្មភាពការឃោសនា

បើប្រៀបធៀបជាមួយការបោះឆ្នោតឆ្នាំ២០១៣ ដែលជាការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ហើយមណ្ឌលបោះឆ្នោត គឺរាជធានី/ខេត្តនោះ សកម្មភាពអំពីការឃោសនាបោះឆ្នោតនៅឃុំ/សង្កាត់សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ត្រូវបានគណបក្សនយោបាយចំណាយច្រើនជាង ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដោយសារមណ្ឌលបោះឆ្នោតនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់គឺឃុំ/សង្កាត់ផ្ទាល់។

[115] For the purposes of analysis and calculations COMFREL has utilized an exchange rate of 4,000 Riel = 1USD.

តារាងទី២ ការផ្លាស់ប្តូរការចំណាយសម្រាប់ការឃោសនាបោះឆ្នោតឆ្នាំ២០១២ និងឆ្នាំ២០១៧

Political Parties	for Commune / whole Election	Estimate Expenditure ($)			Change	2012-2017 (%)	2013-2017 (%)
		2012	2013	2017			
Cambodian People Party (CPP)	for a commune	9,000	3,900	15,014		40.06	74.02
	for whole election	14,697,000	15,708,400	24,713,610		40.53	36.44
Cambodia National Rescue Patry (CNRP)	for a commune	1,800	1,563	3,462		48.01	54.85
	for whole election	2,743,500	3,494,025	5,698,864		51.86	38.69
FUNCINPEC Party (FUN)	for a commune	200	129	537		62.76	75.98
	for whole election	282,600	412,053	454,407		37.81	9.32
League for Democracy Party (LDP)	for a commune	N/A	N/A	920	N/A	N/A	N/A
	for whole election	N/A	N/A	776,995	N/A	N/A	N/A

ខ្ទង់ចំណាយរបស់គណបក្សសង្គ្រោះជាតិសម្រាប់ការបោះឆ្នោតឆ្នាំ២០១២ គឺជាផលបូកនៃខ្ទង់របស់គណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្ស ព្រោះចាប់តាំងពីក្រោយការបោះឆ្នោតឆ្នាំ២០១២ កម្លាំងនយោបាយនៃគណបក្សទាំងបានរួមបញ្ចូលគ្នា បង្កើតជាគណបក្សសង្គ្រោះជាតិសម្រាប់ការចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត។

៤.៣.២ ការចំណាយលើប្រភេទសម្ភារៈបរិក្ខារ/សេវាកម្មសម្រាប់សកម្មភាពឃោសនាបោះឆ្នោត

រូបភាពទី១ បែងចែកការប៉ាន់ប្រមាណសំភារៈរបស់គណបក្សនយោបាយនិមួយៗ



ក្នុងដំណើរការឃោសនាបោះឆ្នោតជ្រើសជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ ១៤ថ្ងៃ (២០ ឧសភា ដល់ ០២មិថុនា) គណបក្សនយោបាយដែលចូលរួមកប្រកួតប្រជែងបានប្រើប្រាស់នូវសម្ភារៈនិងបរិក្ខារមួយចំនួនដើម្បីធ្វើសកម្មភាពឃោសនា។ គណបក្សនយោបាយបានចំណាយថវិកាលើសំភារៈ និងបរិក្ខារ រួមទាំងសេវាផ្សេងៗ ដើម្បីគាំទ្រដល់ការប្រារព្ធសកម្មភាពឃោសនារបស់ខ្លួន និងបង្ហាញអត្តសញ្ញាណគណបក្សឲ្យប្រជាពលរដ្ឋ ជាពិសេស អ្នកបោះឆ្នោតបានស្គាល់។ បរិក្ខារសម្ភារៈគាំទ្រដល់សកម្មភាពឃោសនាបោះឆ្នោតមានដូចជា៖ រទេះ ម៉ូតូ ឡាន វេទិកា ឆាកតន្ត្រី ម៉ាស៊ីនភ្លើង មេក្រូ ឬឧបករណ៍បំពងសម្លេងផ្សេងៗ ទង់ជាតិ និងគ្រឿងបរិភោគ។ ថវិកាត្រូវបានចាត់ទុកជាផ្នែកសំភា

រៈដែលគាំទ្រសកម្មភាពឃោសនាបោះឆ្នោត។ ថវិកាត្រូវបានគណបក្សនយោបាយផ្តល់ជូនអ្នកចូលរួមសកម្មភាពឃោសនា ដោយចាត់ទុកជាសោហ៊ុយធ្វើដំណើរ និងជាគ្រឿងលើកទឹកចិត្តសម្រាប់ការចូលរួមសកម្មភាពឃោសនា។ ខាងក្រោមជាភាគរយប៉ាន់ស្មាននៃខ្នង់ចំណាយរបស់គណបក្ស លើការចំណាយលើសំភារៈគាំទ្រការឃោសនា និងសំភារៈបង្ហាញពីអត្តសញ្ញាណគណបក្សប្រកួតប្រជែង៖

តារាងទី៣ បែងចែកការប៉ាន់ប្រមាណការចំណាយរបស់គណបក្សនយោបាយនិមួយៗ

គណបក្សនយោបាយ	សំភារៈ/សេវាកម្មគាំទ្រការឃោសនា	សំភារៈបង្ហាញពីអត្តសញ្ញាណគណបក្ស
គណបក្សប្រជាជនកម្ពុជា	46.12%	53.88%
គណបក្សសង្គ្រោះជាតិ	66.54%	33.46%
គណបក្សហ៊្វុនស៊ិនប៉ិច	63.50%	36.50%
គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ	72.26%	27.74%

៤.៣.៣ ប្រភពចំណាយលើសកម្មភាពឃោសនាបោះឆ្នោត

រូបភាពទី២ ប្រភពចំណាយលើសកម្មភាពឃោសនាបោះឆ្នោត



សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ មិនមានបទបញ្ញត្តិច្បាប់ណាមួយ ចែងអំពីតម្លាភាពនៃព័ត៌មាននៃប្រភពនៃការចំណាយលើសកម្មភាពឃោសនា របស់គណបក្សនយោបាយដែលចូលរួមប្រកួតប្រជែងការបោះឆ្នោតឡើយ។ ប្រភពនៃការចំណាយ របស់គណបក្សនយោបាយលើសកម្មភាពឃោសនាបោះឆ្នោតត្រូវបានគេដឹងថា មកពីគណបក្សនយោបាយពីថ្នាក់ឃុំ/សង្កាត់ ដល់រាជធានីខេត្ត បេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោត និងអ្នកគាំទ្ររបស់គណបក្សនយោបាយ។

តារាងទី៤ ប្រភពចំណាយលើសកម្មភាពឃោសនាបោះឆ្នោត

គណបក្សនយោបាយ	គណបក្សថ្នាក់ឃុំ/សង្កាត់	គណបក្សថ្នាក់ខេត្ត/រាជធានី	បេក្ខជនឈរឈ្មោះ	អ្នកគាំទ្រ
គណបក្សប្រជាជនកម្ពុជា	39.22%	36.14%	18.08%	6.56%
គណបក្សសង្គ្រោះជាតិ	10.43%	14.36%	59.11%	16.10%
គណបក្សហ៊្វុនស៊ិនប៉ិច	20.37%	27.78%	51.85%	0.00%
គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ	27.50%	2.50%	32.92%	37.08%

៤.៣.៤ សមាសភាពចូលរួមការឃោសនាបោះឆ្នោត

រូបភាពទី៣ សមាសភាពចូលរួមការឃោសនាបោះឆ្នោត



រយៈពេល១៤ថ្ងៃនៃយុទ្ធនាការឃោសនាបោះឆ្នោត គ្រប់គណបក្សប្រកួតប្រជែងក្នុងការបោះឆ្នោតបានធ្វើសកម្មភាពការឃោសនារបស់ខ្លួនយ៉ាងសកម្ម ដោយមានការចូលរួមពីអ្នកគាំទ្រមានដូចជា សមាជិកគណបក្ស ប្រជាពលរដ្ឋសាមញ្ញ ប្រជាពលរដ្ឋជាមន្ត្រីរាជការ ឬកងម្លាំង (ទាហាន នគរបាល) និងផ្សេងៗទៀត។ ច្បាប់ និងបទបញ្ជា និងនីតិវិធីស្តីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំសង្កាត់ អនុញ្ញាតឲ្យមន្ត្រីតុលាការ នគរបាល និងកងម្លាំងប្រដាប់អាវុធចូលរួមសកម្មភាពឃោសនាក្រៅពីម៉ោងធ្វើការ និងក្នុងរយៈពេលឈប់សំរាកពិសេស ខណៈដែលអង្គការសង្គមស៊ីវិលត្រូវបានហាមឃាត់ បើទោះបីជាចូលរួមជាបុគ្គលក៏ដោយ។ សកម្មភាពការឃោសនា របស់គណបក្សប្រជាជនកម្ពុជា ដែលជាគណបក្សកាន់អំណាច មានការចូលរួមពីកងកម្លាំង(នគរបាល និងទាហាន) ប្រមាណ៦% ខណៈសកម្មភាពការឃោសនារបស់គណបក្សសង្គ្រោះជាតិមានប្រមាណ២% ផងដែរ។

តារាងទី៥ សមាសភាពចូលរួមការយោសនាបោះឆ្នោត

គណបក្សនយោបាយ	សមាជិកគណបក្ស	ប្រជាពរដ្ឋ សាមញ្ញ	អ្នកមានមុខរបជាកងកម្លាំង
គណបក្សប្រជាជនកម្ពុជា	70.55%	23.47%	5.99%
គណបក្សសង្គ្រោះជាតិ	71.40%	28.41%	0.19%
គណបក្សហ៊្វុនស៊ិនប៉ិច	90.79%	9.21%	0.00%
គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ	96.16%	3.84%	0.00%

៤.៣.៥ សកម្មភាពយោសនាបោះឆ្នោត

ច្បាប់ និងបទបញ្ជានីតិវិធីសម្រាប់ការបោះឆ្នោត បានកំណត់ពីសកម្មភាពយោសនាសម្រាប់គណបក្សនយោបាយធ្វើសកម្មភាព ក្នុងអំឡុងពេលយោសនាមានដូចជា៖ ការជួបប្រជុំជាសាធារណៈរបស់គណបក្សនយោបាយ ឬបេក្ខជន ការរៀបចំក្បួនព្យុះហយាត្រា ឬក្បួនដំណើរដោយថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទនៅឃុំសង្កាត់ ការជួបជុំ ឬការយោសនាតាមផ្ទះ ការផ្សព្វផ្សាយតាមវិទ្យុ ឬទូរទស្សន៍ ឬសារព័ត៌មាន ការផ្សព្វផ្សាយតាមរលកធាតុអាកាស ឬការយោសនាតាមឧបករណ៍បំពងសំឡេង ឬតាមរយៈការចាត់កាស្សែតវីដេអូ ឬវីស៊ីឌី ឬឌីវីឌី ក្នុងរោងវិដេអូសាធារណៈ ឬទីធ្លាសាធារណៈ សកម្មភាពបិទផ្សាយនូវបដាពាក្យស្លោក ឬកម្មវិធីនយោបាយ ឬរូបភាពយោសនានានា សកម្មភាពចែកចាយខិត្តប័ណ្ណគណបក្សនយោបាយ ដើម្បីឲ្យអ្នកបោះឆ្នោត បោះឆ្នោតឲ្យ សកម្មភាពចែកចាយស្លាកសញ្ញាគណបក្សនយោបាយ ឬមួក សំលៀកបំពាក់ ឬសម្ភារៈផ្សេងៗទៀត ដែលបោះពុម្ព ឬគូរ ឬផលិត ដែលមានស្លាកសញ្ញាគណបក្ស ឬ/និងបេក្ខជន សកម្មភាពលើកបដានៅទីសាធារណៈណាមួយ ឬ/និងតំឡើងបន្ទះក្តារបិទប្រកាសផ្សាយពីគោល នយោបាយរបស់គណបក្សនយោបាយ ឬបេក្ខជន ការប្រគំតន្ត្រីនៅនឹងកន្លែងណាមួយ ឬច្រៀងចម្រៀងយោសនា ឬការលេងភ្លេង យោសនាបោះឆ្នោត ដើម្បីផ្សព្វផ្សាយគាំទ្របេក្ខជនណាម្នាក់ គណបក្សនយោបាយណាមួយ ការរៀបចំកម្មវិធីប្រកួតកីឡាដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់។

ក្នុងចំណោមសកម្មភាពទាំងនោះ ក្រៅពីសកម្មភាពយោសនាបោះឆ្នោត ដែលបានផ្សាយតាមរយៈកម្មវិធីរបស់ គ.ជ.ប តាមរយៈកញ្ចាក់ទូរទស្សន៍ និងវិទ្យុជាតិកម្ពុជា ការជួបប្រជុំជាសាធារណៈរបស់គណបក្សនយោបាយ ឬបេក្ខជន ការរៀបចំក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទនៅឃុំសង្កាត់ ការផ្សព្វផ្សាយតាមរលកធាតុអាកាស ឬការយោសនាតាមឧបករណ៍បំពងសំឡេង សកម្មភាពបិទផ្សាយនូវបដាពាក្យស្លោក ឬកម្មវិធីនយោបាយ ឬរូបភាពយោសនានានា សកម្មភាពចែកចាយខិត្តប័ណ្ណគណបក្សនយោបាយ គឺត្រូវបានគណបក្សនយោបាយប្រើប្រាស់ច្រើនជាងគេ ក្នុងរយៈពេល១៤ថ្ងៃនៃការយោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់នេះ។

តារាងទី៦ សកម្មភាពឃោសនាបោះឆ្នោត

គណបក្សនយោបាយ	ប្រជុំផ្សាយ	ដង្ហែក្បួន	ចាក់ឧបករណ៍បំពងសម្លេងផ្សព្វផ្សាយ	ចាក់វីដេអូផ្សព្វផ្សាយ	បិទរូបភាព ផ្សព្វផ្សាយ(poster)	ចែកខិតប័ណ្ណផ្សព្វផ្សាយ	ចែកសំភារៈឃោសនា (អាវយឺត មួក...)	ចែករំ ណោយ (សំភារៈប្រើប្រាស់ប្រចាំ	ដំឡើងបដា ឬបាណូ	ប្រគុំតន្ត្រី	ផ្សេងៗ
	%	%	%	%	%	%	%	%	%	%	%
គណបក្សប្រជាជនកម្ពុជា	21.80	15.79	30.08	5.26	9.77	11.28	3.01	0.00	2.26	0.75	0.00
គណបក្សសង្គ្រោះជាតិ	8.88	19.63	29.44	6.07	14.02	13.55	6.07	0.47	0.93	0.47	0.47
គណបក្សហ៊្វុនស៊ិនប៉ិច	13.70	21.92	21.92	5.48	15.07	10.96	1.37	2.74	1.37	4.11	1.37
គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ	8.33	9.52	45.24	16.67	11.90	4.76	3.57	0.00	0.00	0.00	0.00

៥. ការប្រើប្រាស់ធនធានរដ្ឋ និងទីធ្លាសាធារណៈ

នៅក្នុងរយៈពេលនៃការឃោសនាបោះឆ្នោតជាផ្លូវការចាប់ពីថ្ងៃទី២០ ខែឧសភា ដល់ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៧ អ្នកសង្កេតការណ៍ខុមហ្វ្រែល បានសង្កេតឃើញការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវចំនួន ៧៩៣ករណី ដែលបានកើតឡើងនៅទូទាំងប្រទេស។ ក្នុងចំណោមករណីទាំងនេះ មានករណីប្រមាណចំនួន ៧៦៦ ដែលជាចំនួនច្រើនជាងគេ ជាករណីចូលរួមរបស់អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកំលាំងប្រដាប់អាវុធ មន្ត្រីតុលាការ និងមេភូមិ បានធ្វើសកម្មភាពក្នុងការចូលរួមឃោសនាជាមួយគណបក្សនយោបាយ។

រូបភាពទី៤ ប្រើប្រាស់ធនធានរដ្ឋសម្រាប់ឃោសនាបោះឆ្នោត

ករណីប្រើប្រាស់យានជំនិះរបស់រដ្ឋ ឬប្រើប្រាស់យានជំនិះដោះស្លាកលេខចេញសម្រាប់ជាមធ្យោបាយក្នុងការឃោសនាដឹកជញ្ជូនរបស់គណបក្សមានយ៉ាងតិច១៦ករណី ដែលរកឃើញថាកើតមានក្នុងខេត្តព្រៃវែង ខេត្តបាត់ដំបង និងខេត្តរតនគីរី។ ក្រៅពីនោះមានករណីស្លាកសញ្ញា និងសម្ភារឃោសនារបស់គណបក្សនយោបាយ បានបិទ ឬលើកនៅក្នុងបរិវេណ ឬលើអាគារ ឬការិយាល័យរបស់រដ្ឋ យ៉ាងតិច ១១ករណី ដែលអ្នកសង្កេតការណ៍សង្កេតឃើញកើតមាននៅក្នុងខេត្តបន្ទាយមានជ័យ និងខេត្តកោះកុង។

៦. តួនាទីប្រព័ន្ធផ្សព្វផ្សាយក្នុងដំណើរការបោះឆ្នោត

ក្រៅពីប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដូចជាទូរទស្សន៍ វិទ្យុនិង កាសែត ប្រព័ន្ធផ្សព្វផ្សាយសង្គម ជាពិសេសហ្វេសប៊ុក ដើរតួនាទីយ៉ាងសំខាន់ក្នុងការចែករំលែកព័ត៌មាន អំពីដំណើរការបោះឆ្នោត និងស្ថានភាពនយោបាយដល់សាធារណជន។ ទោះបីជាព័ត៌មានមួយចំនួននៅលើហ្វេសប៊ុកមិនត្រូវបានផ្ទៀងផ្ទាត់ និងបញ្ជាក់ជាផ្លូវការក៏ដោយ មាតិកាភាគច្រើនត្រូវបានជឿទុកចិត្តដោយសាធារណជន។

លើសពីនេះ វិទ្យុ និងទូរទស្សន៍នៅតែដើរតួយ៉ាងសំខាន់ក្នុងការផ្តល់ព័ត៌មាននយោបាយ និងការបោះឆ្នោតរួមទាំងព័ត៌មានដំណើរការបោះឆ្នោត ទៅដល់ប្រជាពលរដ្ឋភាគច្រើននៅក្នុងប្រទេសកម្ពុជា។ ប្រព័ន្ធផ្សព្វផ្សាយទាំងអស់ គឺជាកម្មសិទ្ធិឯកជន លើកលែងតែទូរទស្សន៍ជាតិកម្ពុជា (ទទក) និងវិទ្យុជាតិ FM 96 MHz និងវិទ្យុជាតិ វត្តភ្នំ FM 105.70 MHz ។

បើតាមការប្រកួតប្រជែងបែបប្រជាធិបតេយ្យ និងយុត្តិធម៌ គណបក្សនយោបាយទាំងអស់ដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃត្រូវបានអនុញ្ញាតឱ្យផ្សព្វផ្សាយសកម្មភាពរបស់ពួកគេ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ។ រហូតមកដល់សព្វថ្ងៃនេះ កម្ពុជាមិនទាន់មានច្បាប់ស្តីពីប្រព័ន្ធផ្សព្វផ្សាយ ដើម្បីគ្រប់គ្រងការផ្សាយព័ត៌មានបោះឆ្នោត នយោបាយឲ្យជានាថាបានគោរពតាមក្រមសីលធម៌។ ច្បាប់ស្តីពីប្រព័ន្ធផ្សព្វផ្សាយ មានសារៈសំខាន់ មិនត្រឹមតែក្នុងការផ្តល់ពេលវេលាផ្សព្វផ្សាយតាមលក្ខខណ្ឌស្មើៗគ្នាទៅនឹងគណបក្សនយោបាយ និងបេក្ខជនអំឡុងពេលឃោសនាបោះឆ្នោតនោះទេ ប៉ុន្តែវាថែមទាំងចាំបាច់ក្នុងការគ្រប់គ្រងការផ្សាយព័ត៌មាននយោបាយលាបពណ៌ រើសអើង លំអៀង និងប្រមាថជាដើម។

ខុមហ្វ្រែល បានរៀបចំសង្កេតប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន អំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ចាប់ពីថ្ងៃទី២០ ខែឧសភា ដល់ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៧។ ខុមហ្វ្រែលបានធ្វើការវិភាគទៅលើកម្មវិធីទូរទស្សន៍រដ្ឋ និងឯកជន រួមមាន ទូរទស្សន៍រដ្ឋ (ទទក) និងទូរទស្សន៍ឯកជនដូចជា ទូរទស្សន៍បាយ័នពត៌មាន ទូរទស្សន៍ ស៊ី.ធី.អិន និងទូរទស្សន៍ហង្សមាស។ ការជ្រើសរើសទូរទស្សន៍ទាំងនេះ គឺផ្អែកទៅលើប្រជាប្រិយ៍ភាព ឯករាជភាព ឬការដែលសាធារណជនអាចទទួលព័ត៌មានបាន។ ខ្លឹមសារនៃការផ្សាយចាប់ពីម៉ោង ១៧:00 ដល់ ២៤:00 របស់ស្ថានីយទូរទស្សន៍ទាំងនេះ ត្រូវបានថតទុកក្នុងអំឡុងពេលនៃយុទ្ធនាការឃោសនាបោះឆ្នោត។ ការវិភាគ គឺផ្តោតទៅលើការបែងចែកពេលវេលាសំរាប់ព័ត៌មានទាក់ទងគណបក្សនយោបាយ កម្មវិធីគណបក្សនយោបាយ ការអប់រំ និងដំណើរការបោះឆ្នោត និង

ការផ្សាយពីសមិទ្ធិផលរបស់រាជរដ្ឋាភិបាល។ បន្ថែមពីលើការវិភាគទៅលើផ្នែកទូរទស្សន៍ ខុមហ្វ្រែលក៏បានធ្វើការវិភាគទៅលើផ្នែកអត្ថបទសារព័ត៌មាន នៅលើគេហទំព័រចំនួន១២ស្ថាប័នទៀត ដែលមានគេហទំព័រដើម្បីផ្សព្វផ្សាយ និងដែលផ្សព្វផ្សាយតាមរយៈហ្វេសប៊ុក។ ជាលទ្ធផលនៃការសង្កេត ខុមហ្វ្រែល សន្និដ្ឋានថានៅក្នុងការបោះឆ្នោតឆ្នាំ២០១៧ ការទទួលបានការផ្សព្វផ្សាយរបស់គណបក្សនយោបាយ ក្នុងអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោត មិនមានតុល្យភាពដោយគណបក្សប្រជាជនកម្ពុជា ដែលកំពុងកាន់អំណាចទទួលបានឱកាសច្រើនជាង ជាពិសេស ក្នុងករណីដែលស្ថានីយទូរទស្សន៍គ្របគ្រង់ដោយឯកជន។

៦.១ ការរំលោភលើគោលការណ៍ណែនាំ និងក្រមសីលធម៌របស់ គ.ជ.ប

ឧបសគ្គនៃការទទួលបានភាពស្មើគ្នាក្នុងការផ្សព្វផ្សាយរបស់គណបក្សនយោបាយ គឺកើតឡើងពីការអនុវត្តន៍មិនត្រឹមត្រូវនៃគោលការណ៍ណែនាំរបស់ គ.ជ.ប អំពីប្រព័ន្ធផ្សព្វផ្សាយ ដែលបានណែនាំទាក់ទងនឹងការហាមឃាត់ការផ្តល់ការផ្សាយដោយអយុត្តិធម៌ លម្អៀង និងរើសអើង និងការផ្សាយដោយមានខ្លឹមសារហឹង្សាប្រមាថជាដើម។ ដោយធ្វើការសង្កេតប្រព័ន្ធផ្សព្វផ្សាយ គេអាចសន្និដ្ឋានបានថា គ.ជ.ប មិនបានអនុវត្តឲ្យមានប្រសិទ្ធភាពនូវគោលការណ៍ណែនាំ ស្តីពីប្រព័ន្ធផ្សព្វផ្សាយក្នុងពេលឃោសនាបោះឆ្នោតបានទេ ដោយសារគ្មានក្របខ័ណ្ឌច្បាប់សម្រាប់ការត្រួតពិនិត្យប្រព័ន្ធផ្សព្វផ្សាយ និងការប្រើប្រព័ន្ធផ្សព្វផ្សាយ។ គោលការណ៍ណែនាំស្តីពីប្រព័ន្ធផ្សព្វផ្សាយចេញផ្សាយដោយ គ.ជ.ប ត្រូវបានគេមើលឃើញថា មិនបានអនុវត្តពេញលេញដោយស្ថានីយ៍ផ្សព្វផ្សាយឯកជននោះទេ។

នៅក្នុងបទបញ្ជា និងនីតិវិធីនៃការឃោសនាបោះឆ្នោត និងគោលការណ៍ណែនាំ ស្តីពីប្រព័ន្ធផ្សព្វផ្សាយ គ.ជ.ប បានចែងថា នៅក្នុងអំឡុងពេលឃោសនាបោះឆ្នោត ប្រព័ន្ធផ្សព្វផ្សាយទាំងរដ្ឋ និងឯកជនត្រូវតែផ្តល់ឱ្យគ្រប់គណបក្សនយោបាយប្រកួតប្រជែងនូវពេលវេលាស្មើៗគ្នា។ គ.ជ.ប ក៏តម្រូវឱ្យមានស្ថានីយទូរទស្សន៍ វិទ្យុ ឯកជនរាយការណ៍ពីចំនួនម៉ោងដែលទំនេរ សម្រាប់លក់ជូនគណបក្សនយោបាយផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ស្ថានីយទូរទស្សន៍ និងវិទ្យុឯកជនបានរាយការណ៍ថា ពួកគេមិនមានម៉ោងទំនេរសម្រាប់លក់ជូនគណបក្សនយោបាយ ក្នុងអំឡុងពេលឃោសនាបោះឆ្នោត ដូច្នេះមិនចាំបាច់រាយការណ៍ទៅ គ.ជ.ប ទេ។

តាមគោលការណ៍ណែនាំរបស់ គ.ជ.ប ប្រព័ន្ធផ្សព្វផ្សាយឯកជន អាចបដិសេធមិនលក់ម៉ោងផ្សាយទៅឱ្យគណបក្សនយោបាយបាន ហើយតម្រូវឲ្យប្រព័ន្ធផ្សព្វផ្សាយនោះ មិនត្រូវលក់ម៉ោងផ្សាយទៅឱ្យគណបក្សនយោបាយណាមួយឡើយ។ ជាក់ស្តែង នៅក្នុងការឃោសនាបោះឆ្នោតឆ្នាំ២០១៧ ស្ថានីយ៍ទូរទស្សន៍ឯកជន ត្រូវបានគេសង្កេតឃើញថា បានលក់ម៉ោងផ្សាយទៅឱ្យគណបក្សប្រជាជនដោយមិនបានរាយការណ៍ពីម៉ោងទំនេររបស់ខ្លួនទៅ គ.ជ.ប ជាមុនសិន តាមគោលការណ៍ណែនាំរបស់ គ.ជ.ប។ យោងតាមលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រធានគណបក្សប្រជាជនកម្ពុជាបានថ្លែងថា គណបក្សនេះបានទិញម៉ោងផ្សាយពីទូរទស្សន៍ឯកជន ដែលមានតម្លៃ៣០០ដុល្លារអាមេរិកក្នុងមួយនាទី ដើម្បីផ្សព្វផ្សាយសកម្មភាពយុទ្ធនាការផ្សាយផ្ទាល់នៅថ្ងៃចុងក្រោយនៃយុទ្ធនាការឃោសនា។

ខុមប្រៀលរកឃើញថា ក្របខ័ណ្ឌច្បាប់ និងបទបញ្ជាមិនគ្រប់គ្រាន់ ក្នុងការផ្តល់នូវលក្ខខណ្ឌនៃការប្រកួតប្រជែងផ្នែកនយោបាយដែលស្មើភាព និងដោយយុត្តិធម៌។ ការសង្កេតប្រព័ន្ធផ្សព្វផ្សាយបានបង្ហាញយ៉ាងច្បាស់ថា ក្នុងអំឡុងពេលយុទ្ធនាការឃោសនា គណបក្សនយោបាយមួយទទួលអត្ថប្រយោជន៍ ឬឱកាសច្រើនជាងគេ ក្នុងការផ្សព្វផ្សាយតាមទូរទស្សន៍ និងវិទ្យុឯកជន។ គ.ជ.ប មិនទាន់បានបង្កើតយន្តការដែលមានប្រសិទ្ធភាពដើម្បីឃ្លាំមើល និងអនុវត្តបទបញ្ជារបស់ប្រព័ន្ធផ្សព្វផ្សាយសម្រាប់ស្ថានីយទូរទស្សន៍ឯកជននោះទេ។[116]

៦.២ កម្មវិធីផ្សាយរបស់ទូរទស្សន៍ក្នុងអំឡុងពេលឃោសនាបោះឆ្នោត

ក្រៅពីកម្មវិធីដែលផ្សាយជាប្រចាំ ក្នុងអំឡុងពេលឃោសនាចាប់ផ្តើមពីថ្ងៃទី២០ ខែឧសភា ដល់ថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០១៧ ស្ថានីយទូរស្សន៍ទាំង០៤ បានផ្សាយកម្មវិធីបន្ថែមមួយចំនួនទៀត ក្នុងគោលបំណងផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋ។ កម្មវិធីដែលយើងសង្កេតឃើញមានការផ្សាយបន្ថែម ក្នុងអំឡុងពេលឃោសនាបោះឆ្នោតមានដូចជា៖ ឯកសារវីដេអូស្តីអំពីការអភិវឌ្ឍន៍សង្គម និងប្រទេសជាតិ កម្មវិធីរបស់គណបក្សនយោបាយ និងកម្មវិធីព័ត៌មានអប់រំ និងដំណើរការបោះឆ្នោត ព្រមទាំងឃើញមានការប្រើប្រាស់សារជាអក្សរ ឬពាក្យសម្តីពាក់ព័ន្ធនឹងគណបក្សនយោបាយ ឬតួអង្គនយោបាយក្នុងកម្មវិធីផ្សាយផ្សេងៗរបស់ខ្លួន ជាពិសេសកម្មវិធីផ្សាយព័ត៌មាន ឬកម្មវិធីអត្ថាធិប្បាយផ្សេងៗ។[117]

វីដេអូរឯកសារស្តីពីការអភិវឌ្ឍន៍សង្គមជាតិ ដែលត្រូវបានផលិតដោយទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវបានចាក់ផ្សាយលើស្ថានីយទូរទស្សន៍ទាំងបួន។ ខ្លឹមសារនៃវីដេអូទាំងនេះមិនត្រឹមតែបង្ហាញពីការអភិវឌ្ឍន៍សង្គមជាតិនោះទេ ហើយថែមទាំងផ្សារភ្ជាប់ការអភិវឌ្ឍន៍ទាំងនោះទៅនឹងលទ្ធផលនៃការដឹកនាំរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលជាតួអង្គនយោបាយសំខាន់មួយរូបនៃគណបក្សកាន់អំណាច ក្នុងការចូលរួមប្រកួតប្រជែងការបោះឆ្នោត។

[116] It is notable that the portion of media consumption by Cambodian citizens is shifting considerably away from traditional media and towards social media, as greater numbers of eligible voters are turning to internet and Facebook for news.

[117] Defined by Wikipedia as a: "text-based display either in the form of a graphic that typically resides in the lower third of the screen space on a television station or network (usually during news programming) or as a long, thin scoreboard-style display seen around the facades of some offices or public buildings dedicated to presenting headlines or minor pieces of news."

តារាងទី៧ កម្មវិធី និងការបែងចែកពេលវេលា(នាទី)ផ្សាយរបស់ស្ថានីយ៍ទូរទស្សន៍៖

ស្ថានីយទូរទស្សន៍ \ ប្រភេទ និងពេលវេលាផ្សាយ (នាទី)	សមិទ្ធិផលរាជរដ្ឋាភិបាល	ព័ត៌មានទាក់ទងគណបក្សនយោបាយ	កម្មវិធីគណបក្សនយោបាយ	ការអប់រំ និងដំណើរការបោះឆ្នោត
ទូរទស្សន៍ជាតិកម្ពុជា (TVK)	64.15	10.52	803.65	507.65
ទូរទស្សន៍បាយ័នព័ត៌មាន (BTV News)	61.75	286.78	140.40	31.83
ទូរទស្សន៍ ស៊ី ធី អិន (CTN)	39.15	69.07	132.85	32.65
ទូរទស្សន៍ហង្សមាស (HM HDTV)	128.68	187.70	202.05	410.10
សរុបរយៈពេលផ្សាយ	**293.73**	**554.07**	**1,278.95**	**982.23**

រូបភាពទី៥ កម្មវិធី និងការបែងចែកពេលវេលា(នាទី)ផ្សាយរបស់ស្ថានីយ៍ទូរទស្សន៍



រូបភាពទី៦ ការបែងចែកពេលវេលាលើកម្មវិធីផ្សាយរបស់ស្ថានីយ៍ទូរទស្សន៍



៦.៣ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយក្នុងទូរទស្សន៍ជាតិ

៦.៣.១ ការផ្សាយព័ត៌មានទាក់ទងគណបក្សនយោបាយ និងខ្លឹមសារ របស់ស្ថានីយ៍ទូរទស្សន៍

តារាងទី៨ ការបែងចែកពេលវេលាសម្រាប់គណបក្សនយោបាយនីមួយៗលើស្ថានីយទូរទស្សន៍

រយៈពេលផ្សាយ (នាទី) / ស្ថានីយទូរទស្សន៍	ប្រ.ជ	ត.ស.ជ	រ.ជ.ក.ឯ.អ.	ត.ស.ប	ខ.រ.ជ	ត.ស.ស.ប	ត.ស.ក	ត.អ.ខ	ត.ប.ម	ត.យ.ក	ត.ជ.ប.ក	ត.ស.រ.ប
ទូរទស្សន៍ជាតិកម្ពុជា (TVK)	8.93	1.25	0.00	0.33	0.00	0.00	0.00	0.00	0.00	0.00	0.00	0.00
ទូរទស្សន៍បាយ័នព័ត៌មាន (BTV News)	215.67	59.42	7.58	0.00	4.12	0.00	0.00	0.00	0.00	0.00	0.00	0.00
ទូរទស្សន៍ ស៊ីធីអិន (CTN)	63.95	5.12	0.00	0.00	0.00	0.00	0.00	0.00	0.00	0.00	0.00	0.00
ទូរទស្សន៍ហង្សមាស (HM HDTV)	182.32	5.38	0.00	0.00	0.00	0.00	0.00	0.00	0.00	0.00	0.00	0.00
សរុបរយៈពេលផ្សាយ	**470.87**	**71.17**	**7.58**	**0.33**	**4.12**	**0.00**	**0.00**	**0.00**	**0.00**	**0.00**	**0.00**	**0.00**

ក្នុងរយៈពេលឃោសនាបោះឆ្នោតនេះ ព័ត៌មានទាក់ទងនឹងគណបក្សប្រជាជនកម្ពុជា ត្រូវបានស្ថានីយ៍ទូរទស្សន៍ទាំងបួនផ្សាយរយៈពេលប្រមាណ៤៧០នាទី។ ហើយខ្លឹមសារនៃការផ្សាយព័ត៌មានទាំងនោះ បង្ហាញពីសកម្មភាពឃោសនារបស់គណបក្សនេះ និងខ្លឹមសារមួយចំនួនផ្សេងទៀត បង្ហាញពីភាពវិជ្ជមាន

មានដូចជា៖ ការចាត់ទុកលទ្ធផលនៃការអភិវឌ្ឍន៍វិស័យនានាជាស្នាដៃរបស់គណបក្សប្រជាជនកម្ពុជាថែមទាំងលើកយកសារនយោបាយរបស់ថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជាមកផ្សាយផងដែរ។

ព័ត៌មានទាក់ទងនឹងគណបក្សសង្គ្រោះជាតិ[118] ក៏ត្រូវបានស្ថានីយទូរទស្សន៍ទាំងបួន (០៤) ផ្សាយចំនួនប្រមាណ៧១នាទីផងដែរ។ ជាពិសេស ស្ថានីយ៍ទូរទស្សន៍បាយ័នព័ត៌មាន (BTV News) បានផ្សាយរហូតដល់ប្រមាណ៥៩នាទី ប៉ុន្តែខ្លឹមសារនៃការផ្សាយទាំងនោះ ខុសគ្នាពីខ្លឹមសារនៃការផ្សាយអំពីគណបក្សប្រជាជនកម្ពុជា។ ការសង្កេតឃើញថា រូបភាពបង្ហាញពីភាពមិនមានសណ្តាប់នៃការឃោសនាបោះឆ្នោតរបស់គណបក្សសង្គ្រោះជាតិត្រូវបានយកមកចាក់ផ្សាយ។

<u>រូបភាពទី៧ ភាគរយនៃការបែងចែកនាទីទៅគណបក្សនយោបាយដែលផ្សាយតាមរយៈស្ថានីយទូរទស្សន៍</u>



[118] This does not refer to programing produced by the CNRP, but rather to news programs by the TV station during the campaign period discussing the CNRP.

៦.៣.២ ការផ្សាយកម្មវិធីរបស់គណបក្សនយោបាយតាមស្ថានីយ៍ទូរទស្សន៍

តារាងទី៩ ការបែងចែកពេលវេលាសម្រាប់កម្មវិធីគណបក្សនយោបាយលើទូរទស្សន៍

រយៈពេលផ្សាយ (នាទី) / ស្ថានីយទូរទស្សន៍	ប្រ.ជ	ត.ស.ជ	រ.ជ.ក.ឯ. អ.អ.ស	ត.ស.ប	ខ.រ.ជ	ត.ស.ស.ប	ត.ស.ក	ត.អ.ខ	ត.ប.ម	ត.យ.ក	ត.ជ.ប.ក	ត.ស.រ.ប
ទូរទស្សន៍ជាតិកម្ពុជា (TVK)	73.12	69.83	72.58	72.35	66.90	58.80	64.48	69.42	66.63	82.03	37.73	69.77
ទូរទស្សន៍បាយ័នព័ត៌មាន (BTV News)	140.40	0.00	0.00	0.00	0.00	0.00	0.00	0.00	0.00	0.00	0.00	0.00
ទូរទស្សន៍ ស៊ី ធី អិន (CTN)	132.85	0.00	0.00	0.00	0.00	0.00	0.00	0.00	0.00	0.00	0.00	0.00
ទូរទស្សន៍ហង្សមាស (HM HDTV)	202.05	0.00	0.00	0.00	0.00	0.00	0.00	0.00	0.00	0.00	0.00	0.00
សរុបរយៈពេលផ្សាយ	**548.42**	**69.83**	**72.58**	**72.35**	**66.90**	**58.80**	**64.48**	**69.42**	**66.63**	**82.03**	**37.73**	**69.77**

ជាទូទៅ គណបក្សនយោបាយដែលចូលរួមប្រកួតប្រជែងការបោះឆ្នោត ទទួលបានរយៈពេលស្មើគ្នាដែលផ្តល់ឲ្យដោយ គ.ជ.ប ឲ្យផ្សព្វផ្សាយកម្មវិធីនយោបាយ ឬព័ត៌មានរបស់គណបក្ស តាមរយៈស្ថានីយទូរទស្សន៍ ជាតិកម្ពុជា (ទទក/TVK)។ រយៈពេលដែលផ្តល់ឲ្យដោយ គ.ជ.ប ត្រូវបានគណបក្សនយោបាយប្រើប្រាស់ សម្រាប់ផ្សព្វផ្សាយឯកសារវីដេអូរបស់គណបក្ស និងផ្តល់ឆ្លើយសំណួរអំពីគោលនយោបាយ ឬការដោះស្រាយបញ្ហានានាដែលសម្របសម្រួលដោយមន្ត្រី គ.ជ.ប។ គួរឲ្យកត់សម្គាល់ដែរថា គណបក្សនយោបាយមួយចំនួនមិនបានប្រើប្រាស់អស់នូវរយៈពេលដែល គ.ជ.ប បានផ្តល់ជូននោះទេ។

<u>រូបភាពទី៨ ការផ្សាយកម្មវិធីរបស់គណបក្សនយោបាយតាមរយៈទូរទស្សន៍ជាតិកម្ពុជា (ទទក/TVK)</u>



ក្នុងអំឡុងពេលឃោសនាបោះឆ្នោតនេះ វីដេអូរបស់គណបក្សសង្គ្រោះជាតិ ដែលបានផលិតដើម្បីចាក់ផ្សាយក្នុងកម្មវិធីរបស់ គ.ជ.ប តាមរយៈទូរទស្សន៍ជាតិកម្ពុជា (ទទក) ត្រូវបានបដិសេធក្នុងការចាក់ផ្សាយដោយ គ.ជ.ប តាមលិខិតលេខ ១០៧ គ.ជ.ប.អ.គ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧។ ការបដិសេធរបស់ គ.ជ.ប ក្រោមហេតុផលថា ក្រសួងព័ត៌មានមិនអនុញ្ញាត ឲ្យទូរទស្សន៍ជាតិកម្ពុជា (ទទក) ចាក់ផ្សាយវីដេអូសេចក្តីថ្លែការណ៍របស់លោក សម រង្ស៊ី ដែលតាមអំណាចសាលក្រមលោកមានឋានៈជាទណ្ឌិត។ សេចក្តីសម្រេចបដិសេធការចាក់ផ្សាយនេះ ត្រូវបានមើលឃើញថា មិនត្រូវបានយោងតាមបទបញ្ញត្តិនៃច្បាប់ណាមួយឡើយ ខណៈដែលខ្លឹមសារនៃវីដេអូមានអត្ថន័យដូចជា៖ អំពាវឲ្យពលរដ្ឋគាំទ្រគណបក្សសង្គ្រោះជាតិ តាមរយៈការបោះឆ្នោត និងការផ្សព្វផ្សាយគោលនយោបាយរបស់គណបក្សសង្គ្រោះជាតិតែប៉ុណ្ណោះ។

មានតែគណបក្សប្រជាជនកម្ពុជាទេ បានប្រើប្រាស់ស្ថានីយ៍ទូរទស្សន៍ឯកជន ដែលត្រូវបានសង្កេតដូចជា៖ ទូរទស្សន៍បាយ័នព័ត៌មាន(BTVNews)ទូរទស្សន៍ស៊ីធីអិន(CTN) និងទូរទស្សន៍ហង្សមាស (HMHDTV) ដើម្បីផ្សាយសកម្មភាពឃោសនារបស់គណបក្ស។ គណបក្សប្រជាជនកម្ពុជាបានទិញម៉ោងផ្សាយរបស់ស្ថានីយ៍ទូរទស្សន៍ឯកជនយ៉ាងហោចចំនួន ០៨ស្ថានីយ៍ ដើម្បីផ្សាយសកម្មភាពឃោសនានាថ្ងៃចុងក្រោយរបស់ខ្លួន។ ប្រធានគណបក្សប្រជាជនកម្ពុជា លោកនាយករដ្ឋ មន្ត្រី ហ៊ុន សែនបានឲ្យដឹងថា គណបក្សប្រជាជនកម្ពុជាបានទិញម៉ោងទូរទស្សន៍ដើម្បីផ្សាយផ្ទាល់ពីសកម្មភាពនៃថ្ងៃឃោសនាចុងក្រោយរបស់គណបក្ស ក្នុងតម្លៃ៣០០ដុល្លារសហរដ្ឋអាមេរិកនៃក្នុងផ្សាយមួយនាទី។ ការអះអាងរបស់ប្រធានគណបក្សខាងលើ ត្រូវបានគេប៉ាន់ស្មានពីតម្លៃនៃការផ្សព្វផ្សាយតាមរយៈទូរទស្សន៍ឯកជនពីសកម្មភាពឃោសនាបោះឆ្នោត នាថ្ងៃចុងក្រោយប្រមាណ៧២ម៉ឺនដុល្លារសហរដ្ឋអាមេរិក។

ដូចនេះ គណបក្សប្រជាជនកម្ពុជាបានទទួលបានឱកាសច្រើនជាងគេ ក្នុងការផ្សព្វផ្សាយគោលនយោ បាយ និងសកម្មភាពឃោសនារបស់គណបក្ស តាមរយៈស្ថានីយ៍ទូរទស្សន៍ ជាពិសេសស្ថានីយ៍ទូរទស្សន៍ឯកជន។ បើប្រៀបរយៈពេលផ្សាយតាមស្ថានីយ៍ទូរទស្សន៍ទាំង០៤ គណបក្សប្រជាជនកម្ពុជាមានប្រើប្រាស់រយៈពេលផ្សាយប្រមាណ៤៣% នៃរយៈពេលផ្សាយរបស់គណបក្ស តាមរយៈស្ថានីយ៍ទូរទស្សន៍ទាំង ០៤ដូចគ្នា។

<u>រូបភាពទី៩ រយៈពេលផ្សាយរបស់គណបក្សនយោបាយតាមស្ថានីយ៍ទូរទស្សន៍ទាំង០៤</u>



៦.៤ អត្ថបទសារព័ត៌មាននៅលើបណ្តាញផ្សព្វផ្សាយ គេហទំព័រ និងហ្វេសប៊ុក

ក្នុងអំឡុងពេលឃោសនាបោះឆ្នោត ស្ថាប័នសារព័ត៌មាន តាមរយៈគេហទំព័ររបស់ខ្លួនបានចុះផ្សាយនូវព័ត៌មានអំពីគណបក្សនយោបាយ និងសកម្មភាពឃោសនា របស់គណបក្សនយោបាយប្រកួតប្រជែង។ ហើយ អត្ថបទសារព័ត៌មានទាំងនោះ ភាគច្រើនត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័រហ្វេសប៊ុករបស់ស្ថាប័នសារព័ត៌មាន ដែលចែកចាយបន្ត(Share)ច្រើននៅក្នុងអំឡុងពេលបោះឆ្នោត។

អត្ថបទសារព័ត៌មានទាក់ទងនឹងគណបក្សនយោបាយ និងសកម្មភាពឃោសនា ត្រូវបានសង្កេត និងបានវាយតម្លៃខ្លឹមសារដូចជា៖ ព័ត៌មានគណបក្ស ការលើកសរសើរគណបក្ស(វិជ្ជមាន) និងការរិះគន់គណបក្ស(អវិជ្ជមាន) ជាដើម។ ក្នុងរយៈពេល១៤ថ្ងៃនៃការឃោសនាបោះឆ្នោត យ៉ាងហោចណាស់ មានអត្ថបទសារព័ត៌មានប្រមាណចំនួន៦០០ បានចុះផ្សាយពី ព័ត៌មានគណបក្ស ការលើកសរសើរគណបក្ស និងការរិះគន់គណបក្សនៃគណបក្សនយោបាយទាំង១២ ដែលប្រកួតប្រជែងក្នុងការបោះឆ្នោត។ ទិន្នន័យចំនួនអត្ថបទព័ត៌មានទាក់ទងនឹងគណបក្ស និងស្ថាប័នសារព័ត៌មានមាននៅក្នុងតារាងខាងក្រោមនេះ៖

៦.៤.១ គណបក្សនយោបាយ និងចំនួនអត្ថបទសារព័តមាន

ក្នុងចំណោម១២គណបក្សនយោបាយប្រកួតប្រជែង មានតែព័ត៌មានគណបក្សនយោបាយ ដែលមានសម្លេងគាំទ្រច្រើនជាងគេចំនួន០២តែប៉ុណ្ណោះ ដែលត្រូវបានចុះផ្សាយដោយស្ថាប័នព័ត៌មានច្រើនជាងគេ។ ព័ត៌មានគណបក្សប្រជាជនកម្ពុជា ត្រូវបានចុះផ្សាយក្នុង៣៧៥អត្ថបទ(៥៨%) ចំណែកឯព័ត៌មានគណបក្សសង្គ្រោះជាតិ ត្រូវបានចុះផ្សាយក្នុង១៩៥អត្ថបទ(៣០%)។

រូបភាពទី១០ ចំនួនអត្ថបទសារព័ត៌មាននៃគណបក្ស



៦.៤.១.១ អត្ថបទសារព័ត៌មានអំពីគណបក្សប្រជាជនកម្ពុជា

រូបភាពទី១១ អត្ថបទសារព័ត៌មានអំពីគណបក្សប្រជាជនកម្ពុជា



ព័ត៌មានគណបក្សប្រជាជនកម្ពុជា ដែលជាគណបក្សកាន់អំណាច ត្រូវបានចុះផ្សាយ នៅលើគេហទំព័រចំនួន ៣៧៥អត្ថបទ ដែលប្រមាណ ១៦៩អត្ថបទ (៤៥%) ត្រូវបានចុះផ្សាយដោយស្ថាប័ន ព័ត៌មាន Fresh News ដែលនាពេលកន្លងមក តែងតែទទួលបាននិងចុះផ្សាយព័ត៌មានដែលលេចធ្លាយ (មិនអាចបញ្ជាក់ប្រភពបាន) អំពីរឿងអាស្រូវឯកជនរបស់ថ្នាក់ដឹកនាំគណបក្សប្រឆាំង។ សារព័ត៌មានដើម អំពិល (DAP News) ក៏បានផ្សាយព័ត៌មាន គណបក្សប្រជាជនកម្ពុជា ប្រមាណ ៧៦អត្ថបទ (២១%) ផងដែរ។

៦.៤.១.២ អត្ថបទសារព័ត៌មានអំពីគណបក្សសង្គ្រោះជាតិ

រូបភាពទី១២ អត្ថបទសារព័ត៌មានអំពីគណបក្សសង្គ្រោះជាតិ



ការផ្សាយព័ត៌មានគណបក្សសង្គ្រោះជាតិ ដោយស្ថាប័នសារព័តមានគឺមានសមធម៌ច្រើន។ មានន័យថា ចំនួនអត្ថបទព័ត៌មាន គណបក្សសង្គ្រោះជាតិ ត្រូវចុះផ្សាយប្រហាក់ប្រហែលគ្នា ដោយស្ថាប័នសារព័ត៌មាន នីមួយៗ ហើយមិនមានស្ថាប័នសារព័ត៌មានណាមួយ បានផ្សាយ

ដល់ចំនួន១/៤ នៃអត្ថបទសារព័ត៌មានឡើយ។ ស្ថាប័នសារព័ត៌មានដើមអំពិល (DAP News) ដែលផ្សាយអំពីគណបក្សសង្គ្រោះជាតិច្រើនជាងគេ បើប្រៀបធៀបនឹងស្ថាប័នសារព័ត៌មានដទៃ បានផ្សាយអត្ថបទចំនួនត្រឹមតែ ៤៤ (២១%) ប៉ុណ្ណោះ។

<u>រូបភាពទី១៣ អត្ថបទព័ត៌មានអំពីគណបក្សប្រជាជនកម្ពុជា ឬ/និងគណបក្សសង្គ្រោះជាតិ</u>



៦.៤.២ ព័ត៌មានលេចធ្លាយ ឬមិនអាចបញ្ជាក់ប្រភព ឬ/និងព័ត៌មានក្លែងក្លាយ

ក្នុងរយៈពេលឃោសនាបោះឆ្នោត យ៉ាងហោចណាស់ អត្ថបទសារព័ត៌អំពីគណបក្សនយោបាយ ឬ/និងថ្នាក់ដឹកនាំគណបក្សប្រកួតប្រជែងការបោះឆ្នោត មានចំនួន០៤ដែលមានលក្ខណៈជាការលេចធ្លាយ ឬគ្មានប្រភពច្បាស់លាស់។ យោងតាមការវិភាគ និងការវាយតម្លៃដែលធ្វើឡើងដោយខុមហ្រ្វែល ក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត និងសង្កេតការណ៍បោះឆ្នោតឃុំ សង្កាត់ឆ្នាំ ២០១៧ ព័ត៌មានក្លែងក្លាយ និងលេចធ្លាយ តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គមមិនមានផលប៉ះពាល់គួរឱ្យកត់សម្គាល់លើដំណើរការបោះឆ្នោត និងស្ថានភាពមុនការបោះឆ្នោតទេ។

តារាងទី១០ អត្ថបទនៃព័ត៌មានបែកធ្លាយលើប្រព័ន្ធព័ត៌មានសង្គម

ល.រ	ស្ថាប័នរងឥទ្ធិពល	ចំណងជើងព័ត៌មាន/ដំណឹង	កាលបរិច្ឆេទការផ្សាយ	ប្រភពផ្សាយ	ការព័ណ៌នា	ការវាយតម្លៃ
១	គណបក្សស	អង្គការមិនមែន រដ្ឋាភិបាលនិងដៃគូ	២៦	កាសែតរស្មីកម្ពុជា	អង្គការមិនមែនរដ្ឋាភិបាល)NGO) ជាង៥០អង្គការ និង ដៃគូអភិវឌ្ឍន៍	មិនបញ្ជាក់

	គ្រោះជាតិ	អភិវឌ្ឍន៍មួយចំនួនអន់ចិត្តនឹងសម្តីលោកកឹម សុខា	ឧសភា	https://goo.gl/nrZTYL	ធំៗច្រើនជាង១០បានអន់ចិត្តនឹងលោកកឹម សុខាដែលបានប្រកាសថាបើគណបក្សសង្គ្រោះជាតិឈ្នះឆ្នោតលុបក្រសួងអភិវឌ្ឍន៍ជនបទចោល	ប្រភព
២	គណបក្សប្រជាជនកម្ពុជា	Members Confirm CPP-Linked 'Cyber War Room'	២៦ ឧសភា	The cambodiadaily https://goo.gl/GxsB4D	Documents leaked to media this week suggest Prime Minister Hun Sen, his eldest son Hun Manet and son-in-law Sok Puthyvuth, and other prominent CPP-affiliated officials, were involved in an ongoing campaign to spread CPP rhetoric, monitor opposition supporters on social media and attack CNRP leaders.	លេចធ្លាយ
៣	គណបក្សប្រជាជនកម្ពុជា ឬ/និងរាជរដ្ឋាភិបាល	Justice official denies authenticity of emails	២២ ឧសភា	The Phnom Penh Post https://goo.gl/mmNBRS	Cambodia's embattled justice system and its alleged tight alignment with the ruling party have been thrust into the spotlight after what appeared to be a string of hacked emails were leaked from Justice Ministry spokesman Kim Santepheap's account over the weekend.	លេចធ្លាយ
៤	អង្គការសង្គមស៊ីវិល	BREAKING NEWS: បែកធ្លាយផែនការសំងាត់ទុច្ចរិតរបស់ NGO និងអង្គការសង្គមស៊ីវិលមួយចំនួន ធ្វើយុទ្ធនាការជួយគណបក្សប្រឆាំង	០១ ឧសភា	សារព័ត៌មាន Fresh News https://goo.gl/exe1Qv	មន្ត្រីជាន់ខ្ពស់មួយរូបផ្នែកសន្តិសុខជាតិ បានទម្លាយប្រាប់បណ្តាញព័ត៌មាន Fresh News មុននេះបន្តិចនាព្រឹកថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៧នេះ ឲ្យដឹងថា មានអង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិលមួយចំនួន ដែលមាននិន្នាការគាំទ្របក្សប្រឆាំងបានរៀបចំផែនការសំងាត់ធ្វើយុទ្ធនាការតាមទូរស័ព្ទ និង Online	លេចធ្លាយ និងមិនបញ្ជាក់ប្រភព

					ដើម្បីជៈឥទ្ធិពលលើប្រជាពលរដ្ឋជាម្ចាស់ឆ្នោត។	

៧ .ក្របខណ្ឌច្បាប់សម្រាប់ការបោះឆ្នោត និងប្រព័ន្ធបោះឆ្នោត

ក្របខណ្ឌច្បាប់សម្រាប់ការការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ត្រូវបានរៀបចំថ្មី តាមរយៈការធ្វើវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ ការវាយតម្លៃទៅលើចំណុចផ្លាស់ប្តូរនៃប្បញ្ញត្តិនៅក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ថ្មី) និងច្បាប់ (ចាស់) ឃើញថា មានចំណុចផ្លាស់ប្តូរជាអវិជ្ជមានច្រើនជាងចំណុចផ្លាស់ប្តូរជាវិជ្ជមាន។ ក្នុងចំណោមចំណុចផ្លាស់ប្តូរនៃប្បញ្ញត្តិនៅក្នុងច្បាប់(ថ្មី) ចំនួន២១ ចំណុចមាន ១០ចំណុចអវិជ្ជមាន ៥ចំណុចមិនច្បាស់លាស់ និង៦ចំណុចវិជ្ជមាន។[119]

៧.១ ការផ្លាស់ប្តូរសំខាន់ៗនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានធ្វើវិសោធនកម្មថ្មីទាំងស្រុង ហើយចំណុចផ្លាស់ប្តូរសំខាន់ៗទាំងនោះរួមមាន:

១. ការចុះឈ្មោះបោះឆ្នោត និងបញ្ជីបោះឆ្នោត គឺមានភាពវិជ្ជមាន ដោយស្របទៅនឹងបញ្ញត្តិនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

២. ចំនួនអ្នកបោះឆ្នោតក្នុងមួយការិយាល័យ ៧៥០នាក់ គឺភាពមិនច្បាស់លាស់ ដែលអាចអវិជ្ជមាន ឬវិជ្ជមាន។

៣. និយមន័យ និងសកម្មភាពនៃការឃោសនាបោះឆ្នោត គឺមានភាពអវិជ្ជមាន ព្រោះបញ្ញត្តិថ្មីបានរឹតត្បឹតសេរីភាពក្នុងបញ្ចេញមតិរិះគន់ និងសកម្មភាពឃោសនាបោះឆ្នោត ពិសេសការរៀបចំក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទនៅឃុំ សង្កាត់ ត្រូវបានបន្ថយយ៉ាងច្រើន ០២ (ពីរ) ដង ក្នុងអំឡុងពេលឃោសនាបោះឆ្នោត។

៤. ការលើកស្លាកសញ្ញាគណបក្សនយោបាយ នៅទីសាធារណៈ គឺមានមានភាពវិជ្ជមាន ដោយបានលើកកំពស់នៃគោលការណ៍ស្មើភាពគ្នា និងការសម្របសម្រួលពីអាជ្ញាធរឃុំ សង្កាត់។

[119] The assessment of Electoral Reform Alliance (ERA).

៥. រយៈពេលនៃការឃោសនាបោះឆ្នោត គឺមានភាពអវិជ្ជមាន ព្រោះបញ្ញត្តិថ្មីបានកាត់បន្ថយរយៈពេលនៃការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយដែលចូលរួមការបោះឆ្នោត។

៦. ការហាមឃាត់មួយផ្នែកនៃការបោះឆ្នោត និងបទល្មើស គឺមានភាពមិនច្បាស់លាស់ ដោយសារមិនមានការផ្តន្ទាទោសចំពោះបទល្មើសបោះឆ្នោត ដែលបានចែងថា "គ្រប់គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រទាំងអស់ មិនត្រូវធ្វើការគំរាមកំហែង បំភិតបំភ័យ និងលួងលោមឲ្យបុគ្គលផ្តិតមេដៃ ឬស្បថ ឬសន្យាបោះឆ្នោតឲ្យគណបក្សនយោបាយណាមួយឡើយ"។

៧. ការហាមឃាត់លើការចូលរួមក្នុងសកម្មភាពគណបក្សនយោបាយនៃមន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ ក្នុងការឃោសនាបោះឆ្នោត គឺមានភាពវិជ្ជមាន ក្នុងការកំណត់បំរាមលើការចូលរួមក្នុងសកម្មភាពគណបក្សនយោបាយពីក្រុមមន្ត្រីទាំងនេះ។

៨. ការលើកទឹកចិត្តការចូលរួមក្នុងសកម្មភាពគណបក្សនយោបាយរបស់មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ នគរបាលជាតិក្នុងការឃោសនាបោះឆ្នោត គឺមានភាពអវិជ្ជមាន ខណៈដែលបញ្ញត្តិនេះផ្ទុយពីមាត្រា ៧២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នេះ និងមាត្រា ១៥ នៃច្បាប់ស្តីពីគណបក្សនយោបាយ។ មន្ត្រីកងយោធពលខេមរភូមិន្ទ នគរបាលយុត្តិធម៌មានតួនាទី និងការទទួលខុសត្រូវសំខាន់ដោយផ្ទាល់ក្នុងការរក្សាសន្តិសុខនៃដំណើរការបោះឆ្នោត ហើយមន្ត្រីតុលាការក៏នឹងចូលរួមក្នុងការងារដោះស្រាយ និងកាត់សេចក្តីលើបណ្តឹងដែលទាក់ទងការបោះឆ្នោត។

៩. ការហាមឃាត់បណ្តុំប្រជាពលរដ្ឋដែលជាសមាគម ឬអង្គការក្នុងសកម្មភាពចូលរួមជាមួយគណបក្សនយោបាយក្នុងការឃោសនាបោះឆ្នោត គឺមានភាពអវិជ្ជមានធ្ងន់ធ្ងរ ព្រោះបានរំលោភយ៉ាងធ្ងន់ធ្ងរលើរដ្ឋធម្មនុញ្ញ ក្នុងបញ្ញត្តិនៃមាត្រា ៣៥, ៣៦, ៤១, និងមាត្រា៤២ ពិសេសរំលោភសិទ្ធិចូលរួមសកម្មក្នុងជីវភាពនយោបាយ សេរីភាពខាងបញ្ចេញមតិ និងសិទ្ធិបង្កើតអង្គការ សមាគមមិនមែនរដ្ឋាភិបាល។

១០. ហាមជនបរទេស ធ្វើសកម្មភាព ក្នុងការឃោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ គឺមានភាពមិនច្បាស់លាស់ ដោយការអនុវត្តន៍អាចវិជ្ជមាន ឬអវិជ្ជមាន។

១១. ការសម្របសម្រួលរបស់ គ.ជ.ប ក្នុងការផ្សព្វផ្សាយអត្ថបទឃោសនា របស់គណបក្សនយោបាយ គឺមានភាពវិជ្ជមាន ព្រោះបានតម្រូវឲ្យ គ.ជ.ប ចាត់វិធានការក្នុងការផ្សព្វផ្សាយអត្ថបទឃោសនា របស់គណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត តាមគោលការណ៍ស្មើភាព។

១២. ការទទួលស្គាល់ សម្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត គឺមានភាពវិជ្ជមាន ដោយបានចែងអំពីពេលវេលានៃការសម្រេចរបស់ គ.ជ.ប ដើម្បីពិនិត្យ និងសម្រេចការដាក់ពាក្យសុំសង្កេតការណ៍។

១៣. បម្រាមសម្រាប់ភ្នាក់ងារគណបក្ស និងអ្នកសង្កេតការណ៍ គឺមានភាពអវិជ្ជមាន ជាមួយនឹងបញ្ញត្តិអំពីបម្រាមចំពោះភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត ដោយបានភ្ជាប់នឹងមាត្រា ១៨៨នៃច្បាប់នេះ ដែលបានដាក់ទោសផាកពិន័យជាប្រាក់ពី ១លានរៀល ដល់ ១០លានរៀល ដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍។

១៤. ការហាមឃាត់បណ្តុំប្រជាពលរដ្ឋដែលជាសមាគម ឬអង្គការក្នុងសកម្មភាពចូលរួមជាមួយគណបក្សនយោបាយក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត គឺមានភាពអវិជ្ជមានធ្ងន់ធ្ងរ ដែលដកសិទ្ធិសេរីភាពបញ្ចេញមតិទាក់ទងជីវភាពនយោបាយ ក្នុងអំឡុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដូចមាត្រា ៧៤ នៃច្បាប់បោះឆ្នោតថ្មីនេះ។

១៥. ការពិន័យដោយ គ.ជ.ប លើការក្លែងបន្លំឯកសារបញ្ជាក់អត្តសញ្ញាណពាក់ព័ន្ធនឹងការបោះឆ្នោត គឺមានភាពវិជ្ជមាន។ ច្បាប់បោះឆ្នោតចាស់ មិនមានចែងឡើយអំពីទោសប្បញ្ញត្តិនៃការក្លែងបន្លំឯកសារបញ្ជាក់អត្តសញ្ញាណ ខណៈដែលបញ្ញត្តិនេះបានឆ្លើយតបទៅនឹងបញ្ហានៃការក្លែងបន្លំឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់ការបោះឆ្នោត។

១៦. ទណ្ឌកម្ម និងទុច្ចរិតក្នុងការព្យាយាមចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតលើសពីមួយ គឺមានភាពមិនច្បាស់លាស់ ដោយការអនុវត្តន៍អាចវិជ្ជមាន ឬអវិជ្ជមាន។

១៧. ទណ្ឌកម្មចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអន្តរជាតិដែលបំពេញការងារក្នុងកម្ពុជា ទាក់ទងសកម្មភាពចូលរួមជាមួយគណបក្សនយោបាយក្នុងការបោះឆ្នោត គឺមានភាពអវិជ្ជមានយ៉ាងធ្ងន់ធ្ងរ។ វាគឺជាបញ្ញត្តិថ្មីស្រឡាង ដោយបានដាក់ទោសពិន័យយ៉ាងធ្ងន់ធ្ងរដល់ការប្រព្រឹត្តរបស់អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិ។

១៨. ទណ្ឌកម្មជនបរទេសដែលមានវត្តមាននៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលក្នុងចេតនាឃោសនាបោះឆ្នោត គឺមានភាពមិនច្បាស់លាស់។ វាជាបញ្ញត្តិថ្មី ដែលមិនច្បាស់លាស់សម្រាប់ការអនុវត្តន៍។

១៩. ការប្រមាថជាសាធារណៈ ចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោត និងទណ្ឌកម្ម គឺមានភាពអវិជ្ជមាន។ វាជាបញ្ញត្តិថ្មី ការប្រមាថជាសាធារណៈចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោតអាចប្រតិបត្តិ រហូតដល់ត្រូវលុបឈ្មោះបេក្ខភាពប្រកួតប្រជែងរបស់គណបក្សនយោបាយនោះបញ្ចូលជាមួយមាត្រា ១៩០។

២០. ទណ្ឌកម្មចំពោះអ្នកសង្កេតការណ៍បោះឆ្នោត គឺមានភាពអវិជ្ជមាន។ ការងារសង្កេតការណ៍បោះឆ្នោត គឺជាការងារស្មុគ្រចិត្ត ដែលត្រូវមានការលើកទឹកចិត្ត ត្រូវមានការចូលរួមពីប្រជាពលរដ្ឋ ពិសេសយុវជន ដោយមិនត្រូវស្ថិតក្រោមសម្ពាធ ឬការគំរាមកំហែងទៅសកម្មភាពពួកគេទេ។

២១. ការលុបបេក្ខភាពឈរឈ្មោះរបស់គណបក្សនយោបាយណា គឺមានភាពអវិជ្ជមានយ៉ាងធ្ងន់ធ្ងរ ដោយហេតុថា មានការភ្ជាប់បទល្មើស ដែលប្រព្រឹត្តដោយបុគ្គលឯកជនទៅនឹងបទល្មើសស្ថាប័នទាំងមូល។

៧.២ អនុសាសន៍ដែលបានផ្តល់ដោយខុមហ្វ្រែល និងសម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត

ក្រៅពីការវាយតម្លៃលើចំណុចផ្លាស់ប្តូរសំខាន់ៗ ខុមហ្វ្រែល រួមជាមួយសម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត ក៏បានផ្តល់ជាអនុសាសន៍មួយចំនួនសម្រាប់កែលម្អក្របខណ្ឌច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ដែលរួមមាន៖

- រក្សាប្បញ្ញត្តិដូចក្នុងច្បាប់ (ចាស់) ដែលគណបក្សនយោបាយមានសិទ្ធិរៀបចំក្បួនព្យុហយាត្រា ឬក្បួនដំណើរ ឬដោយយានជំនិះបានក្នុងអំឡុងនៃការឃោសនាបោះឆ្នោត។ ព្រោះថា ប្រព័ន្ធបោះឆ្នោតជាប្រព័ន្ធសមាមាត្រជាមួយបញ្ជីបិទ ដែលថ្នាក់ដឹកនាំគណបក្សនយោបាយ ត្រូវចុះទៅធ្វើឃោសនាបោះឆ្នោតនៅតាមរាជធានី ខេត្ត ប្រកួតប្រជែងការបោះឆ្នោត។
- ពង្រឹងការអនុវត្តច្បាប់ស្តីពីគណបក្សនយោបាយ (មាត្រា១៥) ឱ្យបានពេញលេញ ក្នុងសម័យឃោសនាបោះឆ្នោត និងដើម្បីធានាបរិយាកាសអព្យាក្រឹត្យ ដោយមន្ត្រីកងយុទ្ធពលខេមរភូមិន្ទ នគរបាល និងមន្ត្រីតុលាការមិនត្រូវធ្វើសកម្មភាពគាំទ្រ និងប្រឆាំងគណបក្សនយោបាយណាមួយនៅគ្រប់ពេលវេលាក្នុងការឃោសនាបោះឆ្នោត។ ព្រោះថា កងយោធពលខេមរភូមិន្ទ នគរបាលមានតួនាទីសំខាន់ផ្នាល់រក្សាសន្តិសុខក្នុងដំណើរការបោះឆ្នោត ហើយមន្ត្រីតុលាការក៏នឹងចូលរួមផ្នាល់ក្នុងការងារបណ្តឹងទាក់ទិនការបោះឆ្នោត។
- ដកប្បញ្ញត្តិ (មាត្រា៧៨ និងមាត្រា១៥៩) ហាមឃាត់អង្គការ សមាគមមិនមែនរដ្ឋាភិបាលចេញពីច្បាប់បោះឆ្នោត ដើម្បីរក្សាសេរីភាព និងសិទ្ធិនយោបាយរបស់អង្គការសង្គសុីវិល ជាពិសេសអង្គការមិនមែន រដ្ឋាភិបាលក្នុងសម័យកាលឃោសនាបោះឆ្នោត។ បញ្ញត្តិនេះអាចជាផ្នែកនៃក្រមសីលធម៌សម្រាប់អង្គការ សមាគមមិនមែនរដ្ឋាភិបាល ដែលទទួលស្គាល់ដោយ គ.ជ.ប ដើម្បីធ្វើសកម្មភាពទាក់ទងការបោះឆ្នោត និងសង្កេតការណ៍បោះឆ្នោត។ និងព្រមទាំងលុបបញ្ញត្តិទាក់ទងការដាក់ទណ្ឌកម្មចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអន្តរជាតិដែលបំពេញការងារក្នុងកម្ពុជា ទាក់ទងសកម្មភាពចូលរួមជាមួយគណបក្សនយោបាយក្នុងការបោះឆ្នោត។
- គ.ជ.ប គួរប្រតិភូកម្មអំណាចដល់គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ក្នុងការផ្តល់ប័ណ្ណសម្គាល់ឲ្យអ្នកសង្កេតការណ៍។ សំណើនេះគឺក្នុងគោលបំណងកាត់បន្ថយចំណាយ និងការិយាធិបតេយ្យ។

- លុបមាត្រា ១៨៨ ខណៈដែលបម្រាមសម្រាប់អ្នកសង្កេតការណ៍ គឺរក្សាទុកកម្រិតក្រមសីលធម៌។ អ្នកសង្កេតការណ៍រំលោភក្រមសីលធម៌ គ.ជ.ប អាចធ្វើការព្រមាន ហើយបន្ទាប់មក ហាមឃាត់មិនឲ្យអ្នកសង្កេតការណ៍ជាបុគ្គលចូលសង្កេតការណ៍បោះឆ្នោត ដែលទណ្ឌកម្មនេះគឺគ្រប់គ្រាន់ហើយ។
- លុបមាត្រា ១៩០ ដើម្បីការពារសិទ្ធិនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត។
- រៀបចំប្រព័ន្ធបោះឆ្នោតចម្រុះដែលមានក្រុមបេក្ខជនឯករាជ្យ (ដែលផ្តុំពីបុគ្គលឯកកត្តនាម) និងគណបក្សនយោបាយអាចឈរឈ្មោះបោះឆ្នោត។
- រូបមន្តមធ្យមភាគខ្ពស់បំផុត ដោយយករូបមន្តសំណល់ខ្ពស់បំផុតវិញសម្រាប់គណនាអាសនៈដែលនៅសល់ ដូចកាលបោះឆ្នោតសម័យអ៊ុនតាក់។
- កំណត់លក្ខខណ្ឌក្នុងការចុះបញ្ជីបេក្ខជនសម្រាប់គណបក្សនយោបាយ ដែលក្នុងបញ្ជីបេក្ខជននីមួយៗ ត្រូវមានបេក្ខជនជាបុរស ឬជាស្ត្រីយ៉ាងហោចចំនួនស្មើគ្នា និងបេក្ខជនជាយុវជនយ៉ាងហោច ៣០ភាគរយផងដែរ។ ក្នុងបញ្ជីនីមួយៗ ត្រូវដាក់ឆ្លាស់គ្នារវាងបេក្ខជន និងបេក្ខនារីពីលើចុះក្រោម។
- គ.ជ.ប ត្រូវធ្វើការប្រកាសផ្សាយជាសាធារណៈនូវរបាយការណ៍ចំណូល និងចំណាយពេលឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយចូលរួមប្រកួតប្រជែងការបោះឆ្នោត។
- ចែងឱ្យមានការចូលរួមពី គយ/សប ជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីជួយសម្របសម្រួលដល់គណបក្សនយោបាយក្នុងការលើកស្លាកសញ្ញាគណបក្ស។
- ត្រូវមានការផ្តន្ទាទោសចំពោះបទល្មើសបោះឆ្នោត ដែលបានចែងថា "គ្រប់គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រទាំងអស់ មិនត្រូវធ្វើការគំរាមកំហែង បំភិតបំភ័យ និងលួងលោមឲ្យបុគ្គលផ្តិតមេដៃ ឬស្បថ ឬសន្យាបោះឆ្នោតឲ្យគណបក្សនយោបាយណាមួយឡើយ" ។

៧.៣ បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប

គ.ជ.ប បានរៀបចំបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ជាពីរដំណាក់កាល ដែលទី១. គឺបទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មីឆ្នាំ២០១៦ និងទី២. គឺបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤។ ការរៀបចំបទបញ្ជា និងនីតិវិធីទាំងនេះ គ.ជ.ប បានបើកឱ្យមានការផ្តល់យោបល់ និងព្រមទាំងរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធផងដែរ។

សម្រាប់បទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មីឆ្នាំ២០១៦ គឺមានភាពវិជ្ជមានច្រើន ស្របទៅនឹងការផ្លាស់ប្តូរនៃបញ្ញត្តិនៅក្នុងច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រថ្មី។ ទន្ទឹមគ្នានេះក៏មានចំណុចគួរកែលម្អមួយចំនួនដូចជា ១) នីតិវិធីក្នុងការផ្ទៀងផ្ទាត់របស់ក្រុមចុះឈ្មោះបោះឆ្នោត និងអ្នកសុំចុះឈ្មោះបោះឆ្នោត ២) នីតិវិធីនៃការចេញបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ៣) ការណែនាំ ឬនីតិវិធីក្នុងការផ្តិតស្នាមម្រាមដៃ និងការថតរូបអ្នកស្នើសុំចុះឈ្មោះបោះឆ្នោត ៤) សម្ភារៈ និង

ឧបករណ៍ចុះឈ្មោះបោះឆ្នោត ដែល គ.ជ.ប គួរតែបន្ថែមម៉ាស៊ីនព្រីនធ័រដើម្បីបោះពុម្ពបង្កាន់ដៃ ៥) ពង្រឹងសមត្ថភាពមន្ត្រីចុះឈ្មោះបោះឆ្នោត និង ៦) ធានាសិទ្ធិអ្នកបោះឆ្នោត ពិសេសពលករចំណាកស្រុកទៅក្រៅប្រទេស និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណជូនប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត។

ដោយឡែក បទបញ្ជានិងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ក៏មានចំណុចផ្លាស់ប្តូរជាវិជ្ជមានផងដែរ។ ទោះជាយ៉ាងណាក្តី ខុមហ្វ្រែល និងសម្ព័ន្ធកំណែទម្រង់ការបោះឆ្នោតបានផ្តល់ជា អនុសាសន៍ចំនួន១៤ចំណុចដល់ គ.ជ.ប ដែលក្នុងនោះ អនុសាសន៍ចំនួន៥ គ.ជ.ប ទទួលយកទាំងស្រុង និងទទួលយកខ្លះ ហើយអនុសាសន៍ចំនួន៩ គ.ជ.ប មិនបានទទួលយក។

អនុសាសន៍ដែលគ.ជ.ប ទទួលយកទាំងស្រុង និងទទួលយកខ្លះរួមមាន:

១. យន្តការសម្របសម្រួល និងត្រួតពិនិត្យក្នុងការអនុវត្តន៍គោលការណ៍ស្មើភាព និងការកំណត់ និងរៀបចំបញ្ជី ទីធ្លាសាធារណៈ ឬមហោស្រព ឬមណ្ឌលកីឡា ឬឧទ្យាន ពិសេសកម្មសិទ្ធិឯកជនរបស់រដ្ឋ ដែលគណបក្សនយោបាយចុះឈ្មោះប្រកួតប្រជែងប្រើប្រាស់ ឬជួលក្នុងតម្លៃទាបសមរម្យមួយ។

២. ការត្រួតពិនិត្យបញ្ជីឈ្មោះបោះឆ្នោតរូបថត ជាមួយអ្នកបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោតដែលអ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយ គួរមានសិទ្ធិផ្ទៀងផ្ទាត់បញ្ជីបោះឆ្នោត និងអ្នកមកបោះឆ្នោតជាក់ស្តែង ដោយអាចឈរនៅពីក្រោយលេខាធិការ ដើម្បីពិនិត្យរកឈ្មោះ និងផ្ទៀងផ្ទាត់ឈ្មោះអ្នកចូលទៅបោះឆ្នោតជាមួយ អ.ខ ឬឯ.អ និងបញ្ជីបោះឆ្នោត។

៣. ការរាប់សន្លឹកឆ្នោត បើទោះបីដកការហាមនៅក្នុងក្រមសីលធម៌អ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្ស បទបញ្ជា និងនីតិវិធីត្រូវបានបញ្ជាក់បន្ថែមទៀតអំពីសិទ្ធិត្រូវបានអនុញ្ញាតឱ្យថតបានក្នុងពេលរាប់ និងធ្វើកំណត់ហេតុលទ្ធផលរាប់សន្លឹកឆ្នោតបណ្តោះអាសន្ន អាចជារូបភាព ឬវីដេអូ។ ក៏គួរឱ្យមានការបើកចំហរបងក្នុងបរិវេណនៃទីតាំងការិយាល័យបោះឆ្នោត។

៤. នៅពេលសមាជិកទី២នៃ គ.ក.រ ទៅបិទផ្សាយកំណត់ហេតុលទ្ធផលរាប់សន្លឹកឆ្នោត (១១០២) នៅការិយាល័យបោះឆ្នោតជាសាធារណៈ នៅពេលនោះ សមាជិកទីពីរ ត្រូវថត និងបញ្ជូនរូបភាពនៃកំណត់ហេតុនៃការរាប់បោះឆ្នោត(១១០២) តាមមធ្យោបាយអេឡិចត្រូនិច Online ដូចជាអ៊ីមែល(Email) ឬ/និងApps មកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងបង្ហោះនៅក្នុងវេបសាយរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬ/និងប្រព័ន្ធបណ្តាញសង្គម(Social Media)។

៥. ការចែកជូនកំណត់ហេតុ ១២០២ ទៅគណបក្សនយោបាយ ត្រូវមានត្រាផ្លូវការពីការិយាល័យរាប់សន្លឹកឆ្នោត។

អនុសាសន៍ដែល គ.ជ.ប មិនទទួលយករួមមាន:

១. ហិរញ្ញវត្ថុឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ដែលមានសមត្ថិច្ចរបស់ គ.ជ.ប ក្នុងការត្រួតពិនិត្យ និងការបើកចំហរបាយការណ៍ហិរញ្ញវត្ថុរបស់គណបក្សនយោបាយក្នុងពេលឃោសនាបោះឆ្នោត។

២. ការទទួលពាក្យបណ្តឹង:

- បើមានពាក្យបណ្តឹង គឃ សប ឬគធ ខប ត្រូវតែទទួល បើទោះជាគ្មានភស្តុតាងគ្រប់គ្រាន់នៅពេលប្តឹងក៏ដោយ។
- មន្ត្រីទទួលពាក្យបណ្តឹងមានភារកិច្ចជួយសរសេរពាក្យបណ្តឹង បើមានការស្នើសុំពីប្រជាពលរដ្ឋ។
- នៅថ្នាក់ គ.ជ.ប ត្រូវបង្កើតគណៈកម្មការទទួលពាក្យបណ្តឹង និងអង្កេតបណ្តឹងបោះឆ្នោត ដែលមានសមាសភាពមកពីសមាជិក គ.ជ.ប និងមន្ត្រីនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃ គ.ជ.ប។ គណៈកម្មការនេះ មានភារកិច្ចទទួលពាក្យបណ្តឹងជំនួសឲ្យការងាររបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប និងតួនាទីអង្កេតបណ្តឹង។
- គ.ជ.ប ត្រូវមានសៀវភៅណែនាំលម្អិត ស្តីអំពីការទទួលពាក្យបណ្តឹង និងការអង្កេតសម្រាប់គណៈកម្មការទទួលពាក្យបណ្តឹង និងអង្កេតបណ្តឹងបោះឆ្នោត។

៣. ការស៊ើបអង្កេតលើបណ្តឹង: គណៈកម្មការទទួលពាក្យបណ្តឹង និងអង្កេតបណ្តឹងបោះឆ្នោត ត្រូវធ្វើការស៊ើបអង្កេតករណីរបស់ពាក្យបណ្តឹង ក្នុងរយៈពេលសមស្របមួយ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង។

៤. សវនាការ:

- គ.ជ.ប ត្រូវធ្វើជាសាធារណៈ និងបើកចំហគ្រប់សវនាការដែលអាចឱ្យមានការចូលរួមសង្កេត។
- សវនាការសង្ខេប សវនាការតទល់ និងសវនាការសួរដេញដោលរបស់គ.ជ.ប ត្រូវធ្វើឡើងជា «សាធារណៈ»។

៥. ការសម្រេចដាក់ទោស និងពិន័យលើអ្នកប្រព្រឹត្តបទល្មើស(ប្រការ១៥.៥.៦.២) បង្កើតនីតិវិធីនៃការសម្រេច ព្រមាន(កាតលឿង) បើល្មើសអំណាច និងក្រមសីលធម៌ តែពិន័យកាតក្រហមជាមួយវិន័យ ដែលល្មើសច្បាប់ ឬបន្តបំពានល្មើសក្រមសីលធម៌លើសមួយដង។

៦. ព័ត៌មាននៃការគ្រប់គ្រងព័ត៌មានអំពីការទទួលពាក្យបណ្តឹង ការអង្កេត បណ្តឹង ការដោះស្រាយ និងសេចក្តីសម្រេចលើបណ្តឹង ជាប្រពន្ធ័ទិន្នន័យ ដាក់ក្នុងគេហទំព័ររបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

៧. ការកំណត់អំពីអំណាចរបស់ប្រធានការិយាល័យបោះឆ្នោតស្នើឱ្យមន្ត្រីសន្តិសុខជាមួយអាវុធ តែក្នុងករណីពិសេសបទល្មើសធ្ងន់ធ្ងរឱ្យទៅក្នុងការិយាល័យបោះឆ្នោត។

៨. ការបោះឆ្នោតឆ្នោតឡើងវិញ: កំណត់ភាពមិនប្រក្រតីកម្រិតធ្ងន់ធ្ងរ ដែលចាំបាច់តម្រូវឱ្យបោះឆ្នោតឡើង វិញ។ ត្រូវកំណត់អំពីកម្រិត និងប្រភេទនៃភាពមិនប្រក្រតីជាប្រព័ន្ធ ដែលឈានទៅដល់ការបដិសេធលទ្ធផលបោះឆ្នោតបណ្តោះអាសន្ននៅក្នុងមណ្ឌលបោះឆ្នោតមួយ ដែលនឹងធ្វើការរៀបចំការបោះឆ្នោតសាជាថ្មី។ បណ្តុំនៃភាពមិនប្រក្រតីទាំងនោះ គួរត្រូវកំណត់ដូចខាងក្រោម៖

- កំហុសបច្ចេកទេសធ្ងន់ធ្ងរក្នុងការិយាល័យបោះឆ្នោត (ការអនុវត្តន៍ខុសបទបញ្ជា និងនីតិវិធី) ឬ
- កំហុសបច្ចេកទេសធ្ងន់ធ្ងរក្នុងការិយាល័យរាប់សន្លឹកឆ្នោត ឬ
- ការទិញសន្លឹកឆ្នោតក្នុងភូមិ ចាប់គិតពីដំណើរការយុទ្ធនាការឃោសនាបោះឆ្នោត រហូតដល់ថ្ងៃស និងថ្ងៃបោះឆ្នោត ឬ
- ការបំភិតបំភ័យ គំរាមកំហែង និងអំពើហឹង្សាកើតមានក្នុងភូមិ ករណីពិសេស (ករណីគំរាមកំហែង បំភិតបំភ័យធ្ងន់ធ្ងរ ឬសំលាប់ពាក់ព័ន្ធនយោបាយ...)

៩. ការរាប់សន្លឹកឆ្នោតឡើងវិញ នៅក្នុងក្របខ័ណ្ឌការិយាល័យបោះឆ្នោត ឬឃុំ សង្កាត់និមួយៗ ឃុំ សង្កាត់ណាដែលមានកម្រិតលម្អៀងយ៉ាងច្រើន០.៥% រវាងបញ្ជីបេក្ខជនពីរ ឬច្រើនអាចត្រូវត្រួតពិនិត្យ និងរាប់សន្លឹកឆ្នោតឡើងវិញ ប៉ុន្តែឃុំ សង្កាត់ដែលមានកម្រិតភាពមិនប្រក្រតីធ្ងន់ធ្ងរជាប្រព័ន្ធ ទាក់ទិនការរាប់សន្លឹកឆ្នោត ក៏ត្រូវបានរាប់សន្លឹកឆ្នោតឡើងវិញដែរ។

៨ .ការជ្រើសរើសសមាជិកគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប)

៨.១ ក្របខណ្ឌច្បាប់នៃការជ្រើសរើស គធ.ខប

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានប្រកាសជ្រើសរើសសមាសភាពគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) ចំនួន១៧៥រូប ដើម្បីបម្រើការងារនៅតាម គធ.ខប សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៧។ គធ.ខប ចាប់ផ្តើមបម្រើការងារពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧។ សម្រាប់រាជធានី ខេត្តនីមួយៗ សមាជិក គធ.ខប

មានចំនួន៧រូប ដែលរួមមាន: ១.ប្រធាន ២.អនុប្រធាន ៣.សមាជិកទទួលបន្ទុកផ្នែករដ្ឋបាល ៤.សមាជិកទទួលបន្ទុកផ្នែកប្រតិបត្តិការ និងបញ្ជីបោះឆ្នោត ៥.សមាជិកទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ ៦.សមាជិកទទួលបន្ទុកផ្នែកបណ្តុះបណ្តាល អប់រំអ្នកបោះឆ្នោត ព័ត៌មាន និងទំនាក់ទំនងសាធារណៈ និង៧.សមាជិកទទួលបន្ទុកផ្នែកសេវកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត។

នៅក្នុងសេចក្តីជូនដំណឹងរបស់ គ.ជ.ប មានកំណត់អំពីលក្ខខណ្ឌទូទៅ លក្ខខណ្ឌបច្ចេកទេស លក្ខខណ្ឌដោយឡែក ភារកិច្ច និងការទទួលខុសត្រូវនៃ គធ.ខប។ ជាមួយគ្នានេះ ក៏កំណត់អំពីរយៈពេលបម្រើការងារ ប្រាក់កម្រៃ ទំនាក់ទំនងព័ត៌មាន កាលបរិច្ឆេទនៃការទទួលពាក្យ ការប្រឡង និងការធ្វើតេស្ត។ ក្នុងសេចក្តីជូនដំណឹងនោះក៏មានប្រកាសលើកទឹកចិត្តចំពោះជនពិការ និងជនជាតិដើមភាគតិចផងដែរ។

ក្នុងសេចក្តីជូនដំណឹងរបស់ គ.ជ.ប បានកំណត់កាលបរិច្ឆេទនៃការទទួលពាក្យ ការប្រឡង និងការធ្វើតេស្ត ដូចខាងក្រោម:

- ការចាប់ផ្តើមទទួលពាក្យ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ (វេលាម៉ោង ៧:០០ ព្រឹក)
- ការឈប់ទទួលពាក្យ ថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ (វេលាម៉ោង ៥:៣០ នាទីល្ងាច)
- ការបិទផ្សាយបញ្ជីឈ្មោះបេក្ខជនដែលត្រូវប្រឡងសរសេរ-QCM និងសម្ភាសន៍ ថ្ងៃទី២១ ខែមករា ឆ្នាំ ២០១៧ នៅតាម លធ/ខប
- ការប្រឡងសរសេរ-QCM និងសម្ភាសន៍ ចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧ នៅតាម លធ/ខប
- លទ្ធផលនៃការប្រឡងសរសេរ-QCM និងសម្ភាសន៍ នឹងបិទផ្សាយ នៅតាម លធ/ខប។

សមាសភាព គធ.ខប ត្រូវជ្រើសរើសឡើងក្នុងចំណោមប្រជាពលរដ្ឋ ឬ/និងមន្ត្រីរាជការក្នុងរាជធានី ខេត្តដែលមានសិទ្ធិបោះឆ្នោត លើកលែងតែកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ បព្វជិត សាសនា អភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បេក្ខជនឈរឈ្មោះបោះឆ្នោតសម្រាប់សមាជិកក្រុមប្រឹក្សាទាំងនោះ មេភូមិ ជំនួយការមេភូមិ និងជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយមិនទាន់មានសិទ្ធិសម្បទាឡើងវិញ។

ប្រធាន អនុប្រធាន និងសមាជិក គធ.ខប ដែលជាសមាជិកគណបក្សនយោបាយ ឬ/និងអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬ/និងមន្ត្រីរាជការ ក្រោយពីបានទទួលការតែងតាំង ត្រូវសុំលាលែងពីសមាជិកនៃគណបក្សនយោបាយ ឬ/និងអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬ/និងត្រូវដាក់ពាក្យសុំទៅបម្រើការងារក្រៅក្របខ័ណ្ឌដើម រហូតដល់ថ្ងៃចប់ភារកិច្ច។

គធ.ខប ត្រូវមានលេខាធិការដ្ឋានមួយ ជាជំនួយការ។ នៅក្នុងដំណាក់កាលបោះឆ្នោតលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) បំពេញភារកិច្ចជាជំនួយការឲ្យ គធ.ខប ហើយត្រូវហៅថា លេខាធិការដ្ឋាននៃ គធ.ខប (លគធ.ខប)។

គ.ជ.ប ត្រូវចាត់តាំងគណៈកម្មការថ្នាក់ជាតិមួយ ដើម្បីប្រឡងជ្រើសរើសសមាសភាព គធ.ខប ប្រកបដោយលក្ខណៈបើកចំហ និងមានតម្លាភាព។ គណៈកម្មការជ្រើសរើសថ្នាក់ជាតិ មានសភាសភាពដូចជា: តំណាង គ.ជ.ប ១រូប ជាប្រធាន សមាសភាព គ.ជ.ប ១រូប ជាអនុប្រធាន សមាសភាព គ.ជ.ប ផ្សេងៗទៀត ជាសមាជិក អគ្គលេខាធិការ និងអគ្គលេខាធិការរង ជាសមាជិក។[120] គណៈកម្មការជ្រើសរើសថ្នាក់ជាតិ មានអនុគណៈកម្មការមួយចំនួនដូចជា: អនុគណៈកម្មការរៀបចំការប្រឡង អនុគណៈកម្មការកណ្តាល អនុគណៈកម្មការកំណែ អនុគណៈកម្មការផ្សេងៗទៀតតាមការចាំបាច់។

៨.១.១ ការវាយតម្លៃលើក្របខណ្ឌច្បាប់

ឆ្លងតាមរយៈនៃការសង្កេត យើងអាចវាយតម្លៃបានថា ក្របខណ្ឌច្បាប់មានលក្ខណៈល្អប្រសើរជាងក្របខណ្ឌច្បាប់កន្លង ព្រោះបានតម្រូវឲ្យជ្រើសរើសសមាសភាព គធ.ខប ប្រកបដោយលក្ខណៈបើកចំហ និងមានតម្លា ភាព។ ក្នុងន័យនេះ សមាសភាពប្រធាន និងអនុប្រធាន គធ.ខប មិនបានត្រូវតែងដោយស្វ័យប្រវត្តដោយ គ.ជ.ប នោះទេ។ គួរបញ្ជាក់ថា ការអនុវត្តន៍កន្លងមករបស់ គ.ជ.ប តំណែងប្រធាន និងអនុប្រធាន លធ.ខប ត្រូវបានតែងតាំងដោយស្វ័យប្រវត្តិដោយ គ.ជ.ប ដោយមិនឆ្លងកាត់ដំណាក់កាលជ្រើសរើស (ប្រឡង និងសម្ភាសន៍)ទេ។

បើទោះជាមានការចែងថា មន្ត្រីរាជការ ក្រោយពីបានទទួលការតែងតាំងជាប្រធាន ឬអនុប្រធាន ឬសមាជិក គធ.ខប ត្រូវដាក់ពាក្យសុំទៅបម្រើការងារក្រៅក្របខ័ណ្ឌដើម រហូតដល់ថ្ងៃចប់ភារកិច្ច។ មន្ត្រីបុគ្គលិកនៃ លធ.ខប ស្ថិតក្នុងក្របខណ្ឌជាមន្ត្រីរាជការ ដែលកំណត់ដោយព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីរាជការនៃ គ.ជ.ប។ ចំណុចទាំងនេះមិនគួរត្រូវបកស្រាយថា មន្ត្រី បុគ្គលិកនៃ លធ.ខប គួរដាក់ពាក្យបម្រើការងារក្រៅក្របខណ្ឌជាមន្ត្រីរាជការរបស់ គ.ជ.ប ហើយទៅចូលរួមក្នុងការជ្រើសរើសសមាសភាព គធ.ខប ដែលជាមន្ត្រីកិច្ចសន្យារបស់ គ.ជ.ប នោះទេ។ មន្ត្រី បុគ្គលិកនៃ លធ.ខប ជាអ្នកបច្ចេកទេសក្នុងរៀបចំ និងចាត់ចែងការបោះឆ្នោត ហើយមានភារកិច្ចជាជំនួយការឲ្យ គធ.ខប ដែលខុសពីមន្ត្រីរាជការផ្សេងទៀត ដែលមានសិទ្ធិចូលរួមក្នុងការជ្រើសរើសសមាសភាព គធ.ខប ហើយដាក់ពាក្យសុំទៅបម្រើការងារក្រៅក្របខ័ណ្ឌដើមនៅពេលខ្លួនទទួលបានតែងតាំងជា គធ.ខប។

[120] ប្រការ ១៨១ បទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប

៨.១.២ លទ្ធផលនៃការសង្កេតរបស់ខុមហ្វ្រែល

<u>គណៈកម្មការជ្រើសរើស</u>

ការសង្កេតរកឃើញថា គ.ជ.ប បានបង្កើតគណៈកម្មការ និងអនុគណៈកម្មការជ្រើសរើសដែលមានសមាសភាពចូលរួមស្របតាមបទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចរបស់ គ.ជ.ប។

<u>ការផ្សព្វផ្សាយសេចក្តីជូនដំណឹងជ្រើសរើស</u>

រយៈពេលនៃការទទួលពាក្យ ការប្រឡង និងការធ្វើតេស្តធ្វើឡើងស្របតាមសេចក្តីជូនដំណឹងរបស់ គ.ជ.ប។ ទោះជាយ៉ាងណាការសង្កេតរកឃើញថា ការផ្សព្វផ្សាយអំពីដំណឹងជ្រើសរើសភាគច្រើន គឺតាមរយៈការបិទផ្សាយនៅទីស្នាក់ការលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប)។ ទន្ទឹមគ្នានេះក៏មានបិទផ្សាយនៅក្នុងសាលាខេត្ត ក្នុងមន្ទីរពាក់ព័ន្ធមួយចំនួន និងក្នុងសាលាក្រុង ស្រុក ខណ្ឌ និងបិទផ្សាយនៅក្នុងសាលាឃុំ សង្កាត់មួយចំនួន។ ការសង្កេតឃើញថា ការបិទផ្សាយ គឺធ្វើតែនៅក្នុងទីតាំងទាំងនោះដោយមិនមែនបិទផ្សាយនៅតាមទីសាធារណៈនោះទេ ដែលការនេះ សាធារណជនទូទៅមិនបានដឹងដំណឹងនៃការបិទផ្សាយនេះទេ។ បើទោះជាមានការផ្សព្វផ្សាយខ្លះៗតាមរយៈវិទ្យុ ទូរទស្សន៍ និងតាមបណ្តាញសង្គមប៉ុន្តែដំណឹងអំពីការជ្រើសរើសនេះមិនបានផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់សាធារណជនទូទៅនោះទេ។ ការសង្កេតក៏បានរកឃើញដែរថា អ្នកដែលទទួលបានព័ត៌មានភាគច្រើន គឺជាមន្ត្រីដែលធ្លាប់បម្រើការងារនៅគណៈកម្មការរៀបចំការបោះឆ្នោតក្នុងការបោះឆ្នោតកន្លងមក និងជាមន្ត្រីរាជការ។

ជុំវិញការផ្សព្វផ្សាយនេះ តំណាងគណបក្សនយោបាយមួយចំនួនបានបញ្ចេញយោបល់ថា វាហាក់មានភាពលាក់លៀម ហើយធ្វើឡើងសម្រាប់តែបក្សពួក និងខ្សែបណ្តាយរបស់ខ្លួនប៉ុណ្ណោះ។

<u>ដំណើរការជ្រើសរើស</u>

ការសង្កេតបានរកឃើញថា បេក្ខជនដែលបានដាក់ពាក្យសម្រាប់តំណែងនីមួយៗនៃ គធ.ខប ពិសេសតំណែងប្រធានមានចំនួនតិច ដូចជា ខេត្តសៀមរាប ខេត្តកោះកុង ខេត្តឧត្តរមានជ័យ ខេត្តព្រៃវែង ខេត្តប៉ៃលិន ខេត្តត្បូងឃ្មុំ ខេត្តកំពង់ស្ពឺ ខេត្តស្ទឹងត្រែង ខេត្តក្រចេះ ខេត្តមណ្ឌលគីរី ខេត្តព្រះសីហនុ ខេត្តរតនគីរី និងខេត្តពោធិ៍សាត់។

រីឯនៅខេត្តមួយចំនួនទៀតបេក្ខជនសម្រាំងយកប្រលង និងធ្វើសម្ភាសន៍សម្រាប់តំណែងប្រធាន គធ.ខប មានតែ១រូប ហើយបេក្ខជននោះ គឺជាប្រធាន លធ.ខប ដូចជា ខេត្តកោះកុង ខេត្តឧត្តរមានជ័យ ខេត្តព្រៃវែង ខេត្តប៉ៃលិន ខេត្តត្បូងឃ្មុំ ខេត្តកំពង់ស្ពឺ ខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគីរី ខេត្តព្រះសីហនុ និងខេត្តរតនគីរី។

លទ្ធផលផ្លូវការនៃការតែងតាំងជាសមាសភាព គធ.ខប ឲ្យបម្រើការងារនៅគណៈកម្មការរៀបចំការបោះឆ្នោតក្នុងរាជធានី ខេត្តទាំង២៥ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៧ ភាគច្រើនជាមន្ត្រីចាស់ដែលកំពុង និងធ្លាប់បម្រើការងារនៅ លធ.ខប និង គធ.ខប សម្រាប់ការបោះឆ្នោតកន្លងមក។ លទ្ធផលផ្លូវការក៏បានបង្ហាញថា ប្រធាន លធ.ខប បច្ចុប្បន្នជាប់ជាប្រធាន គធ.ខប មានចំនួន២៣ រូប ដែលរួមមានក្នុងខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តកំពង់ធំ ខេត្តកំពត ខេត្តកណ្តាល ខេត្តកោះកុង ខេត្តក្រចេះ ខេត្តមណ្ឌលគីរី ខេត្តព្រះវិហារ ខេត្តព្រៃវែង ខេត្តពោធិ៍សាត់ ខេត្តរតនគីរី ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តស្ទឹងត្រែង ខេត្តស្វាយរៀង ខេត្តតាកែវ ខេត្តកែប ខេត្តប៉ៃលិន ខេត្តឧត្តរមានជ័យ និងខេត្តត្បូងឃ្មុំ។

ជុំវិញការដាក់ពាក្យរបស់បេក្ខជន អ្នកសង្កេតការណ៍បានរកឃើញថា មិនមានកាលំបាក ឬឧបសគ្គ សម្រាប់បេក្ខជនក្នុងការដាក់ពាក្យនោះទេ ហើយការសំរាំងយកបេក្ខជន គឺផ្អែកលើបទពិសោធន៍ ចំណេះដឹង និងជំនាញរបស់បេក្ខជន ហើយមានការធ្វើតេស្ត តាមរយៈការប្រឡង និងការតេស្តដោយផ្ទាល់ត្រឹមត្រូវបទបញ្ជា និងតាមសេចក្តីណែនាំរបស់ គ.ជ.ប។

ជាមួយគ្នានេះដែរ បេក្ខជនដែលបានដាក់ពាក្យប្រកួតប្រជែងមួយចំនួនធំ និងតំណាងគណបក្សនយោបាយមួយចំនួនបានបញ្ចេញទស្សនៈថា ការជ្រើសរើសសមាសភាព គធខប ប្រព្រឹត្តទៅដោយត្រឹមត្រូវ.
ហើយការជ្រើសរើសដោយផ្អែកលើសមត្ថភាព។ខណៈដែលបេក្ខជនមួយចំនួនតូច និងតំណាងគណបក្សនយោបាយខ្លះបង្ហាញទស្សនៈថា ការជ្រើសរើសហាក់មានការប្រកាន់បក្សពួក ដោយភាគច្រើនជ្រើសរើសតែអ្នកចាស់ និងមាននិន្នាការគាំទ្រគណបក្សកាន់អំណាច។ ពួកគេក៏យល់ឃើញថា គណៈកម្មការជ្រើសរើសធ្វើការហាក់មិនសូវមានតម្លាភាព ហើយដំណើរការជ្រើសរើសក៏មិនសូវមានភាពទូលំទូលាយដែរ។

ការសង្កេតឃើញថា មានការបន្ថែមពិន្ទុសម្រាប់បេក្ខជនដែលមានបទពិសោធន៍លើការគ្រប់គ្រង និងចាត់ចែងការបោះឆ្នោត។ ចំណុចនេះបានធ្វើឲ្យអ្នកថ្មីដែលមិនមានបទពិសោធន៍ការងារបោះឆ្នោតមិនមានឱកាសជាប់ជា គធ.ខប។ អ្នកសង្កេតការណ៍ខុមហ្វ្រែលក៏ពិនិត្យឃើញថា បេក្ខជនខ្លះដែលសម្រាំងយក ហាក់មិនគ្រប់លក្ខខណ្ឌដែលបានកំណត់ដោយ គ.ជ.ប។

គណៈកម្មការជ្រើសរើសមួយចំនួន បានលើកឡើងពីការលំបាកខ្លះៗដូចជា មិនសូវមានបេក្ខជនដែលមានសមត្ថភាពដាក់ពាក្យ និងពេលវេលានៃការជ្រើសរើសមានរយៈពេលខ្លី។ ទន្ទឹមគ្នានេះ គណៈកម្មការជ្រើសរើសមួយចំនួនមិនបានសហការផ្តល់ព័ត៌មានដល់អ្នកសង្កេតការណ៍របស់ខុមហ្វ្រែលទេ។

ការសង្កេតក៏រកឃើញថា សមាសភាព គធ.ខប ភាគច្រើនលើសលប់ជាបុរសដែលក្នុងចំណោមសមាសភាព គធ.ខប សរុបចំនួន១៧៥រូប គឺមានស្ត្រីតែចំនួន១៤រូបប៉ុណ្ណោះ។

ដោយឡែក ការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លីបម្រើការនៅ គធ.ខប អ្នកសង្កេតការណ៍ខុមហ្វ្រែលបានរកឃើញថា យ៉ាងហោចណាស់មានពីរខេត្ត (ខេត្តកំពង់ឆ្នាំង និងខេត្តបន្ទាយមានជ័យ) មានករណីមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លី ជាប់សាច់ញាតិនៅក្នុងគណៈកម្មការតែមួយ។

៨.១.៣ ការវាយតម្លៃលើលទ្ធផលនៃការសង្កេតរបស់ខុមហ្វ្រែល

ឆ្លងតាមរយៈនៃការសង្កេត យើងអាចវាយតម្លៃបានថាដំណើរការជ្រើសរើសសមាសភាព គធ.ខប មានលក្ខណៈល្អប្រសើរជាងការជ្រើសរើសក្នុងការបោះឆ្នោតកន្លងមក។ គណៈកម្មការជ្រើសរើសបានអនុវត្តតាមលក្ខខណ្ឌដែលកំណត់ដោយបទបញ្ជាហើយការធ្វើតេស្តប្រឡងនិងសម្ភាសន៍គ្រប់បេក្ខជនសម្រាំងយក។

ប៉ុន្តែទន្ទឹមនឹងនេះ ការសង្កេតក៏រកឃើញនូវចំណុចខ្វះខាតមួយចំនួនដូចជា អ្នកទទួលព័ត៌មានពីការផ្សព្វផ្សាយដំណឹងជ្រើសរើសនៅមានកម្រិត ព្រោះការផ្សព្វផ្សាយមិនបានទូលំទូលាយ ឱកាសទទួលបានការងារតិចតួចសម្រាប់បេក្ខជនថ្មី ព្រោះអ្នកជាប់ភាគច្រើន គឺអ្នកចាស់ ពិសេសតំណែងប្រធាន កម្រិតនៃការចូលរួមពីបេក្ខជនជាស្ត្រី និងការនៅមិនទាន់ជឿទុកចិត្តអំពីតម្លាភាពរបស់គណៈកម្មការជ្រើសរើសពីភាគីពាក់ព័ន្ធជាដើម។

៨.២ ការជ្រើសរើសគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត(គឃ.សប)

សម្រាប់ការជ្រើសរើសគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) វិញ គ.ជ.ប បានប្រកាសជ្រើសរើសចំនួន ៨.២៣០រូប និងជំនួយការ គឃ.សប ចំនួន ៣៣រូប (សម្រាប់ឃុំ សង្កាត់មួយចំនួន) ជាមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លី ដើម្បីបម្រើការងារបោះឆ្នោតនៅតាម គឃ.សប។

ការវាយតម្លៃលើកក្របខណ្ឌច្បាប់ឃើញថា មានលក្ខណៈល្អប្រសើរជាងក្របខណ្ឌច្បាប់កន្លងមក ដូចនឹងការជ្រើសរើសសមាសភាព គធ.ខប ដែរ។

ចំពោះដំណើរការនៃការជ្រើសរើស អ្នកសង្កេតការណ៍របស់ខុមហ្វ្រែល បានរកឃើញនូវចំណុចវិជ្ជមាន និងចំណុចអវិជ្ជមានមួយចំនួនដូចជា:

- មានបង្កើតគណៈកម្មការ និងអនុគណៈកម្មការជ្រើសរើសដែលមានសមាសភាពចូលរួមស្របតាមបទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចរបស់ គ.ជ.ប។
- គណៈកម្មការ និងអនុគណៈកម្មការជ្រើសរើសបានអនុវត្តតាមជំហាននៃការជ្រើសរើស។
- មានចុះពិនិត្យដំណើរការជ្រើសរបស់គណៈកម្មការ និងអនុគណៈកម្មការពីសមាជិក គ.ជ.ប និងមន្ត្រីជាន់ខ្ពស់របស់ គ.ជ.ប។
- ការផ្សព្វផ្សាយអំពីដំណឹងជ្រើសរើសមិនសូវទូលំទូលាយ (ភាគច្រើន គឺតាមរយៈការបិទផ្សាយ) ដែលសាធារណៈទូទៅមិនសូវទទួលបានព័ត៌មាន។ អ្នកទទួលព័ត៌មានភាគច្រើនគឺអ្នកចាស់ និងជាមន្ត្រីរាជការ ហើយទទួលព័ត៌មានតាមរយៈខ្សែរបណ្តោយរបស់ខ្លួន។

- បេក្ខជនដាក់ពាក្យ និងសម្រាំងយកមានចំនួនតិចនៅតាមគណៈកម្មការជ្រើសរើសមួយចំនួន។ ការជ្រើសរើសនៅឃុំ សង្កាត់ខ្លះ បេក្ខជនដាក់ពាក្យមានតែ៥រូបហើយជ្រើសយកទាំងអស់តែម្តង។
- ការជ្រើសរើសហាក់មានការប្រកាន់បក្សពួក ដោយភាគច្រើនជ្រើសរើសតែអ្នកចាស់ (ប្រមាណ ៧០%) និងមាននិន្នាការគាំទ្រគណបក្សកាន់អំណាច។
- គណៈកម្មការ និងអនុគណៈកម្មការជ្រើសរើសមួយចំនួនមិនបានផ្តល់កិច្ចសហការក្នុងការផ្តល់ព័ត៌មានទាក់ទងនឹងការជ្រើសរើសដល់អ្នកសង្កេតការណ៍។
- មានការជ្រើសរើសយកបេក្ខជនជាប់ទៅបំរើការងារខុសពីមុខតំណែង ដែលបេក្ខជននោះបានដាក់ និងមានការសាកសួរពីអាជ្ញាធរស្រុកចំពោះបេក្ខជនដែលសំរាំងយកទៅសម្ភាសន៍អំពីការគាំទ្រ និងនិន្នាការនយោបាយ (ករណីទាំងនេះកើតមានឡើងនៅខេត្តកំពង់ឆ្នាំង)។
- មានការសម្រេចតែងតាំងជាសមាជិក គឃ/សប ជាសាច់ញាតិ បងប្អូនបង្កើត ឬឪពុក ឬម្តាយ ឬកូន ឬប្តី ឬប្រពន្ធនៅក្នុងគណៈកម្មការតែមួយ។
- យ៉ាងហោចណាស់ក៏មានការប្តឹងជំទាស់ទៅនឹងលទ្ធផលកំណែរបស់បេក្ខជន១ករណីនៅខេត្តព្រះវិហារ។
- ការជ្រើសរើសហាក់មានរយៈពេលខ្លី ព្រោះថា បេក្ខជនដែលត្រូវបានជ្រើសរើសយក ត្រូវបានហៅចូលរួមវគ្គបណ្តុះបណ្តាលពី គធ/ខប នៅមុនការប្រកាសលទ្ធផលជ្រើសរើសជាផ្លូវការ និងទទួលបានការតែងតាំងពី គ.ជ.ប។

៨.៣ ការជ្រើសរើសគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (គកប/គករ)

ដំណើរការជ្រើសរើសមន្ត្រី គកប/គករ មិនមានភាពខុសប្លែកគ្នាពីដំណើរការជ្រើស គធ/ខប និង គឃ/សប ទេ។ ការសង្កេតបានរកឃើញថា ដំណើរការជ្រើសរើស មានលក្ខណៈល្អប្រសើរជាងការជ្រើសរើសក្នុងការបោះឆ្នោតកន្លងមក។ គណៈកម្មការជ្រើសរើសបានអនុវត្តតាមលក្ខខណ្ឌដែលកំណត់ដោយសេចក្តីណែនាំ បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប។ ការជ្រើសរើសមានការបើកចំហ ហើយបេក្ខជនត្រូវឆ្លងកាត់ការធ្វើតេស្តប្រឡង និងការសម្ភាសន៍។

ប៉ុន្តែទន្ទឹមនឹងនេះ ការសង្កេតក៏រកឃើញនូវចំណុចខ្វះខាតមួយចំនួនដូចជា អ្នកទទួលព័ត៌មានពីការផ្សព្វផ្សាយដំណឹងជ្រើសរើសនៅមានកម្រិត ព្រោះការផ្សព្វផ្សាយមិនបានទូលំទូលាយ និងមិនសូវមានបេក្ខជនដាក់ពាក្យនៅតាមការិយាល័យក្នុងឃុំ សង្កាត់មួយចំនួន ក្នុងខេត្តមណ្ឌលគីរី ខេត្តរតនគីរី ខេត្តប៉ៃលិន ខេត្តព្រះវិហារ និងខេត្តកំពង់ឆ្នាំង។ ជាមួយគ្នានេះ អ្នកជាប់បម្រើការងារភាគច្រើន គឺអ្នកចាស់ ពិសេសតំណែងប្រធាន គកប/គករ ហើយជាមន្ត្រីរាជការ ដែលមានការសង្ស័យពីទំនាក់ទងជាមួយអាជ្ញាធរ និងគណបក្សកាន់អំណាច។ ម្យ៉ាងវិញទៀត ក៏មានមន្ទិលសង្ស័យអំពីភាគីពាក់ព័ន្ធលើតម្លាភាពក្នុងការសំរាំងយកបេក្ខជនសម្រាប់ការប្រឡង និងសម្ភាសន៍ផងដែរ។

៩. ការគ្រប់គ្រងការបោះឆ្នោត

៩.១ ការចុះឈ្មោះបោះឆ្នោត

ក្រោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៥ ឆ្នាំ២០១៣ ស្ថាប័នគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) ត្រូវបានកែទម្រង់ឡើងវិញ ជាពិសេសការរៀបចំបញ្ជីឈ្មោះបោះឆ្នោតថ្មី ក្រោមកិច្ចព្រមព្រៀងនៃគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភានៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤។ ឆ្នាំ ២០១៦ គ.ជ.ប បានចុះឈ្មោះបោះឆ្នោតថ្មី ដោយធ្វើការប៉ាន់ស្មានអ្នកមានសិទ្ធិចុះឈ្មោះបោះឆ្នោតប្រមាណ ចំនួន ៩,៦៦៤,២១៦នាក់ ដោយបានចុះឈ្មោះបានចំនួន ៧,៨៦៥,០៣៣នាក់ ស្មើនឹង ៨១.៣៨%។ តួលេខក្នុងការប៉ាន់ស្មាននេះ គឺមានចំនួនប្រហាក់ប្រហែលតួលេខប៉ាន់ស្មានក្នុងឆ្នាំ២០១៣ ដែលមានចំនួន ៩,៦៧៥,៤៥៣នាក់។ ទោះបីយ៉ាងណា មិនមានសេចក្តីរាយការណ៍ណាមួយដែលបង្ហាញ និងពន្យល់ពីតួលេខ គ.ជ.ប ដែលមានចំនួនប្រហាក់ប្រហែលគ្នានេះទេ។ ការចុះឈ្មោះបោះឆ្នោតថ្មី ត្រូវបានរៀបចំចុះដោយប្រើប្រាស់កុំព្យូទ័រដែលមានថតរូបថត និងមានផ្ទៃតស្មាមមេដៃ ជាមួយលិខិតខ្ទង់ឯកសារជាគោល គឺប្រើប្រាស់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ(អ.ខ) ឬឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់ការចុះឈ្មោះបោះឆ្នោត(ឯ.អ)។ ក្នុងការចុះឈ្មោះបោះឆ្នោតថ្មី ការកែទម្រង់ថ្មីមិនត្រូវបានប្រើប្រាស់សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ឬស្មៀនឃុំសង្កាត់ជាអ្នកទទួលខុសត្រូវនោះទេ គឺ គ.ជ.ប ជាអ្នកទទួលខុសត្រូវ ដោយមានក្រុមការងារសម្រាប់ចុះឈ្មោះ ៣នាក់ និងចំនួនច្រើនតាមឃុំសង្កាត់ ដែលមានស្ថិតិប្រជាពលរដ្ឋគ្រប់អាយុតិច ឬច្រើន។ ក្រុមការងារចុះឈ្មោះបោះឆ្នោត បានរៀបចំចុះនៅក្នុងឃុំសង្កាត់ចំនួន ១៦៣៣ ដែលត្រូវប្រើប្រាស់សំភារៈសម្រាប់ចុះឈ្មោះចំនួន ២៤០០សម្រាប់[121] ជាមួយថវិកាចំណាយសម្រាប់ចុះឈ្មោះអស់ចំនួន ២៣លានដុល្លារអាមេរិក។

នៅក្នុងដំណើរការចុះឈ្មោះបោះឆ្នោតថ្មីឆ្នាំ២០១៦នេះ មានភ្នាក់ងារគណបក្សនយោបាយចំនួន៩ និងអ្នកសង្កេតការណ៍មកពី សមាគម អង្គការមិនមែនរដ្ឋាភិបាល ចំនួន៧ ដែលបានចូលរួមសង្កេត។ ក្នុងដំណើរការសង្កេតការណ៍ចុះឈ្មោះបោះឆ្នោត មានភ្នាក់ងារគណបក្សនយោបាយចំនួន២ គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ បានដាក់ភ្នាក់ងារគ្រប់ឃុំ សង្កាត់។ ក្នុងចំណោមអ្នកសង្កេតការណ៍របស់សមាគម និងអង្គការក្រៅរដ្ឋាភិបាល ខុមហ្វ្រែលសហការជាមួយសម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត បានដាក់ពង្រាយអ្នកសង្កេតការណ៍ចំនួន៩៤៧នាក់ នៅក្នុងឃុំសង្កាត់ចំនួន៩៤៧ ផងដែរ។

តាមរយៈរបាយការណ៍សវនកម្មបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៦ ខុមហ្វ្រែលបានធ្វើការសន្និដ្ឋានថា បញ្ជីឈ្មោះបោះឆ្នោតថ្មីឆ្នាំ២០១៦ ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៤ ឆ្នាំ២០១៧ ឃើញថា មានភាពត្រឹមត្រូវ និងមានគុណភាពខ្ពស់ បើប្រៀបធៀបជាមួយបញ្ជីឈ្មោះមុនឆ្នាំ

[121] Each set contains a computer, fingerprint scanner, camera, battery backup/power bank, and a modem.

២០១៥។ ការរកឃើញរបស់សវនកម្មបានបង្ហាញទៀតថា ៨៩.៣ភាគរយ នៃអ្នកមានសិទ្ធិចុះឈ្មោះបោះឆ្នោតដែលមានវត្តមាននៅក្នុងប្រទេសបានចុះឈ្មោះ និងមានឈ្មោះនៅក្នុងបញ្ជីឈ្មោះបោះឆ្នោត។ ភាយនៃចំនួនអ្នកចុះឈ្មោះរបស់ គ.ជ.ប មាន ៨១.៣៨ភាគរយខុសពីភាគរយដែលខុមហ្វ្រែលបានរកឃើញ ព្រោះដោយសារការសិក្សាគិតពីចំនួនអ្នកមានវត្តមាននៅក្នុងស្រុក។ នេះបង្ហាញថា គ.ជ.ប ត្រូវតែយកចិត្តទុកដាក់ជាមួយប្រជាពលរដ្ឋដែលធ្វើចំណាកស្រុកនៅឯក្រៅប្រទេសបន្ថែមទៀត ដើម្បីឱ្យពួកគាត់មានលទ្ធភាពបានចុះឈ្មោះបោះឆ្នោត។

ការសិក្សាបានបន្ថែមទៀតថា ប្រជាពលរដ្ឋដែលមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតថ្មីឆ្នាំ២០១៦ មានចំនួន៩៨ភាគរយ បានរកឃើញវត្តមានតាមអាសយដ្ឋាន ឈ្មោះ និងផ្ទៀតផ្ទាត់រូបថតថា ត្រឹមត្រូវ។ រីឯ ២ ភាគរយ គឺមិនមានប្រជាពលរដ្ឋ ឬអាជ្ញាធរណាម្នាក់អាចបញ្ជាក់បានថា គាត់រស់នៅទីកន្លែងដូចក្នុងអាសយដ្ឋានក្នុងបញ្ជីឈ្មោះ ឬមកពីណានោះទេ។

ទោះបីបញ្ជីឈ្មោះបោះឆ្នោតមានភាពល្អប្រសើរ ក៏ប៉ុន្តែនៅក្នុងដំណើរការចុះឈ្មោះបោះឆ្នោត ខុមហ្វ្រែលបានរកឃើញថា មានភាពមិនប្រក្រតីមួយចំនួនដែលបានកើតឡើង ដូចជាការផ្តិតស្នាមមេដៃមិនត្រឹមត្រូវ អ្នកចុះឈ្មោះបោះឆ្នោតមិនបានទទួលបង្កាន់ដៃនៃការចុះឈ្មោះបោះឆ្នោត ការបញ្ចូលទិន្នន័យខុសពិសេសបញ្ហារអាក់រអួលក្នុងការបញ្ចូនទិន្នន័យពីនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីឈ្មោះបោះឆ្នោត។

ដោយយល់ឃើញពីភាពមិនប្រក្រតីអំពីបញ្ជីឈ្មោះបោះឆ្នោត អនុសាសន៍របស់សង្គមស៊ីវិល និងគណបក្សនយោបាយមួយចំនួន ដែលស្នើសុំ គ.ជ.ប ធ្វើការបិទផ្សាយនៅតាមភូមិមុនការបោះឆ្នោត។ ការបិទផ្សាយនេះ គឺបានជួយឲ្យអ្នកបោះឆ្នោតមានពេលវេលាច្រើនក្នុងការពិនិត្យឈ្មោះរបស់ខ្លួន ដែលជួយសម្រួលដល់អ្នកបោះឆ្នោត ក៏ដូចជាមន្ត្រីការិយាល័យនៅថ្ងៃបោះឆ្នោត។ ប៉ុន្តែគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានធ្វើកែសម្រួលនីតិវិធីក្នុងការបិទផ្សាយបញ្ជីបោះឆ្នោត ដោយបានធ្វើការបិទផ្សាយបញ្ជីនេះជាសាធារណៈរយៈពេលដប់ថ្ងៃ (ចាប់ពីថ្ងៃទី៣ ខែមករា ដល់ថ្ងៃទី១៧ខែមករា ឆ្នាំ២០១៧) នៅសាលាឃុំ/សង្កាត់។ ទោះជាយ៉ាងនេះក្តី ការសង្កេតឃើញថា ការបិទផ្សាយនៅសាលាឃុំសង្កាត់ ហាក់មិនសូវមានប្រសិទ្ធិភាពទេ ព្រោះថា មានអ្នកបោះឆ្នោតតិចតួច(ប្រហែល៣០ភាគរយ) បានទៅពិនិត្យឈ្មោះរបស់ខ្លួន។ មូលហេតុចំបង។ នៃការមិនសូវចាប់អារម្មណ៍ទៅពិនិត្យឈ្មោះរបស់អ្នកបោះឆ្នោតរួមមានដូចជា ការផ្សព្វផ្សាយមិនបានទូលំទូលាយ ដែលធ្វើឲ្យប្រជាពលរដ្ឋភាគច្រើនមិនបានចាប់អារម្មណ៍ និងមិនបានទទួលព័ត៌មាន។

ជុំវិញបញ្ជីបោះឆ្នោតនេះដែរ ការសង្កេតឃើញថា ការដាក់បង្ហោះនៅគេហទំព័រ គ.ជ.ប ដែលមានអាស័យដ្ឋាន www.voterlist.org.kh គឺបានជួយសម្រួលច្រើនដល់អ្នកបោះឆ្នោត ដែលមានលទ្ធភាពប្រើប្រាស់អ៊ិនធឺណែតក្នុងការស្វែងរកឈ្មោះរបស់ខ្លួន និងក្រុមខ្លួនដែលវាមានភាពឆាប់រហ័ស និងងាយស្រួល ដោយ

មិនចាំបាច់ធ្វើដំណើរទៅពិនិត្យនៅសាលាឃុំ/សង្កាត់។ ក្នុងការបោះឆ្នោតឆ្នាំ២០១៧ គេហទំព័រសំរាប់ស្វែងរកឈ្មោះក្នុងបញ្ជីមិនត្រូវបានបិទដូចការបោះឆ្នោត ឆ្នាំ២០១៣ នោះទេ។

៩.១.១ បញ្ជីឈ្មោះបោះឆ្នោតថ្មី និងការចុះឈ្មោះបោះឆ្នោត

ការចុះឈ្មោះបោះឆ្នោត និងរៀបចំបញ្ជីឈ្មោះថ្មីឆ្នាំ២០១៦ ត្រូវបានធ្វើឡើងចាប់តាំងពីថ្ងៃទី១ ខែកញ្ញា ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦។

គ.ជ.ប បានរៀបចំក្រុមការងារចុះឈ្មោះបោះឆ្នោត ដែលស្ថិតក្រោមការជួយសម្របសម្រួលរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ គ.ជ.ប បានរៀបចំក្រុមចុះឈ្មោះនៅក្នុងឃុំ សង្កាត់ចំនួន ១,៦៣៣ក្រុម (មួយឃុំ សង្កាត់ គឺមួយក្រុម) ដែលក្រុមនិមួយៗ មានសមាជិកចំនួន៣នាក់ និងលើសពីនេះតាមចំនួនអ្នកមានសិទ្ធិចុះឈ្មោះបោះឆ្នោតតិច ឬច្រើន។ គ.ជ.ប បានធ្វើការប៉ាន់ប្រមាណប្រជាពលរដ្ឋដែលមានសិទ្ធិចុះឈ្មោះបោះឆ្នោតក្នុងឆ្នាំ២០១៦នេះ ចំនួនប្រមាណ ៩,៦៦៤,២១៦នាក់។ គ.ជ.ប បានផ្តល់សុពលភាពបញ្ជីបោះឆ្នោតថ្មីជាផ្លូវការនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៦ ដោយមានអ្នកបោះឆ្នោតចំនួន ៧,៨៦៥,០៣៣នាក់ ដែលបានចុះឈ្មោះក្នុងបញ្ជីលើការិយាល័យបោះឆ្នោត ចំនួន ២២,១៤៨។ ការប៉ាន់ប្រមាណអ្នកមានសិទ្ធិចុះឈ្មោះបោះឆ្នោតនេះ ត្រូវបាន គ.ជ.ប ទម្លាក់ចំនួន ៩,៦៧៥,៤៥៣នាក់(បញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១២ សម្រាប់ការបោះឆ្នោតឆ្នាំ២០១៣) មកត្រឹម ៩,៦៦៤,២១៦នាក់ សម្រាប់ការបោះឆ្នោតឆ្នាំ២០១៧។

តារាងទី១១ អ្នកបានចុះឈ្មោះបោះឆ្នោត និងអ្នកបានបោះឆ្នោតក្នុងការបោះឆ្នោតឆ្នាំ១៩៩៣ ដល់ ២០១៧

ឆ្នាំបោះឆ្នោត	អ្នកបានចុះឈ្មោះបោះឆ្នោត	អ្នកបានបោះឆ្នោត	អ្នកបានបោះឆ្នោតធៀបអ្នកបានចុះឈ្មោះបោះឆ្នោត
1993	4,764,430	4,267,192	89.56%
1998	5,395,595	5,057,830	93.74%
2003	6,341,834	5,277,494	83.22%
2008	8,125,529	6,110,828	75.21%
2012	9,203, 493	5,993,992	65.13%
2013	9,675,453	6,735,244	69.61%
2017	7,865,033	7,107,395	90.37%

រូបភាពទី១៤ ភាគរយនៃអ្នកចេញទៅបោះឆ្នោតធៀបជាមួយអ្នកបានចុះឈ្មោះបោះឆ្នោត



សវនកម្មបញ្ជីឈ្មោះបោះឆ្នោតមួយត្រូវបានធ្វើឡើងដោយអង្គការខុមហ្រ្វែល និងបានដាក់ពង្រាយអ្នកសង្កេតការណ៍ចំនួន២៥២នាក់ ដើម្បីចុះសម្ភាសន៍ប្រជាពលរដ្ឋចំនួន៥៣៨០នាក់(វិធីសាស្ត្រពីមនុស្សទៅបញ្ជីចំនួន២៦៩០នាក់ និងពីបញ្ជីទៅមនុស្សចំនួន២៦៩០នាក់) ក្នុងការិយាល័យចំនួន៥៣៨ ត្រូវជា ៥១៤ ភូមិ (វិធីសាស្ត្រនិមួយៗ មាន២៦៩ការិយាល័យ) ដែលគ្របដណ្តប់ក្នុងឃុំ សង្កាត់ចំនួន២៥២ ក្នុង២៥រាជធានី ខេត្ត។

ជាលទ្ធផលបានរកឃើញថា ប្រជាពលរដ្ឋចំនួន៨៩.៣ភាគរយនៃប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត និងមានវត្តមានក្នុងប្រទេសមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតថ្មីឆ្នាំ២០១៦ ជាមួយលទ្ធផលដែលបានប្រកាសជាផ្លូវការដោយ គ.ជ.ប គឺ ៨១.៣៨ភាគរយ។ សវនកម្មនេះបានបង្ហាញទៀតថា ៩៨ភាគរយនៃឈ្មោះដែលមាននៅក្នុងបញ្ជីឈ្មោះបោះឆ្នោតថ្មីត្រូវបានផ្ទៀងផ្ទាត់ និងរកឃើញ។ ម៉្យាងទៀត គុណភាពនៃបញ្ជីឈ្មោះបោះឆ្នោត បង្ហាញទៀតថា ៩៣.៧ភាគរយ មានទិន្នន័យថ្ងៃខែឆ្នាំកំណើត ភេទ ឈ្មោះ ដូចគ្នា។ ទោះបីយ៉ាងណា ៦.៣ភាគរយ ដែលមានទិន្នន័យខុសគ្នាត្រង់ចំណុចខ្លះនោះ វាមិនបណ្តាលឱ្យបាត់បង់សិទ្ធិនោះទេ ព្រោះគ.ជ.ប និង ចេញគោលការបន្ថែមទៀតក្នុងថ្ងៃបោះឆ្នោត។

ការចុះឈ្មោះបោះឆ្នោតថ្មីឆ្នាំ២០១៦ បានបង្ហាញពីភាពល្អប្រសើរនៃគុណភាពបញ្ជីឈ្មោះបោះឆ្នោតដែលអាចធានាការបាត់បង់សិទ្ធិប្រជាពលរដ្ឋ ការបាត់ឈ្មោះ ឈ្មោះស្ទួនជាដើម ដែលខុសពីបញ្ជីឈ្មោះកាលពីមុន។ ទោះជាយ៉ាងនេះ ភាពមិនប្រក្រតីតិចតួចត្រូវបានរកឃើញផងដែរ គឺការបញ្ជូនឈ្មោះយឺត ឬការបាត់ឈ្មោះមួយចំនួនដែលមិនទាន់បញ្ជូនដល់នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីឈ្មោះបោះឆ្នោត ពេលចេញបញ្ជីឈ្មោះដំបូង។ ជាមួយករណីបញ្ជូនឈ្មោះយឺតចំនួន២៣១៨ឈ្មោះ គ.ជ.ប បានបញ្ជាក់ថា គឺបណ្តាលមកពីកំហុសមន្ត្រីការីកុំព្យូទ័រមួយផ្នែក ដែលធ្វើការមានចន្លោះប្រហោង ព្រមទាំងចំណេះដឹងមានកម្រិត និងមួយផ្នែកទៀត គឺបណ្តាលមកពីសេវាអ៊ីនធឺណិត។ រីឯករណីបាត់ឈ្មោះវិញ ក៏បណ្តាលមកពីក្រុមចុះឈ្មោះមិនបានធ្វើឱ្យត្រឹមត្រូវតាមការណែនាំ ដូចជានៅខាងខេត្តត្បូងឃ្មុំ និងខេត្តបន្ទាយមានជ័យ

ដែលបានប្តឹងដោយគណបក្សនយបាយ និងក្រុមប្រឹក្សាឃុំសង្កាត់។ ករណីបាត់ឈ្មោះនេះ គ.ជ.ប ក៏មិនទាន់ដឹងច្បាស់ថា តើមានបាត់បង់នៅកន្លែងណាទៀតដែរ ព្រោះថា គ.ជ.ប មិនទទួលខុសត្រូវចំពោះឈ្មោះដែលបាត់ ជាមួយប្រជាពលរដ្ឋដែលមិនបានមកប្តឹងតវ៉ា ក្នុងអំឡុងពេលបិទបញ្ជីឈ្មោះឯដំបូងនោះ។ បញ្ហាដែលមិនអាចគ្រប់គ្រងបានពីទិន្នន័យដែលបាត់បង់នេះ គឺបណ្តាលមកពីប្រព័ន្ធរៀបចំត្រួតពិនិត្យរបស់នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីឈ្មោះបោះឆ្នោតមិនបានធ្វើការផ្ទៀងផ្ទាត់ចំនួនទិន្នន័យ ដែលធ្វើតាមរយៈសេវាអ៊ីនធឺណិត ជាមួយចំនួនតួលេខដែលបានបូកសរុបប្រចាំថ្ងៃដោយក្រុមចុះឈ្មោះបោះឆ្នោតជាមួយគ្នា។ ខុមហ្វ្រែលក៏បានរកឃើញមានឈ្មោះស្ងួនមួយចំនួន ក្នុងបញ្ជីឈ្មោះបោះឆ្នោត និងបានដាក់ឈ្មោះទាំងនោះទៅ គ.ជ.ប ដើម្បីពិនិត្យបន្ថែម។ ទាក់ទងបញ្ហានេះ នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីឈ្មោះបោះឆ្នោត ក៏បានបង្ហាញពីបញ្ហាទាក់ទងឈ្មោះស្ងួន និងភាពមិនប្រក្រតីនៃទិន្នន័យផងដែរ ដែលមានចំនួន១៩,៣១២នាក់ ប្រហែល៣ភាគរយនៃទិន្នន័យសរុប។ ការរកឃើញនេះ គ.ជ.ប បានលុបឈ្មោះចោលជាង ៣ពាន់នាក់ គឺដោយសារឈ្មោះទាំងនោះចុះជាច្រើនកន្លែង និងមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររួមទាំងទិន្នន័យដូចគ្នាផងដែរ។ តាមពិតប្រព័ន្ធទិន្នន័យចុះឈ្មោះបោះឆ្នោត មិនត្រូវបានអនុញ្ញាតឱ្យចុះឈ្មោះស្ងួនឡើយ ការចុះឈ្មោះស្ងួននេះ គ.ជ.ប បានបញ្ជាក់ថាបណ្តាលមកពីការចុះឈ្មោះសាកល្បង ការផ្លាស់ប្តូរទីលំនៅ ការផ្ទេរកន្លែងចុះឈ្មោះ ពីរនាក់ប្រើប្រាស់អត្តសញ្ញាណប័ណ្ណតែមួយ និងមនុស្សម្នាក់ប្រើប្រាស់ឯកសារបញ្ជាក់អត្តសញ្ញាណពីរ។ ទោះបីយ៉ាងណាក៏ដោយ គ.ជ.ប បានសម្រេចចិត្តលុបឈ្មោះស្ងួនដែលបានបង្ហាញដូចករណីខាងលើ និងបញ្ចូលឈ្មោះបន្ថែមចំពោះទិន្នន័យដែលបាត់បង់ក្នុងប្រព័ន្ធទិន្នន័យ ដែលបានរកឃើញ នឹងដាក់បញ្ចូលទៅក្នុងបញ្ជីផ្លូវការឆ្នាំ២០១៦ សម្រាប់ការបោះឆ្នោតឆ្នាំ២០១៧។

បន្ថែមលើបញ្ហាទាំងនេះ ខុមហ្វ្រែលបានសង្កេតឃើញទៀតថា ព្រះសង្ឃនៅតែមានបញ្ហាប្រឈមក្នុងការចុះឈ្មោះបោះឆ្នោតផងដែរ ព្រោះថាព្រះសង្ឃនិមន្តមកចុះឈ្មោះចំនួនតិចតួចណាស់ បើប្រៀបធៀបជាមួយចំនួនព្រះសង្ឃសរុបទូទាំងប្រទេសប្រហែលចំនួន៥ម៉ឺនអង្គ (យោងតាមព័ត៌មានរបស់វិទ្យុអាស៊ីសេរី ព្រះសង្ឃតែជាង៨ពាន់៨រយអង្គបានចុះឈ្មោះបោះឆ្នោតតាមឃុំសង្កាត់)។ បញ្ហាចំពោះព្រសង្ឃ គឺខុមហ្វ្រែលសង្កេតឃើញថា បណ្តាលមកពីការហាមប្រាមរបស់មន្ត្រីសង្ឃជាន់ខ្ពស់កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលហាមព្រះសង្ឃមិនឱ្យជាប់ពាក់ព័ន្ធរឿងនយោបាយ ព្រមទាំងមិនទាន់លុបចោលសង្ឃប្រកាសនៅឡើយ។ ម្យ៉ាងទៀត ព្រះសង្ឃព្រះអង្គមិនមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដែលជាឯកសារចម្បងបម្រើឱ្យការចុះឈ្មោះបោះឆ្នោត និងមិនត្រូវបានចេញដោយក្រសួងមហាផ្ទៃ ជាពិសេសពិបាកក្នុងការទៅបញ្ជាក់ឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់ការចុះឈ្មោះបោះឆ្នោត ដែលតម្រូវឱ្យមានសាក្សី និងសំបុត្រកំណើត។

សម្រាប់ការិយាល័យចុះឈ្មោះបោះឆ្នោត ខុមហ្វ្រែលបានសង្កេតឃើញថា ការិយាល័យមួយចំនួនបានបង្កើតឡើងប្រើប្រាស់សម្រាប់តែប៉ូលិស និងទាហាន ដែលអាចត្រូវបកស្រាយជាបញ្ហាទាក់ទិននយោបាយក្នុងឃុំសង្កាត់ទាំងនោះ ដូចជាការិយាល័យ១០២៦ ដែលមាននៅក្នុងទីតាំងភូមិស្លាបក្តោង ឃុំជប់ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ដែលប្រើប្រាស់សម្រាប់តែការចុះឈ្មោះឲ្យតែទាហានចំនួន៣០០(បីរយ)នាក់ ទោះបីទីនោះមានប្រជាពលរដ្ឋរស់នៅជាមួយក៏ដោយ។ បញ្ហានេះធ្វើឲ្យមានការជជែកគ្នា រវាងក្រុមប្រឹក្សាឃុំសង្កាត់ដែលមកពីគណបក្សប្រជាជន និងគណបក្សសង្គ្រោះជាតិ រហូតមានការតវ៉ាគ្នា ក្រោយមកក៏មានការ

បើកឲ្យប្រជាពលរដ្ឋដែលរស់នៅទីនោះចូលរួមចុះឈ្មោះជាមួយគ្នាវិញ។ គួរឲ្យកត់សម្គាល់ផងដែរថា ភូមិនេះ កាលពីការបោះឆ្នោតឆ្នាំ២០១២ គណបក្សប្រជាជនទទួលបានសម្លេង៥១៦៣សម្លេង និងគណបក្សសង្គ្រោះជាតិទទួលបាន៣១៦៦សម្លេង (សមរង្ស៊ី១៥៦៣សម្លេង និងសិទ្ធិមនុស្ស១៦០៣សម្លេង)។ តែលទ្ធផលការបោះឆ្នោតក្នុងឆ្នាំ២០១៣ គឺគណបក្សប្រជាជនទទួលបាន៤១៨៤សម្លេង និងគណបក្សសង្គ្រោះជាតិទទួលបាន៥៤២២សម្លេង។

ឧទាហរណ៍មួយទៀត នៅក្នុងខេត្តកំពង់ឆ្នាំង នៅភូមិថ្លុកឫស្សី ឃុំសេដ្ឋី មានការិយាល័យលេខ ០៧៨០ គឺត្រូវបានបំបែកចេញពីការិយាល័យ០៦២៤ សំរាប់ទាហាន និងក្រុមគ្រួសារ និងប្រជាពលរដ្ឋមានចំនួនភាគតិច តែនៅក្នុងឃុំនេះមានការិយាល័យជាច្រើនទៀតមិនទាន់គ្រប់ចំនួនអ្នកចុះឈ្មោះនៅឡើយទេ ដូចជាការិយាល័យលេខ០៦១៦, ០៦១៧, ០៦១៤, ០៦១៥, ០៦២៥ និង០៦២២ ដែលមានចម្ងាយក្រោម ២គីឡូម៉ែត្រពីបន្ទាយ និងមានប្រជាពលរដ្ឋគ្រប់ចុះឈ្មោះមិនលើសពី៤០០(បួនរយ)នាក់ ក្នុងការិយាល័យនិមួយៗ។ ការស្នើសុំបង្កើតការិយាល័យនេះ ក្រោមហេតុផលពីស្មៀន និងក្រុមប្រឹក្សាឃុំសង្កាត់គ្រាន់តែបានបញ្ជាក់ថា មានទាហាន និងក្រុមគ្រួសាររបស់ពួកគេអាចចុះឈ្មោះច្រើន។ បើមើលនូវលទ្ធផលប្រកួតប្រជែងក្នុងការបោះឆ្នោតឆ្នាំ២០១៣ បង្ហាញថា សម្លេងគណបក្សទាំងពីរ គឺគណបក្សប្រជាជនកម្ពុជា(មានសម្លេង ១៨៣១សម្លេង) និងគណបក្សសង្គ្រោះជាតិ(ទទួលបាន១៨៤០សម្លេង) មានសម្លេងប្រកៀកគ្នា។

នៅក្នុងខេត្តកំពង់ឆ្នាំងនេះដដែលក៏មានការបង្កើតការិយាល័យថ្មីមួយទៀតលេខ០៧៨១ គឺជាការស្នើសុំរបស់ក្រុមប្រឹក្សាឃុំ ដែលបានដាក់សំណើតាំងពីមុនការចុះឈ្មោះបោះឆ្នោតមកម្ល៉េះ តែ គ.ជ.ប មិនបានផ្តល់អោយ លុះដល់ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ទើបមានការអនុញ្ញាតជាផ្លូវការនៅក្នុងកុំព្យូទ័រ។ តាមការបញ្ជាក់ពីមេឃុំ ការបង្កើតការិយាល័យថ្មីនេះ ដោយសារតែមានភូមិទើបបង្កើតថ្មី គឺភូមិក្តុលអភិវឌ្ឍន៍នៅដាច់ឆ្ងាយពីភូមិផ្សេងៗ និងការិយាល័យបោះឆ្នោតចាស់ដែលស្ថិតនៅក្នុងឃុំស្វាយជុកប្រហែល២៧គីឡូម៉ែត្រ ហើយការិយាល័យនេះនៅជាប់តំបន់ដែលមានកងកម្លាំងរាជអាវុធហត្ថ និងក្រុមគ្រួសាររស់នៅ តែទោះជាយ៉ាងណា តាមការសង្កេតការិយាល័យថ្មីនេះមានប្រជាពលរដ្ឋចំនួន១២៤នាក់ និងទាហានចំនួន៤២០នាក់ (តាមលិខិតស្នើសុំរបស់មេឃុំក្នុងឧបសម្ព័ន្ធចំណុច១)។ លទ្ធផលនៃឃុំស្វាយជុកនេះ មិនខុសពីលទ្ធផលនៃឃុំសេដ្ឋីនោះទេ បើមើលលទ្ធផលនៃការប្រកួតប្រជែងវិញសង្កេតឃើញថា លទ្ធផលនៃការបោះឆ្នោតឆ្នាំ ២០១៣ លទ្ធផលនៃគណបក្សទាំងពីរ គឺប្រកៀកប្រកិតគ្នា ដោយគណបក្សប្រជាជនទទួលបាន១៨៧២សម្លេង និងគណបក្សសង្គ្រោះជាតិទទួលបាន២០១៤សម្លេង។

ជារួមនៅក្នុងដំណើរការចុះឈ្មោះបោះឆ្នោតនេះ ខុមហ្វ្រែលបានសង្កេត និងសង្ខេបការរកឃើញដូចខាងក្រោម៖

១. លទ្ធផលនៃការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៦ បានចុះឈ្មោះប្រមាណ៧.៨៦លាននាក់ (៨១.៣៨%)ក្នុងចំណោមអ្នកមានសិទ្ធិចុះឈ្មោះ ៩.៦លាននាក់ ដែលមិនបានពេញលេញ(សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោតយល់ថាយ៉ាង តិចក៏៩៥% នៃអ្នកមានសិទ្ធិបោះឆ្នោត)។ អ្នក

មានសិទ្ធិបោះឆ្នោតនៅសល់មួយចំនួន ក៏នៅចង់មកចុះឈ្មោះបោះឆ្នោត បន្ទាប់ពីការបិទការចុះឈ្មោះបោះឆ្នោតនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦។

២. ដំណើរការរៀបចំការចុះឈ្មោះបោះឆ្នោត បានប្រព្រឹត្តទៅតាមបទបញ្ជា និងនីតិវិធីនៃការចុះឈ្មោះបោះឆ្នោត និងផែនការរបស់ គ.ជ.ប ដែលអាចទទួលយកបាន បើទោះបីមានភាពមិនប្រក្រតីខ្លះ។ ការជ្រើសរើសមន្ត្រីចុះឈ្មោះបោះឆ្នោត មានការចូលរួមពីសមាជិក គ.ជ.ប និងការបើកចំហ និងតម្លាភាពជាងការជ្រើសរើសមន្ត្រីពីមុន ហើយមន្ត្រីទាំងនោះមានការខិតខំបំពេញភារកិច្ច។

- ការបង្កើតការិយាល័យបោះឆ្នោតភាគច្រើនមានលក្ខណៈត្រឹមត្រូវទៅតាមស្ថានភាពភូមិសាស្ត្រ ដង់ស៊ីតេប្រជាពលរដ្ឋនៅតាមភូមិឃុំ សង្កាត់ និងបទបញ្ជានីតិវិធីចុះឈ្មោះបោះឆ្នោត ប៉ុន្តែមានការបង្កើតការិយាល័យ និងការចេញលិខិតបញ្ជាក់ទីលំនៅដល់នគរបាល និងយោធិន ដែលអាចត្រូវបកស្រាយជាបញ្ហាទាក់ទិននយោបាយនៅក្នុង ១៩ឃុំ និងក៏អាចប៉ះពាល់ដល់ភាពសម្ងាត់នៃក្រុមចុះឈ្មោះជាកងកម្លាំងប្រដាប់អាវុធពិសេសយោធា។
- មានការរារាំង និងការមិនលើកទឹកចិត្តចំពោះការអប់រំ និងការផ្សព្វផ្សាយព័ត៌មានការចុះឈ្មោះបោះឆ្នោតដោយអាជ្ញាធរ។
- មិនមានភាពប្រក្រតីធ្ងន់ធ្ងរ និងបណ្តឹងច្រើននៅក្នុងអំឡុងពេលនៃការសង្កេតដំណើរការចុះឈ្មោះបោះឆ្នោត តែក្នុងចំណោមភាពមិនប្រក្រតីសរុបចំនួន១៥,៥៤០ករណី (ចំនួនអ្នកសង្កេតការណ៍សរុប៥៤៦នាក់ មកពីខុមហ្វ្រែលសហការជាមួយសម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត ហៅថា ERA មានដូចជា អង្គការនិកហ្វិច អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន) ភាពមិនប្រក្រតីកើតច្រើន ដែលគួរឲ្យយកចិត្តទុកដាក់នោះ គឺការបញ្ចូលទិន្នន័យខុស និងការមិនពិនិត្យ និងផ្ទៀងផ្ទាត់ឈ្មោះ នៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត។ ក្រុមប្រឹក្សាឃុំសង្កាត់ក៏ខិតខំដោះស្រាយបណ្តឹងបាន៥០% នៃ៥២ពាក្យបណ្តឹង ដែលមានការទទួលពាក្យបណ្តឹង និងបដិសេធបណ្តឹងមិនច្រើន។

៣. សម្រាប់ប្រព័ន្ធចុះឈ្មោះបោះឆ្នោតថ្មី គ.ជ.ប មានសមត្ថភាពក្នុងការផ្ទៀងផ្ទាត់ ហើយរកឃើញភាពមិនប្រក្រតីឈ្មោះស្ទួនជា២ម៉ឺនឈ្មោះ និងកំហុសទិន្នន័យប្រមាណ៣% នៃអ្នកបានចុះឈ្មោះបោះឆ្នោតតែប្រព័ន្ធនេះក៏អាចកែតម្រូវផងដែរ។

៤. នៅក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះបោះឆ្នោតឃើញថា ប្រជាពលរដ្ឋប្រហែល៣០% បានមកពិនិត្យផ្ទៀងផ្ទាត់ឈ្មោះនៅសាលាឃុំ សង្កាត់ ជាមួយនិងការសង្កេតឃើញថា ឃុំ សង្កាត់មួយចំនួននៅមានបាត់បង់ឈ្មោះ ដែល គ.ជ.ប មិនទាន់បញ្ចូលទៅក្នុងបញ្ជីឈ្មោះនៅឡើយ។

៩.២ ការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះ និងការបោះឆ្នោត

ការស្នើសុំ និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណ ត្រូវបានបែងចែកជាពីរដំណាក់កាល គឺទី១. ដំណាក់កាលចុះឈ្មោះបោះឆ្នោត ត្រូវចេញដោយអាជ្ញាធរឃុំ សង្កាត់ (មេឃុំ ចៅសង្កាត់) ដើម្បីបំពេញលក្ខខណ្ឌចុះឈ្មោះបោះឆ្នោត និងទី២.ដំណាក់កាលបោះឆ្នោត ត្រូវចេញដោយស្ថាប័នពីរ គឺ គយ.សប និងអាជ្ញាធរឃុំ សង្កាត់ ដើម្បីប្រើប្រាស់ក្នុងការបោះឆ្នោត។

យោងតាមរបាយការណ៍របស់ គ.ជ.ប ការចេញក្នុងដំណាក់កាលទី១ មានចំនួន៣២១.៧២៦សន្លឹក ស្មើប្រមាណ៤% នៃអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ (៧.៨៦៥.០៣៣នាក់)។ ក្នុងដំណាក់កាលទី២ វិញ ការចេញមានចំនួន១៣៨.១២៥សន្លឹក ស្មើប្រមាណ១.៧៥% នៃអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ។

ការចេញឯកសារនេះនៅក្នុងដំណាក់កាលបោះឆ្នោត បានចាប់ផ្តើមពីថ្ងៃទី៤ ខែឧសភា និងបញ្ចប់នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៧។ ដោយអត្រាប្រជាពលរដ្ឋដែលបានស្នើសុំឯកសារនេះសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតមានចំនួនតិចតួច គ.ជ.ប និងក្រសួងមហាផ្ទៃ បានសម្រេចឱ្យអ្នកចុះឈ្មោះបោះឆ្នោតដែលប្រើឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត អាចយកឯកសារនេះ ទៅបោះត្រានៅ គយ.សប ដើម្បីផ្តល់សុពលភាពសម្រាប់យកទៅប្រើប្រាស់ក្នុងការបោះឆ្នោតត្រឹមថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៧។

នីតិវិធីនៃការផ្តល់ឯកសារនេះ មានការកែលម្អ ជាពិសេសក្នុងដំណាក់កាលទី២ ព្រោះបានបើកឱ្យមានការចូលរួមពីមន្ត្រីរៀបចំការបោះឆ្នោតថ្នាក់ឃុំ សង្កាត់ (គយ.សប) ក្នុងការចេញលិខិតនេះ ប៉ុន្តែវាហាក់ដូចជាបង្កភាពស្មុគស្មាញ និងមានការលំបាកសម្រាប់ប្រជាពលរដ្ឋ ព្រោះការផ្សព្វផ្សាយ និងការយល់ដឹងរបស់ប្រជាពលរដ្ឋអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែមិនមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ គឺនៅមានកម្រិត។[122] ករណីបានបណ្តាលឱ្យអ្នកបោះឆ្នោតមួយចំនួន គ្មានឯកសារបញ្ជាក់អត្តសញ្ញាណប្រើប្រាស់នៅថ្ងៃបោះឆ្នោត ហើយបានធ្វើឱ្យពួកគេមិនបានបោះឆ្នោត។

ជុំវិញការចេញឯកសារនេះ បញ្ហាមិនប្រក្រតីត្រូវបានកាត់បន្ថយ បើប្រៀបធៀបទៅនឹងការនឹងការបោះឆ្នោតកន្លងមក។ ទន្ទឹមគ្នានេះ អ្នកសង្កេតការណ៍ខុមហ្វ្រែលក៏បានរកឃើញបញ្ហាមួយចំនួនដូចជា: ប្រជាពលរដ្ឋជួបការលំបាកក្នុងការស្វែងរកសាក្សី (២រូប) និងរូបថត ការចំណាយពេលវេលាច្រើន ព្រោះមិនជួបមេឃុំ ចៅសង្កាត់ (មេឃុំ ចៅសង្កាត់មួយចំនួនទៅចូលរួមការឃោសនាបោះឆ្នោត ហើយមិនបានធ្វើការផ្ទេរ

[122] Voters had not been informed about the issue. Many of them were under the impression the Identify Certificate for Voter Registration and on the Election was all that was needed on Election Day to vote. They were not aware of the additional required certificate to be used for the vote on the Election Day other than ICVR.

សិទ្ធិត្រឹមត្រូវ) ការណែនាំមន្ត្រី (សម្រាប់ដំណាក់កាលទី២) និងការផ្សព្វផ្សាយដំណឹងមានរយៈពេលខ្លី និងមិនសូវបានទូលំទូលាយ និងប្រជាពលរដ្ឋមួយចំនួនមិនស្គាល់ទីស្នាក់ការរបស់ គយ.សប ជាដើម។

បើពិនិត្យមើលក្នុងការបោះឆ្នោតកន្លងមក ការចេញឯកសារនេះ គឺកើតមានបញ្ហាមិនប្រក្រតីច្រើនដូចជា មេឃុំ ចៅសង្កាត់មួយចំនួន មិនបានអនុវត្តតាមសេចក្តីណែនាំរួមរបស់ គ.ជ.ប និងក្រសួងមហាផ្ទៃ ទាក់ទងនឹងការធ្វើរបាយការណ៍ និងការផ្សព្វផ្សាយ ការចេញខុសរយៈពេលដែលបានកំណត់ ការចេញឲ្យអ្នកដែលគ្មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោត (ដំណាក់កាលទី២ បន្ទាប់ពីការផ្តល់សុពលភាពបញ្ជីបោះឆ្នោត) ការចេញដោយគ្មានបោះត្រាឃុំ សង្កាត់ និងបិទរូបថតត្រឹមត្រូវ ការចេញដោយយកឈ្មោះអ្នកផ្សេងមកបិទរូបថតអ្នកផ្សេងមួយទៀត គល់បញ្ជីមិនបានបំពេញត្រឹមត្រូវ និងបញ្ហាខ្វះតម្លាភាពក្នុងការចេញលិខិតនេះជាដើម។ ជាមួយគ្នានេះ ចំនួននៃការដ៏ច្រើនលើសលប់បានបង្កឲ្យមានការសង្ស័យអំពីភាពមិនប្រក្រតីនៃការចេញលិខិតនេះរបស់អាជ្ញាធរឃុំ សង្កាត់ផងដែរ (គិតចាប់តាំងពីឆ្នាំ២០១១ រហូតមកដល់ការបោះឆ្នោតក្នុងឆ្នាំ ២០១៣ ឯកសារនេះត្រូវបានចេញប្រមាណ១.៨លានសន្លឹក)។[123]

៩.៣ ការបែងចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត

ការបែងចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត គឺដើម្បីជួយដល់អ្នកបោះឆ្នោត ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត បានយល់ដឹងអំពីលេខរៀង ឈ្មោះ ទិន្នន័យពាក់ព័ន្ធនឹងសាមីខ្លួនក្នុងបញ្ជីបោះឆ្នោត ឈ្មោះទីតាំងនិងលេខកូដការិយាល័យបោះឆ្នោត កាលបរិច្ឆេទ និងពេលវេលានៃការបោះឆ្នោត ព្រមទាំងឯកសារសម្រាប់ប្រើប្រាស់ក្នុងថ្ងៃបោះ។ គ.ជ.ប បានផលិតប័ណ្ណព័ត៌មានអ្នកបោះឆ្នោតចំនួន ៧.៨៦៥.០៣៣ ប័ណ្ណ ស្មើនឹងចំនួនឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ។

រូបភាពទី១៥៖ ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត



(ប្រភព: ហ្វេសប៊ុក)

[123] See COMFREL's 2013 National Assembly Elections: Final Assessment and Report.

ដំណើរការចែកប័ណ្ណព័ត៌មានបានអនុវត្តចាប់ផ្តើមពីថ្ងៃទី១៧ ខែមេសា ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ ២០១៧ ដោយក្រុមចែកប័ណ្ណព័ត៌មានតាមឃុំ សង្កាត់។ ប័ណ្ណព័ត៌មានដែលនៅសល់ ត្រូវបានយកទៅរក្សាទុក និងបន្តចែកជូនប្រជាពលរដ្ឋនៅស្នាក់ការ គឃ.សប។ យោងតាមរបាយការណ៍របស់ គ.ជ.ប ការចែងប័ណ្ណព័ត៌មានជូនដល់អ្នកបោះឆ្នោត បានចំនួនសរុប ៧.៤៥៧.៥៩១ សន្លឹកប័ណ្ណ ស្មើនឹង ៩៤.៨២% ក្នុងនោះការចុះបែងចែកតាមភូមិ និងឃុំ សង្កាត់ បានចំនួន ៧.៣៦៥.៩១៨ សន្លឹកប័ណ្ណ ស្មើនឹង ៩៣.៦៥% និងការចែកបន្តនៅស្នាក់ការ គឃ.សប ចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧ បានចំនួន ៩១.៦៧៣ សន្លឹកប័ណ្ណ ស្មើនឹង ១.១៧%។ ប័ណ្ណព័ត៌មានដែលនៅសល់មានចំនួន ៤០៧.៤៤២ សន្លឹកប័ណ្ណ ស្មើនឹង ៥.១៨%។

ដំណើរការ និងចំនួននៃការបែងចែកប័ណ្ណព័ត៌មានក្នុងការបោះឆ្នោតនេះ មានភាពល្អប្រសើរជាងការបោះឆ្នោតកន្លងមក។ ការបែងចែកនៅតាមភូមិ និងឃុំ សង្កាត់នៅក្នុងការបោះឆ្នោតឆ្នាំ២០១២ បានចំនួន ៨៦.៩៣% ហើយក្នុងការបោះឆ្នោតឆ្នាំ២០១៣ បានចំនួន ៨៤.៥%។ បើទោះបីជាយ៉ាងណាក៏ដោយ ការសង្កេតក៏រកឃើញថា ការបែងចែកប័ណ្ណព័ត៌មាននៅតែបន្តមានការរើងអើង និងមានការបញ្ហាក់ពីគោលបំណងមិនច្បាស់លាស់ដែលធ្វើឲ្យអ្នកបោះឆ្នោត និងមន្ត្រីការិយាល័យរៀបចំការបោះឆ្នោតមួយចំនួនមានការភ័ន្តច្រឡំ។

លទ្ធផលនៃការស្រាវជ្រាវទៅលើអ្នកបោះឆ្នោតរបស់ខុមហ្វ្រៃលកន្លងមក បានរកឃើញថា មានអ្នកមានសិទ្ធិបោះឆ្នោតមួយចំនួនមិនបានទៅបោះឆ្នោត ដោយសារពួកគេគ្មានប័ណ្ណព័ត៌មានអ្នកបោះឆ្នោត។ ដូចគ្នាដែរ នៅក្នុងការបោះឆ្នោតឆ្នាំ២០១៧នេះ អ្នកសង្កេតការណ៍របស់ខុមហ្វ្រៃលបានរាយការណ៍ថា មានករណីអ្នកបោះឆ្នោតគ្មានប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ដែលធ្វើឱ្យពួកគេពិបាកក្នុងការស្វែងរកឈ្មោះ ក្នុងបញ្ជីបោះឆ្នោត និងស្វែងរកការិយាល័យបោះឆ្នោត ហើយករណីនេះបានធ្វើឱ្យអ្នកបោះឆ្នោតមួយចំនួន មិនបានបោះឆ្នោត។

ខុមហ្វ្រៃលតែងតែបង្ហាញការគាំទ្រចំពោះការចែកប័ណ្ណនេះ ព្រោះវាមានសារៈសំខាន់ ដូចបានបញ្ជាក់ជូនខាងដើម ប៉ុន្តែអ្វីដែលសោកស្តាយនោះ គឺដំណើរការបែងចែកនេះ មិនបានប្រព្រឹត្តទៅដូចអ្វីដែលភាគីពាក់ព័ន្ធរំពឹងទុកនោះទេ ព្រោះថា អ្នកមានតួនាទីបែងចែក ជាពិសេសអាជ្ញាធរមូលដ្ឋានមានការរើសអើងក្នុងការបែងចែក និងបានប្រើប្រាស់វាសម្រាប់ផលចំណេញនយោបាយ។ ម្យ៉ាងវិញទៀត ការផ្តល់ព័ត៌មានមិនច្បាស់លាស់អំពីគោលបំណងនៃប័ណ្ណនេះ បានធ្វើឲ្យអ្នកមានសិទ្ធិបោះឆ្នោតមួយចំនួន បាត់បង់សិទ្ធិដោយសារតែឯកសារមួយនេះ។

៩.៤ វិធានការរបស់ គ.ជ.ប ដើម្បីធានាការបោះឆ្នោតមួយសម្រាប់អ្នកបោះឆ្នោតម្នាក់ និងការសាកល្បងទឹកខ្មៅលុបលាងមិនជ្រះ

រូបភាពទី១៦ ខាងក្រោម គឺជាការចូលរួមសាកល្បងដោយមន្ត្រីខុមហ្វ្រៃល ក្នុងកម្មវិធីសន្និសីទសារព័ត៌មាន ស្តីពី«ការបង្ហាញ និងការសាកល្បងទឹកខ្មៅលុបលាងមិនជ្រះសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោត

ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ ឆ្នាំ២០១៧» ដែលបានអញ្ជើញដោយ គ.ជ.ប នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧។ ក្នុងកម្មវិធីសាកល្បងនោះ មានតំណាងចូលរួមពីស្ថានទូតមួយចំនួន តំណាងគណបក្សនយោបាយ តំណាងអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិមួយចំនួន។

ទឹកថ្នាំលុបលាងមិនជ្រះ ដែលប្រើសម្រាប់ការបោះឆ្នោតឆ្នាំ២០១៧ គ.ជ.ប បានបញ្ជាទិញពីក្រុមហ៊ុនឥណ្ឌា មានឈ្មោះថា Mysore Paints and Varnish Limited ចំនួនក្នុងទឹកប្រាក់ជិត៨សែនដុល្លារ។

រូបភាពទី១៦ ការសាកល្បងទឹកខ្មៅលុបលាងមិនជ្រះ

ទឹកខ្មៅផលិតនៅប្រទេសឥណ្ឌា

ការសាកល្បងលាងទឹកខ្មៅដោយប្រើថ្នាំលាបសក់ទិញដោយខុមហ្វ្រៃល

ការសាកល្បងដោយមន្ត្រីខុមហ្វ្រៃលបានរកឃើញថា គុណភាពនៃទឹកខ្មៅ ៩៥ភាគរយ ត្រូវបានលុបលាងជ្រះដោយទឹកថ្នាំលាបសក់របស់ស្ត្រី ដែលផលិតនៅប្រទេសថៃ។ ជាមួយគ្នានេះដែរ តំណាងមកពីគណបក្សសង្គ្រោះជាតិ (លោក ម៉ន ផល្លា ប្រធានប្រតិបត្តិរាជធានីភ្នំពេញ និងជាតំណាងគណបក្សសង្គ្រោះជាតិ) ដែលបានចូលរួមសង្កេត និងសាកល្បងផងដែរនោះ បានបង្ហាញថា ទឹកថ្នាំដែលបានសាកល្បងបានលុបជ្រះជាង ៩០ភាគរយ។

ទាក់ទងទឹកថ្នាំនេះ ឯកឧត្តមប្រធាន ស៊ិក ប៊ុនហុក ក៏បានបង្ហាញថា គ.ជ.ប ក៏បានធ្វើការសាកល្បងលុបលាងជ្រះផងដែរ មុនយកមកដាក់ឱ្យសាកល្បងជាសាធារណៈនេះ។ គ.ជ.ប ក៏បានបញ្ជូនទឹកថ្នាំនោះទៅក្រុមហ៊ុន និងជជែកគ្នារកវិធីដោះស្រាយ ព្រមទាំងបានអនុញ្ញាតឱ្យក្រុមហ៊ុនមួយចំនួនដាក់គំរូមកប្រកួតប្រជែងផងដែរ។ អាស្រ័យដោយថវិកា និងពេលវេលាមិនគ្រប់គ្រាន់ គ.ជ.ប ក៏បានសម្រេចបញ្ជាទិញពីក្រុមហ៊ុនមកពីឥណ្ឌាដដែល ក៏ប៉ុន្តែបានបន្ថែមពីគុណភាពនៃទឹកថ្នាំនេះ ហើយបានបញ្ចូលនូវវិធានការណែនាំទៅមន្ត្រីការិយាល័យបោះឆ្នោតចំនួន៥ចំណុច សម្រាប់ទប់ទល់អ្នកបោះឆ្នោតលើសពីមួយដង។ វិធានការទាំង៥ចំណុចនោះរួមមាន៖

១. ពង្រឹងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ) ជូនអ្នកបោះឆ្នោតដែលពុំមាន ឬបាត់ ឬខូចអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ។

២. ពង្រឹងភារកិច្ចរបស់លេខាធិការការិយាល័យបោះឆ្នោត ក្នុងការអនុវត្តន៍ការពិនិត្យផ្ទៀងផ្ទាត់ ឯ.អ ឬអ.ខ របស់អ្នកបោះឆ្នោតជាមួយនឹងរូបពិតរបស់ជននោះ ធៀបនឹងរូបថត ឈ្មោះ និងទិន្នន័យរបស់គាត់ក្នុងបញ្ជីបោះឆ្នោត មុននឹងធិចសញ្ញាសម្គាល់ ដើម្បីបញ្ជាក់ថា ជននោះបានមកបោះឆ្នោត។

៣. ណែនាំលេខាធិការឱ្យធិចលើប្រអប់លេខរៀងនៃបញ្ជីបោះឆ្នោត និងណែនាំអ្នកបោះឆ្នោត ឱ្យធិចនៅលើបញ្ជីបោះឆ្នោតត្រង់ចន្លោះទំនេរ នៃឈ្មោះរបស់អ្នកបោះឆ្នោត ដើម្បីផ្ទៀងផ្ទាត់ និងបញ្ជាក់ថា សាមីខ្លួនបានមកបោះឆ្នោត។

៤. រំលឹកដល់ភ្នាក់ងារគណបក្សនយោបាយ ដែលមានបញ្ជីបោះឆ្នោតនៅក្នុងដៃ និងអ្នកសង្កេតការណ៍បោះឆ្នោត ឱ្យតាមដានពិនិត្យមើលដំណើរការពិនិត្យផ្ទៀងផ្ទាត់ឯកសារប្រើប្រាស់ សម្រាប់ការបោះឆ្នោតរបស់អ្នកបោះឆ្នោត ជាមួយនឹងរូបពិត ធៀបនឹងរូបថត ឈ្មោះ និង ទិន្នន័យរបស់គាត់ក្នុងបញ្ជីបោះឆ្នោត។

៥. ផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីការពង្រឹងការអនុវត្តន៍ទោសប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា ១៧១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាកពិន័យជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀល ទៅ ២0.000.000(ម្ភៃលាន) រៀល ដោយ គ.ជ.ប ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។

ទោះបីជាទឹកខ្មៅដែលធ្វើការសាកល្បងមានបញ្ហាក៏ដោយ ក៏ប៉ុន្តែសង្គមស៊ីវិល និងគណបក្សនយោបាយរីករាយជាមួយវិធានការទាំង៥ ដែលបានរៀបចំដោយ គ.ជ.ប នេះ ហើយក៏យល់ឃើញថា មិនមានអ្វីដែលជាបញ្ហាទៀតឡើយសម្រាប់ទឹកខ្មៅនេះ។[124]

ការសន្និដ្ឋានរបស់ខុមហ្វ្រែលយល់ឃើញថា ទឹកខ្មៅវាមិនមែនជាបញ្ហាសម្រាប់អ្នកបោះឆ្នោតទៀតទេ ព្រោះថា វិធានការទាំង ៥ចំណុច អាចជួយទប់ស្កាត់បាន ម្យ៉ាងទៀតកាលពីបោះឆ្នោតអាណត្តិមុនៗ អ្វីដែល គ.ជ.ប ត្រូវតែយកចិត្តទុកដាក់ខ្ពស់ចំពោះទឹកខ្មៅនោះ ព្រោះដោយសារតែបញ្ជីឈ្មោះអ្នកបោះឆ្នោតមិនមានគុណភាព ដែលកើតជាការព្រួយបារម្ភចំពោះជនទុច្ចរិតអាចបោះឆ្នោតលើសពីមួយដង ក៏ប៉ុន្តែបញ្ជីឈ្មោះបោះឆ្នោតថ្មីឆ្នាំ២0១៦ អាចធានាបានពីឈ្មោះស្ងួន ឈ្មោះខ្មោច និងការបាត់ឈ្មោះ ថែមទាំងបញ្ជីឈ្មោះមានបញ្ចូលរូបថតអ្នកបោះឆ្នោត ហើយការបោះឆ្នោតឆ្នាំ២0១៧ អនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ

[124] See: https://www.cambodiadaily.com/news/129896-129896/; http://www.khmertimeskh.com/news/38478/voting-ink-faces-the-acid-test/

អាចមានសិទ្ធិនាំយកបញ្ជីឈ្មោះបោះឆ្នោតទៅជាមួយ ដើម្បីពិនិត្យក្នុងការិយាល័យបោះឆ្នោតបាន រួមទាំងការផ្ទៀងផ្ទាត់រូបភាពពិតរបស់អ្នកបោះឆ្នោតជាមួយរូបថតក្នុងបញ្ជីឈ្មោះ និងរូបពិតអ្នកបោះឆ្នោត ដូច្នេះវាជាហេតុធ្វើឱ្យទឹកខ្មៅលុបលាងមិនជ្រះដែលប្រើក្នុងថ្ងៃបោះឆ្នោតលែងជាបញ្ហាសំខាន់ និងមិនអាចអនុញ្ញាតឱ្យអ្នកបោះឆ្នោតបោះលើសពីមួយដង។

៩.៥ ការចុះឈ្មោះបេក្ខជននៃគណបក្សនយោបាយ

ការចុះឈ្មោះបញ្ជីបេក្ខជននៃគណបក្សនយោបាយ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៤ ឆ្នាំ២០១៧ បានប្រព្រឹត្តទៅចាប់ពីថ្ងៃទី០៣ ខែមីនា ដល់ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៧។ មានគណបក្សនយោបាយចំនួន១២ បានស្នើសុំចុះបញ្ជីបេក្ខជន ហើយ គ.ជ.ប ក៏បានសម្រេចទទួលចុះបញ្ជីឲ្យគណបក្សទាំងនោះ ដើម្បីចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតនេះ។ គណបក្សទាំងនោះរួមមាន: គណបក្សប្រជាជនកម្ពុជា គណបក្សសង្គ្រោះជាតិ គណបក្សហ៊្វុនស៊ិនប៉ិច គណបក្សគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ គណបក្សខ្មែររួបរួមជាតិ គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ គណបក្សសញ្ជាតិកម្ពុជា គណបក្សប្រជាធិបតេយ្យមូលដ្ឋាន គណបក្សយុវជនកម្ពុជា គណបក្សអំណាចខ្មែរ គណបក្សជនជាតិដើមប្រជាធិបតេយ្យ គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ។

គណបក្សនយោបាយដែលចូលរួមឈរបោះឆ្នោត ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ ឆ្នាំ២០១៧នេះ មានចំនួនដូចគ្នានឹងការបោះឆ្នោតក្នុងឆ្នាំ២០០៧ និងមានចំនួនច្រើនជាង ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងឆ្នាំ២០០២ និងឆ្នាំ២០១២។

តារាងទី១២៖ គណបក្សនយោបាយដែលចូលរួមក្នុងការបោះឆ្នោតចាប់ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០១៧

1993	1998	2002	2003	2007	2008	2012	2013	2017
20	39	8	23	12	11	10	8	12

រូបភាពទី១៧ ចំនួនគណបក្សនយោបាយដែលចូលរួមប្រកួតប្រជែងក្នុងឆ្នាំបោះឆ្នោត



ខុសប្លែកពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់កន្លងមក ការបោះឆ្នោតក្នុងអាណត្តិទី៤នេះ មាន គណបក្សនយោបាយចំនួន២ គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ បានចុះបញ្ជីបេក្ខជនប្រកួតប្រជែងនៅគ្រប់ឃុំ សង្កាត់ (១,៦៤៦)។ គួរបញ្ជាក់ថា ការបោះឆ្នោតកន្លងមកមានតែគណបក្សប្រជាជនកម្ពុជា ដែលជាគណបក្សកាន់អំណាចប៉ុណ្ណោះ បានចុះបញ្ជីបេក្ខជនរបស់ខ្លួននៅគ្រប់ឃុំ សង្កាត់ ដោយឡែកគណបក្សដទៃទៀតមិនបានចុះបញ្ជីបេក្ខជននៅគ្រប់ឃុំ សង្កាត់នោះទេ។

លទ្ធផលផ្លូវការនៃការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៤ បានបង្ហាញថា: ១.គណបក្សប្រជាជនកម្ពុជា និង២.គណបក្សសង្គ្រោះជាតិបានចុះបញ្ជីបេក្ខជននៅគ្រប់ឃុំ សង្កាត់ ៣.គណបក្សហ៊្វុនស៊ិនប៉ិចបានចុះបញ្ជីបេក្ខជននៅ៨៤៦ឃុំ សង្កាត់ ក្នុង២៤រាជធានី ខេត្ត (លើកលែងខេត្តប៉ៃលិន) ៤.គណបក្សគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ បានចុះបញ្ជីបេក្ខជននៅ៨៤៤ឃុំ សង្កាត់ ក្នុង២៤រាជធានី ខេត្ត (លើកលែងខេត្តស្ទឹងត្រែង) ៥.គណបក្សខ្មែររួបរួមជាតិបានចុះបញ្ជីបេក្ខជននៅ៧១៣ឃុំ សង្កាត់ ក្នុង២៤ រាជធានី ខេត្ត (លើកលែងខេត្តកែប) ៦.គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យបានចុះបញ្ជីបេក្ខជននៅ ២៥០ឃុំ សង្កាត់ ក្នុង១៦រាជធានី ខេត្ត ៧.គណបក្សសញ្ជាតិកម្ពុជាបានចុះបញ្ជីបេក្ខជននៅ៥២ ឃុំ សង្កាត់ក្នុង៨ខេត្ត ៨.គណបក្សប្រជាធិបតេយ្យមូលដ្ឋានបានចុះបញ្ជីបេក្ខជននៅ២៧ឃុំ សង្កាត់ ក្នុង៩ខេត្ត ៩.គណបក្សយុវជនកម្ពុជាបានចុះបញ្ជីបេក្ខជននៅ១៩ឃុំ សង្កាត់ក្នុងខេត្តត្បូងឃ្មុំ ១០.គណបក្សអំណាចខ្មែរបានចុះបញ្ជីបេក្ខជននៅ១៦ ឃុំ សង្កាត់ ក្នុង៥ខេត្ត ១១.គណបក្សជនជាតិដើមប្រជាធិបតេយ្យបានចុះបញ្ជីបេក្ខជននៅ១៧ ឃុំ សង្កាត់ ក្នុងខេត្តក្រចេះ និងខេត្តមណ្ឌលគីរី និង១២.គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យបានចុះបញ្ជីបេក្ខជននៅ១៤ឃុំ សង្កាត់ ក្នុង៨ខេត្ត។

ជុំវិញដំណើរការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ អ្នកសង្កេតការណ៍របស់ខុមហ្វ្រែល បានរកឃើញនូវបញ្ហាមួយចំនួនមួយចំនួនដូចជា:

- គណបក្សនយោបាយមួយចំនួនជួបការលំបាកក្នុងការស្នើសុំលិខិតបញ្ជាក់របស់បេក្ខជនថា ពិតជាមានឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ដែលសាមីខ្លួនឈរឈ្មោះបោះឆ្នោត។ ជាក់ស្តែង គណបក្សប្រជាធិបតេយ្យមូលដ្ឋានបានជួបការលំបាកក្នុងការបញ្ជាក់លិខិតនេះពីមេឃុំនៅក្នុងខេត្តកំពង់ស្ពឺ និងខេត្តរតនគីរី រហូតទាល់តែមានការអន្តរាគមន៍ពី គធ.ខប ទើបមេឃុំទាំងនោះបញ្ជាក់ជូន។
- ការកំណត់លក្ខខណ្ឌចុះបញ្ជីដោយ គយ.សប មានការខុសប្លែកគ្នានៅតាមឃុំ សង្កាត់មួយចំនួនហើយ គយ.សប ខ្លះបានត្រូវឱ្យគណបក្សនយោបាយបំពេញលក្ខខណ្ឌលើសពីការកំណត់របស់បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប។ ជាក់ស្តែងនៅឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ កយ.សប បានទាមទារឱ្យតំណាងគណបក្សសង្គ្រោះជាតិដាក់លិខិតបញ្ជាក់របស់បេក្ខជនពីមេឃុំចំនួនពីរច្បាប់ ខណៈដែលលក្ខខណ្ឌច្បាប់កំណត់តែមួយច្បាប់។ ករណីនេះក៏ត្រូវបានតំណាងគណបក្សនយោបាយផ្សេងទៀតលើកឡើងផងដែរ។
- តំណាងគណបក្សនយោបាយមួយចំនួននៅតាមឃុំ សង្កាត់ លើកពីការលំបាកទាក់ទងនឹងពេលវេលានៃការទទួលពាក្យចុះបញ្ជីបេក្ខជន ព្រោះមានរយៈពេលខ្លី ហើយការតម្រូវឱ្យដាក់សំណុំឯកសារច្រើនពេកក៏ជាការលំបាកសម្រាប់គណបក្សនយោបាយផងដែរ។
- គណបក្សនយោបាយភាគច្រើនបានជួបការលំបាកក្នុងការស្វែងបេក្ខជនឈរឈ្មោះ ជាពិសេសបេក្ខជនមានសក្តានុពល និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមលក្ខខណ្ឌកំណត់។ ជាក់ស្តែង តំណាងគណបក្សខ្មែររួបរួមជាតិ ក្នុងឃុំខ្វាស់ ស្រុកសូទ្រនិគម ខេត្តសៀមរាប បានលើកឡើងពីការលំបាកក្នុងការបំពេញលក្ខខណ្ឌចុះបញ្ជីបេក្ខជន ព្រោះរយៈពេលនៃការទទួលពាក្យខ្លី និងពិបាកក្នុងស្វែងរកបេក្ខជនឈរឈ្មោះ។[125] ករណីដោយឡែក តំណាងគណបក្សសាធារណរដ្ឋប្រជាធិប្បតេយ្យក្នុងសង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប បានលើកពីការលំបាកក្នុងការបំពេញលក្ខខណ្ឌចុះបញ្ជី ព្រោះពិបាកស្វែងរកបេក្ខជនឈរឈ្មោះ និងរយៈពេលនៃការទទួលពាក្យមានរយៈពេលខ្លី ហើយមានការសុំដកខ្លួនរបស់បេក្ខជនចំនួន៨នាក់ ដោយមូលហេតុមិនគ្រប់លក្ខខណ្ឌដើម្បីឈរឈ្មោះ។ ទន្ទឹមគ្នានេះ គណបក្សហ៊ុនស៊ិនប៊ិច គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ គណបក្ស សង្គ្រោះជាតិ គណបក្សយុវជនកម្ពុជា និងគណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា ក៏បានលើកឡើងពីការលំបាករបស់

[125] In the rural areas of Cambodia, it is not easy to take and get pictures on the same day. Some communes are very far away from town or cities and roads make travel difficult. In addition to the short timeframe, it costs money to go for the photograph and return.

ខ្លួនជុំវិញបញ្ហានេះផងដែរ។ តំណាងប្រចាំឃុំ សង្កាត់ខ្លះនៃគណបក្សប្រជាជនកម្ពុជា ក៏លើកឡើងពីការលំបាកក្នុងការបំពេញលក្ខខណ្ឌនេះដែរ។

- ករណីគំរាមកំហែងដោយផ្ទាល់ ឬដោយប្រយោល ចំពោះបេក្ខជនឈរឈ្មោះ ជាពិសេសបេក្ខជនឈរឈ្មោះឱ្យគណបក្សប្រឆាំង (គណបក្សសង្គ្រោះជាតិ)។ ជាក់ស្តែងនៅឃុំសំបូរ ស្រុកសំបូរ ខេត្តក្រចេះ បេក្ខជនឈរឈ្មោះឱ្យគណបក្សសង្គ្រោះជាតិ ត្រូវបានអាជ្ញាធរមូលដ្ឋានតាមឃ្លាំមើលសកម្មភាពរបស់ខ្លួន ដែលករណីនេះ ត្រូវបានសាមីខ្លួន និងតំណាងគណបក្សប្រចាំឃុំថា ជាការគំរាមកំហែង។
- ករណីសុំដកខ្លួនពីបេក្ខជនឈរឈ្មោះ ដោយមូលហេតុភ័យខ្លាច ព្រួយបារម្ភខ្លាចមានការរើសអើង គិតថាខ្លួនគ្មានសមត្ថភាព ទទួលការរារាំងពីក្រុមគ្រួសារ និងទទួលការបញ្ចុះបញ្ចូលទៅឈរឈ្មោះឱ្យគណបក្សផ្សេងជាដើម។ ជាមួយគ្នានេះ ក៏មានករណីបេក្ខជនម្នាក់ត្រូវបានគណបក្សនយោបាយចំនួនពីរដាក់បញ្ចូលក្នុងបញ្ជីបេក្ខជនរៀងៗខ្លួន ហើយបេក្ខជនខ្លះមិនដឹងថា ឈ្មោះខ្លួនត្រូវបានដាក់ឱ្យឈរឈ្មោះទៀតផង។ ជាក់ស្តែងនៅសង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាម តំណាងគណបក្សហ៊ុនសុិនប៊ិចប្រចាំសង្កាត់ បានអះអាងថា ការសុំដកខ្លួនចេញពីបេក្ខជនចំនួន១៣នាក់ គឺបណ្តាលមកពីពួកគេមានការភ័យខ្លាច។
- អ្នកបោះឆ្នោតមួយចំនួននៅមូលដ្ឋាន មិនដឹង/មិនទទួលព័ត៌មានអំពីបេក្ខជនឈរឈ្មោះ ខណៈពេលដែលការបិទផ្សាយបញ្ជីបេក្ខជនដោយ គយ.សប ភាគច្រើន គឺធ្វើនៅស្មាក់ការរបស់ គយ.សប។ មានភាពល្អប្រសើរជាងការបោះឆ្នោតកន្លងមក បញ្ជីរាយនាមបេក្ខជនឈរឈ្មោះបោះឆ្នោតតាមគណបក្សនយោបាយនីមួយៗ ត្រូវបាន គ.ជ.ប ផ្សព្វផ្សាយជាសាធារណៈនៅលើគេហទំព័រផ្លូវការរបស់ខ្លួន ខណៈដែលការបោះឆ្នោតក្នុងឆ្នាំ២០១២ គ.ជ.ប ផ្តល់បញ្ជីបេក្ខជនផ្លូវការឱ្យតែក្រសួងមហាផ្ទៃប៉ុណ្ណោះ។

ពិនិត្យជារួម បើទោះជាមានបញ្ហាមួយចំនួនដូចដែលបានរកឃើញខាងលើ ក៏ដំណើរការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤នេះ ប្រព្រឹត្តទៅដោយសន្តិវិធី និងគ្មានបញ្ហារាំស្ទះជាដុំកំភួនដែលឈានទៅដល់មិនអាចចុះបញ្ជីបេក្ខជនបានរបស់គណបក្សនយោបាយទេ។

៩.៦ ថ្ងៃបោះ និងរាប់សន្លឹកឆ្នោត (ថ្ងៃទី៤ មិថុនា)

ខុមហ្វ្រែលបានដាក់ពង្រាយអ្នកសង្កេតការណ៍ចំនួន ១៤,៥៨៩នាក់ (ស្ត្រី ៦,១៥៣នាក់) ដើម្បីសង្កេតដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅក្នុង៩,៨៨៩ទីតាំងការិយាល័យបោះឆ្នោត (ស្មើនឹង ៨៤%នៃទីតាំងការិយាល័យបោះឆ្នោតសរុបចំនួន១១,៧៨១)។ របាយការណ៍របស់អ្នកសង្កេតការណ៍ខុមហ្វ្រែលបានបង្ហាញថា ចំនួនភាពមិនប្រក្រតីដែលកើតមាននៅពេលបោះឆ្នោតមានការថយចុះ បើប្រៀបធៀបនឹងការបោះឆ្នោតក្នុងឆ្នាំ២០១២ និងឆ្នាំ២០១៣។ ការបោះឆ្នោតក្នុងឆ្នាំ២០១២ អ្នកសង្កេតការណ៍ខុមហ្វ្រែលសង្កេតឃើញមានភាពមិនប្រក្រតីចំនួន៣,១២៧ករណី ខណៈដែលការបោះឆ្នោតឆ្នាំ២០១៣ ភាពមិន

ប្រក្រតីមានចំនួនរហូតដល់១១,១៣៩ករណី។ ប៉ុន្តែភាពមិនប្រក្រតី អំឡុងពេលរាប់សន្លឹកឆ្នោតមានការកើនឡើងបើប្រៀបធៀបនឹងការបោះឆ្នោតក្នុងឆ្នាំ២០១២មាន៩០ករណី ហើយការបោះឆ្នោតក្នុងឆ្នាំ២០១៣មាន២៦៣ករណី។ ការបោះឆ្នោតឆ្នាំ២០១៧នេះ អ្នកសង្កេតការណ៍ខុមហ្វ្រែលបានសង្កេតឃើញមានភាពមិនប្រក្រតីនៅថ្ងៃស(ថ្ងៃទី៣ ខែមិថុនា)ចំនួន០៦ករណី ភាពមិនប្រក្រតីក្នុងអំឡុងពេលបោះឆ្នោតចំនួន២,២៧៦ករណី និងភាពមិនប្រក្រតី ក្នុងអំឡុងពេលរាប់សន្លឹកឆ្នោតចំនួន៧៦៨ករណី។ ចំនួនភាពមិនប្រក្រតីនេះកើតឡើងនៅការិយាល័យបោះឆ្នោតចំនួន១,៦៥៧ ស្មើនឹងប្រមាណ៩% នៃការិយាល័យបោះឆ្នោតចំនួន ១៨,៨៩៤ ដែលខុមហ្វ្រែលបានដាក់ពង្រាយអ្នកសង្កេតការណ៍។ ការិយាល័យបោះឆ្នោតសរុបមានចំនួន ២២,១៤៨ ត្រូវបានប្រើប្រាស់សម្រាប់ការបោះឆ្នោតក្នុងឆ្នាំ២០១៧នេះ។

ភាពមិនប្រក្រតីទាំងនេះកើតឡើងច្រើនជាគេនៅខេត្តតាកែវ (៥៥៤ករណី) ខេត្តសៀមរាប (៤១៩ករណី) ខេត្តត្បូងឃ្មុំ (៣២៣ករណី) ខេត្តបាត់ដំបង (២៧៣ករណី) រាជធានីភ្នំពេញ (២៧២ករណី) ខេត្តកំពង់ចាម (២៥៣ករណី) ខេត្តព្រៃវែង (២១៦ករណី) ខេត្តកណ្តាល (១៤០ករណី) និងខេត្តកំពង់ឆ្នាំង (១៣៤ករណី)។ នៅខេត្តផ្សេងទៀត ភាពមិនប្រក្រតីកើតមានឡើងតិចជាង១០០ករណី។

បើប្រៀបធៀបទៅនឹងការបោះឆ្នោតក្នុងឆ្នាំ២០១២ និងឆ្នាំ២០១៣ ករណីមិនប្រក្រតីដែលកើតឡើងច្រើនជាងគេ គឺឧបសគ្គចំពោះអ្នកបោះឆ្នោតនៅតាមការិយាល័យបោះឆ្នោត ដែលបង្កឱ្យអ្នកបោះឆ្នោតមួយចំនួនមិនបានបោះឆ្នោត។ ករណីទាំងនេះមានដូចជា: (១) អ្នកបោះឆ្នោតគ្មានឯកសារបញ្ជាក់អត្តសញ្ញាណ[126]សម្រាប់ការបោះឆ្នោត (២) អ្នកបោះឆ្នោតគ្មានប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ដែលធ្វើឱ្យពួកគេពិបាកក្នុងការស្វែងរកឈ្មោះ និងការិយាល័យបោះឆ្នោត (៣) ករណីខុសឈ្មោះ ឬទិន្នន័យរបស់អ្នកបោះឆ្នោត និង(៤) ករណីបាត់ឈ្មោះ ឬរកការិយាល័យបោះឆ្នោតមិនឃើញ។ ការបោះឆ្នោតក្នុងឆ្នាំ២០១២ ករណីទាំងនេះមានចំនួន១,២៩៨ករណី ខណៈឆ្នាំ២០១៣កើតមានច្រើនរហូតដល់៨,៤៩០ករណី ហើយការបោះឆ្នោតក្នុងឆ្នាំ២០១៧នេះ មានចំនួន១,២៧៦ករណី ដែលកើតមានឡើងច្រើនជាងគេក្នុងខេត្តកំពង់ចាម ខេត្តបាត់ដំបង ខេត្តតាកែវ ខេត្តត្បូងឃ្មុំ ខេត្តក្រចេះ ខេត្តកំពង់ធំ ខេត្តកំពង់ស្ពឺ ខេត្តប៉ៃលិន រាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តកណ្តាល ខេត្តព្រៃវែង ខេត្តព្រះសីហនុ ខេត្តបន្ទាយមានជ័យ និងខេត្តកំពង់ឆ្នាំង។

៩.៦.១ ភាពមិនប្រក្រតីក្នុងអំឡុងពេលបោះឆ្នោត

នៅក្នុងពេលបោះឆ្នោត អ្នកសង្កេតការណ៍ខុមហ្វ្រែល បានសង្កេតឃើញករណីមិនប្រក្រតីចំនួន ១,០០០ករណី ផ្សេងពីករណីមិនប្រក្រតីចំនួន១,២៧៦ករណី ទាក់ទងនឹងឧបសគ្គចំពោះអ្នកបោះឆ្នោតនៅតាមការិយាល័យបោះឆ្នោត ដែលបង្កឱ្យអ្នកបោះឆ្នោតមួយចំនួនមិនបានបោះឆ្នោត។ ការសង្កេតបានរកឃើញភាពមិនប្រក្រតីក្នុងអំឡុងពេលបោះឆ្នោត (២,២៧៦ករណី) មានចំនួនច្រើនជាង ភាពមិនប្រក្រតីក្នុងអំឡុង

[126] For those who did not register their names by using Khmer ID Card and had not obtained any ID certificate for voting.

ពេលរាប់សន្លឹកឆ្នោត (៧៦៨ករណី)។ ភាពមិនប្រក្រតីក្នុងអំឡុងពេលបោះឆ្នោតរួមបញ្ចូលការអនុវត្តន៍មិនត្រឹមត្រូវតាមបទបញ្ជា និងនីតិវិធីរបស់មន្ត្រីការិយាល័យបោះឆ្នោត ករណីបាត់ភាពសម្ងាត់នៃការបោះឆ្នោត ករណីបំភិតបំភ័យអ្នកបោះឆ្នោត ឧបសគ្គសម្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត និងករណីទិញទឹកចិត្តអ្នកបោះឆ្នោតជាដើម។ តារាងទី១៣ ខាងក្រោម គឺជាទម្រង់នៃភាពមិនប្រក្រតី និងចំនួនករណីដែលសង្កេតឃើញក្នុងអំឡុងពេលបោះឆ្នោតដោយអ្នកសង្កេតការណ៍ខុមហ្វ្រែល:

តារាងទី១៣: ភាពមិនប្រក្រតីសង្កេតឃើញក្នុងអំឡុងពេលបោះឆ្នោត

ទម្រង់នៃភាពមិនប្រក្រតី	ចំនួនករណី
ឧបសគ្គចំពោះអ្នកបោះឆ្នោតនៅតាមការិយាល័យបោះឆ្នោត ដែលរួមមានដូចជា: ១. អ្នកបោះឆ្នោតគ្មានឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់ការបោះឆ្នោត។ ២. អ្នកបោះឆ្នោតគ្មានប័ណ្ណព័ត៌មានអ្នកបោះឆ្នោតដែលធ្វើឱ្យពួកគេពិបាកក្នុងការស្វែងរកឈ្មោះ និងការិយាល័យបោះឆ្នោត។ ៣. ករណីខុសឈ្មោះ ឬទិន្នន័យរបស់អ្នកបោះឆ្នោត។ ៤. ករណីបាត់ឈ្មោះ ឬរកការិយាល័យបោះឆ្នោតមិនឃើញ។ ករណីនេះបានធ្វើឱ្យអ្នកបោះឆ្នោតមួយចំនួនមិនបានបោះឆ្នោត។	១,២៧៦
ករណីបាត់ភាពសម្ងាត់នៃការបោះឆ្នោត។ ករណីទាំងនោះមានដូចជា ជញ្ជាំងរហែក ការសាកសួរ ការលបមើល ការបើកបង្អួចមើល ការថតរូប ឬការិយាល័យបោះឆ្នោតនៅក្រោយផ្ទះប្រជាពលរដ្ឋ ដែលអាចមើល។	១៦៥
ករណីខ្វះសម្ភារៈមួយចំនួនបង្កឱ្យមានការរាំងស្ទះដល់ការបើកការិយាល័យបោះឆ្នោត ឬរាប់សន្លឹកឆ្នោត ឬការរៀបចំមិនតាមគំរូប្លង់របស់ គ.ជ.ប។	១០៥
ករណីមិនពិនិត្យម្រាមដៃ ឬមិនជ្រលក់ទឹកខ្មៅលុបលាងមិនជ្រះ។	៨៩
វត្តមានដោយខុសច្បាប់របស់អាជ្ញាធរមូលដ្ឋាន ជាពិសេស មេភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់ ឬ/និងកងកម្លាំងប្រដាប់អាវុធ (ដែលមិនមានពាក់ប្រឡង់ដៃសន្តិសុខរបស់គ.ជ.ប) នៅមុខ ឬក្បែរការិយាល័យបោះឆ្នោត ឬស្លៀកពាក់ឯកសណ្ឋាន ឬមានសកម្មភាពបំភិតបំភ័យអ្នកបោះឆ្នោត។	៨៦
ករណីបដិសេធមិនឱ្យអ្នកសង្កេតការណ៍ ឬភ្នាក់ងារគណបក្សនយោបាយចូលសង្កេតក្នុងការិយាល័យបោះឆ្នោត ឬរាប់សន្លឹកឆ្នោត។	៨៥
ករណីបើកការិយាល័យបោះឆ្នោតយឺតជាងម៉ោង ៧:០០នាទីព្រឹក ដោយគ្មានមូលហេតុត្រឹមត្រូវ។	៨០
ករណីមិនមានបង្ហាញហិបឆ្នោតទទេ មុនពេលចាប់ផ្តើមដំណើរការបោះឆ្នោត។	៨០
ករណីមិនពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យក្នុងឯកសារ និងបញ្ជីបោះឆ្នោត។	៧៤
ករណីការផ្អាក ឬបិទការិយាល័យនៅពេលកំពុងដំណើរការបោះឆ្នោត។	៧០
ករណីបដិសេធ ឬមិនអើពើ ឬមិនព្រមប្រគល់ទម្រង់ប្តឹងតវ៉ាឬ ជំទាស់(លេខ១២០២)ទៅអ្នកបោះឆ្នោត ឬភ្នាក់ងារគណបក្ស នយោបាយ ពីសំណាក់មន្ត្រីការិយាល័យបោះឆ្នោត។	៦៧
ករណីរារាំងអ្នកបោះឆ្នោតដោយវិធីផ្តល់លុយកាក់ ឬសម្ភារៈ ដើម្បីកុំឲ្យទៅបោះឆ្នោត។	៣

ករណីមិនប្រក្រតីផ្សេងទៀត	៩៦
សរុបករណីមិនប្រក្រតី	**២,២៧៦**

៩.៦.២ ភាពមិនប្រក្រតីក្នុងអំឡុងពេលរាប់សន្លឹកឆ្នោត

ការរាប់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ នាថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៧ នៅការិយាល័យភាគច្រើន បានប្រព្រឹត្តទៅស្របតាមនីតិវិធី។ ទន្ទឹមគ្នានេះ អ្នកសង្កេតការណ៍ខុមហ្វ្រែលបានរកឃើញនូវភាពមិនប្រក្រតីប្រមាណ៧៦៨ករណី។ ករណីមិនប្រក្រតីទាំងនេះមានដូចជា: ការមិនអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ចូលដំណើរការរាប់សន្លឹកឆ្នោត ការទទួលស្គាល់សន្លឹកឆ្នោតមិនបានការ ឬមិនបានការដោយគ្មានការត្រួតពិនិត្យពីភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ការបិទទ្វារ ឬបង្អួចការិយាល័យរាប់សន្លឹកឆ្នោត ការរាប់សន្លឹកឆ្នោតដោយអានញាប់ពេក ឬមិនបានបង្ហាញឲ្យឃើញច្បាស់ពីគំនូសសន្លឹកឆ្នោត ភាពខុសគ្នារវាងសន្លឹកឆ្នោតក្នុងហិបឆ្នោតដែលបានរាប់ឃើញ និងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ការពន្យារពេលរាប់សន្លឹកឆ្នោត ឬបិទការិយាល័យរាប់សន្លឹកឆ្នោត ការមិនផ្តល់ឱ្យនូវកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដល់ភ្នាក់ងារគណបក្សនយោបាយ ឬមិនបិទផ្សាយកំណត់ហេតុនេះនៅមុខការិយាល័យ ការមិនមូលភ្ជិតសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោត និងមិនចាក់សោឃ្លុំហិបឆ្នោត ការរំខាន រារាំងដល់ដំណើរការរាប់សន្លឹកឆ្នោត និងការប្រកាសរាប់សន្លឹកឆ្នោតដោយមិនត្រឹមត្រូវ ឬដោយបន្លំ។ តារាងទី១៤ ខាងក្រោមគឺបង្ហាញអំពីទម្រង់នៃភាពមិនប្រក្រតី និងចំនួនករណីមិនប្រក្រតីក្នុងអំឡុងពេលរាប់សន្លឹកឆ្នោតដែលបានរាយការណ៍ដោយអ្នកសង្កេតការណ៍ខុមហ្វ្រែល:

តារាងទី១៤: ភាពមិនប្រក្រតីសង្កេតឃើញក្នុងអំឡុងពេលរាប់សន្លឹកឆ្នោត

ទម្រង់នៃភាពមិនប្រក្រតី	ចំនួនករណី
ករណីមិនអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ចូលដំណើរការរាប់សន្លឹកឆ្នោត។	៩៨
ករណីទទួលស្គាល់សន្លឹកឆ្នោតមិនបានការ ខូច ឬការបដិសេធលើសន្លឹកឆ្នោតគួសត្រឹមត្រូវ ដោយគ្មានការត្រួតពិនិត្យពីភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍។	៩៦
ករណីបិទទ្វារ ឬបង្អួចការិយាល័យរាប់សន្លឹកឆ្នោតនៅពេលកំពុងដំណើរការរាប់សន្លឹកឆ្នោត។	៨៣
ករណីការរាប់សន្លឹកឆ្នោត ដោយអានញាប់ពេក ឬ មិនបាន បង្ហាញឲ្យឃើញច្បាស់ពីគំនូសសន្លឹកឆ្នោត។	៧៨
ភាពខុសគ្នារវាងសន្លឹកឆ្នោតក្នុងហិបឆ្នោតដែលបានរាប់ឃើញ និងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត។	៧៣
ករណីពន្យារពេលការរាប់សន្លឹកឆ្នោត ឬបិទការិយាល័យរាប់សន្លឹកឆ្នោតដែលកំពុងដំណើរការរាប់។	៧១
ករណីមិនផ្តល់ឱ្យនូវកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត(ទ.១១០២) ដល់ភ្នាក់ងារគណបក្សនយោបាយ ឬមិនបិទផ្សាយកំណត់ហេតុនេះនៅមុខការិយាល័យ។	៧០

ករណីការមិនមួលភ្ជិតសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោត និងមិនចាក់សោឃ្លុំហិបឆ្នោត។	៦៨
ករណីការរំខាន រារាំង ដល់ដំណើរការរាប់សន្លឹកឆ្នោត។	៦៨
ករណីមិនត្រឹមត្រូវ ឬបន្លំលើការប្រកាសរាប់សន្លឹកឆ្នោត។	៦៣
សរុបករណីមិនប្រក្រតី	**៧៦៨**

១០ .បណ្តឹង និងដំណោះស្រាយទាក់ទងការបោះឆ្នោត

ដំណើរការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ ក៏រួមបញ្ចូលផងដែរអំពីប្រព័ន្ធដោះស្រាយវិវាទនៅក្នុងដំណាក់កាលនានានៃដំណាក់កាលនៃការបោះឆ្នោតមួយ។ យន្តដោះស្រាយបណ្តឹងបោះឆ្នោត ត្រូវបើកអោយអ្នកបោះឆ្នោត បេក្ខជនឈរឈ្មោះ និងគណបក្សនយោបាយ អាចតតាំង និងលើកឡើងពីកង្វល់ផ្សេងៗ និងត្រូវទទួលបានការដោះស្រាយត្រឹមត្រូវ និងយុត្តិធម៌។ ប្រព័ន្ធដោះស្រាយបណ្តឹងដែលមានប្រសិទ្ធភាពសម្រាប់ដោះស្រាយពាក្យបណ្តឹង ត្រូវធានាដល់អ្នកបោះឆ្នោត បេក្ខជនឈរឈ្មោះ និងគណបក្សនយោបាយអំពីកង្វល់ ឬការចង់បានរបស់ពួកគេ ត្រូវបានគេយកចិត្តទុកដាក់យ៉ាងម៉ឺងម៉ាត់ និងឆ្លងកាត់ការដោះស្រាយដោយតម្លាភាព។

យន្តការសម្រាប់ការដោះស្រាយពាក្យបណ្តឹងបោះឆ្នោត ត្រូវធ្វើឱ្យប្រាកដថា អ្នកបោះឆ្នោត បេក្ខជនឈរឈ្មោះ និងគណបក្សនយោបាយ ដែលចូលរួមប្រកួតប្រជែងទាំងអស់ មានឱកាសក្នុងការបញ្ចេញសំឡេងតាមរយៈដំណើរការបណ្តឹង និងទទួលបានការដោះស្រាយទាន់ពេលវេលាលើបណ្តឹងដែលភាគីបានប្តឹង ហើយយន្តការនេះក៏ត្រូវបើកអោយមានការប្តឹងឧទ្ធរណ៍ ជំទាស់នឹងការសម្រេចចិត្តនានា ដែលធ្វើឡើងដោយស្ថាប័នដោះស្រាយបោះឆ្នោតជាន់ទាប។ ប្រព័ន្ធសម្រាប់ការដោះស្រាយពាក្យបណ្តឹងបោះឆ្នោតចាំបាច់ត្រូវកសាងជំនឿទុកចិត្ត ឬភាពជឿជាក់ពីសាធារណជន ហើយភាពជឿទុកចិត្តបាន និងត្រូវតែជាស្ថាប័នរដ្ឋបាល ឬតុលាការដែលទទួលបន្ទុកលើដំណើរការនៃការដោះស្រាយពាក្យបណ្តឹងដែលត្រូវបានគេចាត់ទុកថាជាស្ថាប័នមិនលំអៀង មានតម្លាភាព និងឯករាជ្យ។ យន្តការដោះស្រាយបណ្តឹងនានា ត្រូវលើកកម្ពស់តម្លាភាពភាព បើកទូលាយ មានគណនេយ្យភាពក្នុងដំណើរការបោះឆ្នោត ប្រព័ន្ធនយោបាយ និងជំរុញអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យឱ្យកាន់តែទូលំទូលាយ។ ដោយមានដំណើរការដោះស្រាយតាមរយៈដំណើរការពាក្យបណ្តឹង អ្នកបោះឆ្នោត បេក្ខជនឈរឈ្មោះបោះឆ្នោត និងគណបក្សនយោបាយ ដែលចូលរួមប្រកួតប្រជែង គួរមានសមត្ថភាពអាចយល់ដឹងអោយបានជ្រាលជ្រៅ ស៊ីជម្រៅ អំពីនីតិវិធីវាយតម្លៃសុចរិតភាព នៃដំណើរការដោះស្រាយបណ្តឹង និងការទាមទាររកភាពយុត្តិធម៌ តម្លាភាព ការទទួលបានព័ត៌មាន និងគណនេយ្យភាព។ គ្រប់គណបក្សនយោបាយត្រូវបានធានាថា ពួកអាចគេទទួលបានការគោរពដោយភាពស្មើគ្នាចំពោះមុខច្បាប់ និងគ្រប់ទិដ្ឋភាពច្បាប់ បទដ្ឋានគតិយុត្តិផ្សេងៗដែលពាក់ព័ន្ធ។

ក្រុមអង្គការសង្គមស៊ីវិលឃ្លាំមើលការបោះឆ្នោតឯករាជ្យ និងមិននិន្នាការនយោបាយ ដូចជាអង្គការខុមហ្វ្រែល បានវាយតម្លៃអំពីតម្លាភាព និងយុត្តិធម៌ ភាពត្រឹមត្រូវនៃដំណើរការដោះស្រាយពាក្យបណ្តឹងតាមរយៈការត្រួតពិនិត្យ ដើម្បីធ្វើឱ្យមានកំណត់ត្រាត្រឹមត្រូវផ្សព្វផ្សាយព័ត៌មាន និងធានាការយល់ដឹងជាសា

ធារណៈ ហើយបានលើកអនុសាសន៍ស្នើឱ្យមានការកែលម្អសម្រាប់ការអនុវត្តន៍សម្រាប់ការបោះឆ្នោតនាពេលអនាគត។ អង្គការសង្គមស៊ីវិលក្នុងស្រុក រួមជាមួយអង្គការខុមហ្វ្រែល ជាពិសេសការវាយតំលៃជារួមដែលធ្វើឡើងដោយសមាជិកក្រុមការងារអតីតបន្ទប់ស្ថានការណ៍ សង្កេតឃើញថា យន្តការដោះស្រាយវិវាទនៃបណ្តឹងបោះឆ្នោតដែលធ្វើឡើងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) និងស្ថាប័នដែលមានសមត្ថកិច្ចជាន់ថ្នាក់របស់ខ្លួននៅថ្នាក់ក្រោមជាតិដែលស្ថិតនៅក្រោមការគ្រប់គ្រង ចំពោះការដោះស្រាយបណ្តឹងបោះឆ្នោត មិនទាន់បានប្រសើរឡើងខ្លាំងគួរអោយកត់សំគាល់នៅឡើយទេ។[127] យើងបានរកឃើញថា ការដោះស្រាយបណ្តឹងនៅតែមានបញ្ហាប្រឈមមួយចំនួន និងទាមទារអោយមានការកែលម្អឱ្យប្រសើរឡើង ដើម្បីធានាឱ្យមានដំណោះស្រាយជម្លោះការបោះឆ្នោតប្រកបដោយប្រសិទ្ធភាព តម្លាភាព បើកចំហ អាចជឿទុកចិត្តបាន និងស្របតាមច្បាប់ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតនៅពេលអនាគត។ ការសង្កេត និងវិភាគលើដំណើរការនៃការដោះស្រាយបណ្តឹងរកឃើញថា ការដោះស្រាយនៅមានខ្វះតម្លាភាព ខ្វះមធ្យោបាយច្បាស់លាស់ដើម្បីធ្វើអោយមានទំនាក់ទំនងគ្នា រវាងការសម្រេចចិត្តរបស់ស្ថាប័នដោះស្រាយបណ្តឹង ជាមួយបទបញ្ញត្តិនៃច្បាប់ពាក់ព័ន្ធនឹងការបោះឆ្នោតក្រុមប្រឹក្សាឃុំ និងបទបញ្ជា និងនីតិវិធីរៀបចំការបោះឆ្នោត និងមានករណីបដិសេធមិនទទួលដោះស្រាយបណ្តឹងយ៉ាងច្រើនសន្ធឹកសន្ធាប់ បើទោះបី ជាអង្គហេតុរកឃើញថា វាគួរតែត្រូវបានដោះស្រាយក៏ដោយចុះ ឬបានបដិសេធការស្នើសុំរាប់សន្លឹកឆ្នោតឡើងវិញនៅក្នុងការិយាល័យបោះឆ្នោតជាក់លាក់ជាច្រើនបន្ទាប់ពីមានពាក្យបណ្តឹងអំពីភាពមិនប្រក្រតី។ ទី១ បណ្តឹងពាក់ព័ន្ធនឹងការស្នើសុំអោយមានការដាក់ទោសពិន័យ នៅពេលដែលអ្នកប្រព្រឹត្តខុសត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តរំលោភបំពាន នឹងបទបញ្ញត្តិនៃច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត។[128] ដូច្នេះ គោលបំណងនៃការដាក់ពាក្យបណ្តឹងនេះ គឺស្នើសុំអោយ គ.ជ.ប ដាក់ទោសពិន័យយោងទៅតាមច្បាប់ដែលមានចែង។ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតរាជធានី ខេត្ត និងគណៈកម្មការរៀបចំការបោះឆ្នោតឃុំ សង្កាត់ ត្រូវបានផ្តល់អំណាចដោយច្បាប់ក្នុងការដោះស្រាយបណ្តឹងបោះឆ្នោត ដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងការប្រើប្រាស់ដែនសមត្ថកិច្ច ឆន្ទានុសិទ្ធិក្នុងកម្រិតណាមួយ ដើម្បីធ្វើសេចក្តីសម្រេចលើបណ្តឹងបោះឆ្នោត ការបដិសេធបណ្តឹង និងបដិសេធមិនដោះស្រាយបណ្តឹង។ ទី២ បណ្តឹងបោះឆ្នោត ដែលប្តឹងជំទាស់នឹងសេចក្តីសម្រេចលើលទ្ធផលបោះឆ្នោតបឋម ដែលត្រូវបានប្រកាសដោយគណៈកម្មការបោះឆ្នោតឃុំ សង្កាត់។ បណ្តឹងប្រភេទនេះ អាចបណ្តឹងដោយតំណាងគណបក្សនយោបាយ ឬភ្នាក់ងារគណបក្សនយោបាយដែលបានចូលរួមសង្កេតការណ៍បោះឆ្នោត និងអ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតក្នុងឃុំសង្កាត់នោះ ប្រសិនបើយល់ថា លទ្ធផលបឋមនៃការបោះឆ្នោតមានភាពមិនប្រក្រតី ដែលបានកើតឡើងក្នុងថ្ងៃស ថ្ងៃបោះ និងថ្ងៃរាប់សន្លឹកឆ្នោត។ គណបក្សនយោបាយដែលបានចុះឈ្មោះប្រកួតប្រជែង និងប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោត អាចដាក់ពាក្យបណ្តឹងទៅកាន់គណៈកម្មការរៀបចំការបោះ

[127] See the Joint-Statement of Situation Room for 2017-Commune/Sangkat Election.

[128] The election campaign period of the 2017 Commune/Sangkat Election began on 20 May 2017, and ended on 2 June 2017

ឆ្នោតរាជធានីខេត្ត ជំទាស់នឹងលទ្ធផលបោះឆ្នោតបឋមដែលសម្រេចដោយគណៈកម្មការរៀបចំការបោះឆ្នោតឃុំសង្កាត់ ក្នុងរយៈពេល ៣ថ្ងៃបន្ទាប់ពីថ្ងៃបិទផ្សាយលទ្ធផលបោះឆ្នោតបឋម។[129] បណ្តឹងទាំងនោះអាចពាក់ព័ន្ធ ឧទាហរណ៍ ការស្នើសុំអោយរាប់សន្លឹកឆ្នោតឡើងវិញ ដោយផ្អែកលើភាពមិនប្រក្រីជាក់លាក់ដែលបានកើតឡើងក្នុងការិយាល័យបោះឆ្នោតជាក់លាក់ណាមួយ ឬច្រើន។ ភាពមិនប្រក្រតីទាំងនោះអាចជា ចំនួនសន្លឹកឆ្នោតមិនបានការច្រើនពេកនៅក្នុងការិយាល័យនោះជាដើម។ អង្គការខុមហ្វ្រែល រកឃើញថា បញ្ហាទាំងអស់ខាងលើនេះ គឺជាបញ្ហាចំបងសម្រាប់ការដោះស្រាយបណ្តឹងបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧។ ការបោះឆ្នោតឃុំសង្កាត់អាណត្តិទី៤នេះ គណបក្សនយោបាយដែលបានចូលរួមប្រកួតប្រជែង ជាពិសេសគណបក្សសង្គ្រោះជាតិ ដែលជាគណបក្សជំទាស់ដ៏ធំជាងគេ ពួកគេបានចាត់ទុកថា សន្លឹកឆ្នោតមិនបានការ គឺជាបញ្ហាចំបងដែលបានកើតឡើងស្ទើរតែគ្រប់ការិយាល័យបោះឆ្នោត។ មានបណ្តឹងស្នើសុំអោយរាប់សន្លឹកឆ្នោត ជាច្រើន ដែលត្រូវបានប្តឹងដោយគណបក្សនយោបាយ ពិសេសនៅក្នុងឃុំសង្កាត់ដែលមានសំលេងលម្អៀងគ្នាតិចតួចរវាងគណបក្សនយោបាយធំៗទាំងពីរ ក្នុងចន្លោះរវាងតិចជាង ០,៥ ភាគរយ ខណៈដែលក្នុងឃុំ សង្កាត់ទាំងនោះ ក៏មានចំនួនសន្លឹកឆ្នោតមិនបានការច្រើន។ សន្លឹកឆ្នោតមិនបានការអាចពាក់ព័ន្ធជាមួយភាពមិនប្រក្រតីនៃគំនូសសន្លឹកឆ្នោតដែលមានទំនាស់គ្នា។ យោងតាមរាយការណ៍របស់ គ.ជ.ប មានបណ្តឹងរហូតដល់ទៅ ៥២ភាគរយ ជាបណ្តឹងស្នើសុំអោយរាប់សន្លឹកឆ្នោតឡើងវិញ ក្រោយពីការប្រកាសលទ្ធផលបឋមតាមឃុំ សង្កាត់ ក្នុងនោះ ៣០ភាគរយនៃបណ្តឹង គឺប្តឹងដោយគណបក្សសង្គ្រោះជាតិ។ ជាងនេះទៀត បណ្តឹងពាក់ព័ន្ធនឹងការស្នើសុំអោយរាប់សន្លឹកឆ្នោតនៅតាមការិយាល័យមួយចំនួន ប្រមាណជា ៣៣ភាគរយ ត្រូវបានប្តឹងនៅអំឡុងថ្ងៃបោះ ថ្ងៃរាប់សន្លឹកឆ្នោត និងមុនម៉ោង១១ កន្លះព្រឹក បន្ទាប់ពីថ្ងៃបោះឆ្នោត (មុនថ្ងៃប្រកាសលទ្ធផលបឋមតាមឃុំសង្កាត់)។

មានបណ្តឹងជាច្រើនដែលពាក់នឹងសំណើស្នើសុំអោយរាប់សន្លឹកឆ្នោតឡើងវិញ ជាក់ស្តែងគឺការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលការបោះឆ្នោតនេះ ភាគរយនៃនៃការឈ្នះប្រកៀកប្រកើយគ្នារវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ គឺខុសគ្នាមិនដល់ ០.០៥ភាគរយផង។ មានសន្លឹកឆ្នោតដែលទុកជាមោឃៈជាច្រើនសន្លឹក មិនត្រូវបានរាប់បញ្ចូលនៅឯមណ្ឌលបោះឆ្នោតតាមគោលដៅ នៅក្នុងឃុំទាំងនោះ។

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ បើកសិទ្ធិអោយគណបក្សនយោបាយដែលចុះឈ្មោះប្រកួតប្រជែងក្នុងឃុំសង្កាត់នីមួយៗ និងភាគីពាក់ព័ន្ធនឹងផលប្រយោជន៍នៃបណ្តឹង រួមមានជនរងគ្រោះ និងជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ផ្សេងៗនៃវិវាទ ឬជនដែលមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់នោះ មានសិទ្ធិដាក់ពាក្យបណ្តឹងចំពោះមុខអាជ្ញាធរមានសមត្ថកិច្ច (ស្ថាប័នដែលមានសមត្ថកិច្ចស្ថិតនៅក្រោមការគ្រប់គ្រងរបស់ គ.ជ.ប)។ ពាក្យបណ្តឹងក៏អាចដាក់បានផងដែរ ចំពោះមុខប្រធាន

[129] មាត្រា ១៤៩ នៃច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៦។

ការិយល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត។[130] នៅក្នុងដំណាក់កាលនៃការបូកសរុបលទ្ធផលបោះឆ្នោតតាមឃុំ សង្កាត់ (ពេលវេលាបន្ទាប់ពីថ្ងៃបោះ និងរាប់) ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកតំណាង ក៏ត្រូវបានផ្តល់សិទ្ធិដាក់ពាក្យបណ្តឹងតវ៉ាចំពោះមុខប្រធានគណៈកម្មការបោះឆ្នោតរៀបចំការបោះឆ្នោតឃុំ សង្កាត់បានដែរ ដោយផ្អែកទៅលើភាពមិនប្រក្រតីដែលកើតមាននៅពេលកំពុងបូកសរុប។ បណ្តឹងទាំងនោះ អាចជាបណ្តឹងស្នើសុំអោយមានការផ្តន្ទាទោសតាមច្បាប់កំណត់។[131] គណបក្សនយោបាយ អាចដាក់ពាក្យបណ្តឹងក្នុងរយៈពេលបីថ្ងៃបន្ទាប់ពីថ្ងៃបិទផ្សាយលទ្ធផលបោះឆ្នោតបឋមនៅតាមឃុំសង្កាត់។[132] ខុមប្រឹ្វលសង្កេតឃើញថា មានចំណុចប្រសើរខ្លះពាក់ព័ន្ធនឹងការដោះស្រាយបណ្តឹង បើធៀបនឹងការបោះឆ្នោតមុនៗ ដូចជាការបំពេញតួនាទី ការងាររបស់មន្ត្រី គ.ជ.ប ក្នុងការទទួល និងពិនិត្យលើពាក្យបណ្តឹង និងផ្នែកខ្លះនៃការដោះស្រាយបណ្តឹង។ ទោះជាយ៉ាងណា វានៅតែមានបញ្ហាច្រើនខ្លះទៀត ដែលទាមទារអោយមានការកែលម្អនូវគោលការណ៍ និងនីតិវិធីសមរម្យ និងយុត្តិធម៌សម្រាប់ការដោះស្រាយបណ្តឹង។ គណបក្សនយោបាយ និងអ្នកតំណាង បានឆ្លុះបញ្ចែងថា ពួកគេនៅតែជួបប្រទះការលំបាក មានបញ្ហាប្រឈមនៅឡើយ ចំពោះដំណើរការនៃការដាក់ពាក្យបណ្តឹងទៅកាន់ស្ថាប័នដោះស្រាយបណ្តឹង ក្រោមបង្គាប់របស់ គ.ជ.ប មួយចំនួននៅថ្នាក់ក្រោមជាតិ។

មន្ត្រីទទួលបន្ទុកទទួលពាក្យបណ្តឹង មានការយល់ដឹងប្រសើរជាងមុន និងធ្វើការប្រុងប្រយ័ត្ន និងហ្មត់ចត់ជាងមុន លើការអនុវត្តន៍ច្បាប់ បទបញ្ជា និងនីតិវិធី។ ជាទូទៅនៅក្នុងដំណាក់កាលនៃការទទួលពាក្យបណ្តឹង មន្ត្រីទទួលបន្ទុកទាំងនោះ ធ្វើសេចក្តីសម្រេចចិត្តដោយផ្អែកលើលក្ខខណ្ឌ ២សំខាន់ៗ គឺ(១) បណ្តឹងត្រូវតែមានឈ្មោះ អាសយដ្ឋាន របស់ដើមបណ្តឹង ឬអ្នកតំណាង និង (២) កម្មវត្ថុនៃបណ្តឹង (ជាបណ្តឹងពាក់ព័ន្ធនឹងការបោះឆ្នោត ដែលចែងក្នុងច្បាប់បោះឆ្នោត ហើយមិនមែនជាបណ្តឹងព្រហ្មទណ្ឌសុទ្ធ) និងអាជ្ញាយុកាល (រយៈពេល) ក្នុងការដាក់ពាក្យបណ្តឹង។ អាជ្ញាយុកាលនៃការដាក់ពាក្យបណ្តឹងមានន័យថា បណ្តឹងបោះឆ្នោតត្រូវតែដាក់នៅក្នុងអំឡុងពេលវេលាដែលច្បាប់បានកំណត់។ ឧទាហរណ៍ បើបណ្តឹងមួយពាក់ព័ន្ធនឹងភាពមិនប្រក្រតី ដែលកើតឡើងក្នុងថ្ងៃស ឬថ្ងៃបោះ និងថ្ងៃរាប់ បណ្តឹងទាំងនោះត្រូវដាក់អោយបានមុនម៉ោង ១១ និង៣០នាទីព្រឹក នៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោតជាកំហិត។[133] លើសពីនេះ បើមន្ត្រីទទួលពាក្យបណ្តឹងពិនិ

---

[130] បណ្តឹងដែលពាក់ព័ន្ធនឹងភាពមិនប្រក្រតីក្នុងដំណាក់កាលបោះ និងរាប់សន្លឹកឆ្នោត។ បណ្តឹងទាំងនោះអាចប្តឹងជំទាស់/ប្រឆាំងនឹងជនណាដែលពាក់ព័ន្ធជាមួយនឹងការប្រព្រឹត្តិមិនប្រក្រតី ឬបំពានច្បាប់ រួមទាំងមន្ត្រីរបស់ គជប ផងដែរ។ ពាក្យបណ្តឹងជាទូទៅ គឺត្រូវបានប្តឹងដោយភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមានសង្កេតការណ៍នៅការិយាល័យដែលកើតមានភាពមិនប្រក្រតីទាំងនោះ។ បើសិនជាភ្នាក់ងារគណបក្សនយោបាយរូបនោះ មិនអាចដាក់ពាក្យបណ្តឹងកើត គាត់អាចផ្ទេរសិទ្ធិជាលាយលក្ស័ណ៍អក្សរទៅជនដទៃជាតំណាង។ បណ្តឹងប្រភេទនេះ ត្រូវតែដាក់មិនអោយលើសពីម៉ោង១១ កន្លះ នៅថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត។

[131] អានប្រការ ១០.២.៣.១ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧។

[132] ៣ថ្ងៃ គឺជាការកំណត់ដោយច្បាប់(អាជ្ញាយុកាលនៃបណ្តឹង) សម្រាប់ដើមបណ្តឹងដាក់ពាក្យបណ្តឹង។ បើហួសរយៈពេលកំណត់នេះ វាត្រូវបានគេចាត់ទុកថា ជាការថ្លស់សិទ្ធិ។

[133] អានប្រការ១០.៨ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧។

ត្យឃើញថា បណ្តឹងមានខ្វះព័ត៌មានសំខាន់ ពួកគេតម្រូវទាមទារអោយដើមបណ្តឹងបំពេញ ឬស្វែងរកបន្ថែមមកបំពេញ បើសិនជាមិនគ្រប់គ្រាន់ព័ត៌មានសំខាន់នោះ ពួកគេនឹងបដិសេធមិនទទួលពាក្យបណ្តឹងនោះ។ ខុមព្រៀលសង្កេតឃើញថា ចំនួនបណ្តឹងបានធ្លាក់ចុះច្រើន បើធៀបជាមួយការបោះឆ្នោតឃុំ សង្កាត់នៅឆ្នាំ២០១២។ នៅក្នុងដំណាក់កាលឃោសនាបោះឆ្នោត បណ្តឹងមួយចំនួនត្រូវបានប្តឹងប្រឆាំងគណបក្សជំទាស់ ប៉ុន្តែបណ្តឹងស្តីពីភាពមិនប្រក្រតីកើតក្នុងថ្ងៃស ថ្ងៃបោះ និងរាប់សន្លឹកឆ្នោត ត្រូវបានប្តឹងដោយគណបក្សសង្គ្រោះជាតិច្រើនជាង។[134] ជាងនេះទៅទៀត បណ្តឹងភាគច្រើនដែលប្តឹងដោយគណបក្សប្រជាជនកម្ពុជា គឺជាបណ្តឹងស្នើសុំអោយមានការផ្តន្ទាទោសប្រឆាំងនឹងគណបក្សជំទាស់ ខណៈដែលបណ្តឹងភាគច្រើនរបស់គណបក្សសង្គ្រោះជាតិ គឺជាបណ្តឹងស្នើសុំរាប់សន្លឹកឆ្នោតឡើងវិញ។[135]

១០.១ ការទទួល និងការដោះស្រាយបណ្តឹងនៅក្នុងដំណាក់កាលឃោសនាបោះឆ្នោត

១០.១.១ ការទទួល និងដោះស្រាយបណ្តឹងនៅថ្នាក់គណៈកម្មការរៀបចំការបោះឆ្នោតឃុំសង្កាត់

ការឃោសនាបោះឆ្នោតឃុំសង្កាត់បានប្រព្រឹត្តទៅ ចាប់ពីថ្ងៃទី២០ ខែឧសភា និងបញ្ចប់ទៅវិញនៅថ្ងៃទី០២ ខែមិថុនាឆ្នាំ២០១៧ (មានរយៈពេល១៤ថ្ងៃគត់)។ ការឃោសនាការបោះឆ្នោតឃុំសង្កាត់ បានប្រព្រឹត្តទៅដោយសន្តិវិធី គ្មានអំពើហឹង្សា និងមានឧបទ្ទហេតុតិចតួចប៉ុណ្ណោះដែលបានកើតឡើង។ ការឃោសនាបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០១២ ត្រូវបានកត់សំគាល់ឃើញថា គណបក្សប្រឆាំងបានដើរតួនាទីសំខាន់ជាដើមបណ្តឹងអំពីភាពមិនប្រក្រតីនៃការប្រព្រឹត្តិបំពានច្បាប់ និងបទបញ្ញត្តិផ្សេងៗពាក់ព័ន្ធនឹងការបោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់រៀបចំការបោះឆ្នោតឃុំសង្កាត់ក្នុងរយៈពេលយុទ្ធនាការឃោសនាបោះឆ្នោត ដោយឡែកសម្រាប់មួយរយៈពេលនៃយុទ្ធនាការឃោសនាបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០១៧នេះ គណបក្សប្រជាជនកម្ពុជា ជាគណបក្សកាន់អំណាច បានដើរតួនាទីសំខាន់ជាអ្នកប្តឹងអំពីភាពមិនប្រក្រតីប្រឆាំងនឹង

---

[134] ក្នុងមួយពេញអំឡុងពេលឃោសនាបោះឆ្នោត គណបក្សប្រជាជនបានប្តឹងប្រឆាំងគណបក្សសង្គ្រោះជាតិ រហូតដល់៥៨បណ្តឹង ចំណែកគណបក្សសង្គ្រោះជាតិដាក់ពាក្យបណ្តឹងបានតែ២៣បណ្តឹងប៉ុណ្ណោះ។

[135] គណបក្សប្រជាជនកម្ពុជាបានដាក់ពាក្យបណ្តឹងរហូតដល់៤១បណ្តឹង និងគណបក្សសង្គ្រោះជាតិបានដាក់ពាក្យបណ្តឹងបាន៤៣បណ្តឹងនៅថ្នាក់គណៈកម្មការរៀបចំការបោះឆ្នោតឃុំសង្កាត់ ដែលបណ្តឹងទាំងអស់នោះគឺពាក់ព័ន្ធជាមួយភាពមិនប្រក្រតីដែលកើតឡើងក្នុងថ្ងៃស ថ្ងៃបោះ និងរាប់សន្លឹកឆ្នោត។ សម្រាប់បណ្តឹងជំទាស់នឹងលទ្ធផលបោះឆ្នោតដែលប្រកាស និងបិទផ្សាយដោយគណៈកម្មការរៀបចំការបោះឆ្នោតឃុំសង្កាត់ ភាគីគណបក្សប្រជាជនកម្ពុជាបានដាក់ពាក្យបណ្តឹងចំនួន២០បណ្តឹង និងគណបក្សសង្គ្រោះជាតិដាក់បានចំនួន៣៤បណ្តឹង ទៅកាន់គណៈកម្មការរៀបចំការបោះឆ្នោតរាជធានីខេត្ត។ នៅថ្នាក់គជប មានបណ្តឹងចំនួន១០ត្រូវបានប្តឹងឡើងមកដោយគណបក្សប្រជាជនកម្ពុជាជំទាស់នឹងសេចក្តីសម្រេចរបស់គណៈកម្មការរៀបចំការបោះឆ្នោតរាជធានីខេត្ត។ និងមានចំនួន១០បណ្តឹង២៧ បដឹងដោយគណបក្សសង្គ្រោះជាតិជំទាស់នឹងសេចក្តីសម្រេចរបស់គណៈកម្មការរៀបចំការបោះឆ្នោតរាជធានីខេត្ត។ សូមអានរបាយការណ៍ពង្រាងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧។

គណបក្សប្រឆាំងទៅវិញ។ មានបណ្តឹងមួយចំនួនត្រូវបានប្តឹងទៅតុលាការពាក់ព័ន្ធ នឹងអំពើហឹង្សាដែលបានប៉ះទង្គិចគ្នាបន្តិចបន្តួចនៅក្នុងអំឡុងពេលឃោសនាបោះឆ្នោតនៅក្នុងខេត្តតាកែវ ហើយត្រូវបានតុលាការចោទប្រកាន់បេក្ខជនក្រុមប្រឹក្សាឃុំ សង្កាត់មកពីគណបក្សសង្គ្រោះជាតិពីបទល្មើសព្រហ្មទណ្ឌ។ បណ្តឹងព្រហ្មទណ្ឌនេះ ត្រូវបានប្តឹងដោយគណបក្សប្រជាជនកម្ពុជា ហើយបច្ចុប្បន្ននេះ ករណីនេះនៅបន្តនីតិវិធីបណ្តឹងនៅតុលាការនៅឡើយ។ ទោះជាយ៉ាងណា ការចោទប្រកាន់ដ៏ធ្ងន់ធ្ងរនេះ ត្រូវបានរិះគន់យ៉ាងខ្លាំងថាវាមានជាប់ពាក់ព័ន្ធ និងជម្រុញដោយអ្នកនយោបាយ និងអ្នកមានអំណាច ដោយប្រើប្រាស់តុលាការជាឧបករណ៍។ គ.ជ.ប បានព្យាយាមផ្សះផ្សាជម្លោះបោះឆ្នោតនេះដែរ ប៉ុន្តែបានបរាជ័យដោយសារភាគីនៃដើមបណ្តឹងមិនព្រមសម្របសម្រួល និងសះជា ហើយទទូចចង់ប្តឹងអោយខានតែបាន។

ក្នុងរយៈពេល១៤ថ្ងៃនៃយុទ្ធនាការឃោសនាបោះឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតទូទាំងប្រទេស ទទួលពាក្យបណ្តឹងបានចំនួន ៨៨បណ្តឹង[136]។ បណ្តឹងទាំងអស់ គឺជាបណ្តឹងពាក់ព័ន្ធនឹងការស្នើសុំអោយមានការដាក់ទោសទណ្ឌ យោងទៅតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។ ក្នុងចំណោមបណ្តឹងទាំង៨៨ មាន៥៨បណ្តឹងត្រូវបានប្តឹងដោយគណបក្សប្រជាជនកម្ពុជា និង២៣ បណ្តឹង ប្តឹងដោយគណបក្សសង្គ្រោះជាតិ ចំនួន០១បណ្តឹង ប្តឹងដោយគណបក្សហ៊្វុនស៊ិនប៉ិច និងមាន០៦ បណ្តឹង ត្រូវបានបណ្តឹងដោយប្រជាពលរដ្ឋ។ ដំណោះស្រាយដោយការផ្សះផ្សារលើបណ្តឹងទាំង៨៨ ខាងលើដោយគណៈកម្មការរៀបចំការបោះឆ្នោតឃុំសង្កាត់មាន ដូចខាងក្រោម៖

- ៣២ បណ្តឹងត្រូវបានផ្សះផ្សាដោយសះជា
- ២៣ បណ្តឹងមិនត្រូវបានផ្សះផ្សាដោយជោគជ័យ
- ២៦ បណ្តឹងត្រូវបានជូនដំណឹងដោយគណៈកម្មការរៀបចំការបោះឆ្នោតឃុំសង្កាត់[137]
- ០៤ បណ្តឹងត្រូបានដកពាក្យបណ្តឹងដោយដើមបណ្តឹង
- ០២ បណ្តឹងត្រូវបានចារបដិសេធមិនធ្វើការដោះស្រាយ [138] និង

[136] NEC's drafted Report on the Organization and Functioning of the Commune/sangkat Election 2017.

[137] ពាក្យថា លិខិតជូនដំណឹង មិនត្រូវបានផ្តល់និយមន័យអោយជាក់លាក់ដោយ គជប ឡើយ។ តែទោះជាយ៉ាងណា ពាក្យជូនដំណឹងនេះ គឺអាចមានន័យជាសេចក្តីសម្រេចរបស់ គយ/សប គធ/ខប និង គជប។ សេចក្តីជូនដំណឹងនេះ គឺចេញតាមរយៈទម្រង់ ១២០៣ ។ វាគឺជាលិខិតរដ្ឋបាលសម្រាប់ធ្វើការឆ្លើយតបទៅកាន់ដើមបណ្តឹង និងជូនដំណឹងដល់ពួកគេអោយដឹងអំពីសេចក្តីសម្រេចរបស់ខ្លួនពាក់ព័ន្ធនឹងការដោះស្រាយបណ្តឹង (ដោយគយ/សប, គធ/ខប និងគជប)។ សេចក្តីសម្រេចនោះអាចជា ការចារបដិសេធលើ បណ្តឹងដោយមូលហេតុផ្សេងៗ សេចក្តីសម្រេចច្រានចោលមិនដោះស្រាយបណ្តឹង ការលើកចោលការដោះស្រាយបណ្តឹង ឬសេចក្តីសម្រេចទទួលដោះស្រាយបណ្តឹង។ យោងតាមច្បាប់ សេចក្តីសម្រេចទាំងអស់នេះ ត្រូវសម្រេចដោយស្ថាប័នដែលមានសមត្ថកិច្ចដោះស្រាយបណ្តឹងបោះឆ្នោតរបស់ គជប។

[138]សេចក្តីសម្រេចនេះធ្វើឡើងដោយមន្ត្រីទទួលបន្ទុកទទួលពាក្យបណ្តឹង ហើយជាទូទៅគឺចារបដិសេធចំពោះមុខម្ចាស់បណ្តឹងតែម្តង ដូចជាបណ្តឹងដែលផុតអាជ្ញាយុកាល (ផុតកំណត់ថ្ងៃ)។

- ០១ បណ្តឹងត្រូវបានលើកចោល មិនដោះស្រាយដោយ គយ.សប ដោយសារអវត្តមានដើមបណ្តឹងនៅថ្ងៃបើកសវនាការដោះស្រាយបណ្តឹង។

បើធៀបជាមួយការបោះឆ្នោតឆ្នាំ២០១៣ បណ្តឹងក្នុងដំណាក់កាលឃោសនាការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០១៧នេះ គឺមានចំនួនធ្លាក់ច្រើន ហើយបើធៀបជាមួយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សឃុំសង្កាត់ឆ្នាំ២០១២ ក្នុងដំណាក់កាលឃោសនាដូចគ្នា មានការធ្លាក់ចុះច្រើនដែរ។[139] ការធ្លាក់ចុះចំនួនបណ្តឹងយ៉ាងច្រើនសន្ធឹកសន្ធាប់នេះ អាចមកពីកត្តាមួយចំនួន ទី១ ដូចជា សកម្មភាពហឹង្សាត្រូវបានធ្លាក់ចុះច្រើន ហើយនេះអាចប្រហែលមកពីភាពភ័យខ្លាចក្នុងការអនុវត្តន៍ច្បាប់ ដែលមានចរិតតឹងតែងចែងក្នុងទោសបញ្ញត្តិក្នុងច្បាប់បោះឆ្នោតឃុំសង្កាត់ថ្មីនេះ។[140] គណបក្សនយោបាយបានបង្ហាញឥរិយាបថថាស់ទុំ ព្យាយាមអត់ធ្មត់គោរពច្បាប់ក្នុងកម្រិតខ្ពស់ជាអតិបរិមា និងប្រកបដោយការទទួលខុស ត្រូវដើម្បីបញ្ចៀសទំនាស់ ឬការប្រឈមមុខដាក់គ្នា។ ចំនួនបណ្តឹងដែលត្រូវបានដាក់តិចតួចដោយគណបក្សសង្គ្រោះជាតិ អាចបញ្ជាក់ថាសកម្មជនគណបក្សនេះ បានព្យាយាមគេចចេញពីជម្លោះ និងមានការអត់ធ្មត់ខ្លាំងចំពោះការប្រឈមដាក់គ្នាពីគណបក្សកាន់អំណាច។ ក្នុងដំណាក់កាលឃោសនាបោះឆ្នោតទាំងមូល គណបក្សសង្គ្រោះជាតិបានដាក់ពាក្យបណ្តឹងត្រឹមតែ២៣បណ្តឹងប៉ុណ្ណោះ[141] ចំណែកគណបក្សប្រជាជនកម្ពុជា បានដាក់ពាក្យបណ្តឹងរហូតដល់ចំនួន៥៨បណ្តឹង។ ទី២ អាចបណ្តាលមកពីមូលហេតុ ការរឹតត្បិតក្នុងច្បាប់ដែលតម្រូវអោយមានការដង្ហែរក្បួនព្យុហយាត្រាបានតែចំនួន២ដងប៉ុណ្ណោះក្នុងរយៈពេល១៤ថ្ងៃនៃយុទ្ធនាការឃោសនាបោះឆ្នោត ដែលផ្ទុយពីការបោះឆ្នោតកន្លងទៅ ការបង្ហែរក្បួនព្យុយាត្រា មិនត្រូវបានកំណត់ចំនួន ហើយពួកគេអាចធ្វើការឃោសនាដោយសេរី។

ទិន្នន័យនៃចំនួនបណ្តឹងបោះឆ្នោតសម្រាប់រយៈពេលឃោសនាបោះឆ្នោតឆ្នាំ២០១២ បង្ហាញអោយឃើញថា មានបណ្តឹងចំនួន១៧បណ្តឹងត្រូវបដិសេធមិនដោះស្រាយដោយ គយ/សប ខណៈ ការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០១៧ក្នុងរយៈពេលឃោសនាបោះឆ្នោត គយ/សប បដិសេធមិនដោះស្រាយមានតែពីរបណ្តឹងប៉ុណ្ណោះ។ ការបដិសេធទទួលពាក្យបណ្តឹង គឺកើតមានតាំងពីដំណាក់កាលនៃការដាក់ពាក្យបណ្តឹង។ ការសង្កេត និងវិភាគទៅលើការសង្កេតរកឃើញថា ការដោះស្រាយបណ្តឹងបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាតឆ្នាំ២០១៧នេះ សវនាការដោះស្រាយបណ្តឹងដែលដោះស្រាយយ គយ/សប

---

[140]របាយការណ៍អង្គការខុមហ្វ្រែលសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១២ ក្នុងរយៈពេលនៃការឃោសនាបោះឆ្នោត ក្នុងរយៈពេល១៥ថ្ងៃ បណ្តឹងចំនួន ៩៣បណ្តឹងត្រូវបានប្តឹងដោយគណបក្ស សម រង្ស៊ី ០៣បណ្តឹង ត្រូវបានប្តឹងដោយគណបក្សសិទ្ធិមនុស្ស ១២បណ្តឹង ត្រូវបានប្តឹងដោយគណបក្សនប្រជាជនកម្ពុជា ០៣បណ្តឹង ប្តឹងដោយគណបក្សហ៊្វុនស៊ីនប៉ិច ០១បណ្តឹង ប្តឹងដោយគណបក្សនរោត្តមឫណរិទ្ធិ ០១បណ្តឹង ប្តឹងដោយប្រជាជនធម្មតា និង០១បណ្តឹងប្តឹងដោយអាជ្ញាធរ។

[141] ក្នុងការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០១២ គណបក្សប្រជាជនកម្ពុជាដាក់ពាក្យបណ្តឹងបានចំនួន ១២បណ្តឹង ចំណែកគណបក្សជំទាស់បានដាក់ពាក្យបណ្តឹងចំនួនរហូតដល់៧១បណ្តឹង (គណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស)។

គឺមានតម្លាភាព និងមានភាពប្រសើរច្រើនក្នុងការអនុញ្ញាតអោយដើមបណ្តឹង ឬអ្នកសង្កេតការណ៍មានវត្តមាននៅក្នុងសវនការដោះស្រាយ។ គយ/សប ព្យាយាមដោះស្រាយបណ្តឹងដោយការផ្សះផ្សាអស់ពីសមត្ថភាព ហើយករណីភាគច្រើន គឺ គយ/សប សម្រេចត្រឹមតែការស្តីបន្ទោសអ្នកប្រព្រឹត្តខុស និងតម្រូវអោយសុំទោសជនរងគ្រោះ ឬគណបក្សរងគ្រោះ ចៀសជាងការសម្រេចតាមទោសបញ្ញត្តិដែលមានចែងក្នុងច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់។ មានករណីខ្លះ គយ/សប បានព្យាយាមលួងលោម និងលើកទឹកចិត្ត ជម្រុញអោយភាគីវិវាទជាសះនឹងគ្នាដោយការផ្សះផ្សា។

១០.១.២ ការទទួល និងដោះស្រាយបណ្តឹងក្នុងដំណាក់កាលឃោសនាបោះឆ្នោតនៅ គធ/ខប

នៅក្នុងដំណាក់កាលនេះ គធ/ខប បានទទួលពាក្យបណ្តឹងបានចំនួន២១បណ្តឹង ក្នុងមួយរយៈពេលឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១៧។[142] នៅក្នុងដំណាក់កាលនៃការដោះស្រាយបណ្តឹងនៅ គធ/ខប នេះ ក្នុងចំណោមបណ្តឹងទទួលបាន[143] ក្នុងនោះ មាន១៣បណ្តឹង ប្តឹងដោយគណបក្សប្រជាជនកម្ពុជា ០៧បណ្តឹង ប្តឹងដោយគណបក្សសង្គ្រោះជាតិ និងមាន០១បណ្តឹង ដែលប្តឹងដោយគណបក្សហ៊្វុនស៊ិនប៉ិច។ ក្នុងចំណោម ២១បណ្តឹងនេះ មាន២០បណ្តឹងត្រូវបានប្តឹងឡើងមកពី គយ/សប និងមាន០១បណ្តឹង ប្តឹងផ្ទាល់មក គជប។[144] រីឯលទ្ធផលដំណោះស្រាយបណ្តឹងធ្វើឡើងដោយ គធ/ខប មានដូចខាងក្រោម៖

- បណ្តឹងចំនួន០៤ ត្រូវបានដោះស្រាយដោយជោគជ័យ ដោយការផ្សះផ្សា
- បណ្តឹងចំនួន ០៣ ត្រូវបានដោះស្រាយមិនសះជា
- បណ្តឹងចំនួន ០២ ត្រូវបានបដិសេធមិនធ្វើការដោះស្រាយដោយ គធ/ខប និង
- បណ្តឹងចំនួន ១២ ត្រូវបានជូនដំណឹងដោយលិខិតជូនដំណឹង។[145]

---

[142] ចំនួននេះបានធ្លាក់ចុះយ៉ាងច្រើនបើធៀបជាមួយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣។ កាលណោះបណ្តឹងដែលត្រូវបានប្តឹងឡើងមក គធ/ខប គឺមានរហូតដល់១២២បណ្តឹង។ ក្នុងចំណោម១២២បណ្តឹងនេះ មាន៧៨បណ្តឹងត្រូវបានដោះស្រាយ និង៤៤បណ្តឹងត្រូវបានប្តឹងបន្តទៅកាន់ គជប។ សម្រាប់ការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០១២ មានបណ្តឹងសរុប២៦បណ្តឹងបានប្តឹងឡើងមកកាន់ គធ/ខប ក្នុងនោះមាន១៣បណ្តឹងមិនត្រូវបានដោះស្រាយ ហើយប្តឹងបន្តទៅកាន់ គជប។

[143] សូមអានរបាយការណ៍ពង្រាងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧។

[144] បណ្តឹងស្តីពីការប្តឹងប្រឆាំងនឹងមន្ត្រីបោះឆ្នោត។

[145] សូមអានរបាយការណ៍ពង្រាងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧។

ដំណើរការនៃការដោះស្រាយបណ្តឹងបោះឆ្នោត និងការប្រើប្រាស់យន្តការដោះស្រាយ មានដំណើរការប្រសើរនៅក្នុងដំណាក់កាលនេះ។ ដំណើរការនេះ ត្រូវបានសង្កេតឃើញថា មានតម្លាភាព និងហើយអ្នកសង្កេតការណ៍អាចចូលស្តាប់ការដោះស្រាយបណ្តឹងបាន ដោយគ្មានការហាមឃាត់។

ភាគីពាក់ព័ន្ធនឹងវិវាទ ជាពិសេសដើមបណ្តឹង អាចចូលរួមក្នុងដំណើរការដោះស្រាយបណ្តឹង មានឱកាសបានបកស្រាយនូវអង្គហេតុ បំភ្លឺទៅកាន់សវនាការនៃបណ្តឹង អ្នកសង្កេតការណ៍បោះឆ្នោតអាចចូលរួមស្តាប់ និងតាមដានការប្រព្រឹត្តិទៅនៃការដោះស្រាយបណ្តឹងដោយសេរី។ យោងតាមរបាយការណ៍របស់ គ.ជ.ប ស្តីពីបណ្តឹង មានតែបណ្តឹងចំនួន០២ប៉ុណ្ណោះ ដែលត្រូវបានបដិសេធមិនដោះស្រាយដោយ គធ/ឧប ដោយសារមូលហេតុមិនបានបណ្តឹងទាំងនោះ មិនបានគោរពពេលានៃការដាក់ពាក្យបណ្តឹង (ជាបណ្តឹងហួសអាជ្ញាយុកាល)។[146] ការសង្កេតរកឃើញថា គធ/ឧប នៃរាជធានី ខេត្តមួយចំនួនបានធ្វើការងារយ៉ាងល្អ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយបណ្តឹង ជូនគូវិវាទនៃបណ្តឹង ពិសេសតាមរយៈយន្តការនៃការផ្សះផ្សារនូវគូភាគីនៃបណ្តឹងអោយសះជានឹងគ្នា។ ខុមហ្វ្រែលរកឃើញថា គ្មានការដាក់ផ្តន្ទាទោសយោងតាមបញ្ញត្តិនៃច្បាប់បោះឆ្នោតឃុំសង្កាត់ត្រូវបានសម្រេចដោយ គធ/ឧប នោះទេ។ វាជាចំណុចវិជ្ជមានមួយដែល គធ/ឧប មិនមានសេចក្តីសម្រេចតឹងរឹង ម៉ឺងម៉ាត់ណាមួយចំពោះភាគីជាអ្នកប្រព្រឹត្តខុស។

១០.១.៣. ការដាក់ ទទួល និងដោះស្រាយបណ្តឹងក្នុងដំណាក់ឃោសនាបោះឆ្នោតនៅ គ.ជ.ប

នៅក្នុងដំណាក់កាលនៃការដោះស្រាយបណ្តឹងបោះឆ្នោតនៃដំណាក់កាលឃោសនាបោះឆ្នោត ដែលប្រព្រឹត្តទៅនៅ គ.ជ.ប មានបណ្តឹងចំនួន០៨ ដែលភាគីបានប្តឹងឧទ្ធរណ៍មកកាន់ គ.ជ.ប។[147] ក្នុងចំណោម ០៨បណ្តឹងនោះ មានបណ្តឹងចំនួន០៥ ត្រូវបានប្តឹងដោយគណបក្សប្រជាជនកម្ពុជា និងមានបណ្តឹងចំនួន០៣ ត្រូវបានប្តឹងដោយគណបក្សសង្គ្រោះជាតិ។ គ.ជ.ប បានបដិសេធលើបណ្តឹងចំនួន០១ ដោយសារបណ្តឹងនោះ ជាបណ្តឹងហួសអាជ្ញាយុកាល (ហួសថ្ងៃកំណត់) ហើយបណ្តឹងចំនួន០៧ ផ្សេងទៀត គ.ជ.ប បានចេញលិខិតជូនដំណឹងដល់ភាគីដើមបណ្តឹង។ លិខិតជូនដំណឹង បានចេញដោយ គ.ជ.ប ក្នុងអត្ថន័យបដិសេធការទទួលដោះស្រាយបណ្តឹងទាំងនោះ។ មូលហេតុមួយចំនួនដែល គ.ជ.ប បានលើកឡើងគឺ ដោយសារបណ្តឹងទាំងនោះមិនមានភស្តុតាងគ្រប់គ្រាន់ ជាបណ្តឹងមិនស្ថិតក្នុងយុត្តាធិការនៃអាណត្តិរបស់ គ.ជ.ប ហើយបណ្តឹងក្នុងសេចក្តីជូនដំណឹងខ្លះរបស់ គ.ជ.ប គឺគ្រាន់តែព្រមានចុងចម្លើយ (អ្នកប្រព្រឹត្តល្មើស) អំពីការប្រព្រឹត្តិរបស់ខ្លួនតែប៉ុណ្ណោះ។ សេចក្តីសម្រេចរបស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គឺជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។

[146] នៅក្នុងការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០១២ មានបណ្តឹងចំនួន២៦ ត្រូវបានប្តឹងឡើងមកកាន់ គធ/ឧប ក្នុងនោះមានបណ្តឹងចំនួន១៣បណ្តឹង ត្រូវបានដិសេធមិនធ្វើការដោះស្រាយដោយ គជប។

[147] យោងតាមរបាយការណ៍របស់ គជប ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧ (ពង្រាង)។

បើប្រៀបធៀបជាមួយការដោះស្រាយបណ្តឹងបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅឆ្នាំ ២០១២ ចំនួនបណ្តឹងក្នុងរយៈពេលឃោសនាបោះឆ្នោតដែលត្រូវបានដោះស្រាយនៅ គ.ជ.ប សម្រាប់ការ បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧នេះ មានការធ្លាក់ចុះយ៉ាងច្រើន។[148] ការសង្កេតរក ឃើញថា ការដោះស្រាយបណ្តឹង គ.ជ.ប បានសម្រេចចេញលិខិតជូនដំណឹងដល់ភាគីនៃបណ្តឹងមានចំនួន ច្រើនជាងសម្រេចលើការចារបដិសេធច្រានចោលមិនដោះស្រាយបណ្តឹង។ យោងតាមរបាយការណ៍បោះ ឆ្នោតឆ្នាំ២០១៣ របស់អង្គការខុមហ្រ្វែល ក្នុងរយៈមួយខែគត់នៃដំណើរការឃោសនាបោះឆ្នោតជ្រើសតាំង តំណាងរាស្ត្រ មានបណ្តឹងចំនួន៤៤បណ្តឹង ដែលត្រូវបានប្តឹងបន្តពី គធ.ខប មកកាន់ គ.ជ.ប ក្នុងនោះមាន ៣២បណ្តឹងត្រូវបានដោះស្រាយ និងមាន១២បណ្តឹង ត្រូវបានប្តឹងបន្តទៅកាន់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលជាស្ថា ប័នដោះស្រាយបណ្តឹងចុងក្រោយបំផុតសម្រាប់បណ្តឹងបោះឆ្នោតមួយចំនួន។[149] ដូច្នេះបើធៀបជាមួយការ បោះឆ្នោតជាតិឆ្នាំ២០១៣ ស្ថានភាពបណ្តឹងប្រភេទនេះ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១៧ មានភាពប្រសើរជាង។ ការអង្កេត និងវិភាគការបោះឆ្នោតឃុំ សង្កាត់ឆ្នាំ២០១៧ បានរក ឃើញថា នីតិវិធីសម្រាប់ការដោះស្រាយបណ្តឹងបោះឆ្នោត ភាពស្រពេចស្រពិលលើភាសាច្បាប់ ហើយ គធ/ ខប រាជធានី ខេត្តតែងបកស្រាយខុសគ្នា។ ការសង្កេតក៏រកឃើញដែរថា គ.ជ.ប មិនបានប្រើប្រាស់នីតិវិធីសវ នាការសាធារណៈ (សវនាការដេញដោល) ដើម្បីដោះស្រាយបណ្តឹងពាក់ព័ន្ធនឹងបណ្តឹងឃោសនាបោះឆ្នោត នេះទេ។ គ.ជ.ប បានប្រើនីតិវិធីសវនាការសង្ខេប ឬសវនាការបិទទ្វារ ដើម្បីដោះស្រាយបណ្តឹងដែលប្តឹងឡើង ពី គធ/ខប មក។ ប្រភេទសវនាការនេះ ត្រូវបានសង្កេតឃើញថា ជាប្រភេទសវនាការខ្វះតម្លាភាព ពីព្រោះ សាធារណៈជនមិនអាចចូលស្តាប់ និងតាមដាននៃការដំណើរការប្រព្រឹត្តិទៅនៃសវនាការរបស់ គ.ជ.ប ចំពោះ ការដោះស្រាយលើបណ្តឹង។ ហេតុផលមួយដែលត្រូវបានលើកដោយ គ.ជ.ប គឺដោយសារពេលវេលាខ្លីពេក សម្រាប់ដោះស្រាយបណ្តឹងដ៏ច្រើន។ មានបណ្តឹងតិចតួចប៉ុណ្ណោះ ត្រូវបានបើកការស៊ើបអង្កេតដោយ គ.ជ. ប។ ករណីដែល គ.ជ.ប បានស៊ើបអង្កេតនោះ គឺដូចជាករណីកើតឡើងនៅក្នុងខេត្តកំពង់ស្ពឺ ដែលបេក្ខជន ឈរឈ្មោះជាមេឃុំរបស់គណបក្សសង្គ្រោះជាតិ ត្រូវបានចោទប្រកាន់ពីការប្រើប្រាស់អំណោយ ដោយបានផ្ត ល់មុងជ្រលក់ថ្នាំទៅអោយអ្នកគាំទ្រ នៅអំឡុងពេលថ្ងៃឃោសនាបោះឆ្នោត។ ក្រោយពីការស៊ើបអង្កេតទៅរក ឃើញថា រឿងគឺបានកើតឡើងប្រហាក់ប្រហែលនឹងការចោទប្រកាន់មែន ប៉ុន្តែមុងដែលសន្យានោះ គឺជាមុង រហែក និងការសន្យានេះ ធ្វើតាំងពីមុនបោះឆ្នោតមកម៉្លេះ ហើយពួកគេ គឺជាមិត្តភក្តិនឹងគ្នាប៉ុណ្ណោះ។ គ.ជ.ប មិនបានសម្រេចដាក់ទោសទណ្ឌទៅលើភាគីដែលត្រូវបានចោទប្រកាន់ឡើយ ដោយគ្រាន់តែស្តីបន្ទោស និង ព្រមានពីការរំលោភបំពាននេះ និងធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ។ គួរបញ្ជាក់ដែរថា ក្នុងមួយរយៈពេល នៃការដោះស្រាយបណ្តឹងបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់នេះ ការសង្កេតរកឃើញថា គ្មានការ

[148] ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១២ មានបណ្តឹងចំនួន០៤ បណ្តឹងត្រូវបានប្តឹងមកកាន់ គ.ជ.ប ហើយក្នុងនោះមានបណ្តឹងចំនួន០៣ ត្រូវបានបដិសេធមិនដោះស្រាយដោយ គ.ជ.ប។

[149] អានរបាយការណ៍ខាងលើ។

សម្រេចផ្តន្ទាទោស ជាការពិន័យជាប្រាក់លើបណ្តឹងណាមួយត្រូវបានសម្រេចដោយ គ.ជ.ប ឬស្ថាប័នថ្នាក់ក្រោមរបស់ខ្លួនឡើយ។

១០.២ ការទទួល និងដោះស្រាយបណ្តឹង ស្តីពីភាពមិនប្រក្រតីកើតឡើងក្នុងថ្ងៃស ថ្ងៃបោះ និងរាប់សន្លឹក ឆ្នោត

១០.២.១ ការទទួល និងដោះស្រាយបណ្តឹងនៅគណៈកម្មការរៀបចំការបោះឆ្នោតឃុំសង្កាត់

មានបណ្តឹងជាច្រើនត្រូវបានដាក់ដោយភ្នាក់ងារ ឬតំណាងនៃគណបក្សនយោបាយ ដែលបានចូលរួមប្រកួតប្រជែងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ស្តីពីភាពមិនប្រក្រតីដែលបានកើតឡើងនៅថ្ងៃស (មុនថ្ងៃបោះឆ្នោត០១ថ្ងៃ) ថ្ងៃបោះ និងថ្ងៃរាប់សន្លឹកឆ្នោត។ [150] បណ្តឹងទាំងអស់នោះ អាចជាបណ្តឹងស្នើសុំអោយមានការដាក់ទោសទណ្ឌពីការប្រព្រឹត្តិរំលោភបំពានលើទោសបញ្ញត្តិ និងបទបញ្ញត្តិដែលមានចែងក្នុងច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ បទបញ្ជា និងនីតិវិធីសម្រាប់រៀបចំការបោះឆ្នោត បណ្តឹងស្តីពីភាពមិនប្រក្រតីដែលកើតឡើងនៅថ្ងៃបោះ និងថ្ងៃរាប់សន្លឹកឆ្នោត និងព្រមទាំងបណ្តឹងស្នើសុំអោយរាប់សន្លឹកឆ្នោតឡើងវិញ នៅក្នុងការិយាល័យមួយចំនួនដែលមានភាពមិនប្រក្រតីធ្ងន់ធ្ងរកើតឡើង។

បណ្តឹងទាំងនេះ ត្រូវបានប្តឹងដោយភ្នាក់ងារសង្កេតការណ៍គណបក្សនយោបាយ និងតំណាងគណបក្សនយោបាយ បេក្ខជនឈរឈ្មោះ និងអាជ្ញាធរមានសមត្ថកិច្ច ព្រមទាំងមន្ត្រី គ.ជ.ប ផងដែរ។ បណ្តឹងដែលត្រូវបានដោះស្រាយដោយ គយ.សប បែងចែកជាពីរដំណាក់កាល (១) បណ្តឹងអំពីភាពមិនប្រក្រតីដែលកើតឡើងនៅអំឡុងពេលបោះ និងរាប់ ដែលប្តឹងចំពោះប្រធានការិយាល័យបោះឆ្នោត[151] និងទី(២) បណ្តឹង

---

[150] ថ្ងៃស គឺជារយៈពេលសម្រាកការឃោសនាបោះឆ្នោត។ ច្បាប់បោះឆ្នោតបានចាត់ទុកថ្ងៃនេះជាថ្ងៃមិនអនុញ្ញាតិអោយគណបក្សនយោបាយធ្វើសកម្មភាពឃោសនាបោះឆ្នោតឡើយ ហើយបានកំណត់វាជាថ្ងៃសម្រាក មានរយៈពេល ២៤ ម៉ោង គត់។ គោលគំនិតនៃការកំណត់គឺដើម្បីអោយការឃោសនាបោះឆ្នោតមានតុល្យភាព និងទប់ស្កាត់នូវបរិយាកាសអាក្រក់ ដែលអាចនឹងកើតឡើងនៅក្នុងរយៈពេលមួយថ្ងៃ មុនថ្ងៃបោះឆ្នោត។

[151] គណបក្សនយោបាយ ឬភ្នាក់ងារគណបក្សអាចដាក់ពាក្យបណ្តឹងប្រឆាំងនឹងជនណាដែលបានរំលោភបំពានបទបញ្ញត្តិនៃច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០១៧ ដោយដាក់ពាក្យបណ្តឹងនៅចំពោះមុខប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត។ ក្នុងករណីដែលពិនិត្យឃើញភាពមិនប្រក្រតីដែលកើតឡើងក្នុងពេលបោះ និងពេលរាប់សន្លឹកឆ្នោត ភ្នាក់ងារសង្កេតការណ៍បោះឆ្នោតដែលមានសិទ្ធិ អាចដាក់ពាក្យបណ្តឹងចំពោះមុខប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត។ ប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត អាចធ្វើការអន្តរាគមដោះស្រាយបណ្តឹងនោះនៅពេលការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតកំពុងដំណើរការដោយផ្ទាល់មាត់បាន។ ករណីប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតមិនអាចដោះស្រាយបាន នៅពេលរាប់សន្លឹកឆ្នោតចប់សព្វគ្រប់ បណ្តឹងទាំងនោះត្រូវផ្ញើទៅ គយ.សប ជាអ្នកដោះស្រាយជូនភាគីដើមបណ្តឹង។ ពួកគេអាចព្យាយាមធ្វើការដោះស្រាយតាមយន្តការសម្របសម្រួលភាគីជម្លោះ ឬផ្សះផ្សាដោយផ្ទាល់មាត់ភ្លាមៗ។

អំពីភាពមិនប្រក្រតីដែលកើតឡើងនៅថ្ងៃស ថ្ងៃបោះ និងរាប់សន្លឹកឆ្នោតនៅចំពោះមុខ គយ.សប មិនអោយ ហួសរយៈពេលកំណត់ត្រឹមម៉ោង១១:៣០នាទីព្រឹក ថ្ងៃបន្ទាប់នៃថ្ងៃបោះ និងរាប់។[152]

ពាក់ព័ន្ធនឹងបណ្តឹងនៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត នីតិវិធីនៃការដោះស្រាយ បណ្តឹងត្រូវបានបែងចែកជា២ជំហាន។ ជំហានទី១ ទទួល និងសម្រេចដោះស្រាយពាក្យបណ្តឹងធ្វើឡើង ដោយគណកម្មការបោះ និងរាប់សន្លឹកឆ្នោត នៅអំឡុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត។ ជំហានទី២ ទទួលពាក្យបណ្តឹងធ្វើឡើងដោយភ្នាក់ងារគណបក្សនយោបាយ ឬបុគ្គលដែលចង់ដាក់ពាក្យបណ្តឹង(មុនម៉ោង ១១:៣០ព្រឹក នៅក្រោយថ្ងៃបោះឆ្នោត) យោងទៅលើភាពមិនប្រក្រតីដែលបានចោទប្រកាន់ ដែលបានកើត ឡើងនៅថ្ងៃស ថ្ងៃបោះឆ្នោត ឬរាប់សន្លឹកឆ្នោត។ ចំពោះបណ្តឹងដែលទទួលដោយគណៈកម្មការការិយាល័យ បោះឆ្នោត ប្រសិនបើបណ្តឹងនោះមិនអាចដោះស្រាយបានទេ នោះបណ្តឹងទាំងនោះនឹងត្រូវបានដោះស្រាយ ដោយគណៈកម្មការឃុំ/សង្កាត់រៀបចំការបោះឆ្នោតនៅម៉ោងឬ ថ្ងៃបន្ទាប់។

ដោយយោងតាមរបាយការណ៍របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានអោយដឹងថា នៅ ក្នុងដំណាក់កាលនេះ គណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោត បានទទួលពាក្យបណ្តឹងសរុបទាំងអស់ ៨៨បណ្តឹង ដោយក្នុងនោះ បណ្តឹងដែលប្តឹងដោយគណបក្សប្រជាជនមានចំនួន៤១ បណ្តឹងដោយគណ សង្គ្រោះជាតិចំនួន៤៣បណ្តឹង និងប្រជាពលរដ្ឋចំនួន៤បណ្តឹង។ ក្នុងចំណោមបណ្តឹងទាំង៨៨ ដែលគណៈ កម្មការឃុំសង្កាត់រៀបការបោះឆ្នោតទទួលបានមាន៣៨បណ្តឹង ដែលទាមទារអោយរាប់សន្លឹកឆ្នោតឡើងវិញ នៅតាមការិយាល័យបោះឆ្នោត ឬក្នុងឃុំ សង្កាត់ទាំងមូល និង៥០បណ្តឹងទាមទារអោយចាត់វិធានការដាក់ ទណ្ឌកម្មលើអ្នកដែលប្រព្រឹត្តខុសតួនាទីក្នុងថ្ងៃបោះឆ្នោត ដែលបានបំពានទៅលើបទបញ្ញត្តិដែលមានចែង ក្នុងច្បាប់បោះឆ្នោត។

ដំណោះស្រាយរបស់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងលទ្ធផលនៃការដោះស្រាយ បណ្តឹងនៅដំណាក់កាលនេះ មានដូចជា៖

- ២៩បណ្តឹង ត្រូវបានដោះស្រាយតាមរយៈការផ្សះផ្សា
- ៩បណ្តឹង មិនអាចដោះស្រាយដោយការផ្សះជា
- ១៣បណ្តឹង ត្រូវបានច្រានចោលដោយមន្ត្រីទទួលពាក្យបណ្តឹង (ផ្អែកលើការខ្វះលក្ខខណ្ឌអំណះ អំណាង ឬលក្ខខណ្ឌដែលបានតម្រូវដោយច្បាប់)
- ៧បណ្តឹង ត្រូវបានម្ចាស់បណ្តឹងដកបណ្តឹងចេញវិញ

[152] ទម្រង់ ១២០២ ជាទម្រង់បណ្តឹងបោះឆ្នោត។ យោងតាមច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សឃុំសង្កាត់ បណ្តឹងអាច ត្រូវបានដាក់នៅអំឡុងពេលបោះ ពេលរាប់។ គយ.សប ត្រូវដោះស្រាយបណ្តឹងទាំងនោះ តាមសមត្ថកិច្ចរបស់ខ្លួនដែល ច្បាប់ និងបទបញ្ជា និងនីតិវិធីបានកំណត់។

- ២បណ្តឹង ត្រូវបានលុបចេញដោយសារតែម្ចាស់បណ្តឹងមិនបានចូលរួមស្តាប់ការដោះស្រាយ
- ៨បណ្តឹង មិនត្រូវបានទទួលដោះស្រាយ ដោយមន្ត្រីទទួលពាក្យបណ្តឹង ដោយសារតែដាក់ពាក្យបណ្តឹងយឺត
- ២០បណ្តឹង ត្រូវបានដោះស្រាយហើយភាគីដែលពាក់ព័ន្ធត្រូវបានជូនដំណឹងដោយលិខិតជូនដំណឹង។

បើប្រៀបធៀបនឹងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់កាលពីឆ្នាំ២០១២ ឃើញថា ចំនួននៃពាក្យបណ្តឹងមានការថយចុះចំនួន៥៧បណ្តឹង។ ចំនួនបណ្តឹងដែលត្រូវបានគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត មិនទទួលដោះស្រាយបានថយចុះពី៦១ មកត្រឹមតែ២១ប៉ុណ្ណោះ។ នៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់កាលពីឆ្នាំ២០១៧ គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ បានដាក់ពាក្យបណ្តឹងប្តឹងគ្នាទៅវិញទៅមក។ ឯនៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់កាលពីឆ្នាំ២០១២ គណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សបានព្រួតគ្នាប្តឹងជំទាស់គណបក្សប្រជាជនកម្ពុជា។ ខុមហ្វ្រែល បានសង្កេតឃើញថា គណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោត មិនបានប្រឹងប្រែងដោះស្រាយបណ្តឹងជាច្រើនដែលពាក់ព័ន្ធនឹងភាពមិនប្រក្រតី និងសំណើដែលស្នើសុំអោយរាប់សន្លឹកឆ្នោតឡើងវិញនោះទេ។ មិនមានឯកសារណាមួយដែលបញ្ជាក់ថា គណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោត បានរាប់សន្លឹកឆ្នោតឡើងវិញ ដែលជាការទាមទាររបស់ភ្នាក់ងារគណបក្ស ឬអ្នកតំណាងគណបក្សនោះទេ។ ករណីជាក់ស្តែង មានបណ្តឹងមួយចំនួន ដោយរួមបញ្ចូលទាំងបណ្តឹងទាមទារអោយរាប់សន្លឹឆ្លោតឡើងវិញ តែត្រូវបានបដិសេធដោយគណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោតទៅវិញ ដូចជានៅក្នុងឃុំឃ្លាំង ស្រុកសណ្តាន់ ខេត្តកំពង់ធំជាដើម។

១០.២.២ ទទួល និងដោះស្រាយបណ្តឹងនៅ គធ.ខប

នៅក្នុងដំណាក់កាលនេះ គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត បានទទួលពាក្យបណ្តឹងចំនួន២៤ ដែលបណ្តឹងទាំងនេះត្រូវបានប្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត។ ក្នុងចំណោមបណ្តឹងទាំង២៤ មានបណ្តឹងចំនួន៣ ដែលប្តឹងដោយគណបក្សប្រជាជនកម្ពុជា បណ្តឹងចំនួន១៨ ត្រូវបានប្តឹងដោយគណបក្សសង្គ្រោះជាតិ និងបណ្តឹងចំនួន៣ទៀត ត្រូវបានប្តឹងដោយប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត។ ក្នុងចំណោមបណ្តឹងទាំងអស់ មានបណ្តឹងចំនួន១៤ ដែលស្នើសុំអោយរាប់សន្លឹកឆ្នោតឡើងវិញ ហើយបណ្តឹងចំនួន១០ បានស្នើសុំអោយចាត់វិធានការដាក់ទោសដល់ជនដែលបានរំលោភច្បាប់បោះឆ្នោត។

ដំណោះស្រាយដែលបានសម្រេចដោយគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត មានដូចខាងក្រោម៖

- បណ្តឹងចំនួន៣ ដែលគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត បានទទួលករណីស្នើសុំអោយរាប់សន្លឹកឆ្នោតឡើងវិញ។ ករណីទី១ គឺបណ្តឹងដែលប្តឹងដោយគណបក្សសង្គ្រោះជាតិ

ដែលបានកើតឡើងនៅក្នុងឃុំបឹងប្រាំ ខេត្តបាត់ដំបង។ ករណីទី២ គឺបណ្តឹងដែលប្តឹងដោយគណបក្សប្រជាជនកម្ពុជា ដែលបានកើតឡើងនៅសង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ ករណីទី៣ ពាក់ព័ន្ធនឹងបណ្តឹងដែលបានកើតឡើងនៅក្នុងឃុំរកាពប្រាំ ខេត្តត្បូងឃ្មុំ។[153]

- បណ្តឹងចំនួន៣ ត្រូវបានដោះស្រាយតាមរយៈការផ្សះផ្សា
- បណ្តឹងចំនួន៨ ត្រូវបានបដិសេធចោលដោយសារអ្នកប្តឹងខ្វះអំណះអំណាង ឬភ័ស្តុតាង និងឬក៏ពួកគេ(អ្នកប្តឹង)មិនបានគោរពតាមនីតិវិធីនៃការដោះស្រាយបណ្តឹង។
- បណ្តឹងចំនួន១ ត្រូវបានបដិសេធ មិនព្រមដោះស្រាយ ដោយសារការដាក់បណ្តឹងមិនទាន់ពេលវេលា(យឺត)។
- បណ្តឹងចំនួន៩ ត្រូវបានផ្តល់ដំណឹងដោយលិខិតជូនដំណឹងដល់ភាគី ដែលពាក់ព័ន្ធក្រោយគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតធ្វើការសម្រេច។

ដោយយោងទៅតាមន្ត្រី ដែលទទួលបន្ទុកខាងបណ្តឹងរបស់គណបក្សសង្គ្រោះជាតិបានអោយដឹងថា យ៉ាងហោចណាស់ មានបណ្តឹងចំនួន៣០[154] ដែលស្នើសុំអោយរាប់សន្លឹកឆ្នោតឡើងវិញ ត្រូវបានដាក់ជូនគណៈកម្មការរៀបចំការបោះឆ្នោតរាជធានី ខេត្ត ហើយបណ្តឹងទាំងនេះជាបណ្តឹងជំទាស់នឹងសម្រេចរបស់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត។ ទោះជាយ៉ាងនេះក្តី ក៏របាយការណ៍ទាំងនេះ មិនបានធ្វើការបែងចែកបណ្តឹងដែលប្តឹងនៅក្រោយថ្ងៃបោះឆ្នោត អោយដាច់ចេញពីបណ្តឹងដែលប្តឹងនៅក្រោយការផ្តល់ដំណឹងអំពីលទ្ធផលនៃការបោះឆ្នោតនោះទេ។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់កាលឆ្នាំ២០១២ មានបណ្តឹងចំនួន១០៤ ត្រូវបានដាក់ជូនគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត។ ពាក្យបណ្តឹងទាំងនោះ មានបណ្តឹងចំនួន១០០ ត្រូវបានដប្តឹងដោយគណបក្ស សម រង្ស៊ី បណ្តឹងចំនួន២ ត្រូវបានប្តឹងដោយគណបក្សប្រជាជនកម្ពុជា និង បណ្តឹងចំនួន២ទៀត ត្រូវប្តឹងដោយអាជ្ញាធរ។ ក្នុងចំណោមបណ្តឹងទាំង១០៤ មានបណ្តឹង៨២ ត្រូវបានគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត បដិសេធមិនព្រមដោះស្រាយ។

ករណីឃុំបឹងប្រាំ៖

គណៈកម្មការរៀបចំការបោះឆ្នោត (គធ.ខប) ខេត្តបាត់ដំបង ទទួលពាក្យបណ្តឹងបានចំនួន០៤ ដែលបណ្តឹងទាំងនោះ ជាបណ្តឹងពាក់ព័ន្ធភាពមិនប្រក្រតី ដែលបានកើតឡើងនៅថ្ងៃស ថ្ងៃបោះ និងថ្ងៃរាប់សន្លឹកឆ្នោត បណ្តឹងទាំងនោះ ត្រូវបានប្តឹងចាប់ពី គឃ.សប មក។ ក្នុងចំណោមបណ្តឹងទាំង០៤ មានបណ្តឹងមួយដែលត្រូវ គធ.ខប លើកយកមកដោះស្រាយតាមពាក្យបណ្តឹង គឺបណ្តឹងស្នើសុំអោយរាប់សន្លឹកឆ្នោតឡើងវិញនៅការិយាល័យមួយចំនួននៃឃុំបឹងប្រាំ ដែលភ្នាក់ងារគណបក្សសង្គ្រោះជាតិរកឃើញថា មានភាពមិន

[153] The identity of the party or person submitting this complaint was not given by the NEC.

[154] **Van Roeun "NEC Finishes Complaints; Voter Registration Prep Continues" Cambodia Daily, 21 June 2017**

ប្រក្រតីធ្ងន់ធ្ងរចំពោះការកំណត់សន្លឹកឆ្នោតថា ជា«សន្លឹកឆ្នោតមិនបានការ» ក្នុងការិយាល័យទាំង០៩។ ក្រោយពីការរាប់សន្លឹកឆ្នោតឡើងវិញ ធ្វើឡើងដោយ គធ.ខប សន្លឹកឆ្នោតស្ទើរតែទាំងអស់ បានប្រែក្លាយជាសន្លឹកឆ្នោតបានការវិញ។ ការសង្កេតរកឃើញថា ការកំណត់លើគំនូសសន្លឹកឆ្នោតថា ជា «សន្លឹកឆ្នោតបានការ និងមិនបានការ» បានបង្កើតជាបញ្ហាចំបងដែលធ្វើអោយមានភាពមិនប្រក្រតី និងបណ្តឹងច្រើនអំពីបញ្ហានេះ។ ក្នុងចំណោមបណ្តឹងទាំង០៤ មានបណ្តឹងចំនួន០៣ ដែលប្តឹងដោយគណបក្សសង្គ្រោះជាតិ ពាក់ព័ន្ធនឹងបណ្តឹងស្នើសុំរាប់សន្លឹកឆ្នោតឡើងវិញ និងមួយបណ្តឹងទៀត ជាបណ្តឹងស្នើសុំអោយមានការដាក់ទោសពិន័យតាមច្បាប់កំណត់ ដែលប្តឹងដោយគណបក្សប្រជាជនកម្ពុជា។ បណ្តឹងដែលពាក់ព័ន្ធនឹងការស្នើសុំអោយមានការដាក់ទោសពិន័យ និងដែលប្តឹងដោយគណបក្សប្រជាជនកម្ពុជានេះ ក៏ត្រូវបានលើកយកមកដោះស្រាយដោយ គធ.ខប ផងដែរ។ ពាក់ព័ន្ធជាមួយបណ្តឹងស្នើសុំរាប់សន្លឹកឆ្នោតឡើងវិញ ដែលប្តឹងដោយភ្នាក់ងារគណបក្សសង្គ្រោះជាតិ ប្រឆាំងនឹងប្រធានការិយាល័យបោះឆ្នោត គឺដោយមូលហេតុថា ប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតមួយចំនួនបានរាប់លឿនពេក ធ្វើអោយពួកគេតាមមើលគំនូសសន្លឹឆ្នោតមិនទាន់។ ក្នុងចំណោមបណ្តឹងទាំងបី មានបណ្តឹងចំនួនពីរ មិនត្រូវបានលើកយកមកដោះស្រាយដោយ គឃ.សប និង គធ.ខប ឡើយ។ បណ្តឹងទាំងពីរនោះ គឺបណ្តឹងពាក់ព័ន្ធនឹងភាពមិនប្រក្រតីដែលកើតឡើងក្នុងឃុំជូនបា ស្រុកគាស់ក្រឡ និងឃុំបឹងព្រីង ស្រុកថ្មគោល ខេត្តបាត់ដំបង។ គធ.ខប មិនបានផ្តល់មូលហេតុជាក់លាក់ ច្បាស់លាស់អំពីការសម្រេចបដិសេធមិនរាប់សន្លឹកឆ្នោតឡើងវិញ តាមបណ្តឹងរបស់គណបក្សសង្គ្រោះជាតិឡើយ។

ករណីមួយដោយឡែកពីករណីទាំងពីរនេះ គឺករណីដែលកើតឡើងក្នុងឃុំបឹងជ្រាំ ស្រុកបវេល។ ករណីនេះត្រូវបានប្តឹងដោយភ្នាក់ងារគណបក្សសង្គ្រោះជាតិ ដែលអ្នកសង្កេតការណ៍នៅក្នុងការិយាល័យទាំង០៩ ដែលកើតមានភាពមិនប្រក្រតីធ្ងន់ធ្ងរជាងគេ (ការិយាល័យលេខ ០៦៦២ ០៦៦៣ ០៦៦៤ ០៦៦៦ ០៦៦៧ ០៦៦៨ ០៦៦៩ ០៦៧០ និងការិយាល័យលេខ ០៦៧២) ។ លទ្ធផលបោះឆ្នោតបឋម ក្នុងឃុំបឹងជ្រាំ ទាំងមូលដែលប្រកាស និងបិទផ្សាយដោយ គឃ.សប នៃឃុំនេះ បានបង្ហាញអោយឃើញថា គណបក្សប្រជាជនកម្ពុជា ទទួលបានសំលេងគាំទ្របានការសរុប៦៣១សឡេង ទល់នឹងសំលេងសន្លឹកឆ្នោតបានការសរុបរបស់គណបក្សសង្គ្រោះជាតិ ៦០៨សំឡេង។ ក្រោយពីការរាប់សន្លឹកឆ្នោតមិនបានការឡើងវិញក្នុងការិយាល័យទាំង០៩ខាងលើ (ជាពិសេសការិយាល័យលេខ ០៦៦៧ ដែលមានសន្លឹកឆ្នោតមិនបានការសរុបចំនួន ៨៥សន្លឹក នៃសន្លឹកឆ្នោតដែលមានក្នុងហិបឆ្នោតទាំងអស់ ១៣២សន្លឹក បានក្លាយជាសន្លឹកឆ្នោតបានការវិញស្ទើរទាំងអស់ និងកំណត់ឡើងវិញរកឃើញថា សន្លឹកមិនបានការមានតែមួយសន្លឹកគត់ប៉ុណ្ណោះ) លទ្ធផលបានផ្លាស់ប្តូរមកជា គណបក្សសង្គ្រោះជាតិបានទទួល១៦៣សន្លឹកបន្ថែម និងគណបក្សប្រជាជនកម្ពុជាទទួលបាន៧៣សន្លឹកបន្ថែមលើសន្លឹកឆ្នោតមិនបានការសរុប ដែលរាប់ឡើងវិញចំនួន ២៥៥ សន្លឹក ពីការិយាល័យទាំងអស់ក្នុងឃុំ ។ ដូច្នេះ ជាលទ្ធផលគណបក្សសង្គ្រោះជាតិទទួលបានសំលេងសរុប ៧៧១សំឡេង ទល់នឹង ៧០៤សំឡេង នៃគណបក្សប្រជាជនកម្ពុជា។ គណបក្សសង្គ្រោះជាតិ ទទួលបានអាសនៈជាមេឃុំនៅក្នុងឃុំនេះ។ ការិយាល័យលេខ០៦៦៧ បើយោងតាមលទ្ធផលរបស់ គឃ.សប គឺរកឃើញ មានសន្លឹកឆ្នោតមិនបានការរហូតដល់៨៥សន្លឹកនៃសន្លឹកឆ្នោតសរុបក្នុងហិបឆ្នោត។ គធ.ខប បាន

កំណត់សន្លឹកឆ្នោតនេះឡើងវិញ ដោយរកឃើញថា គ្មានសន្លឹកឆ្នោតមិនបានការឡើយ ដូចគ្នាគំនូសទាំងនោះ គឺជាគំនូសសន្លឹកឆ្នោតបានការទាំងអស់។ ការិយាល័យនេះកាលរាប់នៅការិយាល័យបោះឆ្នោត គណបក្សប្រជាជនកម្ពុជាទទួលបាន ២២ សន្លឹក គណបក្សសង្គ្រោះជាតិទទួលបាន ២៥សន្លឹក ដែលជាសន្លឹកឆ្នោតបានការ។[155] ទោះជាយ៉ាងណា បន្ទាប់ពីរាប់ឡើងវិញ គណបក្សសង្គ្រោះជាតិទទួលបាន៦៩សំលេងបន្ថែមនៃសំលេងឆ្នោតមិនបានការ និងគណបក្សប្រជាជនកម្ពុជាទទួលបាន ១៦សំលេងបន្តថែម។ គណបក្សប្រជាជនកម្ពុជា បានដាក់ពាក្យបណ្តឹងជំទាស់នឹងការសម្រេចរបស់ គធ.បខ បាត់ដំបងទៅកាន់ គជប។[156]

ករណីឃុំឃ្លាំង

ខេត្តកំពង់ធំ ដោយយោងទៅតាមលទ្ធផលជាផ្លូវការដែលត្រូវបានប្រកាសដោយ គ.ជ.ប កាលពីចុងខែមិថុនា បានដោយដឹងថា គណបក្សសង្គ្រោះជាតិបានទទួលជ័យជំនះ៤១ឃុំសង្កាត់ ដោយមានក្រុមប្រឹក្សាឃុំ សង្កាត់សរុបចំនួន២៨៥នាក់ គណបក្សប្រជានជនកម្ពុជាទទួលជ័យជំនះចំនួន៤០ឃុំ សង្កាត់ ដោយមានក្រុមប្រឹក្សាឃុំ សង្កាត់សរុប១៧៣នាក់ ហើយគណបក្សដទៃទៀតបានទទួលជ័យជំនះ១៩អាសនៈ។ យោងតាមលទ្ធផលជាផ្លូវការរបស់ គ.ជ.ប បានអោយដឹងថា នៅក្នុងឃុំឃ្លាំង គណបក្សសង្គ្រោះជាតិ ទទួលបាន៣អាសនៈ ហើយគណបក្សប្រជាជនកម្ពុជា ទទួលបាន២អាសនៈ។ ជម្លោះបានកើតឡើងដោយសារតែមានភាពមិនប្រក្រតីនៅការិយាល័យបោះឆ្នោតលេខ០៦៦៦ ដែលនៅការិយាល័យនេះ ភ្នាក់ងារគណបក្សសង្គ្រោះជាតិបានអះអាងថា មានសន្លឹកឆ្នោតជាច្រើនដែលប្រជាពលរដ្ឋបានបោះជូនគណបក្សសង្គ្រោះជាតិ តែត្រូវបានចាត់ទុកសន្លឹកឆ្នោតទាំងនោះថាជាសន្លឹកឆ្នោតមិនបានការ ឬខូចទៅវិញ។ ដោយយោងតាមទម្រង់១២០២ សម្រាប់ការិយាល័យបោះឆ្នោតលេខ០៦៦៦ ដែលបានចេញដោយគណៈកម្មការឆ្នោតឃុំសង្កាត់រៀបចំការបោះឆ្នោត កាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៧ បានអោយដឹងថា មានសន្លឹកឆ្នោតចំនួន៣៦សន្លឹកដែលចាត់ទុកថា ជាសន្លឹកឆ្នោតមិនបានការ ក្នុងចំណោមសន្លឹកឆ្នោត៤០៦សន្លឹក។ នៅក្នុងការិយា លយបោះឆ្នោតនោះគណបក្សប្រជាជនកម្ពុជាទទួលបាន១៣៣សំឡេង គណបក្សសង្គ្រោះជាតិទទួលបាន២១៩សំឡេង គណបក្សហ្វុនស៊ិនប៉ិចទទួលបាន១២សំឡេង ហើយគណបក្សខ្មែររួបរួមជាតិទទួលបាន ៦សំឡេង។ គធ.ខប បានប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងឃុំឃ្លាំងទាំងមូល ដោយគណៈប្រជាជនកម្ពុជាទទួលបាន៨៣២សំឡេង គណបក្សសង្គ្រោះជាតិទទួលបាន៨៣១ សំឡេង ដែលលទ្ធផលនេះខុសគ្នាតែមួយសំឡេងប៉ុណ្ណោះ ដើម្បីក្លាយជាមេឃុំ។

ភ្នាក់ងារគណបក្សសង្គ្រោះជាតិបានប្តឹងទៅគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត ដែលពាក់ព័ន្ធនឹងភាពមិនប្រក្រតីនៅការិយាល័យបោះឆ្នោតលេខ០៦៦៦ ដែលបានកើតឡើងនៅក្រោយបោះឆ្នោត និង រាប់សន្លឹកឆ្នោត។ ទោះបីជាយ៉ាងណានេះក្តី ក៏គណកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត នៅតែ

[155] See the annex for a copy of the 1202 Form.
[156] See Appendix for the NEC's resolution.

បដិសេធសំណើដែលស្នើសុំអោយរាប់សន្លឹកឆ្នោតឡើងវិញទាំងអស់ ដោយលើកឡើងថា ភ្នាក់ងារគណបក្សខ្មែរជាតិមិនបានដាក់ពាក្យបណ្តឹងទៅប្រធានគណៈកម្មការ ឃុំ សង្កាត់រៀបចំការបោះឆ្នោត នៅអំឡុងពេលបោះឆ្នោតនិងរាប់សន្លឹកឆ្នោត ហើយបែរដាក់ពាក្យបណ្តឹងក្រោយការបោះឆ្នោត និងរាប់សន្លឹកឆ្នោតទៅវិញ។ ក្នុងករណីនេះគណៈកម្មការ ឃុំ សង្កាត់រៀបចំការបោះឆ្នោត មិនបានគោរពតាមបទបញ្ញត្តិ និងនីតិវិធីក្នុងកថាខណ្ឌ ១០.៨ ដែលបានចែងអំពីកាលផុតកំណត់ ដើម្បីដាក់ពាក្យបណ្តឹងដែលពាក់ព័ន្ធនឹងភាពមិនប្រក្រតីក្នុងថ្ងៃស ថ្ងៃបោះឆ្នោត ឬក្នុងថ្ងៃរាប់សន្លឹកឆ្នោត ដែលបទបញ្ញត្តិនេះអនុញ្ញាតអោយដាក់បណ្តឹងនៅបន្ទាប់ពីថ្ងៃសថ្ងៃបោះឆ្នោត ឬរាប់សន្លឹកឆ្នោត ត្រឹមម៉ោង ១១:៣០ ព្រឹកនោះទេ។ ក្រោយពីការប្រកាសលទ្ធបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ កាលពីថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយនៃការដាក់ពាក្យបណ្តឹងតវ៉ានឹងលទ្ធផលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានប្រកាសដោយ គណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៧)[157] ពាក្យបណ្តឹងផ្សេងទៀតត្រូវបានប្តឹងដោយអ្នកតំណាងគណបក្សសង្គ្រោះជាតិ គឺលោក លឹម គីមយ៉ា និងលោក ស៊ុន ចាន់ថី កាលពីថ្ងៃទី០៦ ខែ មិថុនា ឆ្នាំ២០១៧ ដើម្បីប្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ហើយស្នើសុំអោយរាប់សន្លឹកឆ្នោតឡើងវិញនៅការិយាល័យបោះឆ្នោតលេខ០៦៦៦។ នៅក្នុងករណីនេះ ពាក្យបណ្តឹងត្រូវបានដាក់មុនថ្ងៃផុតកំណត់ តែបែរជាគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតចាត់ទុកថាពាក្យបណ្តឹងនេះដាក់យឺតយ៉ាវទៅវិញ។ ការធ្វើដូចនេះ គឺណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត បានរំលោភច្បាប់ និងបទបញ្ជាទាំងស្រុង។

កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧ គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត បានចេញទម្រង់ ទ.១២០៣។ អង្គភាពដោះស្រាយជំលោះដែលពាក់ព័ន្ធនឹងការបោះឆ្នោតនេះ បានបញ្ជាក់យ៉ាងច្បាស់ថា ពាក្យបណ្តឹងដែលដាក់ដោយលោក គីម យ៉ា ដែលជាអ្នកតំណាងអោយគណបក្សសង្គ្រោះជាតិ ជាពាក្យបណ្តឹងដែលមានអំណាច ហើយលោក គីម យ៉ា មានសិទ្ធិក្នុងការដាក់ពាក្យបណ្តឹង ដើម្បីស្នើសុំអោយមានការរាប់សន្លឹកឆ្នោតឡើងវិញនៅការិយាល័យបោះឆ្នោតលេខ០៦៦៦។ ហើយអង្គភាពដោះស្រាយជំលោះ(គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត)ទទួលស្គាល់ទៀតថា ពាក្យបណ្តឹងដែលត្រូវបានដាក់ជូននេះស្របតាមបទបញ្ញត្តិ និងនីតិវិធីនៃច្បាប់។ តែគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតនេះ បានច្រានចោលបណ្តឹងនោះទៅវិញ ដោយផ្អែកលើមូលដ្ឋានថា ពាក្យបណ្តឹងនោះគ្មានភ័ស្តុតាងគ្រប់គ្រាន់ ហើយចាត់ទុកថា សេចក្តីសម្រេចរបស់គណៈកម្មាធិការឃុំ សង្កាត់រៀបចំការបោះឆ្នោត ទុកជាបានការទៀតផង។

តាមការអង្កេត និងការវិភាគ ការដោះស្រាយជំលោះដែលពាក់ព័ន្ធនឹងការបោះឆ្នោត ត្រូវបានខុមហ្វ្រែលរកឃើញថា គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតបានបដិសេធ(បណ្តឹងរបស់គណបក្សសង្គ្រោះជាតិ)ដោយគ្មានហេតុផលសមរម្យ បើទោះបីជាបណ្តឹងនោះបានបញ្ជាក់យ៉ាងច្បាស់ពីភាពមិនប្រក្រតីដែលបានកើតឡើងក្នុងការិយាល័យបោះឆ្នោតលេខ ០៦៦៦ ក៏ដោយ។ លើសពីនេះទៅទៀត សូម្បីតែពាក្យ

[157] See the attached complaint made by Mr. Sun Chanthy, representative of CRNP in Kampong Thom submitted to the PEC to appeal the decision of the Klaeng commune CEC.

បណ្តឹងនោះមានភ័ស្តុតាងគ្រប់គ្រាន់ និងស្របតាមបទបញ្ញត្តិ និងនីតិវិធីនៃច្បាប់ក៏អង្គភាពដោះស្រាយជំលោះមួយនេះនៅតែបដិសេធមិនព្រមដោះស្រាយដែរ។ តាមការអង្កេតបានរកឃើញទៀតថា មាន៣ចំណុចចដែលសំខាន់ៗដែលអាចបញ្ជាក់បានថា ពាក្យបណ្តឹងនោះទុកជាការបានគឺ ទី១ បណ្តឹងនោះត្រូវបានធ្វើឡើងដោយភ្នាក់ងារគណបក្សនយោបាយដែលចូលរួមអង្កេតក្នុងថ្ងៃបោះ និងរាប់សន្លឹកឆ្នោត ដោយស្របតាមកថាខណ្ឌ ៨.២ នៃបទបញ្ញត្តិ និងនីតិវិធីច្បាប់។ ទី២ ពាក្យបណ្តឹងនោះត្រូវបានដាក់ទាន់ពេលវេលាដែលស្របតាមកថាខណ្ឌទី៨.២ ដែលចែងអំពីកាលកំណត់នៃការដាក់ពាក្យបណ្តឹង។ ទី៣ ខ្លឹមសារនៃពាក្យបណ្តឹងស្របជាមួយបទបញ្ញត្តិ និងនីតិវិធីច្បាប់ក្នុងកថាខណ្ឌទី១១.៧ ដែលបានចែងអំពីការស្នើសុំអោយរាប់សន្លឹកឆ្នោតឡើងវិញ ប្រសិនបើភាគរយនៃជ័យជំនះប្រកៀកប្រកើយគ្នាតិចជាង០.៥% នៅក្នុងឃុំជាក់លាក់មួយ។ ដូចដែលបានដឹងមកហើយថា គណបក្សធំៗពីរ ទទួលលទ្ធផលខុសគ្នាតែមួយសំឡេងគត់គឺ គណបក្សប្រជាជនបាន ៨៣២សំឡេង ចំណែកឯគណបក្សសង្គ្រោះជាតិបាន៨៣១សំឡេង។ ក្រោយពីគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត បដិសេធចោលបណ្តឹងនោះ គណបក្សង្គ្រោះជាតិក៏បានប្តឹងដំទាស់នឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការរាជធានី ខេត្តរៀបចំការបោះឆ្នោតទៅ គ.ជ.ប ទៀត ដើម្បីអោយរាប់សន្លឹកឆ្នោតឡើងវិញនៅការិយាល័យបោះឆ្នោតលេខ០៦៦៦។[158]

១០.២.៣ ការទទួលនិង ដោះស្រាយបណ្តឹងនៅ គ.ជ.ប

គ.ជ.ប បានទទួលពាក្យបណ្តឹងចំនួន១៩ ក្នុងចំណោមបណ្តឹងទាំងនោះ បណ្តឹងចំនួន៣ ត្រូវបានប្តឹងដោយគណបក្សប្រជាជនកម្ពុជា បណ្តឹងចំនួន១៥ ត្រូវបានប្តឹងដោយគណបក្សសង្គ្រោះជាតិ និងបណ្តឹងចំនួន ០១ ត្រូវបានប្តឹងដោយប្រជាពលរដ្ឋដែលសិទ្ធិបោះឆ្នោត។ មានបណ្តឹងចំនួន១១ ដែលប្តឹងស្នើសុំអោយរាប់សន្លឹកឆ្នោតឡើងវិញ បណ្តឹងចំនួន៨ បានប្តឹងអោយចាត់វិធានការដាក់ទោសដល់ជនល្មើសដែលបំពានបទបញ្ញត្តិនៃច្បាប់ឆោះឆ្នោត។ នៅក្នុងដំណាក់កាលនេះ គ.ជ.ប បានបដិសេធបណ្តឹងចំនួន២ ក្នុងចំណោមបណ្តឹងទាំង១១ ដែលស្នើសុំអោយរាប់សន្លឹកឆ្នោតឡើងវិញ។ ទាំងពីរបណ្តឹងនោះ គឺមានមួយបណ្តឹងនៅក្នុងឃុំបឹងប្រាំ ខេត្តបាត់ដំបង និងមួយបណ្តឹងទៀតនៅក្នុងឃុំឃ្លាំង ខេត្តកំពង់ធំ។ ករណីនៅក្នុងឃុំឃ្លាំង គ.ជ.ប បានយល់ព្រមរាប់សន្លឹកឆ្នោតឡើងវិញ តែសន្លឹកឆ្នោតណាដែលសង្ស័យថា មិនយកជាការប៉ុណ្ណោះ (មិនមែនរាប់ឡើងវិញទាំងអស់ទេ)។ ហើយគណបក្សប្រជាជនកម្ពុជា បានប្តឹងដំទាស់នឹងសេចក្តីសម្រេចរបស់គណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ដែលលំអៀងទៅរកគណបក្សសង្គ្រោះជាតិ។ នៅក្នុងករណីនោះ គធ.ខប បានរាប់សន្លឹកឆ្នោតឡើងវិញ ហើយលទ្ធផលនៃការបោះឆ្នោតបានផ្លាស់ប្តូរ។ ដោយសារតែ គធ.ខប បានរាប់សន្លឹកឆ្នោតឡើងវិញ បានធ្វើអោយផ្លាស់ប្តូរលទ្ធផលនៃការបោះឆ្នោត ទើបគណបក្សប្រជាជនកម្ពុជាដាក់ពាក្យបណ្តឹងទៅ គ.ជ.ប ដោយស្នើសុំអោយរាប់សន្លឹកឆ្នោតជាលើកទី២ឡើងវិញ។ ករណីទី២ ដែលពាក់ព័ន្ធនឹងបណ្តឹងដែលគណបក្សសង្គ្រោះជាតិប្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់ គធ.ខប ក្នុងខេត្តកំពង់ធំ ឃុំឃ្លាំង ដែល គធ.ខប ធ្វើការជំទាស់នឹងការអះអាងរបស់គណបក្សសង្គ្រោះជាតិ។ ហើយបណ្តឹងចំនួន១៧

[158] See further in NEC's resolution on Klaeng Commune in the following description

ផ្សេងទៀត ត្រូវបាន គ.ជ.ប ផ្តល់ដំណឹងដោយលិខិតជូនដំណឹង អំពីការដោះស្រាយជំលោះដែលពាក់ព័ន្ធនឹងការបោះឆ្នោត។

ករណីនៅក្នុងឃុំបឹងប្រាំ

គ.ជ.ប បានយល់ព្រមរាប់សន្លឹកឆ្នោតនៅការិយាល័យទាំង៩ឡើងវិញ ក្នុងចំណោមការិយាល័យសរុបទាំងអស់១៦ ដើម្បីឆ្លើយតបនឹងបណ្តឹងដែលត្រូវបានដាក់ដោយគណបក្សប្រជាជនកម្ពុជា ដែលបានប្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់ គធ.ខប ក្នុងខេត្តបាត់ដំបង។ ការរាប់សន្លឹកឆ្នោតឡើងវិញនេះធ្វើឡើងកាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧ នៅទីស្នាក់ការកណ្តាល គ.ជ.ប។ ការរាប់សន្លឹកឆ្នោតឡើងវិញត្រូវបាន គ.ជ.ប អោយដឹងថា គណបក្សប្រជាជនកម្ពុជាទទួលបាន ៤២៧សំឡេង គណបក្សសង្គ្រោះជាតិទទួលបាន ៥១២ សំឡេង។ លទ្ធផលចុងក្រោយដែលសម្រេចដោយ គ.ជ.ប ក្នុងឃុំបឹងប្រាំទាំងមូល គឺគណបក្សប្រជាជនកម្ពុជាទទួលបាន ៧០៧សំឡេង ហើយគណបក្សសង្គ្រោះជាតិទទួលបាន ៧៧៦សំឡេង។ ដំណើរនៃការរាប់សន្លឹកឆ្នោតឡើងវិញនេះ ត្រូវបានអង្កេតឃើញថា មានតម្លាភាពត្រឹមត្រូវ ដោយសារតែ គ.ជ.ប បានជូនដំណឹងពីកាលបរិច្ឆេទ និងបើកចំហអោយមានការចូលសង្កេត និងអ្នកសារព័ត៌មានចូលរួមអង្កេតក្នុងថ្ងៃរាប់ទៀតផង។

ករណីក្នុងឃុំឃ្លាំង

គ.ជ.ប បានយល់ព្រមរាប់សន្លឹកឆ្នោតឡើងវិញទាំងអស់នៅការិយាល័យលេខ០៦៦៦ កាលពីថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០១៧ ក្រោយពីមានបណ្តឹងដែលត្រូវបានប្តឹងដោយគណបក្សសង្គ្រោះជាតិ ដែលប្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់ គធ.ខប ក្នុងខេត្តកំពង់ធំ។ បន្ទាប់ពី គ.ជ.ប បានរាប់សន្លឹកឆ្នោតវិញនៅការិយាល័យលេខ០៦៦៦ បានអោយដឹងថា គណបក្សសង្គ្រោះជាតិបានទទួល២២៥សំឡេង គណបក្សប្រជាជនកម្ពុជា បានទទួល១៣៦សំឡេង គណបក្សហ៊្វុនស៊ិនប៉ិចបានទទួល១៣សំឡេង និងគណបក្សខ្មែររួបរួមជាតិបានទទួល ៩សំឡេង។ ការរាប់សន្លឹកឆ្នោតឡើងវិញនេះ បានផ្លាស់ប្តូរលទ្ធផលរបស់គណបក្សដែលឈ្នះទៅចាញ់ ចំណែកឯគណបក្សដែលទៅជាឈ្នះវិញ នៅក្នុងឃុំឃ្លាំងទាំងមូល គឺគណបក្សសង្គ្រោះជាតិទទួលបាន ៨៣៧សំឡេង គណបក្សប្រជាជនកម្ពុជាទទួលបាន៨៣៥សំឡេង នេះមានន័យថា មេឃុំ គឺមកពីគណបក្សសង្គ្រោះជាតិ។ ចំណែកឯគណបក្សពីរផ្សេងទៀត គឺគណហ៊្វុនស៊ិនប៉ិច ទទួលបាន៥៦ សំឡេង និងគណបក្សខ្មែររួបរួមជាតិទទួលបាន៥១សំឡេង។ តាមការអង្កេត និងការវិភាគរបស់អង្គការខុមហ្វ្រែលដែលជាអង្គការមិនចំណុះអោយគណបក្សនយោបាយ និងដៃគូនៃបន្ទប់ស្ថានការណ៍បានអោយដឹងថា ការសម្រេចរបស់ គ.ជ.ប ដើម្បីធ្វើការរាប់សន្លឹកឆ្នោតឡើងវិញ គឺមានមូលដ្ឋានត្រឹមត្រូវដោយសារតែគណបក្សសង្គ្រោះជាតិបានបំពេញគ្រប់លក្ខខណ្ឌក្នុងការប្តឹងអោយរាប់សន្លឹកឆ្នោតឡើងវិញ ដូចមានចែងក្នុងមាត្រា ១៤៩ និង១៥២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំ សង្កាត់។ លើសពីនេះទៅទៀត ដំណើរការនៃការរាប់សន្លឹកឆ្នោតឡើងវិញនេះឃើញថា មានតម្លាភាពត្រឹមត្រូវដោយសារតែ គ.ជ.ប បាន

កំណត់កាលបរិច្ឆេទ ហើយអំពាវនាវអ្នកអង្កេតការដែលតំណាងពីគណបក្ស តំណាងអង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ និងអ្នកសារព័ត៌មានចូលរួមក្នុងរាប់សន្លឹកឆ្នោតឡើងវិញទៀតផង។

១០.៣. ការទទួល និងការដោះស្រាយបណ្តឹងអំពីការបិទផ្សាយលទ្ធផលបឋមនៅឃុំ សង្កាត់

១០.៣.១ ការទទួល និងការដោះស្រយបណ្តឹងនៅ គធ.ខប

ការទទួល និងដោះស្រាយពាក្យបណ្តឹង គធ.ខប បានទទួលពាក្យបណ្តឹងចំនួន៥៤បណ្តឹង ពាក់ព័ន្ធនឹងបណ្តឹងជំទាស់ទៅនឹងលទ្ធផលបោះឆ្នោតបឋមដែលប្រកាសដោយ គឃ.សប។ ក្នុងចំណោមបណ្តឹងទាំង ៥៤ មានបណ្តឹងចំនួន២០ ជាបណ្តឹងរបស់គណបក្សប្រជាជនកម្ពុជា និងមានបណ្តឹងចំនួន៣៤បណ្តឹង ជាបណ្តឹងរបស់គណបក្សសង្គ្រោះជាតិ។ ក្នុងចំណោមបណ្តឹងសរុបទាំង៥៤ មាន៥២បណ្តឹងជាបណ្តឹងស្នើសុំរាប់សន្លឹកឆ្នោតឡើងវិញ ដែលភាគច្រើនជាបណ្តឹងរបស់គណបក្សសង្គ្រោះជាតិ និងពីរបណ្តឹងទៀតជាបណ្តឹងស្នើសុំអោយមានការផ្តន្ទាទោសតាមច្បាប់បោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

គធ.ខប ដោះស្រាយបណ្តឹងបានចំនួន០៧បណ្តឹង ក្នុងចំណោមបណ្តឹងសរុបទាំង៥៤ ដោយបានសម្រេចរាប់សន្លឹកឆ្នោតឡើងវិញក្នុងឃុំ សង្កាត់ ចំនួន០៤ ដូចជា ឃុំដូង ខេត្តបាត់ដំបង ឃុំស្វាយធំ ខេត្តស្វាយរៀង ឃុំបន្ទាយឆ្មារ និងឃុំគំរូ ខេត្តបន្ទាយមានជ័យ។ គធ.ខប បានសម្រេចបដិសេធមិនរាប់សន្លឹកឆ្នោតតាមពាក្យបណ្តឹង ចំនួន០៤បណ្តឹង និងចារបដិសេធមិនដោះស្រាយចំនួន០៥បណ្តឹង ដោយសារបណ្តឹងទាំងនោះ ផុតអាជ្ញាយុកាលកំណត់ និងបណ្តឹងចំនួន៣៨ផ្សេងទៀត ត្រូវបាន គធ.ខប ធ្វើលិខិតជូនដំណឹងដល់ដើមបណ្តឹង។

ផ្អែកតាមបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ បណ្តឹងដែលប្តឹងជំទាស់នឹងលទ្ធផលបោះឆ្នោតបឋម ដែលប្រកាសដោយ គឃ.សប ត្រូវប្តឹងទៅកាន់ គធ.ខប ក្នុងរយៈពេលយ៉ាងយូរ០៣ថ្ងៃ បន្ទាប់ពីថ្ងៃបិទផ្សាយលទ្ធផលបោះឆ្នោតបឋម។ បណ្តឹងត្រូវតែជាបណ្តឹងធ្វើជាលាយលក្ខណ៍អក្សរ។ ក្នុងករណីបណ្តឹងបានដាក់ហួសរយៈកំណត់០៣ថ្ងៃ បណ្តឹងនោះចាត់ទុកជាបណ្តឹងមោឃភាព ដោយសារមិនគោរពតាមអាជ្ញាយុកាលកំណត់។ ប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ឬគណបក្សនយោបាយ ដែលចុះឈ្មោះប្រកួតប្រជែងក្នុងឃុំសង្កាត់នោះ ក៏អាចមានសិទ្ធិប្តឹងតវ៉ានឹងលទ្ធផលបោះឆ្នោតបឋមនេះបានដែរ។ បណ្តឹងតវ៉ានេះ អាចធ្វើទៅបានបើសិនអ្នកប្តឹងគិតថា ខ្លួនមានភស្តុតាងគ្រប់គ្រាន់ និងរឹងមាំអំពីភាពមិនប្រក្រតី ដែលអាចប៉ះពាល់ដល់លទ្ធផលបោះឆ្នោតក្នុងការិយាល័យបោះឆ្នោតណាមួយ ឬច្រើន។

យោងតាមបញ្ញត្តិនៃប្រការ ១១.៣ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតឃុំ សង្កាត់ បញ្ញត្តិនេះបានកំណត់លទ្ធភាពដល់ស្ថាប័នដោះស្រាយបណ្តឹង ឬអ្នកទទួលពាក្យបណ្តឹង នូវឆន្ទានុសិទ្ធិ ដើម្បីកំណត់នូវលក្ខខណ្ឌមួយចំនួន ហើយក៏ត្រូវមានពាក់ព័ន្ធនឹងប្រការ១០.៨ ទៅទៀត។ ការដោះស្រាយបណ្តឹងប្រកបដោយតម្លាភាព និងគណនេយ្យភាព វាអាចជាការដោះស្រាយដោយប្រសិទ្ធភាព លុះត្រាតែបញ្ញត្តិនៃ

ប្រការខាងលើនេះ មិនមានភាពស្រពេចស្រពិល ដោយកំណត់អោយបានច្បាស់ អំពីលទ្ធភាពរបស់បុគ្គលជាដើមបណ្តឹងក្នុងប្រការនេះ។ ប្រការ១១.៣ ទាំងមូលបានផ្តល់ឆន្ទានុសិទ្ធិទៅដល់ស្ថាប័នដែលមានសមត្ថកិច្ចដោះស្រាយបណ្តឹងបោះឆ្នោត បកស្រាយកំណត់បញ្ហាមួយចំនួនបានយ៉ាងទូលំទូលាយ ដូចជាពាក្យបណ្តឹងតម្រូវអោយមានភ័ស្តុងតាងរឹងមាំ អំពីភាពមិនប្រក្រតី ដែលបានកើតឡើង ឈ្មោះ និងអាសយដ្ឋានសាក្សីដែលមានចែងក្នុងប្រការ១១.៣.៣ ជាដើម។[159]

បញ្ញត្តិនេះបានធ្វើអោយដើមបណ្តឹងរារែកក្នុងការដាក់ពាក្យបណ្តឹង ដោយសារដើមបណ្តឹងតម្រូវអោយបង្ហាញនូវភស្តុតាងរឹងមាំ ដើម្បីអាចធ្វើអោយអ្នកដោះស្រាយបណ្តឹងធ្វើការសម្រេចចិត្តចាត់ការបណ្តឹងរបស់គាត់។ បញ្ញត្តិនៃប្រការ ១១.១.៣ នៃបទបញ្ជា និងនិតិវិធី បើទោះបីលក្ខខណ្ឌខ្លះមិនចាំបាច់ត្រូវតែមានប៉ុន្តែជាការអនុវត្តន៍ជាក់ស្តែង គឺបើសិនជាមិនមានព័ត៌មានទាំងនោះទេ បណ្តឹងនោះនឹងមិនត្រូវបានពិចារណាដោះស្រាយឡើយ។ ជាឧទាហរណ៍ លក្ខខណ្ឌនៃចំណុច *(៨) សេចក្តីអះអាងគាំទ្រ ឬភស្តុតាងផ្សេងៗ បើមាន* វាបានក្លាយជាឧបសគ្គដ៏ធំ ដែលធ្វើអោយបណ្តឹងមិនអាចត្រូវដោះស្រាយបាន បើសិនដើមបណ្តឹងមិនអាចបញ្ជាក់បាន។ ដើម្បីអាចបញ្ជាក់អំពីសេចក្តីអះអាងគាំទ្រ ឬភស្តុតាងផ្សេងៗ ដូចដែលមានចែងក្នុងចំណុចនេះបាន បញ្ញត្តិនៃប្រការ១០.៨ និងប្រការ១១.១.៩[160] ត្រូវតែបំពេញ (បណ្តឹងដែលប្តឹងអំពីភាពមិនប្រក្រតីដែលកើតឡើងក្នុងថ្ងៃស ថ្ងៃបោះ និងថ្ងៃរាប់សន្លឹកឆ្នោត ដោយភ្នាក់ងារសង្កេតការណ៍គណបក្ស

---

[159] ប្រការ១១.៣.៣ ចែងថា ភ្នាក់ងារគណបក្សនយោបាយ ឬជនគ្រប់ក្នុងឃុំសង្កាត់ ដែលមានបំណងប្តឹងតវ៉ា ឬប្តឹងជំទាស់ដូចបញ្ជាក់ក្នុងប្រការ ១១.៣ ខាងលើ អាចស្នើសុំ ទ.១២០២ ចំនួន០៣ច្បាប់ ពីគយ.សប ហើយត្រូវបំពេញ និងចុះហត្ថលេខា ឬផ្តិតស្នាមមេដៃលើពាក្យបណ្តឹង ដែលក្នុងនោះត្រូវផ្តល់ព័ត៌មានច្បាស់លាស់មួយចំនួនដូចខាងក្រោម៖ (១) ឈ្មោះ និងអាស័យដ្ឋានរបស់អ្នកប្តឹង (២) លក្ខណៈសំគាល់នៃ គយ/សប ឬ/និង ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (៣) ពេលវេលានៃការកើតឡើងនូវភាពមិនប្រក្រតី (៤) កម្មវត្ថុនៃបណ្តឹង (៥) ប្រសិនបើអាចធ្វើបាន ត្រូវបញ្ជាក់ពីមាត្រានៃ ច.ប.ឃ.ស ឬប.ខ.ឃ.ស ដែលត្រូវបានរំលោភ (៦) មនុស្សពាក់ព័ន្ធនឹងភាពមិនប្រក្រតី (៧) ឈ្មោះ និងអាស័យដ្ឋានរបស់សាក្សី បើមាន (៨) សេចក្តីអះអាងគាំទ្រ ឬភស្តុតាងផ្សេងៗ បើមាន (៩) ឈ្មោះ និងអាសដ្ឋានរបស់អ្នកសង្កេតការណ៍ ដែលមានវត្តមានក្នុងពេលហេតុការណ៍កើតឡើង។

[160] ប្រការនេះចែងថា ផ្អែកតាមការណែនាំរបស់ គធ.ខប ក្រុមត្រួតពិនិត្យលទ្ធផលត្រូវអនុវត្តការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំសង្កាត់ ចំណុះរាជធានីខេត្ត ដោយត្រូវបំពេញការងារពាក់ព័ន្ធតាមការចំបាច់ និងតាមលំដាប់លំដោយនៃករណីជាក់ស្តែងនីមួយៗដូចខាងក្រោម៖

១១.១.៩.១ ករណីឃុំសង្កាត់ណាដែលគ្មានពាក្យបណ្តឹងតវ៉ាឬបណ្តឹងជំទាស់ត្រូវបានដាក់នៅ គយ.សប និងនៅគធ.ខប

១១.១.៩.២ ករណីឃុំសង្កាត់ណា ដែលមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ត្រូវបានដាក់នៅ គយ.សប និងមានកញ្ចប់សុវត្ថិភាព ក ត្រូវបានបើក ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ហើយគយ.សប បានយល់ព្រម ឬបដិសេធលើបណ្តឹងនោះ និងករណីឃុំសង្កាត់ណាដែលមានពាក្យបណ្តឹងតវ៉ា និងបណ្តឹងជំទាស់ ត្រូវបានដាក់នៅ គធ.ខប។

១១.១.៩.៣ ករណីឃុំសង្កាត់ណា ដែលមានលម្អៀងសំលេងឆ្នោតយ៉ាងច្រើន ០,៥ភាគរយ រវាងបញ្ជីបេក្ខជននៃគណបក្សពីរ ឬច្រើន និងករណីឃុំសង្កាត់នោះមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ត្រូវបានដាក់នៅ គធ.ខប។

នយោបាយ ដែលបានចុះឈ្មោះសង្កេតការណ៍នៅក្នុងការិយាល័យណាមួយ)។ ដូច្នេះជាទូទៅ បើសិនជាគ្មានបណ្តឹង អំពីភាពមិនប្រក្រតីដែលត្រូវបានប្តឹងដោយភ្នាក់ងារគណបក្សនយោបាយនៅមុនពេលវេលាកំណត់ (មុនម៉ោង១១:៣០នាទីព្រឹកថ្ងៃបន្ទាប់ពីថ្ងៃបោះ និងរាប់សន្លឹកឆ្នោត) អំពីភាពមិនប្រក្រតីដែលបានកើតឡើងនៅក្នុងដំណើរការបោះ និងរាប់សន្លឹកឆ្នោត ចំពោះការិយាល័យមួយ ឬច្រើននៅក្នុងឃុំ សង្កាត់នោះ ដោយជាក់លាក់ បណ្តឹងស្តីពីការបដិសេធលទ្ធផលបោះឆ្នោតបឋម ក៏ពិបាកនឹងបញ្ជាក់អោយស្ថាប័នមានសមត្ថកិច្ចដោះស្រាយបណ្តឹង និងធ្វើការសម្រេចចិត្តដោះស្រាយបណ្តឹងនោះបានដែរ។

ប្រការ១១.៣.៣ ចែងថា ភ្នាក់ងារគណបក្សនយោបាយ ឬជនគ្រប់រូបក្នុងឃុំ សង្កាត់ ដែលមានបំណងប្តឹងតវ៉ា ឬប្តឹងជំទាស់ ដូចបញ្ជាក់ក្នុងប្រការ១១.៣ ខាងលើ អាចស្នើសុំ ទ.១២០២ ចំនួន០៣ច្បាប់ ពី គយ.សប ហើយត្រូវបំពេញ និងចុះហត្ថលេខា ឬផ្តិតស្នាមមេដៃលើពាក្យបណ្តឹងដែលក្នុងនោះ ត្រូវផ្តល់ព័ត៌មានច្បាស់លាស់មួយចំនួនដូចខាងក្រោម៖ (១) ឈ្មោះ និងអាស័យដ្ឋានរបស់អ្នកប្តឹង (២) លក្ខណៈសំគាល់នៃ គយ.សប ឬ/និង ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (៣) ពេលវេលានៃការកើតឡើងនូវភាពមិនប្រក្រតី (៤) កម្មវត្ថុនៃបណ្តឹង (៥) ប្រសិនបើអាចធ្វើបាន ត្រូវបញ្ជាក់ពីមាត្រានៃ ច.ប.ឃ.ស ឬ ប.ន.ឃ.ស ដែលត្រូវបានរំលោភ (៦) មនុស្សពាក់ព័ន្ធនឹងភាពមិនប្រក្រតី (៧) ឈ្មោះ និងអាស័យដ្ឋានរបស់សាក្សី បើមាន (៨) សេចក្តីអះអាងគាំទ្រ ឬភស្តុតាងផ្សេងៗ បើមាន (៩) ឈ្មោះ និងអាសដ្ឋានរបស់អ្នកសង្កេតការណ៍ ដែលមានវត្តមានក្នុងពេលហេតុការណ៍កើតឡើង។

វាជាកត្តាសំខាន់ ដែលមន្ត្រីដោះស្រាយបណ្តឹងបោះឆ្នោត ភ្នាក់ងារគណបក្សនយោបាយ ឬតំណាងគណបក្សនយោបាយ ត្រូវតែយល់ច្បាស់ថា ចំណុចទី៧ ៨ និង៩ ត្រូវតែជាព័ត៌មានដែលសំខាន់ និងចាំបាច់ត្រូវតែបញ្ជាក់នៅថ្ងៃដាក់ពាក្យបណ្តឹងដោយអ្នកប្តឹង។ ការសង្កេត និងសិក្សារកឃើញថា ការឃ្លាំមើលការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១៧ ដែលធ្វើឡើងដោយ សមាគម អង្គការសង្គមស៊ីវិលក្រៅរដ្ឋាភិបាលឯករាជក្យ មិនមាននិន្នាការគណបក្សនយោបាយ ក្នុងនោះមានអង្គការ ខុមហ្រ្វែល រួមទាំងបន្ទប់ស្ថានការណ៍ជាដើម បានកំណត់ថាវាជាការរំលោភបំពានបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ លើការបដិសេធមិនធ្វើការដោះស្រាយលើបណ្តឹងបោះឆ្នោតជាច្រើន ដែលបានប្តឹងដោយគណបក្សនយោបាយ ជាពិសេសគណបក្សនយោបាយធំៗទាំងពីរ ដោយត្រឹមតែផ្អែកលើមូលហេតុខ្វះនៃព័ត៌មានបណ្តឹង ដោយសារបណ្តឹងទាំងនោះ មិនត្រូវបានបំពេញ និងបញ្ជាក់ដោយអ្នកប្តឹង (ចំណុចទី៧ ៨ ឬ៩) នៃប្រការ១១.៣.៤។ លើពីនេះទៅទៀត បញ្ហាទាំងនេះហាក់ដូចជាបង្ហាញពីភាពខ្វះចន្លោះនៃយន្តការដោះស្រាយបណ្តឹងបោះឆ្នោត ដោយសារ គយ.សប គធ.ខប និង គ.ជ.ប ខ្លួនឯងផ្ទាល់ បានសម្រេចដោះស្រាយបណ្តឹងមួយចំនួនដែលមិនមានព័ត៌មានគ្រប់គ្រាន់ មិនបានភ្ជាប់ទំនាក់ទំនងជាមួយបញ្ញត្តិនៃប្រការផ្សេងនៃបទបញ្ជា និងនីតិវិធី។ ឧទាហរណ៍ដូចជា មានបណ្តឹងខ្លះត្រូវបានគណបក្សនយោបាយប្តឹងជំទាស់នឹងលទ្ធផលបោះឆ្នោតក្រាសដោយ គយ.សប ហើយ គធ.ខប បានសម្រេចដោះស្រាយបណ្តឹងនោះដោយបានរាប់សន្លឹកឆ្នោតឡើងវិញ តាមការស្នើសុំក្នុងពាក្យបណ្តឹង ប៉ុន្តែមិនបានតម្រូវ ឬទាមលក្ខខណ្ឌថា បណ្តឹងនោះ ចាំបាច់ត្រូវមានបណ្តឹងមួយទៀត ស្តីពីភាពមិនប្រក្រតីដែលត្រូវបានប្តឹង ដោយភ្នាក់ងារគណបក្សយោបាយ ដែលភាពមិនប្រក្រតីនោះបានកើតឡើងនៅក្នុងការិយាល័យជាក់លាក់ណាមួយ ឬច្រើន។ គធ.ខប

សម្រេចដោះស្រាយបណ្តឹងដោយត្រឹមតែលក្ខខណ្ឌ កម្រិតលម្អៀងតិចជាង ០,៥ភាគរយ (ប្រការ ១១.៧.២) និងមានបញ្ហាក់អំពីភាពមិនប្រក្រតីដែលកើតឡើង ក្នុងការិយាល័យមួយចំនួនប៉ុណ្ណោះ។ វាហាក់ដូចជាមិនស៊ីសង្វាក់គ្នាជាមួយការបកស្រាយរបស់ គធ.ខប ឬ គ.ជ.ប ដែលបណ្តឹងខ្លះ បើទោះបីជាបណ្តឹងនោះត្រូវបានដាក់ដោយគណបក្សនយោបាយស្នើសុំអោយរាប់ឡើងវិញ បន្ទាប់ពីលទ្ធផលត្រូបានបិទផ្សាយដោយ គយ .សប ក៏ដោយ ប៉ុន្តែល្អឹកណាគ្មានបណ្តឹងទាក់ទងនឹងភាពមិនប្រក្រតីណាមួយបានកើតឡើង ក្នុងអំឡុងពេលបោះ និងរាប់សន្លឹកឆ្នោត ត្រូវបានដាក់(ប្តឹង)ដោយភ្នាក់ងារងារគណបក្សនយោបាយសង្កេតការណ៍ ឬតំណាងក្នុងរយៈកាលកំណត់មិនអោយលើពីម៉ោង១១ និង៣០នាទីព្រឹកថ្ងៃបន្ទាប់នៃថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោតនោះទេ បណ្តឹងនោះមិនត្រូវបានពិចារណាដោះស្រាយដែរ។[161] សេចក្តីសម្រេចរបស់ គ.ជ.ប ត្រូវបានគេរកឃើញថាមានការប្រើប្រាស់ឆន្ទានុសិទ្ធិសម្រេចដោះស្រាយបណ្តឹង និងបដិសេធមិនដោះស្រាយបណ្តឹងលើសលុបពេក ពីព្រោះថាករណីខ្លះគឺ គ.ជ.ប បានបកស្រាយខុសគ្នាលើសម្រេចសេចក្តីថា រាប់ ឬបដិសេធមិនរាប់សន្លឹកឆ្នោត។[162] គធ.ខប មួយចំនួនត្រូវបានគេរកឃើញថា បានបកស្រាយបញ្ញត្តិ នៃបទបញ្ជា និងនីវិធីសម្រាប់ការបោះឆ្នោតឃុំ សង្កាត់មានលក្ខណៈសេរីនិយម ដែលអាចចាត់ទុកថាជាការបកស្រាយមានគោលការណ៍យុត្តិធម៌ សមហេតុផល មានភាពស៊ីសង្វាក់គ្នា) ដើម្បីសម្រេចលើបណ្តឹងស្នើសុំរាប់សន្លឹកឆ្នោតឡើងវិញ។ មានការខ្វះខាតការបកស្រាយអោយបានច្បាស់លាស់នៅក្នុងសេចក្តីណែនាំសម្រាប់ គធ.ខប ក្នុងការពិចារណាលើបណ្តឹងស្នើសុំរាប់សន្លឹកឆ្នោតឡើងវិញ។ វាច្បាស់ណាស់ថាក្នុងករណីនេះ និយមន័យនៃភាពមិនប្រក្រតីដែលចែងនៅក្នុងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត គឺមានភាពមិនច្បាស់លាស់ ចន្លោះប្រហោង ឬមិនគ្រប់ជ្រុងជ្រោយ។ យ៉ាងហោចណាស់មាន គធ.ខប នៃរាជធានីខេត្តចំនួនពីរ ដែលបានសម្រេចលើកយកបណ្តឹងរបស់គណបក្សប្រជាជនកម្ពុជា ដែលបានប្តឹងតវ៉ាលទ្ធផលបោះឆ្នោតក្រោយពីការប្រកាសលទ្ធផលបឋម មកដោះស្រាយតាមរយៈការរាប់ឡើងវិញ ខណៈដែលបណ្តឹងទាំងនោះត្រូវបានរក

---

[161] ប្រការ១០.៨ នៃបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោតឃុំសង្កាត់ កំណត់ថ្ងៃផុតកំណត់សម្រាប់ការដាក់ពាក្យបណ្តឹងត្រឹមម៉ោង 11:30 ព្រឹកនៅថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត។

[162] ស្ថាប័នគណកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានសម្រេចរាប់សន្លឹកឆ្នោតឡើងវិញបន្ទាប់ពីមានបណ្តឹងឧទ្ធរណ៍របស់គណបក្សសង្គ្រោះជាតិដែលកើតឡើងនៅឃុំបឹងប្រាំ ដោយសារតែពាក្យបណ្តឹងបានពណ៌នាអំពីភាពមិនប្រក្រតីដែលបានកើតឡើងនៅក្នុងការិយាល័យបោះឆ្នោតចំនួន (9) នៅក្នុងឃុំ ហើយកម្មវត្ថុនៃបណ្តឹងគឺមានភាពជាក់លាក់ដោយប្តឹងស្នើសុំអោយរាប់សន្លឹកឆ្នោតឡើងវិញនៅការិយាល័យមួយចំនួន ដូចជា ការិយាល័យលេខ 0662 0663 0664 0667 0668 0669 0670 និង 0672 ជាពិសេសការិយាល័យដែលដែលមានបញ្ហាជាងគេគឺការិយាល័យលេខ 0667 មានមានសន្លឹកឆ្នោតមិនបានការច្រើនជាងគេ។ ពាក្យបណ្តឹងនេះត្រូវបានដាក់ជូនទៅ CEC ប៉ុន្តែ CEC មិនបានពិចារណាដោះស្រាយលើករណីនេះទេ ដោយបដិសេធមិនធ្វើការដោះស្រាយ។ ទោះជាយ៉ាងណាក៏ដោយគណបក្សសង្គ្រោះជាតិបានដាក់ពាក្យបណ្តឹងជំទាស់នឹងលទ្ធផលបឋម ហើយក្រោយមកត្រូវបាន គធ.ខប ខេត្តបាត់ដំបងសម្រេចរាប់សន្លឹកឆ្នោតមិនបានការក្នុងការិយាល័យទាំង០៩នោះ។ ទោះជាយ៉ាងណាបណ្តឹងមួយចំនួនផ្សេងទៀតដែលស្នើសុំការរាប់ឡើងវិញនៅឃុំសង្កាត់មួយចំនួននៅក្នុងខេត្តនេះ គណកម្មាធិការជាតិរៀបចំការបោះឆ្នោតបានសម្រេចបដិសេធមិនរាប់សន្លឹកឆ្នោត។ វាអាចបណ្តាលមកពីមូលហេតុដែលបានលើកឡើងខាងលើ។

ឃើញថា គ្មានបណ្តឹងស្នើសុំរាប់ឡើងវិញ ឬបណ្តឹងអំពីភាពមិនប្រក្រតីនៃការិយាល័យដែលបានកើតឡើងនៅថ្ងៃបោះ និងរាប់ និងត្រូវបានប្តឹងដោយភ្នាក់ងារសង្កេតការណ៍គណបក្សប្រជាជនកម្ពុជាក្នុងការិយាល័យទាំងនោះ នៅពេលវេលាចុងក្រោយផុតកំណត់ត្រឹមម៉ោង១១ និង៣០នាទី ព្រឹកថ្ងៃបន្ទាប់ នៃថ្ងៃបោះឆ្នោត ចំពោះមុខ គយ.សប ឡើយ។ បើផ្អែកតាមសេចក្តីសម្រេចជាច្រើនរបស់ គ.ជ.ប ជាទូទៅ វាគឺជាលក្ខខណ្ឌចាំបាច់ដែល គ.ជ.ប បានកំណត់សម្រាប់ការរាប់សន្លឹកឆ្នោតឡើងវិញ ឬបដិសេធចោល សម្រាប់ការបោះឆ្នោតឃុំសង្កាត់អាណត្តិទី៤នេះ។[163] វាក៏ជាលក្ខខណ្ឌ ដែលត្រូវតែស៊ីសង្វាក់គ្នា មានទំនាក់ទំនងគ្នា រវាងមាត្រា ១៤៩ និង១៥២ នៃច្បាប់បោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឬប្រការ ១០.៨ ប្រការ ១១.១.៩ និងប្រការ. ១១.៧.២ នៃបទបញ្ជា និងនីតិវិធីដែរ។ នៅក្នុងឃុំដូង ស្រុករមាសហែក ខេត្តស្វាយរៀង តំណាងគណបក្សប្រជាជនកម្ពុជា បានដាក់ពាក្យបណ្តឹងអំពីភាពមិនប្រក្រតីដែលបានកើតឡើងនៅក្នុងការិយាល័យទាំង០៩ក្នុងឃុំ[164] ដែលពាក់ព័ន្ធជាមួយសន្លឹកឆ្នោតមិនបានការសរុប ១២៥សំលេង។ ក្នុងឃុំស្វាយធំ តំណាងគណ

---

[163] បណ្តឹងនោះគឺ កើតឡើងនូវសង្កាត់ស្វាយប៉ាក រាជធានីភ្នំពេញ និងឃុំដូង និងឃុំស្វាយធំខេត្តស្វាយរៀង។ បណ្តឹងទាំងបីរនេះ ត្រូវបានប្តឹងដោយតំណាងគណបក្សប្រជាជនកម្ពុជាប្រចាំខេត្ត/រាជធានី តវ៉ានឹងលទ្ធផលបឋមដែលដែលប្រកាសដោយ គយ.សប នៃឃុំសង្កាត់ទាំងបីខាងលើ។ ទោះជាយ៉ាងណា នៅក្នុងពាក្យបណ្តឹង គឺមានសរសេរបញ្ជាក់ច្បាស់អំពីលេខ ទីតាំងដែលមានភាពមិនប្រក្រតីកើតឡើង ដោយមានបញ្ជាក់ជាលេខការិយាល័យបោះឆ្នោតច្បាស់លាស់។ ករណីបណ្តឹងនៅឃុំដូង លទ្ធផលដែលទទួលស្គាល់ដោយ គយ.សប គឺគណបក្សសង្គ្រោះជាតិជាអ្នកឈ្នះអាសនៈជាមេឃុំ។ លទ្ធផលនេះ ត្រូវបានប្តឹងជំទាស់ និងតវ៉ា ដោយតំណាងគណបក្សប្រជាជនកម្ពុជា ស្នើសុំរាប់សន្លឹកឆ្នោតឡើងវិញនូវក្នុងការិយាល័យមួយចំនួនក្នុងឃុំនេះ។ គយ.ខប បានសម្រេចលើបណ្តឹង ហើយបានរាប់សន្លឹកឆ្នោតឡើងវិញនូវការិយាល័យទាំង០៦ ក្នុងឃុំនេះ។ បន្ទាប់ពី គធ.ខប បានរាប់ លទ្ធផលបានប្តូរទៅជា គណបក្សប្រជាជនកម្ពុជាទទួបានសំលេងឆ្នោតច្រើនជាង និងឈ្នះអាសនៈជាមេឃុំ។ គណបក្សសង្គ្រោះជាត មិនអស់ចិត្ត ក៏ប្តឹងឧទ្ធរណ៍ជំតវ៉ា នឹងលទ្ធផលដែលសម្រេចដោយ គធ.ខប នៃខេត្តស្វាយរៀងមក គ.ជ.ប ដើម្បីស្នើសុំរាប់សារឡើងវិញ និងបានប្តឹងពីភាពមិនប្រក្រតីដែលប្រព្រឹត្តឡើងដោយប្រធាន គធ.ខប លោក ឯម សុត ដោយចោទប្រកាន់ថា ប្រធាន គធ.ខប បានឃុបឃិត បន្លំសន្លឹកឆ្នោតនៅថ្ងៃរាប់សន្លឹកឆ្នោតឡើងវិញ។ គ.ស.ជ បានប្តឹងមក គ.ជ.ប សុំរាប់សន្លឹកឆ្នោតឡើងវិញនូវការិយាល័យចំនួន២៣ នៅក្នុងឃុំនេះ។ លទ្ធផលមុនការរាប់សន្លឹកឆ្នោតឡើងវិញគឺ ២៥៩៦ (គ ប្រ.ជ) ទល់ ២៥៩៩ (គ.ស.ជ)។ ក្រោយពីរាប់ឡើងវិញនៅ គធ.ខប នៅថ្ងៃទី០៧ មិថុនា លទ្ធផលគឺ ២៦០២ (គ.ប្រ.ជ) ទល់ ២៦០១ (គ.ស.ជ)។ គ.ជ.ប បានសម្រេចតាមបណ្តឹង ដោយបានរាប់ឡើងវិញនូវការិយាល័យទាំង២៣នោះ ហើយលទ្ធផលបង្ហាញថា ២៦១១ សំលេង (គ.ប្រ.ជ) ទល់ ២៦០៩ សំលេង (គ.ស.ជ)។ ពាក់ព័ន្ធជានឹងដំណើរការរាប់សន្លឹកឆ្នោតឡើងវិញនេះដែរ ខុមហ្វ្រែលបានដាក់អ្នកសង្កេតការណ៍របស់ខ្លួនអោយតាមដាន ហើយបានសង្កេតឃើញថា ដំណើរការបានប្រព្រឹត្តទៅដោយភាពរញ៉េរញ៉ៃ គ្មានសណ្តាប់ធ្នាប់ ហើយប្រធាន គធ.ខប ហាក់ដូចជាទទួលគំនាបពីមន្ត្រីជាន់ខ្ពស់នៃគណបក្សកាន់អំណាច។ (នាម ចេង គ.ជ.ប *បើកការស៊ើបអង្កេតលើបណ្តឹងប្រឆាំងប្រធានប៉ុចខេត្តស្វាយរៀង* កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២២ មិថុនា ឆ្នាំ០២១៧)។

[164] ការិយាល័យដែលមានជម្លោះនោះរួមមាន ការិយាល័យលេខ 0388, 0390, 0392, 0393, 0395, 0402, 0403, 0407, និង 0408។

បក្សទាំងពីរបានដាក់ពាក្យបណ្តឹងជំទាស់នឹងលទ្ធផលបោះឆ្នោតបឋម ដែលសម្រេចដោយ គឃ.សប ឃុំស្វាយធំ ដូចគ្នានៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧។ គណបក្សប្រជាជនកម្ពុជាប្តឹងសុំរាប់សន្លឹកឆ្នោតឡើងវិញនៅការិយាល័យចំនួន០៨ និងគណបក្សសង្គ្រោះជាតិ ប្តឹងសុំរាប់សន្លឹកឆ្នោតឡើងវិញនៅការិយាល័យចំនួន ១៧ បើទោះជាលទ្ធផលបង្ហាញថា ខ្លួនឈ្នះសំលេងច្រើនជាងគណបក្សប្រជាជនកម្ពុជាក៏ដោយ។ បណ្តឹងនៃគណបក្សទាំងពីរ ត្រូវបានសម្រេចរាប់ឡើងវិញដោយ គធ.ខប ខេត្តស្វាយរៀង ហើយទទួលយកសេចក្តីសម្រេចរបស់ គឃ.សប នៃឃុំស្វាយធំ លើលទ្ធផលបឋម។ លទ្ធផលដែល គឃ.សប ឃុំស្វាយធំ ប្រកាសគឺគណបក្សសង្គ្រោះជាតិទទួលបាន ២៨២៦ ទល់ ២៨១៧ ដែលទទួលបានដោយគណបក្សប្រជាជនកម្ពុជា។ ក្រោយពី គធ.ខប បានរាប់ឡើងវិញនៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៧ លទ្ធផលបង្ហាញថា គណបក្សប្រជាជនកម្ពុជាបានថយសំលេងឆ្នោតមកនៅត្រឹម ២៨១៣សំលេង ទល់នឹងគណបក្សសង្គ្រោះជាតិថយមកនៅត្រឹម ២៨២២សំលេង។ លទ្ធផលគណបក្សសង្គ្រោះជាតិ នៅតែឈ្នះអាសនៈជាមេឃុំដដែល។ សេចក្តីសម្រេចនេះ ត្រូវបានប្តឹងឧទ្ធរណ៍តវ៉ាបន្តទៀត ដោយគណបក្សប្រជាជនកម្ពុជាមកកាន់ គ.ជ.ប ប៉ុន្តែ គ.ជ.ប បានបដិសេធមិនធ្វើការរាប់ឡើងវិញទេ ដោយបានដំកល់សេចក្តីសម្រេចរបស់ គធ.ខប ខេត្តស្វាយរៀង។ គួរបញ្ជាក់ថា បណ្តឹងនៃឃុំស្វាយធំ ដែលប្តឹងដោយគណបក្សទាំងពីរនៅក្រោយថ្ងៃប្រកាសលទ្ធផលបឋមរបស់ គឃ.សប គឺមិនមានវត្តមានបណ្តឹងនៃភ្នាក់ងារគណបក្សនយោបាយទាំងពីរឡើយ ប៉ុន្តែបណ្តឹងនេះមានបញ្ជាក់អំពីលេខការិយាល័យដែលមានភាពមិនប្រក្រតីកើតឡើង។

ករណីមួយទៀតដែល ខុមហ្វ្រែលបានតាមដាន និងសិក្សាផងដែរ ករណីបានកើតឡើងនៅសង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ បណ្តឹងនេះ ត្រូវបានប្តឹងដោយភ្នាក់ងារគណបក្សប្រជាជនកម្ពុជា លោក លីន ញ៉ក ជំទាស់នឹងលទ្ធផលបឋមរបស់ គឃ.សប នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧ ក្រោមមូលហេតុថា ភាពមិនប្រក្រតីបានកើតឡើងទាំង១៣ការិយាល័យនៃសង្កាត់ស្វាយប៉ាក។ ទោះជាយ៉ាងណា នៅក្នុង៣ពាក្យបណ្តឹងដែលប្តឹងទៅ គធ.ខប គឺមិនមានរាយឈ្មោះ ឬលេខការិយាល័យទាំងនោះឡើយ។ គធ.ខប រាជធានីភ្នំពេញ ទទួល និងលើកយកបណ្តឹងនេះមកដោះស្រាយ ដោយបានរាប់សន្លឹកឆ្នោតឡើងវិញ។ បើតាមមន្ត្រី គធ.ខប នៃរាជធានីភ្នំពេញ បណ្តឹងនេះក៏ត្រូវបានប្តឹងនៅ គឃ.សប ដោយភ្នាក់ងារគណបក្សប្រជាជនកម្ពុជាផងដែរ ហើយត្រូវបានបដិសេធមិនដោះស្រាយ ដោយ គឃ.សប សង្កាត់ស្វាយប៉ាក។ បើពិនិត្យលើនីតិវិធី គឺបណ្តឹងនេះបានបំពេញគ្រប់គ្រាន់ហើយ រាប់តាំងពីបណ្តឹងចំពោះមុខ គឃ.សប អំពីភាពមិនប្រក្រតីមកម្ល៉េះ គ្រាន់តែថា បណ្តឹងនោះមិនបានប្តឹងបញ្ជាក់អោយច្បាស់អំពីការិយាល័យមួយ ឬច្រើន ហើយបញ្ជាក់អំពីលេខការិយាល័យដែលកើតភាពមិនប្រក្រតី។ នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧ លោក ឆរ ព័ណ្ណ ប្រធាន គធ.ខប រាជធានី បានបើកការរាប់សន្លឹកឆ្នោតឡើងវិញ ហើយបដិសេធលទ្ធផលដែលចេញដោយ គឃ.សប នៃសង្កាត់ស្វាយប៉ាក។ លទ្ធផលដែលប្រកាសដោយ គឃ.សប គឺគណបក្សសង្គ្រោះជាតិទទួលបាន ២៨១១សំឡេងទល់នឹង ២៨០៦សំលេង ដែលទទួលបានដោយគណបក្សប្រជាជនកម្ពុជា។ ចំណែកលទ្ធផលក្រោយពីរាប់ឡើងវិញ បង្ហាញថា គណបក្សប្រជាជនកម្ពុជាទទួលជ័យជំនះឈ្នះអាសនៈចៅសង្កាត់វិញ គឺគណបក្សប្រជាជនកម្ពុជាទទួលបាន ២៧៩២សំឡេង ទល់នឹង ២៧៨៥សំឡេងដែលគណបក្សសង្គ្រោះជាតិទទួលបាន។ គណបក្សសង្គ្រោះជាតិ បានប្តឹងបន្តមក គ.ជ.បនូវសេចក្តីសម្រេចរបស់ គធ.ខប រាជធានី។

ទោះជាយ៉ាងណា គ.ជ.ប បានបដិសេធលទ្ធផល និងសេចក្តីសម្រេចដែលសម្រេចដោយ គធ.ខប រាជធានីភ្នំពេញ និងតំកល់សេចក្តីសម្រេច គឃ.សប សង្កាត់ស្វាយប៉ាកទុកជាបានការ។

ករណីឃុំគំរូ ខេត្តបន្ទាយមានជ័យ តំណាងគណបក្សសង្គ្រោះជាតិបានដាក់ពាក្យបណ្តឹងជំទាស់នឹងលទ្ធផលបោះឆ្នោតបឋមនៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧។ លទ្ធផលដែលប្រកាស និងបិទផ្សាយដោយ គឃ.សប ឃុំគំរូ គឺគណបក្សប្រជាជនកម្ពុជាទទួលបាន ១១២៥សំឡេង ទល់នឹង១១២២ សំលេងទទួលដោយ គណបក្សសង្គ្រោះជាតិ។ គធ.ខប ខេត្តបន្ទាយមានជ័យ បានសម្រេចដោះស្រាយបណ្តឹងរបស់គណបក្សសង្គ្រោះជាតិ ដោយផ្អែកលើកំរិតលំអៀងនៃសំលេងសន្លឹកឆ្នោតនៃគណបក្សនយោបាយទាំងពីរតិចជាង ០.៥ ភាគរយ (ខុសគ្នាតែបីសំលេង) ដែលមានចែងក្នុងមាត្រា១៥២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។ ទោះជាយ៉ាងណា តាមការបញ្ជាក់របស់តំណាងស្រុកនៃគណបក្សសង្គ្រោះជាតិ បានបញ្ជាក់ថា គណបក្ស ឬភ្នាក់ងារគណបក្សមិនបានដាក់ពាក្យបណ្តឹងអំពីភាពមិនប្រក្រតីនៅថ្ងៃបោះ និងរាប់ព្រមទាំងថ្ងៃក្រោយបោះ និងរាប់សន្លឹកឆ្នោត ចំពោះមុខ គឃ.សប នៃឃុំគំរូឡើយ។ អ្នកសង្កេតការណ៍ ខុមហ្វ្រែលដែលបានចូលសង្កេតនៅថ្ងៃដោះស្រាយបណ្តឹង បានសង្កេតឃើញថា ក្រោយពីការរាប់សន្លឹកឆ្នោតឡើងវិញ លទ្ធផលបានផ្លាស់ប្តូរដោយគណបក្សប្រជាជនកម្ពុជាគឺបានបាត់សំឡេងឆ្នោតវិញចំនួន៤៦ សំឡេង និងគណបក្សសង្គ្រោះជាតិបានបាត់សំឡេងឆ្នោតវិញចំនួន៣៥សំឡេង។ សន្លឹកឆ្នោតដែលបានរាប់ឡើងវិញ គឺផ្ទៀងផ្ទាត់ទៅលើសន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការនៃគណបក្សនយោបាយទាំងពីរក្នុងឃុំគំរូ។ លទ្ធផលនោះគឺ គណបក្សសង្គ្រោះជាតិទទួលបាន១០៨៧សំឡេង ទល់នឹង១០៧៩សំឡេង ដែលទទួលបានដោយគណបក្សប្រជាជនកម្ពុជា។ លទ្ធផលនេះ ធ្វើអោយភាគីគណបក្សប្រជាជនកម្ពុជាមិនអស់ចិត្តបានប្តឹងឧទ្ធរណ៍តវ៉ាមក គ.ជ.ប ដើម្បីស្នើសុំរាប់សន្លឹកឆ្នោតឡើងវិញ។ ទោះជាយ៉ាងណា គ.ជ.ប បានសម្រេចច្រានចោលលទ្ធផលដែលរាប់ឡើងវិញដោយ គធ.ខប ខេត្តបន្ទាយមានជ័យ និងបានតំកល់ ឬទទួលស្គាល់លទ្ធផលបោះឆ្នោតដែលប្រកាសដោយ គឃ.សប ឃុំគំរូ ទុកជាបានការ។ ដូច្នេះធ្វើអោយគណបក្សប្រជាជនកម្ពុជា ឈ្នះអាសនៈជាមេឃុំនៃឃុំគំរូ។

ការសិក្សាលើករណីនេះ សន្និដ្ឋានថា ការសម្រេចរាប់ឡើងវិញរបស់ គធ.ខប តាមបណ្តឹងស្នើសុំរបស់តំណាងគណបក្សសង្គ្រោះជាតិ នៅក្រោយការបិទផ្សាយលទ្ធផលបឋមដែលចេញដោយ គឃ.សប គឺអាចផ្អែកលើលក្ខខណ្ឌដែលមានចែងក្នុងមាត្រា១៥២ នៃច្បាប់បោះឆ្នោតឃុំ សង្កាត់ ដែលមានចែងបន្ថែមក្នុងប្រការ ១១.៧ (១១.៧.២) នៃបទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០១៧ ស្តីអំពីកម្រិតលម្អៀងតិចជាង ០.៥ភាគរយ នៃសំឡេងឆ្នោតរវាងបេក្ខជន ឬគណបក្សពីរ និងហេតុផលនៃភាពមិនប្រក្រតីដែលកើតឡើងនៅក្នុងឃុំនេះ គឺមានសន្លឹកឆ្នោតមិនបានការច្រើនខុសប្រក្រតី។ តាមរយៈសេចក្តីសម្រេចនេះ គធ.ខប ខេត្តបន្ទាយមានជ័យ មិនបានផ្អែកលើបញ្ញត្តិនៃមាត្រា១៤៩ នៃច្បាប់បោះឆ្នោតឃុំសង្កាត់ឡើយ។ វាខុសគ្នាពី គធ.ខប នៃរាជធានីផ្សេងៗ ដែលជាទូទៅគឺបានផ្អែកការសម្រេចចិត្តរបស់ខ្លួនលើការដោះស្រាយបណ្តឹង (បដិសេធ ឬយល់ព្រម) ដោយផ្អែកអំពីទំនាក់ទំនងរវាងបញ្ញត្តិនៃមាត្រា១៤៩ និងមាត្រា១៥២ នៃច្បាប់បោះឆ្នោតឃុំសង្កាត់ និងប្រការ១០.៨ និង១១.៧.២ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០១៧។ ជាទូទៅ គ.ជ.ប ឬ គធ.ខប បានសង្កត់ធ្ងន់លើទំនាក់ទំនងបញ្ញត្តិនៃមាត្រា១៤៩ និង

មាត្រា១៥២ នៃច្បាប់បោះឆ្នោត ឬប្រការ ១០.៨ និង១១.១.៩.២ និងប្រការ ១១.១.៩.២[165] ជាមូលហេតុសំខាន់ក្នុងការធ្វើសេចក្តីសម្រេចលើបណ្តឹង ដែលត្រូវបានប្តឹងនៅក្រោយពីបិទប្រកាសលទ្ធផលបឋមរបស់ គយ.សប។ ម៉្យាវិញទៀតករណីបណ្តឹងណាដែលគ្មានបណ្តឹងត្រូវបានដាក់ចំពោះមុខ គយ.សប ឬប្រធានការិយាល័យរាប់សន្លឹកឆ្នោត នៅត្រឹមយ៉ាងយូរម៉ោង១១ និង៣០នាទីព្រឹកថ្ងៃបន្ទាប់នៃថ្ងៃបោះឆ្នោត បណ្តឹងនោះក៏មិនអាចត្រូវដោះស្រាយដោយ គ.ជ.ប ឬ គធ.ខប ឡើយ បើទោះជាកម្រិតលម្អៀងតិចជាង ០.៥ភាគរយ នៃសំលេងឆ្នោត និងភាពមិនប្រក្រតីនៃសន្លឹកឆ្នោតមិនបានការច្រើន ត្រូវបានបញ្ជាក់ ឬបង្ហាញក៏ដោយ។

យោងតាមសេចក្តីសម្រេចជាច្រើនរបស់ គ.ជ.ប បណ្តឹងជាច្រើនដែល គ.ជ.ប សម្រេចបដិសេធមិនធ្វើការដោះស្រាយដោយអនុញ្ញាតអោយរាប់សន្លឹកឆ្នោតឡើងវិញ តាមពាក្យបណ្តឹងស្នើសុំ គឺផ្អែកលើមាត្រាចំនួនពីរដែលត្រូវអនុវត្តជាមួយគ្នា គឺបញ្ញត្តិមាត្រា១៤៩ និងមាត្រា១៥២។ មាត្រា១៥២ ចែងអំពីកម្រិតលម្អៀងតិចជាង០.៥ ភាគរយ គឺអនុញ្ញាតអោយរាប់ឡើងវិញបាន បើមានបណ្តឹង និងមានភាពមិនប្រក្រតី។ ភាពមិនប្រក្រតី គឺត្រូវផ្អែកលើមាត្រា១៤៩ នៃច្បាប់បោះឆ្នោតឃុំ សង្កាត់។ ហានិភ័យនេះមិនត្រឹមតែមើលឃើញនូវពាក្យបណ្តឹងត្រឹមត្រូវមួយចំនួនដែលទាក់ទងនឹងភាពមិនប្រក្រតីដែលកើតឡើង បន្ទាប់ពីព្រឹកបន្ទាប់ពីការបោះឆ្នោតដោយខ្លួនឯង ប៉ុន្តែបង្ខំឱ្យមានសកម្មភាពមិនស្ម័គ្រចិត្តពីសំណាក់តំណាងគណបក្សនយោបាយដោយផ្តល់នូវការលើកទឹកចិត្តយ៉ាងខ្លាំងក្នុងការដាក់ពាក្យបណ្តឹងចំពោះភាពមិនប្រក្រតីដែលមានសក្តានុពលមុនពេលពួកគេបានកើតមានឡើង ដែលជាមធ្យោបាយតែមួយគត់ ដើម្បីពិចារណាលើសំណុំរឿងនៅពេលក្រោយដោយស្ថាប័នបោះឆ្នោត។ ការសម្រេចចិត្តដោះស្រាយបណ្តឹងដែលបង្កប់ជាមួយនូវហានិភ័យនេះ មិនត្រឹមតែទាមទារអោយបណ្តឹងស្នើសុំរាប់សន្លឹកឆ្នោតមួយ គ្រាន់តែជាបណ្តឹងជំទាស់ ឬតវ៉ាអំពីភាពមិនប្រក្រតីនៃលទ្ធផលបោះឆ្នោតធ្វើនៅក្រោយម៉ោង ១១ និង៣០នាទីព្រឹកប៉ុណ្ណោះទេ ប៉ុន្តែដើម្បីអាចពិចារណាដោះស្រាយបណ្តឹងនេះបាន វាទាមទារអោយមានបណ្តឹងអំពីភាពមិនប្រក្រតី ដែលត្រូវបានដាក់ឱ្យបានមុនម៉ោង១១ និង៣០នាទីព្រឹក ថ្ងៃបន្ទាប់នៃថ្ងៃបោះ និងរាប់សន្លឹកឆ្នោត ដោយភ្នាក់ងារសង្កេតការណ៍នៃគណបក្ស ឬតំណាងគណបក្សនយោបាយថែមទៀត។

---

[165] ប្រការនេះចែងថា ផ្អែកតាមការណែនាំរបស់ គធ.ខប ក្រុមត្រួតពិនិត្យលទ្ធផលត្រូវអនុវត្តការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំសង្កាត់ ចំណុះរាជធានីខេត្ត ដោយត្រូវបំពេញការងារពាក់ព័ន្ធតាមការចំបាច់ និងតាមលំដាប់លំដោយនៃករណីជាក់ស្តែងនីមួយៗដូចខាងក្រោម៖

១១.១.៩.១ ករណីឃុំសង្កាត់ណាដែលគ្មានពាក្យបណ្តឹងតវ៉ាឬបណ្តឹងជំទាស់ត្រូវបានដាក់នៅ គយ.សប និងនៅគធ.ខប

១១.១.៩.២ ករណីឃុំសង្កាត់ណា ដែលមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ត្រូវបានដាក់នៅ គយ.សប និងមានកញ្ចប់សុវត្ថិភាព ក ត្រូវបានបើក ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ហើយគយ.សបបានយល់ព្រម ឬបដិសេធលើបណ្តឹងនោះ និងករណីឃុំសង្កាត់ណាដែលមានពាក្យបណ្តឹងតវ៉ា និងបណ្តឹងជំទាស់ ត្រូវបានដាក់នៅ គធ.ខប។

១១.១.៩.៣ ករណីឃុំសង្កាត់ណា ដែលមានលម្អៀងសំឡេងឆ្នោតយ៉ាងច្រើន ០,៥ភាគរយ រវាងបញ្ជីបេក្ខជននៃគណបក្សពីរ ឬច្រើន និងករណីឃុំសង្កាត់នោះមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ត្រូវបានដាក់នៅ គធ.ខប។

១០.៣.២. ការទទួល និងដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

ក្នុងតំណាក់កាលនេះ គ.ជ.ប បានទទួលពាក្យបណ្តឹងចំនួន៣៧បណ្តឹង ក្នុងនោះបណ្តឹងចំនួន១០ ត្រូវបានប្តឹងឡើងមកដោយគណបក្សប្រជាជនកម្ពុជា និងបណ្តឹងចំនួន២៧ ត្រូវបានប្តឹងដោយគណបក្សសង្គ្រោះជាតិ។ ក្នុងចំណោម ៣៧បណ្តឹង មានបណ្តឹងចំនួន៣៥ គឺពាក់ព័ន្ធជាមួយបណ្តឹងស្នើសុំរាប់សន្លឹកឆ្នោតឡើងវិញ ដែលជាបណ្តឹងតវ៉ា ឬជំទាស់នឹងសម្រេចរបស់ គធ.ខប រាជធានី ខេត្ត។ មានបណ្តឹងចំនួនពីរដែលពាក់ព័ន្ធនឹងការស្នើសុំអោយ គ.ជ.ប ធ្វើការពិន័យដាក់ទណ្ឌកម្មតាមផ្លូវច្បាប់ ចំពោះអ្នកប្រព្រឹត្តល្មើស។ ជាលទ្ធផល បណ្តឹងក្នុងដំណាក់កាលក្រោយការបោះឆ្នោតនេះ មានតែបណ្តឹងមួយគត់ដែល គ.ជ.ប បានលើកយកមកដោះស្រាយ គឺបានយល់ព្រមរាប់សន្លឹកឆ្នោតឡើងវិញ តាមបណ្តឹងស្នើសុំរបស់គណបក្សសង្គ្រោះជាតិករណីឃុំដូង ខេត្តស្វាយរៀង។[166] គ.ជ.ប បានបដិសេធពាក្យបណ្តឹងចំនួន០៣ និងធ្វើលិខិតជូនដំណឹងដល់ភាគីពាក់ព័ន្ធនឹងបណ្តឹងចំនួន៣២បណ្តឹង។

ចំពោះករណីឃុំដូង គ.ជ.ប បានសម្រេចលើកយកមកដោះស្រាយ តាមការស្នើសុំរបស់ភាគីគណបក្សសង្គ្រោះជាតិដែលស្នើសុំរាប់សន្លឹកឆ្នោតឡើងវិញ នៅការិយាល័យចំនួន២៣ការិយាល័យ។ បន្ទាប់ពីការរាប់ឡើងវិញនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧ លទ្ធផលរកឃើញថា មានសន្លឹកឆ្នោតមិនបានការសរុបចំនួន ១៨១សន្លឹក នៃ២៣ការិយាល័យ ត្រូវបានរកឃើញ។ ក្នុងចំណោមសន្លឹកឆ្នោត១៨១ ដែលមិនបានការនេះ មានសន្លឹកឆ្នោតចំនួន៦៦សន្លឹក ដែលក្រុមការងារផ្ទៀងផ្ទាត់មិនអាចកាត់សេចក្តីលើគំនូសសញ្ញាបាន ហើយបានដាក់ជូនសមាជិក គ.ជ.ប ពិនិត្យសម្រេចចុងក្រោយ។ នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ គ.ជ.ប បានរកឃើញថា មានសន្លឹកឆ្នោត សរុបចំនួនតែ៧៥សន្លឹកនៃ១៨១សន្លឹក ជាសន្លឹកឆ្នោតមិនបានការ។ ជាលទ្ធផល គ.ជ.ប បានសម្រេចថា គណបក្សប្រជាជនកម្ពុជា ទទួលបានសំឡេងឆ្នោត ២៦១១សំឡេង ទល់នឹង ២៦០៩សំឡេង នៃគណបក្សសង្គ្រោះជាតិ ដោយគណបក្សប្រជាជនកម្ពុជាជាអ្នកឈ្នះអាសនៈជាមេឃុំដូង។ ការសម្រេចរបស់ គ.ជ.ប គឺជាការសេចក្តីចុងក្រោយ បិទផ្លូវតវ៉ា។

ជារួមខុមប្រៀលរកឃើញ និងសន្និដ្ឋានថា ដំណើរការដោះស្រាយបណ្តឹងបោះឆ្នោតទាំងមូលសម្រាប់ការបោះឆ្នោតជ្រើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី០៤នេះ នៅខ្វះតម្លាភាពត្រង់ចំណុចខ្លះ និងគណនេយ្យភាពនៃការដោះស្រាយបណ្តឹង ជាពិសេសការសម្រេចបដិសេធមិនធ្វើការដោះស្រាយបណ្តឹងស្នើសុំរាប់សន្លឹកឆ្នោតឡើងវិញជាច្រើនបណ្តឹង។ ទឡ្ហីករណ៍ ឬហេតុផលក្នុងការបដិសេធបណ្តឹងមានភាពមិនច្បាស់លាស់ និងមិនស៊ីសង្វាក់គ្នា ឬទីទៃពីគ្នារវាងការបកស្រាយបញ្ញត្តិច្បាប់ បទបញ្ជា និងនីតិវិធីសម្រាប់ដោះស្រាយបណ្តឹង។ គ.ជ.ប ខ្លួនឯងក៏ទទួលស្គាល់ថា ចន្លោះប្រហោងនៃច្បាប់ ភាសាចែងក្នុងមាត្រាទាំងនោះ នៅមានបញ្ហាស្រពេចស្រពិលដែលនាំអោយមានការយល់ច្រឡំ និងមានការបកស្រាយទីទៃពីគ្នារវាងស្ថាប័នមានសមត្ថកិច្ច

[166] It is important to note that this complaint was filed after the notification of preliminary results for the relevant commune

ដោះស្រាយបណ្តឹងរបស់ គ.ជ.ប។ ខាងក្រោមនេះ ជាលក្ខខណ្ឌមួយចំនួនដែលក្រុមការងារ ខុមហ្វ្រែលរកឃើញថា គ.ជ.ប បានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ពិចារណាលើបណ្តឹង និងបដិសេធបណ្តឹងស្នើសុំរាប់សន្លឹកឆ្នោតឡើងវិញ៖

១. ប្រសិនបើពិនិត្យឃើញថា មានភាពមិនប្រក្រតីធ្ងន់ធ្ងរ ជាពិសេសចំនួននៃសន្លឹកឆ្នោតមិនបានការច្រើនហួសហេតុ ដែលមាននៅក្នុងការិយាល័យមួយ ឬច្រើន ឬទូទាំងឃុំសង្កាត់។

២. កម្រិតលម្អៀងតិចជាង ០,៥ភាគរយនៃសំលេងឆ្នោតរវាងបញ្ជីបេក្ខភាពគណបក្សពីរ ឬច្រើន

៣. ករណីមានបណ្តឹងត្រូវបានដាក់ដោយភ្នាក់ងារសង្កេតការណ៍គណបក្សនយោបាយ ឬតំណាងដែលបានសង្កេតការណ៍បោះឆ្នោតនៅតាមការិយាល័យ ដែលកើតមានភាពមិនប្រក្រតី។ បណ្តឹងនេះត្រូវប្តឹងយ៉ាងយូរត្រឹមម៉ោង១១ និង៣០នាទីព្រឹកថ្ងៃបន្ទាប់នៃថ្ងៃបោះ និងរាប់សន្លឹកឆ្នោត។[167]

៤. បណ្តឹងត្រូវតែដាក់ក្នុងរយៈពេលកំណត់ដោយច្បាប់ (អាជ្ញាយុកាលនៃបណ្តឹង)។ រយៈពេលកំណត់ គឺក្នុងរយៈពេលបីថ្ងៃ បន្ទាប់ពីថ្ងៃប្រកាសលទ្ធផលបឋមដោយ គយ.សប ឬសេចក្តីសម្រេចរបស់ គធ.ខប លើបណ្តឹងនោះ។ បណ្តឹងនោះក៏ត្រូវតែប្តឹងដោយអ្នកតំណាងស្របច្បាប់នៃគណបក្សនយោបាយ។

លក្ខខណ្ឌទាំងនេះ ជាហេតុធ្វើអោយមានភាពស្រពេចស្រពិល ហើយការសន្និដ្ឋាន និងការវិភាគបានសន្និដ្ឋានថាលក្ខខណ្ឌចាំបាច់ទាំងនេះ មិនបានផ្តល់យន្តការសមរម្យដើម្បីសម្រួលដល់យន្តការនៃការ (ទទួលពិនិត្យ និងដោះស្រាយ) បណ្តឹងស្នើសុំរាប់សន្លឹកឆ្នោតឡើងវិញឡើយ។ ជាលទ្ធផល ឃើញថា ដោយសារតែភាពខ្វះចន្លោះ ឬភាពទូលំទូលា និងភាពមិនច្បាស់លាស់នៃភាសាដែលចែងក្នុងច្បាប់ បទបញ្ញត្តិ បានអនុញ្ញាតអោយស្ថានប័នមានសមត្ថកិច្ចដោះស្រាយបណ្តឹងបោះឆ្នោត ប្រើឆន្ទានុសិទ្ធិទូលំទូលាយពេក ក្នុងការបដិសេធមិនដោះស្រាយបណ្តឹងជាច្រើន បើទោះបីជាបណ្តឹងទាំងនោះមានភ័ស្តុតាងរឹងមាំ គ្រប់លក្ខខណ្ឌច្បាប់តម្រូវក៏ដោយ។ ជាពិសេសក្នុងលក្ខខណ្ឌទី៣ ដែលលក្ខខណ្ឌនេះ វាពិតជាលក្ខខណ្ឌដែលតឹងតែងហើយមានគុណវិបត្តិធ្ងន់ធ្ងរដល់ការដោះស្រាយបណ្តឹង និងនាំអោយមានការទាត់ចោលនូវបណ្តឹងស្នើសុំ។

---

[167] ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧នេះ បណ្តឹងបោះឆ្នោតត្រូវតែប្តឹងដោយភ្នាក់ងារគណបក្សនយោបាយ ដែលមានវត្តមានសង្កេតការណ៍បោះឆ្នោតនៅក្នុងការិយាល័យណាមួយ ឬច្រើននៃឃុំសង្កាត់នោះក្នុងអំឡុងពេលដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោត។ បណ្តឹងនេះត្រូវតែដាក់អោយបានយ៉ាងយូរត្រឹមម៉ោង ១១ និង៣០នាទីព្រឹកថ្ងៃបន្ទាប់ នៃថ្ងៃបោះឆ្នោត។

លក្ខខណ្ឌទី១ ទី២ និងទី៤ ជាលក្ខខណ្ឌអាចទទួលយកបានសម្រាប់ការដោះស្រាយបណ្តឹង ពីព្រោះវាមានភាពសមហេតុសមផលរបស់វា។

អង្គការខុមហ្វ្រែលបានរកឃើញថា មានបណ្តឹងស្នើសុំរាប់សន្លឹកឆ្នោតឡើងវិញជាច្រើនដែលមិនត្រូវបាន គ.ជ.ប យកមកពិនិត្យដើម្បីដោះស្រាយ ដោយសារតែខ្វះលក្ខខណ្ឌទី៣នេះឯង។ មានបណ្តឹងជាច្រើនដែលត្រូវបាន គ.ជ.ប មិនយកមកពិនិត្យ ដែលលក្ខខណ្ឌផ្សេងទៀតបានបំពេញហើយ ប៉ុន្តែលើកលែងតែលក្ខខណ្ឌទី៣។ លក្ខខណ្ឌទី៣នេះ ជាទូទៅវាបានក្លាយជាមូលដ្ឋានសម្រាប់រឹងមាំមួយ ដែលគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត និង គ.ជ.ប ធ្វើការសម្រេចចិត្តលើការដោះស្រាយបណ្តឹង ឬបដិសេធមិនដោះស្រាយបណ្តឹង។ បទបញ្ជា និងនីតិវិធីដែលលំអិត ច្បាស់លាស់ និងអាចធ្វើការបកស្រាយ និងបំពេញអត្ថន័យគ្រប់គ្រាន់ ទាមទារអោយមានការជជែកគ្នា និងកែតម្រូវអោយមានភាពប្រសើឡើងសម្រាប់ប្រើប្រាស់ក្នុងការដោះស្រាយបណ្តឹងបោះឆ្នោតទៅថ្ងៃអនាគត។ ការសិក្សារបស់អង្គការខុមហ្វ្រែលបានរកឃើញថា គ.ជ.ប និង គធ.ខប ការដោះស្រាយបណ្តឹងមានកំណត់លក្ខខណ្ឌឯកភាពមួយ ដើម្បីយកជាមូលដ្ឋានគោលសម្រាប់ស្ថាប័នមានសមត្ថកិច្ចដោះស្រាយបណ្តឹងរបស់ គ.ជ.ប ទាំងអស់អោយមានការឯកភាពគ្នា។ ឧទាហរណ៍ ដូចជា ក្នុងឃុំដូង គ.ជ.ប បានទទួលស្គាល់សេចក្តីសម្រេចរបស់ គធ.ខប អំពីការរាប់សន្លឹកឆ្នោតឡើងវិញ ក្រោយពេលដែលគណបក្សប្រជាជនប្តឹងអោយរាប់សន្លឹកឆ្នោតវិញ បើទោះបីជាបណ្តឹងនេះមិនស្របតាមលក្ខខណ្ឌទី៣ ក៏ដោយ។[168]

គ.ជ.ប បានសម្រេចរាប់សន្លឹកឆ្នោតឡើងនៅការិយាល័យបោះឆ្នោតទាំង២៣ នៅឃុំដូង ដែលជាការទាមទាររបស់គណៈបក្សសង្គ្រោះជាតិ។[169] ការសម្រេចដើម្បីរាប់សន្លឹកឡើងវិញនេះ គឺធ្វើផ្ទុយនឹងការសម្រេចបដិសេធរាប់សន្លឹឆ្នោតឡើងវិញ ដែលត្រូវបានប្តឹងជំទាស់ដោយគណបក្សប្រជាជនកម្ពុជា ដែលជំទាស់នឹងសេចក្តីសម្រេចរបស់ គធ.ខប ស្ថិតក្នុងឃុំគំរូ ខេត្តបន្ទាយមានជ័យ ចំណែកសេចក្តីសម្រេចរបស់ គធ.ខប ស្ថិតនៅសង្កាត់ស្វាយបាក់ រាជធានីភ្នំពេញ ត្រូវបានប្តឹងជំទាស់ដោយគណបក្សសង្គ្រោះជាតិ ហើយចំពោះនៅខេត្តសៀមរាប ស្ថិតនៅក្នុងឃុំកែវព័ណ៌ និងគ្រប់ឃុំ សង្កាត់ទាំងអស់ ដែលភាគរយនៃជ័យជំនះខុសគ្នាមិនដល់ ០.៥ភាគរយ ត្រូវបានគណបក្សសង្គ្រោះជាតិប្តឹងជំទាស់នឹងសេចក្តីរបស់ គធ.ខប ប៉ុន្តែក្នុងលក្ខខណ្ឌទី៣ ដែលទាមទារក្នុងដោះស្រាយមិនត្រូវបានយកមកប្រើឡើយ។ ទោះជាបែបនេះក្តីក៏វា (លក្ខខណ្ឌ) ត្រូវបានឃើញថា រឿងក្តីជាច្រើន ដូចជាបណ្តឹងដែលពាក់ព័ន្ធនឹងឃុំឃ្លាំង បង្ហាញអោយឃើញ

[168] The Svay Rieng's PEC decided to recount the ballots upon the complaint made by CPP while the decision of Daung Commune was in favor of CNRP. However, after the recounting made, the victory was still the CNRP's side.

[169] The party or representative of the party did not file the complaint during the stipulated time period which requires submission before 11:30 am on the day after Election Day. The representative only filed the complaint concerning irregularities at specific polling stations after the date preliminary results were announced for that commune.

ថា គ.ជ.ប បានបង្ហាញឆន្ទៈ និងលទ្ធភាព ដើម្បីកែតម្រូវកំហុសដែលដោះស្រាយដោយស្ថាប័នដោះស្រាយជំលោះពាក់ព័ន្ធនឹងការបោះឆ្នោត នៅពេលដែលបណ្តឹងបានកើតឡើងសមស្របទៅតាមអ្វីដែលមានចែងក្នុងបទបញ្ញត្តិ និងនីតិវិធី។

១១. ការផ្ទៀងផ្ទាត់ និងវិភាគលទ្ធផលបោះឆ្នោត

១១.១ ការផ្ទៀងផ្ទាត់ និងភាពត្រឹមត្រូវនៃលទ្ធផលបោះឆ្នោត

សមាគម អង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍ ស្តីពីការបោះឆ្នោតឆ្នាំ២០១៧ បានធ្វើការផ្ទៀងផ្ទាត់ទិន្នន័យ និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដែលផ្សាយក្នុងគេហទំព័ររបស់ គ.ជ.ប ក្រោយពេលបោះឆ្នោត ជាមួយនឹងកំណត់នៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដែលប្រមូលបានដោយបន្ទប់ស្ថានការណ៍។ កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដែលប្រមូលបានដោយបន្ទប់ស្ថានការណ៍ចំនួន ៤៨១ការិយាល័យ បោះឆ្នោតដែលជាការិយាល័យសំណាក ក្នុងកំរិតជឿជាក់៩៥% ជាមួយកំរិតលំអៀង ៤.៣% ត្រូវបានជ្រើសរើសដោយចៃដន្យ(Sample Random) និងយកមកផ្ទៀងផ្ទាត់។ ជាលទ្ធផលបានរកឃើញចំណុចមួយចំនួន ដូចខាងក្រោម៖

១. គ.ជ.ប បានចេញផ្សាយចំនួន០២លើក អំពីអត្រានៃចំនួនបណ្តោះអាសន្ននៃអ្នកបានទៅបោះឆ្នោតលើកទី១ នៅថ្ងៃទី០៤ ខែមិថុនា ២០១៧ គឺមានចំនួន ៨៥,៧៤% (ស្មើប្រមាណ៦,៧លាននាក់) និងលើកទី២ នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៧ គឺមានចំនួន៩០,៣៧% (ស្មើប្រមាណ៧លាននាក់)។ ការផ្ទៀងផ្ទាត់ទិន្នន័យដែលប្រមូលបានដោយបន្ទប់ស្ថានការណ៍រកឃើញថា អត្រានៃចំនួននៃអ្នកបោះឆ្នោតបានទៅបោះឆ្នោតមានចំនួន៨៩,៩% នៃប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតនៃការិយាល័យសំណាក។

២. ការសង្កេត និងការផ្ទៀងផ្ទាត់របស់បន្ទប់ស្ថានការណ៍ រកឃើញទំហំ «សន្លឹកឆ្នោតមិនបានការ» នៅក្នុងដំណើរការរាប់សន្លឹកឆ្នោតមានចំនួន១,៨% នៃសន្លឹកឆ្នោតដែលមានក្នុងហិបសរុប។ ការកំណត់សន្លឹកឆ្នោតមិនបានការ អាចក្លាយជាភាពមិនប្រក្រតី ដូចជាករណីខ្លះ ការកំណត់សន្លឹកឆ្នោតមិនបានការមានចំនួនច្រើនពេក ហើយមិនស្របតាមការណែនាំរបស់ គ.ជ.ប ដូចជានៅការិយាល័យ០០១៦ ឃុំសាមឃួយ ខេត្តស្ទឹងត្រែង ឃុំភ្នំលៀប ខេត្តបន្ទាយមានជ័យ ឃុំឫស្សីស្រុក ខេត្តសៀមរាប និងកន្លែងផ្សេងទៀត។ ករណីនេះអាចប៉ះពាល់លទ្ធផលបោះឆ្នោតបឋម ដែលនាំឱ្យមានបណ្តឹងនៃរាប់សន្លឹកឆ្នោតឡើងវិញចំនួន២៨ នៅ៨៧ការិយាល័យ តាមសេចក្តីប្រកាសព័ត៌មានរបស់គ.ជ.ប នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ ២០១៧។

៣. ការផ្ទៀងផ្ទាត់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត(ទ.១១០២)៖

៣.១. ការផ្ទៀងផ្ទាត់ទិន្នន័យនៃកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ប្រមូលដោយបន្ទប់ស្ថានការណ៍ ជាមួយនឹងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដែលបានផ្សាយក្នុងគេហទំព័ររបស់គ.ជ.ប មានភាពត្រឹមត្រូវដូចគ្នានឹងកំណត់ហេតុដែលប្រមូលដោយបន្ទប់ស្ថានការណ៍មានចំនួន៨៨.១% នៃទម្រង់ការិយាល័យសំណាក(ខុសគ្នា១១.៩%)។ ទោះជាយ៉ាងណា លទ្ធផលនៃការរាប់សន្លឹកឆ្នោតសម្រាប់គណបក្សនយោបាយនិមួយៗ តាមការិយាល័យរាប់សន្លឹកឆ្នោត ខុសគ្នាចំនួន៦.៩% (ចំនួន៩៣.១% ដូចគ្នា) ដែលទាក់ទិនការបំពេញសន្លឹកឆ្នោតបានការ ឬមិនបានការ ហើយខ្លះទៀតបូកលេខខុសតែម្តងដោយសារតែភាពធ្វេសប្រហែស។ រីឯលទ្ធផលនៃការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោត តាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត រកឃើញថា ៩៣.៦% ដូចគ្នា (៦.៤% រកឃើញថា មានតួលេខខុសគ្នា)។ ការខុសគ្នាអាចកើតឡើងដោយការធ្វេសប្រហែស ឬការមិនយល់ក្នុងការគណនា និងកត់ត្រា (វាអាចបណ្តាលមកពីមន្ត្រីចម្លងច្រើនសន្លឹក និងមិនប្រើក្រដាសកាល់)។ ចំណុចដែលជាកំណត់ត្រាសាក្សីដែលជាភ្នាក់ងារគណបក្សនយោបាយ រកឃើញថា ១.៧% ខុសគ្នាត្រង់សាក្សីនៃភ្នាក់ងារគណបក្សនយោបាយទម្រង់ខ្លះមិនចុះហត្ថលេខា។

៣.២. ការផ្ទៀងផ្ទាត់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដែលមានភាពមិនប្រក្រតី ប្រមូលដោយអ្នកសង្កេតការណ៍នៃបន្ទប់ស្ថានការណ៍ ជាមួយនឹងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដែលផ្សាយក្នុងគេហទំព័ររបស់ គ.ជ.ប រកឃើញថា ក្នុងចំណោម ៣០ទំរង់ (ទ.១១០២) មានតែមួយទំរង់ទេ ដែលមានភាពមិនប្រក្រតីដូចគ្នា ហើយ ២៩ទំរង់ទៀតរបស់ គ.ជ.ប គឺមានភាពត្រឹមត្រូវ។ ភាពមិនប្រក្រតីទាំងនោះមានដូចជា៖ ការបិទប្រកាសដោយមិនបានកត់ត្រាសំឡេងឆ្នោតរបស់គណបក្សនយោបាយនៅការិយាល័យ០១៥៥ ខេត្តរតនគិរី ការសរសេរឈ្មោះបេក្ខជនក្នុងសំឡេងគណបក្សនយោបាយ (ការិ.០៤៩៥ នៅខេត្តកំពង់ចាម) ការមិនបំពេញឈ្មោះគណបក្សនយោបាយ(ការិ.០០៦៣ ខេត្តកំពង់ឆ្នាំង) ការមិនបំពេញតួលេខឱ្យបានត្រឹមត្រូវក្នុងចំណុចសន្លឹកឆ្នោតបានការ និងមិនបានការ ចំនួនសន្លឹកឆ្នោតសរុបមិនស្មើគ្នា មានតួលេខលើសនិងខ្វះ ឬច្រឡំកន្លែងដែលត្រូវចុះរវាងសន្លឹកឆ្នោតខូច ជាមួយសន្លឹកឆ្នោតមិនបានការ កន្លែងខ្លះមានប្រើទឹកលុប ការគូសសញ្ញាបញ្ជាក់លើចំណុចផ្សេងៗជាដើម។

៤. ការផ្ទៀងផ្ទាត់លើលទ្ធផលបឋមនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទម្រង់ ទ.១១០៥)

លទ្ធផលបោះឆ្នោតបឋមនៅតាមឃុំសង្កាត់ ដែលបានមកពីការបូកសំឡេងឆ្នោតរបស់គណបក្សនៃកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដែលប្រមូលដោយបន្ទប់ស្ថានការណ៍ ហើយយកទៅផ្ទៀងផ្ទាត់ជាមួយកំណត់ហេតុ ទ.១១០៥ របស់គ.ជ.ប ចំនួន៣០ឃុំ រកឃើញថា មានមួយករណីនៅឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ក្នុងការិយាល័យ ០៣០៤ មានសន្លឹកឆ្នោតរបស់គណបក្សនយោបាយខុសគ្នារវាង គ.ជ.ប និងក្នុងកំណត់ហេតុលទ្ធផលឆ្នោត(ទ.១១០២) ដែលបានប្រមូលដោយបន្ទប់ស្ថានការណ៍នៃលទ្ធផលបឋមនៃការបោះឆ្នោតក្នុងឃុំ សង្កាត់។ បើទោះបីមានកំហុសខ្លះ នៃលទ្ធផលបឋមដែលកំពុងត្រួត

ពិនិត្យ គ.ជ.ប អាចមានលទ្ធភាពកែតម្រូវភ្លាមៗ។ ការសង្កេតរកឃើញថា លទ្ធផលបឋម(កំពុងត្រួតពិនិត្យ) យ៉ាងហោចខុសពីរឃុំ បើផ្ទៀងផ្ទាត់កំណត់ហេតុ ទ.១១០២ និង ទ.១១០៥។

លទ្ធផលនៃការបោះឆ្នោតបានបញ្ជាក់ពីភាពលើសលប់របស់គណបក្សប្រជាជនកម្ពុជា (គណបក្សកាន់អំណាច) ក្នុងការទទួលបានសម្លេងឆ្នោត។ គណបក្សកាន់អំណាចបានបង្កើតឡើងតាំងពីឆ្នាំ១៩៧៩ ហើយក៏ជាគណបក្សតែមួយដែលធ្វើឱ្យគណបក្សដទៃទៀត មានការលំបាកក្នុងការប្រកួតប្រជែងសន្លឹកឆ្នោត។ គណបក្សប្រជាជនកម្ពុជាទទួលបានអាសនៈនៅក្នុងការបោះឆ្នោតគ្រប់ឃុំ សង្កាត់ ដែលក្នុងនោះមានអាសនៈមេឃុំចំនួន១,១៥៦ ក្នុងចំណោមនោះ មានអាសនៈមេឃុំចំនួន១៤ជាឃុំ សង្កាត់ទើបជាប់ថ្មី ដែលពីមុនគាត់មិនបានគ្រប់គ្រង។ ក្នុងឆ្នាំ២០១៧ ចំនួនឃុំ សង្កាត់ទូទាំងប្រទេសបានកើនឡើងពី១,៦៣៣ ដល់ ១,៦៤៦។ យោងតាមលទ្ធផលនៃអាសនៈរបស់គណបក្សនយោបាយ ឃុំ សង្កាត់ ចំនួន៣៧ ដែលត្រូវបានគណបក្សប្រជាជនកម្ពុជា ទទួលបានការគ្រប់គ្រងអាសនៈជាក្រុមប្រឹក្សាតែឯកបក្ស (ក្រុមប្រឹក្សាទាំងអស់មានតែគណបក្សប្រជាជនកម្ពុជាតែមួយ) ទោះបីឃុំសង្កាត់នោះ មានគណបក្សចំរុះបានចូលរួមធ្វើការប្រកួតប្រជែងក៏ដោយ (យ៉ាងតិចបំផុត២គណបក្សនយោបាយ)។ ឃុំសង្កាត់ចំនួន៤៩០ ក្នុងចំណោមមេឃុំ១,៦៤៦ គឺជាមេឃុំ ចៅសង្កាត់មកពីគណបក្សផ្សេងៗ ក្រៅពីគណបក្សប្រជាជនកម្ពុជា។ ក្នុងចំណោមមេឃុំ ចៅសង្កាត់ក្រៅពីគណបក្សប្រជាជន គណបក្សសង្គ្រោះជាតិទទួលបានអាសនៈមេឃុំចំនួន៤៨៩ និងគណបក្សខ្មែររួបរួមជាតិទទួលបានអាសនៈចំនួន១ មេឃុំ។ គណបក្សសង្គ្រោះជាតិ ទោះបីមានកើនចំនួនមេឃុំចៅសង្កាត់ក៏ដោយ ក៏ប៉ុន្តែមានឃុំសង្កាត់ខ្លះបានបាត់បង់អាសនៈជាមេឃុំផងដែរ។ ចំណែកគណបក្ស៨ផ្សេងទៀត មិនបានទទួលអាសនៈជាមេឃុំ/ចៅសង្កាត់ទេ តែបានទទួលអាសនៈជាក្រុមប្រឹក្សាឃុំសង្កាត់ ដូចជាគណបក្សហ៊្វុនស៊ិនប៉ិច គណបក្សប្រជាធិបតេយ្យមូលដ្ឋាន គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ និងគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ។ រីឯគណបក្សនយោបាយផ្សេងទៀត មិនបានទទួលសម្លេងគ្រប់គ្រាន់ដើម្បីទទួលបានអាសនៈនៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ ឬដើម្បីជ្រើសរើសជាមេឃុំ ចៅសង្កាត់នោះទេ។

គិតជាភាគរយនៃសន្លឹកឆ្នោតសរុប គណបក្សប្រជាជនកម្ពុជាទទួលបានសម្លេងសរុបចំនួន៥០.៧៦ភាគរយនៃសន្លឹកឆ្នោតសរុប និងទទួលបានអាសនៈសរុបចំនួន៦,៥០៣អាសនៈ ដែលចំណាត់ថ្នាក់បន្ទាប់គឺគណបក្សសង្គ្រោះជាតិទទួលបានសំឡេងចំនួន៤៣.៨៣ភាគរយនៃសន្លឹកឆ្នោតសរុប និងទទួលបានអាសនៈចំនួន ៥,០០៧អាសនៈ។ គណបក្សហ៊្វុនស៊ិនប៉ិចបានទទួលបាន១.៩ភាគរយនៃសន្លឹកឆ្នោតសរុប និងទទួលបានអាសនៈចំនួន២៨អាសនៈ។ គណបក្សខ្មែររួបរួមជាតិទទួលបាន១.១៣ភាគរយ និងទទួលបានអាសនៈចំនួន ២៤។ គណបក្សប្រជាធិបតេយ្យមូលដ្ឋានទទួលបានសម្លេងចំនួន០.០៧ភាគរយ និងអាសនៈចំនួន ៥អាសនៈ។ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យទទួលបានសម្លេងចំនួន១.៧៦ភាគរយ និងទទួលបានអាសនៈចំនួន៤អាសនៈ និងគណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យទទួលបានសម្លេងចំនួន០.៤៥ភាគរយ និងអាសនៈចំនួន១អាសនៈ។ គណបក្សនយោបាយប្រជែងផ្សេងទៀតទទួលបានសម្លេងតិចជាង១ភាគរយ និងមិនទទួលបានអាសនៈជាប់ជាសមាជិកក្រុមប្រឹក្សាឃុំនៅក្នុងការបោះឆ្នោតនេះទេ (សូមមើលឧបសម្ព័ន្ធទី២: ការបែងចែកអាសនៈ)។ រូបភាពទី១៨ ខាងក្រោមបង្ហាញអំពីភាគរយនៃអាសនៈឃុំសង្កាត់ដែលគណបក្ស

នយោបាយនីមួយៗទទួលបាន និងរូបភាពទី១៩ ភាគរយនៃការបោះឆ្នោតដែលគណបក្សនយោបាយនីមួយៗទទួលបានសំឡេង។

រូបភាពទី១៨ ភាគរយនៃការគណនាអាសនៈសម្រាប់ក្នុងការបោះឆ្នោតឃុំ សង្កាត់២០១៧



រូបភាពទី១៩ ភាគរយអ្នកបោះឆ្នោតតាមគណបក្សក្នុងការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០១៧



គណបក្សប្រជាជនកម្ពុជា បានឈ្នះអាសនៈក្រុមប្រឹក្សាឃុំភាគច្រើននៅក្នុងខេត្តចំនួន២១។ ខេត្តដែលគណបក្សប្រជាជនកម្ពុជាទទួលបានអាសនៈឈ្នះភាគច្រើន និងមានការប្រកួតប្រជែងតិចតួចពីគណបក្សផ្សេងៗ ដែលទទួលបានអាសនៈក្នុងក្រុមប្រឹក្សា(ចំនួនតិចជាង៣០%នៃអាសនៈសរុបក្នុងខេត្ត) មានខេត្តកែប ខេត្តពោធិ៍សាត់ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី។ ខេត្តចំនួន៩ ដែលគណបក្សប្រជាជន

កម្ពុជាទទួលបានអាសនៈឈ្នះទាំងប្រធិតប្រជើយ(ចន្លោះពី៥០% ទៅ៦០%) នៃចំនួនអាសនៈរបស់ក្រុមប្រឹក្សាឃុំសង្កាត់សរុបទូទាំងខេត្តមាន ខេត្តបន្ទាយមានជ័យ(៥៥.៥%) បាត់ដំបង(៥០.៥%) កំពង់ឆ្នាំង(៥៩.៧%) កំពត(៥៦.៥%) កណ្តាល(៥២.៩%) ព្រៃវែង(៥៤.៦%) តាកែវ(៥៦.៧%) ប៉ៃលិន(៥៧.៧%) និងត្បូងឃ្មុំ(៥៧.៦%)។ សម្រាប់ខេត្តផ្សេងទៀត គណបក្សប្រជាជនកម្ពុជាទទួលបានអាសនៈក្រុមប្រឹក្សាចន្លោះពី៦០% ទៅ៧០%នៃអាសនៈសរុបក្រុមងខេត្តនិមួយៗ មានខេត្តកំពង់ស្ពឺ(៦០.៣%) ខេត្តកោះកុង(៦៧.១%) ខេត្តក្រចេះ(៦០.៣%) ខេត្តព្រះវិហារ(៦០.០%) ខេត្តព្រះសីហនុ(៦៤.៤%) ខេត្តស្វាយរៀង(៦៤.១%) និងខេត្តឧត្តរមានជ័យ(៦៧.១%)។ ទោះបីយ៉ាងណាមានរាជធានីខេត្តចំនួន៤ដូចជា ខេត្តកំពង់ចាមខេត្តកំពង់ធំ ខេត្តសៀមរាប និងរាជធានីភ្នំពេញដែលគណបក្សសង្គ្រោះជាតិ ទទួលបានអាសនៈលើសពី ៥០%នៃអាសនៈសរុបក្នុងខេត្ត នោះមានន័យថា គណបក្សប្រជាជនកម្ពុជាទទួលបានអាសនៈក្រោម៥០% ដូចជាខេត្តកំពង់ចាម(៤៦.៥%) ខេត្តកំពង់ធំ(៤៧.៣%) ខេត្តសៀមរាប(៤៧.៦%) និងរាជធានីភ្នំពេញ(៤៧.៩%) (សូមមើលតារាងទី៥ ក្នុងឧបសម្ព័ន្ធ២)។

១១.២ វិភាគលទ្ធផលបោះឆ្នោតឃុំសង្កាត់

លទ្ធផលបានបង្ហាញថា មានតែគណបក្សប្រជាជន និងគណបក្សប្រឆាំងតែប៉ុណ្ណោះដែលនៅតែមានភាពរឹងមាំ ក្នុងការទទួលបានការគាំទ្រពីម្ចាស់ឆ្នោត បើប្រៀបធៀបទៅនឹងការបោះឆ្នោតឃុំ សង្កាត់ នៅក្នុងឆ្នាំ២០១២ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣។ គណបក្សប្រជាជនកម្ពុជាទទួលបានសំឡេងឆ្នោតគាំទ្រចំនួន៣,៥៤០,០៥៦សម្លេងនៅក្នុងឆ្នាំ២០១៧ លទ្ធផលនេះបានធ្លាក់ចុះចំនួន ៩១,០២៦សំឡេងបើធៀបជាមួយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១២ នៅពេលគណបក្សប្រជាជនកម្ពុជាទទួលបានសម្លេងឆ្នោតចំនួន៣,៦៣១,០៨២សំឡេង ហើយបានកើនសំឡេងចំនួន ៣០៤,០៨៧សំឡេងធៀបជាមួយលទ្ធផលក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣ ដែលនៅពេលនោះគណបក្សប្រជាជនកម្ពុជាទទួលបានសំឡេងចំនួនតែ៣,២៣៥,៩៦៩សំឡេង។

ដូចគ្នានេះដែរ គណបក្សសង្គ្រោះជាតិដែលជាដៃគូប្រកួតប្រជែងយ៉ាងធំបំផុតមួយនៅក្នុងប្រទេសកម្ពុជា នៅតែបន្តទទួលបានសម្លេងគាំទ្រ ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១៧នេះផងដែរ បើប្រៀបធៀបទៅនឹងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១២ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣។ គណបក្សសង្គ្រោះជាតិទទួលបានសំឡេងឆ្នោតចំនួន៣,០៥៦,៨២៤សំឡេងក្នុងការបោះឆ្នោតឆ្នាំ២០១៧ ដែលកើនឡើងចំនួន១,២៥១,៨៨១សំឡេង បើធៀបជាមួយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១២ នៅពេលដែលគណបក្សង្គ្រោះជាតិទទួលបានតែសំឡេងចំនួន១,៨០៤,៩៤៣សំឡេង(ការបូកបញ្ចូលគ្នារវាងគណបក្សសិទ្ធិមនុស្សចំនួន ៥៨០៤៨៣សំឡេង និងគណបក្ស សម រង្ស៊ី ចំនួន១,២២៤,៤៤៦០សំឡេង)។

គណបក្សសង្គ្រោះជាតិបានកើនឡើងចំនួន១១០,៦៤៨សំឡេង ធៀបជាមួយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣ នៅពេលដែលគណបក្សសង្គ្រោះជាតិ ទទួលបានសម្លេងឆ្នោតចំនួនតែ

២,៩៤៦,១៧៦សំឡេង។ ក្រៅពីគណបក្សដែលទទួលបានសំឡេងភាគច្រើនបំផុត ក៏មានគណបក្សហ៊ុនស៊ិនប៊ិច នៅតែបន្តមានសំឡេងគាំទ្រក្នុងការបោះឆ្នោតឆ្នាំ២០១៧ ទោះបីមិនបានសំឡេងច្រើនក៏ដោយ។ គណបក្សហ៊ុនស៊ិនប៊ិច ទទួលបានសំឡេង១៣២,៣១៩សំឡេង ធ្លាក់ចុះចំនួន៩០,៣៥២សំឡេង ធៀបជាមួយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១២ ដែលនៅពេលនោះគណបក្សហ៊ុនស៊ិនប៊ិចទទួលបានចំនួន ២២២,៦៧១សំឡេង និងបន្តធ្លាក់ចុះការគាំទ្រចំនួន ១១០,០៩៤សំឡេង បើប្រៀបធៀបជាមួយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣ ដែលនៅពេលនោះទទួលបានចំនួន២៤២,៤១៣សំឡេង។

មានគណបក្សចំនួន៣ ដែលទើបតែបង្កើតឡើងនិងបានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧ ទោះបីមិនបានសំឡេង និងអាសនៈច្រើនតែគណបក្សទាំងនោះបានទទួលសំឡេង និងអាសនៈក្នុងក្រុមប្រឹក្សាផងដែររួមមាន គណបក្សខ្មែររួបរួមជាតិ គណបក្សប្រជាធិបតេយ្យមូលដ្ឋាន និងគណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ។ ផ្ទុយទៅវិញគណបក្សនយោបាយផ្សេងទៀត មានការចូលរួមប្រកួតប្រជែង ក៏ប៉ុន្តែមិនបានទទួលសំឡេងគ្រប់ចំនួនក្នុងការទទួលបានអាសនៈក្រុមប្រឹក្សាឃុំសង្កាត់នោះទេ។

រូបភាពទី២០ ភាគរយនៃអ្នកបោះឆ្នោតជាមួយគណបក្សនយោបាយចាប់ពីឆ្នាំ១៩៩៣ ដល់ ២០១៧



ដូចគ្នាដែរ គណបក្សនយោបាយទាំងអស់ លើកលែងតែគណបក្សសង្គ្រោះជាតិ និងគណបក្សទើបតែបង្កើតថ្មី បានបាត់បង់កៅអីក្រុមប្រឹក្សាឃុំសង្កាត់ និងអាសនៈជាមេឃុំចៅសង្កាត់។ គណបក្សប្រជាជនបានបាត់បង់អាសនៈជាមេឃុំ ចៅសង្កាត់ចំនួន៤៣៦មេឃុំ ចៅសង្កាត់ ធៀបជាមួយអាណត្តិឆ្នាំ២០១២។ ការបាត់អាសនៈមេឃុំ ចៅសង្កាត់ភាគច្រើនបានទៅលើគណបក្សសង្គ្រោះជាតិ ក្នុងនោះមានចំនួន១០ឃុំសង្កាត់នៅក្នុងខេត្តបន្ទាយមានជ័យ ចំនួន៤៩ឃុំសង្កាត់នៅក្នុងខេត្តបាត់ដំបង ចំនួន៨០ ឃុំសង្កាត់នៅក្នុងខេត្តកំពង់

ចាម និងត្បូងឃ្មុំ ចំនួន៦ ឃុំសង្កាត់ នៅក្នុងខេត្តកំពង់ឆ្នាំង ចំនួន៨ ឃុំសង្កាត់នៅក្នុងខេត្តកំពង់ស្ពឺ ចំនួន៣៩ ឃុំសង្កាត់ នៅក្នុងខេត្តកំពង់ធំ ចំនួន២១ឃុំសង្កាត់ នៅក្នុងខេត្តកំពត ចំនួន៤៨ឃុំសង្កាត់ នៅក្នុងខេត្តកណ្តាល ចំនួន៣ឃុំសង្កាត់ នៅក្នុងខេត្តកោះកុង ចំនួន៨ឃុំសង្កាត់ នៅក្នុងខេត្តក្រចេះ ចំនួន៤៨សង្កាត់ នៅក្នុងរាជធានីភ្នំពេញ ចំនួន២ឃុំសង្កាត់ នៅក្នុងខេត្តព្រះវិហារ ចំនួន៣១ឃុំសង្កាត់ នៅក្នុងខេត្តព្រៃវែង ចំនួន១ឃុំសង្កាត់ នៅក្នុងខេត្តរតនគិរី ចំនួន៥៤ឃុំសង្កាត់ នៅក្នុងខេត្តសៀមរាប ចំនួន១ឃុំសង្កាត់ នៅក្នុងខេត្តព្រះសីហនុ ចំនួន៧ឃុំសង្កាត់ នៅខេត្តស្វាយរៀង ចំនួន១៨ឃុំសង្កាត់ នៅក្នុងខេត្តតាកែវ ចំនួន១ឃុំសង្កាត់ នៅក្នុងខេត្តប៉ៃលិន និងមួយឃុំសង្កាត់ នៅក្នុងខេត្តឧត្តរមានជ័យ។

រូបភាពទី២១ មេឃុំ ចៅសង្កាត់ដែលគណបក្សនិមួយៗទទួលបាន



លើសពីនេះ គណបក្សប្រជាជនបានបាត់បង់អាសនៈក្រុមប្រឹក្សាឃុំសង្កាត់ ចំនួន១,៧៨៩អាសនៈ បើធៀបអាសនៈទទួលបានរវាងការបោះឆ្នោតក្នុងឆ្នាំ២០១២ និងការបោះឆ្នោតឆ្នាំ២០១៧។ គណបក្សប្រជាជនកម្ពុជាទទួលបានអាសនៈក្រុមប្រឹក្សាឃុំសង្កាត់ចំនួន៨,២៩២អាសនៈក្នុងឆ្នាំ២០១២ និងទទួលបានអាសនៈចំនួន៦,៥០៣អាសនៈក្នុងការបោះឆ្នោតឆ្នាំ២០១៧តែប៉ុណ្ណោះ។. គួរបញ្ជាក់ថា គណបក្សប្រជាជនកម្ពុជាមិនអាចឈ្នះមេឃុំ ចៅសង្កាត់ភាគច្រើននៅក្នុងរាជធានីភ្នំពេញ ខេត្តកំពង់ចាម ខេត្តកំពង់ធំ និងខេត្តសៀមរាបក្នុងការបោះឆ្នោតឆ្នាំ២០១៧នេះទេ ហើយខេត្តទាំងនេះធ្លាប់ទទួលបានជោគជ័យក្នុងការបោះឆ្នោតឆ្នាំ២០១២កន្លងមក។ លទ្ធផលនៃការបោះឆ្នោតបានបង្ហាញថា គណបក្សប្រជាជនកម្ពុជាដែលជាគណបក្សគ្រប់គ្រងអំណាចបានបាត់បង់អាសនៈ និងសម្លេងភាគច្រើន បើធៀបជាមួយការបោះឆ្នោតឆ្នាំ២០១២។ ការ

បាត់បង់អាសនៈរបស់គណបក្សប្រជាជននេះ ត្រូវបានពន្យល់ផងដែរថា គណបក្សប្រជាជន ដែលជាគណបក្សកាន់អំណាច បានធ្វើឱ្យប្រជាពលរដ្ឋអស់ជំនឿក្នុងការដោះស្រាយបញ្ហាមួយចំនួនដែលបានកើតមាន ដូចជាករណីឃាតកម្ម បញ្ហាដីធ្លី និងបញ្ហាចាប់ខ្លួនអ្នកការពារសិទ្ធិមនុស្ស...។ គណបក្សប្រជាជនកម្ពុជាក៏បានប្រើប្រាស់ធនធានទាំងអស់របស់ខ្លួនរួមទាំងធនធានរបស់រដ្ឋ និងការគ្រប់គ្រងអំណាចក្នុងមូលដ្ឋានឃុំសង្កាត់ដើម្បីបង្កការលំបាកដល់គណបក្សផ្សេងទៀត។ ជាមួយគ្នានេះដែរ គណបក្សប្រជាជនដែលមានអាសនៈភាគច្រើនក្នុងរដ្ឋសភាបានធ្វើការកែប្រែច្បាប់ទាក់ទងគណបក្សនយោបាយ ច្បាប់ទាក់ទងអង្គការ សមាគមផងដែរ ដែលជាផ្នែកមួយរឹតត្បិតសិទ្ធិនយោបាយ និងសិទ្ធិចូលរួមនាំឱ្យមិនសប្បាយចិត្តដល់ប្រជាពលរដ្ឋ។

តារាងទី១៥ ប្រៀបធៀបអាសនៈគណបក្សនយោបាយរវាងឆ្នាំឆ្នាំ២០១២ និងឆ្នាំ២០១៧

ល.រ	ខេត្ត/រាជធានី	ប្រជាជនកម្ពុជា		សង្គ្រោះជាតិ		ហ៊ុនសុិនប៊ិច		សម្ព័ន្ធ.ធិបតេយ្យ	
		2012	2017	2012	2017	2012	2017	2012	2017
១	បន្ទាយមានជ័យ	405	286	72	211	35	0	0	0
២	បាត់ដំបង	641	411	160	399	10	3	0	0
៣	កំពង់ចាម	812	380	294	435	4	0	0	0
៤	កំពង់ឆ្នាំង	300	252	87	170	4	0	0	0
៥	កំពង់ស្ពឺ	410	367	100	242	0	0	0	0
៦	កំពង់ធំ	363	273	158	285	36	15	0	2
៧	កំពត	428	317	101	240	3	3	0	1
៨	កណ្តាល	651	484	165	431	0	0	0	0
៩	កោះកុង	145	112	22	55	0	0	0	0
១០	ក្រចេះ	203	178	70	116	3	1	0	0
១១	មណ្ឌលគីរី	94	86	12	21	1	0	0	0
១២	ភ្នំពេញ	570	431	234	468	0	0	0	0
១៣	ព្រះវិហារ	243	203	83	129	5	0	0	0
១៤	ព្រៃវែង	532	487	151	405	0	0	0	0

១៥	ពោធិ៍សាត់	315	251	25	92	0	0	0	0
១៦	រតនគីរី	223	207	30	51	7	0	0	2
១៧	សៀមរាប	490	318	147	347	19	0	7	0
១៨	ព្រះសីហនុ	142	114	25	63	1	0	0	0
១៩	ស្ទឹងត្រែង	149	132	19	39	7	5	0	0
២០	ស្វាយរៀង	425	332	63	186	3	0	0	0
២១	តាកែវ	555	417	108	318	4	1	0	0
២២	កែប	31	24	0	7	0	0	0	0
២៣	ប៉ៃលិន	41	30	11	22	0	0	0	0
២៤	ឧត្តរមានជ័យ	124	102	18	49	9	0	1	0
២៥	ត្បូងឃ្មុំ	0	309	0	226	0	0	0	0
សរុប		**8292**	**6503**	**2155**	**5007**	**151**	**28**	**8**	**5**
សំគាល់		**ថយចុះ**	**1789**	**កើន**	**2852**	**ថយចុះ**	**123**	**ថយចុះ**	**3**

ក្រៅពីគណបក្សប្រជាជនដែលបានបាត់បង់អាសនៈ និងសំឡេង គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យក៏បានបាត់បង់សំឡេង និងអាសនៈផងដែរ បើធៀបជាមួយអាសនៈដែលទទួលបានក្នុងឆ្នាំ២០១២។ នៅពេលនោះ គណបក្សហ៊្វុនស៊ិនប៉ិចទទួលបាន១៥១អាសនៈបាត់បង់អស់ចំនួន ១២៣អាសនៈ ដែលធៀបជាមួយការបោះឆ្នោតឆ្នាំ២០១៧ ដែលទទួលបានចំនួន២៨អាសនៈ។ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ បានបាត់បង់ចំនួន៣អាសនៈ បើធៀបជាមួយការបោះឆ្នោតឆ្នាំ២០១២ ខណៈពេលនោះគណបក្សនេះទទួលបានចំនួន៨អាសនៈ និងទទួលបានតែចំនួន៥អាសនៈប៉ុណ្ណោះសម្រាប់ការបោះឆ្នោតឆ្នាំ២០១៧។ ការបាត់បង់សំឡេង និងអាសនៈរបស់គណបក្សហ៊្វុនស៊ិនប៉ិច គេសង្កេតឃើញថាអាចបណ្តាលមកពីគណបក្សនេះមានជម្លោះផ្ទៃក្នុងដែលពីមុនឆ្នាំ២០១២ បានដឹកនាំដោយព្រះអង្គម្ចាស់នរោត្តមរណឫទ្ធិ ហើយព្រះអង្គបានចេញទៅបង្កើតគណបក្សថ្មី ក្រោយមកការបោះឆ្នោតឆ្នាំ២០១៧ នេះព្រះអង្គយាងមកគ្រប់គ្រងគណបក្សនេះវិញ ដែលជម្លោះនេះបានហែកហួរ និងធ្លាក់ប្រជាប្រិយភាពរបស់ខ្លួន។

ទោះបីយ៉ាងណា គណបក្សសង្គ្រោះជាតិជាគណបក្សដែលបានរួបរួមគ្នារវាងគណបក្សសិទ្ធិមនុស្ស និងគណបក្សសមរង្ស៊ី កាលពីឆ្នាំ២០១៣ ហើយជាគណបក្សប្រឆាំងយ៉ាងធំជាងគេនៅក្នុងប្រទេសកម្ពុជា គណបក្សនេះបានឈ្នះសម្លេងឆ្នោត និងអាសនៈក្រុមប្រឹក្សាឃុំសង្កាត់រួមទាំងមេឃុំ ចៅសង្កាត់ភាគច្រើនផង

ដែរ។ គណបក្សសង្គ្រោះជាតិបានឈ្នះអាសនៈលើគណបក្សកាន់អំណាចចំនួន៤រាជធានីខេត្ត មានរាជធានីភ្នំពេញ ខេត្តកំពង់ចាម ខេត្តកំពង់ធំ និងខេត្តសៀមរាប ខេត្តទាំងនេះត្រូវបានគ្រប់គ្រងអាសនៈច្រើនលើសលុបដោយគណបក្សប្រជាជនក្នុងការបោះឆ្នោតឆ្នាំ២០១២។ ក្រៅពីនោះ ខេត្តផ្សេងៗ ហោចណាស់គណបក្សនេះបានកើនអាសនៈជាមធ្យមចំនួន ៥០ភាគរយនៃអាសនៈទាំងអស់ក្នុងខេត្តផងដែរ។

ទោះបីយ៉ាងណាក៏ដោយ ខុមហ្វ្រែលសង្កេតឃើញថា គណបក្សប្រជាជនកម្ពុជាបានឈ្នះការប្រកួតប្រជែងដោយគ្រប់គ្រងសមាជិកក្រុមប្រឹក្សាទាំងអស់នៅក្នុងឃុំចំនួន៣៧ឃុំ ក្នុងខេត្តចំនួន៧ ដោយមិនមានគណបក្សណាមួយផ្សេងទៀតអាចដណ្តើមបាន ទោះបីឃុំទាំងនោះមានបេក្ខជនរបស់គណបក្សនយោបាយយ៉ាងហោចពីរគណបក្សបានចូលរួមប្រកួតប្រជែងហើយក៏ដោយ។ ខេត្តទាំងនោះរួមមានខេត្តកោះកុង ខេត្តក្រចេះ ខេត្តមណ្ឌលគិរី ខេត្តព្រះវិហារ ខេត្តពោធិ៍សាត់ ខេត្តរតនគិរី ខេត្តស្ទឹងត្រែង និងខេត្តស្វាយរៀង។ គណបក្សប្រជាជនកម្ពុជាដែលធ្លាប់តែឈ្នះការប្រកួតប្រជែងក្នុងការគ្រប់គ្រងអាសនៈ ទាំងអស់ដោយឯកបក្សនៃក្រុមប្រឹក្សាឃុំសង្កាត់ បានធ្លាក់ចំនួនឃុំសង្កាត់ឯកបក្សក្នុងការបោះឆ្នោតក្នុងឆ្នាំ២០១៧នេះ ក្នុងនោះឆ្នាំ២០០២ មានចំនួន១៤៨ឃុំសង្កាត់ ក្នុងឆ្នាំ២០០៧ មានចំនួន១៦៦ឃុំសង្កាត់ និងឆ្នាំ២០១២ កើនដល់ចំនួន២៣៣ឃុំសង្កាត់ ដូចដែលបានបង្ហាញក្នុងរូបភាពទី? ខាងក្រោម:

រូបភាពទី២២ ឃុំ សង្កាត់ដែលមានសមាសភាពក្រុមប្រឹក្សាមកពីគណបក្សប្រជាជនតែមួយ



រូបភាពទី២៣ អាណត្តិនៃការទទួលបានការគ្រប់គ្រងក្រុមប្រឹក្សាឃុំសង្កាត់មានតែមួយគណបក្ស



រូបភាពទី២៤ ផែនទីបង្ហាញពីឃុំសង្កាត់ដែលក្រុមប្រឹក្សាតែមួយមកពីគណបក្សប្រជាជនកម្ពុជា



ការសិក្សាលើប្រព័ន្ធបោះឆ្នោតសម្រាប់ជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ក្នុងពេលបច្ចុប្បន្ន វាជាការព្រួយបារម្ភមួយដែលប្រឈមនឹងការជ្រើសរើសរបស់អ្នកបោះឆ្នោត ដើម្បីឱ្យការរៀបចំការបោះឆ្នោតតាមបែបលទ្ធិប្រជាធិបតេយ្យបានប្រសើរ។ ការព្រួយបារម្ភមួយទៀត សម្រាប់ខុមហ្វ្រែល គឺថារូបមន្តក្នុងការគណនាដើម្បីផ្ទេរសម្លេងឆ្នោតទៅជាអាសនៈ ជាមួយរូបមន្តដែលគេហៅថា«មធ្យមភាគខ្ពស់បំផុត(Highest Average Formula)»ត្រូវបានគេចាត់ទុកថា ជារូបមន្តដែលទទួលបានអាសនៈតិចតួចបំផុតសម្រាប់គណបក្សនយោបាយដែលបានសម្លេងតិច តែផ្ទុយទៅវិញវាបានផ្តល់ផលចំណេញកាន់តែច្រើនចំពោះគណបក្សដែលមានសំឡេងកាន់តែច្រើន ខុសពីរូបមន្តដទៃទៀត ដូចជា«រូបមន្តសំណល់ខ្ពស់បំផុត(Greatest Reminder Formula)»ដែលត្រូវបានប្រើនៅក្នុងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រលើកដំបូងក្នុងឆ្នាំ ១៩៩៣ បន្ទាប់មក ត្រូវបានផ្លាស់ប្តូរមកជាប្រព័ន្ធបោះឆ្នោត ដូចពេលបច្ចុប្បន្ន នៅក្នុងឆ្នាំ១៩៩៧។ រូបមន្តសមាមាត្រដែលបានប្រើប្រាស់ក្នុងពេលបច្ចុប្បន្នគឺមិនត្រូវបានឆ្លុះបញ្ចាំងពីចំនួនមេឃុំ និងអាសនៈក្រុមប្រឹក្សាឃុំសង្កាត់ដែលទទួលបានដោយគណបក្សនយោបាយនិមួយៗនោះទេ។ គណបក្សប្រជាជនកម្ពុជាទទួលបានសំឡេងឈ្នះ ៥០.៧៦ភាគរយនៃសន្លឹកឆ្នោតសរុប បើគិតជាសមាមាត្រស្មើគ្នាដាច់ខាត(equalizes in absolute proportionality to)នោះត្រូវទទួលបានអាសនៈក្រុមប្រឹក្សាឃុំសង្កាត់សរុបតែចំនួន៥,៨៧៤អាសនៈ(៥០.៧៦% x ១១,៥៧២អាសនៈ) និងអាសនៈមេឃុំតែចំនួន ៨៣៦នៃ១,៦៤៦ឃុំសង្កាត់។ ផ្ទុយទៅវិញការប្រើប្រាស់រូបមន្តបច្ចុប្បន្នធ្វើឱ្យគណបក្សប្រជាជនឈ្នះអាសនៈក្រុមប្រឹក្សាឃុំសង្កាត់ ចំនួន៦៥០៣អាសនៈ និងអាសនៈជាមេឃុំ ចៅសង្កាត់ចំនួន១,១៥៦នៃ១៦៤៦អាសនៈមេឃុំសង្កាត់ចៅសង្កាត់។ គណបក្សសង្គ្រោះជាតិទទួលបានសម្លេងចំនួន៤៣.៨៣ភាគរយនៃសន្លឹកឆ្នោតសរុបដែលស្មើនឹងសមាមាត្រស្មើគ្នាដាច់ខាតទៅនឹងអាសនៈក្រុមប្រឹក្សាឃុំសង្កាត់ចំនួន៥,០៧២អាសនៈ និងអាសនៈជាមេឃុំចំនួន៧២២មេឃុំ ចៅសង្កាត់។

ទោះបីជារូបមន្តមិនសមាមាត្រត្រូវបានពន្យល់យ៉ាងណាក៏ដោយ (តើមានចំនួនអាសនៈប៉ុន្មានដែលធ្វើការប្រកួតប្រជែងក្នុងឃុំសង្កាត់ ហើយមានចំនួនធំប៉ុន្មានដែលមានតម្លៃធំជាងសមាមាត្រ) ហេតុផល និងបច្ចេកទេសដែលបានបកស្រាយពីតម្លៃលទ្ធផល ដែលទទួលបានសម្រាប់គ្រប់គណបក្សនយោបាយទាំងតូចនិងធំ ដូចបានរៀបរាប់ខាងលើយ៉ាងណាក៏ដោយ សមាមាត្រដាច់ខាត គឺមិនអាចកើតមានឡើងឡើយ ព្រោះថាលទ្ធផលនៃការបោះឆ្នោតនាពេលបច្ចុប្បន្ននៅតែបង្ហាញថា រូបមន្តនេះបានផ្តល់ការពេញចិត្តដល់គណបក្សប្រជាជន និងបង្កើតការមិនពេញចិត្តចំពោះភាគីប្រកួតប្រជែងប្រជែងផ្សេងទៀត។

តារាងទី១៦ ខាងក្រោមបង្ហាញពីភាពមិនស្មើគ្នានៃគណបក្សប្រជាជនដែលទទួលបានអាសនៈលើសពី ៥.៤៤ភាគរយ ច្រើនជាងអាសនៈដែលបានទទួលនៅក្នុងការបោះឆ្នោតឃុំ សង្កាត់ ខណៈដែលគណបក្សនយោបាយដទៃទៀតបានបាត់បង់អាសនៈ បើទោះបីជាសម្លេងដែលទទួលបានមានភាគរយខ្ពស់ក៏ដោយ។

តារាងទី១៦ សរុបចំនួនអ្នកបោះឆ្នោត និងភាគរយអាសនៈក្រុមប្រឹក្សាឃុំសង្កាត់ក្នុងឆ្នាំ២០១៧

ឈ្មោះគណបក្សនយោបាយ	សរុបសម្លេងឆ្នោត	ក្រុមប្រឹក្សាឃុំសង្កាត់	មេឃុំចៅសង្កាត់
ប្រជាជនកម្ពុជា	3,540,056 (50.76%)	6,503 (56.20%) ភាពមិនសមាមាត្រ: + 5.44%	1,156 (70.23%)
សង្គ្រោះជាតិ	3,056,824 (43.83%)	5,007 (43.27%) ភាពមិនសមាមាត្រ: - 0.56%	489 (29.71%)
ហ៊្វុនស៊ិនប៉ិច	132,319 (1.90%)	28 (0.24%) ភាពមិនសមាមាត្រ: - 1.66%	0 (1%)
ខ្មែររួបរួមជាតិ	78,724 (1.13%)	24 (0.21%) ភាពមិនសមាមាត្រ: -0.92%	1 (0.06%)
ប្រជាធិបតេយ្យមូលដ្ឋាន	4,981 (0.07%)	5 (0.04%) ភាពមិនសមាមាត្រ: -0.03%	0 (0%)
សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ	122,882 (1.76%)	4 (0.03%) ភាពមិនសមាមាត្រ: -1.73%	0 (0%)
សំបុកឃ្មុំសង្គមប្រជាធិបតេយ្យ	31,334 (0.45%)	1 (0.01%) ភាពមិនសមាមាត្រ: -0.44%	0 (0%)
ប្រភព: គណនាដោយខុមហ្វ្រែល			

១២. ការរំពឹងទុកសម្រាប់ការបោះឆ្នោតព្រឹទ្ធសភា និងការបោះឆ្នោតថ្នាក់ជាតិឆ្នាំ២០១៨

ការប្រកួតប្រជែងខាងនយោបាយសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៨ ខាងមុខវាជាការប្រកួតប្រជែងមួយ ដែលមើលឃើញថា មានកម្លាំងក្រកួតប្រជែងខ្លាំងរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ។ គណបក្សសង្គ្រោះជាតិជាគណបក្សមួយដែលកើតចេញពីការ បញ្ចូលគ្នារវាងគណបក្សសិទ្ធិមនុស្ស និងគណបក្សសមរង្ស៊ីក្នុងឆ្នាំ២០១៣កន្លងមក។ គណបក្សថ្មីចំនួន៣ ត្រូវបានបង្កើតឡើង សម្រាប់ការប្រកួតប្រជែងក្នុងការបោះឆ្នោតឆ្នាំ២០១៧ និងបន្តប្រកួតប្រជែងការបោះឆ្នោតឆ្នាំ២០១៨ រួមមាន គណបក្សខ្មែររួបរួមជាតិ គណបក្សប្រជាធិបតេយ្យមូលដ្ឋាន និងគណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ។ ច្បាប់គណបក្សនយោបាយនាពេលបច្ចុប្បន្ន បានផ្តល់ឱកាសឱ្យគណបក្សនយោបាយមានលទ្ធភាពបញ្ចូលគ្នាជាគណបក្សមួយថ្មី។ ក្នុងករណីគណបក្សសង្គ្រោះជាតិ ដែលជាគណបក្សកើតចេញពីការបញ្ចូលគ្នា បើសិនជាត្រូវបានបែកបាក់គ្នា ហើយត្រឡប់ទៅគណបក្សចាស់វិញ នោះពួកគេនឹងត្រូវបានបាត់បង់អាសនៈព្រឹទ្ធសភា និងអាសនៈក្រុមប្រឹក្សាឃុំសង្កាត់នាពេលបច្ចុប្បន្ន ដែលអាសនៈទាំងនេះនឹងត្រូវប្រគល់ឱ្យទៅគណបក្សប្រជាជនកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច គណបក្សខ្មែររួបរួមជាតិ ឬគណបក្សប្រជាធិបតេយ្យមូលដ្ឋាន។ ភាពជោគជ័យ និងការប្រកួតប្រជែងមួយកាន់តែខ្លាំងក្លារបស់គណបក្សប្រឆាំងយ៉ាងធំជាមួយគណបក្សប្រជាជនកម្ពុជា បើសិនជាគណបក្សនេះនូវតែរក្សាការបញ្ចូលគ្នា។ គណបក្សសង្គ្រោះជាតិនូវតែរក្សាដៃគូ

ប្រកួតប្រជែងនយោបាយជាមួយគណបក្សប្រជាជន បើមេដឹកនាំគណបក្សនៅតែដឹកនាំដោយលោកសមរង្ស៊ី និងលោកកឹមសុខា ជាពិសេសការទទួលបានសំឡេង និងអាសនៈក្នុងការបោះឆ្នោតថ្នាក់ជាតិឆ្នាំ២០១៣ និងការបោះឆ្នោតជ្រើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧នេះ។

លើសពីនេះទៅទៀត នៅក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧ មានការវិវត្តន៍នយោបាយគួរឱ្យកត់សម្គាល់ គឺគេមើលឃើញថា គណបក្សកាន់អំណាចខិតខំធ្វើវិសោធនកម្មច្បាប់គណបក្សនយោបាយ សង្គមស៊ីវិល ស្ថាប័នអ្នកសារព័ត៌មានជាច្រើនត្រូវបានធ្វើការរឹតបន្តឹង រហូតមានការដេញចេញអង្គការមិនមែនរដ្ឋាភិបាលរបស់សហរដ្ឋអាមេរិក គឺវិទ្យាស្ថានជាតិប្រជាធិបតេយ្យ (NDI) បណ្តាញសារព័ត៌មានសេរី និងឯករាជ្យដែលដើរតួរសំខាន់ក្នុងការផ្តល់ព័ត៌មានបោះឆ្នោត ប្រជាធិបតេយ្យ និងបញ្ហាសង្គមដល់ប្រជាពលរដ្ឋត្រូវបានបញ្ឈប់ការបោះពុម្ពផ្សាយ និងផ្សាយបន្តតាមវិទ្យុFM ក្រោយពីមានវិធានការរបស់រាជរដ្ឋាភិបាល និងអាជ្ញាធរ ដែលមានដូចជា៖ វិទ្យុអាស៊ីសេរី (RFA) វិទ្យុសំឡេងសហរដ្ឋអាមេរិក (VOA) វិទ្យុសំឡេងប្រជាធិបតេយ្យ (VOD) និងវិទ្យុមហានគរ (FM 92.5Hz) និងសារព័ត៌មានកាសែត ឌឺខេមបូឌាដេលី (The CAMBODIA DAILY)។ រីឯគណបក្សនយោបាយមួយចំនួន ត្រូវបានចាប់ខ្លួនដោយអាជ្ញាធរមានសមត្ថកិច្ច ដូចជាប្រធានគណបក្សសង្គ្រោះជាតិ លោក កឹម សុខា អតីតៈប្រធានគណបក្សសង្គ្រោះជាតិ លោក សម រង្ស៊ី ប្រធាណគណបក្សខ្មែររួបរួមជាតិ លោក ញឹក ប៊ុនឆៃ ប្រធានគណបក្សអំណាចខ្មែរ លោក សួន សេរីរដ្ឋា។ លោក សម រង្ស៊ី កំពុងតែរស់នៅក្រៅប្រទេសដោយជាប់ឈ្មោះជាពិរុទ្ធជន ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារ និងចោទពីការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ និងការញុះញង់។ រីឯលោក កឹម សុខា កំពុងត្រូវរងការចោទវប្រកាន់ពីតុលាការពាក់ព័ន្ធនឹងបទល្មើសក្បត់ជាតិ ឬសន្និដ្ឋិភាពជាមួយបរទេស ក្នុងការរៀបចំផ្តួលរំលំរដ្ឋាភិបាល។ បញ្ហាទាំងអស់នេះ ត្រូវបានសហគមន៍អន្តរជាតិយកចិត្តទុកដាក់ផងដែរ ជាពិសេសអ្នកវាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស គឺលោក សុរិយាប្រាសាទស៊ូប៊ែរឌី ពីស្ថានទូតសហភាពអឺរ៉ុប សហរដ្ឋអាមេរិក ក្នុងការចាប់លោក កឹម សុខា ដែលមើលឃើញថា វាជាបញ្ហាមួយដែលអាចអវត្តមានថ្នាក់ដឹកនាំទាំងនេះក្នុងការចូលរួមការបោះឆ្នោតនាពេលខាងមុខ។

ដោយឡែកគណបក្សខ្មែររួបរួមជាតិដែលគេស្គាល់ថា ជាដៃគូនយោបាយរបស់គណបក្សកាន់អំណាចគឺលោក ញឹក ប៊ុនឆៃ ត្រូវបានចាប់ខ្លួនដោយចោទប្រកាន់ពីតុលាការក្នុងសំណុំរឿងឆ្នាំ២០០៧ ក្រោយពីមានការលេចធ្លាយព័ត៌មានថា ប្រធានគណបក្សនេះបានទាក់ទងជាមួយគណបក្សប្រឆាំង និងលោក សួន សេរីរដ្ឋា ក៏ត្រូវបានកាត់ទោសជាប់ពន្ធគារយៈពេលប្រាំឆ្នាំ ពាក់ព័ន្ធនឹងបទល្មើសញុះញង់យោធិនកុំឲ្យស្តាប់ បង្គាប់ ដែលចែងក្នុងមាត្រា ៤៧១ ៤៧២ ៤៩៤ និង ៤៩៥ នៃក្រមព្រហទណ្ឌ ក្នុងពេលដែលកម្ពុជាមានជម្លោះព្រំដែនដែលចូលឈ្លានពានដោយទាហាននៃប្រទេសឡាវ។ គណបក្សទាំងអស់នេះគេអាចមើលឃើញថា និងអាចបង្កើនការប្រកួតប្រជែងផ្នែកនយោបាយ និងប្រកួតប្រជែងជាមួយភាពលេចធ្លោនៃគណបក្សប្រជាជនកម្ពុជាបច្ចុប្បន្ន ក៏ដូចជាគណបក្សប្រឆាំងបច្ចុប្បន្ន ដែលអាចនាំឱ្យមានការបាត់បង់ការបោះឆ្នោតនៅពេលខាងមុខផងដែរ។

លទ្ធផលនៃការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១៧ បានបង្ហាញពីសម្លេងគាំទ្រយ៉ាងច្រើនដល់គណបក្សទាំងពីរ ក្នុងនោះគណបក្សប្រជាជនកម្ពុជាទទួលបានសម្លេងគាំទ្រ៥០.៧៦ភាគរយ (៣,៥៤០,០៥៦សម្លេង) និងគណបក្សសង្គ្រោះជាតិ ទទួលបានសម្លេងគាំទ្រចំនួន៤៣.៨៣ភាគរយ (៣,០៥៦,៨២៤សម្លេង) ដែលលទ្ធផលនេះវាមានការប្រកួតប្រជែងប្រកិតប្រកើយគ្នាយ៉ាងខ្លាំង នៅក្នុងការប្រកួតប្រជែងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៦ ឆ្នាំ២០១៨នាពេលខាងមុខ។ ការប្រកួតប្រជែងនេះ យោងតាមលទ្ធផលនៃការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១៧ យើងអាចសាកល្បងគណនាអាសនៈគណបក្សនយោបាយ ដែលទទួលបានក្នុងការបោះឆ្នោតរដ្ឋសភាជាតិនាឆ្នាំ២០១៨ខាងមុខ លទ្ធផលបង្ហាញថា គណបក្សសង្គ្រោះជាតិនឹងទទួលបានអាសនៈជាតំណាងរាស្ត្រ ថយចុះមកត្រឹមតែចំនួន ៥៤អាសនៈ ដែលបច្ចុប្បន្នគាត់មានអាសនៈចំនួន៥៥ រីគណបក្សប្រជាជនកម្ពុជា គាត់អាចទទួលបានអាសនៈកើនឡើងចំនួន៧០អាសនៈ ដែលបច្ចុប្បន្នមានចំនួន៦៨អាសនៈ។ ទោះជាយ៉ាងណាក៏ដោយ តាមរយៈលទ្ធផលនេះ គេនៅតែមិនទាន់សន្និដ្ឋានឱ្យបានច្បាស់ថា គណបក្សណាមួយដែលអាចគ្រប់គ្រង ឬទទួលបានសំឡេងភាគច្រើនក្នុងអាសនៈរដ្ឋសភានោះនៅឡើយទេ។

លើសពីនេះទៅទៀត បើសិនជាក្នុងករណីមិនមានការសម្របសម្រួលណាមួយខាងផ្នែកនយោបាយឱ្យមានការចូលរួមប្រកួតប្រជែងដោយស្មើភាពគ្នាទេនោះ ហើយនាំឱ្យគណបក្សសង្គ្រោះជាតិចាកចេញពីការប្រកួតប្រជែង ឬគណបក្សនេះត្រូវបានរំលាយនោះ គេមើលមិនទាន់ឃើញថា មានគណបក្សណាមួយផ្សេងទៀត ដែលអាចមានសំឡេងប្រកួតប្រជែងជាមួយគណបក្សប្រជាជនកម្ពុជា ដែលកាន់កាប់អំណាចក្នុងពេលបច្ចុប្បន្ននេះនៅឡើយទេ មានន័យថា គណបក្សប្រជាជនកម្ពុជានឹងត្រូវគ្រប់គ្រងសំឡេងអាសនៈភាគច្រើនក្នុងរដ្ឋសភា ក្នុងការបោះឆ្នោតថ្នាក់ជាតិឆ្នាំ២០១៨ខាងមុខនេះដដែល។ តាមរយៈលទ្ធផលនៃការគាំទ្រក្នុងការបោះឆ្នោតឆ្នាំ២០១៧ មិនមានសញ្ញាដែលបង្ហាញពីភាពរីកចម្រើនធំធេងណាមួយឡើយទេ ដែលអាចរំពឹងទុកថា គណបក្សហ៊្វុនស៊ិនប៉ិច ឬគណបក្សខ្មែររួបរួមជាតិ ដែលជាគណបក្សរាជានិយម ធ្លាប់តែទទួលបានអាសនៈប្រកួតប្រជែងជាមួយគណបក្សប្រជាជនកម្ពុជា ថានឹងទទួលបានសំឡេងគាំទ្រច្រើនក្នុងការបោះឆ្នោតថ្នាក់ជាតិឆ្នាំ២០១៨ខាងមុខ ដូចការបោះឆ្នោតឆ្នាំ១៩៩៣នោះ។ យ៉ាងណាក៏ដោយ ការទស្សន៍ទាយអំពីលទ្ធផលនៃការបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាតិឆ្នាំ២០១៨ខាងមុខនេះ មិនអាចទទួលយកបានទេ និងនៅតែលំបាកក្នុងការព្យាករណ៍ទុក ពីព្រោះលំនាំអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧ អាចខុសគ្នាជាមួយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រក្នុងឆ្នាំ២០១៨ ខាងមុខ និងប្រហែលជាចំណង់ចំណូលចិត្តផ្សេងទៀត អាចនឹងកើតមានក្នុងចំណោមអ្នកបោះឆ្នោតដែលនាំឱ្យពួកគេបោះឆ្នោតឱ្យគណបក្សនយោបាយខុសពីការបោះឆ្នោតឃុំ សង្កាត់។

ភាពត្រឹមត្រូវភាគច្រើននៃការទស្សន៍ទាយសម្រាប់លទ្ធផលនៃការបោះឆ្នោតគឺការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងការបោះឆ្នោតក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ (ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ដែលអាចកើតឡើង ព្រោះថា សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ក្នុងមុខតំណែង និងសមាជិកតំណាងរាស្ត្រក្នុងមុខតំណែង ដែលចេញពីគណបក្សដែលជាប់ឆ្នោត ហើយជាអ្នកដែលបោះឆ្នោតជ្រើសរើសជំនួសប្រជាពលរដ្ឋ ចំពោះតំណែងសមាជិកព្រឹទ្ធសភា សមាជិកក្រុមប្រឹក្សារាជធានីខេត្ត ក្រុង

ស្រុក ខណ្ឌ។ នៅក្នុងប្រទេសកម្ពុជា ការប្រកាន់វិន័យយ៉ាងរឹងមាំតាមខ្សែបណ្តោយគណបក្សនយោបាយ វាជាកត្តារំពឹងមួយយ៉ាងខ្លាំងក្លានៅក្នុងការបោះឆ្នោត នោះមានន័យថា បេក្ខជនឯករាជ្យមិនត្រូវបានអនុញ្ញាតឱ្យចូលរួមនៅក្នុងការបោះឆ្នោតទាំងនេះទេ។ សមាជិកព្រឹទ្ធសភាទាំងអស់មានចំនួន៦២រូប ក្នុងនោះ ២រូបត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ ២រូបទៀតត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើនដោយប្រៀប។ សមាជិកព្រឹទ្ធសភាចំនួន៥៨រូប ត្រូវធ្វើការបោះឆ្នោតជ្រើសតាំងនៅក្នុង៨ភូមិភាគ មានភូមិភាគទី១ រាជធានីភ្នំពេញ ភូមិភាគទី២ខេត្តកំពង់ចាម និងត្បូងឃ្មុំ ភូមិភាគទី៣ ខេត្តកណ្តាល ភូមិភាគទី៤ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ និងខេត្តប៉ៃលិន ភូមិភាគទី៥ ខេត្តតាកែវ ខេត្តកំពត និងខេត្តកែប ភូមិភាគទី៦ ខេត្តព្រៃវែង និងខេត្តស្វាយរៀង ភូមិភាគទី៧ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តកោះកុង ខេត្តព្រះសីហនុ ភូមិភាគទី៨ ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី។ សមាជិកក្រុមប្រឹក្សារាជធានី ខេត្តដែលត្រូវបោះឆ្នោតជ្រើសរើសសរុបមានចំនួន៣៩៣រូប។ រីឯសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ សរុបមានចំនួន២,៩៣១រូប។ សមាជិកព្រឹទ្ធសភា និងសមាជិកថ្នាក់ក្រោមជាតិ ត្រូវបានបោះឆ្នោតដោយសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ចំនួន១១,៥៧២រូប (ក្នុងនោះសមាជិកមកពីគណបក្សប្រជាជនកម្ពុជាចំនួន៦,៥០៣រូប សមាជិកគណបក្សសង្គ្រោះជាតិចំនួន ៥,០០៧រូប និងសមាជិកមកពីគណបក្សផ្សេងៗទៀតចំនួន៦២រូប) និងសមាជិកតំណាងវាស្ត្រសរុបចំនួន ១២៣រូប(មកពីគណបក្សប្រជាជនកម្ពុជា ចំនួន៦៨រូប និងមកពីគណបក្សសង្គ្រោះជាតិចំនួន៥៥រូប)។ ដូច្នេះ ដោយឈរលើមូលដ្ឋាននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧ និងលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងវាស្ត្រឆ្នាំ២០១៣ គណបក្សប្រជាជនកម្ពុជានៅតែទទួលបានសំឡេងភាគច្រើនក្នុងការគ្រប់គ្រង និងកាន់កាប់អាសនៈព្រឹទ្ធសភា និងអាសនៈក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ មានន័យថាគណបក្សប្រជាជនកម្ពុជាអាចទទួលបានអាសនៈចំនួន៣៣ នៃអាសនៈសរុបក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងគណបក្សសង្គ្រោះជាតិទទួលបានចំនួន២៥អាសនៈ។ លទ្ធផលដែលគណនាខាងលើ មិនទាន់គិតពីសំឡេងនៃគណបក្សដែលមានសមាជិកជាប់ឆ្នោតនៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់នៅឡើយទេ វាអាចមានការប្រែប្រួល(ទោះបីមិនច្រើន)បើសិនជាសំឡេងនៃគណបក្សទាំងនោះចូលរួមបោះឱ្យគណបក្សណាមួយនៃគណបក្សប្រជាជន ឬគណបក្សសង្គ្រោះជាតិ។ លទ្ធផលនេះមើលឃើញថា អាសនៈដែលគណបក្សប្រជាជនទទួលបានចំនួន៣៣ វាបានថយចុះចំនួន១៣ បើធៀបជាមួយអាសនៈព្រឹទ្ធសភាក្នុងអាណត្តិទី៣ កាលនោះទទួលបាន៤៦អាសនៈ។ រីឯគណបក្សសង្គ្រោះជាតិ ដែលទទួលបានលទ្ធផលក្នុងការបោះឆ្នោត ឆ្នាំ២០១៨នេះ(២៥អាសនៈ) វាបានកើនឡើងចំនួន១៤អាសនៈ បើធៀបជាមួយការបោះឆ្នោតក្នុងអាណត្តិទី៣ ទទួលបានតែចំនួន២៥អាសនៈ។ ដូចគ្នានេះផងដែរ នៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ដែលមានសមាជិកក្រុមប្រឹក្សាសរុបចំនួន ៣៩៣អាសនៈ និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ សរុបចំនួន២,៩៣១អាសនៈ ការសន្និដ្ឋានដោយផ្អែកលើការសាកល្បងគណនាបានបង្ហាញថា លទ្ធផលគណបក្សប្រជាជនកម្ពុជានឹងទទួលបានអាសនៈជាច្រើនក្នុងការដឹកនាំអាសនៈក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដដែល។ ការសាកល្បងគណនាផ្អែកលើលទ្ធផលបោះឆ្នោតឆ្នាំ២០១៧ គណបក្សប្រជាជនកម្ពុជានឹងទទួលបានសមាជិកចំនួនប្រហែល២៣៧(៦០.៣ភាគរយ) អាសនៈ និងសម្រាប់គណបក្សសង្គ្រោះជាតិនឹងមិនទទួលបានអាសនៈច្រើនឈានទៅការដឹកនាំអាសនៈក្រុម

ប្រឹក្សារាជធានី ខេត្ត គ្រប់ខេត្តនោះទេ លើកលែងតែខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តសៀមរាប និងរាជធានីភ្នំពេញ។

ការសាកល្បងគណនា គណបក្សនេះទទួលបានចំនួនប្រហែល១៥៦(៣៩.៧ភាគរយ)អាសនៈ។ អាសនៈនៃក្រុមប្រឹក្សារាជធានី ខេត្ត ដែលធ្វើការប៉ាន់ប្រមាណក្នុងការបោះឆ្នោតខាងមុខ ត្រូវបានបង្ហាញថា នឹងមានការថយចុះសម្រាប់អាសនៈគណបក្សប្រជាជនកម្ពុជា ចំនួនប្រហែល១៦៩អាសនៈ (អាណត្តិទី២ ឆ្នាំ២០១៤ មានចំនួន៣០៦អាសនៈ និងអាណត្តិទី៣ ខាងមុខនឹងទទួលបានប្រហែល២៣៧អាសនៈ)។ រីឯគណបក្សសង្គ្រោះជាតិមើលឃើញថាមានកំណើនកើនឡើងនៃសមាជិកក្រុមប្រឹក្សាចំនួនប្រហែល៧០អាសនៈ (អាណត្តិទី២ ឆ្នាំ២០១៤ មានចំនួន៨៦អាសនៈ និងអាណត្តិទី៣ ខាងមុខនឹងទទួលបានប្រហែល១៥៦អាសនៈ)។ ការសាកល្បងគណនាលទ្ធផលការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ លទ្ធផលបានបង្ហាញថា គណបក្សប្រជាជនកម្ពុជាទទួលបានអាសនៈប្រហែលចំនួន១,៧០៣(៥៨.២ភាគរយ)អាសនៈ និងគណបក្សសង្គ្រោះជាតិទទួលបានអាសនៈសរុបចំនួន១,២២៣(៤១.៨ភាគរយ)អាសនៈ នៃអាសនៈសរុប។ លទ្ធផលនៃការបោះឆ្នោតនេះបង្ហាញថា គណបក្សប្រជាជនបានបាត់បង់អាសនៈប្រហែលចំនួន៥៣១អាសនៈ(អាណត្តិទី២មានចំនួន២,២៣៤អាសនៈ ក្នុងលទ្ធផលគណនាសាកល្បងសម្រាប់អាណត្តិទី៣ មានចំនួន១,៧០៣អាសនៈ)។ រីឯគណបក្សសង្គ្រោះជាតិបានកើនចំនួនប្រហែល៥៤៤អាសនៈ (អាណត្តិទី២មានចំនួន៦៧៩អាសនៈ ក្នុងលទ្ធផលគណនាសាកល្បងសម្រាប់អាណត្តិទី៣ មានចំនួន១,២២៣អាសនៈ)។

នៅក្នុងសេចក្តីសន្និដ្ឋាន ដោយផ្អែកលើលទ្ធផលនៃការបោះឆ្នោតឃុំសង្កាត់នាពេលថ្មីៗនេះ និន្នាការនាពេលអនាគតបានបង្ហាញពីការថយចុះនៃអាសនៈរបស់គណបក្សប្រជាជននៅក្នុងព្រឹទ្ធសភា និងក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ចំណែកឯគណបក្សសង្គ្រោះជាតិ ទទួលបានអាសនៈកើនឡើង ជាងការបោះឆ្នោតអាណត្តិមុនៗ ទោះបីមិនបានគ្រប់គ្រងសមាជិកក្រុមប្រឹក្សាព្រឹទ្ធសភាក៏ដោយ ក៏ប៉ុន្តែមានការគ្រប់គ្រងសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត និងសមាជិកក្រុមប្រឹក្សាស្រុក ក្រុង ខណ្ឌ នៅក្នុងមណ្ឌលខ្លះ។ រីឯគណបក្សផ្សេងទៀត ដែលមានសមាជិកនៅក្នុងក្រុមប្រឹក្សាឃុំសង្កាត់ដែរនោះ គឺមិនត្រូវបានជាប់សមាភាពនៅក្នុងសមាជិកព្រឹទ្ធសភា ឬសមាជិកក្រុមប្រឹក្សាថ្នាក់ក្រោមជាតិនោះទេ។

១៣. បរិយាកាសក្រោយការបោះឆ្នោត និងការវិវឌ្ឍន៍នយោបាយ

១៣.១ ការវាយតម្លៃទៅលើលទ្ធផល និងគុណភាពនៃការបោះឆ្នោត

ការប្រែប្រួលផ្នែកនយោបាយ នៅក្រោយការបោះឆ្នោត បានបង្កើននូវភាពតានតឹងកាន់តែខ្លាំងឡើងៗ ដោយរួមបញ្ចូលព្រឹត្តិការណ៍សំខាន់ៗមួយចំនួនដូចជា៖ ការចេញញត្តិប្តោលទោស និងគំរាមកំហែងធ្ងន់ៗទៅលើ ការចេញសេចក្តីថ្លែងការ ណ៍ស្តីពីលទ្ធផលបោះឆ្នោតរបស់គណបក្សសង្គ្រោះជាតិ សេចក្តីថ្លែងការណ៍រិះគន់នានាលើការធ្វើវិសោធនកម្មច្បាប់គណបក្សនយោបាយលើកទី២ និងការហាមឃាត់មិនអោយមានបន្ទប់ស្ថានការណ៍ ដែលជាបណ្តុំនៃអង្គការសង្គមស៊ីវិលជាច្រើន ដែលបង្កើតក្នុងគោលបំណងដើម្បីចូល

រួមឃ្លាំមើល និងសង្កេតមើលការបោះឆ្នោតឃុំ សង្កាត់កន្លងទៅ។ ទោះបីជាយ៉ាងណាក៏ដោយ មិនមានគណបក្សនយោបាយណាមួយបដិសេធអំពីលទ្ធផលនៃការបោះឆ្នោតឃុំ សង្កាត់នេះទេ ដោយហេតុផលថា ការបោះឆ្នោតនេះ ត្រូវបានធ្វើឡើងដោយសន្តិវិធី និងអាចជឿជាក់បានសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។ ការរៀបចំ និងការចាត់ចែងរៀបចំការបោះឆ្នោតដែលធ្វើឡើងដោយ គ.ជ.ប ត្រូវបានស្វាគមន៍ និងសរសេរដោយគណបក្សនយោបាយដែលបានចុះឈ្មោះប្រកួតប្រជែង និងបេក្ខជនឈរឈ្មោះ ក្រុមការងារដែលរៀបចំដំណើរការនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត អង្គការសង្គមស៊ីវិលក្នុងស្រុកដែលចូលរួមសង្កេតការដំណើរការបោះឆ្នោត និងភាគីដែលពាក់ព័ន្ធមកពីសហគមន៍អន្តរជាតិ[170] (រួមបញ្ចូលទាំងអង្គការអន្តររដ្ឋាភិបាល ស្ថានទូត ដែលត្រូវបានអញ្ជើញអោយចូលរួមសង្កេតការណ៍ និងអង្គការក្រៅរដ្ឋាភិបាល) ដោយរដ្ឋាភិបាល។

រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ និងអបអរសាទរចំពោះលទ្ធផលនៃដំណើរការនៃការបោះឆ្នោតនេះ ដោយបានថ្លែងជាឱឡារិកថា «ការបោះឆ្នោតនេះប្រព្រឹត្តទៅដោយសន្តិភាព និងគ្មានហឹង្សា»។ ទោះបីជាយ៉ាងនេះក្តី ភាពចម្រូងចម្រាស និងការជជែកគ្នាពាក់ព័ន្ធនឹងការវាយតម្លៃជារួមលើដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១៧ នៅតែកើតមាន។ បញ្ហាដែលត្រូវចោទសួរគឺថា តើដំណើរការនៃការបោះឆ្នោតនេះប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃការបោះឆ្នោតនៅក្នុងសង្គមប្រជាធិបតេយ្យដែរឬទេ? ហើយការបោះឆ្នោតដែលកំណត់ថា សេរី ត្រឹមត្រូវ និងយុត្តិធម៌នេះ កំណត់ត្រឹមតែដំណើរការក្នុងថ្ងៃបោះ និងថ្ងៃរាប់សន្លឹកឆ្នោត ហើយចាប់ផ្តើមវាយតំលៃជារួម និងជាទូទៅថា ការបោះឆ្នោតនេះ មានភាពសេរី ត្រឹមត្រូវ និងយុត្តិធម៌។[171]

ក្រៅពីការចូលរួមរបស់ប្រជាពលរដ្ឋកម្ពុជា បន្ទប់ស្ថានការណ៍ អង្គការក្រៅរដ្ឋាភិបាលក្នុងតំបន់ អន្តរជាតិមួយចំនួន បានចេញលិខិតអបអរសាទរចំពោះស្ថាប័ន គ.ជ.ប និងរាជរដ្ឋាភិបាលកម្ពុជាដែលបានរៀបចំ និងចាត់ចែងដំណើរការនៃការបោះឆ្នោតនេះ។ ការកែលម្អដែលឃើញមានលេចឡើងប្រសើរជាងការបោះឆ្នោតមុនៗមានដូចជា ដំណើរការរៀបចំក្នុងថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត។ ទោះជាបែបនេះក្តី អ្នកអង្កេតការណ៍ជាតិ និងអន្តរជាតិ មិននបានចាត់ទុកថា ការបោះឆ្នោតនេះមានភាពត្រឹមត្រូវ សេរី និងយុត្តិធម៌ពេញលេញនោះទេ ដោយសារតែកង្វះខាតចំណុចសំខាន់ៗ ដែលចាំបាច់(គោលការណ៍មូលដ្ឋាន)ត្រូវតែមានសម្រាប់ការបោះឆ្នោត តាមបែបប្រជាធិបតេយ្យ។

[170] The second place winner, the opposition CNRP, expressed dissatisfaction with the electoral dispute resolution process because many of the electoral complaints were refused by the NEC's electoral dispute resolution bodies, particularly the NEC itself.

[171] See the Joint Statement of Situation Room on Overall Assessment of 2017-Commune Election, dated June 24th 201

ក្រុមសមាគមន៍ជាតិ រួមបញ្ចូលទាំងក្រុមអង្គការសហគមន៍ជាតិ រួមមានសង្គមស៊ីវិល គណបក្សដែលបានចុះឈ្មោះចូលរួមប្រកួតប្រជែង និងអ្នកជំនាញការបោះឆ្នោត បានបញ្ចេញទស្សនៈខុសៗគ្នា ពាក់ព័ន្ធនឹងដំណើរការនៃការបោះឆ្នោត និងលទ្ធផលនៃការបោះឆ្នោតឃុំ សង្កាត់នេះ។ នៅក្នុងថ្ងៃបោះឆ្នោត (ទាំងថ្ងៃបោះ និងរាប់សន្លឹកឆ្នោត) មានអ្នកសង្កេតការណ៍ជាតិចំនួន៧៤,៦៨០នាក់ ដែលមកពីអង្គការក្រៅរដ្ឋាភិបាល និងសមាគមចំនួន២១ អ្នកសង្កេតការអន្តរជាតិមានចំនួន៤២៥នាក់ មកពីអង្គការអន្តរជាតិ ទីភ្នាក់ងារអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាលក្នុងតំបន់ ប្រទេសម្ចាស់ជំនួយមានចំនួន៣៩នាក់ (ប្រទេស និងអង្គការអន្តរជាតិ)។[172] ភាគីពាក់ព័ន្ធទាំងនេះមួយចំនួន បានសំដែងការយល់ឃើញអំពីចំណុចមួយចំនួន ដែលពួកគេមិនយល់ស្របថា ការបោះឆ្នោតឆ្នោតនេះ វាមានភាពសេរី ត្រឹមត្រូវ និងយុត្តិធម៌ពេញលេញ។

សហភាពសហព័ន្ធយុវជនកម្ពុជា (UYFC) (អង្គការដែលបានដាក់ពង្រាយអ្នកសង្កេតការណ៍ច្រើនជាងគេ) និងអង្គការក្រៅរដ្ឋាភិបាលលចំនួនពីរផ្សេងទៀត (អង្គការ CWPD និង CDSIF) បានចេញសេចក្តីថ្លែងការណ៍អបអរសាទរ និងទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នេះ។ អង្គការទាំងនេះបានចាត់ទុកថា ការបោះឆ្នោតដែលរៀបចំ និងចាត់ចែងដោយ គ.ជ.ប. និងស្ថានប័នដទៃទៀតដែលនៅក្រោមអំណាច និងសមត្ថកិច្ចរបស់ គ.ជ.ប ជាការបោះឆ្នោតដោយសេរី និងយុត្តិធម៌ គ្មានភាពលំអៀង និងមានតម្លាភាពត្រឹមត្រូវ។ ទោះជាយ៉ាងនេះក្តី អង្គការទាំងនោះ បានមើលឃើញពីចំណុចអវិជ្ជមានពីភាពមិនប្រក្រតីមួយចំនួននៅក្នុងដំណើរនៃការដោះស្រាយបណ្តឹងបោះឆ្នោតដែរ។[173] ចំពោះអង្គការ និងសមាគមទាំងបីខាងលើនេះ ត្រូវបានគេស្គាល់ថា ជាអង្គការសង្គមស៊ីវិលដែលគាំទ្ររដ្ឋាភិបាល គណបក្សកាន់អំណាច ដោយសារតែអង្គការទាំងនេះជាសម្ព័ន្ធមិត្ត និងមានភាពជិតស្និទ្ធជាមួយរដ្ឋាភិបាល និងអ្នកដឹកនាំជាមន្ត្រីជាន់ខ្ពស់នៃគណបក្សកាន់អំណាច។

---

[172] See the Drafted Report of the NEC on Administration and Organizing of Commune and Sangkat Council Elections, 2017, at p. 63. The top six NGOs and Associations that deployed election observers were: the Union of Youth Federations of Cambodia (UYFC) deployed 31, 431 observers; the Cambodian Women for Peace and Development (CWPD) deployed 20,792 observers; the Committee for Free and Fair Elections in Cambodia (COMFREL) deployed 14580 observers; the Cambodian Democratic Student Intellectual Federation (CDSIF) deployed 2,642 observers; Transparency International Cambodia (TI-Cambodia) deployed 1,239 observers; and, the Neutral & Impartial Committee for Free & Fair Elections in Cambodia (NICFEC) deployed 1, 052 observers. The following foreign institutions deployed 20 or more election observers: the Embassy of the United States of America in Phnom Penh deployed 98 observers; the Asian Network for Free Elections (ANFREL) deployed 60 observers; the Australian Embassy in Phnom Penh deployed 26 observers; the European Union deployed 22 observers; the Centrist Democrats International (CDI) deployed 22 observers; the International Conference of Asian Political Parties (ICAPP); and, the National Democratic Institute (NDI) deployed 20 observers.

[173] UYCF Statement on the Result of 2017-Commune Elections, dated on June 27th 2017

លើការអបអរសាទរ ការគាំទ្រ និងការបញ្ជាក់ពីភាពសេរី ត្រឹមត្រូវ និងយុត្តិធម៌នៃការបោះឆ្នោតនេះ ត្រូវបានស្ថាប័ន និងអង្គការអន្តរជាតិ៣ទៀត ដែលត្រូវបានអញ្ជើញដោយរដ្ឋាភិបាលកម្ពុជាគឺ ICAPP, CAPDI, ហើយនិង CDI[174] បានចូលរួមសង្កេតការណ៍បោះឆ្នោតឃុំ សង្កាត់ឆ្នាំ២០១៧នេះ ដែលស្ថាប័នទាំងនេះ ត្រូវបានគេស្គាល់ថាជា អង្គការ និងស្ថាប័នដែលមានមាននិន្នាការយ៉ាងជិតស្និទ្ធ និងតែងតែគាំទ្រគណបក្សកាន់អំណាចនៅរាល់ការបោះឆ្នោតកន្លងមក។ អង្គការទាំង៣នេះ បានសន្និដ្ឋានយ៉ាងខ្លីនៅក្រោយការសង្កេតការណ៍នៅតាមមណ្ឌលបោះឆ្នោតតិចតួចថា ការបោះឆ្នោតនេះមានភាពយុត្តិធម៌ និងមានតម្លាភាព។ ក្រុមអ្នកសង្កេតការណ៍អន្តរជាតិទាំង៣ស្ថាប័ន/អង្គការ បានចេញសេចក្តីថ្លែងការណ៍ដាច់ដោយឡែកពីគ្នា គឺលិខិតគាំទ្រអំពីលទ្ធផលនៃការបោះឆ្នោត និងលិខិតសរសើរពីការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ដើម្បីពង្រឹងដំណើរការប្រជាធិបតេយ្យនៅកម្ពុជា។ សារលិខិតសរសើរដូចគ្នាផងដែរ ត្រូវបានប្រកាសដោយស្ថានទូតបរទេសមួយចំនួនរួមមាន ស្ថានទូតចិន ស្ថានទូតរុស្ស៊ី ស្ថានទូតឥណ្ឌា ព្រមទាំងស្ថានទូតមួយចំនួនទៀតដែលមកពីប្រទេសក្នុងតំបន់អាស៊ាន(ASEAN)។

នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៧ ខុមហ្រ្វែល និងអង្គការជាដៃគូនៃអតីតបន្ទប់ស្ថានការណ៍បានចេញសេចក្តីថ្លែងការណ៍ស្តីពីការវាយតម្លៃអំពីដំណើរការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១៧។ ការវាយតម្លៃរបស់ក្រុមអង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍នេះគឺ បានសម្តែងនូវការសាទរចំពោះការបោះឆ្នោតឃុំ សង្កាត់នេះ ថាជាការបោះឆ្នោតប្រព្រឹត្តទៅដោយគ្មានអំពើហឹង្សា មន្ត្រីបម្រើការបោះឆ្នោតធ្វើការប្រកបដោយវិជ្ជាជីវៈ និងគណបក្សនយោបាយមានភាពចាស់ទុំច្រើនបានប្តេជ្ញាចិត្តខ្ពស់ចូលរួមក្នុងការគោរព។ ទោះបីជាយ៉ាងណា ការវាយតម្លៃជារួមនេះ ក៏បានបង្ហាញផងដែរអំពីភាពខ្វះខាតនូវធាតុសំខាន់ដូចជា សេរីពុហុបក្សនិយម អភិបាលកិច្ចបែបប្រជាធិបតេយ្យ បានយកមកគិតពិចារណាក្នុងបរិបទត្រួសៗនៃការខ្វះពហុសេរីនិយម អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងនីតិរដ្ឋ ដែលកត្តានេះហើយបានបង្ខំអោយមានការសន្និដ្ឋានភ្ជាប់ជាមួយថា ការបោះឆ្នោតនេះខ្វះភាពសេរី និងយុត្តិធម៌។[175] អង្គការខុមហ្រ្វែលនិងបន្ទប់ស្ថានការណ៍ដែលជាបណ្តុំនៃអង្គការជាដៃគូដែលបានសង្កត់ធ្ងន់លើបញ្ហាមួយចំនួន ដូចជា ក្រប

[174] The CDI statement on the result of the election "We welcome the use of multiparty, free, fair and regular elections as a democratic means to compete for public offices has become Cambodia's destiny." Suos Yara, Letter to Editor – Cambodia's elections: Another milestone in democracy, June 8, 2017, Khmer Times; http://www.khmertimeskh.com/news/39127/letter-to-editor---cambodia---s-elections--another-milestone-in-democracy/

[175] See Situation Room & COMFREL Final Assessment Statement on 2017-Commune/Sangkat elections.

ខណ្ឌនៃច្បាប់ បរិយាកាសនយោបាយមុនការបោះឆ្នោត ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយមិនស្មើភាព និងការរឹតត្បិតសេរីភាពនៃការបញ្ចេញមតិខាងនយោបាយក្នុងអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោតជាដើម។

អង្គការសង្គមស៊ីវិលក្នុងតំបន់ ដែលមានកេរ្តិ៍ឈ្មោះល្បីៗល្បាញមួយចំនួន ដូចជាអាន់ហ្វ្រែល (ANFREL) និងអង្គការឃ្លាំមើលសិទ្ធិមនុស្ស បានធ្វើការវិភាគរួមគ្នាអំពីដំណើរនៃការបោះឆ្នោតឃុំ សង្កាត់នេះ។ អាន់ហ្វ្រែលបានលើកឡើងថា ការបោះឆ្នោតនេះ ត្រូវបានរៀបចំឡើងក្រោមរបបគតិយុត្តដែលមានភាពយ៉ាងតឹងរឹង។ ច្បាប់ស្តីគ្រប់គ្រងសមាគម និងអង្គការក្រៅរដ្ឋាភិបាល ច្បាប់បោះឆ្នោត និងច្បាប់វិសោធនកម្មនៃច្បាប់ស្តីពីគណបក្សនយោបាយ គឺបានរឹតបន្តឹងសេរីភាពរបស់សង្គមស៊ីវិល និងគណបក្សនយោបាយជាពិសេសគណបក្សប្រឆាំង។ ច្បាប់នេះ បានដាក់សំពាធយ៉ាងធ្ងន់ធ្ងរបន្ថែមទៀតទៅលើស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេស រហូតដល់នាំអោយមានការចាប់ខ្លួនសកម្មជនសិទ្ធិមនុស្ស ការចោទប្រកាន់តាមផ្លូវច្បាប់ ដើម្បីប្រឆាំងនឹងសមាជិកមន្ត្រីគណបក្សប្រឆាំង និងការគំរាមកំហែងអំពីហឹង្សា(បង្ក្រាប) និងការព្រមានអំពីបញ្ហាកើតសង្គ្រាមស៊ីវិលរបស់នាយករដ្ឋមន្ត្រី និងថ្នាក់ដឹកនាំគណបក្សកាន់អំណាច ដែលទាំងអស់នេះបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើបរិយាកាសនៃយុទ្ធនាការនៃការឃោសនាបោះឆ្នោត។ ជារូបភាពវិជ្ជមាន អាន់ហ្វ្រែល បានមើលឃើញដំណើរនៃការបោះឆ្នោតប្រព្រឹត្តទៅដោយរលូន គ.ជ.ប និងស្ថាប័នក្រោមសមត្ថកិច្ចរបស់ខ្លួនបានអនុវត្តបទបញ្ជា និងនីតិវិធី មានប្រសិទ្ធភាពសម្រាប់ថ្ងៃបោះឆ្នោត។[176]

គណបក្សនយោបាយទាំងអស់ ដែលបានចូលរួមប្រកួតប្រជែងការបោះឆ្នោតនេះ បានទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត។ ទោះជាបែបនេះក្តី មានគណបក្សប្រឆាំងដ៏ធំជាងងគេ គឺគណបក្សសង្គ្រោះជាតិ មិនសំដែងនូវការមិនពេញចិត្តនឹងបរិយាកាសនយោបាយ និងដំណើរនៃការដោះស្រាយបណ្តឹងបោះឆ្នោត។ (គណបក្សសង្គ្រោះជាតិបានលើកឡើងថា ការរឹតបន្តឹងទៅលើសេរីភាពនៃការចូលរួម និងសេរីភាពនៃការបញ្ចេញមតិ និងភាពមិនច្បាស់លាស់នៅក្នុងបទបញ្ញត្តិ ដែលពាក់ព័ន្ធនឹងការដោះស្រាយបណ្តឹងបោះឆ្នោត ជាហេតុធ្វើឱ្យដំណើរការនៃការបោះឆ្នោតមានភាពលំអៀងទៅរកគណបក្សកាន់អំណាច។ ប៉ុន្តែនៅទីបំផុត គណបក្សសង្គ្រោះជាតិបានទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាតនេះ ។

ស្ថានទូតជប៉ុន និង សហភាពអឺរ៉ុបប្រចាំនៅកម្ពុជាមិនបានចេញ សេចក្តីថ្លែងការជាផ្លូវការណ៍ណាមួយពាក់ព័ន្ធនឹងដំណើរការនៃការការបោះឆ្នោត និងលទ្ធផលវាយតំលៃនៃការបោះឆ្នោតនេះទេ តែស្ថានទូត

[176] The 2017 International Election Observation Mission (IEOM) of the Asian Network for Free Elections (ANFREL)
to the Kingdom of Cambodia's Commune and Sangkat Council Elections Final-Report, ANFREL;
http://anfrel.org/wp-content/uploads/2017/07/The-2017-Cambodia-IEOM-Final-Report.pdf

ទាំងពីរនេះបានលើកឡើងពីការប្តេជ្ញាចិត្តបន្តដើម្បីជួយគាំទ្រ និងផ្តល់ជំនួយទៅ គ.ជ.ប សម្រាប់ការបោះឆ្នោតជាតិឆ្នាំ២០១៨ខាងមុខ ដើម្បីលើកស្ទួយការបោះឆ្នោតប្រកបដោយសេរី និងយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា។ ស្ថានទូតសហរដ្ឋអាមេរិកបានដាក់ពង្រាយអ្នកសង្កេតការណ៍របស់ខ្លួន ចំនួន៤០នាក់នៅទូទាំងប្រទេស ក្នុងថ្ងៃបោះឆ្នោត ដោយមានការសហការជាមួយ គ.ជ.ប ផងដែរ។ អ្នកអង្កេតការណ៍ទាំងនេះបានចុះទៅដល់ទីតាំងជាង៣០០ នៅរាជធានីភ្នំពេញ និង១៣ខេត្ត។ ស្ថានទូតអាមេរិកបានចេញរបាយការណ៍កាលពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៧ ថា "ស្ថានភាពទូទៅក្នុងមណ្ឌល និងការិយាល័យបោះឆ្នោនានា ត្រូវបានសង្កេតឃើញថា ការបោះឆ្នោតមានសណ្តាប់ធ្នាប់ល្អ និងដោយសន្តិវិធី"។

១៣.១.១. ការយោយីពីស្ថាប័ននីតិបញ្ញត្តិ

ការបោះជំហានដើរថយក្រោយនៃប្រជាធិបតេយ្យ គឺមានការពាក់ព័ន្ធជាមួយនឹងការធ្វើវិសោធនកម្មនៃច្បាប់មួយចំនួន។ ការធ្វើវិសោធនកម្មច្បាប់ ស្តីពីគណបក្សនយោបាយ និងកែបន្ថែមបញ្ញត្តិមួយចំនួនក្នុងច្បាប់ស្តីការបោះឆ្នោតឃុំ សង្កាត់ គឺបានរំលោភដោយផ្ទាល់ទៅលើគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស។ ច្បាប់ស្តីពីគណបក្សនយោបាយដែលត្រូវបានធ្វើវិសោធនកម្មនេះ មានចរឹតត្បិតការនិយាយស្តីរបស់មន្ត្រីគណបក្សនយោបាយ ដែលសូម្បីតែការអនុវត្តន៍សិទ្ធិបុគ្គលឯកជនជាប្រជាពលរដ្ឋ។ ច្បាប់នេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងឈានទៅប្រព័ន្ធគ្រប់គ្រងដោយឯកបក្ស និងអាចនាំអោយមានការគ្រប់គ្រងតាមបែបផ្តាច់ការនិយម ដោយសារតែច្បាប់នេះចែងបើកផ្លូវអោយមានការអនុញ្ញាតអោយរំលាយគណបក្សមួយចំនួន ដែលបានប្រព្រឹត្តខុសដោយរូបវន្តបុគ្គលទទួលខុសត្រូវនៃគណបក្សនយោបាយ។ ផ្អែកតាមការចង្អុលបង្ហាញនៃច្បាប់នេះ ប្រព័ន្ធតុលាការ នឹងអាចអនុវត្តឆន្ទានុសិទ្ធិ ដោយសារថា ស្ថាប័ននីតិប្រតិបត្តិអាចគ្រប់គ្រង (ធ្វើអ្វីៗដែលចង់ធ្វើ) សម្រាប់រៀបចំអោយមានការបោះឆ្នោតប្រកដោយប្រសិទ្ធភាពក្រោមការគ្រប់គ្រងរបស់ខ្លួន។ ការធ្វើវិសោធនកម្មច្បាប់ ស្តីពីគណបក្សនយោបាយជាលើកទី២នៅឆ្នាំ២០១៧នេះ បានបង្កអោយមានបញ្ហាប្រឈមជាឧបសគ្គជាច្រើនដល់គណបក្សនយោបាយក្នុងការចូលរួមប្រកួតប្រជែង តាមបែបប្រជាធិបតេយ្យ (គ្មានការវិវត្តន៍សមត្ថភាពណាមួយ ដើម្បីបង្កើតអោយមានការជឿជាក់ និងជោគជ័យដែលទទួលបានមកពីការប្រកួតប្រជែង ឈរលើមូលដ្ឋានគោលនយោបាយរបស់គណបក្ស) ដែលក្នុងវិសោធនកម្មនេះ បានរំលេចឃ្លា ទណ្ឌិត នៅក្នុងច្បាប់ មានន័យថា បានហាមប្រាមគណបក្សនយោបាយមិនអោយប្រើប្រាស់សារនយោបាយ សំឡេង ឬរូបថតអ្នកនយោបាយឃោសនាបោះឆ្នោតជាដើម។ ភាគីពាក់ព័ន្ធសំខាន់ៗ យល់ឃើញថា ច្បាប់នេះបានបង្ហាញជាសញ្ញាណយ៉ាងច្បាស់ពីចេតនា ព្យាយាមដកលោក សម

រង្សី ដែលជាអតីតប្រធានគណបក្សប្រឆាំងដ៏ធំ ចេញពីការចូលរួមសកម្មភាពជាមួយគណបក្ស។[177] ដូច្នេះ ដោយសារតែលោក សម រង្សី គឺជាទណ្ឌិត ដោយគ្រាន់តែប្រើប្រាស់ខ្លឹមសារនៃសារនយោបាយ រូបភាព សំឡេង វីដេអូ របស់លោក សម រង្សី គណបក្សនោះ ក៏អាចនឹងត្រូវចាត់ការតាមផ្លូវច្បាប់បានដែរ។ ដើមចមនៃការធ្វើវិសោធនកម្មច្បាប់នេះ ដោយសារតែសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងជាសាធារណៈក្នុងការប្រារព្ធខួបលើកទី៦៦ របស់គណបក្សកាន់អំណាចកាលពីថ្ងៃទី២៨ ខែមិថុនា ដោយលោកបានធ្វើការចោទប្រកាន់គណបក្សសង្គ្រោះជាតិថា គណបក្សនេះកំពុងតែព្យាយាមចោទប្រកាន់អតីតព្រះមហាក្សត្រថាជាក្បត្រក្បត់ជាតិ។[178] ខណៈពេលដែលក្រុមគណបក្សប្រឆាំងទាំងអស់បានធ្វើពហិការមិនចូលរួមសម័យប្រជុំរដ្ឋសភាជាតិ ស្តីពីការធ្វើវិសោធនកម្ម។ ការអនុម័តលើវិសោធនកម្មច្បាប់នេះ គឺបក្សកាន់អំណាចបានប្រជុំអនុម័តដោយឯកបក្សមានសំឡេងត្រឹមតែ ៦៥សំឡេងនៃសមាជិករដ្ឋសភាទាំងមូល (លោកនាយករដ្ឋមន្ត្រីមិនបានចូលរួមទេ)កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧។ [179]

ច្បាប់វិសោធនកម្មលើកទីពីរនេះ បានធ្វើការហាមឃាត់ មិនអោយគណបក្សនយោបាយធ្វើការទាក់ទងជាមួយបុគ្គលណាដែលត្រូវបានគេកាត់ទោសពីបទឧក្រិដ្ឋ សូម្បីតែការប្រើប្រាស់សំឡេង រូបភាព និងលិខិតលាយល័ក្ខណអក្សររបស់បុគ្គលនោះក៏ដោយ។ មាត្រា៤៤(២) បានចែងទៀតថា វាជាការខុសច្បាប់សម្រាប់គណបក្សនយោបាយដែលរៀបចំផែនការ ឬអនុវត្ត "សកម្មភាពប្រឆាំងនឹងផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា" ដែលត្រូវបានភាគីពាក់ព័ន្ធការបោះឆ្នោត និងអង្គការសង្គមស៊ីវិល វិភាគឃើញថា វាបានបង្កប់នូវភាពមិនច្បាស់លាស់ជ្រុលពេក ហើយអាចនឹងត្រូវបានបកស្រាយតាមអំពើចិត្ត និងការអនុវត្តដោយបំពាន។ ចំពោះទោសបញ្ញត្តិនៃច្បាប់នេះ បានចែង ហាមឃាត់ពីការធ្វើសកម្មភាពនយោបាយ មិនអោយចូលរួមប្រប្រកួតប្រជែងក្នុងការបោះឆ្នោតក្នុងរយៈពេល៥ឆ្នាំ ក្រោយពេលគណបក្សត្រូវបានរំលាយ។ ការធ្វើវិសោធនកម្មច្បាប់នេះ គឺក្នុងបំណងទប់ស្កាត់មិនអោយមានគណបក្សប្រឆាំង ទោះបីជាក្នុងកាលៈទេសៈណាក៏ដោយ គណបក្សប្រឆាំងនឹងមិនអាចធ្វើអ្វីដល់គណបក្សកាន់អំណាចបានដាច់ខាត។

ខុមហ្វ្រែល និងអង្គការសង្គមស៊ីវិលដៃគូផ្សេងទៀត បានសំដែងនូវការព្រួយបារម្ភយ៉ាងខ្លាំងអំពីចរិកលក្ខណៈរបស់ច្បាប់ដែលត្រូវបានធ្វើវិសោធនកម្មនេះ ខណៈដែលការធ្វើវិសោធនកម្មនេះមិនបានប្រឹក្សាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធនានា ជាពិសេសគណបក្សនយោបាយ។ ច្បាប់នេះត្រូវគេមើលឃើញថា វាមាន

[177] Meas, Sokchea and Erin Handley "Breaking: Assembly passes Party Law changes targeting Rainsy" Phnom Penh Post, 10 July 2017.
[178] Alex Willemyns and Dara Mech "As CPP marks 66th anniversary, Hun Sen takes opportunity to accuse CNRP" Phnom Penh Post, 29 June 2017. Note that this occurred just days after the call for reform speech given by the PM which is mentioned below.
[179] Thai, Tha "Cambodia amendment effectively cuts ties Sam Rainsy ties to the CNRP" RFA, 10 July 2017.

ចរិតផ្ទុយនឹងគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញក្នុងមាត្រា៣១។ វាមានភាពមិនស៊ីសង្វាក់គ្នានឹងវឌ្ឍនភាព ដែលទាមទារអោយមានការចូលរួមដោយពេញលេញរបស់ប្រជាពលរដ្ឋខ្មែរ ដូចដែលមានចែងក្នុងមាត្រា៣៥ នៃរដ្ឋធម្មនុញ្ញ។ ច្បាប់វិសោធនកម្មនេះ បានដកសិទ្ធិ និងសេរីភាពនៃការបញ្ចេញមតិរបស់ប្រជាពលរដ្ឋខ្មែរទាំងមូល ដែលត្រូវតែពង្រឹងសមត្ថភាព ដើម្បីគាំទ្រដោយសេរី និងបើកចំហចំពោះបេក្ខជនដែលពួកគេបានជ្រើសរើស ដូចមានចែងក្នុងមាត្រា៤១។ នៅទីបំផុត វាបានរំលោភយ៉ាងច្បាស់ទៅលើមាត្រា៤២ ដែលបានចែងអំពីសិទ្ធិរបស់ប្រជាពលរដ្ឋ ដើម្បីបង្កើត រឺ/និងគាំទ្រគណបក្សនយោបាយ។ ច្បាប់ វិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយនេះ តាមពិតទៅវាបានឆ្លុះបញ្ចាំងពីភាពបរាជ័យរបស់រាជរដ្ឋាភិបាលក្នុងការបំពេញកាតព្វកិច្ចក្រោមច្បាប់អន្តរជាតិ។ ការធ្វើវិសោធនកម្មច្បាប់ ស្តីពីគណបក្សនយោបាយនេះ អាចធ្វើទៅបានប៉ុន្តែត្រូវស្របជាមួយមាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក្នុងលក្ខខណ្ឌដែលចាប់បង្ខំ ភាពចាំបាច់ប៉ុណ្ណោះ។ ប៉ុន្តែស្ថានភាពរបស់កម្ពុជា មិនគួរជាការចាំតម្រូវអោយច្បាប់ចែងតឹងរឹងបែបនេះឡើយ ពីព្រោះថា រដ្ឋាភិបាលកម្ពុជាមិនបានបង្ហាញអោយច្បាស់លាស់ថា អ្វីជាការគម្រាមកំហែងដល់សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ ធ្វើអោយប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិពលរដ្ឋដទៃក្នុងប្រទេស។

តាមរយៈការការតស៊ូមតិយ៉ាងស្វិតស្វាញលើសំណើច្បាប់ ដែលត្រូវបានធ្វើវិសោធនកម្មនេះ អង្គការសង្គមស៊ីវិលយល់ឃើញថា ការធ្វើវិសោធនកម្មច្បាប់នេះ នឹងនាំអោយមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់គោលការណ៍នៃការចូលរួមដ៏មានអត្ថន័យនៃភាគីពាក់ព័ន្ធ តម្លាភាព និងការចូលរួមតាមបែបប្រជាធិបតេយ្យ។ អង្គការខុមហ្រៃ្វល និងអង្គការជាដៃគូសង្គមស៊ីវិលជាច្រើនទៀត បានបង្ហាញទស្សនៈទៅកាន់ស្ថាប័នដែលពាក់ព័ន្ធរបស់រដ្ឋាភិបាលទាំងអស់ ដូចជាស្ថាប័ននីតិបញ្ញត្តិ និងសហគមន៍អន្តរជាតិថា ច្បាប់វិសោធនកម្មនៃច្បាប់ស្តីពីគណបក្សនយោបាយថ្មីនេះ គឺជាច្បាប់បង្កើតអោយមានការគំរាមកំហែងធ្ងន់ធ្ងរដល់ការវិវឌ្ឍន៍ដ៏ប្រសើរនៃប្រជាធិបតេយ្យនៅកម្ពុជា ហើយប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្សមួយ ត្រូវតែកើតចេញពីជម្រើសដ៏ពិតប្រាកដរបស់ប្រជាជនកម្ពុជា និងជាតំណាងដ៏ពិតប្រាកដរបស់ពួកគេ។ ម្យ៉ាងទៀត រាល់លក្ខខណ្ឌ និងភាសាដែលបានចែងក្នុងច្បាប់នេះត្រូវបានអ្នកវិភាគរកឃើញថា មានភាពមិនច្បាស់លាស់ ហើយមានភាពអត្តនោម័ត។ អង្គការសង្គមស៊ីវិលបានកត់សំគាល់ឃើញថា "អ្វីដែលគួរអោយចាប់អារម្មណ៍ច្បាប់វិសោធនកម្មច្បាប់នេះបានផ្តល់អំណាចទាំងស្រុង ទៅអោយគណបក្សកាន់អំណាច ដែលអាចអោយគណបក្សនេះធ្វើអ្វីតាមតែអំពើចិត្ត ហើយអាចឈានយកហេតុផលអ្វីក៏បាន ដើម្បីផ្អាក បង្កើតបញ្ហាប្រឈមដល់ប្រជាធិបតេយ្យនៅកម្ពុជា"។[180]

[180] Savi, Khorn "Cambodia signs controversial amendment into law" RFA, 28 July 2017

១៣.១.២ ការបង្ក្រាបជាលក្ខណៈទ្រង់ទ្រាយធំ និងដោយមានការរៀបចំច្បាស់លាស់ទៅលើអង្គការសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ

សញ្ញាណនៃការគំរាមកំហែងដល់ដំណើរការប្រជាធិបតេយ្យនៅក្នុង ក្រោយការបោះឆ្នោត បានកើតឡើងជាមួយនឹងការបើកការស៊ើបអង្កេត និងគំរាមចាត់វិធានការផ្លូវច្បាប់ ប្រឆាំងអង្គការឃ្លាំមើលការបោះឆ្នោត។ នៅដើមខែមិថុនា ក្នុងរយៈពេល ១សប្តាហ៍ បន្ទាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អ្នកនាំពាក្យក្រសួងមហាផ្ទៃបានទទួលស្គាល់នៅចំពោះមុខអ្នកសារព័ត៌មាន និងសាធារណជនថា ការគំរាមចោទប្រកាន់អង្គការសង្គមស៊ីវិល ភ្ជាប់ជាមួយគណបក្សប្រឆាំងរបស់ខ្លួន ដែលត្រូវបានធ្វើឡើងនៅក្រោយការបោះឆ្នោត គឺជាការភាន់ច្រឡំតែប៉ុណ្ណោះ។ អ្នកនាំពាក្យបានលើកឡើងទៀតថា ចេតនារបស់ក្រសួង គឺដើម្បីបន្លាចសង្គមស៊ីវិល "ខ្ញុំគ្រាន់តែចង់និយាយថា ក្រសួងមហាផ្ទៃបានចាប់ផ្តើមបើកការស៊ើបអង្កេត ដោយសារតែពួកយើងចង់គំរាមដល់អង្គការទាំងនោះអោយខ្លាចតែប៉ុណ្ណោះ។ បើមិនធ្វើបែបនេះទេ ពួកគេនឹងប្រព្រឹត្តបំពានច្បាប់"។[181]

ទោះជាយ៉ាងណា នៅក្រោយពេលប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ និងការបដិសេធរបស់អង្គការសង្គមស៊ីវិល លើការវាយតំលៃការបោះឆ្នោត នូវការអោយនិយមន័យពេញលេញនៃការបោះឆ្នោតនេះថាបានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ហើយពួកគេត្រូវបានចោទប្រកាន់ថា ជាសត្រូវជាមួយរដ្ឋាភិបាលកម្ពុជា។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងជាសាធារណៈ ដោយបានចាត់ទុកក្រុមអង្គការសង្គមស៊ីវិលដែលជាអ្នកតាំងខ្លួនថា ជាអ្នកសង្កេតការណ៍បោះឆ្នោតឯករាជ្យ សន្តិភាព អហឹង្សា និងស្របតាមបញ្ញត្តិនៃច្បាប់នោះ គឺពួកគេទាំងនោះកំពុងតែងធ្វើហួសតួនាទីរបស់ខ្លួន ហើយកំពុងតែជំរុញអោយមានបដិវត្តន៍ពណ៌។ គាត់បានថ្លែងទៀតថា "បញ្ហាខ្លះពួកយើងត្រូវតែដោះស្រាយអោយបានឆាប់បំផុត ហើយចំពោះបន្ទប់ស្ថានការណ៍ជាអ្វី ដែលហ៊ានធ្វើអោយលទ្ធផលនៃការបោះឆ្នោតទៅជាល្អក់កករដូចនេះ? តើបន្ទប់ស្ថានការណ៍បានចុះបញ្ជីនៅក្រសួងមហាផ្ទៃឬទេ? តើពួកគេមានសិទ្ធិបង្កើតបន្ទប់ស្ថានការណ៍ទេ ឬក៏បន្ទប់ស្ថានការណ៍បង្កើតឡើងដើម្បីបដិវត្តន៍ពណ៌ទេ? ប្រសិនបើអញ្ចឹងមែន ក្រសួងមហាផ្ទៃត្រូវតែចាត់វិធានការណ៍ជាបន្ទាន់ ដើម្បីប្រឆាំងនឹងពួកគេ ដើម្បីកុំអោយពួកគេយកលេសថា ការបង្កើតបន្ទប់ស្ថានការណ៍ គឺ

[181] Savi, Khorn "Cambodia signs controversial amendment into law" RFA, 28 July 2017.

ដើម្បីសង្កេតការណ៍ការបោះឆ្នោត"។[182] ចំណែកក្រសួងមហាផ្ទៃវិញ បានអោយដឹងថា ខ្លួននឹងបើកការស៊ើបអង្កេត និងធ្វើការសិក្សាទៅលើសង្គមស៊ីវិលនីមួយៗ។[183]

នៅមុនពេលដែលលោកនាយករដ្ឋមន្ត្រីបានព្រមានថា ក្រុមអង្គការសង្គមស៊ីវិលខុសច្បាប់ អង្គការខុមហ្វ្រែល និងអង្គការសង្គមស៊ីវិលជាសមាជិកផ្សេងទៀតដែលបានបង្កើត "បន្ទប់ស្ថានការណ៍ សម្រាប់ឃ្លាំមើលការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១៧" បានចេញសេចក្តីវាយតម្លៃចុងក្រោយរបស់ខ្លួនអំពីដំណើរការរៀបចំការបោះឆ្នោតឃុំ សង្កាត់ឆ្នាំ២០១៧ ដោយចាត់ទុកថា ការបោះឆ្នោតនេះ ខ្វះភាពសេរី និងយុត្តិធម៌ ពីព្រោះកង្វះប្រព័ន្ធតុលាការឯករាជ្យ ការដាក់សម្ពាធនយោបាយ(លើបក្សប្រឆាំង) និងការបំភិតបំភ័យមកលើក្រុមសង្គមស៊ីវិលជាដើម។[184] ខុមហ្វ្រែល និងអង្គការសង្គមស៊ីវិលជាសមាជិកដៃគូ បានកត់សម្គាល់ឃើញថា បញ្ហាជាច្រើនរួមមានទាំងច្បាប់សំខាន់ៗ ដូចជាការធ្វើវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ការចាប់ឥស្សរជនរបស់គណបក្សប្រឆាំងជាច្រើនដាក់ពន្ធនាគារជាដើម។ ដូចគ្នាផងដែរ ហិរញ្ញវត្ថុគណបក្សនយោបាយសម្រាប់ប្រើប្រាស់ចំណាយលើយុទ្ធនាការឃោសនាបោះឆ្នោត ត្រូវបានរកឃើញថាខ្វះតម្លាភាព និងមិនមានបទបញ្ញត្តិចែងនៅក្នុងច្បាប់ស្តីពីការបោះឆ្នោតឃុំ សង្កាត់ ហើយចំណែកឯការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ក៏មិនមានភាពស្មើគ្នាផងដែរ។[185] ខុមហ្វ្រែលបានផ្តល់អនុសាសន៍ចំនួនប្រាំបីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៨ ខាងមុខ ហើយអនុសាសន៍ចំនួន០៣ ចំណុចក្នុងចំណោម៨ចំណុចមានរួមមាន ការលុបបំបាត់ក្នុងបទបញ្ញត្តិមួយចំនួន នៅក្នុងច្បាប់ស្តីពីការបោះឆ្នោត និងច្បាប់វិសោធនកម្មច្បាប់ ច្បាប់ស្តីពីគណបក្សនយោបាយដែលកំពុងមានភាពចម្រូងចម្រាសគ្នា ការស្នើសុំអោយមានការដោះលែងអ្នកទោសនយោបាយ (អ្នកទោសមនសិការ) និងអ្នកការពារសិទ្ធិមនុស្ស និងទាមទារអោយកងកំលាំងប្រដាប់អាវុធ និងមន្ត្រីតុលាការត្រូវរក្សាអព្យាក្រឹត្យ។[186]

ខុមហ្វ្រែល និងអង្គការសង្គមស៊ីវិលដែលជាអតីតជាសមាជិកបន្ទប់ស្ថានការណ៍ គឺជាអង្គការក្រៅរដ្ឋាភិបាលដែលមានប្រវត្តិប្រតិបត្តិការយូរអង្វែង បានរួមចំណែកការជួយសង្គមកម្ពុជា និងសាធារណជន ព្រមទាំងបានសហការគ្នាប្រកបដោយភាពជោគជ័យជាមួយស្ថាប័នរាជរដ្ឋាភិបាលផ្សេងៗ មានដូចជា ស្ថាប័ន គ.

[182] Alex Willemyns and Dara Mech "As CPP marks 66th anniversary, Hun Sen takes opportunity to accuse CNRP" Phnom Penh Post, 29 June 2017.
[183] Tin, Zakariya, Vuthy Tha and Sopheak Chin "Cambodia's Hun Sen pushes for tighter restrictions on political opposition" RFA, 28 June 2017.
[184] Reuters "Cambodia's PM Hun Sen orders probe into rights group" The Indian Express, 28 June 2017
[185] Van, Roeun "Hun Sen bites back at critics of commune election process" Cambodia Daily, 27 June 2017.
[186] See: https://www.comfrel.org/eng/index.php?view=article&catid=188%3Aother&id=821%3Astatement-overall-and-ultimate-assessment-on-commune-council-election-for-the-4th-mandate-restrictions-on-political-freedom-and-limits-to-fairness-but-improved-election-management-&format=pdf&option=com_content

ជ.ប. ដែលក្នុងបំណងជួយពង្រឹង និងកំណែទម្រង់អោយប្រសើរឡើងនូវប្រព័ន្ធរៀបចំការបោះឆ្នោត តាំងពីឆ្នាំ ២០១៣ ដល់ឆ្នាំ២០១៧។ ផ្អែកលើមូលហេតុចោទប្រកាន់នេះ គឺដើម្បីបង្ហាញជាសាធារណៈ ឬសហគមន៍អន្តរជាតិឱ្យឃើញថា អង្គការក្រៅរដ្ឋាភិបាលទាំងនេះ កំពុងតែព្យាយាមធ្វើបដិវត្តពណ៌ ដោយសារពួកគេបានធ្វើអោយមានបរិកាស "ល្អក់កករ" ចំពោះលទ្ធផលនៃការបោះឆ្នោត។[187] ដោយសារតែការរិះគន់របស់អង្គការក្រៅរដ្ឋាភិបាល មុនការបោះឆ្នោត និងក្រោយការបោះឆ្នោតនេះហើយ ទើបលោកនាយករដ្ឋមន្ត្រីបានចាត់ទុកទង្វើររបស់អង្គការសង្គមស៊ីវិលទាំងនេះ មានផែនការសំងាត់ដែលមានការជួយសម្រួលដោយបរទេសផ្តួលរំលំរដ្ឋាភិបាល ហើយលោកបានចោទប្រកាន់ទៀតថា អង្គការសង្គមស៊ីវិលទាំងនេះបានអោយនិយមន័យពីពាក្យថា សេរីភាពរបស់ពួកគេ ដូចជាផ្តល់ឱកាសអោយពួកគេសម្លាប់លោកនាយរដ្ឋមន្ត្រីផ្ទាល់អីចឹង។ ហើយក្រោយមកទៀត គាត់បានគំរាមចាប់ខ្លួនដល់ជនបរទេសណាដែលសង្ស័យថាជា ចារកិច្ច។188 គាត់បានលើកឡើងថា "គណបក្សនយោបាយមួយ និងអង្គការក្រៅរដ្ឋាភិបាលមួយនោះបាននិយាយថា ការបោះឆ្នោតមិនសេរី និងយុត្តិធម៌ ខ្ញុំថាសេរី សម្រាប់ពួកវា គឺសេរី ទាល់តែពួកគេវាចូលទៅសំលាប់ដល់ក្នុងផ្ទះនាយករដ្ឋមន្ត្រី អានុ្ទងបានវាសេរី"។ គាត់បានព្រមានដែរថា ស្ថានភាពនយោបាយបែបនេះ គឺងាយស្រួលនឹងធ្លាក់ចូលសង្គ្រាមស៊ីវិលវិញណាស់ ហើយគាត់បាននិយាយប្រាប់ជា សាធារណជនថា សង្គ្រាមអាចទៅរួច បើទោះបីជាគណបក្សប្រឆាំងគ្មានអាវុធ ឬទាហានក៏ដោយ តែពាក្យសម្តីរបស់ពួកគេអាចធ្វើអោយផ្ទុះសង្គ្រាមបាន។[189] ដោយសំដៅលើលោកឯកអគ្គរដ្ឋទូតអឺរ៉ុបប្រចាំនៅកម្ពុជា លោក George Edgar លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បាននិយាយថា "ឯកឧត្តម George Edgar ឯកឧត្តម និងមនុស្សរបស់ឯកឧត្តម បានផ្តល់មូលនិធិដើម្បីបង្កើតបន្ទប់ស្ថានការណ៍។ បន្ទប់ស្ថានការណ៍នេះ គឺមិនខុសគ្នាជាមួយមូលដ្ឋានបញ្ជាការយោធានោះទេ។ តើហេតុអ្វីបានជាបន្ទប់ស្ថានការណ៍ ត្រូវបានបង្កើតជាលើកដំបូងក្នុងប្រទេសកម្ពុជាទៅវិញ? រដ្ឋមន្ត្រីក្រសួងមហាផ្ទៃរបស់ខ្ញុំនឹងមិនអនុញ្ញាតអោយមានវត្តមានទៀតទេ។"[190] អ្នកសម្របសម្រួលរបស់អង្គការខុមហ្វ្រែលដែលជាអ្នកសង្កេតការណ៍ឃ្លាំមើលការបោះឆ្នោត បានព្យាយាមពន្យល់ដល់ប្រព័ន្ធផ្សព្វផ្សាយនានា

[187] Hul, Reaksmey "Hun Sen uses CPP anniversary to attack election monitors" VOA, 3 July 2017.
[188] Touch, Sokha and Ananth Baliga "Hun Sen slams watchdog for saying commune elections 'not completely free, fair'" Phnom Penh Post, 27 June 2017.
[189] Without showing any connection, he linked CSOs the false news facebook post of an individual that claimed he had died in a plane crash. PM Hun Sen stated, "They come out and wish me dead. Is this still freedom of expression?"
[190] Yang, Chandara "Hun Sen threatens to shut down Cambodia Daily amid tax allegations" RFA, 22 August 2017.

ដើម្បីធានាថា ចេតនារបស់ក្រុមអង្គការសង្គមស៊ីវិលដែលបង្កើតបន្ទប់ស្ថានការណ៍ក្រៅផ្លូវការនេះ គឺមានភាពស្របច្បាប់ និងសន្តិភាព។

នៅត្រឹមសប្តាហ៍ទី១នៃ ខែកក្កដា ក្រសួងមហាផ្ទៃបានបញ្ចប់ការស៊ើបអង្កេតរបស់ខ្លួនទៅលើបន្ទប់ស្ថានការណ៍។ សេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃលើការបើកការស៊ើបអង្កេតនេះ បានបញ្ជាក់យ៉ាងច្បាស់ទៅដល់អង្គការសង្គមស៊ីវិលថា ច្បាប់ស្តីពីការគ្រប់គ្រងសមាគម និងអង្គការក្រៅរដ្ឋាភិបាល នឹងត្រូវយកមកអនុវត្តយ៉ាងតឹងរឹង ហើយរំលាយចោលនូវអង្គការណាដែលច្រើនមានទស្សនៈ ឬជំហរផ្ទុយពីរដ្ឋាភិបាល។ បរិយាកាសនយោបាយមុនការបោះឆ្នោត ក៏ទទួលបានការចាប់អារម្មណ៍ និងរិះគន់ពីអង្គការសហប្រជាតិ ប្រទេស ឬភាគីម្ចាស់ជំនួយ ប្រទេសដែលរីកចំរើនផ្នែកប្រជាធិបតេយ្យ និងអង្គការអន្តរជាតិធំៗផងដែរ។ បើទោះបីជាសង្គមស៊ីវិលមិនមានទំនាក់ទំនងផ្សារភ្ជាប់អ្វីជាមួយគណបក្សនយោបាយមួយចំនួនក៏ដោយ ក៏ក្រសួងមហាផ្ទៃនៅតែចាត់ទុកថា ការរិះគន់របស់សង្គមស៊ីវិលនេះគឺ មិនត្រឹមត្រូវ មានភាពលំអៀង ហើយបានរំលោភទៅលើមាត្រា២៤ ដែលចែងថា "សង្គមស៊ីវិលត្រូវមានភាពអព្យាក្រឹត្យចំពោះគ្រប់គណបក្សនយោបាយទាំងអស់"។ ក្រសួងមហាផ្ទៃបានលើកឡើងទៀតថា ការវាយតម្លៃរបស់ក្រុមអង្គការសង្គមស៊ីវិលនេះគឺ "គ្មានតម្លៃគតិយុត្តិ និងមិនឆ្លុះបញ្ចាំងពីភាពអព្យាក្រឹត្យឡើយ"។ អ្នកនាំពាក្យក្រសួងមហាផ្ទៃបានបញ្ជាក់ថា ការរកឃើញរបស់អង្គការសង្គមស៊ីវិល គឺវាស្រដៀងគ្នាខ្លាំងពេកជាមួយនឹងអ្វីដែលគណបក្សប្រឆាំងបានរកឃើញ ដូច្នេះមានន័យថា ពួកគេបានសហការជាមួយគ្នាធ្វើរឿងនេះ។[191] បើទោះបីជាសង្គមស៊ីវិលបានលើកឡើងអំពីចំណុចវិជ្ជមានដែលប្រសើរឡើងជាងមុន ប៉ុន្តែការរឹតបន្តឹងសេរីភាពដល់គណបក្សនយោបាយ គឺមានរូបភាពធ្ងន់ធ្ងរ។ ក្រសួងមហាផ្ទៃបានលើកទឡ្ហីករណ៍ថា បន្ទប់ស្ថានការណ៍បានរំលោភបំពានច្បាប់ ដោយសារបន្ទប់ស្ថានការណ៍នេះមិនបានចុះឈ្មោះនៅក្រសួងមហាផ្ទៃឡើយ។[192] ចំពោះបន្ទប់ស្ថានការណ៍នេះដែរ ក្រសួងមហាផ្ទៃបានចេញសេចក្តីបង្គាប់ថា នឹងអនុវត្តច្បាប់ស្តីការគ្រប់គ្រងសមាគម និងអង្គការក្រៅរដ្ឋាភិបាល ហើយបានព្រមានអោយអង្គការសង្គមស៊ីវិលទាំងអស់ដាក់ឯកសារតាមការទាមទារដែលមានចែងក្នុងមាត្រា១០ ដែលទាមទារអោយបញ្ជូនរបាយការណ៍គណនេយ្យហិរញ្ញវត្ថុនៅធនាគារ លក្ខន្តិកៈសមាសភាពថ្នាក់ដឹកនាំ ទីតាំងរបស់អង្គការ និងព័ត៌មានស្តីអំពីជំនួយនានាយ៉ាងយូរ៣០ថ្ងៃ មកក្រសួងមហាផ្ទៃ។

[191] Ben, Sokhean and Ben Paviour "NGOs warned to comply with law or face action" Cambodia Daily, 6 July 2017.

[192] Khy, Sovuthy "Ministry declines to meet with poll watchdogs" Khmer Times, 22 August 2017.

ខុមហ្វ្រែល និងនិចហ្វិក ព្រមទាំងដៃគូផ្សេងទៀត បានប្រាប់ពីសកម្មភាពរបស់ខ្លួនទៅកាន់ប្រព័ន្ធផ្សព្វផ្សាយ និងភាគីដែលពាក់ព័ន្ធសំខាន់ៗថា សកម្មភាពរបស់ខ្លួនជាសកម្មភាពអហឹង្សា ស្របតាមច្បាប់ និងមិនពាក់ព័ន្ធនឹងគណបក្សនយោបាយណាមួយឡើយ។ ក្រុមអង្គការសង្គមស៊ីវិលបានសង្កត់ធ្ងន់ថា ពួកគេមិនមានភាពលម្អៀងខាងនយោបាយឡើយ ហើយរាល់សកម្មភាពរបស់ពួកគេ គឺធ្វើត្រឹមត្រូវតាមនិយាមអន្តរជាតិស្តីពីការអនុវត្តន៍ការបោះឆ្នោត តាមបែបលទ្ធិប្រជាធិបតេយ្យនៃប្រទេសដទៃទៀត។[193] នៅក្នុងសេចក្តីថ្លែងការណ៍រួមរបស់សង្គមស៊ីវិលបានអោយដឹងថា បន្ទប់ស្ថានការណ៍មិនមែនជាអង្គការផ្លូវការនោះទេ តែបន្ទប់ស្ថានការណ៍ត្រូវបង្កើតឡើងដោយមានការចូលរួមស្មគ្រចិត្តពី អង្គការសង្គមស៊ីវិលប្រហែល៤០អង្គការសមាគម ដើម្បីសម្រេចនូវគោលបំណង៣ សំខាន់ៗគឺ៖ ទី១ ពង្រឹងលទ្ធភាព និងស្វែងរកកៀងគរមូលនិធិ និងសម្ភារៈ និងធនធាន ដើម្បីគាំទ្រដល់សកម្មភាពបេសកម្មដាក់ពង្រាយអ្នកសង្កេតការណ៍ក្នុងថ្ងៃបោះឆ្នោត ទី២ ចែករំលែកព័ត៌មាន ស្តីពីស្ថានភាពនៃការបោះឆ្នោត និងទី៣ ធ្វើការវាយតម្លៃ ព្រមទាំងធ្វើការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោត អោយស្របតាមគោលការណ៍ជាតិ និងអន្តរជាតិដែលបានកំណត់ ព្រមទាំងស្របតាមបទដ្ឋានអន្តរជាតិដែលកំពុងអនុវត្ត។[194]

អ្នកវិភាគឯករាជ្យ និងអង្គការសង្គមស៊ីវិលជាច្រើនបានសម្តែងនូវការព្រួយបារម្ភ អំពីការអនុវត្តន៍ច្បាប់ស្តីពីការគ្រប់គ្រងសមាគម និងអង្គការក្រៅរដ្ឋាភិបាល ដោយសារតែច្បាប់នេះបានរឹតបន្តឹងការចូលរួមរបស់សង្គមស៊ីវិល និងការហាមឃាត់មិនអោយមានការប្រមូលផ្តុំ។[195] សង្គមស៊ីវិល ដែលបានសហការគ្នាដើម្បីបកស្រាយ និងពន្យល់គោលបំណងរបស់ពួកគេដល់ប្រព័ន្ធផ្សព្វផ្សាយនានាថា ការងាររបស់ពួគេ គឺស្របតាមនិយាមដែលគេនិយមប្រើប្រាស់បែបអន្តរជាតិ សម្រាប់ការអង្កេតការបោះឆ្នោត ព្រមទាំងត្រឹមត្រូវតាមបែបសិទ្ធិមនុស្ស និងច្បាប់អន្តរជាតិ ដែលជាមូលដ្ឋាននៃការសង្កេតការណ៍ និងការសហការរបស់អង្គការសង្គមស៊ីវិល។ សិទ្ធិទាំងនេះ រួមបញ្ចូលទាំងសិទ្ធិពលរដ្ឋ និងសិទ្ធិរបស់ក្រុមអង្គការសង្គមស៊ីវិល ចូលរួមក្នុងដំណើរការសង្កេតការណ៍បោះឆ្នោត និងវាយតម្លៃដំណើរនៃការបោះឆ្នោត។

នៅក្នុងសប្តាហ៍ទី៣ កាលពីខែកក្កដា ខុមហ្វ្រែល និងនិចហ្វិក បានដាក់លិខិតមួយច្បាប់ដែលមានចុះហត្ថលេខាដោយសង្គមស៊ីវិល ដែលជាអតីតសមាជិកបង្កើតបន្ទប់ស្ថានការណ៍ចំនួន២៤អង្គការបានស្នើសុំ

---

[193] Handley, Erin "Election monitors get warning over law on neutrality" Phnom Penh Post, 5 July 2017

[194] See: https://www.comfrel.org/eng/index.php?view=article&catid=188%3Aother&id=822%3Aannouncement-situation-room-for-the-2017-election-purposes-and-activities&format=pdf&option=com_content

[195] Baliga Ananth, and Chheng Niem "NGOs parse LANGO warning" Phnom Penh Post, 7 July 2017.

អោយមានជំនួបជាមួយក្រសួងមហាផ្ទៃដើម្បីធ្វើការពិភាក្សាការងារអំពីបញ្ហាដែលក្រសួងមហាផ្ទៃ បានហាមឃាត់មិនអោយបន្ទប់ស្ថានការណ៍ ធ្វើការប្រមូលផ្តុំគ្នាសង្កេត និងសកម្មភាពដទៃទៀតនៅក្នុងការបោះឆ្នោតឆ្នាំ ២០១៨។ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ហ្វ្រេសញ្ជូវ (**Fresh News**) ដែលលម្អៀងទៅរករដ្ឋាភិបាលបានចុះផ្សាយថា អ្នកនាំពាក្យក្រសួងមហាផ្ទៃបានប្រាប់អោយដឹងថា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានយល់ព្រមជួបជាមួយអ្នកតំណាងក្រុមសង្គមស៊ីវិល។[196] ទោះបីជាបែបនេះក្តី នៅដើមខែសីហា ក្រសួងមហាផ្ទៃបានប្រាប់ប្រព័ន្ធផ្សព្វផ្សាយនេះថា ពួកគាត់ (មន្ត្រីនៃក្រសួងមហាផ្ទៃ) រវល់ណាស់មិនអាចជួបជាមួយអ្នកតំណាងសង្គមស៊ីវិលដែលបានបង្កើតបន្ទប់ស្ថានការណ៍បានឡើយ។[197] ខុមហ្វ្រែល និងអង្គការសង្គមស៊ីវិលដែលជាអង្គការដៃគូបានប្រាប់ទៅកាន់ភាគីដែលពាក់ព័ន្ធសំខាន់ៗថា ពួកគេនឹងគោរពតាមការសម្រេចរបស់ក្រសួងមហាផ្ទៃ។[198]

ករណីបង្ហាញអំពីការរំលោភទៅលើច្បាប់ ស្តីពីការគ្រប់គ្រងសមាគម និងអង្គការក្រៅរដ្ឋាភិបាលដោយសារច្បាប់នេះបានចែងអំពីភាពស្របច្បាប់នៃការបញ្ចេញមតិ របស់អង្គការសង្គមស៊ីវិល ដោយពួកគេអាចធ្វើការវាយតម្លៃ និងការពន្យល់អំពីការព្រួយបារម្ភលើស្ថានភាពនយោបាយ ប៉ុន្តែជាអកុសលពួកគេត្រូវបានអាជ្ញាធររឹតបន្តឹង។ អង្គការសិទ្ធិមនុស្សក្នុងតំបន់បានលើកឡើងជំទាស់នឹងរដ្ឋាភិបាល ហើយបានរិះគន់ថា រដ្ឋាភិបាលបានព្យាយាមបំផ្លាញ ឬធ្វើអោយប៉ះពាល់ដល់សង្គមស៊ីវិល ដោយអង្គការមួយនេះបានពន្យល់ថា សង្គមស៊ីវិលអាចជួយអោយរដ្ឋមួយ មានការលូតលាស់រីកចំរើន និងមានភាពរឹងមាំដែលវាជាបំណងប្រាថ្នារបស់រដ្ឋនោះ ដើម្បីអោយភាពចម្រុងចម្រើន (វិបុលភាព) ដោយផ្អែកទៅលើនីតិរដ្ឋ និងអភិបាលកិច្ចដែលមានគណនេយ្យភាពត្រឹមត្រូវ។[199] ពួកគេបានសន្និដ្ឋានថា បទបញ្ជាដែលចេញដោយក្រសួងមហាផ្ទៃដោយអោយក្រុមសង្គមស៊ីវិលឈប់បង្កើតបន្ទប់ស្ថានការណ៍ "តាមពិតច្បាប់ស្តីពីការគ្រប់គ្រងសមាគម និងអង្គការក្រៅរដ្ឋាភិបាលនេះ បានក្លាយឧបករណ៍ដ៏ស្របច្បាប់សម្រាប់យុទ្ធនាការបស់រដ្ឋាភិបាល ដើម្បីទប់ស្កាត់មិនអោយក្រុមសង្គមស៊ីវិលហ៊ានធ្វើការរិះគន់ និងធ្វើសកម្មភាពផ្សេងៗ ក្នុងការបោះឆ្នោតខាងមុខឆាប់ៗ តែប៉ុណ្ណោះ"។[200] នៅក្នុងការវាយតម្លៃពីលទ្ធនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់កាលពីឆ្នាំ ២០១៧ បណ្តាញសម្រាប់ការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅអាស៊ីអាគ្នេយ៍បានកត់សម្គាល់ឃើញថា ការបើកការស៊ើបអង្កេត និងការដាក់ទណ្ឌកម្មរបស់ក្រសួងមហាផ្ទៃមកលើអង្គការសង្គមស៊ីវិល គឺជាឧបសគ្គដល់សកម្មភាពស្របច្បាប់របស់សង្គមស៊ីវិល សកម្មភាពក្នុងកិច្ចការឃ្លាំមើលពីដំណើរការនៃការបោះឆ្នោ

[196] Ben, Sokhean "Situation Room seeks meeting with minister" Cambodia Daily, 21 July 2017.
[197] Khy, Sovuthy "Ministry declines to meet with poll watchdogs" Khmer Times, 22 August 2017.
[198] Khuon, Narim "Election watchdog group banned" Khmer Times, 25 July 2017.
[199] See the comments by Amnesty International and Human Rights Watch. Ben, Sokhean and Ben Paviour "NGOs warned to comply with law or face action" Cambodia Daily, 6 July 2017.
[200] "Cambodia: Revoke ban on election monitors" Human Rights Watch, 9 July 2017.

ត។[201] ក្នុងពេលដំណាលគ្នានេះដែរ ក្រុមអង្គការសង្គមស៊ីវិលក៏បានសង្កត់ធ្ងន់ អំពីកិច្ចសហប្រតិបត្តិការ និងការចូលរួមបង្កើតគោលនយោបាយជាមួយរដ្ឋាភិបាល ដែលជាអ្នកបង្កើតគោលនយោបាយជាតិផងដែរ។ អង្គការសង្គមស៊ីវិលបានបញ្ជាក់ច្រាប់ប្រព័ន្ធផ្សព្វផ្សាយ និងភាគីដែលពាក់ព័ន្ធដទៃទៀតថា ពួកគេនឹងធ្វើតាមដំណើរនីមួយៗ ហើយនឹងរៀបចំឯកសារ និងរបាយការណ៍ទាំងអស់ដើម្បីដាក់ជូនក្រសួងមហាផ្ទៃ ដើម្បីអោយស្របតាមបទបញ្ញត្តិនៃច្បាប់នានាដែលក្រសួងតម្រូវ។[202]

ការរឹតបន្តឹងពីការជួបជុំនៅតាមទីសាធារណៈ និងការដាក់ទណ្ឌកម្មលើអង្គការសង្គមស៊ីវិល និងការបិទទ្វារវិទ្យាស្ថានជាតិប្រជាធិបតេយ្យ(NDI)។ ការិយាល័យវិទ្យាស្ថានប្រជាធិបតេយ្យបានបិទទ្វារដែលវិទ្យាស្ថានមួយនេះបានដំណើរអស់រយៈពេល២៥ឆ្នាំមកហើយ បន្ទាប់ពីវិទ្យាស្ថានមួយនេះត្រូវបានចោទប្រកាន់ថាបានផ្តល់យុទ្ធសាស្ត្រទៅអោយគណបក្សប្រឆាំងដើម្បីផ្តួលរំលំគណបក្សកាន់អំណាច។[203] នៅក្នុងថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ ក្រសួងកិច្ចការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបញ្ជាអោយបិទវិទ្យាស្ថាន NDI ហើយបុគ្គលិកបរទេសទាំងអស់ត្រូវចាកចេញពីកម្ពុជាក្នុងរយៈពេល៧ថ្ងៃ។

សេចក្តីថ្លែងការណ៍របស់ក្រសួងបានអះអាងថា NDI ត្រូវបានរដ្ឋាភិបាលបញ្ជាអោយចាកចេញពីប្រទេសហើយ ដោយសារតែមិនបានចុះបញ្ជីជាមួយក្រសួងការបរទេស។ ការចុះបញ្ជីអង្គការក្រៅរដ្ឋាភិបាលទាំងអស់ គឺធ្វើតាមការទាមទារច្បាប់ ស្តីការគ្រប់គ្រងសមាគម និងអង្គការក្រៅរដ្ឋាភិបាល ដែលត្រូវបានអនុម័តនៅឆ្នាំ២០១៥ ចំណែកឯ NDI បានដាក់សំណុំបែបបទរបស់ខ្លួនកាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦។ រាជរដ្ឋាភិបាលកម្ពុជាបានលើកឡើងថា "ដោយក្រសួងមិនទាន់បានសម្រេចទៅលើទម្រង់បែបបទរបស់ NDI ថាអោយបន្តសកម្មភាព ឬមិនអោយបន្តសកម្មភាពនៅឡើយផង ស្រាប់តែ NDI បានបន្តអនុវត្តសកម្មភាពរបស់ខ្លួនដោយមិនខ្លាចរអារអ្វីសោះ។[204] NDI ត្រូវបានចោទប្រកាន់ដោយរំលោភបំពានលើមាត្រា៣៤ នៃច្បាប់ស្តីពីការគ្រប់គ្រងសមាគម និងអង្គការក្រៅរដ្ឋាភិបាល ដែលបានចែងថា អង្គការក្រៅរដ្ឋាភិបាលអាចត្រូវបានបិទទ្វារ ប្រសិនបើមិនបានចុះបញ្ជី ឬទទួលបានអនុស្សារណៈយោគយល់ទេនោះ។ ហើយក្រសួងបានធ្វើការអះអាងទៀតថា NDI បានរំលោភបំពានច្បាប់ពន្ធដារ ដោយសារមិនបានចុះបញ្ជីនៃការជួលបុគ្គលិកក្នុងរយៈពេល១៥ថ្ងៃយ៉ាងយូរ ដោយគិតចាប់ពីពេលចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួន។[205]

[201] Khy, Sovuthy "Ministry declines to meet with poll watchdogs" Khmer Times, 22 August 2017.
[202] Khuon, Narim "NGOs to meet deadline" Khmer Times, 22 August 2017.
[203] Khuon, Narim "Government to close NDI, expel foreign staff" Khmer Times, 23 August 2017
[204] Khuon, Narim "US poll body told: Get out" Khmer Times, 24 August 2017
[205] Cambodia orders U.S.-backed National Democratic Institute to leave country" Xinhua, 23 August 2017.

តាមការសង្កេតបានអោយដឹងថា NDI បានធ្វើប្រតិបត្តិការដោយមានគណនេយ្យភាព និងមានតម្លាភាព ហើយមិនលំអៀង។ ការអង្កេតនេះ បង្ហាញអោយឃើញកាន់តែច្បាស់ថែមទៀតគឺ នៅក្នុងសេចក្តីថ្លែងការណ៍របស់ប្រធាន NDI នៅកម្ពុជាថា ក្នុងអំឡុងពេលជាច្រើនខែមកនេះ មានខែមករា កុម្ភៈ មីនា និងខែមេសា ឆ្នាំ២០១៧ NDI បានផ្តល់វគ្គបណ្តុះបណ្តាលដល់គណបក្សប្រជាជន គណបក្សសង្គ្រោះជាតិ និងគណបក្ស ០៣ផ្សេងទៀត អំពីប្រធានបទ «ការពង្រឹងសមត្ថភាព របស់គណបក្ស»។[206] នៅក្នុងវគ្គបណ្តុះបណ្តាលនេះ NDI បានផ្តល់ឱកាសអោយគណបក្សទាំងអស់ ប្រាប់ពីបញ្ហាដែលពួកគេបានជួបប្រទះ ហើយត្រូវការដំណោះស្រាយពីការចូលរួមវគ្គបណ្តុះបណ្តាលនេះ។ ពួកយើងអាចប្រាប់អ្នក (ក្រសួងមហាផ្ទៃ)អំពីគណបក្សទាំងអស់យ៉ាងលំអិត ដែលបានចូលរួមវគ្គបណ្តុះបណ្តាល។ NDI ជាអង្គការមិនចំណុះអោយគណបក្សណាមួយឡើយ។ កិច្ចការរបស់ NDI គឺផ្តោតលើការពង្រឹងដំណើរលទ្ធិប្រជាធិបតេយ្យ ដែលជាអត្ថប្រយោជន៍សម្រាប់បេក្ខជនឈរឈ្មោះបោះឆ្នោត និងអ្នកបោះឆ្នោតតែប៉ុណ្ណោះ។[207]

លើសពីនេះទៀត ក្រៅពីបានផ្តល់ការបណ្តុះបណ្តាលដល់គណបក្សប្រឆាំងនានា កាលពីឆ្នាំ២០១៧ NDI បានរួមការងារជាមួយគណបក្សប្រជាជនកម្ពុជា ដើម្បីគាំទ្រអោយទទួលបានការបំពាក់បំប៉នសមត្ថភាព និងការកសាងសមត្ថភាពរបស់គណបក្សទាក់ទងនឹងទំនាក់ទំនងខាងក្រៅយុទ្ធសាស្ត្រនៃការសង្កេតការបោះឆ្នោត និងការចុះឈ្មោះរបស់អ្នកបោះឆ្នោត។[208]

សេចក្តីថ្លែងការណ៍របស់ស្ថានទូតសហរដ្ឋអាមេរិកបានអោយដឹងថា NDI បានចុះអនុស្សារណៈយោគយល់ស្របច្បាប់ជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងធ្លាប់មានប្រវត្តិសហការជាមួយជាមួយ គ.ជ.ប និងក្រសួងមហាផ្ទៃប្រកបដោយភាពជោគជ័យ ហើយចំពោះគោលបំណងរបស់ NDI ត្រូវបានកំណត់ដើម្បីជួយធានាគណនេយ្យភាពរបស់រដ្ឋាភិបាល និងដំណើរការនៃការចូលរួមក្នុងរបបប្រជាធិបតេយ្យប្រកបដោយអត្ថន័យពេញលេញ។[209] NDI គ្រប់គ្រងគម្រោង៤ឆ្នាំ ដែលត្រូវចំណាយអស់ទឹកប្រាក់ចំនួន ៨.៥លានដុល្លារ គម្រោង៤ឆ្នាំគឺ កំណែទម្រង់លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ដែលមានគោលបំណងគាំទ្រដល់ការប្រកួតប្រជែងផ្នែកនយោបាយ និងជួយពង្រឹងគណនេយ្យភាពរបស់រដ្ឋាភិបាលអោយមានភាពប្រសើរឡើង។ នៅលើគេហទំព័ររបស់អង្គការ NDI បានអោយដឹងថា "គណបក្សប្រជាជនកម្ពុជា នៅតែបន្តគ្រប់គ្រងអំណាចអស់រយៈពេលជាង៣០ឆ្នាំ ដោយមេដឹកនាំដដែលៗ"។ ប្រជាពលរដ្ឋត្រូវបានកំរិត រារាំង មិនអោយចូលរួមជាមួយសកម្មភាពមន្ត្រីគណបក្សប្រឆាំងដែលជាប់ឆ្នោត ហើយការបាត់បង់ទំនុកចិត្តរវាងសង្គមស៊ីវិល

[206] NDI replies but fails to answer questions", Khmer Times, 22 August 2017.
[207] "NDI replies but fails to answer questions", Khmer Times, 22 August 2017.
[208] Khuon, Narim "US poll body told: Get out" Khmer Times, 24 August 2017.
[209] Khuon, Narim "US poll body told: Get out" Khmer Times, 24 August 2017.

និងរដ្ឋាភិបាល គឺជាឧបសគ្គរារាំងមិនអោយមានការចូលរួមតាមបែបប្រជាធិបតេយ្យ។[210] ក្នុងការឆ្លើយតបទៅនឹងកង្វល់របស់គណបក្សសង្គ្រោះជាតិ ដែលព្រួយបារម្ភអំពីផលប៉ះពាល់ ទៅលើការបោះឆ្នោតដែលមានភាពយុត្តិធម៌នោះ ហើយបានធ្វើអោយសាធារណជនមានទំនុកចិត្តតិចណាស់ ក្នុងដំណើរការនៃការបោះឆ្នោត។ អ្នកនាំពាក្យនៃគណបក្សកាន់អំណាចបានច្រានចោលពីការព្រួយបារម្ភនេះ គាត់បានលើកឡើងថា «ពួកយើងមិនអាចធ្វើការព្យាករណ៍ទុកអំពីការបោះឆ្នោតនៅខាងមុខបានទេ ថាការបោះឆ្នោតនោះមិនមានភាពសេរី និងយុត្តិធម៌ ឬអត់នោះទេ»។[211]

កាសែតឌឹខេមបូឌាដេលីបានបិទទ្វារនៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៧ បន្ទាប់ពីប្រតិបត្តិការ២៤ ឆ្នាំរបស់ខ្លួនជាសំឡេងឯករាជ្យមួយក្នុងការគាំទ្រដល់សេរីភាពសារព័ត៌មានដ៏មានឥទ្ធិពល និងបានដើរតួយ៉ាងសំខាន់ក្នុងការឃ្លាំមើលរបស់សង្គមប្រជាធិបតេយ្យ។ កាលពីដើមខែសីហានេះ កាសែតឌឹខេមបូឌាដេលីត្រូវបានគេជូនដំណឹងថា មិនបានបំពេញកាតព្វកិច្ចបង់ពន្ធជូនរដ្ឋ។ នៅថ្ងៃជាមួយគ្នានេះដែរ បញ្ហាពន្ធលើប្រាក់បៀវត្សរបស់អង្គការសង្គមស៊ីវិល ត្រូវបានគេយកទៅពិភាក្សានៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រី (ថ្ងៃទី៤ ខែមេសា) ។ អគ្គនាយកដ្ឋានពន្ធដារ (នាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) បានចេញលិខិតមួយច្បាប់ទៅកាសែតខេមបូឌាដេលី អំពីការជំពាក់ពន្ធរដ្ឋជាង ៦លានដុល្លារ លើអាជីវកម្មរបស់ខ្លួនដែលដំណឹងនេះត្រូវបានលេចលើចេញពីកាសែតដែលស្និទ្ធនឹងរដ្ឋាភិបាលគឺ កាសែត Fresh News។ លិខិតមួយត្រូវបានបែកធ្លាយតាមរយៈគណនីហ្វេសប៊ុករបស់តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ[212] ដែលត្រូវបានគេចូលទៅគ្រប់គ្រងហើយត្រូវបានចែកចាយបន្តតាមរយៈ Fresh News។ កំណត់ហេតុរបស់កិច្ចប្រជុំមួយដែលទទួលបានពីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យមួយបានសរសេរថា ការស៊ើបអង្កេតពាក់ព័ន្ធរឿងពន្ធអាករ នឹងអនុវត្តទៅលើក្រុមអង្គការក្រៅរដ្ឋាភិបាលដែលមិនរកប្រាក់ចំណេញ និងអាជីវកម្មឯកជន។ អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រីបាននិយាយថា "អង្គការក្រៅរដ្ឋាភិបាលមួយចំនួនមិនបានបំពេញកាតព្វកិច្ចបង់ពន្ធទេ ហើយអ្នកដែលរកស៊ីទាំងអស់ គឺត្រូវតែបង់ពន្ធ។"[213]

---

[210] Beech, Hannah "Cambodia orders expulsion of foreign staff members with American nonprofit" New York Times, 23 August 2017

[211] Khuon, Narim "US poll body told: Get out" Khmer Times, 24 August 2017.

[212] Lost control of the account when it was hacked in April, at time when several opposition lawmakers were hacked.

[213] Hang, Sokunthea and Ben Paviour "Government digs into tax returns of NGOs, Cambodia Daily" Cambodia Daily, 7 August 2017. "All Cambodian and foreign employees who make more than 1 million riel a month, or about $250, are liable to pay salary tax, according to the tax department's website. But some salaries are exempt from the tax, according to a 2015 booklet prepared by international professional services firm PricewaterhouseCoopers, including the salaries of lawmakers and senators as well as 'certain employees of approved diplomatic, international and aid organizations.'"

លោកនាយករដ្ឋមន្ត្រីបានចោទប្រកាន់ជាលាយលក្ខណ៍អក្សរថា "ចោរ" និងបានច្រានចោលការរិះគន់ដែលអះអាងថា ករណីនេះគឺជាហេតុផលនយោបាយ។ ក្រុមអ្នកវិភាគឯករាជ្យបានបង្ហាញថា អាជីវកម្មឯកជនទាំងអស់គួរតែបង់ពន្ធតាមច្បាប់ ប៉ុន្តែបើការបង់ពន្ធនេះសំដៅតែលើការបង្ក្រាបសំឡេងសង្គមស៊ីវិលដែលរិះគន់រដ្ឋាភិបាលនោះ គឺការអនុវត្តន៍គោលនយោបាយរបស់រដ្ឋាភិបាលមានភាពលំអៀង និងអយុត្តិធម៌។ ម្ចាស់ និងអ្នកបោះពុម្ពផ្សាយកាសែត បានកត់សម្គាល់ថាក្នុងករណីនេះគឺជាចំណាត់ការមិនទៀងទាត់ "ប្រសិនបើនាយកដ្ឋានពន្ធដារ ជឿជាក់ថា ខេមបូឌាដេលីបានជំពាក់ពន្ធរដ្ឋពិតមែន ពួកគេត្រូវប្រាប់ថា មកពីមូលហេតុអ្វី ឬឲ្យយើងផ្តល់ព័ត៌មានដល់ពួកគេវិញ។" រហូតមកទល់ពេលនេះ មិនទាន់មានការឆ្លើយតបណាមួយនៅឡើយទេ។ នាយកដ្ឋានពន្ធដារទាមទារអោយបង់ពន្ធ ៦.១លានដុល្លារ ដោយគ្មានបង្ហាញភស្តុតាងណាមួយ ហើយថែមទាំងកំណត់រយៈពេល៣០ថ្ងៃ សំរាប់ការឆ្លើយតបថែមទៀត។ ជាទូទៅ នៅពេលក្រុមហ៊ុន ឬបុគ្គលណាម្នាក់មិនយល់ស្របពីដំណើរការចាប់ផ្តើមការធ្វើសវនកម្មនោះ នៅពេលនោះគឺត្រូវមានការត្រួតពិនិត្យ និងសើរើផ្នែកហិរញ្ញវត្ថុឡើងវិញ។[214]

ម្ចាស់កាសែតដេលីបាននិយាយទៅកាន់ប្រព័ន្ធផ្សព្វផ្សាយជាតិថា "ប្រសិនបើ (លោកនាយករដ្ឋមន្ត្រី) ចង់អោយប្រជាពលរដ្ឋនៅកម្ពុជា មានទំនុកចិត្តលើប្រព័ន្ធពន្ធរបស់ខ្លួននោះ គាត់ត្រូវតែបង្ហាញថា មន្ត្រីនៅក្នុងនាយកដ្ឋានពន្ធដារបានអនុវត្តទៅតាមច្បាប់ និងធ្វើការដោយស្មើភាព។ លោក ហ៊ុន សែន អាចបញ្ឈប់ការបិទកាសែតឌឺខេមបូឌាដេលី ហើយអនុញ្ញាតឲ្យដំណើរការដោយស្របច្បាប់។ ប្រសិនបើដំណើរការចុងក្រោយត្រូវបានគេរកឃើញថា ជំពាក់ពន្ធពិតមែន យើងនឹងបង់ប្រាក់ជូន។[215] ទោះជាយ៉ាងណាក៏ដោយ គាត់ត្រូវតែអនុញ្ញាតឱ្យយើងមានសិទ្ធិក្នុងដំណើរនោះជាមុនសិនដែរ។ វាជាការសំខាន់ណាស់ដែលនាយកដ្ឋានពន្ធដារកត់ចំណាំថា ការពិនិត្យ និងវាយតម្លៃដែលបានដាក់ជូនជារៀងរាល់ឆ្នាំនោះថា ពន្ធណាដែលមិនបង់តាំងពីឆ្នាំទីមួយ។ ម្ចាស់កាសែតដេលីក៏បានលើកដែរថា ការគណនាពន្ធនោះគួរតែពិចារណា ត្រឡប់ទៅជាការងារសម្បរសធម៌ ឬក៏ជាមូលនិធិវិញទៅ។[216] ក្នុងរយៈពេលតាំងពីដំណើរការអាជីវកម្មមក ខេមបូឌារដេលីបានបរិចាគទឹកប្រាក់ប្រមាណ៣៩លាន ដុល្លារទៅក្នុងការងារសម្បរសធម៌។ ដេលីក៏បានធ្វើជាសំឡេងមួយរបស់កម្ពុជាទៅកាន់ពិភពលោកផងដែរ ព្រោះវាជាមធ្យោបាយមួយនាំឲ្យមនុស្សគ្រប់គ្នាទាំងអស់ ទទួលបានព័ត៌មាន និងតាមដាននូវព្រឹត្តិការណ៍ដែលបានកើតឡើងនៅកម្ពុជា។ ប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិក៏បានកត់សម្គាល់ផងដែរថា កាសែតឌឺខេមបូឌារដេលីត្រូវទទួលរងតិះទៀនពីរដ្ឋាភិបាលកម្ពុជាតាំងពីឆ្នាំ១៩៩៣មកម្ល៉ះ ដោយសារតែដេលីផ្សាយពីព័ត៌មានពីការរំលោភសិទ្ធិមនុស្ស ការបំផ្លាញធនធានបរិស្ថាន និងបញ្ហាអំពើពុករលួយជាដើម។[217] ជាពិសេសមានការបង្ហាញមួយដែរថា ប្រព័ន្ធផ្សព្វផ្សាយមួយចំនួននឹងត្រូវបានស្ងប់

[214] Khuon, Narim "PM labels critical newspaper a thief" Khmer Times, 23 August 2017.
[215] Yang, Chandara "Hun Sen threatens to shut down Cambodia Daily amid tax allegations" RFA, 22 August 2017.
[216] Sel, San "Cambodia Daily shuts down amid government threat of closure for tax debt" RFA, 5 September 2017.
[217] "Cambodia PM orders English-language newspaper to pay taxes or close" Reuters, 22 August 2017; Steger, Isabella "Cambodia's leader has told a newspaper to pay a $6.3 million tax bill or shut down" Quartz, 24 August 2017; Wright, George "Cambodia's crumbling democracy" The Diplomat, 16 September 2017; "'Cambodia

ស្ងាត់បន្ទាប់ពីត្រូវបានគេលាបព័ណ៌ថា ជាព័ត៌មានក្លែងក្លាយ ដែលបានកើតឡើងនៅដើមខែកុម្ភៈ។[218] ការចុះផ្សាយចុងក្រោយរបស់កាសែតខេមបូឌាដេលីបានគូសបញ្ជាក់ថា រដ្ឋាភិបាលគណបក្សប្រជាជន គឺបាននឹងកំពុងប្រើរបបផ្តាច់ការច្បាស់ណាស់ ពីការរំលោភលើលទ្ធិប្រជាធិបតេយ្យ និងការប្រមូលផ្តុំអំណាចនៅក្នុងអង្គការប្រតិបត្តិ។ ឌឺខេមបូឌារដេលី ត្រូវបានបង្គាប់ឱ្យបង់ពន្ធ ឬក៏បិទកាសែតដេលី ក្រោយមកនាយកដ្ឋានពន្ធដារបានអះអាងថា ទោះបីជាបិទទ្វារក៏ដោយ ក៏ត្រូវតែទទួលខុសត្រូវលើការបង់ពន្ធដែរ។ រដ្ឋាភិបាលបានប្រើអំណាចដ៏គួរឲ្យខ្លាចមួយ គឺឲ្យប្រធាននៃនាយកដ្ឋានពន្ធដារចេញ "ការស្នើសុំ" ការបញ្ជាក់ពីអន្តោប្រវេសន៍ដើម្បីធានាអោយប្រាកដថា ម្ចាស់ដេលីមិនបានចាកចេញពីកម្ពុជា។[219] "អគ្គនាយកដ្ឋានពន្ធដារចង់ស្នើសុំកិច្ចសហប្រតិបត្តិការខ្ពស់ពីអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដោយចាត់វិធានការហាមមិនឱ្យមានការធ្វើដំណើរចាកចេញពីកម្ពុជារបស់លោកស្រីឌូបាវ៉ាគ្រីសសីស្ទេ និងលោក ឌូលក្លាសអ៊ីស្ទីឡេ ជាម្ចាស់កាសែតដេលី ដើម្បីដាក់បន្ទុកលើពួកគេ និងបង្ខំឲ្យពួកគេទាំងពីរនាក់មកដោះស្រាយបំណុលពន្ធដារ។[220]

នីតិវិធីត្រឹមត្រូវ តម្លាភាព នីតិរដ្ឋ និងការជឿទុកចិត្តពីសាធារណជន នឹងនាំឱ្យមានការធ្វើសវនកម្មមួយពេញលេញ និងអាចពន្យល់ទៅស្ថាប័នសារព័ត៌មាន អំពីរបៀបគណនាពន្ធ និងរយៈពេលនៃការរៀបចំឯកសារ។ តាមការគណនា គន់គូរពន្ធរបស់ដេលី គឺខុសគ្នាស្រឡះពីនាយកដ្ឋានពន្ធដារ។ ដោយសារការគណនាពន្ធមានភាពខុសគ្នានេះហើយ ត្រូវបានគេសន្និដ្ឋានថា ការគណនាលើពន្ធរបស់រដ្ឋាភិបាលមិនត្រឹមត្រូវ និងបានរំលោភលើបទបញ្ញាត្តិដែលបានចែង។ លិខិតរបស់ម្ចាស់កាសែតខេមបូឌាដេលីមួយ បានផ្ញើទៅកាន់នាយកដ្ឋានពន្ធដារ បានរំលឹកដល់អ្នកទាំង អ្នកធ្វើនយោបាយ និងសាធារណជនថា សិទ្ធិនិងការទទួលខុសត្រូវចំពោះតម្លាភាពត្រូវបង្ហាញជាសាធារណៈ និងគណនេយ្យភាពលើភស្តុតាង គឺនាំអោយមានការសវនកម្មមួយដែលពេញលេញ។[221] ទស្សនៈរបស់ប្រធានក្លឹបអ្នកកាសែតកម្ពុជា[222] បានលើកឡើងថា បញ្ហានេះមិនមែនជាហេតុផលនយោបាយនោះទេ ប៉ុន្តែជាឧទាហរណ៍មួយនៃការអនុវត្តន៍ច្បាប់ ដែលខកខានមិនបានធ្វើការពិនិត្យឡើងវិញនូវអាជីវកម្មដែលមិនស្របច្បាប់ និងធានាការចចារមួយដែលល្អប្រសើរឡើង។ អង្គការសង្គមស៊ីវិលគាំទ្រយ៉ាងពេញទំហឹងចំពោះការអនុវត្តន៍ច្បាប់ពន្ធដារ សម្រាប់អង្គការស្ថាប័នទាំងអស់។ ហើយ

Daily' newspaper may be shut over taxes" Bangkok Post, 21 August 2017. For example: "In February the Cambodia Daily reported on an academic paper that alleged Hun Sen's rule was a "personalist dictatorship". A week ago it published an investigation revealing that top staff members at Cambodia's largest human rights organisations were suffering "intensifying levels of harassment, surveillance, intimidation and threats" before the general election." Holmes, Oliver "Cambodia threatens purge of critical media and US charity" The Guardian, 23 August 2017.

[218] Gallo, William "Cambodia threatens media outlets, using Trump as justification" VOA, 27 February 2017.

[219] Khuon, Narim "Daily publishers banned from leaving the country" Khmer Times, 5 September 2017.

[220] Sel, San "Cambodia Daily shuts down amid government threat of closure for tax debt" RFA, 5 September 2017.

[221] Baliga, Ananth "Daily calls or 'true audit' as Tax Department refutes challenges" Phnom Penh Post, 24 August 2017.

[222] Yeang, Sothearin "Shuttered Cambodian radio stations appeal to Hun Sen for reinstatement" RFA, 28 August 2017.

វាក៏ជាមូលដ្ឋានដើម្បីសំរេចបាននូវការអនុវត្តន៍ច្បាប់ពន្ធដារ ឲ្យស្របទៅតាមគោលការណ៍នីតិរដ្ឋ និងភាពស្មើគ្នាដែលមានចែងក្នុងរដ្ឋធម្មនុញ្ញផងដែរ។

លិខិតមួយចុះថ្ងៃទី១១ ខែសីហា របស់នាយកដ្ឋានពន្ធដារស្នើសុំទៅក្រសួងព័ត៌មាន អោយដាក់ទណ្ឌកម្មលើវិទ្យុអាស៊ីសេរី និងវិទ្យុវីអូអេ សម្រាប់ការសងពន្ធដែលបានជំពាក់ និងមិនត្រូវបានផ្តល់អាជ្ញាប័ណ្ណ។ នាយកដ្ឋានពន្ធដារបានអះអាងថា វិទ្យុទាំងពីរនោះមិនបានបង់ពន្ធ ទាំងស្ថាប័ន និងប្រាក់ខែបុគ្គលិក។[223] ការឆ្លើយតបដំបូងរបស់រដ្ឋមន្ត្រីក្រសួងព័ត៌មាន គឺថាពន្ធត្រូវបានបង់ដោយស្ថានីយវិទ្យុដែលជួលម៉ោងផ្សាយមិនមែនជាអ្នកផលិតកម្មវិធី។ យ៉ាងណាក៏ដោយអ្នកនាំពាក្យក្រសួងព័ត៌មានបានឲ្យដឹងថា វិទ្យុទាំងពីរនេះត្រូវតែបង់ពន្ធ។ នាយកដ្ឋានពន្ធដារបានជូនដំណឹងទៅក្រសួងព័ត៌មានថា ព័ត៌មានទាក់ទងនឹងការជួលម៉ោងផ្សាយពីក្រសួងត្រូវបានពិនិត្យឡើងវិញ ប៉ុន្តែវិទ្យុអាស៊ីសេរី និងវីអូអេ បានបំពានលើច្បាប់ពន្ធដារ។ លិខិតនោះបានកត់សម្គាល់ថា មិនមានប្រព័ន្ធផ្សព្វផ្សាយណាមួយមានប្រអប់បញ្ជូនទូរលេខផ្ទាល់ខ្លួនទេ ទាំងដំណើរការដោយការជួលម៉ោងផ្សាយ ប៉ុន្តែបានបង្ខំឱ្យក្រសួងព័ត៌មានចាត់វិធានការ ប្រសិនបើវិទ្យុទាំងពីរនេះមិនសហការ។[224]

នៅចុងខែសីហា ស្ថានីយ៍វិទ្យុចំនួន ១៩ត្រូវបានបិទ ម៉្យាងវិញទៀតក្រសួងមហាផ្ទៃបានអះអាងថា ការចោទប្រកាន់ដែលបិទទ្វារវិទ្យុ គឺជាការខកខាន ឬធ្វើប្រហែសមិនបានស្នើសុំការអនុញ្ញាតពីក្រសួង។[225] ក្រសួងមហាផ្ទៃបានលើកឡើងពីការបំពានរបស់ពួកគេដែលបានផ្សាយទៅខាងក្រៅ ដោយគ្មានការអនុញ្ញាតពីក្រសួងពាក់ព័ន្ធ។[226] មួយវិញទៀតរដ្ឋមន្ត្រីបានបញ្ជាក់យ៉ាងច្បាស់ថា គោលនយោបាយឆ្លើយតបទៅនឹងបញ្ជារបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ថា ការបោះឆ្នោតឆ្នាំ ២០១៣ មិនត្រូវឲ្យកើតមានម្តងទៀតនោះ ដោយធានាថា សេចក្តីរាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយ មិនបង្កឱ្យមានញុះញង់ខ្វែងយោបល់គ្នាឡើយ។[227] អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រី បានដាក់ឈ្មោះឲ្យវិទ្យុសំឡេងប្រជាធិបតេយ្យ VOD ថា ជា "ភ្នាក់ងារបរទេស" ដែលស្ថិតក្នុងបញ្ជីជាអ្នកទទួលយកជំនួយពីបរទេស និងចូលរួមជាមួយអង្គការសង្គមស៊ីវិលសម្រាប់ការត្រួតពិនិត្យការបោះឆ្នោត ហៅថា "បន្ទប់ស្ថានភាព" (សូមមើលខាងលើ)។ [228] ក្រសួងព័ត៌មានបានថ្លែងទៅកាន់ប្រព័ន្ធផ្សព្វផ្សាយថា បទល្មើសទាក់ទងការផ្សព្វផ្សាយរបស់វិទ្យុអាស៊ីសេរី និងវីអូអេ គឺមាន «ភាពព្រហើន»

[223] Chheng, Niem and Ananth Baliga "After Cambodia Daily's $6 million bill, tax authorities target RFA, VOA" Phnom Penh Post, 14 August 2017.
[224] Khuon, Narim "Foreign radio under tax scrutiny" Khmer Times, 14 August 2017.
[225] Leng, Len and Ben Paviour "Anger mounts as radio purge knocks 19 stations off-air" Cambodia Daily, 28 August 2017.
[226] Yeang, Sothearin "Shuttered Cambodian radio stations appeal to Hun Sen for reinstatement" RFA, 28 August 2017.

[227] Mech, Dara and Ananth Baliga "Government closes 15 radio stations" Phnom Penh Post, 25 August 2017.

[228] Len, Leng and Ben Paviour "Anger mounts as radio purge knocks 19 stations off-air" Cambodia Daily, 28 August 2017.

និងមាន «អាកប្បកិរិយាមួយរំលោភបំពានច្បាប់»។[229] ការបោសសំអាតលើប្រព័ន្ធផ្សព្វផ្សាយដ៏សំខាន់នេះ ត្រូវបានអន្តរជាតិយកចិត្តទុកដាក់ ហើយបានកត់សម្គាល់ពីទំនាក់ទំនង រវាងការបិទប្រព័ន្ធផ្សព្វផ្សាយ និងការពិភាក្សាមួយដ៏សំខាន់លើបញ្ហាអំពើពុករលួយ ការរំលោភបំពានដីធ្លី និងភាពមិនប្រក្រតីក្នុងការបោះឆ្នោត។[230]

នៅក្នុងថ្ងៃដដែលនោះ ខេមបូឌាដេលីបានចេញការផ្សាយចុងក្រោយរបស់ខ្លួនថា ស្ថានីយ៍វិទ្យុពីរទៀតនៅភ្នំពេញ ត្រូវបានបញ្ជាឲ្យផ្អាកការផ្សាយរបស់វិទ្យុអាស៊ីសេរី និងវីអូអេ នៅតាមមូលដ្ឋានដោយចោទថាពួកគេកំពុងប្រតិបត្តិការខុសច្បាប់ និងហាមឃាត់មិនឱ្យចាក់ផ្សាយ។[231] នៅពាក់កណ្តាលខែកញ្ញា វិទ្យុអាស៊ីសេរីបានប្រកាសផ្អាកដំណើរការរបស់ខ្លួននៅភ្នំពេញ។ អាស៊ីសេរីបានប្រកាសនៅក្នុងសេចក្តីថ្លែងការណ៍ជាសាធារណៈថា "រដ្ឋាភិបាលធ្វើគ្រប់យ៉ាងទាំងអស់ដើម្បីតាមចាប់ ក្រុមអ្នកវិះគន់គណបក្សប្រឆាំង អង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ដែលមានបំណងរាយការណ៍សេចក្តីពិត ក្រោមលេសថា មិនបង់ពន្ធជូនរដ្ឋ និងការបំពានបែបបទរដ្ឋបាល។[232] ប្រភពព័ត៌មានមួយរាយការណ៍ថា ថ្មីៗនេះរាជរដ្ឋា

ភិបាលកម្ពុជាបានបិទការផ្សាយរបស់ស្ថានីយ៍វិទ្យុ ចំនួន១៣ ក្នុងខេត្តចំនួន១០ ដែលបានទទួលការផ្សាយបន្តពីអាស៊ីសេរី។[233] ជាសរុបក្នុងមួយខែមុនការបិទទ្វារវិទ្យុ ដែលរងការចោទប្រកាន់ពីបទមិនបង់ពន្ធក្នុងការប្រតិបត្តិការដោយគ្មានអាជ្ញាប័ណ្ណនោះ ប្រេកង់វិទ្យុចំនួន៣០ ដែលដំណើរការកម្មវិធីរបស់ខ្លួនក៏ត្រូវបានបិទ។[234] អ្នកនាំពាក្យក្រសួងព័ត៌មានបានចោទប្រកាន់វិទ្យុអាស៊ីសេរីពីបទញុះញង់ និង"ធ្វើសកម្មភាពដូចចារកម្ម"។[235] ប៉ុន្មានសប្តាហ៍មុនការបិទវិទ្យុអាស៊ីសេរី និងស្ថានីយ៍វិទ្យុគណនេយ្យហ្វេសប៊ុកជាច្រើនដែលធ្វើការចោទប្រកាន់ ត្រូវបានផ្តល់ឱ្យដោយ Fresh News វិទ្យុអាស៊ីសេរី ដើម្បីគូសបញ្ជាក់កិច្ចខិតខំប្រឹងប្រែងក្នុងការធ្វើបដិវត្តន៍តាមអ្វីដែលហាក់ដូចជាមានការប៉ុនប៉ង ដើម្បីបង្ហាញពួកគេថា ជាការយល់ដឹងដែលមានមូលដ្ឋានលើភ័ស្តុតាងដែលគួរឱ្យជឿជាក់ ច្រើនជាងការអះអាងមិនច្បាស់លាស់។[236] ទោះបីជាយ៉ាងណាក៏ដោយអ្នកនាំពាក្យរបស់ក្រសួងព័ត៌មានបានបដិសេធយ៉ាងដាច់ខាត់ថា ក្រសួងនេះមានជាប់ពាក់ព័ន្ធ នឹងការបិទវិទ្យុ។[237]

---

[229] Niem, Chheng "More stations told to stop VOA, RFA shows" Phnom Penh Post, 4 September, 2017.
[230] Holmes, Oliver "Cambodia threatens purge of critical media and US charity" The Guardian, 23 August 2017.
[231] Niem, Chheng "More stations told to stop VOA, RFA shows" Phnom Penh Post, 4 September 2017.
[232] Kann, Vicheika "Radio Free Asia closes reporting hub, Cambodian miss critical coverage" VOA, 18 September 2017.
[233] Mom, Sophon "Radio Free Asia shuts Phnom Penh office after 20 years" Khmer Times, 13 September 2017.
[234] Baliga, Ananth, Dara Mech and Chheng Niem "RFA shuts down Cambodia operations amid media crackdown" Phnom Penh Post, 12 September 2017.
[235] Mom, Sophon "Radio Free Asia shuts Phnom Penh office after 20 years" Khmer Times, 13 September 2017.
[236] Paviour, Ben and Roeun Van "CNRP to be investigated for 'Color Revolution'" Cambodia Daily, 30 August 2017.
[237] Baliga, Ananth, Dara Mech, and Chheng Niem "RFA shuts down Cambodia operations amid media crackdown" Phnom Penh Post, 12 September 2017.

តាមរយៈការបង្ក្រាបថ្មីៗនេះលើ សេរីភាពសារព័ត៌មាន និងការបញ្ចេញមតិជាសាធារណៈរបស់ប្រជាពលរដ្ឋ អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជាបាននិយាយថា នេះមិនមែនជាជម្រើសទេ ប៉ុន្តែជាការចាត់វិធានការតាមផ្លូវច្បាប់ ដើម្បីការពារលទ្ធិប្រជាធិបតេយ្យ និងពង្រឹងនីតិរដ្ឋនៅកម្ពុជា។[238] ទោះជាយ៉ាងណាក៏ដោយវាប៉ះពាល់ធ្ងន់ធ្ងរដល់លទ្ធភាពក្នុងការផ្សព្វផ្សាយព័ត៌មាន និងទទួលមតិយោបល់ពីអ្នកបោះឆ្នោតរបស់គណបក្សផ្សេងទៀត ក្រៅពីគណបក្សកាន់អំណាច។ គណបក្សសង្គ្រោះជាតិបានប៉ាន់ស្មានថា ខ្លួនបានបាត់បង់អ្នកស្តាប់ជាប្រចាំរបស់ខ្លួនចំនួនប្រមាណ១០លាននាក់។[239] ទោះបីជាមានការអះអាងថា សកម្មភាពនេះមិនមែនជារឿងនយោបាយក៏ដោយ ក៏វាបង្ហាញឱ្យឃើញថា សម្លេងសង្គមស៊ីវិល ស្ថាប័នឯករាជ្យសំខាន់ៗ ត្រូវបានគេបង្ក្រាប។

ប្រជាពលរដ្ឋបានឃើញថា ការរឹតត្បិតលើសិទ្ធិក្នុងការបញ្ចេញមតិ និងសិទ្ធិទទួលបានព័ត៌មាន បានធ្វើឱ្យប៉ះពាល់ដល់ជំនឿទុកចិត្តរបស់សាធារណជន និងធ្វើឱ្យជំនឿទុកចិត្តលើសង្គមចុះអន់ថយ ដែលជាធាតុសំខាន់នៅក្នុងសង្គមសន្តិភាព និងសង្គមដែលមានវិបុលភាព។ បទសម្ភាសន៍មួយជាមួយម្ចាស់ស្ថានីយ៍វិទ្យុបានបង្ហាញពីការយល់ស្របយ៉ាងច្បាស់លាស់ថា ពួកគេបានមើលឃើញពីការវិត្តន៍នយោបាយ ដែលផ្ទុយពីការចេញសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាល។[240] ប្រធានក្លឹបអ្នកកាសែតក្រៅប្រទេសរបស់កម្ពុជាបានអះអាងថា វិធានការប្រឆាំងនឹងវិទ្យុអាស៊ីសេរី គឺជាផ្នែកមួយនៃវិធីសាស្ត្រមួយ ក្នុងការលុបបំបាត់សម្លេងប្រឆាំងនានាមុនការបោះឆ្នោតនៅឆ្នាំក្រោយ។[241] ការបង្ក្រាបមិនសំចៃទៅលើប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ធ្វើឱ្យសាធារណជនមានការសង្ស័យ និងលែងមានទំនុកចិត្តទៅទៀតលើសន្តិភាព និងស្ថេរភាព។ ភាពអន់ថយ និងកម្សោយនៃភាពស្របច្បាប់របស់អ្នកធ្វើគោលនយោបាយសំខាន់ៗ បានកើនឡើងហើយត្រូវបានសាធារណជន និងសហគមន៍អន្តរជាតិ ដែលមើលឃើញថាជាកម្លាំងនៃការផ្លាស់ប្តូរមួយដ៏ហួសហេតុ។ ប្រជាពលរដ្ឋម្នាក់បានអះអាងថា "ពួកគេបំពានសិទ្ធិរបស់យើងក្នុងការទទួលបានព័ត៌មាន" ប្រសិនបើព័ត៌មានតែមួយគត់ដែលគាំទ្ររដ្ឋាភិបាលនោះវាមិនស្មើគ្នាទេ។[242] "ការធ្វើអត្ថាធិប្បាយស្ទើរតែទាំងស្រុងលើទំព័រហ្វេសប៊ុករបស់ស្ថានទូតអាមេរិក បានរិះគន់ចំពោះការបិទទ្វាររបស់អង្គការ NDI។ លើសពីនេះ សហគមន៍ និងប្រជាពលរដ្ឋបានបង្ហាញពីការមិនសប្បាយចិត្តរបស់ពួកគេ ជាមួយនឹងការរឹតត្បិតលើប្រព័ន្ធផ្សព្វផ្សាយសំខាន់ៗ ដែលបានចូលរួមដោះស្រាយបញ្ហាប្រឈមយ៉ាងពិតប្រាកដសម្រាប់បញ្ហាអភិវឌ្ឍន៍ និងសុខុមាលភាពសង្គម។[243] ការរឹតត្បិតលើប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងអង្គការសង្គមស៊ីវិលត្រូវបានក្រុមអ្នកវិភាគអន្តរជាតិ ចាត់

[238] May, Titthara "Media crackdown under fire" Khmer Times, 30 August 2017.
[239] Len, Leng and Ben Paviour "Anger mounts as radio purge knocks 19 stations off-air" Cambodia Daily, 28 August 2017.
[240] Yeang, Sothearin "Shuttered Cambodia radio stations appeal to government for reinstatement" RFA, 28 August 2017.
[241] Kann, Vicheika "Radio Free Asia closes reporting hub, Cambodian miss critical coverage" VOA, 18 September 2017.
[242] Yon, Sineat and Shaun Turton "Public skeptical of media attacks" Phnom Penh Post, 30 August 2017.
[243] Oung, Sereyvuth and Sokheng Saut "Cambodia denies radio closure tied to US broadcasters" RFA, 24 August 2017; Len, Leng and Ben Paviour "Anger mounts as radio purge knocks 19 stations off-air" Cambodia Daily, 28 August 2017.

ចូលជាផ្នែកមួយនៃយុទ្ធសាស្ត្រប្រឆាំងនឹងលោកខាងលិច ដើម្បីគ្រប់គ្រងស្ថានការណ៍ការបោះឆ្នោតសម្រាប់ឆ្នាំ២០១៨។[244]

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានកត់សម្គាល់អំពីបញ្ហានាការបោះឆ្នោតឆ្នាំ២០១៨ខាងមុខ ទាក់ទងនឹង "សិទ្ធិនយោបាយ និងសិទ្ធិពលរដ្ឋ និងសេរីភាពសារព័ត៌មាន" ។ លើសពីនេះក្រុមអ្នកវិភាគនយោបាយបានកត់សម្គាល់ថា តួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយ គឺដើម្បីបង្ហាញការពិតដល់សាធារណជន តែនៅពេលដែលរដ្ឋាភិបាលបង្ខំប្រព័ន្ធផ្សព្វផ្សាយមួយចំនួនអោយបិទទ្វារនោះ រដ្ឋាភិបាលកំពុងតែរឹតត្បិតការទទួលបានព័ត៌មាន និងគ្រប់គ្រងលើការបញ្ចេញមតិរបស់មហាជន ហើយមានតែប្រព័ន្ធផ្សព្វផ្សាយដែលរិះគន់រដ្ឋាភិបាលដែលទទួលបានការដាក់ទណ្ឌកម្មនេះ។ ទាំងអស់នេះ ជារូបភាពដែលគ្មានវិជ្ជាជីវៈ និងភាពលំអៀងរបស់ស្ថាប័នរដ្ឋាភិបាល។[245] អ្នកតំណាងមកពីអង្គការឃ្លាំមើលសិទ្ធិមនុស្ស បានអត្ថាធិប្បាយ អំពីគោលនយោបាយគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយ និងបោសសំអាតឥទ្ធិពលបក្សប្រឆាំង។ សម្ព័ន្ធភាពព័ត៌មានអាស៊ីអាគ្នេយ៍ (SEAPA) បានដាក់ឈ្មោះស្ថានភាពនេះថា ជាការវាយប្រហារជាប្រព័ន្ធទៅលើប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពសារព័ត៌មាន។ ក្លឹបសារព័ត៌មាននៅក្រៅប្រទេសរបស់កម្ពុជា (OPCC) បានលើកឡើងថា ព្រឹត្តិការណ៍នានាដែលជាការបង្ក្រាបលើសម្លេងប្រឆាំងទាំងអស់ គឺព្រោះតែគណបក្សកាន់អំណាចភ័យខ្លាចក្នុងការគំរាមកំហែងចំពោះការបោះឆ្នោតឆ្នាំ២០១៨។[246] ខណៈក្រុមអ្នកវិភាគមួយចំនួនបានអះអាងថា រដ្ឋាភិបាលកំពុងអនុវត្តការបោសសំអាតគ្រប់អង្គការទាំងអស់ ដែលស្ថិតក្នុងបញ្ជីខ្មៅ គឺកំចាត់នៅពេលនេះខ្លះ និងខ្លះទៀតកំចាត់ទៅតាមក្រោយ។ អ្នកឯកទេសអំពីប្រព័ន្ធនយោបាយនៅអាស៊ីអាគ្នេយ៍បានពិពណ៌នាថា វាជាការផ្លាស់ប្តូរមួយពីអំណាចផ្តាច់ការដែលមានការប្រកួតប្រជែង ទៅជាអំណាចផ្តាច់ការដែលធ្វើតាមតែអំពើចិត្ត។ យោងតាមបទសម្ភាស៍មួយមន្ត្រីផ្នែកច្បាប់ និងអង្កេតនៃអង្គការខុមហ្វ្រែលបានអះអាងថា "សេរីភាពក្នុងការបញ្ចេញមតិស្ថិតក្នុងស្ថានការណ៍មួយដ៏គ្រោះថ្នាក់ នេះហើយ គឺជាការងារ និងជីវិតរបស់អ្នកតស៊ូមតិសិទ្ធិមនុស្ស។"[247]

នៅក្នុងសង្គមប្រជាធិបតេយ្យ ទស្សនរបស់កិច្ចសន្យាសង្គម ដែលតំណាងដោយរដ្ឋធម្មនុញ្ញបានអះអាងថា អំណាចដែលអ្នកតំណាងរាស្ត្របាន គឺជាកើតចេញពីឆន្ទៈរបស់ប្រជាជនតាមរយៈការបោះឆ្នោតដោយសេរី និងយុត្តិធម៌។ បើគ្មានការប្រកួតប្រជែងនយោបាយ និងពហុបក្សពិតប្រាកដនៅក្នុងស្ថាប័នរដ្ឋសភាទេ មុខងារសំខាន់ពីរនៃការត្រួតពិនិត្យលើអំណាចប្រតិបត្តិនឹងទទួលបរាជ័យ និងមិនអាចធានាការបង្កើតច្បាប់ដែលឆ្លើយតបតាមផលប្រយោជន៍ជាមូលដ្ឋាន និងឆន្ទៈរបស់ប្រជាជនទាំងមូលបានឡើយ។ ការ

[244] "Cambodia orders US-funded group to leave in new anti-American move" Nikkei Asian Review, 24 August, 2017.
[245] May, Titthara "Media crackdown under fire" Khmer Times, 30 August 2017.
[246] Corben, Ron "Cambodian media crackdown seen as key step by government ahead of 2018 elections" VOA, 31 August 2017.

[247] Paviour, Ben "Observers warn of new era of repression in Cambodia" Cambodia Daily, 24 August 2017.

រំលោភលើគណបក្សប្រឆាំង និងសង្គមស៊ីវិល (រួមទាំងអង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសហជីពឯករាជ្យ) ពួកគេមិនត្រឹមតែមិនយល់ស្របទេ ប៉ុន្តែថែមទាំងប្រឆាំងនឹងការរស់នៅរបស់ពួកគេទាំងស្រុងដោយការឃោសនាមិនស្របច្បាប់។ នេះបានធ្វើឲ្យមានការគំរាមកំហែងដល់ការយល់ដឹងជាសាធារណៈ ដែលធ្វើឲ្យយន្តការគណនេយ្យភាពរបស់រដ្ឋាភិបាលចុះខ្សោយ។ **<u>លើសពីនេះទៀត វាបានបង្កើតឲ្យមានលំហសេរីភាពសម្រាប់ប្រជាពលរដ្ឋ និងទីសាធារណៈមិនទុកចិត្ត និងឧបសគ្គចំពោះការរីកចម្រើននៃដើមទុនសង្គម។</u>** ការប្រមូលផ្តុំទៅក្នុងក្រុមសហគមន៍ ឬក្រុមដែលមានការយកចិត្តទុកដាក់លើបញ្ហាការអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាលត្រូវបានប្រឈមនឹងបញ្ហាជាមូលដ្ឋាននៃការគំរាមកំហែងដល់ស្ថិរភាព។ ការមិនផ្តល់ឲ្យប្រជាពលរដ្ឋឱ្យមានសេរីភាពក្នុងការបញ្ចេញមតិ ដោយបង្កើតឲ្យមានអសន្តិសុខ និងគំរាមកំហែងនានា សាមគ្គីភាពក្នុងចំណោមក្រុមដែលមិនយល់ស្របនឹងគោលនយោបាយ មិនមានមធ្យោបាយដែលសាធារណជនអាចប្រមូលផ្តុំធ្វើយុទ្ធនាការតស៊ូមតិលើបញ្ហាសង្គមបាន។ ការមិនផ្តល់ឱកាសឱ្យមានសឡេងរិះគន់ នោះការឆ្លើយតបរបស់អភិបាលកិច្ច គឺមិនមានព័ត៌មានគ្រប់គ្រាន់សម្រាប់អ្នកបង្កើតគោលនយោបាយ និងមន្ត្រីដើម្បីធ្វើការសំរេចចិត្តបានត្រឹមត្រូវនោះទេ។ ចំណាត់ថ្នាក់លើអំពើពុករលួយនៅតែជាលេខរៀងជួរមុខ និងការបង្កើតបរិបទនយោបាយដោយគ្មានពហុបក្សពិតប្រាកដ មានន័យថា ជាឧបសគ្គធំធេងចំពោះការបង្កើតលទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅក្នុងប្រទេសកម្ពុជា។

១៣.២ ការផ្ទេរអំណាចមេឃុំ ចៅសង្កាត់

១៤ថ្ងៃបន្ទាប់ពីការបោះឆ្នោតរួចមក គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានប្រកាសលទ្ធផលចុងក្រោយនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៧។ ក្រសួងមហាផ្ទៃបានរៀបចំសន្និសីទមួយក្នុងការប្រកាសសុពលភាពលើក្រុមប្រឹក្សាឃុំ សង្កាត់។ មានចំនួនតួលេខយ៉ាងច្រើនពីការផ្ទេរអំណាចពីមេឃុំ ចៅសង្កាត់របស់គណបក្សប្រជាជនទៅឱ្យមេឃុំ ចៅសង្កាត់គណបក្សសង្គ្រោះជាតិ ជាគណបក្សជាប់ឆ្នោតថ្មី។

ដោយផ្អែកលើរូបមន្តបច្ចុប្បន្ន គណបក្សប្រជាជនកម្ពុជាទទួលបាន៦,៥០៣អាសនៈនៃអាសនៈក្រុមប្រឹក្សាឃុំ សង្កាត់សរុបចំនួន១១,៥៧២ និង១,១៥៦មេឃុំ ចៅសង្កាត់ ក្នុងចំណោមអាសនៈជាតំណែងមេឃុំ ចៅសង្កាត់ចំនួន១,៦៤៦។ គណបក្សសង្គ្រោះជាតិទទួលបានអាសនៈក្រុមប្រឹក្សាចំនួន៥,០០៧អាសនៈ និងអាសនៈមេឃុំ ចៅសង្កាត់ចំនួន៤៨៩។

អង្គការខុមហ្វ្រែលបានជ្រើសរើសយកឃុំ សង្កាត់ចំនួន២៣ ដើម្បីសង្កេតការណ៍ពីការផ្លាស់ប្តូរមេឃុំចាស់ ទៅមេឃុំថ្មី (ទាំងការផ្ទេរពីការគណបក្សកាន់អំណាច ទៅគណបក្សប្រឆាំង និងពីគណបក្សប្រឆាំងទៅគណបក្សកាន់អំណាច) ទោះជាការផ្ទេរអំណាចនោះទៅរលូន ឬក៏អត់ គឺអាស្រ័យទៅលើច្បាប់។ តាមរយៈការសង្កេតការណ៍បានរកឃើញថា ឃុំ សង្កាត់ចំនួន១៤ មានបញ្ហាការផ្ទេរអំណាចនេះ គឺបញ្ហាទីកន្លែង ឬ

បន្ទប់អង្គុយធ្វើការ សម្ភារៈការិយាល័យ ឯកសារ និងភាពមិនចុះសម្រុងគ្នាជាមួយស្មៀនឃុំ។[248] ទ្រព្យសម្បត្តិនៅក្នុងការិយាល័យខ្លះ ត្រូវបានមេឃុំ ចៅសង្កាត់ចាស់ដកហូតជារបស់កម្មសិទ្ធិគណបក្សកាន់អំណាច។[249] ឃុំ សង្កាត់ទាំងអស់នោះរួមមាន៖

នៅរាជធានីភ្នំពេញ សង្កាត់វាលវង្ស ខណ្ឌ៧មករា៖ អតីតចៅសង្កាត់ចាស់ពីគណបក្សប្រជាជនកម្ពុជា មិនព្រមប្រគល់បន្ទប់ធ្វើការទៅអោយចៅសង្កាត់ ដែលទើបតែជាប់ឆ្នោតមកពីគណបក្សសង្គ្រោះជាតិ ហើយគាត់បាននិយាយថា បន្ទប់ធ្វើការនេះគឺគាត់បានសាងសង់ និងប្រើប្រាស់យូរហើយ មិនតែប៉ុណ្ណោះ គាត់ថែមទាំងអោយចៅសង្កាត់ថ្មី ទៅសង់បន្ទប់ធ្វើការថ្មីដោយខ្លួនឯងទៅ ប៉ុន្តែចៅសង្កាត់ថ្មីមិនព្រមឡើយ។ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ៖ អតីតចៅសង្កាត់គណបក្សប្រជាជនកម្ពុជា ដកយកសម្ភារៈ និងរបស់របរទាំងអស់ឡើងពីការិយាល័យធ្វើការរបស់ចៅសង្កាត់។

ខេត្តព្រះសីហនុ សង្កាត់លេខ១ ក្រុងព្រះសីហនុ៖ អតីតចៅសង្កាត់គណបក្សប្រជាជនកម្ពុជា មិនព្រមប្រគល់ការិយាល័យទៅឲ្យចៅសង្កាត់ថ្មី ដែលទើបតែជាប់ឆ្នោតពីគណបក្សសង្គ្រោះជាតិទេ។ ហើយគាត់ថែមទាំងនិយាយថា ការិយាល័យនេះត្រូវធ្វើឡើង និងបង្កើតឡើងដោយប្រើមូលនិធិសប្បុរសធម៌ និងមូលនិធិវិភាគទានរបស់គណបក្សប្រជាជន។ គាត់បន្ថែមថា គាត់អង្គុយនៅការិយាល័យនេះច្រើនឆ្នាំហើយ ប៉ុន្តែដោយសារតែឯកសារច្រើន ហើយសម្ភារៈការិយាល័យ និងរបស់របរផ្សេងៗទៀតច្រើន គាត់មិនអាចរើចេញក្រៅបានទេ។ ចៅសង្កាត់ចាស់បង្ខំអោយចៅសង្កាត់ថ្មីប្រើបន្ទប់ផ្សេងនៅក្នុងការិយាល័យទៅ។ សង្កាត់លេខ ៤ ស្រុកព្រៃនប់៖ ចៅសង្កាត់បដិសេដមិនរើចេញពីកន្លែង លុះត្រាតែមានការសុំពីចៅសង្កាត់ថ្មីដែលទើបជាប់ឆ្នោតពីគណបក្សសង្គ្រោះជាតិ។ ចៅសង្កាត់ថ្មីមិនបានទាមទារឲ្យចៅសង្កាត់រើចេញទេ ប៉ុន្តែសុខចិត្តរៀបចំបន្ទប់ថ្មីខ្លួនឯង។ បញ្ហាដែលនៅតែបន្តមាននោះ គឺចៅសង្កាត់ចាស់មិនព្រមសហការធ្វើការជាមួយ និងគ្មានឆន្ទៈផ្ទេររបស់របរបរិក្ខារ ឯកសារទៅចៅសង្កាត់ថ្មីឡើយ។

ខេត្តសៀមរាប ឃុំបាគង និងឃុំកំរើក ស្រុកសៀមរាប៖ អតីតៈចៅសង្កាត់ចាស់ មិនព្រមរើចេញពីបន្ទប់ធ្វើការ។ នៅឃុំកំរើកវិញ អតីតចៅសង្កាត់ចាស់ចាក់សោរបន្ទប់គាត់អស់រយៈពីរបីថ្ងៃ។ បន្ទាប់ពីប្រតិកម្មពីបណ្តាញសង្គម និងព័ត៌មានរាយការណ៍ពីស្ថានភាពនេះ គាត់ក៏បានចាក់សោរទ្វារអោយចៅសង្កាត់ថ្មីសង្គ្រោះជាតិវិញ។

ក្នុងខេត្តកំពតមានប្រាំពីរឃុំនៅក្នុងស្រុកជុំគិរី រួមមាន ឃុំជ្រៃស ជម្ពូវ័ន្ត ស្នាយអន្ធិត ស្រែចេង ស្រែក្នុង ស្រែសំរោង និងស្រែត្រពាំងរាំង៖ អតីតចៅសង្កាត់ មិនព្រមរើចេញពីបន្ទប់របស់ចៅសង្កាត់ទេ ហើយថែមទាំងប្រាប់ទៅចៅសង្កាត់ថ្មីថាអោយរៀបបន្ទប់ថ្មីខ្លួនឯងទៅ ហើយថែមទាំងមិនព្រមផ្ទេរគ្រឿងបរិក្ខារ ឯកសារ

[248] For example, in one case that happened in Sihanoukville, the newly elected commune chief and commune clerk (responsible for keeping the commune seal) were unable to cooperate.
[249] Case happened

របស់របរផ្សេងទៀតទៅចៅសង្កាត់ថ្មីទេ។ នេះមានន័យថា ពួកគាត់មិនអាចផ្តល់សេវាសាធារណៈទៅប្រជាពលរដ្ឋ ដោយសារតែខ្វះនូវធនធាន និងឯកសារចាំបាច់។

ចំណែកឯសង្កាត់ចំនួន៩ទៀត ដែលបានរកឃើញនៅក្នុងការសង្កេតការណ៍ ហើយបានផ្ទេរតំណែងយ៉ាងរលូន និងបានប្រគល់បន្ទប់ធ្វើការទៅចៅសង្កាត់ដែលទើបជាប់ថ្មី។ ឃុំសង្កាត់ទាំងអស់នោះរួមមាន៖ សង្កាត់វាលវង្ស ក្រុងកំពង់ចាម ខេត្តកំពង់ចាម ឃុំជីរូ នៅស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ សង្កាត់សង្គោរ ក្រុងស្វាយរៀង ខេត្តស្វាយរៀង សង្កាត់ស្រាយ៉ូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន ឃុំរមទម្យ ស្រុករវៀង ខេត្តព្រះវិហារ ឃុំឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី សង្កាត់សំរោងយ៉ា ស្រុកពួក ខេត្តសៀមរាប និងសង្កាត់កំពង់ស្វាយ ក្រុងសេរីសោភណ្ឌ ខេត្តបន្ទាយមានជ័យ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានអាណត្តិ៥ឆ្នាំ ហើយអាណត្តិនេះផុតកំណត់នៅពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានជាប់ឆ្នោតថ្មីបានកាន់តំណែង។[250] ១៤ថ្ងៃក្រោយពីការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតឃុំ សង្កាត់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបើកកិច្ចប្រជុំលើកដំបូង។ ការប្រជុំដឹកនាំដោយអ្នកដែលត្រូវបានចាត់តាំងដោយក្រសួងមហាផ្ទៃ ដើម្បីប្រកាសពីសុពលភាពនៃអាណត្តិថ្មីរបស់ក្រុមប្រឹក្សាឃុំ និងប្រកាសឈ្មោះក្រុមប្រឹក្សា ដែលទើបតែបានជាប់ឆ្នោតរួមមានមេឃុំជាប់ឆ្នោតថ្មី និងអនុប្រធានទី១ និងទី២។[251] លទ្ធផលផ្លូវការសម្រាប់ការបោះឆ្នោតអាណត្តិទី៤ របស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានប្រកាសនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៧។ អនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ ក្រសួងមហាផ្ទៃត្រូវណែនាំដល់ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមរបស់ខ្លួនឱ្យចងក្រង និងរៀបចំសម្រាប់ការចាប់ផ្តើមអាណត្តិថ្មីនៃក្រុមប្រឹក្សាឃុំ សង្កាត់នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៧។

ក្រសួងមហាផ្ទៃបានណែនាំអតីតក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យធ្វើរបាយការណ៍ ស្តីពីសមិទ្ធិផលក្នុងអំឡុងពេលប្រាំឆ្នាំកន្លងមក និងបញ្ហាប្រឈមដែលនៅសេសសល់សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាប់ឆ្នោតថ្មី។ ក្រុមប្រឹក្សាឃុំ សង្កាត់ក៏ត្រូវណែនាំ និងអោយព័ត៌មានដល់សមាជិកក្រុមប្រឹក្សាថ្មី អំពីកិច្ចការណាជាចម្បងដែលត្រូវផ្តោតលើ។ ក្រសួងមហាផ្ទៃក៏បានណែនាំដល់ស្មៀនឃុំ សង្កាត់អោយចងក្រង រៀបចំ និងថែរក្សាកំណត់ត្រារបស់រដ្ឋបាលឃុំ សង្កាត់អាណត្តិមុនៗសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាប់ឆ្នោតថ្មី ដើម្បីធានានិរន្តភាពនៃការងាររដ្ឋបាល។

ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវធានាឱ្យបានគ្រប់គ្រាន់នូវធនធានមនុស្ស និងសម្ភារៈបរិក្ខាររបស់របរសម្រាប់ដំណើរការរដ្ឋបាលរបស់ឃុំ សង្កាត់។[252] មេឃុំ ចៅសង្កាត់ គឺជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តន៍ការសម្រេចចិត្ត និងនីតិវិធីនៃក្រុមប្រឹក្សាឃុំ សង្កាត់។ ក្រសួងមហាផ្ទៃមិនបានរក ភាពមិនប្រក្រតីទេ។ អ្នកនាំពាក្យក្រសួងមហាផ្ទៃបាននិយាយថា មិនមានច្បាប់ណាដែលចែងពីការដាក់ទណ្ឌកម្មចំពោះអតីតមេឃុំ ចៅ

[250] Art. 11 of the Law on Administration Management of Commune/Sangkat, 2001.
[251] Art. 19 of the Law on Administration Management of Commune/Sangkat, 2001.
[252] Art. 13 of the Law on Administration Management of Commune/Sangkat, 2001.

សង្កាត់ដែលបានប្រព្រឹត្តនូវភាពមិនប្រក្រតី ឬអាកប្បកិរិយាមិនត្រឹមត្រូវនោះទេ ហើយគាត់បានចាត់ទុកថា វាមិនមែនជាបញ្ហាធ្ងន់ធ្ងរនោះទេ។ អង្គការសង្គមស៊ីវិល ដែលសង្កេតមើលស្ថានភាពបោះឆ្នោតបានអះអាងថា ការឆ្លើយតបរបស់ក្រសួងមហាផ្ទៃបង្កការគំរាមកំហែងចំពោះនូវអាកប្បកិរិយាបែបនេះ។ ក្រសួងមហាផ្ទៃបានជំរុញឱ្យភាគីដែលពាក់ព័ន្ធនៅក្នុងជម្លោះនេះដោះស្រាយបញ្ហាដោយខ្លួនឯង។ ក្រសួងមហាផ្ទៃក៏បានសង្កត់ធ្ងន់ថា នេះមិនមែនជាបញ្ហាថ្មីទេ ហើយវាបានកើតឡើងអស់រយៈពេលជាយូរមកហើយ។ ចំណុចនេះបង្ហាញយ៉ាងច្បាស់ដល់សាធារណជន និងភាគីពាក់ព័ន្ធសំខាន់ផ្សេងទៀត ថាក្រសួងមហាផ្ទៃមានចេតនាមិនយកចិត្តទុកដាក់ដោះស្រាយបញ្ហានេះ។

អង្គការសង្គមស៊ីវិល និងគណបក្សនយោបាយមិនចាត់ទុកបញ្ហាទាំងនេះ ជាបញ្ហាតូចតាចទេ។ ក្រសួងមហាផ្ទៃ ត្រូវយកទៅពិចារណាដោយយកចិត្តទុកដាក់ និងឆ្លើយតបចំពោះដំណោះស្រាយ ព្រោះថាក្រសួងមហាផ្ទៃជាអាជ្ញាធរមានសមត្ថកិច្ចលើរដ្ឋបាលឃុំ សង្កាត់។ ឃុំ សង្កាត់ទាំងនេះ គឺជាអង្គភាពរដ្ឋហើយទ្រព្យសម្បត្តិទាំងអស់ដែលជាកម្មសិទ្ធរបស់រដ្ឋបាលឃុំ សង្កាត់គឺជាទ្រព្យសម្បត្តិរបស់រដ្ឋដោយមិនគិតថាតើពួកគេត្រូវបានផ្តល់មូលនិធិ ឬដោយការបរិច្ចាគឯកជន ឬក៏អត់ទេ។ ដូច្នេះអតីតមេឃុំ ចៅសង្កាត់ដែលចាញ់ឆ្នោតនោះ ត្រូវតែប្រគល់វត្ថុទាំងអស់នោះ (ការិយាល័យ ឯកសាររបស់របរផ្សេងទៀត។ល។) ទៅឱ្យមេឃុំជាប់ឆ្នោតថ្មី។

ទោះបីច្បាប់ ឬបទបញ្ជាពាក់ព័ន្ធដទៃទៀត មិនមានចែងច្បាស់លាស់អំពីការរៀបចំការិយាល័យរបស់មេឃុំ ចៅសង្កាត់ (ឬតំណាងរាស្ត្រ ឬសមាជិកក្រុមប្រឹក្សា) ក្រសួងមហាផ្ទៃគួរតែចេញសេចក្តីណែនាំ ឬគោលការណ៍ណែនាំដើម្បីទប់ស្កាត់ និងដោះស្រាយទំនាស់ទាំងនោះ។ ក្រសួងមហាផ្ទៃ មិនគួរបោះបង់ចោលបញ្ហានេះទេ ហើយអនុញ្ញាតឱ្យជម្លោះនេះបន្ត ដោយគ្មានវិធានការអសកម្មចំពោះដំណោះស្រាយនោះទេ។ ភាពអសកម្មរបស់ក្រសួងមហាផ្ទៃបានបង្ហាញឱ្យឃើញនូវភាពមិនស្មើភាពគ្នា និងការមិនពេញចិត្តចំពោះដំណើរការងាររលូន និងសុខដុមរមនារបស់រដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន។ គណបក្សនយោបាយផ្សេងៗទៀត គួរតែធ្វើការរួមគ្នាដោយសន្តិភាព ដោយគ្មានការរើសអើង ដើម្បីផលប្រយោជន៍ប្រជាពលរដ្ឋដែលរស់នៅមូលដ្ឋាន។ ដើម្បីឆ្ពោះទៅរកទិសដៅជាអាទិភាពខ្ពស់ជាងគេបំផុត គឺរដ្ឋបាលអភិបាលកិច្ចនៅមូលដ្ឋានជាអ្នកតំណាងអោយមាននិរន្តរភាព។

១៤. ការចូលរួម និងសិទ្ធិទៅបោះឆ្នោត

១៤.១ អ្នកបានបោះឆ្នោត និងអ្នកបោះឆ្នោតដែលត្រូវបានដកហូតសិទ្ធិ

តារាងទី១៧ អ្នកមានសិទ្ធិបោះឆ្នោត ចុះឈ្មោះបោះឆ្នោត និងអ្នកចេញបោះឆ្នោតឆ្នាំ១៩៩៣ ដល់២០១៧

ឆ្នាំបោះឆ្នោត	អ្នកមានសិទ្ធិបោះឆ្នោត	អ្នកចុះឈ្មោះបោះឆ្នោត		អ្នកបានបោះឆ្នោត	
		ចំនួន	%	ចំនួន	%
1993	4,654,000	4,764,430	102%	4,267,192	89.56%

1998	5,488,029	5,395,595	98%	5,057,830	93.74%
2002	6,251,832	5,190,307	83%	4,543,974	87.55%
2003	6,749,876	6,341,834	94%	5,277,494	83.22%
2007	7,291,084	7,799,371	107%	5,293,327	67.87%
2008	7,828,161	8,125,529	104%	6,100,884	75.08%
2012	8,894,219	9,203,493	104%	5,993,992	65.13%
2013	9,509,732	9,675,453	102%	6,735,244	69.61%
2017	9,664,216	7,865,033	81.38%	7,107,395	90.37%

តារាងទី១៧ ខាងលើបង្ហាញថា ចំនួនអ្នកទៅបោះឆ្នោតបានធ្លាក់ចុះជាបន្តបន្ទាប់ ចាប់តាំងពីការបោះឆ្នោតឆ្នាំ២០០២។ ក្នុងឆ្នាំ២០១២ ចំនួនអ្នកទៅបោះឆ្នោតបានឈានដល់ចំណុចទាបបំផុត គឺមានតែ ៦៥.១៣ភាគរយប៉ុណ្ណោះ។ ក្នុងឆ្នាំ២០១៣ អ្នកទៅបោះឆ្នោតបានកើនឡើងបន្តិច(៦៩.៦១ភាគរយ) រហូតមកដល់ការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧នេះ ឃើញថា អ្នកទៅបោះឆ្នោតបានកើនឡើងខ្ពស់រហូតដល់៩០.៣៧ភាគរយ ហើយជាតួលេខដែលមានកម្រិតខ្ពស់ជាងការបោះឆ្នោតនៅឆ្នាំកន្លងមកទាំងអស់ លើកលែងតែការបោះឆ្នោតក្នុងឆ្នាំ១៩៩៨ ដែលមានភាគរយចំនួន៩៣.៧៤ភាគរយ។ ការកើនឡើងនេះអាចជាហេតុផលដែលអាចកើតចេញពី ការកែទម្រង់ស្ថាប័នគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) ការរៀបចំបញ្ជីឈ្មោះបោះឆ្នោតថ្មី ដែលរៀបចំតាមប្រព័ន្ធកុំព្យូទ័រ ដោយមានរូបថត និងបញ្ចូលស្នាមក្រយៅដៃ ការបើកឱ្យមានការចូលរួមពីគណបក្សប្រឆាំង ក្នុងការជជែកការកោះហៅមន្ត្រីរដ្ឋាភិបាលជាមួយគណៈកម្មការអចិន្ត្រៃយ៍រដ្ឋសភា ការចុះជួបសកម្មជននៅមូលដ្ឋានដែលបង្ហាញពីគោលនយោបាយរបស់ខ្លួន ការចូលរួមរបស់ប្រព័ន្ធផ្សព្វផ្សាយនៃអង្គការសង្គមស៊ីវិល ព្រមទាំងភាគីពាក់ព័ន្ធជាច្រើន។ លើសពីនេះ បញ្ជីឈ្មោះបោះឆ្នោតបានធានាគុណភាពចំពោះអ្នកបោះឆ្នោត ដោយកាត់បន្ថយជាអតិបរមានៃការខុសឈ្មោះ រហូតមិនមានការបាត់បង់សិទ្ធិ ការបាត់ឈ្មោះ ឈ្មោះស្ងួន ឬឈ្មោះដែលត្រូវបានគេបោះជំនួសដូចកាលអាណត្តិបោះឆ្នោតកន្លងមកនោះទេ។ ទាក់ទងបញ្ជីឈ្មោះនេះផងដែរ ខុមហ្វ្រែលសង្កេតឃើញថា ការចុះឈ្មោះចាប់ពីឆ្នាំ២០០៧ រហូតដល់ឆ្នាំ២០១៣ អ្នកទៅចុះឈ្មោះបោះឆ្នោតតែងតែមានភាគរយច្រើនជាង ១០០ភាគរយ បើធៀបជាមួយការប៉ាន់ប្រមាណរបស់ គ.ជ.ប ក៏ប៉ុន្តែការចុះឈ្មោះឆ្នាំ២០១៦ បង្ហាញពីបញ្ជីឈ្មោះបោះឆ្នោតមានគុណភាព ហើយការធ្វើសវនកម្មរបស់ខុមហ្វ្រែលក៏បានបង្ហាញថាមានគុណភាពផងដែរ គឺ៨៩ភាគរយនៃប្រជាពលរដ្ឋដែលរស់នៅក្នុងស្រុកបានចុះឈ្មោះបោះឆ្នោត ហើយបញ្ជីឈ្មោះបោះឆ្នោត៩៨ ភាគរយ ត្រូវបានបង្ហាញថារកវត្តមានអ្នកបោះឆ្នោតឃើញតាមអាសយដ្ឋានដែលមាននៅក្នុងបញ្ជីឈ្មោះបោះ

ឆ្នោត។ សម្រាប់ឯកសារដែលបានប្រើប្រាស់ក្នុងការចុះឈ្មោះបោះឆ្នោត និងបោះឆ្នោតក៏ត្រូវបាន គ.ជ.ប ជួយសម្រួលដោយប្រើប្រាស់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់ការចុះឈ្មោះ ឬបោះឆ្នោត។ ក្រសួងមហាផ្ទៃក៏បានជួយសម្រួលបង្កើនល្បឿន ក្នុងការធ្វើអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរសម្រាប់ប្រជាពលរដ្ឋផងដែរ។ អ្នកសង្កេតការណ៍របស់ខុមហ្វ្រែលចំនួន១៤,៥០០នាក់ មិនបានរកឃើញថា អ្នកបោះឆ្នោត បាត់បង់ឈ្មោះក្នុងបញ្ជីឈ្មោះ ឬឈ្មោះត្រូវបានគេបោះជំនួសនៅក្នុងថ្ងៃបោះឆ្នោតនោះទេ។

កត្តាផ្សេងទៀតបានបង្ហាញថា ការកើនឡើងនៃការទៅបោះឆ្នោត គឺការបង្កើតការិយាល័យបោះឆ្នោតមិននៅឆ្ងាយពីលំនៅរបស់អ្នកបោះឆ្នោតដូចកាលពីមុន ហើយប្រជាពលរដ្ឋមានអាសយដ្ឋាន ឬទីសំណាក់កន្លែងណាអាចចុះឈ្មោះ និងបោះឆ្នោតបាននៅកន្លែងនោះផងដែរ។ ម្យ៉ាងទៀត ថ្ងៃបោះឆ្នោត(ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧) ស្ថានភាពអាកាសធាតុបានអំណោយផលល្អសម្រាប់អ្នកបោះឆ្នោតក្នុងការចេញទៅបោះឆ្នោតដោយមិនមានភ្លៀងមករំខាននោះទេ។ កត្តាផ្សេងៗទៀត គឺការជំរុញការចូលរួមផ្សព្វផ្សាយពីគ្រប់ភាគីពាក់ព័ន្ធដើម្បីផ្តល់ព័ត៌មានអំពីការបោះឆ្នោត តាមរយៈការអប់រំក្នុងប្រព័ន្ធវិទ្យុ ទូរទស្សន៍ និងទំព័រព័ត៌មានសង្គម ពិសេសសម្រាប់យុវជន។

រូបភាពទី២៥ ភាគរយនៃអ្នកបោះឆ្នោតមិនបានបោះឆ្នោតនៅឆ្នាំ២០១៧



ទោះជាយ៉ាងណា ក៏មានប្រជាពលរដ្ឋមួយចំនួន មិនបានទៅបោះឆ្នោតផងដែរ។ ការស្ទង់មតិមួយរបស់ខុមហ្វ្រែល ក្រោយការបោះឆ្នោតមួយថ្ងៃដែលមានឈ្មោះថា «ការស្ទង់មតិលឿន ឬស្ទង់មតិសម្រាប់អ្នកមិនមានទឹកខ្មៅលើម្រាមដៃ» ជាមួយអ្នកបោះឆ្នោតចំនួន៧៥៧នាក់ ដែលមិនមានទឹកខ្មៅនៅម្រាមដៃក្រោយ

ការបោះឆ្នោតមួយថ្ងៃ បានបង្ហាញពីលទ្ធផលដែលមិនបានទៅបោះឆ្នោតរបស់ពួកគេ។ ការស្ទង់មតិបានបង្ហាញថា អ្នកបោះឆ្នោត៤៨ភាគរយនៃអ្នកមិនបានទៅបោះឆ្នោត បានទៅដល់ការិយាល័យហើយមិនបានបោះឆ្នោត និង៥២ភាគរយទៀត មិនបានទៅដល់ការិយាល័យបោះឆ្នោតនោះទេ(ក្នុងចំណោមនោះ គឺ១៥% ចិត្តមិនចង់ទៅបោះឆ្នោត និង៨៥% ចិត្តចង់ទៅបោះឆ្នោតដែរ) ។

ក្នុងចំណោមអ្នកដែលបានទៅដល់ការិយាល័យបោះឆ្នោត ហើយអ្នកទាំងនោះមិនត្រូវបានបោះឆ្នោតដោយសារតែ គ្មានឯកសារបញ្ជាក់អត្តសញ្ញាណប្រើប្រាស់សំរាប់ការបោះឆ្នោតមានចំនួន៤៦ភាគរយ។ ៤៣ ភាគរយ គឺដោយសារតែគ្មានបណ្ណព័ត៌មាន ដែលពិបាករកលេខការិយាល័យ និងរកឈ្មោះ។ ក្រៅពីនោះ គឺដោយសារតែការិយាល័យមានភាពរញ៉េរញ៉ៃ និងខុសទិន្នន័យ។

សម្រាប់ប្រជាពលរដ្ឋដែលចង់បោះឆ្នោត តែគាត់មិនបានបោះឆ្នោតបានបង្ហាញថា ៦០ភាគរយ គឺពួកគាត់មិនបានទទួលព័ត៌មាន ព្រមទាំងមិនបានចុះឈ្មោះបោះឆ្នោតក្នុងអំឡុងពេលចុះឈ្មោះបោះឆ្នោត។ រីឯ១៦ភាគរយទៀត គឺដោយសារតែទីតាំងនៅឆ្ងាយ ព្រមទាំងថៅកែនៅកន្លែងធ្វើការមិនឱ្យសំរាក។ រីឯក្នុងចំណោមផ្សេងទៀតគឺដោយសារពួកគាត់ខ្លះរវល់ការងារផ្ទះ ខ្លះថាមិនសំខាន់។

ចំពោះអ្នកបោះឆ្នោត ដែលមិនចង់ទៅបោះឆ្នោត គាត់បានបង្ហាញថា ៣៦ភាគរយគឺខ្ជិល រីឯអ្នកខ្លះមូលហេតុរបស់គាត់គឺជាប់រវល់ការងារ និងរវល់កិច្ចការផ្ទះមានចំនួន៣៦ភាគរយ ក្រៅពីនោះ គឺមិនចូលចិត្តគណបក្ស និងគិតថា មិនមានសារៈសំខាន់។

១៤.២ ការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ

ការចូលរួមរបស់ស្ត្រីក្នុ ងផ្នែកនយោបាយសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ ឆ្នាំ២០១៧ ខុមហ្វ្រែលបានសង្កេតឃើញថា ការចូលរួមរបស់ស្ត្រីនៅតែមានភាពប្រឈម ចាប់ពីការទទួលបានឱកាសក្នុងការឈរឈ្មោះជាបេក្ខជនបោះឆ្នោត និងឱកាសឈានទៅមុខក្នុងជីវិតនយោបាយរបស់ស្ត្រីដែលបានជាប់ឆ្នោត។ ចាប់ពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី ១ ឆ្នាំ២០០២ រហូតមកដល់អាណត្តិទី៣ ឆ្នាំ២០១២ ចំនួនស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់ មានការកើនឡើងជាបន្តបន្ទាប់ ហើយស្ត្រីក៏បានចូលរួមក្នុងការបោះឆ្នោតយ៉ាងសស្រាក់សស្រាំ និងចូលរួមក្នុងកិច្ចការនយោបាយយ៉ាងសកម្មផងដែរ។ ផ្ទុយទៅវិញ ចំនួនស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ ឆ្នាំ២០១៧នេះបែរជាធ្លាក់ចុះទៅវិញ។

ផ្អែកលើរបាយការណ៍វាយតម្លៃរបស់ខុមហ្វ្រែលស្តីពី «ការចូលរួមនយោបាយរបស់ស្ត្រីក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៧» រកឃើញថា ស្ត្រីនៅតែភ័យខ្លាចក្នុងការភ្ជាប់ខ្លួនជាមួយនឹងកិច្ចការនយោបាយ និងការបោះឆ្នោត។ ការភ័យខ្លាចចម្បង។ ចំនួន៣ដែលបានកើតឡើងសម្រាប់ពួកគេគឺទី១៖ ខ្វះនូវគោលនយោបាយជាក់លាក់ជាលាយលក្ខណ៍អក្សរដែលជាវិធានការពិសេសបណ្តោះអាសន្ន និងមាត្រាមួយចំនួននៃច្បាប់បោះឆ្នោត ដើម្បីគាំទ្រ និងផ្តល់ឱកាសឲ្យស្ត្រី-បុរសចូលរួមស្មើគ្នាក្នុងវិស័

យនយោបាយ ជាពិសេសការឈរឈ្មោះជាបេក្ខជន។ ទី២៖ បន្តការរើសអើងប្រឆាំងនឹងស្ត្រីក្នុងដំណើរការបោះឆ្នោតជ្រើសរើសបេក្ខជននៅក្នុងគណបក្សនយោបាយ និងទី៣៖ បរិយាកាសនយោបាយ ក្នុងអំឡុងពេលដំណើរការនៃការបោះឆ្នោត ដូចជា ការគំរាមកំហែង បំភិតបំភ័យ ការប្រមាថមាក់ងាយ ការគំរាមសម្លាប់ និងការប្រើប្រាស់ប្រព័ន្ធតុលាការមកលើសកម្មជនគណបក្ស និងបេក្ខជនរបស់គណបក្សប្រឆាំង។

១៤.២.១ បេក្ខជនស្ត្រី

យោងតាមលទ្ធផលផ្លូវការនៃការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយរបស់ គ.ជ.ប កាលពីថ្ងៃ ១៨ ខែមេសា ឆ្នាំ២០១៧ សម្រាប់ឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤នេះ មានបេក្ខជនស្រី-ប្រុសប្រកួតប្រជែងសរុបចំនួន៩៤៥៩៥ (បេក្ខជនពេញសិទ្ធិ) ក្នុងនោះបេក្ខជនស្ត្រីមានចំនួន ២៥ ៧៨៨នាក់ (២៧,២៦%) មកពីគណបក្សនយោបាយចំនួន១២។ ក្នុងចំណោមគណបក្សនយោបាយទាំង១២ មានតែគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិតែប៉ុណ្ណោះ ដែលបានរៀបចំបញ្ជីបេក្ខជនឈរឈ្មោះនៅទូទាំងប្រទេសដែលគ្រប់ចំនួន១៦៤៦ឃុំ សង្កាត់។ បើប្រៀបធៀបជាមួយតួលេខកាលឆ្នាំ២០១២ (មានចំនួន២៥,៦៤%) មានការកើនតិចតួចគឺចំនួនតែ១,៦២% ។

ចំណែកឯបេក្ខជនស្ត្រីឈរឈ្មោះនៅលេខរៀងទី១ សរុបចំនួន៤៨១នាក់(៧,៨៩%)នៃបេក្ខជនលេខរៀងទី១ប្រុស-ស្រីសរុប៦,០៩២នាក់ គឺមានភាគរយកើនតែ១,១៧% ធៀបនឹងឆ្នាំ២០១២ (មានចំនួន ៦,៧២%)។ គណបក្សដែលមានអាសនៈនៅក្នុងសភា និងមានប្រជាប្រិយភាពខ្លាំងបានខិតខំដាក់បេក្ខជនស្ត្រី ឈរឈ្មោះនៅលេខរៀងទី១ច្រើនជាងមុនគួរឲ្យកត់សម្គាល់ ដូចជាគណបក្សប្រជាជនកម្ពុជា ចំនួន ១៣១នាក់ (៧,៩៦%) គឺកើនចំនួន៣៨នាក់ ធៀបនឹងឆ្នាំ២០១២ មានចំនួនតែ៩៣នាក់ (៥,៦៩%) ខណៈដែលគណបក្ស សង្គ្រោះជាតិមានចំនួន១០៣នាក់ (៦,២៥%) គឺ កើនប្រមាណ១៥នាក់ (ដោយគិតជាមធ្យមភាគរវាង គណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សឆ្នាំ២០១២ មានចំនួនតែ៨៧នាក់) ។ បេក្ខជនស្ត្រីឈរឈ្មោះ នៅលេខរៀងទី១នេះ ក៏ត្រូវបានបង្កើនដោយគណបក្សផ្សេងៗទៀតផងដែរ ។

ថ្វីបើចំនួនបេក្ខជនស្ត្រីឈរឈ្មោះមានការកើនឡើងពីអាណត្តិមួយទៅអាណត្តិមួយក៏ដោយ ក៏តួលេខនេះនៅតែជាចំនួនតិចតួច ខណៈដែលបេក្ខជនបុរសនៅតែមានចំនួនច្រើនលើសលុបដដែល។ នេះបង្ហាញឲ្យឃើញថា កម្ពុជានៅតែបន្តបញ្ហាអតុល្យភាពនៃការអនុវត្តសិទ្ធិ និងអំណាចនយោបាយរវាងបុរស និងស្ត្រី បើទោះបីកម្ពុជាទទួលយកនូវវិធានការពិសេស ដូចជា អនុសញ្ញាអន្តរជាតិស៊ី-ដរ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងផែនការអភិវឌ្ឍន៍ជាតិដើម្បីលើកកម្ពស់ និងផ្តល់ឱកាសឲ្យស្ត្រីចូលរួមសកម្ម និងស្មើភាពរវាង ស្ត្រី-បុរសទាំងបរិមាណ និងសិទ្ធិអំណាចក៏ដោយ។

១៤.២.២ កម្មវិធីនយោបាយរបស់គណបក្ស និងបេក្ខជនស្ត្រី

មានការយកចិត្តទុកដាក់ពីគណបក្សនយោបាយ និងបេក្ខជនស្ត្រីទាក់ទងនឹងការដោះស្រាយបញ្ហាស្ត្រី និងកុមារនៅក្នុងកម្មវិធីនយោបាយរបស់ខ្លួន ។ គណបក្ស និងបេក្ខជនមួយចំនួនក៏បានបង្ហាញពីការបង្កើតគោលនយោបាយសមភាពយេនឌ័រ ដើម្បីលើកស្ទួយការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត លើកស្ទួយសិទ្ធិកុមារ កុមារពិការ កុមារកំព្រា កុមារមកពីគ្រួសារក្រីក្រ គោរពសិទ្ធិស្ត្រី និងសិទ្ធិជនជាតិភាគតិច ព្រមទាំងជួយដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋ ជាពិសេសស្ត្រីមានផ្ទៃពោះ ស្ត្រីមេម៉ាយ ចាស់ជរា ជនពិការ និងកុមារដែលមានជីវភាពក្រីក្រ។

១៤.២.៣ អ្នកបោះឆ្នោតស្ត្រី

ស្ត្រីបានចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦ក្នុងបញ្ជីបោះឆ្នោតផ្លូវការ ចំនួន៤,២១០,៩១៤នាក់ ស្មើនឹង៥៣,៥៣% នៃចំនួនប្រុស-ស្រីដែលបានចុះឈ្មោះសរុប៧,៨៦៥,០៣៣នាក់ ហើយអ្នកបោះឆ្នោត ស្ត្រីសង្កេតឃើញថាមានចំនួនច្រើនជាងបុរសដែលបានចេញទៅបោះឆ្នោតនៅថ្ងៃបោះឆ្នោតផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយមានការខកខានប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងការចុះឈ្មោះបោះឆ្នោត និងទៅបោះឆ្នោត ដូចជា ចាស់ជរា ស្ត្រីទើបសម្រាលកូន ពិរុទ្ធជន ដែលមិនមានក្រុមចល័តទៅចុះឈ្មោះបោះឆ្នោតដល់ផ្ទះ ឬទីកន្លែងរបស់ពួកគាត់ និងអ្នកផ្លាស់ប្តូរទីលំនៅ ឬទៅតាមប្តី-ប្រពន្ធ ប្តូរទីកន្លែងធ្វើការ ជាពិសេសកម្មករ កម្មការិនីចំណាកស្រុកទៅក្រៅប្រទេសដែលមិនមាននីតិវិធីសម្របសម្រួលណាមួយឲ្យពួកគេបានអនុវត្តសិទ្ធិរបស់ខ្លួនស្របនឹងរដ្ឋធម្មនុញ្ញដែលបានធានាអំពីសិទ្ធិនេះ។

របាយការណ៍សង្កេតការណ៍ស្ត្រីរបស់ខុមហ្រ្វែលក្នុងខេត្តគោលដៅទាំង៥ ដូចជា ខេត្តកំពង់ចាម ខេត្ត កំពង់ឆ្នាំង ខេត្តកំពង់ធំ ខេត្តតាកែវ និងខេត្តព្រះវិហារ បង្ហាញថា ៣៨,៤៦%នៃអ្នកបោះឆ្នោតស្ត្រីខកខានមិន បានទៅបោះឆ្នោត និង/ឬមិនបានបោះឆ្នោត ដោយសារពួកគេជួបនូវភាពមិនប្រក្រតីមួយចំនួន ចំនួនដូចជា រវល់ធ្វើកិច្ចការផ្ទះ និងស្រែចម្ការ ជាប់រវល់លក់ដូរ បាត់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងមិនបានចុះឈ្មោះបោះឆ្នោត ។

១៤.២.៤ ស្ត្រីជាប់ឆ្នោត

ចំនួនស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤នេះមានការថយចុះចំនួន១.០២% (៩៨ នាក់) ពី១៧.៧៨% (២,០៣៨នាក់) ឆ្នាំ២០១២ មកត្រឹម១៦.៧៦% (១,៩៤០នាក់) ឆ្នាំ២០១៧ នៃចំនួនអ្នកជាប់ឆ្នោត ស្រី-ប្រុសសរុបចំនួន១១,៥៧២នាក់។ ប៉ុន្តែមានការកើនឡើងចំនួនមេឃុំ ចៅសង្កាត់ស្ត្រី ១.៩៦% (៣៣នាក់) ពី៥.៨១% (៩៥នាក់) ឆ្នាំ២០១២ ទៅ៧.៧៧% (១២៨នាក់)ឆ្នាំ២០១៧។ គណបក្សពីរ គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិបានទទួលសម្លេងឆ្នោតគាំទ្រពីអ្នកបោះឆ្នោត និងមានស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សា ឃុំ សង្កាត់ គឺ គណបក្សប្រជាជនកម្ពុជា មានស្ត្រីចំនួន១៣៨៧ នាក់ (២១.៣៣%) ក្នុងនោះមេឃុំ ចៅសង្កាត់ ស្ត្រីចំនួន៩២នាក់ (៧.៩៦%) ខណៈដែលគណបក្សសង្គ្រោះជាតិមានស្ត្រីចំនួន៥៥៣នាក់ (១១.០៤%) និង ៣៦នាក់ (៧.៣៦%)ជាមេឃុំ ចៅសង្កាត់ស្ត្រី ។

តួលេខនេះបង្ហាញថា កម្ពុជានឹងអាចប្រឈមក្នុងការធ្វើឲ្យបានសម្រេចតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព(SDG) ដែលបានកំណត់នៅឆ្នាំ២០៣០ ថា «ធ្វើឲ្យសម្រេចសមភាពយេនឌ័រ និងផ្តល់អំណាច ដល់ស្ត្រី និងកុមារីទាំងអស់ក្នុងលោក» នៅគ្រប់ថ្នាក់សម្រេចចិត្ត។ ដូច្នេះ រាជរដ្ឋាភិបាលកម្ពុជា ត្រូវបង្កើត និងអនុវត្តវិធានការពិសេសជាក់លាក់មួយចំនួនចាប់តាំងពីពេលនេះតទៅ ដើម្បីបង្កើនចំនួនស្ត្រីជាអ្នកដឹកនាំ ដៀសវាងការបរាជ័យដូចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDG) ។ ក្រៅពីខិតខំប្រឹងប្រែងបង្កើនចំនួនស្ត្រី ការយកចិត្តទុកដាក់ទៅលើគុណភាពនៃការចូលរួមរបស់ស្ត្រីកាន់តែជារឿងសំខាន់ គឺត្រូវធ្វើយ៉ាងណាឲ្យស្ត្រីមានសម្លេង ក្នុងការសម្រេចចិត្ត និងផ្តល់តួនាទី សិទ្ធិអំណាចឲ្យបានពេញលេញក្នុងពេលបំពេញការងារដោយគ្មានការ រើសអើងពីសំណាក់បុរសដែលជាសហការី និងអ្នកដឹកនាំ។

១៤.៣ យុវជន

ដំណាក់កាលនៃការបោះឆ្នោតពីរអាណត្តិ(បោះឆ្នោតឆ្នាំ២០១៣ និងបោះឆ្នោតឆ្នាំ២០១៧) ខុមប្រៃ្ហល បានសង្កេតឃើញថា ការចូលរួមរបស់យុវជននៅក្នុងការបោះឆ្នោត និងនយោបាយ កំពុងកើនឡើងជាលំដាប់នៅក្នុងប្រទេសកម្ពុជា។ ការកំណត់ថា ជាយុវជនបោះឆ្នោត គឺត្រូវបានកំណត់នៅក្នុងចំណោមប្រជាពលរដ្ឋដែលមានអាយុចន្លោះចាប់ពី១៨ ដល់៣៥ឆ្នាំ។ របាយការណ៍ផ្លូវការដែលចេញដោយ គ.ជ.ប បានបង្ហាញថា ក្នុងចំណោមអ្នកបោះឆ្នោត៧,៨៦៥,០៣៣នាក់ ក្នុងនោះចំនួនយុវជនដែលបានចុះឈ្មោះបោះឆ្នោត មានចំនួន២,៦២១,១៩០នាក់(៣៣.៣ភាគរយ) និងស្ត្រីជាយុវជនមានចំនួន១,៣៦៩,០៤៦នាក់(៥២.៣ភាគរយនៃចំនួនយុវជនសរុប)។

ក្នុងអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោត ការចូលរួមរបស់អ្នកបោះឆ្នោតជាយុវជនក្នុងសកម្មភាពឃោសនាត្រូវបានសង្កេតឃើញថាមានសកម្មភាពផុលផុស និងមាននិន្នាការថ្មីមួយសម្រាប់គណបក្សនយោបាយនៅក្នុងដំណើរការបោះឆ្នោត ក្នុងសម័យក្រោយសង្គ្រាមដែលពួកគេទទួលបាននូវការអប់រំខ្ពស់។ គណបក្សនយោបាយបានផ្តោតលើអ្នកបោះឆ្នោតជាយុវជន ហើយធ្វើការផ្លាស់ប្តូរយុទ្ធសាស្ត្រក្នុងយុទ្ធនាការថ្មីៗ ដើម្បីទាក់ទាញអ្នកបោះឆ្នោតយុវជន។ យុទ្ធសាស្ត្រទាំងនោះគឺគណបក្សនយោបាយបានដាក់បេក្ខភាពឈរឈ្មោះជាយុវជនសម្រាប់ការបោះឆ្នោតក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ និងការលើកស្ទួយឱ្យយុវជនចូលរួមឃោសនា។

បេក្ខជនឈរឈ្មោះបោះឆ្នោតសរុបបានបង្ហាញដោយ គ.ជ.ប ដែលមានអាយុពី២៥ ដល់ ៣៥ឆ្នាំ មានចំនួន ១០,២៨៥នាក់ (ក្នុងនោះស្ត្រីចំនួន ៤,២៦១នាក់ ស្មើនឹង ៤១.៤ភាគរយ) ត្រូវបានគណបក្សនយោបាយដាក់ឱ្យឈរឈ្មោះសម្រាប់ធ្វើការប្រកួតប្រជែងក្នុងការបោះឆ្នោត។ ក្នុងចំណោមយុវជនជាបេក្ខជនសម្រាប់ឈរឈ្មោះបោះឆ្នោត មានយុវជនពេញសិទ្ធិចំនួន ៤,៥៣៥នាក់ ក្នុងមានយុវជនពេញសិទ្ធិជាស្ត្រី មានចំនួន ១៧១៣នាក់។ នៅក្រោយការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧នេះ យុវជនដែលមានអាយុពី២៥ឆ្នាំ ដល់៣៥ឆ្នាំ បានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំសង្កាត់មានចំនួន ៨៦២នាក់ បើគិតពីអាយុ២៥ឆ្នាំដល់ ៣០ឆ្នាំ មានចំនួន ៣២៨នាក់។

លទ្ធផលជាប់ឆ្នោតសម្រាប់យុវជននេះ ឃើញថា បេក្ខជនមកពីគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះ (អាយុ២៥ ដល់៣៥ឆ្នាំ) មានចំនួនច្រើនជាងគណបក្សដទៃ ក្នុងនោះគណបក្សសង្គ្រោះជាតិជាប់ច្រើនជាងគេ គឺមានចំនួន៤៣៦នាក់ រីឯគណបក្សប្រជាជនកម្ពុជា គឺចំនួន៤២២នាក់។ គួរឱ្យកត់សម្គាល់និងតាមការសង្កេតរបស់អ្នកសង្កេតការណ៍នៅមូលដ្ឋានបានបង្ហាញថាយុវជនចូលរួមបោះឆ្នោតបានកើនជាងឆ្នាំ២០១២ ប្រហែលចន្លោះពី១០ ទៅ១៥ភាគរយ។ លទ្ធផលនៃការចូលរួមនេះ ខុមហ្វ្រែលសន្និដ្ឋានថាទោះបីយុវជនមានការចូលរួម និងធ្វើសកម្មភាពផលផុសក្នុងសកម្មភាពឃោសនា និងចូលរួមបោះឆ្នោតយ៉ាងក៏ដោយ ក៏យុវជនជាប់ឆ្នោតនៅតែទទួលបានឱកាស និងកំណើនជាប់ឆ្នោតតិចតួច បើប្រៀបធៀបជាមួយលទ្ធផលបោះឆ្នោតឆ្នាំ២០១២។

រូបភាពទី២៦ យុវជនចូលរួមឃោសនាបោះឆ្នោត

១៥. ការផ្តល់ភាគអ្នកសង្កេតការណ៍ និងគ្លាក់ចារគណបក្សនយោបាយ

១៥.១ ចំនួននៃអ្នកសង្កេតការណ៍ឯករាជ្យដែលបានទទួលស្គាល់

ជាទូទៅ ការរៀបចំបញ្ជីឈ្មោះអ្នកសង្កេតការណ៍ សម្រាប់ចូលរួមពិនិត្យមើលការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់របស់ខុមហ្វ្រែល អាចចំណាយពេលយ៉ាងយូរ២ថ្ងៃ (អាស្រ័យឈ្មោះអ្នកសង្កេតការណ៍ច្រើន ឬតិច) ដោយសារយើងត្រូវពិនិត្យមើលអត្តរាវិរុទ្ធ ឈ្មោះស្ងួន ថ្ងៃខែឆ្នាំកំណើត (គ្រប់អាយុចុះឈ្មោះឬអត់) និង ថាតើទម្រង់ឯកសារត្រូវបានរៀបចំតាមទម្រង់ គ.ជ.ប ឬអត់។ បទពិសោធន៍ពីការរៀបចំស្នើឈ្មោះអ្នកសង្កេតការណ៍សម្រាប់ការបោះឆ្នោតឃុំ សង្កាត់ និងរយៈពេល ដែលបានទទួលសេចក្តីសម្រេចដោយ គ.ជ.ប គឺជាមធ្យម១សប្តាហ៍ ទើបទទួលបាន (ទោះបញ្ជីដែលស្នើឈ្មោះអ្នកសង្កេតការណ៍តិច ឬច្រើនក៏ដោយ)។ ហេតុផលដែលត្រូវបានផ្តល់ដោយការិយាល័យកិច្ចការគណបក្សនយោបាយ និងអ្នកសង្កេត

ការណ៍ និងតាមរយៈសំណុំឯកសារច្បាប់ដើមដែលសម្រេចដោយ គ.ជ.ប គឺដោយសារ ទំរាំបានសេចក្តីសម្រេចអនុញ្ញាត សម្រាប់សង្កេតការណ៍ ត្រូវឆ្លងកាត់ការចុះហត្ថលេខាពីប្រធាននាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មពិនិត្យ និងបន្ទាប់មកបញ្ជូនទៅខុទ្ទកាល័យឯកឧត្តមប្រធាន គ.ជ.ប ចុះហត្ថលេខា និងវាយត្រា។ ហេតុនេះ បើគ្មានវត្តមានពួកគាត់ទេ ឯកសារទាំងអស់ គឺមិនអាចចេញបានឡើយ។

តាមរយៈបទពិសោធន៍ ក្នុងការដាក់ពាក្យអ្នកសង្កេតការណ៍កន្លងមក បើបើកសំបកកាតនៅតាមរាជធានី ខេត្ត គឺ មិនមានភាពខ្វះខាតអ្វីឡើយ តែសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់នេះ ស្ទើរតែគ្រប់ខេត្តគឺ គធ.ខប ខ្វះខាតសំបកកាតដើម្បីបើកឲ្យខុមប្រ៊ែលៗ។

ចំនួនអ្នកសង្កេតការណ៍ជាតិសរុប ដែលបានដាក់ទៅ គ.ជ.ប ពីគ្រប់ស្ថាប័នជាអង្គការ សមាគម មានជាង ៧៤,៦៧១នាក់ ក្នុងនោះ ខុមប្រ៊ែលមានចំនួន១៤,៥៨០នាក់។ សូមមើលតារាងខាងក្រោម៖

តារាងទី១៨ ឈ្មោះអង្គការដែលបានដាក់ពង្រាយអ្នកសង្កេតការណ៍ក្នុងឆ្នាំ២០១៧[253]

ល.រ	ឈ្មោះសមាគម ឬអង្គការ	អ្នកសង្កេតការណ៍ជាតិ		
		សរុប	ស្ត្រី	ចល័ត
01	សហភាពសហព័ន្ធយុវជនកម្ពុជា (UYFC)	31,431	9,293	0
02	សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ (CWPD)	20,793	20,717	10
03	គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)	14,580	6,153	10
04	សហព័ន្ធនិស្សិត បញ្ញាវន្ត ប្រជាធិបតេយ្យកម្ពុជា (CDSIF)	2,642	1,407	10
05	អង្គការតម្លាភាពកម្ពុជា (TIC)	1,239	560	10
06	គណៈកម្មាធិការអព្យាក្រឹត្យ និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា (NICFEC)	1,052	411	10
07	គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW)	567	304	10
08	សមាគមរួបរួមគ្នាដើម្បីអភិវឌ្ឍន៍កម្ពុជា (CCDA)	438	19	0
09	សមាគមយុវជនកិច្ចការសង្គម	407	145	0
10	សហគមន៍អភិវឌ្ឍន៍ជាតិ (UND)	265	45	3
11	មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីការអភិវឌ្ឍន៍ និងសន្តិភាព (PDP-Center)	228	107	10
12	អង្គការប្រជាធិបតេយ្យ និងសិទ្ធិមនុស្សក្នុងប្រតិបត្តិការ (DHRAC)	201	104	8
13	សមាគមសិទ្ធិមនុស្សដើម្បីអភិវឌ្ឍន៍ និងថែរក្សាកុមារកំព្រាស្ត្រីក្រីក្រ (CO.PA)	162	45	7
14	អង្គការជនពិការកម្ពុជា (CDPO)	141	61	0
15	អង្គការសេវាប្រជាធិបតេយ្យ (DSO)	134	48	6
16	សមាគមយុវជនសេដ្ឋកិច្ចកម្ពុជា (ស.យ.ស.ក)	119	51	0

[253] Information provided by the National Election Committee.

17	សមាគម បញ្ញាវ័ន្ត និងយុវជនស្ម័គ្រចិត្ត (VIVA)	64	27	10
18	សហព័ន្ធសិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា (C.FHRAD)	60	30	0
19	សមាគមអ្នកលក់ឌីសថកម្ពុជា (C.P.A)	60	26	0
20	វិទ្យាស្ថានអភិវឌ្ឍន៍ធនធានមនុស្ស	50	2	0
21	សមាគម សិស្ស និស្សិត បញ្ញាវ័ន្តក្មេងវត្ត (PCISA)	38	0	0
សរុប		**74,671**	**39,555**	**104**

៥.២ ចំនួននៃភ្នាក់ងារគណបក្សនយោបាយ

មានគណបក្សនយបាយចំនួន១២ បានធ្វើការប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧។ សម្រាប់ការបោះឆ្នោតឆ្នាំ២០១៧ គ.ជ.ប បានទទួលស្គាល់អ្នកសង្កេតការណ៍ជាភ្នាក់ងារគណបក្សនយោបាយសម្រាប់សង្កេតការណ៍បោះឆ្នោតចំនួន១០៥,០៧៦នាក់ ក្នុងចំណោមគណបក្សប្រកួតប្រជែងទាំង១២។ គណបក្សប្រជាជនកម្ពុជា ជាគណបក្សកាន់អំណាចបានដាក់ពង្រាយអ្នកសង្កេតការណ៍ចំនួន៤៤,៦១៤នាក់ និងគណបក្សសង្គ្រោះជាតិដែលជាគណបក្សប្រឆាំងបានដាក់ពង្រាយអ្នកសង្កេតការណ៍ចំនួន៤៣,៥៩៦នាក់។ គណបក្សហ៊្វុនស៊ិនបិច បានដាក់ពង្រាយអ្នកសង្កេតការណ៍ចំនួន ៤,៩៨៨នាក់ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យបានដាក់ពង្រាយអ្នកសង្កេតការណ៍ចំនួន៥,១៦៦នាក់ (ភាគច្រើននៃពួកគេ គឺជាយុវជន) គណបក្សខ្មែររួបរួមជាតិ ដាក់ពង្រាយអ្នកសង្កេតការណ៍ចំនួន៥,១៩៩នាក់ គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យដាក់ពង្រាយអ្នកសង្កេតការណ៍ចំនួន៨៣៤នាក់ គណបក្សសញ្ជាតិខ្មែរដាក់ពង្រាយអ្នកសង្កេតការណ៍ចំនួន៩នាក់ គណបក្សប្រជាធិបតេយ្យមូលដ្ឋាន ដាក់ពង្រាយអ្នកសង្កេតការណ៍ចំនួន៣៤៤នាក់ គណបក្សយុវជនកម្ពុជា ដាក់ពង្រាយអ្នកសង្កេតការណ៍ចំនួន៥៦នាក់ គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជាដាក់ពង្រាយអ្នកសង្កេតការណ៍ចំនួន១០៨នាក់ គណបក្សអំណាចខ្មែរដាក់ពង្រាយង្កសង្កេតការណ៍ចំនួន៩៨នាក់ និងគណបក្សសាធារណៈរដ្ឋប្រជាធិបតេយ្យដាក់ពង្រាយអ្នកសង្កេតការណ៍ចំនួន៦៤នាក់។

តារាងទី១៩ ចំនួនភ្នាក់ងារគណបក្សនយោបាយបានដាក់ពង្រាយអ្នកសង្កេតការណ៍បោះឆ្នោតឆ្នាំ២០១៧

លរ.	ឈ្មោះគណបក្សនយោបាយ	ចំនួនភ្នាក់ងារគណបក្សនយោបាយ	
		សរុប	ស្ត្រី
01	គណបក្សប្រជាជនកម្ពុជា (ប្រ.ជ)	44,614	7,369
02	គណបក្សសង្គ្រោះជាតិ (គ.ស.ជ)	43,596	10,058

03	គណបក្សហ៊្វុនស៊ិនប៉ិច(រាជកឯអសស)[254]	4,988	1,819
04	គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ (គ.ស.ប)	5,166	1,364
05	គណបក្សខ្មែររួបរួមជាតិ (ខ.រ.ជ)	5,199	1,876
06	គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ (គ.ស.ស.ប)	834	219
07	គណបក្សសញ្ជាតិកម្ពុជា (គ.ស.ក)	9	6
08	គណបក្សប្រជាធិបតេយ្យមូលដ្ឋាន (គ.ប.ម)	344	108
09	គណបក្សយុវជនកម្ពុជា (គ.យ.ក)	56	20
10	គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា (គ.ជ.ប.ក)	108	19
11	គណបក្សអំណាចខ្មែរ (គ.អ.ខ)	98	50
12	គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ (គ.ស.រ.ប)	64	16
សរុប		**105,076**	**22,924**

គ.ជ.ប បានទទួលស្គាល់អ្នកសង្កេតការណ៍អន្តរជាតិចំនួន៣៨៤នាក់ មកពី៣៤ អង្គការអន្តរជាតិ ស្ថានទូត និងប្រទេសផ្សេងៗ។ ចំនួនសអ្នកសង្កេតការណ៍ដែលដាក់ពង្រាយចំនួនច្រើនជាងគេ គឺមកពីស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅទីរាជធានីភ្នំពេញ ដែលបានដាក់ពង្រាយអ្នកសង្កេតការណ៍ចំនួន៩៨នាក់។ តួលេខបន្ទាប់ គឺបណ្តាញអាស៊ានសម្រាប់ការបោះឆ្នោត (ANFREL) ដែលបានដាក់ពង្រាយអ្នកសង្កេតការណ៍ចំនួន៥១នាក់។

តារាងទី២០ ការទទួលស្គាល់អ្នកសង្កេតការណ៍អន្តរជាតិសម្រាប់ការបោះឆ្នោតឆ្នាំ២០១៧

ល.រ	**ឈ្មោះអ្នកសង្កេតការណ៍អន្តរជាតិ**	**ចំនួនអ្នកសង្កេតការណ៍**	
		សរុប	**ស្ត្រី**
01	ស្ថានទូតសហរដ្ឋអាមេរិកក្នុងរាជធានីភ្នំពេញ	98	28
02	បណ្តាញអាស៊ានសម្រាប់ការបោះឆ្នោត (ANFREL)	51	14
03	Australian Embassy in Phnom Penh ស្ថានទូតអូស្ត្រាលីក្នុងរាជធានីភ្នំពេញ	26	13
04	EU (including 3 interpreters)	22	9

[254] FUNCIPEC is an acronym for Front uni national pour un Cambodge indépendant neutre, pacifique et coopératif (United national front for an independent, neutral, peaceful, and cooperative Cambodia).

	សហគមន៍អឺរ៉ុន (រួមទាំងអ្នកបកប្រែ ៣នាក់)		
05	Centrist Democrats International (CDI) អង្គការ ស៊ីឌីអាយ	22	4
06	International Conference of Asian Political Parties (ICAPP)	18	6
07	National Democratic Institute (NDI) វិទ្យាស្ថានជាតិដើម្បីប្រជាធិបតេយ្យ)អិនឌីអាយ(	17	8
08	Centrist Asia-Pacific Democrats International (CAPDI)	16	3
09	Sweden Embassy in Phnom Penh ស្ថានទូតស្វីសក្នុងរាជធានីភ្នំពេញ	14	9
10	Japan Embassy in Phnom Penh ស្ថានទូតជប៉ុនក្នុងរាជធានីភ្នំពេញ	11	4
11	Germany Embassy in Phnom Penh ស្ថានទូតអាឡឺម៉ង់ក្នុងរាជធានីភ្នំពេញ	11	4
12	People´s Republic of China Embassy in Phnom Penh ស្ថានទូតសាធារណៈរដ្ឋចិនក្នុងរាជធានីភ្នំពេញ	9	2
13	DAN Church Aid	7	2
14	Swiss Cooperation office and Swiss Consular Agency in Cambodia	6	2
15	Inter Band Organization	6	2
16	Royal Thai Embassy in Phnom Penh ស្ថានទូតព្រះរាជាណាចក្រថៃក្នុងរាជធានីភ្នំពេញ	6	2
17	Canada Embassy in Phnom Penh ស្ថានទូតកាណាដាក្នុងរាជធានីភ្នំពេញ	5	2
18	British Embassy in Bangkok ស្ថានទូតអង់គ្លេសក្នុងទីក្រុងបាងកក	5	1
19	The Socialist Republic of Vietnam Embassy in the Kingdom of Cambodia	4	
20	International For Electoral Systems (IFES) អង្គការអាយហ្វេស	4	1
21	French Embassy in Cambodia ស្ថានទូតបារាំងក្នុងប្រទេសកម្ពុជា	4	1

22	The Embassy of the Republic of the Philippines in PP ស្ថានទូតសាធារណៈរដ្ឋក្នុងរាជធានីភ្នំពេញ	3	1
23	Poland Embassy in Bangkok ស្ថានទូតប៉ូឡូញក្នុងទីក្រុងបាងកក	2	1
24	Indonesian Embassy in PP ស្ថានទូតឥណ្ឌូនេស៊ីក្នុងរាជធានីភ្នំពេញ	2	1
25	អង្គការ ជីធីហ្សែត (GIZ)	2	1
26	The Democratic Republic of Timor Lester Embassy in PP ស្ថានទូតទីម័រឡេស្តេក្នុងរាជធានីភ្នំពេញ	2	
27	Singapore Embassy in Phnom Penh ស្ថានទូតសង្ហបុរីក្នុងរាជធានីភ្នំពេញ	2	
28	Brunei Darussalam Embassy in Phnom Penh ស្ថានទូតប្រ៊ុយណេក្នុងរាជធានីភ្នំពេញ	2	1
29	Japan International Cooperation Agency in Cambodia (JICA)	2	
30	Belgium Embassy in Bangkok ស្ថានទូតបេហ្ស៊ិកក្នុងទីក្រុងបាងកក	1	1
31	New Zealand Embassy in Bangkok ស្ថានទូតញ៉ូហ្ស៊ីឡេន ក្នុងទីក្រុងបាងកក	1	1
32	Finland Embassy of Phnom Penh ស្ថានទូតហ្វាំងឡង់ក្នុងរាជធានីភ្នំពេញ	1	
33	Malaysia Embassy of Phnom Penh ស្ថានទូតម៉ាឡេស៊ីក្នុងរាជធានីភ្នំពេញ	1	
34	Embassy of Switzerland in Thailand ស្ថានទូតស្វីសក្នុងព្រះរាជាណាចក្រថៃ	1	
សរុប		**384**	**124**

១៥.៣ ការសហការណ៍ និងជួយសម្រួលរបស់ គ.ជ.ប ក្នុងដំណើរការរៀបចំកាតអ្នកសង្កេតការណ៍

ថ្វីត្បិតតែដំណើរការដាក់ពាក្យស្នើសុំអ្នកសង្កេតការមានភាពលំបាក តែក្នុងនោះ យើងក៏ឃើញថា គ.ជ.ប បានប្រឹងប្រែងកែសម្រួល នីតិវិធី និងសម្រួលការងារមួយចំនួន៖

- កែសម្រួលនីតិវិធីដោយមិនចាំបាច់ឲ្យសាមីខ្លួនចុះហត្ថលេខាលើប័ណ្ណសម្គាល់អ្នកសង្កេតការណ៍ មុនការចុះហត្ថលេខាលើកាត និងវាយត្រាដោយ លធ.ខប។

- ជួយសម្រួលទទួលពាក្យស្នើសុំធ្វើជាអ្នកសង្កេតការណ៍បន្ថែម ដោយសារកំហុសបច្ចេកទេសខុមហ្វ្រែលខកខានមិនបានដាក់ពាក្យស្នើសុំ បើទោះជាមានការហួសកំណត់កាលបរិច្ឆេទទទួលពាក្យអ្នកសង្កេតការណ៍ (បញ្ជីឈ្មោះអ្នកសង្កេតការណ៍ខេត្តកំពតចំនួន២៣៣នាក់)។ ព្រមទាំងរៀបចំសម្រួលនីតិវិធីបន្តទៀតជាមួយ លធ.ខប ខេត្តសាមី ដើម្បីបានសំបកកាត និងផ្តល់ឲ្យ ខុមហ្វ្រែលខេត្តយកទៅបំពេញព័ត៌មានអ្នកសង្កេតការណ៍ និងចុះហត្ថលេខាពី លធ.ខប។
- ការជួយសម្រួលក្នុងការផ្តល់សំបកកាតពីដោយផ្ទាល់ពី គ.ជ.ប ទៅ លធ.ខប ទៅតាមចំនួនកាតជាក់ស្តែងដែលខុមហ្វ្រែលខ្វះ នៅតាមខេត្ត រាជធានី បន្ទាប់ពីមានការផ្តល់ព័ត៌មានពីក្រុមការងារស្នាក់ការកណ្តាលខុមហ្វ្រែល។ ករណីនេះដោយសារនៅតាម បណ្តាខេត្តរាជធានី មិនមានសំបកកាតដើម្បីបើកឲ្យលេខាខុមហ្វ្រែល ជាពិសេសគឺនៅពេលគៀកជិតដល់កាលបរិច្ឆេទឈប់ទទួលពាក្យអ្នកសង្កេតការណ៍។
- ការសម្រួលពាក់ព័ន្ធការកែតម្រូវឯកសារ បញ្ជីឈ្មោះអ្នកសង្កេតការណ៍ដែលខ្វះខាត ឬខុសថ្ងៃខែ និងផ្តល់ព័ត៌មានដល់ក្រុមការងារស្នាក់ការកណ្តាលឲ្យកែតម្រូវភ្លាមៗ។

១៦. ការគាំទ្រសង្គមស៊ីវិល និងការចូលរួមជាមួយគោលនយោបាយទាក់ទងសកម្មភាពបោះឆ្នោតរបស់ខុមហ្វ្រែល

បញ្ជីឈ្មោះបោះឆ្នោតបឋម (នៅតែទទួលរងពាក្យបណ្តឹង និងការលុបឈ្មោះ) គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានប្រកាសថា ខ្លួនបានចុះឈ្មោះអ្នកបោះឆ្នោតដោយជោគជ័យនូវអ្នកបោះឆ្នោតចំនួន៧,៨៦៤,៤២៩នាក់ (ប្រហែល៨០ភាគរយនៃស្ថិតិប៉ាន់ប្រមាណ៩,៧លាននាក់)។ របាយការណ៍នេះ ក៏បានជូនដំណឹងផងដែរដល់អ្នកពាក់ព័ន្ធសំខាន់ៗ និងសាធារណៈថា ខ្លួនបានត្រៀមរួចរាល់ក្នុងការលុបឈ្មោះ ៨,៣៨៦ឈ្មោះ ចេញពីបញ្ជីឈ្មោះបោះឆ្នោត ដែលក្នុងនោះមានឈ្មោះចំនួន២,៧៣៧ ដែលត្រូវបានគេបោះបង់ចោលពីកម្មវិធីកាលចុះឈ្មោះសាកល្បង ដែលត្រូវបានប្រើដើម្បីវាយតម្លៃលើការអនុវត្តន៍លើប្រព័ន្ធចុះឈ្មោះបោះឆ្នោតថ្មី។[255] នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៧ គ.ជ.ប បានប្រកាសតាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងអ្នកពាក់ព័ន្ធសំខាន់ៗ ថាបញ្ជីនេះនឹងមានសម្រាប់អ្នកបោះឆ្នោត បន្ទាប់ពីនោះ វានៅតែអាចរកបាននៅលើអ៊ីនធឺណិត។ អង្គការសង្គមស៊ីវិលនានា បានផ្តល់អនុសាសន៍ថា គ.ជ.ប គាំទ្រយុទ្ធនាការផ្សព្វផ្សាយតាមរយៈប្រព័ន្ធអ៊ិនធឺណេត និងព័ត៌មានសង្គម ដើម្បីលើកកម្ពស់ការយល់ដឹងរបស់អ្នកបោះឆ្នោត និងបង្កើនអត្រាអ្នកបោះឆ្នោតដែលផ្ទៀងផ្ទាត់ព័ត៌មានរបស់ពួកគេនៅក្នុងបញ្ជី។[256]

[255] “Preliminary voter lists made available to the public” Cambodia Daily, 4 January 2017.

[256] Hean, Socheata “New voter registration list released ahead of local elections” VOA, 5 January 2017

នៅដើមឆ្នាំនេះគេហទំព័ររបស់ គ.ជ.ប ត្រូវបានគេលួចចូល។ ការព្រួយបារម្ភចំពោះសក្តានុពលក្នុងការបំផ្លាញទិន្នន័យ ឬផលប៉ះពាល់លើទិន្នន័យ ដែលប្រមូលបានទាក់ទងទៅនឹងលទ្ធផលនៃការបោះឆ្នោតដែលបានលើកឡើងក្នុងគេហទំព័រ និងសារៈសំខាន់នៃការចុះឈ្មោះអ្នកបោះឆ្នោតទំនើប ដែលផ្អែកលើប្រព័ន្ធថ្មីជាមួយនឹងការប្រើប្រាស់ជីវមាត្រ (ផ្តិតស្នាមក្រយៅដៃហើយបំលែងជាកូដ)នេះ គឺជាបញ្ហាដ៏សំខាន់មួយសម្រាប់ភាពត្រឹមត្រូវនៃការបោះឆ្នោត។ ទោះជាយ៉ាងណាក៏ដោយ គ.ជ.ប បានធ្វើសកម្មភាពប្រកបដោយសមត្ថភាព និងមានតម្លាភាព ដោយផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានពាក់ព័ន្ធនឹងបញ្ហា និងពន្យល់ដល់អ្នកពាក់ព័ន្ធសំខាន់ៗថា ហេតុអ្វីបានជាអ្នកលួច(Hack) មិនបានធ្វើឱ្យខូចប្រព័ន្ធ និងបញ្ជីឈ្មោះអ្នកបោះឆ្នោត។ ខុមហ្វ្រែល និងអង្គការសង្គមស៊ីវិលដែលជាដៃគូបានសង្កេត និងវិភាគស្ថានភាពហើយបានរកឃើញថា គ.ជ.ប បានគ្រប់គ្រងបញ្ហានេះដោយសមរម្យ ហើយបានប្រាប់ដល់ប្រព័ន្ធផ្សព្វផ្សាយថា ខ្លួនគាំទ្រការវាយតម្លៃរបស់ គ.ជ.ប។[257] គ.ជ.ប ក៏បានប្រកាសអំពីបញ្ហានៅពេលនោះទាក់ទងទៅនឹងអ្នកទស្សនាគេហទំព័រដែលពិបាកក្នុងការបើកមើល ហើយការបង្កើននូវល្បឿនសម្រាប់អ្នកចូលមើលគេហទំព័រ ត្រូវបានគេរៀបចំ។[258] អ្នកទស្សនាជាច្រើនមិនអាចចូលបើកគេហទំព័រនេះបានទេ ពួកគេជួបបញ្ហានៃការចូល និងការតភ្ជាប់ល្បឿនលឿន។ គ.ជ.ប ត្រូវបានគេមើលឃើញថា មានលទ្ធភាពទទួលបានការឆ្លើយតបចំពោះតម្រូវការរបស់ប្រជាពលរដ្ឋ ហើយតម្រូវការខ្ពស់ពីអ្នកបោះឆ្នោតដែលមានសិទ្ធិបោះឆ្នោត គឺជាសញ្ញាល្អនៃចេតនាចូលរួមក្នុងការបោះឆ្នោត។ ខុមហ្វ្រែលបានផ្តល់ព័ត៌មានដល់ប្រព័ន្ធផ្សព្វផ្សាយ និងស្ថាប័នបោះឆ្នោត ក៏ដូចជារដ្ឋាភិបាល ដែលបានដាក់ពង្រាយអ្នកឃ្លាំមើលការបោះឆ្នោតចំនួន២៦៩នាក់ ដែលបានទទួលការបណ្តុះបណ្តាលឱ្យសង្កេតមើលដំណើរការ និងកត់ត្រាភាពមិនប្រក្រតី។[259]

នៅចុងខែមករា គ.ជ.ប បានបញ្ចប់ការពិនិត្យឡើងវិញលើពាក្យបណ្តឹង ដែលទាក់ទងនឹងការចុះឈ្មោះអ្នកបោះឆ្នោតឆ្នាំ២០១៦ និងលទ្ធផលនៃបញ្ជីឈ្មោះបោះឆ្នោត។ ពាក្យបណ្តឹងសរុបចំនួន១៤២ ត្រូវបានបញ្ជូនដោយភ្នាក់ងារ ឬអ្នកគាំទ្រគណបក្សសង្គ្រោះជាតិ ពាក់ព័ន្ធនឹងជនបរទេសប្រហែល២,៥០០នាក់ដែលបានចុះឈ្មោះបោះឆ្នោត។ ពីលើការកាត់បន្ថយចំនួនពាក់កណ្តាលនៃឈ្មោះចំនួនជិត៥,០០០ ដើម្បីពិនិត្យឡើងវិញការស៊ើបអង្កេតដំបូង គឺ១៨១ឈ្មោះដែលបានដាក់ជូនដោយគណបក្សប្រឆាំងបានរកឃើញឈ្មោះចំនួន១៤ ដែលមិនដែលមាននៅក្នុងបញ្ជី។[260] គ.ជ.ប បានរកឃើញថា មានតែពាក្យបណ្តឹងពីរប៉ុណ្ណោះដែលទាមទារការស៊ើបអង្កេតបន្ថែម។ នៅពេលនោះក្រសួងមហាផ្ទៃបានប្រកាសថា ១៧៩ឈ្មោះនៃបញ្ជី ដែលខ្លួនបានទទួលកាលពីថ្ងៃទី១៥ ខែមករា មាន១៥២ឈ្មោះត្រូវបានគេផ្ទៀងផ្ទាត់ជាមួយនឹងប្រព័ន្ធ

[257] Lay, Samean "NEC says website hacked" Phnom Pen Post, 6 January 2017.

[258] Khuon, Narim "Police probe hack of voter list website" Cambodia Daily, 6 January 2017.

[259] Taing, Vida "Technical issue mars voter list publication" Khmer Times, 4 January 2017.

[260] Lay, Samean "CNRP's voter roll challenged rebuffed" Phnom Penh Post, 17 January 2017.

ទិន្នន័យរបស់ក្រសួងមហាផ្ទៃ។[261] ក្រុមអ្នកសង្កេតការណ៍បានរកឃើញថា បញ្ហានេះមិនបាននាំឱ្យមានការខ្វែងគំនិតគ្នារវាងគណបក្សធំៗពីរ ឬគំរាមកំហែងខ្លាំងដល់ការធ្វើឱ្យប៉ះពាល់ភាពជឿជាក់នៃបញ្ជីឈ្មោះអ្នកបោះឆ្នោតនោះទេ។ លើសពីនេះទៅទៀត វាត្រូវបានរកឃើញថា គ.ជ.ប ធ្វើសកម្មភាពប្រកបដោយសមត្ថភាព និងវិជ្ជាជីវៈ ហើយបានចេញសេចក្តីសម្រេចរបស់ខ្លួន ស្របតាមច្បាប់នៃអាណត្តិរបស់ខ្លួន។[262] ខុមហ្វ្រែលបានធ្វើការតស៊ូមតិ ដើម្បីឱ្យមានតម្លាភាពកាន់តែទំលំទូលាយថែមទៀត ទាក់ទងនឹងលក្ខណៈនៃការទទួលបានឯកសារបញ្ជាក់អត្តសញ្ញាណ ដែលជាដំណោះស្រាយចំពោះករណីដែលមានជម្លោះ ឬភាពមិនច្បាស់លាស់។[263] ខុមហ្វ្រែលក៏បានផ្តល់អនុសាសន៍ ស្តីពីការគាំទ្រដល់ការកែលម្អ បទបញ្ជា និងនីតិវិធី។[264]

ថ្ងៃទី៣០ ខែមករា ក្រុមប្រឹក្សាធម្មនុញ្ញបានចាប់ផ្តើមពិនិត្យឡើងវិញនូវពាក្យបណ្តឹងនៅ គ.ជ.ប អំពីបញ្ជីឈ្មោះបោះឆ្នោត ដែលប្តឹងដោយគណបក្សសង្គ្រោះជាតិ ហើយបណ្តឹងទាំងនោះត្រូវបានបដិសេធចោលដោយ គ.ជ.ប ផងដែរ។ ពាក្យបណ្តឹងសរុបចំនួន២,៤៤១ ពាក្យបណ្តឹងត្រូវបានបដិសេធដោយសារតែមានភស្តុតាងមិនគ្រប់គ្រាន់។[265] នៅពាក់កណ្តាលខែកុម្ភៈ ក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសលទ្ធផលនៃការស៊ើបអង្កេតរយៈពេល៩ថ្ងៃលើពាក្យបណ្តឹងដំទាស់នឹងអ្នកចុះឈ្មោះបោះឆ្នោតចំនួន២,០០០នាក់ ក្នុងបញ្ជីឈ្មោះបោះឆ្នោតរបស់គណបក្សសង្គ្រោះជាតិ។ ក្រុមប្រឹក្សាធម្មនុញ្ញ បានរក្សាសេចក្តីសម្រេចរបស់ គ.ជ.ប ដោយបានបដិសេធពាក្យបណ្តឹងរបស់គណបក្សសង្គ្រោះជាតិ ចំនួន៧៨ករណី។ អ្នកនាំពាក្យក្រុមប្រឹក្សាធម្មនុញ្ញបានឲ្យដឹងថា អ្នកបានចុះឈ្មោះបោះឆ្នោតចំនួន២,០០០នាក់នោះ ត្រូវបានស៊ើបអង្កេតហើយរកឃើញថាពួកគេមានអត្តសញ្ញាណប័ណ្ណត្រឹមត្រូវ និងបានបញ្ជាក់ថា ការការចុះឈ្មោះអ្នកបោះឆ្នោតរបស់ពួកគេនោះគឺត្រឹមត្រូវស្របតាមច្បាប់។[266]

នៅសប្តាហ៍ទី៣ ខែកុម្ភៈ គ.ជ.ប បានផ្សព្វផ្សាយប្រតិទិននៃការបោះឆ្នោត រួមទាំងកាលបរិច្ឆេទកំណត់សំខាន់ៗ សម្រាប់ការចុះឈ្មោះគណបក្ស និងបេក្ខជននៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍។ គ.ជ.ប បានផ្តល់តែរយៈពេល ៣ថ្ងៃ (ពីថ្ងៃទី៣ ដល់ថ្ងៃទី៥ ខែមីនា) សម្រាប់គណបក្សចុះឈ្មោះ

[261] Lay, Samean "NEC end complaint review" Phnom Penh Post, 27 January 2017.

[262] A CNRP official expressed the view that the solution provided by the MoI was inadequate because it did not investigate the legitimacy of the Khmer ID cards in those cases. Nevertheless, such an investigation would fall under the authority of the MoI, rather than the NEC, and so the NEC acted within its mandate by seeking to ensure valid identification (rather than assessing citizenship) in the disputed cases.

[263] Lay, Samean "CNRP's voter roll challenged rebuffed" Phnom Penh Post, 17 January 2017; Lay, Samean "NEC end complaint review" Phnom Penh Post, 27 January 2017.

[264] Lay, Samean "Comfrel critiques opacity of the voter review process" Phnom Penh Post, 18 January 2017.

[265] Khuom, Narim "Council starts rejecting CNRP voter complaints" Cambodia Daily, 31 January 2017.

[266] Lay, Samean "Council back NEC in rejecting CNRP claims" Phnom Penh Post, 13 February 2017.

បេក្ខជននៃគណបក្សខ្លួន ដូច្នេះវាចាំបាច់ណាស់ដែលគណបក្សនយោបាយត្រូវរៀបចំទុកជាមុន។[267] គ.ជ.ប ក៏បានណែនាំដល់គណបក្សនយោបាយ ឱ្យដាក់បេក្ខជនបម្រុងផងដែរ។ អ្នកឃ្លាំមើលឯករាជ្យ និងអង្គការសង្គមស៊ីវិល យល់ឃើញថាការប្រកាស និងការកំណត់ពេលវេលាអាចទទួលយកបាន ទោះបីជាមានរយៈពេលខ្លីបន្តិចក្នុងការចុះបញ្ជីបេក្ខជនគណបក្សនយោបាយក៏ដោយ។ ខុមហ្វ្រែល និងអង្គការដៃគូបានធ្វើការផ្សព្វផ្សាយព័ត៌មានការចុះបញ្ជីនេះតាមបណ្តាញព័ត៌មានរបស់ខ្លួន ដើម្បីបង្កើនការយល់ដឹងដល់អ្នកបោះឆ្នោត និងគណបក្ស ឬបេក្ខជនផងដែរ។

In late February, COMFREL and civil society partners engaged with media and other key stakeholders to disseminate a collaborative plan for the monitoring and observation of the 2017 elections, and ensure that related CSO activities were conducted in a fully transparent manner and in accordance with best practices for election monitoring. As reported by national media:

នៅចុងខែកុម្ភៈ ខុមហ្វ្រែល និងអង្គការសង្គមស៊ីវិលជាដៃគូ បានផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកពាក់ព័ន្ធសំខាន់ៗ អំពីផែនការសហការគ្នាដើម្បីសង្កេតដំណើរការបោះឆ្នោតឆ្នាំ២០១៧ និងធានាថា សកម្មភាពអង្គការសង្គមស៊ីវិលដែលពាក់ព័ន្ធត្រូវបានធ្វើឡើងដោយមានតម្លាភាពយ៉ាងពេញលេញ និងស្របតាមការអនុវត្តល្អបំផុតសម្រាប់ការសង្កេតការណ៍ ការបោះឆ្នោត។ ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកបានលើកឡើងថា «គម្រោងមួយដែលមានឈ្មោះថា បន្ទប់ស្ថានការណ៍សម្រាប់ការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់នៅកម្ពុជា ឆ្នាំ២០១៧ ត្រូវបានចាប់ផ្តើម នឹងដំណើរការរហូតដល់ខែកក្កដា ឆ្នាំ២០១៧។ បន្ទប់ស្ថានការណ៍នេះ គឺជាការប្រមូលផ្តុំមកពីសម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត(ERA) អង្គការសង្គមស៊ីវិលឯករាជ្យ និងអ្នកជំនាញ ដើម្បីប្រមូលធនធាន បង្កើនសមត្ថភាព និងរួមចំណែកជាមូលនិធិ ឬការគាំទ្រ ដើម្បីដាក់ពង្រាយអ្នកសង្កេតការណ៍នៅថ្ងៃបោះឆ្នោត។ តំណាងបន្ទប់ស្ថានការណ៍បាននិយាយថា បន្ទប់ស្ថានការណ៍ គឺជាវេទិកាមួយសម្រាប់ចែករំលែក និងធ្វើបច្ចុប្បន្នភាពព័ត៌មាន វាយតម្លៃផ្នែងផ្ទាត់លទ្ធផលនៃការបោះឆ្នោត និងធ្វើអន្តរាគមន៍ភ្លាមៗក្នុងករណីមានបញ្ហា និងហានិភ័យនៃភាពអសន្តិសុខ និងការយាយី ... បន្ទប់ស្ថានការណ៍ត្រូវបានបើកចំហសម្រាប់ការចូលរួមយ៉ាងទូលំទូលាយពីសំណាក់អង្គការ សមាគម និងសហជីព ដទៃទៀត ដើម្បីរួមចំណែកដល់ការងារសង្កេតដំណើរការបោះឆ្នោតឃុំ សង្កាត់។»

ដោយមានការគាំទ្រពីសហភាពអឺរ៉ុប តាមរយៈការិយាល័យសេវាកម្មគម្រោងអង្គការសហប្រជាជាតិ (UNOPS) ខុមហ្វ្រែលបានប្រកាសផែនការរួមជាមួយដៃគូសង្គមស៊ីវិល ដើម្បីបណ្តុះបណ្តាល និងដាក់ពង្រាយអ្នកសង្កេតការណ៍១២,០០០នាក់ ហើយខ្វង់ចវិកាសម្រាប់បណ្តុះបណ្តាល និងដាក់អ្នកសង្កេតការណ៍ក្នុងមួយនាក់នោះ ត្រូវបានបង្ហាញឲ្យសាធារណជនបានដឹងផងដែរ។ គ.ជ.ប បានប្រកាសថា ខ្លួននឹងទទួលយកពាក្យស្នើសុំជាអ្នកសង្កេតការណ៍ជាតិ រហូតដល់ថ្ងៃទី២៤ ខែឧសភា និងពាក្យស្នើសុំជាអ្នកសង្កេតការណ៍អន្តរជាតិ រហូតដល់ថ្ងៃទី៣០ ខែឧសភា។ ការធ្វើការក្នុងលក្ខខណ្ឌនៃច្បាប់ និងបទបញ្ជា នីតិវិធី

[267] Lay, Samean "NEC lays out timeline ahead of local elections" Phnom Penh Post, 21 February 2017.

សម្រាប់ការបោះឆ្នោត និងការប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់ចំពោះការមិនប្រកាន់និន្នាការនយោបាយ និងស្របតាមការអនុវត្តល្អបំផុតសម្រាប់ការសង្កេតការបោះឆ្នោតដោយឯករាជ្យ ដើម្បីឲ្យការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ត្រូវបានអនុវត្តដោយបន្ទប់ស្ថានការណ៍។ ខុមហ្វ្រែល រួមជាមួយអង្គការសង្គមស៊ីវិលដៃគូបានបណ្តុះបណ្តាល ផ្គត់ផ្គង់សំភារៈ និងដាក់ពង្រាយបណ្តាញអ្នកសង្កេតការណ៍ជាតិដែលមានសមត្ថភាព (ទាំងក្នុងរយៈពេលវែង និងរយៈពេលខ្លី) ដើម្បីធានាបាននូវភាពយុត្តិធម៌ និងការបង្ការភាពមិនប្រក្រតីនៅថ្ងៃបោះឆ្នោតស្របពេលកំពុងបន្តទំនាក់ទំនងជាមួយ គ.ជ.ប ដើម្បីចែករំលែកព័ត៌អំពីសកម្មភាពរបស់ខ្លួន។

ថ្ងៃទី៧ ខែមីនា គ.ជ.ប បានប្រកាសអំពីលទ្ធផលនៃការចុះបញ្ជីបេក្ខជនថា បានចំនួន៨៨,២១៦ នាក់ មកពីគណបក្សនយោបាយចំនួន១២ ដែលច្រើនជាងការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ កាលពីឆ្នាំ ២០១២ ចំនួន២គណបក្ស។[268] ប៉ុន្តែមានតែគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិប៉ុណ្ណោះ ដែលបានដាក់បេក្ខជនចូលរួមប្រកួតប្រជែងនៅក្នុងឃុំ សង្កាត់ទាំងអស់។ គណបក្សទាំងអស់នឹងចូលរួមប្រកួតប្រជែងដណ្តើមអាសនៈចំនួន១១,៥៧២ នៃឃុំសង្កាតចំនួន១,៦៤៦។ ប្រហែលមួយសប្តាហ៍ក្រោយ គ.ជ.ប បានប្រកាសថាអង្គការជាតិពីរត្រូវបានអនុញ្ញាតឱ្យចូលរួមជាអ្នកសង្កេតការណ៍ ហើយអ្នកសង្កេតការណ៍សរុបចំនួន៥២១ នាក់ត្រូវបានទទួលស្គាល់ដោយ គ.ជ.ប ដែល២៩៣ មកពីអង្គការខុមហ្វ្រែល និង ២២៨មកពីសហភាពសហព័ន្ធយុវជនកម្ពុជា។[269] ដូច្នេះក្នុងរយៈពេលប៉ុន្មានខែមុនការបោះឆ្នោត ខុមហ្វ្រែល និងដៃគូអង្គការសង្គមស៊ីវិល បានធ្វើសកម្មភាពដោយមានតម្លាភាពទាំងស្រុង និងកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយ គ.ជ.ប និងបានអនុវត្តតាមសេចក្តីណែនាំដែលពាក់ព័ន្ធសម្រាប់ការដាក់ពង្រាយសង្កេតការណ៍ឯករាជ្យ។ បញ្ហាដែលរកឃើញដោយអ្នកសង្កេតការណ៍ឯករាជ្យ និងជាការព្រួយបារម្ភចំពោះភាគីពាក់ព័ន្ធជាតិ និងអន្តរជាតិ គឺថាតាមរយៈក្រសួងមហាផ្ទៃ ក្នុងចំណោមគណបក្សនយោបាយ៤៥ បានចុះឈ្មោះនៅកម្ពុជា មានគណបក្សចំនួន១២ ត្រូវបានរងទទួលពាក្យនៅតុលាការ។

នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៧ ខុមហ្វ្រែល និងដៃគូអង្គការសង្គមស៊ីវិល បានចេញរបាយការណ៍លំអិតស្តីពីលទ្ធផលនៃសវនកម្មបញ្ជីឈ្មោះអ្នកបោះឆ្នោត ដែលបានផ្តល់នូវវិធានការមួយចំនួនទាក់ទងនឹងការយល់ដឹងរបស់អ្នកបោះឆ្នោត និងការចូលរួមរបស់ប្រជាពលរដ្ឋ។[270] ការស្វង់មតិសម្រាប់គោលបំណងសវនកម្មបញ្ជីឈ្មោះអ្នកបោះឆ្នោត តម្រូវឱ្យមានការសម្ភាសន៍អ្នកបោះឆ្នោត ចំនួន២,៦៩០ នាក់មកពីគ្រប់ខេ

[268] Ouch, Sony and Sokhean Ben "Over 88,000 candidates register for upcoming election" Cambodia Daily, 7 March 2017.

[269] Pech, Sotheary "NEC says 12 parties contesting in elections" Khmer Times, 16 March 2017.

[270] Ben, Sokhean and Hannah Hawkins "Election day coming, many voters unsure" Cambodia Daily, 6 April 2017.

ត្ត។ សំណាកសម្រាប់ការធ្វើសវនកម្មបញ្ជីអ្នកបោះឆ្នោតមានភូមិចំនួន៥១៤ នៃឃុំចំនួន២៥២ ។ ខុមហ្វ្រែល បានផ្សព្វផ្សាយការរកឃើញដល់រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធសំខាន់ៗដែលបង្ហាញថា ៨៩%នៃប្រជាជនដែលមានសិទ្ធិបោះឆ្នោតនៅក្នុងប្រទេសបានចុះឈ្មោះហើយ ៩២%នៃអ្នកឆ្លើយសំណួរបានដឹង ពីឯកសារដែលត្រូវការដើម្បីបោះឆ្នោតនៅថ្ងៃបោះឆ្នោត។ ទោះជាយ៉ាងណាក៏ដោយ របាយការណ៍បានបង្ហាញថាមានការខ្វះខាតចំណេះដឹងរបស់អ្នកចុះឈ្មោះបោះឆ្នោតទាក់ទងទៅនឹងការយល់ដឹងអំពីកាលបរិច្ឆេទនៃការបោះឆ្នោត។[271] ខុមហ្វ្រែល និងអង្គការសង្គមស៊ីវិលដែលជាដៃគូបានតស៊ូមតិជាមួយ គ.ជ.ប ដើម្បីសហការគ្នាក្នុងការលើកកម្ពស់ប្រសិទ្ធភាព និងលទ្ធផលនៃបណ្តាញអង្គការសង្គមស៊ីវិលទាក់ទងនឹងការអប់រំពលរដ្ឋ។ ខុមហ្វ្រែល និងដៃគូអង្គការសង្គមស៊ីវិលបានបង្ហាញពីទំនុកចិត្តលើគុណភាពនៃបញ្ជីឈ្មោះបោះឆ្នោតថ្មី ហើយបានចង្អុលបង្ហាញនូវភាពប្រសើរឡើង គួរអោយកត់សំគាល់ពីបញ្ហីដែលបានប្រើនៅក្នុងការបោះឆ្នោតឆ្នាំ២០១៣ (ដែលនាំឱ្យមានបញ្ហាសំខាន់ៗ ទាក់ទងនឹងភាពជឿជាក់នៃការបោះឆ្នោត)។ តាមរយៈការផ្សព្វផ្សាយការរកឃើញដោយឯករាជ្យអំពីភាពត្រឹមត្រូវ និងទុកចិត្តបាននៃបញ្ជីឈ្មោះអ្នកបោះឆ្នោត ទំនុកចិត្តសាធារណជនលើការបោះឆ្នោត ត្រូវបានពង្រឹងមុនពេលបោះឆ្នោតដែលជាការផ្តល់ឱ្យអ្នកបោះឆ្នោតនូវការលើកទឹកចិត្តដើម្បីអនុវត្តសិទ្ធិចូលរួមបោះឆ្នោត និងគាំទ្រ គ.ជ.ប ក្នុងការបំពេញការងាររបស់ខ្លួន។[272]

ដោយមិនអាចអនុវត្តបានស្របតាមស្តង់ដារសម្រាប់ការបោះឆ្នោតនៃលទ្ធិប្រជាធិបតេយ្យ និងដោយមានការរឹតបន្តឹងយ៉ាងតឹងរ៉ឹងលើការពិភាក្សាជាសាធារណៈ នៅដើមខែមេសា គ.ជ.ប បានអនុម័ត និងផ្សព្វផ្សាយការហាមឃាត់ការស្ទង់មតិ ឬការស្ទាបស្ទង់ពីលទ្ធផលបោះឆ្នោតក្នុងអំឡុងពេលបោះឆ្នោត។ ការផ្សព្វផ្សាយ ការហាមឃាត់នេះ ធ្វើឡើងក្រោយពីមានការពិភ្សាដោយបុគ្គលិក ខុមហ្វ្រែល តាមវិទ្យុអំពីការបោះឆ្នោត និងលទ្ធផលនៃការបោះឆ្នោតដែលព្យាករណ៍ អំពីដំណើរការដ៏រឹងមាំរបស់គណបក្សប្រឆាំងក្នុងការបោះឆ្នោត។ ដោយផ្អែកលើហេតុផលដែលថា គ.ជ.ប គឺជាស្ថាប័នតែមួយគត់ដែលត្រូវបានអនុញ្ញាតឱ្យប្រកាសលទ្ធផលនៃការបោះឆ្នោត ហើយអ្នកបោះឆ្នោតមិនអាចបែងចែកលទ្ធផលបោះឆ្នោតប្រកាសដោយ គ.ជ.ប ជាមួយលទ្ធផលនៃការបោះឆ្នោតចេញពីប្រភពផ្សេងបាន។ គ.ជ.ប បានអះអាងថា ការស្ទង់មតិលទ្ធផលបោះឆ្នោតនឹងនាំឱ្យមានអស្ថេរភាពសង្គម។ ខុមហ្វ្រែល និងអង្គការសង្គមស៊ីវិលជាដៃគូបានបញ្ចេញមតិយោបល់ដល់ប្រព័ន្ធផ្សព្វផ្សាយដែលកត់សំគាល់ពីអត្ថប្រយោជន៍នៃការស្ទង់មតិ ដូចជាការជួយឱ្យគណបក្សនានាកែលម្អយុទ្ធនាការបោះឆ្នោត និងសារនយោបាយរបស់ពួកគេ ដើម្បីឆ្លុះបញ្ចាំងពីផលប្រយោជន៍របស់អ្នកបោះឆ្នោត។[273] ការរកឃើញរបស់ខុមហ្វ្រែលលើផលប៉ះពាល់នៃការស្ទង់មតិលទ្ធផលបោះឆ្នោត មិនស្របគ្នាជាមួយការយល់ឃើញរបស់ គ.ជ.ប ទេ ប៉ុន្តែខុមហ្វ្រែល និងដៃគូអង្គការសង្គមស៊ីវិល បានបង្ហាញ

[271] Ven, Rathavong “Voter list given the green light” Khmer Times, 6 April 2017.

[272] Touch, Soka “Voter rolls accurate: Comfrel” Phnom Penh Post, 6 April 2017.

[273] Touch, Sokha and Ananth Baliga “NEC defends printing of extra ballots for vote” Phnom Penh Post, 5 May 2017.

ដល់ គ.ជ.ប និងប្រព័ន្ធផ្សព្វផ្សាយថា ខ្លួននឹងអនុវត្តតាមគោលការណ៍ ដើម្បីគាំទ្រការងាររបស់ គ.ជ.ប។[274] គ្មានមូលដ្ឋានច្បាប់ច្បាស់លាស់សម្រាប់ការហាមឃាត់ ត្រូវបានរកឃើញក្នុងច្បាប់បោះឆ្នោតទេ។ ច្បាប់ LEMNA បានចែងតែរយៈពេល៧ថ្ងៃមុនការបោះឆ្នោត ហាមមិនឲ្យមានការស្ទង់មតិ ឬផ្សព្វផ្សាយលទ្ធផលនៃការស្ទង់មតិ។ យ៉ាងណាក៏ដោយ ការហាមឃាត់ការស្ទង់មតិក្នុងរយៈពេល ៧ថ្ងៃ មុនថ្ងៃបោះឆ្នោតនៃច្បាប់ LEMNA ក៏ដូចជារយៈពេល៥ថ្ងៃ មុនថ្ងៃបោះឆ្នោតក្នុងឆ្នាំ២០១៣ ការបង្កើនចំនួនថ្ងៃសម្រាប់ហាមឃាត់លើការស្ទង់មតិមិនត្រូវបានរកឃើញថាមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើភាពយុត្តិធម៌នៃការបោះឆ្នោត ឬ បរិយាកាសនយោបាយមុនពេលបោះឆ្នោតនោះទេ។

នៅថ្ងៃទី៣០ ខែមេសា អ្នកនាំពាក្យ គ.ជ.ប បានប្រកាសថា សន្លឹកឆ្នោតសម្រាប់ការបោះឆ្នោត ២០១៧ មានចំនួន៩,៤លានសន្លឹក នឹងត្រូវបោះពុម្ពសម្រាប់អ្នកបោះឆ្នោត ចំនួន៧,៨លាននាក់ ហើយការបោះពុម្ពនោះប្រើប្រាក់ថវិកាសរុប២លានដុល្លារ ដែលរួមទាំងសន្លឹកឆ្នោតបម្រុងយ៉ាងហោចចំនួន៥០សន្លឹកសម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ។[275] ផ្អែកលើការវិភាគ ខុមហ្វ្រែល និងអង្គការសង្គមស៊ីវិលជាដៃគូ បានស្នើអនុសាសន៍ ដល់ គ.ជ.ប ដើម្បីកាត់បន្ថយចំនួនសន្លឹកឆ្នោតបម្រុងតាមការិយាល័យបោះឆ្នោត ដើម្បីទប់ស្កាត់ភាពមិនប្រក្រតី។ ដោយសារតែរបៀបគណនាចំនួនសន្លឹកឆ្នោត សម្រាប់ការិយាល័យបោះឆ្នោតនោះការិយាល័យបោះឆ្នោតមួយអាចមានសន្លឹកឆ្នោតបន្ថែមចំនួន៩៩សន្លឹក ដែលធ្វើឲ្យមានសន្លឹកឆ្នោតបម្រុងរហូត ២០ភាគរយនៃចំនួនអ្នកបោះឆ្នោតដែលបានចុះឈ្មោះក្នុងបញ្ជី។ វាគួរឲ្យកត់សម្គាល់ផងដែរថាការចំណាយថវិកាសរុបចំនួន៣៣0.000ដុល្លារ សម្រាប់សន្លឹកឆ្នោតបំរុងគឺជាចំនួនដ៏ច្រើន។[276]

នៅពាក់កណ្តាលខែមេសា បញ្ជីបោះឆ្នោតតាមប្រព័ន្ធអ៊ីនធឺណែត ត្រូវបានគេលួចយកទៅគ្រប់គ្រងជាលើកទី២ នៅឆ្នាំ២០១៧។ ទំនុកចិត្តរបស់សាធារណជនចំពោះដំណើរការបោះឆ្នោតត្រូវបានប្រឈម និងភាពតានតឹងកើនឡើងរវាងបក្សកាន់អំណាច និងគណបក្សប្រឆាំង (នៅក្នុងបរិយាកាសនៃការមិនជឿទុកចិត្តដែលបានលេចឡើងដោយការលេចធ្លាយ) នៅពេលក្រុមលួចគ្រប់គ្រងទិន្នន័យបញ្ជីឈ្មោះបោះឆ្នោត បានប្រកាសថា បញ្ជីបោះឆ្នោត គឺងាយស្រួលទទួលរងនូវការគ្រប់គ្រង់របស់ក្រុមនោះ។ ដោយពន្យល់ពីការខ្វះខាតខាងសន្តិសុខដូចជា "SLQ injection" អ្នកលួចគ្រប់គ្រងទិន្នន័យបានអះអាងថា សូម្បីតែអ្នកដែលមានជំនាញមូលដ្ឋានក៏អាចធ្វើឱ្យខូចទិន្នន័យបញ្ជីឈ្មោះបោះឆ្នោតបានដែរ។ អ្នកលួចគ្រប់គ្រងទិន្នន័យបានពន្យល់ពីរបៀបលួចគ្រប់គ្រងទិន្នន័យនៅលើវីដេអូ YouTube ក៏ដូចជាផ្តល់ជាយោបល់អំពីរបៀបជួសជុលតែតម្រូវវា។[277] គ.ជ.ប បានពង្រឹងទំនុកចិត្តរបស់សាធារណជនដោយឆ្លើយតបភ្លាមៗ និងកត់សម្គាល់វិធាន

[274] Ben, Sokhean and Ben Paviour “Opinion polls banned ahead of election” Cambodia Daily, 2 April 2017.

[275] Touch, Sokha “EU sends experts to assess the environment” Phnom Penh Post, 1 May 2017.

[276] Touch, Sokha and Ananth Baliga “NEC defends printing of extra ballots for vote” Phnom Penh Post, 5 May 2017.

[277] Van, Roeun and Zsombor Peter “Hacker warns of serious vulnerability plaguing online voter lists” Cambodia Daily 14 April 2017.

ការទប់ស្កាត់ ដែលបានធ្វើឡើង ដើម្បីចៀសវាងការធ្វើឲ្យខូចខាចបញ្ជីបោះឆ្នោតនៅថ្ងៃបោះឆ្នោត និងការផ្លាស់ប្តូរពាក្យសម្ងាត់នៅថ្ងៃបោះឆ្នោត។ ខុមហ្វ្រែលបានធ្វើការតស៊ូមតិឱ្យមានតម្លាភាព ទាក់ទងនឹងបញ្ជីឈ្មោះអ្នកបោះឆ្នោត និងគណនេយ្យភាពក្នុងដំណើរការថែរក្សាបញ្ជីឈ្មោះអ្នកបោះឆ្នោត។ ខុមហ្វ្រែលបានផ្តល់អនុសាសន៍ឱ្យ គ.ជ.ប ទទួលយកជំនួយបច្ចេកទេសពីអ្នកជំនាញខាងក្រៅបន្ថែម ដើម្បីពង្រឹងប្រព័ន្ធសន្តិសុខទិន្នន័យ។

កាលពីថ្ងៃទី៩ ខែឧសភា គ.ជ.ប បានចេញបម្រាមហាមឃាត់ការដើរហែក្បួននៅតាមផ្លូវធំៗ សួនឧទ្យាន ផ្សារ និងកន្លែងសាធារណៈផ្សេងទៀត។ ការហាមនេះត្រូវបានរកឃើញថា បានកំណត់លទ្ធភាពរបស់គណបក្សនយោបាយក្នុងការផ្សព្វផ្សាយ និងចូលរួមជាមួយអ្នកបោះឆ្នោត និងការផ្តល់ឱ្យអ្នកបោះឆ្នោតបានដឹងនូវគោលនយោបាយគណបក្ស។ ការហាមឃាត់នេះ បានកាត់បន្ថយតំបន់សម្រាប់គណបក្សនយោបាយធ្វើយុទ្ធនាការឃោសនា ខណៈដែលច្បាប់បោះឆ្នោតថ្មី បានកាត់បន្ថយរយៈពេលយុទ្ធនាការឃោសនា។ លើសពីនេះទៀត អង្គការខុមហ្វ្រែល និងអង្គការសង្គមស៊ីវិលជាដៃគូ បានធ្វើការតស៊ូមតិដើម្បីផ្លាស់ប្តូរច្បាប់ និងគោលនយោបាយដែលអនុញ្ញាតអោយមានការដើរហែក្បួនត្រឹមតែពីរលើក ក្នុងអំឡុងពេលយុទ្ធនាការ។[278]

ការផ្លាស់ប្តូរគោលការណ៍ដ៏សំខាន់ដើម្បីគាំទ្រដល់ការអនុវត្តន៍សិទ្ធិបោះឆ្នោតពេញលេញ បានកើតមានឡើងមុនពេលការបោះឆ្នោត គឺថ្ងៃចុងបញ្ចប់នៃយុទ្ធនាការឃោសនាបោះឆ្នោត។ ជាការសោកស្តាយ ការសម្រេចចិត្តលើគោលការណ៍ថ្មីនេះ ត្រូវបានធ្វើឡើងយឺតយ៉ាវ រហូតជាឧបសគ្គដល់ការផ្សព្វផ្សាយព័ត៌មានអំពីការផ្លាស់ប្តូរនេះដល់អ្នកបោះឆ្នោត។ តម្រូវការឯកសារសម្រាប់បោះឆ្នោតត្រូវបានផ្លាស់ប្តូរ និងធ្វើឱ្យមានភាពងាយស្រួលដល់អ្នកមានសិទ្ធិបោះឆ្នោត ដែលគ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។ កាលពីពេលមុន អ្នកបោះឆ្នោត ត្រូវយកលិខិតបញ្ជាក់ការស្នាក់នៅពីមេឃុំដោយនាំសាក្សីពីរនាក់ ដែលជាអ្នករស់នៅក្នុងឃុំផងដែរ ដើម្បីស្នើសុំលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់ការបោះឆ្នោត ប៉ុន្តែដោយមានការផ្លាស់ប្តូរគោលការណ៍ អ្នកបោះឆ្នោតដែលមានសិទ្ធិបោះឆ្នោត គ្រាន់តែត្រូវការ គឃ.សប បញ្ជាក់លើលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់ការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៦។ ខុមហ្វ្រែលបានផ្តល់អនុសាសន៍ដល់ គ.ជ.ប ដើម្បីចាប់ផ្តើមគោលការណ៍នេះនៅដើមសប្តាហ៍នៃការបោះឆ្នោត ប៉ុន្តែ គ.ជ.ប បានពន្យារពេលក្នុងការបង្កើតគោលការណ៍នេះ។ ខណៈដែលមានឧបសគ្គទាក់ទងនឹងពេលវេលា ខុមហ្វ្រែលបានគាំទ្រការផ្លាស់ប្តូរគោលការណ៍ និងបានប្រើប្រាស់បណ្តាញអ្នកសង្កេតការណ៍ និងប្រព័ន្ធផ្សព្វផ្សាយ ដើម្បីផ្សព្វផ្សាយព័ត៌មានដល់អ្នកបោះឆ្នោត។ ខុមហ្វ្រែល ក៏គាំទ្រសេចក្តីប្រកាសរបស់ គ.ជ.ប ដើម្បីជម្រាបដល់អ្នកបោះឆ្នោតថា ពួកគេ

[278] Tin, Zakariya and Sokheng Saut "Cambodia election watchdog slams capital ban on campaign marches" RFA, 11 May 2017.

មិនត្រូវការប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ដើម្បីចូលក្នុងការិយាល័យបោះឆ្នោត ដែលបញ្ហានេះជាការយល់ច្រឡំដែលធ្វើឱ្យអ្នកបោះឆ្នោតមិនច្បាស់លាស់អំពីឯកសារសម្រាប់បោះឆ្នោតជាពេលកន្លងមក។[279]

COMFREL monitoring found the campaign and election day to be a mostly smooth and peaceful process. Both major political parties were found to act in accordance with the relevant laws and organized marches and assemblies in a peaceful manner, effectively avoiding conflicts and ensuring a positive experience for the citizenry. Building on the success achieved in 2016 and the national voter registration, the NEC was found to perform in a capable and fair manner. Some serious concerns arose for CSOs and national and international stakeholders because of the increasingly undemocratic and menacing political climate that preceded the election. Despite that, the NEC carried out its mandate effectively, and good collaboration with CSOs and media was maintained. It was observed that, on the basis of improved working methods, regulations and training, and utilizing the accurate voter list and the MVR system, polling day was a success and the electoral results were accurate. COMFREL and partner CSOs supported the legitimacy of the outcome, necessary for reconciliation between parties to be achieved and maintained, in the broader national interests of peace and democratization.

ការសង្កេតរបស់ខុមហ្វ្រែលបានរកឃើញថា ការឃោសនាបោះឆ្នោត និងការបោះឆ្នោតត្រូវធ្វើឡើងដោយរលូន និងសន្តិវិធី។ គណបក្សនយោបាយធំៗទាំងពីរត្រូវបានគេរកឃើញថា ធ្វើសកម្មភាពស្របតាមច្បាប់ពាក់ព័ន្ធ និងរៀបចំក្បួនដង្ហែ និងសន្និបាតដោយសន្តិវិធី និងជៀសវាងជម្លោះ និងធានានូវបទពិសោធន៍វិជ្ជមានសម្រាប់ប្រជាពលរដ្ឋ។ ដោយឈរលើជោគជ័យដែលសម្រេចបាននៅឆ្នាំ២០១៦ និងការចុះឈ្មោះអ្នកបោះឆ្នោតថ្មី គ.ជ.ប ត្រូវបានគេរកឃើញថា មានសមត្ថភាព និងយុត្តិធម៌ក្នុងការងាររបស់ខ្លួន។ ការព្រួយបារម្ភយ៉ាងធ្ងន់ធ្ងរមួយចំនួនបានកើតឡើងចំពោះអង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធជាតិ និងអន្តរជាតិដោយសារតែបរិយាកាសនយោបាយ ដែលមិនអំណោយផល និងការគំរាមកំហែងដែលកើតមានមុនការបោះឆ្នោត។ ទោះបីជាយ៉ាងនេះក្តី គ.ជ.ប បានអនុវត្តអាណត្តិរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ហើយកិច្ចសហប្រតិបត្តិការល្អជាមួយអង្គការសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយត្រូវបានរក្សាបន្តទៀត។[280] វាត្រូវបានគេសង្កេតឃើញថា មានការបោះឆ្នោត និងលទ្ធផលបោះឆ្នោតមានភាពត្រឹមត្រូវ គឺជាជោគជ័យមូលដ្ឋានចំបងដែលកើតចេញពីវិធីសាស្ត្រការងារ ការអនុវត្តន៍បទបញ្ជា និងនីតិវិធី និងការបណ្តុះបណ្តាល និងការប្រើប្រាស់បញ្ជីអ្នកបោះឆ្នោតត្រឹមត្រូវ និងប្រព័ន្ធចុះឈ្មោះតាមបែបកុំព្យូទ័រ។

[279] Hawkins, Hanna and Sony Ouch "NEC announces shortcut for voter's without ID's" Phnom Penh Post, 2 June 2017

[280] Ben, Sokhean and Zsombor Peter "Independent observers say 'smooth' vote still marred by problems" Cambodia Daily, 5 June 2017.

១៦.១ ការបណ្តុះបណ្តាល ការដាក់ពង្រាយ និងសកម្មភាពសង្កេតការណ៍របស់ខុមហ្វ្រែល

ការសង្កេតថ្ងៃបោះ និងរាប់សន្លឹកឆ្នោត៖

ខុមហ្វ្រែល ដោយមានកិច្ចសហការជាមួយសមាជិកបន្ទប់ស្ថានការណ៍ដែលបង្កើតឡើងពីការចូលរួមនៃអង្គការសង្គមស៊ីវិលចំនួន៤០ រួមទាំងបណ្តាញ និងលេខាធិការខេត្តរបស់ខុមហ្វ្រែល បានជ្រើសរើសអ្នកសង្កេតការណ៍ចំនួន១៤,៥៨០នាក់ (ស្ត្រីចំនួន៦,១១៥នាក់) រួមទាំងអ្នកសង្កេតការណ៍ចល័តចំនួន១,៥៨៧នាក់ (ស្ត្រីចំនួន៧៥០នាក់) ដែលត្រូវបានទទួលស្គាល់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ បន្ទាប់ពីបានបើកវគ្គបណ្តុះបណ្តាលចំនួន១,៣៤៦វគ្គនៅឃុំសង្កាត់ ដើម្បីបណ្តុះបណ្តាលអ្នកសង្កេតការណ៍អំពីរបៀបសង្កេតការណ៍បោះឆ្នោត និងរាប់សន្លឹកឆ្នោត ព្រមទាំងប្រមូលកំណត់ហេតុលទ្ធផលនៃការបោះឆ្នោត (ទម្រង់ ទ.១១០២) និងបញ្ជូនព័ត៌មានទៅការិយាល័យកណ្តាល។ ខុមហ្វ្រែលបានដាក់ពង្រាយអ្នកសង្កេតការណ៍នៅគ្រប់ឃុំ សង្កាត់ចំនួន១,៦៤៦ ដែលត្រូវបានត្រួតពិនិត្យ និងណែនាំដោយដោយលេខារាជធានី ខេត្ត និងបុគ្គលិកការិយាល័យកណ្តាល។ ការិយាល័យកណ្តាលរបស់ខុមហ្វ្រែល គឺជាកន្លែងដែលសមាជិកនៃបន្ទប់ស្ថានការណ៍បានធ្វើការជាមួយគ្នា ដើម្បីប្រមូលព័ត៌មានទាក់ទងនឹងភាពមិនប្រក្រតី និងលទ្ធផលនៃការបោះឆ្នោត ដើម្បីធ្វើការវិភាគ និងផ្សព្វផ្សាយព័ត៌មានជាសាធារណៈ។ ការងារទាំងនេះក៏ត្រូវបានជួយដោយអ្នកស្ម័គ្រចិត្តចំនួន១៥០នាក់ ដែលបានទាក់ទងដោយផ្ទាល់ទៅកាន់លេខារាជធានី ខេត្តនីមួយៗ ដើម្បីប្រមូលទិន្នន័យលទ្ធផលបោះឆ្នោត តាមរយៈកម្មវិធីលើទូរស័ព្ទដៃ។ ក្រុមអន្តរាគមន៍នៃបន្ទប់ស្ថានការណ៍ គឺទទួលខុសត្រូវដោះស្រាយបញ្ហារំលោភបំពានលើអ្នកសង្កេតការណ៍នៅថ្ងៃបោះឆ្នោតផងដែរ។

ការសង្កេតលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

During the 14-day electoral campaign period from 20 May to 02 June 2017, COMFREL conducted television media monitoring including TVK, Bayon News, CTN and Hang Meas. For the purpose of media monitoring during the 2017 commune elections in Cambodia, broadcast content from these stations was recorded from 17:00 to 24:00 during the period of the election campaign. The broadcast content was measured and evaluated in order to calculate time allocated to: regular TV programs, political party programs, voter awareness and election process programs, and programs documenting government achievements. In addition to the content of TV broadcasting, the articles of 12 new presses, disseminating via social media (Facebook), were also collected and analyzed.

អំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោតរយៈពេល១៤ថ្ងៃ ពីថ្ងៃទី២០ ខែឧសភា ដល់ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៧ ខុមហ្វ្រែលបានធ្វើការសង្កេតប្រព័ន្ធផ្សព្វផ្សាយ រួមមាន៖ ទូរទស្សន៍ជាតិកម្ពុជា បាយ័នព័ត៌មាន ស៊ីធីអិន និងហង្សមាស។ គោលបំណងនៃការសង្កេតប្រព័ន្ធផ្សព្វផ្សាយ ក្នុងអំឡុងពេលឃោសនាការបោះឆ្នោត ខ្លឹមសារនៃការផ្សាយព័ត៌មានពីស្ថានីយទាំងនេះ ត្រូវបានថតទុកចាប់ពីម៉ោង១៧:00 ដល់២៤:00 ក្នុងអំឡុងពេល១៤ថ្ងៃនៃយុទ្ធនាការឃោសនាបោះឆ្នោត។ ខ្លឹមសារផ្សព្វផ្សាយ ត្រូវបានសង្កេតអំពីរយៈពេលដែលផ្សាយលើស្ថានីយ៍ទូរទស្សន៍ទាំងនោះនូវកម្មវិធីដូចជា៖ កម្មវិធីផ្សាយរបស់ទូរទស្សន៍អំពីគណបក្សនយោបាយ កម្មវិធីរបស់គណបក្សនយោបាយដែលផ្សាយតាមទូរទស្សន៍ កម្មវិធី

ផ្សព្វផ្សាយព័ត៌មាន នីងចំណេះដឹងអំពីការបោះឆ្នោត និងកម្មវិធីផ្សាយពីសមិទ្ធផលរបស់រដ្ឋាភិបាល។ ក្រៅពីខ្លឹមសារ ការផ្សាយតាមទូរទស្សន៍ អត្ថបទនៃសារព័ត៌មានចំនួន១២ ដែលផ្សព្វផ្សាយតាមរយៈបណ្តាញសង្គម (ហ្វេសប៊ុក) ក៏ត្រូវបានប្រមូល និងវិភាគផងដែរ។

ជាលទ្ធផលនៃការសង្កេត ខុមហ្វ្រែលសន្និដ្ឋានថា នៅក្នុងការបោះឆ្នោតឆ្នាំ២០១៧ ការទទួលបានឱកាសផ្សព្វផ្សាយតាមរយៈ ប្រព័ន្ធផ្សព្វផ្សាយរបស់គណបក្សនយោបាយមិនមានសមភាព។ គណបក្សប្រជាជនកម្ពុជា ដែលកំពុងកាន់អំណាចទទួលបានឱកាសច្រើនជាងគេ ជាពិសេសក្នុងករណីផ្សព្វផ្សាយតាមរយៈស្ថានីយទូរទស្សន៍ឯកជន។

ការសង្កេតហិរញ្ញវត្ថុសម្រាប់ការឃោសនាបោះឆ្នោត

សកម្មភាពឃោសនាបោះឆ្នោតនៅក្នុងឃុំ សង្កាត់ចំនួន០៩ ត្រូវបានសង្កេត និងសិក្សាអំពីការចំណាយរបស់គណបក្សនយោបាយក្នុងអំឡុងពេលឃោសនាបោះឆ្នោត។ ឃុំ សង្កាត់ចំនួន០៩នោះ គឺត្រូវបានជ្រើសរើសចេញពីខេត្តចំនួន៣ ដែលត្រូវបានចាត់ទុកជាខេត្តធំ មធ្យម និងតូច អាស្រ័យលើអាសនៈតំណាងរាស្ត្រ ប្រជាសាស្ត្រ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋត្រូវបានសង្កេត និងសិក្សា។ គណបក្សនយោបាយចំនួន០៤ ត្រូវបានសង្កេតពីការចំណាយសម្រាប់សកម្មភាពឃោសនាបោះឆ្នោត រួមមានគណបក្សប្រជាជនកម្ពុជា (ប្រជ) គណបក្សសង្គ្រោះជាតិ(ស.គ.ជ) គណបក្សហ៊្វុនស៊ិនប៉ិច គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ។ ខ្នង់ចំណាយរបស់គណបក្សនយោបាយមួយ សម្រាប់ឃុំមួយ គឺជាខ្នង់ចំណាយជាមធ្យមសម្រាប់សកម្មភាពឃោសនានៃគណបក្សនីមួយៗ ចំនួន០៩ឃុំ សង្កាត់ដែលបានសង្កេត និងប៉ាន់ស្មាន។ ខ្នង់ចំណាយលើសកម្មភាពឃោសនាទាំង១៤ថ្ងៃ សម្រាប់ការបោះឆ្នោតនៃគណបក្សនយោបាយនីមួយៗ គឺជាខ្នង់ចំណាយសរុបលើសកម្មភាពឃោសនានៃគណបក្សនីមួយៗ ដែលជាផលគុណនៃការចំណាយសម្រាប់មួយឃុំ សង្កាត់ នឹងចំនួនឃុំ សង្កាត់ដែលគណបក្សនយោបាយនោះបានឈរឈ្មោះប្រកួតប្រជែង។

គ្រប់គណបក្សនយោបាយទាំងអស់ ធ្វើសកម្មភាពឃោសនារបស់ខ្លួនយោងទៅតាមធនធានហិរញ្ញវត្ថុរបស់ខ្លួន។ គណបក្សប្រជាជនកម្ពុជាដែលកំពុងកាន់អំណាច ត្រូវបានគេប៉ាន់ប្រមាណថា បានចំណាយច្រើនជាងគណបក្សសង្គ្រោះជាតិ ចំនួនប្រាំដងលើសកម្មភាពឃោសនាបោះឆ្នោត សម្រាប់ការបោះឆ្នោតឃុំ សង្កាត់ឆ្នាំ២០១៧នេះ។ ខ្នង់ចំណាយរបស់គណបក្សប្រជាជនកម្ពុជាភាគច្រើន មានប្រភពមកពីគណបក្សនយោបាយនៅថ្នាក់ឃុំ សង្កាត់ និងរាជធានី ខេត្ត ប៉ុន្តែខ្នង់ចំណាយរបស់គណបក្សសង្គ្រោះជាតិភាគច្រើនមានប្រភពមកពីបេក្ខជនឈរឈ្មោះប្រកួតប្រជែង។

កង្វះយន្តការធ្វើឲ្យមានតម្លាភាព និងគណនេយ្យភាពសម្រាប់ការប្រើប្រាស់ហិរញ្ញវត្ថុឃោសនាបោះឆ្នោត ដែលរួមទាំងការបង្ហាញរបាយការណ៍ជាសាធារណៈ អំពីខ្នង់ចំណាយរបស់គណបក្សនយោបាយនីមួយៗ បានធ្វើឱ្យប៉ះពាល់ដល់គោលការណ៍សមធម៌នៃដំណើរការប្រជាធិបតេយ្យជាមូលដ្ឋាន ដែលធានាការផ្តល់ព័ត៌មានដើម្បីឲ្យម្ចាស់ឆ្នោតធ្វើការសម្រេចចិត្ត។ ដោយហេតុថា គណបក្សនយោបាយមិនបានបង្ហាញ

របាយការណ៍អំពីប្រភពចំណាយ និងការចំណាយវាបានធ្វើឲ្យមានការប្រើប្រាស់ធនធានរបស់រដ្ឋ ដើម្បីបម្រើដល់គណបក្សនយោបាយ ពិសេសគណបក្សកំពុងកាន់អំណាចក្នុងការឃោសនាបោះឆ្នោត។

ការស្ទង់មតិក្រោយថ្ងៃបោះឆ្នោត

អ្នកសង្កេតការណ៍បោះឆ្នោតរយៈពេលវែងទាំងអស់ (D-LTOs) បានធ្វើការសម្ភាសន៍ ជាមួយអ្នកដែលមានសិទ្ធិបោះឆ្នោត ដែលមិនមានទឹកខ្មៅលើម្រាមដៃបន្ទាប់ពីថ្ងៃបោះឆ្នោត ដើម្បីទទួលបានព័ត៌មានផ្ទាល់អំពីមូលហេតុមិនបានបោះឆ្នោត។

អ្នកបោះឆ្នោតស្ត្រី និងក្រុមភាគតិច

ក្នុងអំឡុងពេលការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១៧ ខុមហ្វ្រែលបានបណ្តុះបណ្តាល និងដាក់ពង្រាយអ្នកសង្កេតការណ៍ស្ត្រីរយៈពេលខ្លីចំនួន១០នាក់ ដើម្បីសង្កេតមើលក្នុងឃុំ សង្កាត់ចំនួន១០ នៃស្រុកចំនួន០៦។ លើពីនេះទៀតអ្នកសង្កេតការណ៍ស្ត្រីរយៈពេលវែងចំនួន១១២នាក់ ដែលបានដាក់ពង្រាយនៅ៥៧ឃុំ សង្កាត់ នៃ១២ស្រុក ក្នុងខេត្តចំនួន៥ គឺកំពង់ចាម កំពង់ឆ្នាំង តាកែវ ព្រះវិហារ និងកំពង់ធំ។ ការដាក់ពង្រាយអ្នកសង្កេតការណ៍នេះគឺដើម្បីសង្កេតយុទ្ធនាឃោសនាការបោះឆ្នោត ថ្ងៃស និងថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោតនាថ្ងៃបោះឆ្នោត។

១៦.២ សម្មភាពអប់រំអ្នកបោះឆ្នោតរបស់ខុមហ្វ្រែល

ក្នុងអំឡុងពេលនៃការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១៧ ខុមហ្វ្រែលបានរៀបចំកម្មវិធីវិទ្យុសម្លេងសង្គមស៊ីវិល «VOC» ចំនួន៥៤០ (៣៥៦កម្មវិធីផ្សាយបន្តផ្ទាល់ និង១៨៤ជាកម្មវិធីចាក់ផ្សាយឡើងវិញ) ដែលមានវាគ្មិនសរុបចំនួន ៥៦១នាក់ (ស្ត្រី ១៤,៤៣%) ដើម្បីផ្សព្វផ្សាយ និងផ្តល់ការយល់ដឹងជាសាធារណៈលើបញ្ហាជាច្រើនទាក់ទងនឹងការបោះឆ្នោត។ លើសពីនេះទៅទៀត អ្នកស្តាប់១,៩៣២នាក់ (២០,៩៦% ជាស្ត្រី) បានហៅទូរស័ព្ទចូលរួមក្នុងកម្មវិធីដើម្បីបង្ហាញពីគំនិតរបស់ពួកគេ និងដាក់សំណើ រួមទាំងលើកជាសំណួរទៅវាគ្មិន។ ការផ្សាយទាំងនេះ ក៏ត្រូវបានដាក់នៅលើគេហទំព័រខុមហ្វ្រែលផងដែរ។ ក្រៅពីកម្មវិធីវិទ្យុខុមហ្វ្រែលបានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីផ្សព្វផ្សាយព័ត៌មានដល់សាធារណជន រួមមានដូចជាគេហទំព័រ និងទំព័រហ្វេសប៊ុក។ មានអត្ថបទចំនួន២,១៩៥ ដែលត្រូវបានផ្សព្វផ្សាយផ្សាយទាក់ទងនឹងការបោះឆ្នោត ប្រជាធិបតេយ្យ គ.ជ.ប និងការចុះឈ្មោះអ្នកបោះឆ្នោត។

សំខាន់ជាងនេះទៅទៀត ខុមហ្វ្រែលក៏បានបង្កើតវីដេអូ គំនូរជីវចលអប់រំចំនួន៤៥ ដោយខ្លួនឯងដែលត្រូវបានដាក់ផ្សាយលើទំព័រហ្វេសប៊ុករបស់ខុមហ្វ្រែល រហូតដល់មានគេទស្សនាមានចំនួន ២,៨២៧,៤៦៥ដង ត្រូវបានគេចែករំលែកចំនួន៨១,២៦៥ដង និងត្រូវមានអ្នកចូលចិត្តចំនួន១៤៩,៦២០ នាក់។ មានវីឌីអូមួយបានទៅដល់ (Reached) ជាង១លានគណនីហ្វេសប៊ុក និងត្រូវបានគេចែករំលែកបន្តច្រើនជាង១០ម៉ឺនដង។ សាធារណជនត្រូវបានលើកទឹកចិត្តឱ្យថតរូបភាពកំណត់ហេតុនៃលទ្ធផលបោះឆ្នោត

(ទម្រង់ ទ.១១០២) និងផ្ញើទៅទំព័រហ្វេសប៊ុករបស់ខុមហ្វ្រែល។ ជាលទ្ធផល ខុមហ្វ្រែលទទួលបានលទ្ធផលបោះឆ្នោតចំនួន៣,០៤២ សន្លឹក/ការិយាល័យ (ទម្រង់ ទ.១១០២) ពីសាធារណជន។

បន្ទប់ស្ថានការណ៍សម្រាប់ការបោះឆ្នោត

បន្ទប់ស្ថានការណ៍សម្រាប់ការបោះឆ្នោត នេះបានប្រមូលផ្តុំសមាជិកនៃសម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត (ERA) អង្គការសង្គមស៊ីវិលឯករាជ្យដទៃទៀត (CSOs) និងអ្នកជំនាញរួមគ្នាដើម្បី ទី១ ស្វែងរក និងប្រមូលធនធានជាវិភាគទាន ឬការគាំទ្រដើម្បីបង្កើនសមត្ថភាព និងសហប្រតិបត្តិការរួមដល់ការបង្កើតផែនការសម្រាប់ការសង្កេតការបោះឆ្នោតជាតិនៅថ្ងៃបោះឆ្នោត និងទី២ ផ្តល់នូវវេទិកាសហប្រតិបត្តិការរួមគ្នាដែលមិនមែនបម្រើផលប្រយោជន៍នយោបាយ។

ក្នុងអំឡុងពេលនៃការបង្កើតឡើងនូវផែនការការងារសង្កេតការណ៍ និងការចងក្រងរបាយការណ៍នេះ ខុមហ្វ្រែលបានរៀបចំកិច្ចប្រជុំចំនួន២៣លើក ជាមួយសមាជិកបន្ទប់ស្ថានការណ៍នៅការិយាល័យខុមហ្វ្រែល។ ការប្រជុំទាំងនោះធ្វើឡើងដើម្បីជជែកពីការសហការគ្នា ដែលទាក់ទងនឹងការស្វែងរកមូលនិធិសប្បុរសធម៌ ការជ្រើសរើស ការបណ្តុះបណ្តាល និងការដាក់ពង្រាយអ្នកសង្កេតការណ៍ ការបង្កើតក្រុមអន្តរាគមន៍ ការដេញថ្លៃ និងការបោះពុម្ពសំភារៈសង្កេតការណ៍(អាវយឺតសម្រាប់អ្នកសង្កេតការណ៍) និងការរៀបចំសន្និសីទសារព័ត៌មាន ស្តីពីការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។ ខុមហ្វ្រែល និងបន្ទប់ស្ថានការណ៍បានដាក់អ្នកសង្កេតការណ៍ក្នុងស្រុកជាង១៤,៥៨០នាក់ ដែលគ្របដណ្តប់ជាង៨៦ភាគរយនៃការិយាល័យបោះឆ្នោតទូទាំងប្រទេស។

១៧. ព្រឹត្តិការណ៍សំខាន់ៗសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៤ ឆ្នាំ២០១៧

- **ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧** សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានចោទបណ្តុំអង្គការមិនមែនរដ្ឋាភិបាលនៃបន្ទប់ស្ថានការណ៍នៃការបោះឆ្នោតថា បានរំលោភច្បាប់ ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងជាមូលដ្ឋានបញ្ជានៃគោលការណ៍ "បដិវត្តន៍ពណ៌"។ ការថ្លែងនេះបានធ្វើក្នុងពិធីរំលឹកខួបអនុស្សាវរីយ៍លើកទី៦៦ របស់គណបក្សប្រជាជនកម្ពុជា។
- **អំឡុងខែកក្កដា ឆ្នាំ២០១៧** មានការខ្វែងគំនិតគ្នារវាងស្ថាប័នរដ្ឋ រួមទាំង គ.ជ.ប និងគណបក្សកាន់អំណាច ជាមួយនឹងអង្គការសង្គមស៊ីវិល សហជីព និងគណបក្សប្រឆាំង ទាក់ទងការផ្តល់ថ្ងៃឈប់សម្រាកពី១ថ្ងៃដល់៣ថ្ងៃ ជូនកម្មករ កម្មការិនី និងបុគ្គលិកសម្រាប់ទៅចូលរួមបោះឆ្នោត។ អង្គការសង្គមស៊ីវិល សហជីព និងគណបក្សប្រឆាំង ចង់ឃើញ គ.ជ.ប ដាក់សំណើទៅគ្រប់ស្ថាប័នពាក់ព័ន្ធជាពិសេសក្រសួងការងារ ដើម្បីផ្តល់ថ្ងៃឈប់សម្រាកជូនកម្មករ កម្មការិនី និងបុគ្គលិក សម្រាប់ទៅចូលរួមបោះឆ្នោត ខណៈដែលស្ថាប័នរដ្ឋ គ.ជ.ប និងគណបក្សកាន់អំណាចគ្រាន់តែចេញសេចក្តី

អំពាវនាវទៅដល់ម្ចាស់សហគ្រាស រោងចក្រ និងក្រុមហ៊ុននានា ដើម្បីសុំឲ្យជួយសម្រួលដល់កម្មករ កម្មការិនី និងបុគ្គលិករបស់ខ្លួន បានទៅបោះឆ្នោត។

- **ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧** ក្រសួងមហាផ្ទៃបានចេញលិខិតមួយមកឧុមជ្រៀល និងនិកហ្វិច ដោយលើកឡើងថា ការបង្កើតបន្ទប់ស្ថានការណ៍ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៧ គឺផ្ទុយទៅនឹងបទប្បញ្ញត្តិនៃច្បាប់ ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ ជាមួយគ្នានេះក្រសួងបានបញ្ឈប់សកម្មភាពបន្ទប់ស្ថានការណ៍បន្តទៅមុខទៀត។
- **អំឡុងខែមីនា ឆ្នាំ២០១៧** គណបក្សប្រជាជនកម្ពុជា បានទាមទារឲ្យថ្នាក់ដឹកនាំគណបក្សសង្គ្រោះជាតិ កែតម្រូវជាបន្ទាន់នូវខ្លឹមសារ «ដូរមេឃុំបម្រើបក្ស ដាក់មេឃុំបម្រើរាស្ត្រ»។ ជាការឆ្លើយតប គណបក្សសង្គ្រោះជាតិ បានហាមប្រាមអ្នកគាំទ្ររបស់ខ្លួនប្រើប្រាស់ពាក្យស្លោកណាដែលប៉ះពាល់ដល់អារម្មណ៍បុគ្គល ឬគណបក្សផ្សេង ដើម្បីចៀសវាងភាពល្អក់កករ មុនការបោះឆ្នោត។
- **អំឡុងខែមីនា និងខែមេសា ឆ្នាំ២០១៧** ក្រសួងមហាផ្ទៃ និងគណបក្សសង្គ្រោះជាតិ មានការខ្វែងគំនិតគ្នាទាក់ទងនឹងការជ្រើសរើសថ្នាក់ដឹកនាំថ្មីរបស់គណបក្សសង្គ្រោះជាតិ។ ក្រសួងបានចោទថា គណបក្សសង្គ្រោះជាតិ អនុវត្តផ្ទុយនឹងលក្ខន្តិក:គណបក្ស។ ដោយឡែកគណបក្សសង្គ្រោះជាតិបានរៀបចំសមាជវិសាមញ្ញជ្រើសរើសសមាសភាពដឹកនាំថ្មីរបស់ខ្លួនចំនួន២លើក និងបានធ្វើវិសោធនកម្មលក្ខន្តិក:របស់ខ្លួន ដើម្បីកែតម្រូវតាមក្រសួងមហាផ្ទៃ។
- **អំឡុងខែកុម្ភៈ ឆ្នាំ២០១៧** សហភាពអឺរ៉ុប រដ្ឋាភិបាលអាមេរិក និងអង្គការសមាជិកអាស៊ាន ដើម្បីសិទ្ធិមនុស្ស (APHR) អង្គការជាតិ និងអន្តរជាតិមួយចំនួនបានសំដែងការព្រួយបារម្ភ និងថ្កោលទោសលើការធ្វើវិសោធនកម្មច្បាប់ ស្តីពីគណបក្សនយោបាយ និងបង្ហាញពីក្តីព្រួយបារម្ភជុំវិញបញ្ហានយោបាយនៅកម្ពុជាដែលកំពុងមានភាពអាប់អួរឡើងវិញ ដែលអាចបង្កឲ្យមានការប៉ះពាល់ដល់ការបោះឆ្នោតនាពេលខាងមុខ។
- **ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧** រដ្ឋសភាបើកកិច្ចប្រជុំវិសាមញ្ញពិភាក្សា និងអនុម័តសេចក្តីស្នើវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ។ កិច្ចប្រជុំនេះ មិនមានតំណាងរាស្ត្រមកពីគណបក្សសង្គ្រោះជាតិចូលរួមទេ។ ខ្លឹមសារសំខាន់នៃវិសោធនកម្មច្បាប់គឺការហាមឃាត់ទណ្ឌិតមិនឲ្យឡើងកាន់តំណែងជាប្រធាន និងអនុប្រធានគណបក្ស និងគណបក្សនយោបាយណាមួយអាចនឹងត្រូវបានរំលាយចោលនៅពេលប្រព្រឹត្តខុសច្បាប់ធ្ងន់ធ្ងរ។
- **ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៧** ឯកឧត្តម សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិបានលាលែងពីប្រធានគណបក្ស តាមរយៈលិខិតមួយច្បាប់ដោយបញ្ជាក់ថា ឯកឧត្តមមានហេតុផលផ្ទាល់ខ្លួន។
- **ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៧** គណបក្សយុវជនកម្ពុជា និងគណបក្សមហាសាមគ្គីជាតិខ្មែរប្រកាសផ្តាច់សម្ព័ន្ធភាពគ្នាក្រោយពីចងសម្ព័ន្ធភាពគ្នាបានរយៈពេល៦ថ្ងៃ ព្រោះមិនជឿទុកចិត្តគ្នា។
- **ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៧** គណបក្សយុវជនកម្ពុជា និងគណបក្សមហាសាមគ្គីជាតិខ្មែរប្រកាសចងសម្ព័ន្ធភាពគ្នាក្នុងទិសដៅបង្ហាញពីគំរូល្អដល់អ្នកនយោបាយនៃគណបក្សផ្សេងឲ្យចេះពិភាក្សា និងធ្វើការងារជាមួយគ្នា ដោយចៀសវាងការឈ្លោះទាស់ទែងដើម្បីផលប្រយោជន៍បក្សពួក។

- **ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧** គណបក្សខ្មែររួបរួមជាតិ និងគណបក្សយុត្តិធម៌ជាតិខ្មែរ បានប្រកាសចងសម្ព័ន្ធជាមួយគ្នា។ ការចងសម្ព័ន្ធនេះ គឺដើម្បីទាក់ទាញអ្នកគាំទ្រឲ្យបានកាន់តែច្រើន ជាពិសេសសម្រាប់ការបោះឆ្នោតនាពេលខាងមុខ។
- **ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧** ប្រធានគណៈកម្មការទី៧ នៃរដ្ឋសភា បានស្នើរដ្ឋាភិបាល តាមរយៈរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ឲ្យផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដល់ព្រះសង្ឃ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងជ្រើសរើសអ្នកតំណាងរាស្ត្រនាពេលខាងមុខ។
- **ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៧** ឯកឧត្តម កឹម សុខា អនុប្រធានគណបក្សសង្គ្រោះជាតិ ត្រូវបានព្រះមហាក្សត្រលើកលែងទោស បន្ទាប់ពីមានការស្នើសុំពីសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។
- **ថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៦** ឯកឧត្តម កឹម សុខា ប្រធានស្តីទីគណបក្សសង្គ្រោះជាតិបានធ្វើដំណើរទៅចុះឈ្មោះបោះឆ្នោតនៅសង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ ក្រោយឃុំខ្លួនឯងអស់១៣២ថ្ងៃនៅស្នាក់ការគណបក្ស។
- **ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៦** នៅវេលាយប់ រាជរដ្ឋាភិបាលបានចល័តកងកម្លាំងប្រដាប់អាវុធ នៅក្បែរទីស្នាក់ការកណ្តាលគណបក្សសង្គ្រោះជាតិ។ បក្សប្រឆាំងហៅការចល័តកម្លាំងប្រដាប់អាវុធនោះជាការបំភ័យ (អំឡុងពេលចុះឈ្មោះបោះឆ្នោត) ប៉ុន្តែគណបក្សកាន់អំណាចបានច្រានចោល។
- **ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦** សាលាដំបូងរាជធានីភ្នំពេញ សម្រេចផ្តន្ទាទោសឯកឧត្តម កឹម សុខា ប្រធាន ស្តីទីគណបក្សសង្គ្រោះជាតិឱ្យជាប់ពន្ធនាគារ៥ ខែ និងពិន័យ៨ សែនរៀល តាមមាត្រា ៥៣៨ នៃក្រមព្រហ្មទណ្ឌ «បដិសេធក្នុងការចូលខ្លួន» តាមដីការរបស់តុលាការ។
- **ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៦** ក្រុមមតិភាពច្រើននៃសមាជិករដ្ឋសភាពីគណបក្សប្រជាជនកម្ពុជា បានចេញលិខិតចំហមួយ ដោយប្រាប់បណ្តាថ្នាក់ដឹកនាំអន្តរជាតិថា លិខិតគណបក្សសង្គ្រោះជាតិដែលបានលើកពីកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដាក់តាមបណ្តាស្ថានទូតប្រចាំកម្ពុជានោះ គឺជាការចោទប្រកាន់មកលើរដ្ឋាភិបាលដោយគ្មានមូលដ្ឋានគ្រឹះច្បាស់លាស់ និងមិនមានការទទួលខុសត្រូវ ហើយកំពុងធ្វើឲ្យអន្តរាយដល់លទ្ធិប្រជាធិបតេយ្យ និងស្ថាប័ននយោបាយប្រទេសកម្ពុជា។
- **ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៦** ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស បានចេញសេចក្តីប្រកាសព័ត៌មានមួយ ដោយបានស្នើឲ្យរដ្ឋាភិបាល បង្កបរិយាកាសងាយស្រួល ក្នុងការអនុវត្តន៍សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ការជួបប្រជុំដោយសន្តិវិធី និងក្នុងការបង្កើតសមាគម នៅមុនការបោះឆ្នោតឃុំសង្កាត់ ឆ្នាំ២០១៧ និងការបោះឆ្នោតថ្នាក់ជាតិឆ្នាំ២០១៨។
- **ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦** សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ព្រមានថា នឹងទូទាត់បញ្ជីជាមួយអ្នករិះគន់រឿងទឹកខ្មៅ និងការបាត់ឈ្មោះបោះឆ្នោត។ ការព្រមាននេះ ធ្វើក្នុងពេលសម្តេចទៅចុះឈ្មោះបោះឆ្នោតនៅសង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល។

Appendix1: Comparison of Election Results
ឧសម្ព័ន្ធ១៖ ប្រៀបធៀបលទ្ធផលឆ្នោត

Table1: Percentage of Voting for Political Parties 1993-2017

(តារាងទី១៖ ភាគរយនៃសម្លេងឆ្នោតសម្រាប់គណបក្សនយោបាយនិមួយៗដែលទទួលបានលក្នុងការបោះឆ្នោតពីឆ្នាំ១៩៩៣ ដល់ ២០១៧)

Party		1998		2002		2003		2007		2008		2012		2013		2017	
		No	%	No	%	No	%	No	%	No	%	No	%	No	%	No	%
CPP		2,014,912	41.7	2,647,849	60.89	2,445,177	47.3	3,148,533	60.82	3,492,374	58.11	3,631,082	61.8	3,235,969	48.83	3,540,056	50.76
SRP	CNRP	694,169	14.36	736,454	16.94	1,137,308	22	1,303,906	25.19	1,316,714	21.91	1,224,460	20.84	2,946,176	44.46	3,056,824	43.83
HRP	CNRP	-	-	-	-	-	-	-	-	397,816	6.62	580,483	9.88				
FUN	FUN	1,547,767	32.01	955,200	21.97	1,072,136	20.74	277,545	5.36	303,764	5.05	222,671	3.79	242,413	3.66	132,319	1.9
NRP	FUN	-	-	-	-	-	-	419,791	8.11	337,943	5.62	170,962	2.91				
KNUP		-	-	-	-	-	-	-	-	-	-	-	-	-	-	78,724	1.13
GDP		-	-	-	-	-	-	-	-	-	-	-	-	-	-	4,981	0.07
LDP														-	-	122,882	1.76
BSDP		-	-	-	-	-	-	-	-	-	-	-	-	-	-	31,334	0.45
Others		578,794	11.97	9,061	0.21	514,751	9.96	27,094	0.52	161,666	2.69	46,069	0.78	202,601	3.05	140,275	0.1
Total		**4,835,642**	**100**	**4,348,564**	**100**	**5,169,372**	**100**	**5,176,869**	**100**	**6,010,277**	**100**	**5,985,458**	**100**	**6,627,159**	**100**	**7,107,395**	**100**

Figure1: Comparison of election results in 1993-2017 by year

(រូបភាពទី១៖ ប្រៀបធៀបលទ្ធផលបោះឆ្នោតតាមឆ្នាំចាប់តាំងពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០១៧)



Figure2: Election results for different seat of political parties in each province

រូបភាពទី២៖ ប្រៀបធៀបចំនួនអាសនៈរបស់គណបក្សនយោបាយតាមរាជធានីខេត្ត



Table2: Number and content of Political parties' article on Press Media

(តារាងទី២៖ ចំនួនអត្ថបទរបស់គណបក្សនយោបាយលើប្រព័ន្ធផ្សព្វផ្សាយ)

Political parties	Phnom Penh Post				Cambodia Daily				អាស៊ីសេរី (RFA)				បារាំង (RFI)				Moneakar Khmer				DAP News			
	Simple Political information	Complimentary political party information (Positive)	Critical political party information (Negative)	Total	Simple Political information	Complimentary political party information (Positive)	Critical political party information (Negative)	Total	Simple Political information	Complimentary political party information (Positive)	Critical political party information (Negative)	Total	Simple Political information	Complimentary political party information (Positive)	Critical political party information (Negative)	Total	Simple Political information	Complimentary political party information (Positive)	Critical political party information (Negative)	Total	Simple Political information	Complimentary political party information (Positive)	Critical political party information (Negative)	Total
CPP	11	0	0	11	7	0	0	7	10	0	0	10	3	0	0	3	0	0	0	0	76	2	0	78
CNRP	19	0	0	19	10	0	0	10	27	0	0	27	6	0	0	6	26	3	0	29	44	0	0	44
FUN	1	0	0	1	0	0	0	0	2	0	0	2	0	0	0	0	0	0	0	0	4	0	0	4
LDP	1	0	0	1	0	0	0	0	2	0	0	2	0	0	0	0	0	0	0	0	0	0	0	0
KNUP	0	0	0	0	0	0	0	0	3	0	0	3	0	0	0	0	0	0	0	0	0	0	0	0
BSDP	1	0	0	1	0	0	0	0	3	0	0	3	1	0	0	1	0	0	0	0	0	0	0	0
CNP	0	0	0	0	0	0	0	0	1	0	0	1	0	0	0	0	0	0	0	0	0	0	0	0
KPP	0	0	0	0	0	0	0	0	1	0	0	1	0	0	0	0	0	0	0	0	0	0	0	0
GDP	1	0	0	1	0	0	0	0	2	0	0	2	0	0	0	0	0	0	0	0	2	0	0	2
CYP	0	0	0	0	0	0	0	0	1	0	0	1	0	0	0	0	0	0	0	0	4	0	0	4
CIPDP	0	0	0	0	0	0	0	0	1	0	0	1	0	0	0	0	0	0	0	0	0	0	0	0
RDP	0	0	0	0	0	0	0	0	1	0	0	1	0	0	0	0	0	0	0	0	0	0	0	0
Total article	**34**				**17**				**54**				**10**				**29**				**132**			

Table3 : Number and cotent of Political parties' article on Press Media

(តារាងទី៣៖ចំនួនអត្ថបទរបស់គណបក្សនយោបាយលើប្រព័ន្ធផ្សព្វផ្សាយ)

Political Party	Thmey Thmey				Rasmei Kampuchea				Kohsantepheap Daily				CEN				Fresh News				Others				
	Simple Political information	Complimentary political party information (Positive)	Critical political party information (Negative)	Tot al	Simple Political information	Complimentary political party information (Positive)	Critical political party information (Negative)	Tot al	Simple Political information	Complimentary political party information (Positive)	Critical political party information (Negative)	Tot al	Simple Political information	Complimentary political party information (Positive)	Critical political party information (Negative)	Tot al	Simple Political information	Complimentary political party information (Positive)	Critical political party information (Negative)	Tot al	Simple Political information	Complimentary political party information (Positive)	Critical political party information (Negative)	Tot al	Sub Total Article for political party (tab 1 + table2)
CPP	13	0	0	13	45	0	0	45	8	0	0	8	29	0	0	29	163	6	0	169	2	0	0	2	375
CNRP	14	0	0	14	15	0	0	15	4	0	0	4	10	0	0	10	6	0	11	17	0	0	0	0	195
FUN	3	0	0	3	5	0	0	5	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	15
LDP	4	0	0	4	3	0	0	3	0	0	0	0	1	0	0	1	0	0	0	0	1	0	0	1	12
KNUP	1	0	0	1	4	0	0	4	0	0	0	0	1	0	0	1	0	0	0	0	0	0	0	0	9
BSDP	3	0	0	3	4	0	0	4	0	0	0	0	1	0	0	1	0	0	0	0	0	0	0	0	13
CNP	2	0	0	2	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	3
KPP	2	0	0	2	0	0	0	0	1	0	0	1	0	0	0	0	0	0	0	0	0	0	0	0	4
GDP	2	0	0	2	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	7
CYP	2	0	0	2	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	7
CIPDP	2	0	0	2	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	3
RDP	2	0	0	2	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	3
Sub Total article	**50**				**76**				**13**				**42**				**186**				**3**				

Table4: Election results for different Seat of political parties in each province

(តារាទី៤៖ លទ្ធផលអាសនៈរបស់គណបក្សនយោបាយតាមរាជធានីខេត្ត)

No	Province Name	CPP Seat	CNRP Seat	Other Party Seat	Total
1	Banteay Meanchey	286	211	18	515
2	Battambong	411	399	4	814
3	Kampong Cham	380	435	2	817
4	Kampong Chhnang	252	170	0	422
5	Kampong Speu	367	242	0	609
6	Kampong Thom	273	285	19	577
7	Kampot	317	240	4	561
8	Kandal	484	431	0	915
9	Koh Kong	112	55	0	167
10	Kratie	178	116	1	295
11	Mondol Kiri	86	21	0	107
12	Phnom Penh	431	468	0	899
13	Preah Vihea	203	129	1	333
14	Prey Veng	487	405	0	892
13	Pursat	251	92	0	343
16	Ratanakiri	207	51	2	260
17	Seim Reap	318	347	3	668
18	Preah Sihanuk	114	63	0	177
19	Steung Treng	132	39	5	176
20	Svay Rieng	332	186	0	518
21	Takeo	417	318	1	736
22	Kep	24	7	0	31
23	Pailin	30	22	0	52
24	Oddor Meanchey	102	49	1	152
25	Tboung Khmom	309	226	1	536
Total		**6503**	**5007**	**62**	**11572**

Appendix2: NEC Election Result and Schedule

ឧសម្ព័ន្ធ២៖ កាលវិភាគ និងលទ្ធផលបោះឆ្នោតសម្រាប់ការបោះឆ្នោតឆ្នាំ២០១៧ របស់ គ.ជ.ប

Table1: Schedule for Commune/Sangkat Council Elections in 2017

តារាងទី១៖ កាលវិភាគសម្រាប់ការបោះឆ្នោត



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឆ្នាំ២០១៦

ប្រតិទិននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៤ ឆ្នាំ២០១៧

ល.រ	ការងារត្រូវបំពេញ	កាលបរិច្ឆេទ
១	ការផ្តល់សុពលភាព និងប្រកាសផ្សាយបញ្ជីបោះឆ្នោតផ្លូវការដោយ គ.ជ.ប	ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៧
២	ការចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតជាតិនៅ គ.ជ.ប	ថ្ងៃទី១៥ ខែកុម្ភៈ - ២៤ ខែឧសភា ឆ្នាំ២០១៧
៣	ការចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិនៅ គ.ជ.ប	ថ្ងៃទី១៥ ខែកុម្ភៈ - ៣១ ខែឧសភា ឆ្នាំ២០១៧
៤	ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតនៅ គឃ.សប	ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧
៥	ការទទួលពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតដោយ គឃ.សប រយៈពេល ៣ថ្ងៃ	ថ្ងៃទី០៣-០៥ ខែមីនា ឆ្នាំ២០១៧
៦	ការពិនិត្យ សម្រេចរបស់ គឃ.សប លើពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ រយៈពេល ៧ថ្ងៃ	ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ)
៧	ការកែតម្រូវលើពាក្យសុំចុះបញ្ជីបេក្ខជនដោយសាមីគណបក្សនយោបាយ រយៈពេល៥ថ្ងៃ	ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ)
៨	ការប្តឹងតវ៉ាទាក់ទងនឹងការចុះបញ្ជីបេក្ខជនទៅ គធ.ឧប រយៈពេល ៥ថ្ងៃ	ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ)
៩	ការសម្រេចលើពាក្យបណ្តឹងដោយ គធ.ឧប រយៈពេល ៣ថ្ងៃ	ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ)
១០	ការប្តឹងតវ៉ាទាក់ទងនឹងការចុះបញ្ជីបេក្ខជនទៅ គ.ជ.ប រយៈពេល ៥ថ្ងៃ	ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ)
១១	ការសម្រេចលើពាក្យបណ្តឹងដោយ គ.ជ.ប រយៈពេល ៣ថ្ងៃ	ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ)
១២	ការបិទផ្សាយបញ្ជីបេក្ខជនដំបូងនៅ គឃ.សប រយៈពេល ៣ថ្ងៃ	ថ្ងៃទី០៥-០៧ ខែមេសា ឆ្នាំ២០១៧
១៣	ការប្តឹងជំទាស់នឹងបញ្ជីបេក្ខជនដំបូងទៅ គ.ជ.ប រយៈពេល ៣ថ្ងៃ	ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ)
១៤	ការដោះស្រាយពាក្យបណ្តឹងលើបញ្ជីបេក្ខជនដំបូងដោយ គ.ជ.ប រយៈពេល ៣ថ្ងៃ	ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ)
១៥	ការបិទផ្សាយបញ្ជីបេក្ខជនផ្លូវការនៅ គឃ.សប រយៈពេល ៧ថ្ងៃ	ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ)
១៦	ការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយនៅ គឃ.សប	ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ)
១៧	ការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនៅតាមភូមិក្នុងឃុំ សង្កាត់	ថ្ងៃទី១៧ ខែមេសា - ១៦ ខែឧសភា ឆ្នាំ២០១៧
១៨	ការឃោសនាបោះឆ្នោត រយៈពេល ១៨ថ្ងៃ	ថ្ងៃទី២០ ខែឧសភា - ០២ ខែមិថុនា ឆ្នាំ២០១៧
១៩	ការបិទផ្សាយបញ្ជីបោះឆ្នោតនៅការិយាល័យបោះឆ្នោត	ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៧
២០	ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបិទផ្សាយលទ្ធផលនៅការិយាល័យបោះឆ្នោត	ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៧
២១	ការប្រកាសផ្សាយលទ្ធផលបឋមនៃការបោះឆ្នោតដោយ គ.ជ.ប	ថ្ងៃទី០៤-០៥ ខែមិថុនា ឆ្នាំ២០១៧
២២	ការត្រួតពិនិត្យ ការបូកសរុប និងការបិទផ្សាយលទ្ធផលបណ្តោះអាសន្ននៅ គឃ.សប រយៈពេល ៣ថ្ងៃ	ថ្ងៃទី០៥-០៧ ខែមិថុនា ឆ្នាំ២០១៧
២៣	ការប្តឹងជំទាស់លើលទ្ធផលបណ្តោះអាសន្នតាមឃុំ សង្កាត់ ទៅ គធ.ឧប រយៈពេល ៣ថ្ងៃ	ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ)
២៤	ការសម្រេចលើពាក្យបណ្តឹងជំទាស់ដោយ គធ.ឧប រយៈពេល ៥ថ្ងៃ	ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ)
២៥	ការប្តឹងតវ៉ាលើសេចក្តីសម្រេចរបស់ គធ.ឧប ទៅ គ.ជ.ប រយៈពេល ៤ថ្ងៃ	ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ)
២៦	ការសម្រេចលើពាក្យបណ្តឹងតវ៉ាដោយ គ.ជ.ប រយៈពេល ៤ថ្ងៃ	ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ)
២៧	ការប្រកាសផ្សាយលទ្ធផលផ្លូវការនៃការបោះឆ្នោត	ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ)
២៨	ការបោះឆ្នោតសាជាថ្មី (បើមាន)	ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ)

Table2: The Result of Commune/Sangkat Elections Council in 2017 by Seat

តារាងទី២៖ អាសនៈនៃលទ្ធផលបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
អគ្គលេខាធិការដ្ឋាន
លេខ ០៨៧ គ.ជ.ប/អគ្គ./ប្រ.ក.ព

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០១៧

លទ្ធផលផ្លូវការនៃការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយសម្រាប់ឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៤ ឆ្នាំ ២០១៧

ល.រ	រាជធានី ខេត្ត	ចំនួនឃុំ សង្កាត់ (ឃ.ស.)	ចំនួនសមាជិកក្រុមប្រឹក្សា	ចំនួនគណបក្សនយោបាយ	គណបក្សប្រជាជនកម្ពុជា			គណបក្សសង្គ្រោះជាតិ			គណបក្សហ្វ៊ុនស៊ិនប៉ិច			គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ			គណបក្សខ្មែររួបរួមជាតិ			គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ			គណបក្សសញ្ជាតិកម្ពុជា			គណបក្សប្រជាធិបតេយ្យមូលដ្ឋាន			គណបក្សយុវជនកម្ពុជា			គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា			គណបក្សអំណាចខ្មែរ			គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ			សរុបតាមរាជធានី ខេត្ត	
					ឃ.ស.	បេក្ខជន	ស្រី	ឃ.ស.	បេក្ខជន	ស្រី	ឃ.ស.	បេក្ខជន	ស្រី	ឃ.ស.	បេក្ខជន	ស្រី	ឃ.ស.	បេក្ខជន	ស្រី	ឃ.ស.	បេក្ខជន	ស្រី	ឃ.ស.	បេក្ខជន	ស្រី	ឃ.ស.	បេក្ខជន	ស្រី	ឃ.ស.	បេក្ខជន	ស្រី	ឃ.ស.	បេក្ខជន	ស្រី	ឃ.ស.	បេក្ខជន	ស្រី	ឃ.ស.	បេក្ខជន	ស្រី	បេក្ខជន	ស្រី
01	បន្ទាយមានជ័យ	65	515	7	65	1,202	231	65	1,083	167	59	965	434	53	877	291	64	1,069	269																4	48	13	2	32	14	5,276	1,419
02	បាត់ដំបង	102	814	9	102	2,221	574	102	1,737	326	73	1,186	490	93	1,513	530	36	638	286	6	88	54				2	34	8							6	86	25	1	18	10	7,521	2,303
03	កំពង់ចាម	109	817	7	109	1,914	371	109	1,844	294	89	1,359	544	57	850	296	31	466	186	33	529	178	6	75	42																7,037	1,911
04	កំពង់ឆ្នាំង	70	422	9	70	1,023	213	70	917	133	33	457	137	30	376	146	55	660	250	20	289	119	1	14	8	1	12	2										4	54	20	3,802	1,028
05	កំពង់ស្ពឺ	87	609	7	87	1,412	241	87	1,298	126	33	485	158	50	727	224	87	1,253	498	43	633	209				5	93	29													5,901	1,485
06	កំពង់ធំ	81	577	9	81	1,318	279	81	1,349	205	61	910	290	28	445	188	39	558	157	3	58	25	1	14	7	2	36	12										1	14	11	4,702	1,174
07	កំពត	93	561	7	93	1,318	281	93	1,369	189	53	659	201	37	434	135	17	211	91	2	35	13				2	24	6													4,050	916
08	កណ្ដាល	127	915	8	127	2,088	494	127	1,966	272	73	1,151	489	66	1,004	346	34	486	253	20	338	128	17	295	152										2	36	17				7,364	2,151
09	កោះកុង	29	167	5	29	389	94	29	374	80	2	32	12	3	50	10	2	28	14																						873	210
10	ក្រចេះ	47	295	8	47	709	162	47	689	115	14	201	63	47	628	244	27	367	170	3	48	22	1	14	4							2	24	6							2,680	786
11	មណ្ឌលគិរី	21	107	6	21	249	57	21	231	36	5	51	15	8	80	28	3	30	17													15	156	32							797	185
12	ភ្នំពេញ	106	899	6	106	2,335	736	106	1,955	494	22	359	165	46	785	274	24	452	261	2	27	9																			5,913	1,939
13	ព្រះវិហារ	51	333	5	51	825	189	51	816	145	13	179	72	1	14	5	36	474	142																						2,308	553
14	ព្រៃវែង	116	892	8	116	1,784	368	116	1,853	239	69	1,090	457	89	1,417	506	25	395	179	64	1,065	394	21	292	158	2	36	7													7,932	2,308
15	ពោធិ៍សាត់	49	343	7	49	779	181	49	715	132	28	428	157	7	114	48	7	122	68	4	61	32																2	28	12	2,247	630
16	រតនគិរី	50	260	6	50	603	115	50	532	95	1	10	3	10	116	25	17	191	64							7	88	21													1,540	323
17	សៀមរាប	100	668	7	100	1,532	330	100	1,608	279	59	863	293	90	1,215	247	86	1,231	496	6	96	54																1	22	8	6,567	1,707
18	ព្រះសីហនុ	29	177	5	29	405	73	29	364	45	28	352	128	8	124	40	20	259	83																						1,504	369
19	ស្ទឹងត្រែង	34	176	4	34	438	80	34	404	85	17	219	69				4	42	20																						1,103	254
20	ស្វាយរៀង	80	618	8	80	1,157	274	80	1,102	162	28	397	148	18	252	78	14	192	89	8	136	49	4	48	19	2	24	5													3,308	822
21	តាកែវ	100	736	8	100	1,621	306	100	1,668	190	18	280	112	60	796	279	32	480	180	24	379	147				4	64	19							2	24	7				6,312	1,240
22	កែប	5	31	4	5	88	16	5	62	20	4	48	23	3	39	14																									237	73
23	ប៉ៃលិន	8	52	6	8	158	39	8	124	35				7	94	34	6	76	35																2	24	6	2	25	9	501	168
24	ឧត្តរមានជ័យ	24	162	7	24	346	87	24	317	76	10	144	32	13	180	39	20	257	116	4	69	37																1	14		1,327	387
25	ត្បូងឃ្មុំ	64	536	8	64	1,200	226	64	1,110	151	54	937	368	30	544	206	27	480	256	8	140	59	2	44	30				19	338	161										4,793	1,457
	សរុបរួម	1,646	11,572		1,646	27,114	6,017	1,646	25,487	4,091	846	12,762	4,858	844	12,674	4,233	713	10,417	4,180	250	3,991	1,529	52	796	420	27	411	109	19	338	161	17	180	38	16	218	68	14	207	84	94,595	25,788

Table3: The Result of Commune/Sangkat Elections Council in 2017 by Votes

តារាងទី៣៖ លទ្ធផលបោះឆ្នោតជាសម្លេងតាមគណបក្សនយោបាយ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លទ្ធផលនៃការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ (តារាងសំឡេងឆ្នោត និងតារាងតាមគណបក្ស)

ល.រ	ឈ្មោះរាជធានី/ខេត្ត	គណបក្សនយោបាយ																						សរុបសន្លឹកឆ្នោត				
		ប្រជាជនកម្ពុជា		សង្គ្រោះជាតិ		ហ៊ុន សុំន ប៊ុត		សម្ព័ន.ដើមអម្ពិល		ខ្មែរអភិបូរជាតិ		សំបុកឃ្មុំ		សញ្ជាតិកម្ពុជា		ប្រជា.ប្រុលជ្ញាន		សាធារណរដ្ឋ		យុវជនកម្ពុជា		អ្នកនាមខ្មែរ		ជនជាតិដើម		ចេញការ	មិនចេញការ	ចេញបោះឆ្នោត ស.ខ.ត្រូវបរិប	តាមរយៈ	ចំនួនសន្លឹកត្រូវ បញ្ជីបោះឆ្នោត
		សំឡេង	ភាគរយ	សំឡេង	ភាគរយ	សំឡេង	ភាគរយ	សំឡេង	ភាគរយ	សំឡេង	ភាគរយ	សំឡេង	ភាគរយ	សំឡេង	ភាគរយ	សំឡេង	ភាគរយ	សំឡេង	ភាគរយ	សំឡេង	ភាគរយ	សំឡេង	ភាគរយ	សំឡេង	ភាគរយ	សំឡេង	ភាគរយ					
01	មន្ទាយមានជ័យ	125,549	47.09	112,021	42.01	7,797	2.92	6,242	2.34	14,674	5.50		0.00		0.00		0.00	102	0.04		0.00	246	0.09		0.00	266,631	4,801	271,432	83.79	323,956
02	បាត់ដំបង	207,428	46.28	207,669	46.34	10,659	2.38	18,983	4.24	2,594	0.58	292	0.07		0.00	172	0.04	24	0.01		0.00	357	0.08		0.00	448,178	6,375	454,553	86.17	527,528
03	កំពង់ចាម	205,614	43.05	245,810	51.46	12,230	2.56	6,096	1.28	3,365	0.70	4,306	0.90	246	0.05		0.00		0.00		0.00		0.00		0.00	477,667	8,954	486,621	89.83	541,721
04	កំពង់ឆ្នាំង	143,204	55.09	101,705	39.12	5,152	1.98	2,764	1.06	4,802	1.85	1,721	0.66	68	0.03	282	0.11	254	0.10		0.00		0.00		0.00	259,952	5,950	265,902	91.48	290,655
05	កំពង់ស្ពឺ	241,935	55.22	171,083	39.05	4,291	0.98	6,667	1.52	8,101	1.85	5,383	1.23		0.00	680	0.16		0.00		0.00		0.00		0.00	438,140	7,742	445,882	93.84	475,129
06	កំពង់ធំ	130,075	44.40	133,201	45.47	17,909	6.11	3,543	1.21	6,323	2.16	721	0.25	37	0.01	1,129	0.39	25	0.01		0.00		0.00		0.00	292,963	5,592	298,555	86.48	345,228
07	កំពត	156,526	52.22	125,770	41.96	9,947	3.32	5,054	1.69	1,597	0.53	341	0.11		0.00	491	0.16		0.00		0.00		0.00		0.00	299,726	7,725	307,451	89.01	345,412
08	កណ្តាល	325,758	50.02	305,483	46.91	6,958	1.07	8,093	1.24	1,497	0.23	2,576	0.40	799	0.12		0.00		0.00		0.00	96	0.01		0.00	651,260	8,885	660,145	94.24	700,525
09	កោះកុង	31,759	59.40	20,628	38.58	360	0.67	489	0.91	233	0.44		0.00		0.00		0.00		0.00		0.00		0.00		0.00	53,469	1,277	54,746	88.52	61,846
10	ក្រចេះ	82,322	54.45	58,602	38.76	3,349	2.21	3,798	2.51	2,467	1.63	454	0.30	34	0.02		0.00		0.00		0.00		0.00	171	0.11	151,197	3,121	154,318	89.97	171,520
11	មណ្ឌលគិរី	21,923	68.19	8,164	25.39	175	0.54	691	2.15	96	0.30		0.00		0.00		0.00		0.00		0.00		0.00	1,101	3.42	32,150	857	33,007	89.70	36,797
12	ភ្នំពេញ	351,414	45.00	416,013	53.27	1,930	0.25	9,156	1.17	2,138	0.27	287	0.04		0.00		0.00		0.00		0.00		0.00		0.00	780,938	11,304	792,242	93.29	849,214
13	ព្រះវិហារ	59,046	57.34	38,040	36.94	1,696	1.65	123	0.12	4,079	3.96		0.00		0.00		0.00		0.00		0.00		0.00		0.00	102,984	3,620	106,604	92.20	115,621
14	ព្រៃវែង	278,107	51.00	237,301	43.52	7,245	1.33	11,069	2.03	1,761	0.32	8,804	1.61	652	0.12	342	0.06		0.00		0.00		0.00		0.00	545,281	8,360	553,641	89.15	620,995
15	ពោធិ៍សាត់	136,679	66.48	60,941	29.64	5,264	2.56	1,333	0.65	681	0.33	653	0.32		0.00		0.00	49	0.02		0.00		0.00		0.00	205,600	3,521	209,121	88.90	235,221
16	រតនគិរី	51,438	68.34	20,305	26.98	40	0.05	1,187	1.58	1,433	1.90		0.00		0.00	869	1.15		0.00		0.00		0.00		0.00	75,272	3,520	78,792	90.28	87,273
17	សៀមរាប	176,771	40.76	215,492	49.69	10,603	2.44	19,385	4.47	10,423	2.40	897	0.21		0.00		0.00	134	0.03		0.00		0.00		0.00	433,705	8,910	442,615	89.67	493,626
18	ព្រះសីហនុ	57,937	54.74	41,738	39.44	3,548	3.35	1,203	1.14	1,412	1.33		0.00		0.00		0.00		0.00		0.00		0.00		0.00	105,838	2,332	108,170	90.62	119,362
19	ស្ទឹងត្រែង	41,055	66.49	16,702	27.05	3,793	6.14		0.00	197	0.32		0.00		0.00		0.00		0.00		0.00		0.00		0.00	61,747	2,429	64,176	90.35	71,028
20	ស្វាយរៀង	174,975	60.13	107,022	36.78	4,096	1.41	1,796	0.62	1,207	0.41	1,255	0.43	194	0.07	455	0.16		0.00		0.00		0.00		0.00	291,000	6,078	297,078	90.53	328,166
21	តាកែវ	264,576	53.24	215,329	43.33	3,059	0.62	7,611	1.53	2,873	0.58	2,644	0.53		0.00	561	0.11		0.00		0.00	256	0.05		0.00	496,909	10,317	507,226	92.29	549,599
22	ឪត្បូ	14,092	67.65	5,576	26.77	784	3.76	378	1.81		0.00		0.00		0.00		0.00		0.00		0.00		0.00		0.00	20,830	495	21,325	92.52	23,050
23	ប៉ៃលិន	15,527	51.04	13,487	44.34		0.00	925	3.04	358	1.18		0.00		0.00		0.00	42	0.14		0.00	80	0.26		0.00	30,419	506	30,925	86.26	35,850
24	ឧត្តរមានជ័យ	57,430	58.17	32,767	33.19	1,788	1.81	2,237	2.27	4,035	4.09	291	0.29		0.00		0.00	188	0.19		0.00		0.00		0.00	98,736	3,345	102,081	87.52	116,643
25	កំពង់ធំ	188,916	53.47	145,975	41.32	9,646	2.73	4,059	1.15	2,378	0.67	709	0.20	131	0.04		0.00		0.00	1,505	0.43		0.00		0.00	353,319	7,474	360,793	90.41	399,068
	សរុបរួម	3,540,056	50.76	3,056,824	43.83	132,319	1.90	122,882	1.76	78,724	1.13	31,334	0.45	2,161	0.03	4,981	0.07	818	0.01	1,505	0.02	1,035	0.01	1,272	0.02	6,973,911	133,484	7,107,395	90.37	7,865,033

រាជធានីភ្នំពេញថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០១៧

Table4: The Result of Commune/Sangkat Elections Council in 2017 by Commune Chief

តារាងទី៤៖ លទ្ធផលបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កែតឆ្នាំ២០១៧ ដែលគណបក្សនិមួយៗទទួលបានអាសនៈមេឃុំ ចៅសង្កាត់



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ (តារាងគណបក្សនយោបាយឈ្នះបានអាសនៈ)

ល.រ	ឈ្មោះរាជធានី/ខេត្ត	គណបក្សប្រជាជនកម្ពុជា					គណបក្សសង្គ្រោះជាតិ					គណបក្សហ៊ុន ស៊ុន ម៉ុច					គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ					គណបក្សខ្នែបូបូជាតិ					គណបក្សសំបុកឃ្មុំ					គណបក្សប្រជាធិបតេយ្យ					សរុបតាមខេត្ត	
		ចំនួនអាសនៈ					ចំនួនអាសនៈ					ចំនួនអាសនៈ					ចំនួនអាសនៈ					ចំនួនអាសនៈ					ចំនួនអាសនៈ					ចំនួនអាសនៈ						
		សរុប	ប្រុស	ស្រី	ជាប់ឆ្នោត	ជាប់តំណែង	សរុប	ប្រុស	ស្រី	ជាប់ឆ្នោត	ជាប់តំណែង	សរុប	ប្រុស	ស្រី	ជាប់ឆ្នោត	ជាប់តំណែង	សរុប	ប្រុស	ស្រី	ជាប់ឆ្នោត	ជាប់តំណែង	សរុប	ប្រុស	ស្រី	ជាប់ឆ្នោត	ជាប់តំណែង	សរុប	ប្រុស	ស្រី	ជាប់ឆ្នោត	ជាប់តំណែង	សរុប	ប្រុស	ស្រី	ជាប់ឆ្នោត	ជាប់តំណែង	អាសនៈ	ប្រុស
01	បន្ទាយមានជ័យ	286	59	54	43	11	211	29	10	21	43											18	1	1	11											515	88
02	បាត់ដំបង	411	86	53	53	47	399	62	49	49	51	3				3	1				1															814	148
03	កំពង់ចាម	380	52	35	37	72	435	54	74	72	35											1			1	1			1							817	106
04	កំពង់ឆ្នាំង	252	52	62	62	8	170	21	8	8	62																									422	73
05	កំពង់ស្ពឺ	367	74	78	78	9	242	16	9	9	78																									609	90
06	កំពង់ធំ	273	57	40	45	30	285	35	41	36	34	15				14						2			2									2		1	577	92
07	កំពត	317	86	71	67	22	240	15	22	25	68	3			1	2																		1		1	561	101
08	កណ្តាល	484	95	79	79	48	431	40	48	48	79																									915	135
09	កោះកុង	112	27	26	26	7	55	7	3	3	22																									167	34
10	ក្រចេះ	178	46	38	37	10	116	16	9	10	36	1				1																				295	62
11	មណ្ឌលគិរី	86	20	21	21	4	21				17																									107	20
12	ព្រៃវែង	431	128	48	48	57	468	79	57	57	48																									899	207
13	ព្រះវិហារ	203	51	42	41	10	129	12	9	10	40											1			1											333	63
14	ប៉ៃលិន	487	92	73	73	43	405	32	43	43	73																									892	124
15	ពោធិ៍សាត់	251	48	49	49	5	92	9			44																									343	57
16	រតនគិរី	207	40	48	47	19	51	3	2	2	31																							2		1	260	43
17	សៀមរាប	318	68	44	45	54	347	53	56	55	43						2				2	1			1											668	121
18	ព្រះសីហនុ	114	21	26	26	3	63	7	3	3	26																									177	28
19	ស្ទឹងត្រែង	132	34	33	29	4	39	4	1	5	25	5				5																				176	38
20	ស្វាយរៀង	332	81	73	73	9	186	11	7	7	71																									518	92
21	តាកែវ	417	78	82	81	18	318	14	18	19	81	1				1																				736	92
22	ឱរ៉ែម	24	5	5	5		7	2			5																									31	7
23	ម៉ៃឥន	30	8	7	7	1	22	7	1	1	7																									52	15
24	ឧត្តរមានជ័យ	102	28	23	22	1	49	8	1	2	22						1				1															152	36
25	ភ្នំពេញ	309	50	46	45	18	226	17	18	18	46											1			1											536	97
	សរុបរួម	6,503	1,386	1,156	1,139	510	5,007	553	489	503	1,087	28			1	26	4				4	24	1	2	16	1			1	5		1	2	11,572	1,939		

រាជធានីភ្នំពេញថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០១៧

Table5: Percentage of Seat and Votes of Political Party in Elections 2017

តារាងទី៥៖ គណបក្សនយោបាយទទួលបានសម្លេងឆ្នោត និងអាសនៈ គិតជាភាគរយ



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លទ្ធផលនៃការបោះឆ្នោតរើសអើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ (តារាងគណបក្សនយោបាយទទួលបានសម្លេងឆ្នោតនិងអាសនៈគិតជាភាគរយ)

ល.រ	ឈ្មោះរាជធានី/ខេត្ត	គណបក្សប្រជាជនកម្ពុជា				គណបក្សសង្គ្រោះជាតិ				គណបក្សហ៊្វុន ស៊ុន ចិន្ដ				គណបក្សសម្ព័ន្ធប្រជាធិបតេយ្យ				គណបក្សខ្មែរអភិវឌ្ឍជាតិ				គណបក្សសម្បុកឈើ.ប្រជាធិបតេយ្យ				គណបក្សប្រជា.សុភាព				សរុបតាមខេត្ត		
		សំឡេងឆ្នោត		ចំនួនអាសនៈ		សំឡេងឆ្នោត		ចំនួនអាសនៈ		សំឡេងឆ្នោត		ចំនួនអាសនៈ		សំឡេងឆ្នោត		ចំនួនអាសនៈ		សំឡេងឆ្នោត		ចំនួនអាសនៈ		សំឡេងឆ្នោត		ចំនួនអាសនៈ		សំឡេងឆ្នោត		ចំនួនអាសនៈ				
		សរុប	ភាគរយ	សរុប	ភាគរយ	សរុប	ភាគរយ	សរុប	ភាគរយ	សរុប	ភាគរយ	សរុប	ភាគរយ	សរុប	ភាគរយ	សរុប	ភាគរយ	សរុប	ភាគរយ	សរុប	ភាគរយ	សរុប	ភាគរយ	សរុប	ភាគរយ	សរុប	ភាគរយ	សរុប	ភាគរយ	អាសនៈ	ឃុំ	ភាគរយ
01	បន្ទាយមានជ័យ	125,549	45.45	286	55.53	112,021	40.55	211	40.97	7,797	2.82		0.00	6,242	2.26		0.00	14,674	5.31	18	3.50		0.00		0.00		0.00		0.00	515	88	17.09
02	បាត់ដំបង	207,428	45.00	411	50.49	207,669	45.05	399	49.02	10,659	2.31	3	0.37	18,983	4.12	1	0.12	2,594	0.56		0.00	292	0.06		0.00	172	0.04		0.00	814	148	18.18
03	កំពង់ចាម	205,614	41.49	380	46.51	245,810	49.60	435	53.24	12,230	2.47		0.00	6,096	1.23		0.00	3,365	0.68	1	0.12	4,306	0.87	1	0.12		0.00		0.00	817	106	12.97
04	កំពង់ឆ្នាំង	143,204	52.68	252	59.72	101,705	37.41	170	40.28	5,152	1.90		0.00	2,764	1.02		0.00	4,802	1.77		0.00	1,721	0.63		0.00	282	0.10		0.00	422	73	17.30
05	កំពង់ស្ពឺ	241,935	53.33	367	60.26	171,083	37.71	242	39.74	4,291	0.95		0.00	6,667	1.47		0.00	8,101	1.79		0.00	5,383	1.19		0.00	680	0.15		0.00	609	90	14.78
06	កំពង់ធំ	130,075	42.77	273	47.31	133,201	43.79	285	49.39	17,909	5.89	15	2.60	3,543	1.16		0.00	6,323	2.08	2	0.35	721	0.24		0.00	1,129	0.37	2	0.35	577	92	15.94
07	កំពត	156,526	49.66	317	56.51	125,770	39.90	240	42.78	9,947	3.16	3	0.53	5,054	1.60		0.00	1,597	0.51		0.00	341	0.11		0.00	491	0.16	1	0.18	561	101	18.00
08	កណ្ដាល	325,758	48.69	484	52.90	305,483	45.66	431	47.10	6,958	1.04		0.00	8,093	1.21		0.00	1,497	0.22		0.00	2,576	0.39		0.00		0.00		0.00	915	135	14.75
09	កោះកុង	31,759	56.69	112	67.07	20,628	36.82	55	32.93	360	0.64		0.00	489	0.87		0.00	233	0.42		0.00		0.00		0.00		0.00		0.00	167	34	20.36
10	ក្រចេះ	82,322	52.29	178	60.34	58,602	37.22	116	39.32	3,349	2.13	1	0.34	3,798	2.41		0.00	2,467	1.57		0.00	454	0.29		0.00		0.00		0.00	295	62	21.02
11	មណ្ឌលគិរី	21,923	64.74	86	80.37	8,164	24.11	21	19.63	175	0.52		0.00	691	2.04		0.00	96	0.28		0.00		0.00		0.00		0.00		0.00	107	20	18.69
12	ព្រៃវែង	351,414	43.73	431	47.94	416,013	51.77	468	52.06	1,930	0.24		0.00	9,156	1.14		0.00	2,138	0.27		0.00	287	0.04		0.00		0.00		0.00	899	207	23.03
13	ព្រះវិហារ	59,046	53.57	203	60.96	38,040	34.51	129	38.74	1,696	1.54		0.00	123	0.11		0.00	4,079	3.70	1	0.30		0.00		0.00		0.00		0.00	333	63	18.92
14	ព្រៃវែង	278,107	49.49	487	54.60	237,301	42.22	405	45.40	7,245	1.29		0.00	11,069	1.97		0.00	1,761	0.31		0.00	8,804	1.57		0.00	342	0.06		0.00	892	124	13.90
15	ពោធិ៍សាត់	136,679	64.28	251	73.18	60,941	28.66	92	26.82	5,264	2.48		0.00	1,333	0.63		0.00	681	0.32		0.00	653	0.31		0.00		0.00		0.00	343	57	16.62
16	រតនគិរី	51,438	62.49	207	79.62	20,305	24.67	51	19.62	40	0.05		0.00	1,187	1.44		0.00	1,433	1.74		0.00		0.00		0.00	869	1.06	2	0.77	260	43	16.54
17	សៀមរាប	176,771	39.15	318	47.60	215,492	47.73	347	51.95	10,603	2.35		0.00	19,385	4.29	2	0.30	10,423	2.31	1	0.15	897	0.20		0.00		0.00		0.00	668	121	18.11
18	ព្រះសីហនុ	57,937	52.43	114	64.41	41,738	37.77	63	35.59	3,548	3.21		0.00	1,203	1.09		0.00	1,412	1.28		0.00		0.00		0.00		0.00		0.00	177	28	15.82
19	ស្ទឹងត្រែង	41,055	61.64	132	75.00	16,702	25.08	39	22.16	3,793	5.69	5	2.84		0.00		0.00	197	0.30		0.00		0.00		0.00		0.00		0.00	176	38	21.59
20	ស្វាយរៀង	174,975	57.72	332	64.09	107,022	35.30	186	35.91	4,096	1.35		0.00	1,796	0.59		0.00	1,207	0.40		0.00	1,255	0.41		0.00	455	0.15		0.00	518	92	17.76
21	តាកែវ	264,576	51.12	417	56.66	215,329	41.61	318	43.21	3,059	0.59	1	0.14	7,611	1.47		0.00	2,873	0.56		0.00	2,644	0.51		0.00	561	0.11		0.00	736	92	12.50
22	កែប	14,092	64.58	24	77.42	5,576	25.55	7	22.58	784	3.59		0.00	378	1.73		0.00		0.00		0.00		0.00		0.00		0.00		0.00	31	7	22.58
23	ថៃលិន	15,527	49.40	30	57.69	13,487	42.91	22	42.31		0.00		0.00	925	2.94		0.00	358	1.14		0.00		0.00		0.00		0.00		0.00	52	15	28.85
24	ឧត្ដរមានជ័យ	57,430	54.47	102	67.11	32,767	31.08	49	32.24	1,788	1.70		0.00	2,237	2.12	1	0.66	4,035	3.83		0.00	291	0.28		0.00		0.00		0.00	152	36	23.68
25	ភ្នំពេញ	188,916	51.30	309	57.65	145,975	39.64	226	42.16	9,646	2.62		0.00	4,059	1.10		0.00	2,378	0.65	1	0.19	709	0.19		0.00		0.00		0.00	536	67	12.50
	សរុបរួម	3,540,056	50.76	6,503	56.20	3,056,824	43.83	5,007	43.27	132,319	1.90	28	0.24	122,882	1.76	4	0.03	78,724	1.13	24	0.21	31,334	0.45	1	0.01	4,981	0.07	5	0.04	11,572	1,939	16.76

រាជធានីភ្នំពេញថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០១៧

Appendix3: NEC Press Statement

ឧសម្ព័ន្ធ៣៖ សេចក្តីប្រកាសព័ត៌មានរបស់ គ.ជ.ប

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

អគ្គលេខាធិការដ្ឋាន
លេខ ០៩០/ គ.ជ.ប/អគ្គ/ប្រ.ក.៣
/១៦

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែវិច្ឆិកា ឆ្នាំ២០១៦

សេចក្តីប្រកាសព័ត៌មាន

នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ វេលាម៉ោង ០៩:០០នាទីព្រឹក នៅសាលសន្និសីទ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) មានជំនួបពិភាក្សាក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការរវាង គ.ជ.ប ដឹកនាំដោយ ឯកឧត្តម **ស៊ិក ប៊ុនហុក** ប្រធាន គ.ជ.ប និងអង្គការសង្គមស៊ីវិលចំនួន ១០ ដឹកនាំដោយលោក **គល់ បញ្ញា** នាយកប្រតិបត្តិអង្គការខុមហ្រ្វែល(COMFREL) ។

របៀបវារៈនៃកិច្ចពិភាក្សាមានចំនួន ០៣ សំខាន់ ដែលអង្គការសង្គមស៊ីវិលដាក់មកកាន់ គ.ជ.ប ៖

១- ការបង្ហាញនូវរបាយការណ៍ចុះឈ្មោះបោះឆ្នោត ដែលអង្គការខុមហ្រ្វែល បានរកឃើញ

២- ផែនការ និងវិធីសាស្ត្រធ្វើសវនកម្មបញ្ជីបោះឆ្នោត និងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ

៣- ការសម្រួលគោលការណ៍សម្រាប់ការចេញប័ណ្ណដល់អ្នកសង្កេតការណ៍

កិច្ចពិភាក្សានេះអ្នកចូលរួមមាន៖ តំណាងអង្គការ COMFREL តំណាងអង្គការ NDI តំណាងអង្គការ NICFEC តំណាងអង្គការ ADHOC និងតំណាងអង្គការសង្គមស៊ីវិលចំនួន ០៦ ផ្សេងទៀតរួមទាំងមន្ត្រី គ.ជ.ប សរុបចំនួន ៥៥នាក់។

គ.ជ.ប យល់ឃើញថា ការបង្ហាញនូវរបាយការណ៍ចុះឈ្មោះបោះឆ្នោត ដែលអង្គការខុមហ្រ្វែលបានរកឃើញ គឺមានចំណុចមួយចំនួន គ.ជ.ប បានធ្វើការកែសម្រួលរួចអស់ហើយ ប៉ុន្តែចំពោះការស្នើ គ.ជ.ប ជួយអន្តរាគមន៍ដើម្បីឱ្យប្រជាពលករខ្មែរធ្វើការនៅប្រទេសថៃ បានចុះឈ្មោះបោះឆ្នោត នៅតាមការិយាល័យចុះឈ្មោះបោះឆ្នោតដែលស្ថិតនៅក្នុងឃុំ សង្កាត់ តាមបណ្តោយព្រំដែនកម្ពុជា ថៃ ចំណុចនេះ គ.ជ.ប មិនអាចជួយធ្វើអន្តរាគមន៍បានទេ ព្រោះ គ.ជ.ប អនុវត្តន៍ទៅតាមច្បាប់។ ពលករទាំងអស់អាចចុះឈ្មោះបោះឆ្នោតបាននៅតាម ឃុំ សង្កាត់ ដែលគាត់មានទីលំនៅ ឬទីសំណាក់នៅក្នុងប្រទេស នឹងម៉្យាង គ.ជ.ប និងក្រសួងមហាផ្ទៃក៏បានណែនាំដល់អាជ្ញាធរ ឃុំ សង្កាត់ ឱ្យពង្រឹងការអនុវត្តនីតិវិធី និងបែបបទនៃការចេញលិខិតបញ្ជាក់ទីលំនៅ ដើម្បីគោលដៅនៃការចុះឈ្មោះបោះឆ្នោត។

គ.ជ.ប យល់ឃើញថា ការធ្វើសវនកម្មបញ្ជីបោះឆ្នោតជាការចាំបាច់ ដើម្បីបង្កើនជំនឿទុកចិត្តពីអ្នកបោះឆ្នោត និងដើម្បីឱ្យដឹងអំពីភាពពេញលេញ សុក្រឹតភាព និងបច្ចុប្បន្នភាពនៃបញ្ជីបោះឆ្នោត។ ចំពោះការធ្វើនេះ ប្រសិន

សូមទំនាក់ទំនង : 023 214 231 / 012 855 018 ; E-mail: necinfo@forum.org.kh ; www.necelect.org.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
អគ្គលេខាធិការដ្ឋាន
លេខ 124 គ.ជ.ប/អគ្គ/ប្រ.ព.ព

រាជធានីភ្នំពេញ, ថ្ងៃទី 29 ខែឧសភា ឆ្នាំ២០១៧

សេចក្តីប្រកាសព័ត៌មាន

នៅព្រឹកថ្ងៃច័ន្ទទី២៩ ខែឧសភា ឆ្នាំ២០១៧ វេលាម៉ោង ០៩:០០នាទី គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដឹកនាំដោយឯកឧត្តម **ស៊ិក ប៊ុនហុក** ប្រធាន គ.ជ.ប បានជួបពិភាក្សាការងារជាមួយគណៈប្រតិភូសង្គមស៊ីវិល ដឹកនាំដោយលោក **គល់ បញ្ញា** នាយកប្រតិបត្តិអង្គការ **ខមហ្រ្វែល** នាទីស្តីការ គ.ជ.ប ។

ឯកឧត្តម **ស៊ិក ប៊ុនហុក** ប្រធាន គ.ជ.ប បានជម្រាបជូនព័ត៌មានមួយចំនួនដល់សង្គមស៊ីវិល អំពីទស្សនៈវិស័យថា ដំណើរការរៀបចំការបោះឆ្នោតដែល គ.ជ.ប សម្រេចបាននាពេលកន្លងមក និងការងារចំពោះមុខ ។ បន្ទាប់ពីបានស្តាប់ការពន្យល់ណែនាំរបស់ឯកឧត្តមប្រធាន គ.ជ.ប គណៈប្រតិភូសង្គមស៊ីវិលបានកោតសរសើរ គ.ជ.ប ថា៖

- មានការបើកទូលាយដល់ភាគីពាក់ព័ន្ធការបោះឆ្នោតទាំងអស់ ដែលការបើកទូលាយនេះហើយសង្គមស៊ីវិលមើលឃើញថា មានតម្លាភាពល្អប្រសើរ
- គុណភាពបញ្ជីបោះឆ្នោតដែលរៀបចំដោយ គ.ជ.ប មានលក្ខណៈល្អប្រសើរ
- ការចេញវិធានការ ៥ ចំណុចទប់ស្កាត់មិនឱ្យបោះឆ្នោតលើសពីមួយដង ជាវិធានការល្អបំផុត
- ការសម្រេចឱ្យថតទម្រង់ ១១០២ និង ១១០៥ ដាក់នៅលើវេបសាយ ជាការបង្ហាញពីតម្លាភាព
- ការចេញសេចក្តីណែនាំទៅអ្នកគ្រប់គ្រងផ្សារ ដែលអនុញ្ញាតឱ្យមានការចូលចែកខិត្តប័ណ្ណនៅក្នុងផ្សារពេលឃោសនាបោះឆ្នោត ជាការប្រសើរដែលទប់ស្កាត់នូវបញ្ហាទំនាស់បាន ។

នៅក្នុងជំនួបពិភាក្សានោះសង្គមស៊ីវិលក៏បានស្នើឱ្យ គ.ជ.ប ចេញនូវវិធានការមួយចំនួនដូចជា៖

- សូមឱ្យ គយ.សប បោះត្រាបញ្ជាក់លើ ឯ.អ សម្រាប់បម្រើឱ្យការចុះឈ្មោះបោះឆ្នោតជាការស្រេចសម្រាប់យកទៅបោះឆ្នោត មិនចាំបាច់ធ្វើ ឯ.អ សម្រាប់បម្រើឱ្យការបោះឆ្នោតទេ
- សូមឱ្យ គ.ជ.ប ចេញសេចក្តីប្រកាសបញ្ជាក់បន្ថែម អំពីប័ណ្ណព័ត៌មានអ្នកបោះឆ្នោតថា អ្នកគ្មានប័ណ្ណព័ត៌មានក៏បោះឆ្នោតបានដែរ ហើយមន្ត្រីការិយាល័យបោះឆ្នោតមិនត្រូវឱ្យទាមទារ ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតពីអ្នកបោះឆ្នោតទេ
- សូមឱ្យ គ.ជ.ប អនុញ្ញាតឱ្យអង្គការសង្គមស៊ីវិលមានបញ្ជីបោះឆ្នោតក្នុងដៃ ដើម្បីផ្ទៀងផ្ទាត់ដូចភ្នាក់ងារគណបក្សនយោបាយដែរ
- ស្នើឱ្យ គ.ជ.ប ចាត់តាំងជនបង្គោលណាម្នាក់នៅថ្នាក់ គ.ជ.ប និងថ្នាក់ គឃ.ខប ដើម្បីងាយស្រួលដល់សង្គមស៊ីវិលក្នុងការទំនាក់ទំនង
- ស្នើឱ្យ គ.ជ.ប ជួយសម្រួលដល់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន បានផ្សាយព័ត៌មាននៅថ្ងៃបោះឆ្នោតជាង ពីព្រោះកន្លងមកក្រសួងព័ត៌មាន មិនអនុញ្ញាតឱ្យប្រព័ន្ធផ្សព្វផ្សាយព័ត៌មានធ្វើការផ្សាយព័ត៌មាននៅថ្ងៃបោះឆ្នោតទេ

សូមទំនាក់ទំនង : 023 214 231 / 012 855 018 ; E-mail: necinfo@forum.org.kh ; www.necelect.org.kh

- សូមឱ្យ គ.ជ.ប ជួយជំរុញបន្ថែមទៀតទាក់ទងនឹងពេលវេលាឈប់សម្រាកមកចូលរួមបោះឆ្នោតរបស់ពលករខ្មែរធ្វើការនៅប្រទេសថៃ តើគួរសម្រួលបែបណា ដើម្បីឱ្យពួកគាត់បានចូលរួមបោះឆ្នោត
- សូមឱ្យ គ.ជ.ប ជួយសម្រួលចំពោះគ្រឹះស្ថានហិរញ្ញវត្ថុ ដើម្បីឱ្យប្រគល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដែលដាក់បញ្ចាំ ឬធានា នៅតាមបណ្តាគ្រឹះស្ថានមួយចំនួនឱ្យប្រគល់មកប្រជាពលរដ្ឋវិញ ដើម្បីឱ្យពួកគាត់ធ្វើជាឯកសារបោះឆ្នោត សម្រាប់ប្រើនៅថ្ងៃបោះឆ្នោត ។

បន្ទាប់ពីបានស្តាប់ការស្នើសុំរបស់គណៈប្រតិភូអង្គការសង្គមស៊ីវិល ឯកឧត្តមប្រធាន គ.ជ.ប បានបញ្ជាក់ថា រាល់ការលើកជាអានុសាសន៍ទាំងនេះវាទាក់ទងនឹងច្បាប់បោះឆ្នោតផង និងបច្ចេកទេសផង ដូចនេះ គ.ជ.ប នឹងដាក់បញ្ចូលទៅក្នុងរៀបវារៈប្រជុំរបស់ គ.ជ.ប ដើម្បីពិនិត្យមើលថាតើត្រូវធ្វើបែបណា ហើយ គ.ជ.ប នឹងធ្វើការឆ្លើយតបវិញនៅពេលក្រោយ ៕

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
អគ្គលេខាធិការដ្ឋាន
លេខ ១៣០ គ.ជ.ប/អគ្គ/ប្រ.ក.ព

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០១៧

ចំនួនអ្នកសង្កេតការណ៍ជាតិ ចូលរួមសង្កេតមើលដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧

ចំនួនអ្នកសង្កេតការណ៍ជាតិ ចូលរួមសង្កេតមើលដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ មានដូចខាងក្រោម ៖

ល.រ	អង្គការ	ចំនួនអ្នកសង្កេតការណ៍		
		សរុប	ស្រី	ចល័ត
១	សហភាពសហព័ន្ធយុវជនកម្ពុជា (UYFC)	៣១,៨៣១	៩,២៩៣	០
២	សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ (CWPD)	២០,៧៩៣	២០,៧១៧	១០
៣	គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)	១៤,៥៨០	៦,១៥៣	១០
៤	សហព័ន្ធនិស្សិត បញ្ញវន្ត ប្រជាធិបតេយ្យកម្ពុជា (CDSIF)	២,៦៤២	១,៤០៧	១០
៥	អង្គការតម្លាភាពកម្ពុជា (TIC)	១,២៣៩	៥៦០	១០
៦	គណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា(NICFEC)	១,០៥២	៤១១	១០
៧	គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW)	៥៦៧	៣០៤	១០
៨	សមាគមរួមគ្នាដើម្បីអភិវឌ្ឍន៍កម្ពុជា (CCDA)	៤៣៨	១៩	០
៩	សមាគមយុវជនកិច្ចការសង្គម	៤០៧	១៤៥	០
១០	សហគមន៍អភិវឌ្ឍន៍ជាតិ(UND)	២៦៥	៤៥	៣
១១	មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (ភីឌីភី), (PDP-Center)	២២៨	១០៧	១០
១២	អង្គការប្រជាធិបតេយ្យ និងសិទ្ធិមនុស្សក្នុងប្រតិបត្តិការ(DHRAC)	២០១	១០៤	៨
១៣	សមាគមសិទ្ធិមនុស្សដើម្បីអភិវឌ្ឍន៍ និងថែរក្សាកុមារកំព្រាស្ត្រីក្រីក្រ(CO.P.A)	១៦២	៤៥	៧
១៤	អង្គការជនពិការកម្ពុជា (C.D.P.O)	១៤១	៦១	០
១៥	អង្គការសេវាប្រជាធិបតេយ្យ(D.S.O)	១៣៤	៤៨	៦
១៦	សមាគមយុវជនសេដ្ឋកិច្ចកម្ពុជា (ស.យ.ស.ក)	១១៩	៥១	០
១៧	សមាគម បញ្ញវន្ត និងយុវជនស្ម័គ្រចិត្ត (VIYA)	៦៤	២៧	១០
១៨	សហព័ន្ធសិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា(C.FHRAD)	៦០	៣០	០
១៩	សមាគមអ្នកលក់ឱសថកម្ពុជា (C.P.A)	៦០	២៦	០
២០	វិទ្យាស្ថានអភិវឌ្ឍន៍ធនធានមនុស្ស, Institute of Human Resources Development (Non-Governmental Organization)	៥០	២	០
២១	សមាគម សិស្ស និស្សិត បញ្ញវន្តក្មេងវត្ត (PCISA)	៣៨	០	០
	សរុប	**៧៤,៦៧១**	**៣៩,៥៥៥**	**១០៤**

សមទំនាក់ទំនង : 023 214 231 / 012 855 018 ; E-mail: necinfo@forum.org.kh ; Website: www.necelect.org.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
អគ្គលេខាធិការដ្ឋាន
លេខ ១២៧ គ.ជ.ប/អគ្គ/ប្រ.ក.ព

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០១៧

សេចក្តីប្រកាសព័ត៌មាន

នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៧ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានចេញលិខិត សេចក្តីណែនាំ និងសេចក្តីជូនដំណឹងមួយចំនួនដល់ស្ថាប័នពាក់ព័ន្ធ ដើម្បីជួយសម្រួលដល់ដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧។

លិខិត សេចក្តីណែនាំ និងសេចក្តីជូនដំណឹងទាំងនោះរួមមាន ៖

- លិខិតលេខ ៨០៩ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៧ ទៅក្រសួងការបរទេសកម្ពុជា ដើម្បីស្នើសុំពិនិត្យលទ្ធភាព សម្រួលដល់ពលករ និងនិស្សិតខ្មែរដែលបានស្នាក់នៅឯបរទេសបានមកបោះឆ្នោតនៅកម្ពុជាវិញ ដែលប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ទី៤ ខែមិថុនា ឆ្នាំ២០១៧។
- សេចក្តីណែនាំរួមបន្ថែម លេខ ០១២ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីនីតិវិធីនៃការស្នើសុំ និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណ បម្រើឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧។
- សេចក្តីណែនាំលេខ ៨១០ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការពង្រឹង សន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយ ក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ក្នុងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧។
- សេចក្តីជូនដំណឹងលេខ ៨១១ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីឯកសារផ្លូវការរបស់ប្រជាពលរដ្ឋ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១៦ សម្រាប់យកទៅប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧។

សាធារណជនអាចស្វែងរកលិខិតទាំងនោះ នៅលើគេហទំព័ររបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) www.necelect.org.kh ។

សូមទំនាក់ទំនង : 023 214 231 / 012 855 018 ; E-mail: necinfo@forum.org.kh ; www.necelect.org.kh

Appendix4: MoI Statement

ឧសម្ព័ន្ធ៤៖ សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងមហាផ្ទៃ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ...

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងមហាផ្ទៃ

នៅក្នុងកម្មវិធីផ្សាយរបស់វិទ្យុអាស៊ីសេរីកាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៧ បានធ្វើការផ្សាយព័ត៌មានថា **អង្គការសង្គមស៊ីវិល និងគណបក្សសង្គ្រោះជាតិ ព្រួយបារម្ភអំពីការប្រើប្រាស់ថវិកាជាតិ ដោយគ្មានប្រសិទ្ធភាព ជុំវិញគម្រោងតែងតាំងមន្ត្រីឃុំ សង្កាត់ចាញ់ឆ្នោតរបស់គណបក្សប្រជាជនកម្ពុជា ជាជំនួយការ ឬទីប្រឹក្សាមន្ត្រីរដ្ឋាភិបាល**។ ការផ្សាយព័ត៌មាននេះ ជាការលើកឡើងក្នុងគោលបំណងបំភាន់ការពិត និងធ្វើឲ្យសាធារណមតិមានការយល់ច្រឡំមកលើរាជរដ្ឋាភិបាលដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា។

ពាក់ព័ន្ធនឹងការផ្សាយព័ត៌មានខាងលើនេះ អ្នកនាំពាក្យក្រសួងមហាផ្ទៃសូមធ្វើការបដិសេធទាំងស្រុង និងសូមធ្វើការគូសបញ្ជាក់ជូនសាធារណមតិជាតិ និងអន្តរជាតិ ដូចតទៅ៖

១-កន្លងមករាជរដ្ឋាភិបាលមានតែគោលការណ៍ក្នុងការរៀបចំតែងតាំងមុខតំណែងជាទីប្រឹក្សា ឬជំនួយការនៅតាមក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលចំពោះតែមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រងមួយចំនួន ដែលមិនបានឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ តែប៉ុណ្ណោះ។

២-ចំពោះការតែងតាំងមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រងដែលមិនឈរឈ្មោះជាបេក្ខជនក្រុមប្រឹក្សាឃុំ សង្កាត់ទៀតនោះ គឺសំដៅប្រើប្រាស់ធនធានមនុស្សដែលមានបទពិសោធន៍ និងសមត្ថភាពសម្រាប់ជួយការងារតាមក្រសួង ស្ថាប័នដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារនៅតាមអង្គភាព និងនៅថ្នាក់មូលដ្ឋាននីមួយៗ។

៣-រាជរដ្ឋាភិបាល ពុំមានគោលការណ៍ក្នុងការតែងតាំងមុខតំណែងបេក្ខជនដែលមិនបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ ឲ្យធ្វើជាទីប្រឹក្សា ឬជំនួយការនៅតាមក្រសួង ស្ថាប័ននានា ដូចជាការផ្សាយរបស់វិទ្យុអាស៊ីសេរី កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៧នោះឡើយ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ២០១៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
ខុទ្ទកាល័យសម្តេចក្រឡាហោម ស ខេង
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ភ្នំពេញ, ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៧

លេខ : ...

សេចក្តីប្រកាសព័ត៌មាន

ខុទ្ទកាល័យសម្តេចក្រឡាហោម មានកិត្តិយសសូមជម្រាបជូនសាធារណជនជ្រាបថា កាលពីថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០១៧ កន្លងទៅនេះ លោក គង់ គាំ ទីប្រឹក្សាជាន់ខ្ពស់គណបក្សសង្គ្រោះជាតិ នាឱកាសចុះធ្វើយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៤ នៅសង្កាត់អូរឫស្សី ក្រុងក្រចេះ ខេត្តក្រចេះ បាននិយាយទៅកាន់អ្នកគាំទ្ររបស់ខ្លួនថា «...បើសង្គ្រោះជាតិឈ្នះឆ្នោតឆ្នាំ២០១៨ ដឹកនាំរាជរដ្ឋាភិបាលធ្វើនាយករដ្ឋមន្ត្រី ទុក សម្តេចក្រឡាហោម ធ្វើឧបនាយករដ្ឋមន្ត្រីដដែល តែសង្គ្រោះជាតិធ្វើរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ...» ។

ពាក់ព័ន្ធនឹងការលើកឡើងនេះ ខុទ្ទកាល័យសម្តេចក្រឡាហោម សូមទាត់ចោលទាំងស្រុងនូវការផ្ដែផ្ដងតាមអារម្មណ៍ក្នុងការយល់សប្តិខាងលើនេះ និងសូមធ្វើការបញ្ជាក់ជូនដូចតទៅ៖

១.ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៤ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ២០១៧ ខាងមុខនេះ មិនមែនជាការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលនឹងត្រូវមានការរៀបចំជ្រើសតាំងសមាជិករាជរដ្ឋាភិបាលសម្រាប់អាណត្តិថ្មីនោះទេ ។ ការលើកឡើងដែលបង្កប់នូវគំនិតទុច្ចរិតរបស់លោក គង់ គាំ គឺជាការឃោសនាបោកប្រាស បន្លំយកឈ្មោះ **សម្តេចក្រឡាហោម ស ខេង** ទៅប្រើប្រាស់បង្កឲ្យមានការភ័ន្តច្រឡំ ក្នុងគោលបំណងកេងចំណេញនយោបាយដើម្បីទាក់ទាញសម្លេងឆ្នោតតែប៉ុណ្ណោះ ។

២.ការលើកឡើងរបស់លោក គង់ គាំ គឺជាការមាក់ងាយមកលើគណបក្សប្រជាជនកម្ពុជា ដែលជាគណបក្សនយោបាយដ៏ចាស់ទុំ ធ្លាប់បានរំដោះប្រទេសជាតិ និងបានរួមសុខរួមទុក្ខជាមួយប្រជាពលរដ្ឋនៅគ្រប់កាលៈទេសៈ ព្រមទាំងបានធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីជាតិ និងប្រជាជន ។

៣.សំដីរបស់លោក គង់ គាំ ក៏ជាការប្រមាថមាក់ងាយយ៉ាងធ្ងន់ធ្ងរមកលើកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ **សម្តេចក្រឡាហោម ស ខេង** ក្នុងនាមជាថ្នាក់ដឹកនាំជាន់ខ្ពស់មួយរូបរបស់រាជរដ្ឋាភិបាល និងគណបក្សប្រជាជនកម្ពុជា ដែលតែងទទួលបាននូវការគោរពស្រឡាញ់ពីសំណាក់មន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងប្រជាពលរដ្ឋទូទៅគ្រប់ស្រទាប់ក្នុងសង្គម ។

ខុទ្ទកាល័យសម្តេចក្រឡាហោម សូមបដិសេធយ៉ាងដាច់អហង្ការចំពោះសំដីមាក់ងាយរបស់លោក គង់ គាំ និងសូមអំពាវនាវដល់សាធារណជនកុំចាញ់បោកឧបាយកលដ៏ពិសពុល បម្រើឲ្យមហិច្ឆតាផ្ទាល់ខ្លួន និងផលប្រយោជន៍នយោបាយរបស់លោក គង់ គាំ និងគណបក្សសង្គ្រោះជាតិ ។ ខុទ្ទកាល័យសម្តេចក្រឡាហោម សូមគូសបញ្ជាក់ជូនសារជាថ្មីនូវជំហរបម្រើជាតិ សាសនា ព្រះមហាក្សត្រ ដោយឥតងាករេរបស់ **សម្តេចក្រឡាហោម ស ខេង** តាមរយៈគណបក្សប្រជាជនកម្ពុជា ដែលជាគណបក្សស្នូលធានាបាននូវការថែរក្សាសន្តិភាព ការបង្រួបបង្រួមជាតិ និងការអភិវឌ្ឍន៍ប្រទេស ទាំងក្នុងពេលបច្ចុប្បន្ន និងតទៅអនាគត ។

ខុទ្ទកាល័យសម្តេចក្រឡាហោម ស ខេង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ១០១៥ សដណ

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧

ជម្រាបមក
លោក គល់ បញ្ញា នាយកប្រតិបត្តិ
គណៈកម្មាធិការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា
(COMFREL)

កម្មវត្ថុ ៖ ករណីបន្ទប់ស្ថានការណ៍ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៧។

យោង ៖ - ព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- លិខិតលេខ ១១៨១ សដណ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៧ របស់ក្រសួងមហាផ្ទៃ ស្តីពីការសុំបង្កើតគណៈកម្មាធិការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា។

តបតាមកម្មវត្ថុ និងយោងខាងលើ ក្រសួងមហាផ្ទៃ សូមជម្រាបជូន លោកនាយកប្រតិបត្តិ នៃគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL) ថា ការបង្កើត **បន្ទប់ស្ថានការណ៍ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៧** ដោយមានការចូលរួមពីអង្គការ និងសមាគម ប្រមាណចំនួន៤០ ជាសមាជិក គឺអនុវត្តផ្ទុយទៅនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ ចំពោះសេចក្តីថ្លែងការណ៍របស់ **បន្ទប់ស្ថានការណ៍** មិនមានតម្លៃគតិយុត្ត និងមិនបានឆ្លុះបញ្ចាំងពីអព្យាក្រឹត្យភាព ដូចមានចែងក្នុង **មាត្រា ២៤** នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមគណៈកម្មាធិការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ត្រូវបញ្ឈប់សកម្មភាពខុសច្បាប់របស់បន្ទប់ស្ថានការណ៍ និងត្រូវអនុវត្តសកម្មភាពរបស់ខ្លួនឲ្យបានត្រឹមត្រូវ ស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

អាស្រ័យហេតុនេះ សូមលោកនាយកប្រតិបត្តិជ្រាប និងចាត់ចែងអនុវត្តឲ្យមានប្រសិទ្ធភាព។

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្តេចក្រឡាហោម ស ខេង

ចម្លងជូន:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងយុត្តិធម៌
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- សាលាដំបូងរាជធានីភ្នំពេញ
(ដើម្បីជ្រាប)
- ឯកសារ-កាលប្បវត្តិ

ទីស្តីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣
ទូរសារ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣ e-mail: moi@interior.gov.kh web: www.interior.gov.kh

Appendix5: COMFREL Statement
ឧបសម្ព័ន្ធ៥៖ សេចក្តីថ្លែងការណ៍របស់ខុមហ្វ្រែល

1. Press Statement on overall assessment on pre-election day situation

បន្ទប់ស្ថានការណ៍ស្តីពីការចោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧

Situation Room on Cambodian Commune Council Election in 2017

រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៧

សេចក្តីថ្លែងការណ៍
ស្តីអំពី
ការវាយតម្លៃលើស្ថានភាព មុនថ្ងៃបោះឆ្នោត
ជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៤

សមាគម និងអង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍ស្តីពីការបោះឆ្នោតឆ្នាំ២០១៧យល់ឃើញថា ការចាត់ចែងការបោះឆ្នោតជាបច្ចេកទេស ដោយ គ.ជ.ប មានចំណុចវិជ្ជមានច្រើន។ បរិយាកាសនយោបាយ និងសន្តិសុខ គឺស្ថិតនៅស្ថានភាពគ្មានអំពើហឹង្សាធ្ងន់ធ្ងរ ដែលធ្វើឲ្យប៉ះពាល់ជាអវិជ្ជមានដល់ការចាត់ចែងការបោះឆ្នោត សេរីភាពសិទ្ធិនយោបាយនៃគណបក្សប្រកួតប្រជែង សមាគម អង្គការសង្គមស៊ីវិល និងម្ចាស់ឆ្នោត។ យើងមានជំនឿថា នឹងមានសន្តិសុខ សុវត្ថិភាពសម្រាប់ដំណើរបោះឆ្នោត និងការប្រកាសលទ្ធផលបោះឆ្នោត។ ខាងក្រោមនេះ ជាការវាយតម្លៃលើចំណុចសំខាន់នៃស្ថានភាព និងដំណើរការចាត់ចែងមុនថ្ងៃបោះឆ្នោត៖

- **ក្រមខណ្ឌច្បាប់៖**
  មានចំណុចវិជ្ជមានខ្លះ និងអវិជ្ជមានខ្លះដែលទាក់ទិននឹងច្បាប់ ស្តីពីការបោះឆ្នោត និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ មានតែច្បាប់ ស្តីពីវិសោធកម្មគណបក្សនយោបាយមានចំណុចអវិជ្ជមានជាងមុន។
- **គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត៖**
  គ.ជ.ប ចាត់ចែងការងាររបស់ខ្លួនបានល្អប្រសើរជាងមុនដូចជា៖ ការជ្រើសរើស និងតែងតាំងមន្ត្រីបោះឆ្នោត ការបំពេញភារកិច្ច ការរៀបចំផែនការ និងវគ្គបណ្តុះបណ្តាល ការអនុវត្តន៍ច្បាប់ និងបទបញ្ជា និងនីតិវិធី។
- **បញ្ជីឈ្មោះបោះឆ្នោត៖**
  បញ្ជីឈ្មោះបោះឆ្នោតមានគុណភាព និងភាពត្រឹមត្រូវល្អប្រសើរជាងមុន។
- **ការចុះឈ្មោះបញ្ជីបេក្ខជនគណបក្សនយោបាយ៖**
  ការចុះឈ្មោះបញ្ជីបេក្ខជនគណបក្សនយោបាយ មានលក្ខណៈវិជ្ជមាន ព្រោះមានគណបក្សនយោបាយចំនួន១២ បានចុះបញ្ជីបេក្ខជន ដើម្បីឈរឈ្មោះប្រកួតប្រជែង។ ហើយគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិបានចុះបញ្ជីបេក្ខជនរបស់ខ្លួនគ្រប់ឃុំ/សង្កាត់។ បេក្ខជនស្ត្រីនៃគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ស្ថិតនៅលំដាប់លេខរៀងខ្ពស់នៃបញ្ជីបេក្ខជន។

- **ការឃោសនាបោះឆ្នោត**
  ការឃោសនាបោះឆ្នោតមានលក្ខណៈវិជ្ជមាន និងមានដំណើរយ៉ាងរលូន ដោយមិនមានហឹង្សា និងទំនាស់រវាងគណបក្សរហូតរារាំងដល់សកម្មភាពឃោសនាឡើយ ហើយមានការចូលរួមយ៉ាងសកម្មពីអ្នកគាំទ្រគណបក្សនយោបាយ។ប៉ុន្តែនៅមានការរឹតត្បិតពីអាជ្ញាធរ ក្នុងការប្រើប្រាស់ទីធ្លាសាធារណៈ និងសេរីភាពបញ្ចេញមតិ។ ទូរទស្សន៍ឯកជនមិនអនុវត្តតាមគោលការណ៍សមភាព និងសេចក្តីណែនាំរបស់ គ.ជ.ប។ គណបក្សនយោបាយមិនមានរបាយការណ៍ ឬព័ត៌មានច្បាស់លាស់អំពីប្រភពចំណាយ និងខ្ទង់ចំណាយក្នុងការរៀបចំសកម្មភាពឃោសនាបោះឆ្នោត។
- **ការត្រៀមរៀបចំការបោះឆ្នោត និងរាប់សន្លឹកឆ្នោត**
  ការត្រៀមរៀបចំការបោះឆ្នោត និងរាប់សន្លឹកឆ្នោតមានលក្ខណៈល្អប្រសើរច្រើនដូចជា ការចេញវិធានការ០៥ចំណុច ដើម្បីធានាអ្នកបោះឆ្នោតម្នាក់បោះឆ្នោតបានតែម្តង ដើម្បីទប់ស្កាត់ការបោះឆ្នោតលើសពីចំនួនម្តង(១) ការត្រៀមសំភារៈសម្រាប់ការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ការផ្តល់សុពលភាពដល់អ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយ ការបិទផ្សាយទម្រង់ ១១០២ នៅមុខការិយាល័យបោះឆ្នោត ស្នាក់ការ គយ.សប និងផ្សព្វផ្សាយនៅលើគេហទំព័រ គ.ជ.ប ។ ការបោះពុម្ពសន្លឹកឆ្នោតបំរុងទុកចំនួនប្រមាណ ២០% ដែលធ្វើឱ្យមានការព្រួយបារម្ភអំពីការគ្រប់គ្រងភាពមិនប្រក្រតី ដែលរកចកើតមានឡើង។
- **បរិយាកាសនយោបាយ**
  តាមការសង្កេតជាទូទៅ បរិយាកាសនយោបាយ និងសន្តិសុខមិនមានអំពើហឹង្សាធ្ងន់ធ្ងរ។ ប៉ុន្តែមានការប្រើប្រាស់សារនយោបាយរបស់មន្ត្រីរដ្ឋអំណាចជាន់ខ្ពស់មួយចំនួន ដែលនាំឲ្យមានការព្រួយបារម្ភ និងភ័យខ្លាចដល់ប្រជាពលរដ្ឋ។

សមាគម និងអង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍អំពាវនាវដល់គ្រប់គណបក្សនយោបាយ ដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតចូលរួមអនុវត្តតាមច្បាប់ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងទទួលយកលទ្ធផលនៃការបោះឆ្នោតនាពេលខាងមុខនេះ និងអំពាវនាវពលរដ្ឋជាម្ចាស់ឆ្នោតចេញទៅបោះឆ្នោតតាមឆន្ទៈរបស់ខ្លួន និងចូលរួមធ្វើជាសាក្សីនៃលទ្ធផលឆ្នោត ក្រោយពីសន្លឹកឆ្នោតត្រូវបានរាប់ និងប្រកាសលទ្ធនៅការិយាល័យបោះឆ្នោតនាថ្ងៃបោះឆ្នោត។

ទំនាក់ទំនងព័ត៌មាន៖

1.	លោក គល់ បញ្ញា	នាយកប្រតិបត្តិ COMFREL	០១២ ៩៤ ២០ ១៧
2.	លោក សំ គន្ធាមី	នាយកប្រតិបត្តិNICFEC	០១២ ៨២ ២២ ៧៣
3.	លោក យង់ គិមអេង	នាយកប្រតិបត្តិ PDP-Center	០១៦ ៨២ ៨២ ១១
4.	លោក ជាង សុខា	នាយកប្រតិបត្តិអង្គការ YRDP	០១២ ៣៦ ០៤ ៦៤
5.	លោក មឿន តុលា	នាយកប្រតិបត្តិ Central	០៩៣ ៥៥ ៦៦ ៤៣

2. Press Statement on overall assessment on election day

បន្ទប់ស្ថានការណ៍ស្តីពីការចោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧
Situation Room on Cambodian Commune Council Election in 2017

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៧

សេចក្តីថ្លែងការណ៍
ស្តីអំពី
ការវាយតម្លៃលើស្ថានភាព ថ្ងៃបោះឆ្នោត
ជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៤

អង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍ ស្តីពីការបោះឆ្នោតឆ្នាំ២០១៧ យល់ឃើញថា បរិយាកាសដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់អាណត្តិទី៤ នាថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៧ នៅការិយាល័យភាគច្រើន បានប្រព្រឹត្តទៅដោយរលូន សុវត្ថិភាព និងសន្តិវិធី ប៉ុន្តែយើងក៏បានរកឃើញថា មានភាពមិនប្រក្រតីបន្តិចបន្តួចក្នុងដំណើរការបោះឆ្នោតនេះផងដែរ ដូចជា៖ ការខ្វះខាតសំភារៈបោះឆ្នោតក្នុងការិយាល័យខ្លះ វត្តមានរបស់អាជ្ញាធរគ្មានភារកិច្ចក្នុងបរិវេណការិយាល័យបោះឆ្នោត ការហាមឃាត់អ្នកសង្កេតការណ៍ ឬត្អាកង់ងារគណបក្សនយោបាយចូលក្នុងការិយាល័យបោះឆ្នោត។ ជាក់ស្តែង អ្នកសង្កេតការណ៍បោះឆ្នោតប្រចាំឃុំ ព្រែកដាច់ និងឃុំព្រែកទន្លាប់ ស្រុកលើកដែក ខេត្តកណ្តាល បានរងការគំរាមកំហែងពីអាជ្ញាធរហួតដល់បោះបង់ការចូលរួមសង្កេតការណ៍បោះឆ្នោត។

អង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍ ស្តីពីការបោះឆ្នោតឆ្នាំ២០១៧ ក៏បានសង្កេតឃើញថា ប្រជាពលរដ្ឋចង់មើលដំណើរការរាប់សន្លឹកឆ្នោតនៅតាមការិយាល័យភាគច្រើន ប៉ុន្តែការអនុវត្តន៍បទបញ្ជា និងនីតិវិធីក្នុងដំណើរការរាប់សន្លឹកឆ្នោតដែលតម្រូវឲ្យប្រជាពលរដ្ឋចេញក្រៅទីតាំងការិយាល័យបោះឆ្នោត ធ្វើឲ្យប្រជាពលរដ្ឋមិនពេញចិត្ត។

ជារួម អង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍ ស្តីពីការបោះឆ្នោតឆ្នាំ២០១៧ សូមអបអរសាទរចំពោះការចេញទៅបោះឆ្នោតរបស់ប្រជាពលរដ្ឋច្រើនជាង៨០ភាគរយនៃប្រជាពលរដ្ឋក្នុងបញ្ជីឈ្មោះបោះឆ្នោតនាថ្ងៃនេះ។

ព័ត៌មានបន្ថែមសូមទាក់ទង៖

1.	លោក គល់ បញ្ញា	នាយកប្រតិបត្តិ COMFREL	០១២ ៩៤ ២០ ១៧
2.	លោក សំ គន្ធាមី	នាយកប្រតិបត្តិNICFEC	០១២ ៨២ ២២ ៧៣
3.	លោក យង់ គិមអេង	នាយកប្រតិបត្តិ PDP-Center	០១៦ ៨២ ៨២ ១១
4.	លោក មឿន តុលា	នាយកប្រតិបត្តិ Central	០៩៣ ៥៥ ៦៦ ៤៣
5.	លោក អ៊ិ សំអាត	អ្នកគ្រប់គ្រងបច្ចេកទេសស៊ើបអង្កេត LICADHO	០១២ ៣២ ៧៧ ៧០

Situation Room's members: COMFREL, NICFEC, ADHOC, LICADHO, CLEC, SILAKA, YRDP, KYSD, PDP-Center, CCFC, CENTRAL, STT, CCIM, CYN, BPO, GADC, CCC, NGO Forum, HRTF, DPA, KYA, FACT, WMC, YCUD, CIYA, YEDP, CYWEN, IDEA, CFSWF, PBO, NGO CEDAW, CVS, TIC, CGCN, YFP, CPN, ANSA-EAP, CCHR, CLC, CDPO.

3. Press Statement on situation assessment on counting process and announcement of electoral result note

បន្ទប់ស្ថានការណ៍ស្តីពីការចោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧

Situation Room on Cambodian Commune Council Election in 2017

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៧

សេចក្តីថ្លែងការណ៍ ស្តីអំពី
ការខាយតម្លៃលើស្ថានភាព ដំណើរការរាប់សន្លឹកឆ្នោត
និងប្រកាសកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត
នៃការចោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៤

អង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍ ស្តីពីការចោះឆ្នោតឆ្នាំ២០១៧ យល់ឃើញថា បរិយាកាសដំណើរការរាប់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់អាណត្តិទី៤ នាថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៧ នៅការិយាល័យភាគច្រើន បានប្រព្រឹត្តទៅស្របតាមនីតិវិធី។ រហូតមកដល់ពេលនេះ យើងសង្កេតឃើញថា មិនទាន់មានពាក្យបណ្តឹងទាក់ទងនឹងកំណត់ហេតុនៃការរាប់ឆ្នោត ប៉ុន្តែយើងក៏បានរកឃើញថា មានភាពមិនប្រក្រតីខ្លះក្នុងដំណើរការរាប់សន្លឹកឆ្នោត និងការប្រកាសកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតដូចជា៖ ការពន្យារពេលចាប់ផ្តើមដំណើររាប់សន្លឹកឆ្នោត ការមិនអនុញ្ញាតអ្នកសង្កេតការណ៍ចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោត ដំណើរការរាប់នៅទីងងឹត និងដោយបិទទ្វារ និងបង្ខូច ការអានប្រកាសសម្លេងឆ្នោត ឬបង្ហាញគំនុសគាំទ្រក្នុងដំណើររាប់សន្លឹកឆ្នោតមិនច្បាស់លាស់ ភាពមិនប្រក្រតីក្នុងការកំណត់សន្លឹកឆ្នោតបានការ ឬមិនបានការ ការបំពេញកំណត់ហេតុនៃការរាប់សន្លឹក ឆ្នោតមានកំហុស និងការមិនចែក ឬការបិទផ្សាយកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២)។

តាមរយៈរបាយការណ៍ដែលទទួលបានមកដល់ពេលនេះ បន្ទប់ស្ថានការណ៍ ស្តីពីការចោះឆ្នោត ឆ្នាំ២០១៧ វាយតម្លៃលើលទ្ធផលនៃការចោះឆ្នោតជាបឋមថា គណបក្សប្រជាជនកម្ពុជា ទទួលបាន ៤៨% និងគណបក្សសង្គ្រោះជាតិទទួលបាន ៤៥% នៃសម្លេងឆ្នោតបានការសរុប និងក្រៅពីនេះ ជាលទ្ធផលនៃគណបក្សផ្សេងៗទៀត។ យើងមានជំនឿចិត្តភាពត្រឹមត្រូវ ៩៥% ចំពោះការវាយតម្លៃនេះ ខណៈដែលកំរិតលំអៀងប្រមាណ+/-៥%។ យើងបាន និងកំពុងបន្តប្រមូលកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងឱកាសជំរឿងផ្ទាត់ជាមួយកំណត់ហេតុ ដែលចេញផ្សាយនៅក្នុងគេហទំព័រ របស់គ.ជ.ប។

ព័ត៌មានបន្ថែមសូមទាក់ទង៖

1.	លោក គល់ បញ្ញា	នាយកប្រតិបត្តិ COMFREL	០១២ ៩៤ ២០ ១៧
2.	លោក សំ គន្ធាមី	នាយកប្រតិបត្តិNICFEC	០១២ ៨២ ២២ ៧៣
3.	លោក យង់ គីមអេង	នាយកប្រតិបត្តិ PDP-Center	០១៦ ៨២ ៨២ ១១
4.	លោក មឿន តុលា	នាយកប្រតិបត្តិ Central	០៩៣ ៥៥ ៦៦ ៨៣
5.	លោក អ៊ិ សំអាត	អ្នកគ្រប់គ្រងបច្ចេកទេសស៊ើបអង្កេត LICADHO	០១២ ៣២ ៧៧ ៧០

Situation Room's members: COMFREL, NICFEC, ADHOC, LICADHO, CLEC, SILAKA, YRDP, KYSD, PDP-Center, CCFC, CENTRAL, STT, CCIM, CYN, BPO, GADC, CCC, NGO Forum, HRTF, DPA, KYA, FACT, WMC, YCUD, CIYA, YEDP, CYWEN, IDEA, CFSWF, PBO, NGO CEDAW, CVS, TIC, CGCN, YFP, CPN, ANSA-EAP, CCHR, CLC, CDPO.

4. Press Statement on assessment on preliminary electoral result

បន្ទប់ស្ថានការណ៍ស្តីពីការចោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧
Situation Room on Cambodian Commune Council Election in 2017

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧

សេចក្តីថ្លែងការណ៍
ស្តីអំពី
ការទាយតម្លៃចំពោះលទ្ធផលបោះឆ្នោតបឋម នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៤

សមាគម អង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍ ស្តីពីការបោះឆ្នោតឆ្នាំ២០១៧ រកឃើញថា ការផ្ទៀងផ្ទាត់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោតនៃ លទ្ធផលបោះឆ្នោតបឋមនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់អាណត្តិទី៤ គឺមានភាព ត្រឹមត្រឹមដូចគ្នា ៩៣,១% នៃលទ្ធផលនៃការរាប់សន្លឹកឆ្នោតសម្រាប់គណបក្សនយោបាយនីមួយៗ[1] បើទោះបីមានកំហុសខ្លះ គ.ជ.ប អាចត្រួតពិនិត្យ និងកែតម្រូវ។ ភាពមិនប្រក្រតី និងភាពខុសគ្នានៃកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត(១១០២) មិនប៉ះពាល់ លទ្ធផលបោះឆ្នោតនៅតាមឃុំ/សង្កាត់ឡើយ។

សមាគម អង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍ ស្តីពីការបោះឆ្នោតឆ្នាំ២០១៧ ស្នើឲ្យ គ.ជ.ប ខិតខំក្នុងការដោះស្រាយបណ្តឹងរបស់គណបក្សនយោបាយទាក់ទងនឹងការរាប់សន្លឹកឆ្នោតឡើងវិញ ពិសេសដោយសារកម្រិតលំអៀងសម្លេងឆ្នោតតិចពេកដែលមិនលើសពី០,៥% ហើយមានបញ្ហានៃសន្លឹកឆ្នោតមិនបានការមានចំនួនច្រើន ដែលអាចឲ្យគូភាគីអស់ចិត្ត និងទទួលយកលទ្ធផលបោះឆ្នោតតាមឃុំសង្កាត់ទាំងនោះ។

សមាគម អង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍ ស្តីពីការបោះឆ្នោតឆ្នាំ២០១៧ យល់ឃើញថា នេះជាលើកទីមួយ គឺស្ថិតក្នុងស្ថានភាពវិជ្ជមាន ដែលគណបក្សប្រកួតប្រជែងសំខាន់ៗបានខិតខំប្រមូលទិន្នន័យ ហើយបានរកឃើញលទ្ធផលបោះឆ្នោតបឋមរបស់ខ្លួន។ បើទោះមានបណ្តឹងតិចតួចទាក់ទងនឹងលទ្ធផលបោះឆ្នោត គណបក្សប្រកួតប្រជែងសំខាន់មិនមានសេចក្តីថ្លែងការណ៍បដិសេធលទ្ធផលនៃការបោះឆ្នោតទេ។

សមាគម និងអង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍ ស្តីពីការបោះឆ្នោតឆ្នាំ២០១៧ ជាដំបូងសូមកោតសរសើរជាខ្លាំងដល់អ្នកសង្កេតការណ៍របស់ខ្លួនទាំងអស់ដែលបានចូលរួមសង្កេតការណ៍បោះឆ្នោត គ្រប់ដំណាក់នៃដំណើរការបោះឆ្នោតដូចជាការឃោសនាបោះឆ្នោត ថ្ងៃបោះឆ្នោតជាដើម និងដែលបានបញ្ជូន និងផ្ទៀងផ្ទាត់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោតក្នុងស្មារតី ទទួលខុសត្រូវ និងអត់ធ្មត់។

សមាគម និងអង្គការសង្គមស៊ីវិល នៃបន្ទប់ស្ថានការណ៍ ស្តីពីការបោះឆ្នោតឆ្នាំ២០១៧ សូមអរគុណដល់ម្ចាស់ជំនួយ រួមទាំងអ្នកបានផ្តល់ថវិកាសប្បុរសធម៌ឧបត្ថម្ភដល់កិច្চការងារអ្នកសង្កេតការណ៍។

[1] ចំណុចទី៤ នៃកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (១១០២)

សមាគម និងអង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍ ស្តីពីការបោះឆ្នោតឆ្នាំ២០១៧ សូមវាយតម្លៃខ្ពស់ចំពោះការផ្តល់កិច្ចសហការរបស់ គ.ជ.ប ជាមួយអង្គការសមាគមនៃបន្ទប់ស្ថានការណ៍ ក្នុងការជួបប្រាស្រ័យទំនាក់ទំនង និងការសម្រួលកិច្ចការជាច្រើនក្នុងបុព្វហេតុតម្លាភាព សុចរិតភាព និងភាពត្រឹមត្រូវនៃការបោះឆ្នោត។

សមាគម និងអង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍ ស្តីពីការបោះឆ្នោតឆ្នាំ២០១៧ ក៏សូមកោតសរសើរចំពោះនគរបាល និងកងម្លាំងរក្សាសន្តិសុខសម្រាប់ការបោះឆ្នោត ដែលបានខិតខំរក្សាសុវត្ថិភាព និងសន្តិសុខក្នុងសម័យបោះឆ្នោត។

សមាគម និងអង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍ ស្តីពីការបោះឆ្នោតឆ្នាំ២០១៧ សូមវាយតម្លៃខ្ពស់ចំពោះស្ថានទូត អង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានា ដែលដាក់អ្នកសង្កេតការណ៍អន្តរជាតិ ហើយបានផ្តល់កិច្ចសហការ និងផ្តល់ភាពកក់ក្តៅដល់អ្នកបោះឆ្នោត និងអ្នកសង្កេតការណ៍ជាតិ ។

សមាគម និងអង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍ ស្តីពីការបោះឆ្នោតឆ្នាំ២០១៧ សូមអបអរសាទរជាថ្មីម្តងទៀតចំពោះម្ចាស់ឆ្នោតទាំងអស់ ដែលបានចូលរួមសកម្ម និងអត់ធ្មត់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់កាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៧ ដែលជាដំណើរការប្រជាធិបតេយ្យនៅកម្ពុជា។

ព័ត៌មានបន្ថែមសូមទាក់ទង៖

1.	លោកស្រី ធីតា ឃឹះ	នាយិកាប្រតិបត្តិ SILAKA	០១២ ៨៣ ៨៤ ៦៤
2.	លោក គល់ បញ្ញា	នាយកប្រតិបត្តិ COMFREL	០១២ ៩៤ ២០ ១៧
3.	លោក សំ គន្ធាមី	នាយកប្រតិបត្តិ NICFEC	០១២ ៨២ ២២ ៧៣
4.	លោក យង់ គិមអេង	នាយកប្រតិបត្តិ PDP-Center	០១៦ ៨២ ៨២ ១១
5.	លោក មឿន តុលា	នាយកប្រតិបត្តិ Central	០៩៣ ៥៥ ៦៦ ៤៣
6.	លោក អ៊ំ សំអាត	អ្នកគ្រប់គ្រងបច្ចេកទេសស៊ើបអង្កេត LICADHO	០១២ ៣២ ៧៧ ៧០

5. Press Statement on verification on preliminary electoral result

បន្ទប់ស្ថានការណ៍ស្តីពីការចោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧

Situation Room on Cambodian Commune Council Election in 2017

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧

របាយការណ៍សង្ខេប
ស្តីអំពី
ការផ្ទៀងផ្ទាត់លើលទ្ធផលបោះឆ្នោតបឋម
នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៤

សមាគម អង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍ ស្តីពីការបោះឆ្នោតឆ្នាំ២០១៧ បានធ្វើការផ្ទៀងផ្ទាត់ទិន្នន័យ និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (១១០២) ដែលផ្សាយក្នុងគេហទំព័ររបស់ គ.ជ.ប ក្រោយពេលបោះឆ្នោត ជាមួយនឹងកំណត់នៃការរាប់សន្លឹកឆ្នោត (១១០២) ដែលប្រមូលបានដោយបន្ទប់ស្ថានការណ៍។ កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (១១០២) ដែលប្រមូលបានដោយបន្ទប់ស្ថានការណ៍ចំនួន ៤៨១ការិយាល័យបោះឆ្នោតដែលជាការិយាល័យសំណាក ក្នុងកំរិតជឿជាក់ ៩៥% ជាមួយកំរិតលំអៀង ៤.៣% ត្រូវបានជ្រើសរើសដោយចៃដន្យ(Sample Random) និងយកមកផ្ទៀងផ្ទាត់ ហើយរកឃើញ ចំណុចមួយចំនួនដូចខាងក្រោម៖

១. បើទោះបីជា គ.ជ.ប បានចេញផ្សាយចំនួន០២លើក អំពីអត្រានៃចំនួនបណ្តោះអាសន្ននៃអ្នកបានទៅបោះឆ្នោត លើកទី១ នៅថ្ងៃទី០៤ ខែមិថុនា ២០១៧ គឺមានចំនួន ៨៥,៧៤% (ស្មើប្រមាណ ៦,៧លាននាក់) និងលើកទី២ នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ ២០១៧ គឺមានចំនួន ៨៩,៥២% (ស្មើប្រមាណ ៧លាននាក់)។ ការផ្ទៀងផ្ទាត់ទិន្នន័យដែលប្រមូលបានដោយបន្ទប់ស្ថានការណ៍រកឃើញថា អត្រានៃចំនួននៃអ្នកបោះឆ្នោតបានទៅបោះឆ្នោតមានចំនួន ៨៩,៩% នៃប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតនៃការិយាល័យសំណាក។

២. ការសង្កេត និងការផ្ទៀងផ្ទាត់របស់បន្ទប់ស្ថានការណ៍ រកឃើញទំហំ «សន្លឹកឆ្នោតមិនបានការ» នៅក្នុងដំណើរការរាប់សន្លឹកឆ្នោតមានចំនួន ១,៨% នៃសន្លឹកឆ្នោតដែលមានក្នុងហិបសរុប។ ការកំណត់សន្លឹកឆ្នោតមិនបានការ អាចក្លាយជាភាពមិនប្រក្រតី ដូចជាករណីខ្លះ ការកំណត់សន្លឹកឆ្នោតមិនបានការមានចំនួនច្រើនពេក ហើយមិនស្របតាមការំណែនាំរបស់ គ.ជ.ប ដូចជានៅការិយាល័យ<u>០០១៦ ឃុំសាមប្លួយ</u> ខេត្តស្ទឹងត្រែង ឃុំភ្នំលៀប ខេត្តបន្ទាយមានជ័យ ឃុំឬស្សីស្រុក ខេត្តសៀមរាប និងកន្លែងផ្សេងទៀត។ ករណីនេះរាចប៉ះពាល់លទ្ធផលបោះឆ្នោតបឋប ដែលនាំឱ្យហានបណ្តឹងនៃរាប់សន្លឹកឆ្នោតឡើងវិញ ចំនួន២៨នៅ៤៧ការិយាល័យតាមសេចក្តីប្រកាសព័ត៌មានរបស់ គ.ជ.ប នៅថ្ងៃទី០៦ ខែមិថុនា។

៣. ការផ្ទៀងផ្ទាត់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត(១១០២)៖

៣.១. ការផ្ទៀងផ្ទាត់ទិន្នន័យនៃកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (១១០២) ប្រមូលដោយបន្ទប់ស្ថានការណ៍ ជាមួយនឹងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (១១០២) ដែលបានផ្សាយក្នុងគេហទំព័ររបស់ គ.ជ.ប មានភាពត្រឹមត្រូវដូចគ្នានឹងកំណត់ហេតុដែលប្រមូលដោយបន្ទប់ស្ថានការណ៍មានចំនួន ៨៨,១% នៃទម្រង់ការិយាល័យសំណាក(ខុសគ្នា ១១.៩%)។ ទោះជាយ៉ាងណា លទ្ធផលនៃការរាប់សន្លឹកឆ្នោតសម្រាប់គណបក្សនយោបាយនិមួយៗតាមការិយាល័យ

រាប់សន្លឹកឆ្នោត[1] ខុសគ្នាចំនួន ៦,៩% (ចំនួន ៩៣,១% ដូចគ្នា) ដែលទាក់ទិនការបំពេញសន្លឹកឆ្នោតបានការ ឬមិនបានការ ហើយខ្លះទៀតបូកលេខខុសតែម្តងដោយសារតែភាពធ្វេសប្រហែស[2]។ រីឯលទ្ធផលនៃការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោត តាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត[3] រកឃើញថា ៩៣,៦% ដូចគ្នា (៦,៤% រកឃើញថាមានតួលេខខុសគ្នា)។ ការខុសគ្នាអាចកើតឡើងដោយការធ្វេសប្រហែស ឬការមិនយល់ក្នុងការគណនា និងកត់ត្រា (វាអាចបណ្តាលមកពីមន្ត្រីចម្លងច្រើនសន្លឹក និងមិនប្រើក្រដាសកាល់)[4]។ សាក្សីដែលជាភ្នាក់ងារគណបក្សនយោបាយ រកឃើញថា ១,៧% ខុសគ្នាត្រង់សាក្សីនៃភ្នាក់ងារទម្រង់ខ្លះមិនចុះហត្ថលេខា[5]។

៣.២. ការផ្ទៀងផ្ទាត់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (១១០២) ដែលមានភាពមិនប្រក្រតី ប្រមូលដោយអ្នកសង្កេតការណ៍បន្ទប់ស្ថានការណ៍ ជាមួយនឹងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (១១០២) ដែលផ្សាយក្នុងគេហទំព័ររបស់ គ.ជ.ប រកឃើញថា ក្នុងចំណោម ៣០ទំរង់ ទ.១១០២ មានតែមួយទំរង់ទេ ដែលមានភាពមិនប្រក្រតីដូចគ្នា ហើយ ២៩ទំរង់ទៀតរបស់ គ.ជ.ប គឺមានភាពត្រឹមត្រូវ[6]។ ភាពមិនប្រក្រតីទាំងនោះ មានដូចជាៈ ការបិទប្រកាសដោយមិនបានកត់ត្រាសំឡេងឆ្នោតរបស់គណបក្សនយោបាយ នៅការិយាល័យ <u>០១៥៥ ខេត្តរតនៈគីរី</u> ការសរសេរឈ្មោះបេក្ខជនក្នុងសំឡេងគណបក្សនយោបាយ (<u>ការិ.០៤៩៥ នៅខេត្តកំពង់ចាម</u>) ការមិនបំពេញឈ្មោះគណបក្សនយោបាយ(<u>ការិ.០០៦៣ ខេត្តកំពង់ឆ្នាំង</u>) ការមិនបំពេញតួលេខឱ្យបានត្រឹមត្រូវក្នុងចំណុចសន្លឹកឆ្នោតបានការ និងមិនបានការ ចំនួនសន្លឹកឆ្នោតសរុបមិនស្មើគ្នា មានតួលេខលើស និងខ្វះ ឬច្រឡំកន្លែងដែលត្រូវចុះរវាងសន្លឹកឆ្នោតខូច ជាមួយសន្លឹកឆ្នោតមិនបានការ កន្លែងខ្លះមានប្រើទឹកលុប ការគូសសញ្ញាបញ្ជាក់លើចំណុចផ្សេងៗជាដើម។

៤. ការផ្ទៀងផ្ទាត់លើលទ្ធផលបឋមនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (១១០៥)

លទ្ធផលបោះឆ្នោតបឋមនៅតាមឃុំសង្កាត់ ដែលបានមកពីការបូកសំឡេងឆ្នោតរបស់គណបក្សនៃកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (១១០២) ដែលប្រមូលដោយបន្ទប់ស្ថានការ ហើយយកទៅផ្ទៀងផ្ទាត់ជាមួយកំណត់ហេតុ ១១០៥ របស់គ.ជ.ប ចំនួន៣០ឃុំ រកឃើញថា មានមួយករណីនៅឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ក្នុងការិយាល័យ ០៣០៤ មានសន្លឹកឆ្នោតរបស់គណបក្សនយោបាយខុសគ្នារវាង <u>គ.ជ.ប</u> និងក្នុងកំណត់ហេតុលទ្ធផលឆ្នោត(១១០២) ដែលបានប្រមូលដោយ<u>បន្ទប់ស្ថានការណ៍</u> នៃលទ្ធផលបឋមនៃការបោះឆ្នោតក្នុងឃុំ សង្កាត់[7] ។ បើទោះបីមានកំហុសខ្លះ នៃលទ្ធផលបឋមដែលកំពុងត្រួតពិនិត្យ គ.ជ.ប អាចមានលទ្ធភាពកែតម្រូវភ្លាមៗ។ ការសង្កេតរកឃើញថាលទ្ធផលបឋម(កំពុងត្រួតពិនិត្យ)យ៉ាងហោចខុសពីរឃុំ បើផ្ទៀងផ្ទាត់កំណត់ហេតុ ទ.១១០២ និង ១១០៥។

៥. បញ្ហាផ្សេងៗៈ

៥.១. ការមិនបិទផ្សាយការប្រកាសកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (១១០២) នៅតាមគណៈកម្មការឃុំ/សង្កាត់រៀបចំការបោះឆ្នោតជាច្រើនឃុំ/សង្កាត់ ដូចជាៈ ខេត្តត្បូងឃ្មុំ ឃុំជីរោទិ១ ក្នុងទីតាំងការិយាល័យ បឋមសិក្សាហ៊ុនសែនរកាធំ ០៩៩០ ០៩៩៥ ០៩៨៩ ខេត្តបាត់ដំបង សង្កាត់ព្រែកព្រះស្តេច ខេត្តបន្ទាយមានជ័យ ឃុំបន្ទាយឆ្មារ ការិយាល័យ

1 ចំណុចទី៤ នៃកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (១១០២)

2 រកឃើញតែមួយករណី (ទ.១១០២ខុសប្រែប្រួល) ខ្វះសំឡេងគណបក្សហ្វ៊ុនស៊ិនប៉ិច នៅក្នុងការិយាល័យ ០៨៨៥ខេត្តកំពង់ចាម។

3 ចំណុចទី២ នៃកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (១១០២)

4 ដូចជាការិយាល័យ ០៣៧០ និង១២៧១ ក្នុងខេត្តកំពង់ចាម និងការិយាល័យផ្សេងទៀត។

5 ដូចជាការិយាល័យ ០៦៥៣ ខេត្តកំពង់ឆ្នាំង ការិយាល័យ ០៨៦០ ខេត្តតាកែវជាដើម។

6 ទម្រង់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត(ទ.១១០២)ចំនួន៣០ ដូចគ្នាតែ១ជាមួយ គ.ជ.ប

7 ចំណុចទី៤ នៃលទ្ធផលបឋមនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (១១០៥)

០៧៧៦(សូម្បីគណបក្សនយោបាយក៏មិនចែកឱ្យគេដែរ) ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង និងខេត្តរតនគីរី អត់មានបិទនៅ គយ.សប ស្ទើគ្រប់ទីកន្លែង ដោយប្រធាន គយ.សប ថាមិនមានការណែនាំ ឬមិនតម្រូវឱ្យបិទ ទោះបីចែងនៅក្នុងចំណុច ១០.៤.៣.១ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ប.ន.ឃ.ស) ក៏ដោយ។

៥.២. ការប្រកាសលទ្ធផលបោះឆ្នោតបឋមដោយ គ.ជ.ប យឺតជាងការគ្រោងទុក។ ការផ្សាយលទ្ធផលបោះឆ្នោតបឋមតាម រយៈទូរទស្សន៍ជាតិកម្ពុជា (ទទក) ពិបាកយល់ និងមិនបានពេញលេញ។ ការផ្សាយលទ្ធផលបោះឆ្នោតបឋមបានតែ ចំនួន៦១៦ឃុំ/សង្កាត់ ហើយមិនត្រូវបានផ្សាយបន្តទៀត ចាប់ពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧។

៥.៣. បណ្តឹងទាក់ទងការរាប់សន្លឹកឆ្នោតឡើងវិញមានចំនួន២៨បណ្តឹង ដោយសារភាពតឹងតែងនៃសំឡេងឆ្នោតរបស់គណបក្សពីរមានចំនួនតិចតួច ប៉ុន្តែសន្លឹកឆ្នោតមិនបានការនៃការិយាល័យនោះមានចំនួនច្រើនជាងសំឡេងលំអៀងនោះ។ ការរាប់សន្លឹកឆ្នោតឡើងវិញបានធ្វើឲ្យប្រែប្រួលលទ្ធផលបឋមនៃការបោះឆ្នោតនៃឃុំ សង្កាត់ចំនួនបួន។

សេចក្តីសន្និដ្ឋាន កំណត់ហេតុ នៃការរាប់សន្លឹកឆ្នោត (១១០២) ដែលប្រមូលដោយបន្ទប់ស្ថានការ និងផ្សាយដោយ គ.ជ.ប ត្រឹមត្រូវដូចគ្នា ៩៣,១%នៃលទ្ធផលនៃការរាប់សន្លឹកឆ្នោតសម្រាប់គណបក្សនយោបាយ[8] និង ៩៣,៦% នៃលទ្ធផលនៃការផ្គៀងផ្ទាត់ចំនួនសន្លឹកឆ្នោត[9]។ ការខុសគ្នា និងភាពមិនប្រក្រតីនៃកំណត់ហេតុ១១០២ មិនអាចនាំឲ្យមានការសង្ស័យប៉ះពាល់លទ្ធផលបោះឆ្នោតបឋមនោះទេ។

ព័ត៌មានបន្ថែមសូមទាក់ទង៖

1. លោក គល់ បញ្ញា	នាយកប្រតិបត្តិ COMFREL	០១២ ៩៤ ២០ ១៧
2. លោក កន សាវង្ស	អ្នកសម្របសម្រួលផ្នែកអង្កេត COMFREL	០១១ ៨៨ ៤៨ ៤០
3. លោក យឿង សុធារ៉ា	មន្ត្រីច្បាប់ និងអង្កេត COMFREL	០៧០ ៤០ ០១ ៣១

[8] ចំណុចទី៤ នៃកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (១១០២)

[9] ចំណុចទី២ នៃកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (១១០២)

6. Press Statement on overall and ultimate assessment on election

បន្ទប់ស្ថានការណ៍ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧

Situation Room on Cambodian Commune Council Election in 2017

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៧

សេចក្តីថ្លែងការណ៍
ស្តីអំពី
ការវាយតម្លៃទាំងមូល និងចុងក្រោយលើការបោះឆ្នោត
ជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់អាណត្តិទី៤
« ខ្វះយុត្តិធម៌ និងរឹតត្បិតសេរីភាព ប៉ុន្តែការចាត់ចែងនៃការបោះឆ្នោតប្រសើរជាងមុន»

បន្ទប់ស្ថានការណ៍សម្រាប់ការបោះឆ្នោតឆ្នាំ២០១៧ វាយតម្លៃថា ការចាត់ចែង និងការអនុវត្តន៍ភារកិច្ចរបស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប)លើបញ្ជីឈ្មោះបោះឆ្នោត ការចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីបេក្ខជនគណបក្សនយោបាយ ការបោះ និងការរាប់សន្លឹកឆ្នោត និងការប្រកាសបិទ និងដាក់ផ្សាយលើគេបាទំព័រអ្នវបេក្ខជនបោះឆ្នោតថា «វិជ្ជមាន និងប្រសើរជាងមុន» ទាក់ទិនតម្លាភាព បើទោះបីជា ការឃោសនាបោះឆ្នោត និងការដោះស្រាយបណ្តឹងបោះឆ្នោត មិនទាន់ប្រសើរដែលត្រូវកែលម្អ។ គ្មានអំពើហឹង្សាទាក់ទិនបោះឆ្នោតធ្ងន់ធ្ងរ ក្នុងសម័យបោះឆ្នោតបានកើតឡើងទេ ប៉ុន្តែមានបញ្ហាមួយចំនួនកើតមុនថ្ងៃបោះឆ្នោតដូចជា៖ បរិយាកាសដែលមានការគាបសង្កត់ខាងនយោបាយ ហិរញ្ញវត្ថុឃោសនាបោះឆ្នោត និងការប្រើប្រាស់ធនធានរដ្ឋ ដែលខ្វះសមធម៌ និងតម្លាភាព ទីលានប្រកួតប្រជែងនយោបាយ(Level of playing field) ដែលខ្វះសមភាព និងបទបញ្ញត្តិបដិវាទ(Controversial) ខ្លះនៃក្របខ័ណ្ឌច្បាប់បោះឆ្នោត និងច្បាប់ ស្តីពីវិសោធនកម្មនៃច្បាប់គណបក្សនយោបាយ និងការខ្វះឯករាជ្យរបស់មន្ត្រីតុលាការ និងការលំអៀងនយោបាយនៃមន្ត្រីជាន់ខ្ពស់កងកម្លាំងប្រដាប់អាវុធ ដែលដាក់សម្ពាធដល់សេរីភាពបញ្ចេញមតិ និងគំរាមដល់ សកម្មភាពគណបក្ស ប្រកួតប្រជែង និងសមាគម សហជីព និងអង្គការសមាគមមិនមែនរដ្ឋាភិបាល។ ទាំងនេះ នាំឲ្យបរិយាកាសសម្រាប់ដំណើរការបោះឆ្នោតស្ថិតនៅក្នុងកំរិតរឹតត្បិតសេរីភាព និងខ្វះយុត្តិធម៌ពេញលេញនៅឡើយ។

សម្រាប់ការបោះឆ្នោតខាងមុខ ជាពិសេសការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៨ បន្ទប់ស្ថានការណ៍ស្នើយោបល់ និងអនុសាសន៍ ដើម្បីឲ្យការបោះឆ្នោតដោយសេរី និងយុត្តិធម៌ដូចខាងក្រោម៖

១. ដកបញ្ញត្តិបដិវាទនៃក្របខ័ណ្ឌច្បាប់បោះឆ្នោត ច្បាប់ ស្តីពីវិសោធនកម្មច្បាប់គណបក្សនយោបាយ ដែលអាចត្រូវបានបកស្រាយមិនច្បាស់លាស់ ក្នុងការលុបបេក្ខភាពឈរឈ្មោះរបស់គណបក្សប្រកួតប្រជែង និងការរំលាយគណបក្សនយោបាយ។

២. ដោះលែងអ្នកជាប់ឃុំទាំងឡាយ ទាក់ទិននយោបាយ មនសិការ និងការពារសិទ្ធិមនុស្ស ដើម្បីឲ្យពួកគេបានចូលរួមជីវភាពនយោបាយ និងដំណើរការបោះឆ្នោត។

៣. ពង្រឹងគោលការណ៍សមធម៌ និងតម្លាភាពនៃហិរញ្ញវត្ថុឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ និងការប្រើប្រាស់ធនធានរដ្ឋសម្រាប់សកម្មភាពនយោបាយ។

Situation Room's members: COMFREL, NICFEC, ADHOC, LICADHO, CLEC, SILAKA, YRDP, KYSD, PDP-Center, CCFC, CENTRAL, STT, CCIM, CYN, BPO, GADC, CCC, NGO Forum, HRTF, DPA, KYA, FACT, WMC, YCUD, CIYA, YEDP, CYWEN, IDEA, CFSWF, PBO, NGO CEDAW, CVS, TIC, CGCN, YFP, CPN, ANSA-EAP, CCHR, CLC, CDPO.

៤. ជំរុញស្ថានីយ៍ទូរទស្សន៍ឯកជន ឲ្យគោរពក្រមសីលធម៌ វិជ្ជាជីវៈ និងគោលការណ៍ណែនាំរបស់ គ.ជ.ប នៅក្នុងសម័យយោសនាការបោះឆ្នោត។

៥. ពង្រឹងអព្យាក្រឹត្យ ឥតលម្អៀងខាងនយោបាយនៃបន្ត្រីកងកម្លាំងប្រដាប់អាវុធ និងបន្ត្រីតុលាការ ដែលហានចែងនៅ ក្នុងក្របសីលធម៌ ច្បាប់ បទបញ្ជា និងសេចក្តីណែនាំផ្សេងៗ។

៦. ពង្រឹងការផ្តល់កិច្ចសហប្រតិបត្តិការរបស់អាជ្ញាធរជាមួយ គ.ជ.ប តែបន្ថយការជ្រៀតជ្រែក និងឥទ្ធិពលលំអៀង នយោបាយទៅលើដំណើរការបោះឆ្នោត ពិសេសយុទ្ធនាការឃោសនា និងនៅថ្ងៃបោះឆ្នោតដែលច្បាប់បោះឆ្នោត បទបញ្ជា និងសេចក្តីណែនាំផ្សេងៗបានកំណត់។

៧. បង្កើតគោលនយោបាយ បុរេន្តការ និងរកមធ្យោបាយ ដើម្បីធានាការអនុវត្តន៍សិទ្ធិចុះឈ្មោះបោះឆ្នោត និងសិទ្ធិបោះឆ្នោតរបស់ពលករចំណាកស្រុកទាំងនៅក្នុងប្រទេស និងនៅក្រៅប្រទេស។

៨. ពង្រឹងនីតិវិធីនៃការពិនិត្យ និងការធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំនូវបញ្ជីបោះឆ្នោត និងលេខការិយាល័យបោះឆ្នោតឲ្យមានតម្លាភាព ដោយពង្រឹងការត្រួតពិនិត្យរបស់បន្ត្រី គ.ជ.ប ទៅលើរាជ្ជាធរមូលដ្ឋាន និងក្រុមប្រឹក្សាឃុំសង្កាត់។

៩. ពង្រឹងការដោះស្រាយបណ្តឹងនៃការរាប់សន្លឹកឆ្នោតឡើងវិញ នៅឃុំ/សង្កាត់ណាដែលមានការលំអៀងសម្លេងឆ្នោតយ៉ាងច្រើន ០.៥ភាគរយ(០.៥%) រវាងបញ្ជីបេក្ខជនពីរ ឬច្រើន នៅពេលរកឃើញថា សន្លឹកឆ្នោតមិនបានការច្រើន ព្រោះថា សន្លឹកឆ្នោតមិនបានការច្រើន អាចចាត់ទុកជាទឡ្ហីករណ៍នៃភាពមិនប្រក្រតី។ ត្រូវបង្កើតការពិភាក្សាជាមួយភាគីពាក់ព័ន្ធការបោះឆ្នោត និងគណបក្សនយោបាយប្រកួតប្រជែង អំពីការកំណត់សន្លឹកឆ្នោតមិនបានការឲ្យបានលំអិត និងច្បាស់លាស់។

១០. បន្ថយចំនួនសន្លឹកឆ្នោតបម្រុងនៅត្រឹម៥% (យ៉ាងច្រើន) នៃប្រជាពលរដ្ឋដែលបានចុះឈ្មោះបោះឆ្នោត ដែលត្រូវបោះពុម្ព។

១១. ពង្រឹងតម្លាភាពនៃការរាប់សន្លឹកឆ្នោត ដោយមិនត្រូវឲ្យមានការបិទបង្គួច និងទ្វារនៃការិយាល័យរាប់សន្លឹកឆ្នោត។

១២. ពង្រឹងការអនុវត្តន៍សេចក្តីណែនាំ អំពីការរាប់សន្លឹកឆ្នោតទប់ស្កាត់មន្ត្រីការិយាល័យ ទាមទារភ្នាក់ងារគណបក្សនយោបាយចុះហត្ថលេខាលើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត១១០២ជាមុន នៅពេលបិនទាន់បានបញ្ចប់ការរាប់សន្លឹកឆ្នោត និងពង្រឹងការយកចិត្តទុកដាក់នៃការសសេរលទ្ធផល នៃការផ្ទៀងផ្ទាត់សន្លឹកឆ្នោតឲ្យបានត្រឹមត្រូវក្នុងទម្រង់១១០២ និងការបិទផ្សាយទម្រង់ ១១០២ និងទម្រង់១១០៥ នៅតាមការិយាល័យគណៈកម្មការឃុំ/សង្កាត់រៀបចំការបោះឆ្នោត។

១៣. ជំរុញការចេញអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងសំបុត្រកំណើត ឲ្យអ្នកមានសិទ្ធិបោះឆ្នោតបានគ្រប់គ្នា១០០ភាគរយ។

១៤. បង្កើតយន្តការរួម ដើម្បីចែករំលែកព័ត៌មាន ជួយអន្តរាគមន៍ និងកែតម្រូវករណីភាពមិនប្រក្រតី ការអនុវត្តន៍ខុសក្រមសីលធម៌ និងទំនាស់បោះឆ្នោតដែលមានសមាសភាពពីសមាជិកគ.ជ.ប មន្ត្រីគ.ជ.ប មន្ត្រីនៃគណៈអចិន្ត្រៃយ៍សន្តិសុខបោះ បោះឆ្នោត មន្ត្រីនៃគណបក្សចុះឈ្មោះប្រកួតប្រជែងក្នុងការបោះឆ្នោត និងតំណាងអង្គការសមាគម មិនមែនរដ្ឋាភិបាលសង្កេតការណ៍បោះឆ្នោត។ យន្តការរួមនេះ គួរតែត្រូវបង្កើតនៅកំរិតថ្នាក់ជាតិ និងថ្នាក់ខេត្តក្រោមការដឹកនាំរបស់សមាជិក គ.ជ.ប។

១៥. ដាក់ចេញនូវវិធានការពិសេសបណ្តោះអាសន្ន ដែលតម្រូវឱ្យគណបក្សនយោបាយទាំងអស់ បង្កើនចំនួនបេក្ខជនជាស្ត្រី និងបង្កើនចំនួនស្ត្រីជាបេក្ខជននៅជួរមុខ ។

សូមភ្ជាប់មកជាមួយនូវតារាងវាយតម្លៃលើកត្តា/ស្ថានភាពក្នុងដំណើរការបោះឆ្នោត៖

កត្តាវាយតម្លៃ	ការវាយតម្លៃ			
	ល្អមាន	ល្អមានផ្នែកខ្លះ	អរល្អមានផ្នែកខ្លះ	អរល្អមាន
១- ក្របខ័ណ្ឌច្បាប់ចោះឆ្នោត ១.១ ការបង្កើត ឬរៀបចំការចោះឆ្នោតដោយសេរី ១.២ សិទ្ធិចោះឆ្នោត និងឈរឈ្មោះចោះឆ្នោត		√	√	
២. ច្បាប់ ស្តីពីវិសោធនកម្មច្បាប់គណបក្សនយោបាយ ២.១ សិទ្ធិគណបក្សប្រឆាំង ឬគណបក្សប្រកួតប្រជែង			√	
៣. ព្រំប្រទល់មណ្ឌល និងការបែងចែកអាសនៈ ៣.១ របបពហុបក្ស និងភាពស្មើភាពគ្នានៃគណបក្សប្រឆាំង ឬគណបក្សមិនកាន់អំណាចដទៃ និងគណបក្សកាន់អំណាច		√		
៤. គណៈកម្មាធិការជាតិរៀបចំការចោះឆ្នោត(ឯករាជ្យ អព្យាក្រឹត្យ តម្លាភាព ផ្ទៃជីវៈ) ៤.១ ការជ្រើសរើស ឬការតែងតាំង ៤.២ តួនាទី/ការអនុវត្តន៍ ៤.៣ ផែនការ/ការបណ្តុះបណ្តាល ៤.៤ ការគាំទ្រធនធាន ៤.៥ ការអនុវត្តន៍ដោយប្រសិទ្ធភាព ៤.៦ ការរៀបចំកិច្ចសហប្រតិបត្តិការផ្នែកសន្តិសុខ		√	√	
៥. ការចុះឈ្មោះ និងបញ្ជីឈ្មោះចោះឆ្នោត ៥.១ ភាគរយអ្នកបានចុះឈ្មោះ ប្រៀបធៀបចំនួនអ្នកមានសិទ្ធិចុះឈ្មោះចោះឆ្នោត ៥.២ ភាពត្រឹមត្រូវ/គុណភាព ៥.៣ សវនកម្ម និងការកែតម្រូវ		√		
៦. ការចុះបញ្ជីគណបក្ស និងបេក្ខជនរបស់គណបក្ស ៦.១ លក្ខខណ្ឌច្បាស់លាស់ និងសមហេតុផល ៦.២ ការរើសអើង (គណបក្សប្រឆាំង ឯករាជ្យភាព សមភាពយេនឌ័រ ជំនឿសាសនា និងពូជសាសន៍)		√		
៧. យុទ្ធនាការឃោសនាចោះឆ្នោត ៧.១ សមភាពនៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ៧.២ ភាពស្មើភាពគ្នានៃការប្រើសប្រាស់ធនធានរដ្ឋទីផ្លាសាធារណៈ/ អាគារ ៧.៣ តម្លាភាពនៃការចំណាយការឃោសនា ៧.៤ សេរីភាពបញ្ចេញមតិ ការជួបជុំ និងប្រមូលផ្តុំ		√	√	

៨. ដំណើរការបោះ និងរាប់សន្លឹកឆ្នោត និងថ្ងៃបោះឆ្នោត ៨.១ ភាពសម្ងាត់នៃការបោះឆ្នោត ៨.២ ការរៀបចំបោះឆ្នោត និងរាប់សន្លឹកឆ្នោត ស្របតាមនីតិវិធី ៨.៣ វត្តមានអ្នកសង្កេតការណ៍បោះឆ្នោត និងភ្នាក់ងារគណបក្សនយោបាយ ៨.៤ ការបោះពុម្ព រៀបចំ ដឹកជញ្ជូន និងរក្សាទុកសន្លឹកឆ្នោត ឲ្យមានប្រសិទ្ធភាព និងតម្លាភាព ៨.៥ សិទ្ធិបោះឆ្នោត ជនជាតិភាគតិច ជនងាយរងគ្រោះ និងជនពិការ ៨.៦ បង្ហាញលទ្ធផលបោះឆ្នោត តាមពេលវេលាដែលបានកំណត់ត្រឹមត្រូវ ដោយមិនមានការពន្យារពេលដោយមូលហេតុណាមួយឡើយ ៨.៧ បរិយាសន្តិភាពដើម្បីឲ្យអ្នកបោះឆ្នោតសំដែងឆន្ទៈដោយសេរី		√		
៩. ការដោះស្រាយទំនាស់បោះឆ្នោត (ឯករាជ្យភាព មិនលំអៀង តម្លាភាព ទាន់ពេលវេលា) ៩.១ មានព័ត៌មានគ្រប់គ្រាន់អំពីនីតិវិធីបណ្តឹងបោះឆ្នោត ៩.២ ការទទួលពាក្យបណ្តឹង ៩.៣ ការស៊ើបអង្កេតលើពាក្យបណ្តឹង ៩.៤ សវនការសាធារណៈ ៩.៥ ការចេញសេចក្តីសម្រេចដែលសមហេតុផល និងមានការពន្យល់		√	√	

អង្គការគាំទ្រ និងទំនាក់ទំនងព័ត៌មានបន្ថែម៖

1.	លោក គល់ បញ្ញា	នាយកប្រតិបត្តិ COMFREL	០១២ ៩៤ ២០ ១៧
2.	លោក សំ គន្ធាមី	នាយកប្រតិបត្តិ NICFEC	០១២ ៨២ ២២ ៧៣
3.	លោកស្រី ធីតា ឃីះ	នាយិកាប្រតិបត្តិ SILAKA	០១២ ៨៣ ៨៤ ៦៤
4.	លោក យង់ គិមអេង	នាយកប្រតិបត្តិ PDP-Center	០១៦ ៨២ ៨២ ១១
5.	លោក ជាង សុខា	នាយកប្រតិបត្តិអង្គការ YRDP	០១២ ៣៦ ០៤ ៦៤
6.	លោក មឿន តុលា	នាយកប្រតិបត្តិ Central	០៩៣ ៥៥ ៦៦ ៤៣
7.	លោក ថាវ គឹមសាន	នាយកប្រតិបត្តិ LICADHO	០១២ ៨០ ៧៧ ៦៣
8.	លោក ថេង សាវឿន	អគ្គលេខាធិការ CCFC	០៧៨ ២២ ៥០ ៨៨
9.	លោក ឡាយ សុវត្ថារ៉ា	អ្នកគ្រប់គ្រងកម្មវិធី CLEC	០១២ ៨០ ៣៨ ២៧
10.	លោក ប៉ា ងួនទៀង	នាយកប្រតិបត្តិ CCIM	០៦០ ៤០ ៩៩ ៩៩
11.	លោក សៅ កុសល	ប្រធានកម្មវិធីបច្ចេកទេស STT	០១៧ ៥៥ ៥៨ ៨៧
12.	លោក ទឹម ម៉ាឡៃ	ប្រធាន CYN	០១៧ ៩៩ ០៦ ៩០
13.	លោកស្រី រស់សុភាព	នាយិកាប្រតិបត្តិ GADC	០១២ ៦២ ៧៨ ៥៧
14.	លោកស្រី ចក់ សុភាព	នាយិកាប្រតិបត្តិ CCHR	០១១ ៩៨៣ ២១៣

15. លោកស្រី ម៉ី សម្ផស្ស	អគ្គលេខាធិការ YCUD	០៨១ ៣២ ៤៦ ៩១
16. លោក ស ម៉ូរ៉ា	ប្រធានសហព័ន្ធ CFSWF	០១៦ ៥២ ៥៧ ៨១
17. លោក សៀ ភារម្យ	នាយកប្រតិបត្តិ HRTF	០១២ ៨៥ ២៣ ២៥
18. លោក ឡុង ខែត	នាយកប្រតិបត្តិ FYP	០១២ ៤០ ២៨ ៨០
19. លោក ប៉ែន សុមុនី	ប្រធាន CVS	០១២ ៧០ ៨០ ៩៣
20. លោក សឿង សារឿន	នាយកប្រតិបត្តិ CCC	០១៦ ៩០ ០៥ ០៣
21. លោក វ៉ន់ ពៅ	ប្រធានសមាគម IDEA	០៩៣ ៦២ ៩២ ៩៨
22. លោក ស៊ឹង សែនករុណា	មន្ត្រីស៊ើបអង្កេតជាន់ខ្ពស់ ADHOC	០៨៩ ៦៦ ៦៣ ១២
23. លោក ឱម សាវ៉ាត	នាយកប្រតិបត្តិ FACT	០១២ ៨៥ ៨៤ ២០
24. លោក អ៊ឹម សុធី	នាយកប្រតិបត្តិ YCC	០៧៧ ៧២ ៣២ ៦៧
25. លោក ហេង សុជាតិ	ទីប្រឹក្សាបច្ចេកទេស CGCN	០១២ ៣៩ ០២ ២៩
26. លោក សន ជ័យ	អ្នកសម្របសម្រួល ANSA	០១២ ៤៤ ៥៦ ៤២
27. លោក ជិន សៅរ៉ែត្ន	នាយកប្រតិបត្តិ CDPO	០១៦ ៨៥ ១៨ ៤១
28. លោក អាត់ ធន់	ប្រធាន C.CAWDU	០១២ ៩៩ ៨៩ ០៦
29. លោកស្រី ជឹម ចាន់នាង	អគ្គលេខាធិការ NGO CEDAW	០១២ ៦៦ ៨៨ ៥៣

7. Press Statement on objectives and missions of the Situation Room for the 2017 election

សេចក្តីប្រកាសព័ត៌មាន
ស្តីពី
សកម្មភាព និងគោលបំណង «អ្វីទៅជាបន្ទប់ស្ថានការណ៍?»

ភ្នំពេញ, ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧

សូមជំរាបជូនជាព័ត៌មានថា «បន្ទប់ស្ថានការណ៍» គឺជាវេទិកាអព្យាក្រឹត្យឥតលំអៀង ដែលរៀបចំ និងចាត់ចែងដោយគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ហៅកាត់ថា «ខុមហ្វ្រែល» និងគណៈកម្មាធិការអព្យាក្រឹត្យ និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា ហៅកាត់ថា«និកហ្វិច» ដែលមានការចូលរួមដោយស្ម័គ្រចិត្តពីអង្គការ និងសមាគម ចំនួន៤០ ទៀត ក្នុងគោលបំណងសម្របសម្រួល និងសហការរួមគ្នាដើម្បី៖

- ប្រមូលផ្តុំធនធាន ដើម្បីបង្កើនសមត្ថភាព និងការរួមចំណែកសហការជាមូលនិធិ ឬគាំទ្រ ដើម្បីដំណើរការផែនការជាក់ពង្រាយអ្នកសង្កេតការណ៍ក្នុងស្រុកនៅថ្ងៃបោះឆ្នោត
- ចែករំលែក និងធ្វើបច្ចុប្បន្នភាពព័ត៌មាន ទាក់ទងការបោះឆ្នោត
- ធ្វើការវាយតម្លៃ និងផ្សារភ្ជាប់លទ្ធផលនៃការបោះឆ្នោត ដោយផ្អែកលើបទដ្ឋានច្បាប់ជាតិ និងអន្តរជាតិក្នុងអំឡុងពេលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧។

ខុមហ្វ្រែល និងនិកហ្វិច បានជាក់ពង្រាយអ្នកសង្កេតការណ៍ដែលមានការទទួលស្គាល់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)។

ក្រោយពីការបោះឆ្នោតត្រូវបានបញ្ចប់រួចរាល់ សកម្មភាពវេទិកាបន្ទប់ស្ថានការណ៍ក៏ត្រូវបានប្រកាសបញ្ចប់នៅក្នុងថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧ ក្នុងវេទិកាសាធារណៈ ស្តីពីការវាយតំលៃចុងក្រោយលើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ នៅស្នាក់ការកណ្តាលខុមហ្វ្រែល នៅចំពោះមុខអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ។

ព័ត៌មានបន្ថែមសូមទាក់ទង៖

១. លោក គឹម ឈន	អ្នកសម្របសម្រួលជាន់ខ្ពស់នៃកម្មវិធីខុមហ្វ្រែល	០១២ ៩៨២ ០១៩
២. លោក សំ គន្ធាមី	នាយកប្រតិបត្តិអង្គការនិកហ្វិច	០១២ ៨២២ ២៧៣

8. Press Statement on rejection of implication of COMFREL's election observation to revolutionary activities

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧

សេចក្តីប្រកាសព័ត៌មាន ស្តីអំពី
ការបដិសេធចំពោះការផ្សារភ្ជាប់សកម្មភាពសង្កេតការណ៍បោះឆ្នោត
របស់ខុមហ្វ្រែលជាមួយ«បដិវត្តន៍ពណ៌»

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) សូមបដិសេធទាំងស្រុង ចំពោះការផ្សារភ្ជាប់សកម្មភាពសង្កេតការណ៍បោះឆ្នោតខ្លះរបស់ខុមហ្វ្រែល ជាមួយការបកស្រាយមិនច្បាស់លាស់នៃសកម្មភាពបដិវត្តន៍ពណ៌ តាមរយៈខ្លឹមសារនៃវីដេអូរបស់អង្គភាពព័ត៌មាន និងប្រតិកម្មរហ័សនៃទីស្តីការគណៈរដ្ឋមន្ត្រី ដែលបានចេញផ្សាយកាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៧ មានចំណងជើងថា «តើកម្ពុជាពិតជាកើតមានបដិវត្តន៍ តាមគំរូបដិវត្តន៍នៅតាមបណ្តាប្រទេសនៅក្នុងពិភពលោកមែនឬទេ?» ។

ខ្លឹមសារវីដេអូ បានលើកឡើងសកម្មភាពសង្កេតការណ៍បោះឆ្នោតរបស់ខុមហ្វ្រែលបម្រើ ឬជាអង្គការសម្ព័ន្ធមិត្តរបស់គណបក្សនយោបាយមួយ ដែលបានយកឧទាហរណ៍នៃការបង្ហាញអំពីការរកឃើញពីការសង្កេតការណ៍បោះឆ្នោតអំពីភាពមិនប្រក្រតី និងការវាយតម្លៃនៃការបោះឆ្នោត។ ខុមហ្វ្រែលមិនអាចទទួលយក និងសម្តែងការខកចិត្តចំពោះការផ្សព្វផ្សាយអំពី ការផ្សារភ្ជាប់ជាមួយសកម្មភាពបែបនយោបាយនេះទេ ហើយខុមហ្វ្រែលសូមបញ្ជាក់សារជាថ្មីថា ខុមហ្វ្រែលជាអង្គការសង្គមស៊ីវិលមិនមែនរដ្ឋាភិបាល មិនទទួលឥទ្ធិពល និងបម្រើគណបក្សនយោបាយណាមួយឡើយ។ សកម្មភាពសង្កេតការបោះឆ្នោតរបស់ខុមហ្វ្រែល តាំងពីការបោះឆ្នោតឆ្នាំ១៩៩៨ ត្រូវបានទទួលស្គាល់ផ្លូវការដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)។ ការសង្កេតគឺ ដើម្បីចូលរួមចំណែកក្នុងការពង្រឹងជំនឿលើសុចរិតភាពទៅលើការចាត់ចែង និងការប្រើប្រាស់សំភារៈបោះឆ្នោតដែរ។ ឧទាហរណ៍ជាក់ស្តែង គឺការចូលរួមសាកល្បងរបស់ខុមហ្វ្រែលនៅទីស្តីការ គ.ជ.ប នូវទឹកខ្មៅជ្រលក់ម្រាមដៃសម្រាប់ការបោះឆ្នោត ថាតើលុបលាងជ្រះ ឬអត់នោះ ដែលមានការអញ្ជើញជាផ្លូវការពី គ.ជ.ប នៅក្នុងការបោះឆ្នោត និងមានអ្នកសារព័ត៌មានជាតិ និងអន្តរជាតិបានចូលរួមយកជាព័ត៌មាន និងធ្វើជាសាក្សីផងដែរ។ នៅការបោះឆ្នោតឆ្នាំ២០១៣ ខុមហ្វ្រែលបង្ហាញពីការរកឃើញនូវហានិភ័យនៃការលុបលាងច្រាសទឹកខ្មៅជ្រលក់ម្រាមដៃ និងភាពមិនប្រក្រតីនៃបញ្ជីឈ្មោះបោះឆ្នោតនិងផ្តល់អនុសាសន៍ ទៅគ.ជ.ប ដើម្បីរកវិធានការទប់ស្កាត់បានីភ័យ។ សម្រាប់ការបោះឆ្នោតឆ្នាំ២០១៧ នេះ គ.ជ.បថ្មីបានទទួលស្គាល់នូវការប្រឈមនៃទឹកខ្មៅជ្រលក់ម្រាមដៃដែលអាចលុបលាងជ្រះ ហើយក៏បានចេញវិធានការជ្រាំចំណុចឆ្លើយតបនឹងការប្រឈមនេះ ដើម្បីធានានូវសម្លេងឆ្នោតមួយពីម្ចាស់ឆ្នោតម្នាក់។ ខុម ហ្វ្រែលអនុវត្តត្រឹមត្រូវនូវសិទ្ធិស្របច្បាប់របស់ខ្លួនក្នុងការធ្វើរបាយការណ៍អំពីការរំលោភច្បាប់ បទបញ្ជា នីតិវិធី និងភាពមិនប្រក្រតីបោះឆ្នោត យោងតាមក្រមសីលធម៌អ្នកសង្កេតការណ៍ ចេញដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ទោះបីយ៉ាងនេះក្តី ខុមហ្វ្រែលក៏ធ្វើរបាយការណ៍ការសង្កេត និងវាយតម្លៃដើម្បីរក

ចំណុចវិជ្ជមាន ឬ/និងអវិជ្ជមាន និងផ្តល់អនុសាសន៍នានាដើម្បីនៃដំណើរការបោះឆ្នោតសេរី និងយុត្តិធម៌ ដែលប្រើវិធីសាស្ត្រ និងស្រតាមនិយាមជាតិ និងអន្តរជាតិ[1] យ៉ាងច្បាស់លាស់ ដោយមិនឆ្លុះបញ្ចាំងពីទស្សនៈ ឬបម្រើឲ្យគណបក្សនយោបាយណាមួយឡើយ។ ក្រៅពីនេះ ខុមហ្វ្រែលក៏បានសហការណ៍ជាមួយ គ.ជ.ប ដើម្បីអប់រំ និងផ្តល់ព័ត៌មានបោះឆ្នោតផងដែរ។

ខុមហ្វ្រែលស្នើសុំឲ្យរង្គភាពព័ត៌ហាន និងប្រតិកម្មរហ័សនៃទីស្តីការគណៈរដ្ឋមន្ត្រីចេត្តាបញ្ឈប់ការផ្សាភ្ជាប់សកម្មភាពស្របច្បាប់នៅក្នុងការសង្កេតការណ៍បោះឆ្នោតរបស់ខុមហ្វ្រែលថា ជាសកម្មភាពបដិវត្តពណ៌តទៅទៀត។

ខុមហ្វ្រែលមានមោទនភាពចំពោះការបំពេញតួនាទី និងការអនុវត្តសិទ្ធិស្របច្បាប់របស់ខ្លួនដើម្បីពង្រឹងការទុកចិត្ត និងការចូលរួមរបស់ម្ចាស់ឆ្នោតក្នុងដំណើរការបោះឆ្នោត ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

០១១ ៨៨៤ ៨៤០/ ០១១ ៥៣ ៥៣ ៥៤/ ០៧០ ៤០០ ១៣១/ ០១២ ៩៤២ ០១៧

[1] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីប្រកាសជាសកលរបស់អង្គការសហប្រជាជាតិ ស្តីអំពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីអំពីកម្ពុជា ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគ.ជ.ប ច្បាប់បោះឆ្នោត សេចក្តីប្រកាស ស្តីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅទីក្រុងបាងកក សេចក្តីថ្លែងការណ៍នៃការបោះឆ្នោតដោយសេរី និងយុត្តិធម៌របស់សហភាពអន្តរសភា(IPU) សន្ធស្សនៃការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅទីក្រុងឌីលី ប្រទេសទីម័រខាងកើត សេចក្តីថ្លែងការណ៍ជាសកលសម្រាប់អ្នកសង្កេតការណ៍ជាតិ (DOGP) និងក្រមសីលធម៌របស់អ្នកសង្កេតការណ៍។

9. Press Statement on Strengthening national and international legitimacy of election following democratic principle and respect of voters' will

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៧

សេចក្តីថ្លែងការណ៍ ស្តីអំពី ពង្រឹងភាពត្រឹមត្រូវតាមច្បាប់ជាតិ និងអន្តរជាតិ(Legitimacy) នៃដំណើរការបោះឆ្នោតបែបប្រជាធិបតេយ្យសេរី និងយុត្តិធម៌ និងការគោរពសម្លេងឆន្ទៈរបស់ម្ចាស់ឆ្នោត

សមាគម អង្គការសង្គមស៊ីវិលមិនមែនរដ្ឋាភិបាលនៅកម្ពុជាដូចមានឈ្មោះខាងក្រោមនេះ មានការព្រួយបារម្ភខ្លាំង ចំពោះការប្តឹងដើម្បីរំលាយគណបក្សសង្គ្រោះជាតិជាគណបក្សប្រជែង និងចំពោះការអនុម័តដោយតំណាងរាស្ត្រតែឯកបក្សនៃគណបក្សដឹកនាំរដ្ឋាភិបាល លើការកែប្រែរូបមន្តថ្មីនៃការបែងចែកអាសនៈតំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាឃុំសង្កាត់នៃគណបក្សត្រូវរំលាយ ដែលមានចែងក្នុងសេចក្តីស្នើវិសោធនកម្មច្បាប់ដោយតំណាងរាស្ត្រមកពីគណបក្សដឹកនាំរដ្ឋាភិបាលគណបក្សប្រជាជនកម្ពុជា។ សមាគម អង្គការសង្គមស៊ីវិលមិនមែនរដ្ឋាភិបាលយល់ឃើញថា ជាយថាហេតុការរំលាយគណបក្សប្រជែងនេះ រហូតមិនអាចចូលរួមប្រកួតការបោះឆ្នោតនឹងនាំឲ្យមានបញ្ហានៃភាពត្រឹមត្រូវតាមច្បាប់ជាតិ និងអន្តរជាតិនៃការបោះឆ្នោតឆ្នាំ២០១៨ខាងមុខនេះ។ ម្យ៉ាងទៀត ការអនុវត្តន៍រូបមន្តថ្មីដើម្បីបែងចែងអាសនៈនេះ នឹងធ្វើឲ្យប៉ះពាល់ជាអវិជ្ជមាន និងអយុត្តិធម៌ធ្ងន់ធ្ងរចំពោះសម្លេងម្ចាស់ឆ្នោត តំណាងឆន្ទៈម្ចាស់ឆ្នោតដែលមិនឆ្លុះបញ្ចាំងសមាមាត្រសន្លឹកឆ្នោតនៃភាពជាតំណាងរាស្ត្រ។

ករណីការរំលាយ និងការបែងចែកអាសនៈនៃគណបក្សសង្គ្រោះជាតិបែបនេះ គឺមិនគោរពសម្លេងឆន្ទៈប្រជាពលរដ្ឋប្រមាណ ០៣លាននាក់ដែលបានបោះឆ្នោតគាំទ្រគណបក្សនេះ។ ក្នុងរដ្ឋធម្មនុញ្ញជំពូក៤ ប្រជាពលរដ្ឋជាម្ចាស់វាសនានៃប្រទេសខ្លួន និងអំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ រាជរដ្ឋាភិបាលកម្ពុជាអនុវត្តនយោបាយបង្រួបបង្រួមជាតិ ដើម្បីការពារឯកភាពជាតិ។ ច្បាប់សិទ្ធិមនុស្សអន្តរជាតិ សេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក៏បញ្ជាក់ថា ឆន្ទៈរបស់ប្រជាពលរដ្ឋត្រូវសម្តែងចេញតាមរយៈការបោះឆ្នោត ហើយឆន្ទៈរបស់ប្រជាពលរដ្ឋជាមូលដ្ឋាននៃអំណាច។

ការរំលាយគណបក្ស នាំមកនូវការរំលាយតំណាងរាស្ត្ររបស់ម្ចាស់ឆ្នោត ដែលរដ្ឋធម្មនុញ្ញកម្ពុជាមាត្រា៧៧ បានហាមអនុវត្ត ឬទុកជាមោឃៈនូវអាណត្តិអាជ្ញាបញ្ជាទាំងឡាយចំពោះតំណាងរាស្ត្រ។ ម្យ៉ាងទៀត មាត្រា៧៦នៃរដ្ឋធម្មនុញ្ញបញ្ជាក់ថា តំណាងរាស្ត្រត្រូវបានជ្រើសតាំងដោយការបោះឆ្នោត។ នោះនាំឲ្យកើតមានចំណោទបញ្ហានៃភាពត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ដែលតំណាងរាស្ត្រនៃគណបក្សគ្មានអាសនៈក្នុងសភា ត្រូវបានជ្រើសតាំងចេញពីការរំលាយនៃគណបក្សដែលបានអាសនៈសភាទៅវិញ។

ការកែប្រែច្បាប់ទាក់ទិននឹងការបោះឆ្នោតបែបប្រជាធិបតេយ្យ សេរីពហុបក្ស តម្លាភាព និងសុចរិតភាព ត្រូវមានការចូលរួមពិភាក្សាជាមួយគណបក្សនយោបាយនានា និងការអនុម័ត យ៉ាងហោចពីគណបក្សដឹកនាំរដ្ឋាភិបាល និងគណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមដឹកនាំរដ្ឋាភិបាល ដូចមានចែងក្នុងជំពូក៥នៃរដ្ឋធម្មនុញ្ញ និង

ការអនុវត្តន៍កន្លងមក។ សមាគម អង្គការសង្គមស៊ីវិលមិនមែនរដ្ឋាភិបាលនៅកម្ពុជានឹងជួបការលំបាកក្នុងការសង្កេតការណ៍ និងការវាយតម្លៃថា ការបោះឆ្នោតមានភាពត្រឹមត្រូវតាមច្បាប់ ដោយសេរី និងយុត្តិធម៌មួយ ដែលគ្មានការចូលរួមរបស់គណបក្សប្រជែងសំខាន់ ដោយសារការរំលាយជាមួយនឹងការចោទប្រកាន់មេដឹកនាំរបស់គណបក្សបែបនេះ។

ការរំលាយគណបក្សប្រកួតប្រជែងការបោះឆ្នោត និងការអនុវត្តន៍នៃការបែងចែងអាសនៈតាមរូបមន្តថ្មីនៃការធ្វើវិសោធនកម្មច្បាប់នឹងនាំឲ្យបាត់បង់ការប្រកួតប្រជែងការបោះឆ្នោត ដោយភាពត្រឹមត្រូវតាមច្បាប់ជាតិ និងអន្តរជាតិ និងយុត្តិធម៌ ហើយក៏នឹងនាំឲ្យធ្លាក់ចុះខ្លាំងនៃដំណើរការប្រជាធិបតេយ្យជាមួយគុណភាពហុបក្ស នៅកម្ពុជា។

សមាគម និងអង្គការសង្គមស៊ីវិលគាំទ្រសេចក្តីថ្លែងការណ៍៖

1. គណៈកម្មាធិការ ដើម្បីការបោះឆ្នោត ដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)
2. គណៈកម្មការអព្យាក្រឹត្យ និងយុត្តិធម៌ ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា (NICFEC)
3. សមាគមធាងឆ្នោត (STT)
4. សម្ព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF)
5. កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)
6. បណ្តាញកសាងសន្តិភាពសហគមន៍ (CPN)
7. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL)
8. មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (PDP)
9. អង្គការស្ម័គ្រចិត្តដើម្បីសង្គម (CVS)
10. សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC)
11. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)
12. ក្រុមការងារពិសេសសិទ្ធិលំនៅឋាន (HRTF)

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

០១៦ ៨២ ៨២ ១១/០១២ ៨២ ២២ ៧/០៩៣ ៥៥៦ ៦៨៣/០១១ ៥៣ ៥៣ ៥៤/០៧០ ៤០០ ១៣១

Appendix6: Activities on the 2017 Elections Commune Sangkat
ឧបសម្ព័ន្ធទី៦៖ កំរងរូបភាពសកម្មភាពការងារសម្រាប់ការបោះឆ្នោតឆ្នាំ២០១៧

សកម្មភាពទី១៖ សកម្មភាពជួបជាមួយគណបក្សនយោបាយទាំង១២ របស់ក្រុមអង្គការសង្គមស៊ីវិល ដើម្បីស្វែងយល់ពីស្ថានភាពក្នុងការចូលរួមការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១៧

ជួបជាមួយគណបក្សខ្មែររួបរួមជាតិ (Meeting with Khmer National United Party)

ជួបជាមួយគណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ (Meeting with Republican Democratic Party)

ជួបជាមួយគណបក្សប្រជាធិបតេយ្យមូលដ្ឋាន (Meeting with Grassroots Democratic Party)

ជួបជាមួយគណបក្សអំណាចខ្មែរ (Meeting with Khmer Power Party)

សកម្មភាពទី២៖ ជួបជាមួយស្ថាប័ន គ ប.ជ.

Activity2: Meeting with NEC

កិច្ចពិភាក្សារវាងសង្គមស៊ីវិល និងស្ថាប័ន គ.ជ.ប ស្តីពីកិច្ចសហប្តិបត្តិការរវាងស្ថាប័នទាំងពីរ

Meeting between NGOs and NEC on Cooperation activities of the 2017 Commune/Sangkat Elections

សកម្មភាពចូលរួមសាកល្បងទឹកខ្មៅលុបលាងមិនជ្រះ រៀបចំដោយ គ.ជ.ប

Join testing Indelible ink at NEC

សកម្មភាពទី៣៖ សន្និសិទសារព័ត៌មាន

Activity3: Press Conferences

សន្និសិទសារព័ត៌មាននៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ ស្តីពីការបង្ហាញលទ្ធផលទាក់ទងការចុះឈ្មោះបោះឆ្នោត និងបញ្ជីឈ្មោះបោះឆ្នោត

17 Jan, 2017, Press conference at the COMFREL office, on the findings and recommendations of voter registration monitoring

សន្និសិទសារព័ត៌មាននៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧ នៅសណ្ឋាគារសាន់វ៉ៃ បង្ហាញពីផែនការសកម្មភាពរបស់ក្រុមអង្គការសង្គមស៊ីវិលចូលរួមសង្កេតការណ៍បោះឆ្នោតឃុំ សង្កាត់ឆ្នាំ២០១៧

28 March, 2017, Press conference at Sunway Hotel, on a Launch of Situation Room for a CSOs' joint observation on the 2017 Commune/Sangkat Election

សន្និសិទសារព័ត៌មាននៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៧ បង្ហាញពីលទ្ធផលចុះឈ្មោះបោះឆ្នោត និងបញ្ជីឈ្មោះបោះឆ្នោតថ្មីឆ្នាំ២០១៦ សម្រាប់ការបោះឆ្នោតឃុំ សង្កាត់ឆ្នាំ២០១៧

Press Conference on 05 April 2017 at COMFREL Head Office, on Finding of the 2016 Voter Registration and Voter List for the 2017 Commune Election

ការចូលរួមវាយតម្លៃដំណើរការបោះឆ្នោតរបស់អង្គការសង្គមស៊ីវិល សម្រាប់ការបោះឆ្នោតឆ្នាំ២០១៧

CSOs' Assessment on the 2017 Election Process



សន្និសិទសារព័ត៌មាននៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៧ បង្ហាញពីលទ្ធផលសង្កេតការយោសនាបោះឆ្នោត

Press Conference on 02 June 2017 at COMFREL Head Office, on Finding of Electoral Campaign

សន្និសិទសារព័ត៌មាននៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៧ បង្ហាញពីស្ថានភាពក្នុងថ្ងៃបោះឆ្នោត

Press Conference on 04 June 2017, on Election Day Situation

សន្និសិទសារព័ត៌មាននៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧ លទ្ធផលបឋមក្នុងការសង្កេតក្រោយការបោះឆ្នោត

Press Conference on 12 June 2017 at COMFREL Head Office, on Preliminary Electoral Result

សន្និសិទសារព័ត៌មាននៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៧ សន្និសិទសារព័ត៌ស្តីពីការវាយតម្លៃដំណើរការបោះឆ្នោតឃុំ សង្កាត់ឆ្នាំ២០១៧

Press Conference on 24 June 2017 at COMFREL Head Office, on Overall and Ultimate Assessment on the 2017 Commune Election

កិច្ចប្រជុំតុមូលនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីអនុសាសន៍សម្រាប់ការចុះឈ្មោះបោះឆ្នោតខាងមុខ

Roundtable Discussion on 19 July 2017 on Recommendations on Voter Registration for Next Elections